របាយការណ៍លេខ ៥៨០១៦ - KH

# ក្រុមអធិការកិច្ច

## របាយការណ៍សើុបអង្កេត

## ប្រទេសកម្ពុជាៈ គម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល

## (ឥណទានលេខ ៣៦៥០ — KH)

ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

# អំពីអធិការកិច្ច

អធិការកិច្ចត្រូវបានបង្កើតឡើងចាប់តាំងពីខែកញ្ញា ឆ្នាំ ១៩៩៣ ដោយក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ធនាគារពិភពលោក ក្នុង តួនាទីជាយន្តការឯករាជមួយដើម្បីធានាអំពីគណនេយ្យភាពក្នុងប្រតិបត្តិការរបស់ធនាគារពិភពលោកដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ និងនិតិវិធីរបស់ខ្លួន។ ក្រុមអធិការកិច្ចគឺជាផ្នែកមួយសម្រាប់ក្រុមនៃប្រជាពលរដ្ឋ ២ ឬច្រើននាក់ដែលជឿថាខ្លួនគេ ឬផលប្រយោជន៍របស់ពួកគេគពុងត្រូវបាន ឬបានខូចផលប្រយោជន៍ដោយសកម្មភាពដែលគាំទ្រហិរញ្ញវត្ថុដោយធនាគារពិភពលោក ដើម្បីបង្ហាញពីការព្រួយបារម្ភរបស់គេតាមរយៈសំណើស្នើសុំធ្វើអធិការកិច្ច។ សរុបមកវិញ អធិការកិច្ចផ្តល់ជាបណ្តាញមួយរវាងធនាគារពិភពលោក និងប្រជាជនដែលទំនងជាទទួលរងផលប៉ះពាល់ដោយគម្រោងដែលគាំទ្រដោយខ្លួន។

សមាជិកនៃក្រុមអធិការកិច្ចត្រូវបានជ្រើសរើស *"ដោយផ្អែកទៅលើសមត្ថភាពក្នុងការដោះស្រាយពេលលេញ និងមានភាពយុត្តិធម៌ ជាមួយនឹងសំណើដែលបានដាក់ស្នើទៅពួកគាត់ មានសុក្រិតភាព និងភាពឯករាជពីថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក ហើយនឹងបទពិសោធន៍របស់ពួកគាត់ចំពោះបញ្ហាអភិវឌ្ឍន៍ និងលក្ខខណ្ឌរស់នៅ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍"។*[1] សមាជិកទាំងបីរូបផ្តល់សិទ្ធិអំណាច ដោយផ្តល់ឱ្យដោយក្រុមប្រឹក្សានាយកប្រតិបត្តិ ដើម្បីស៊ើបអង្កេតបញ្ហាដែលមានការចោទប្រកាន់ដែល បានកើតឡើងចេញពីលទ្ធផលមួយនៃការអនុវត្តដោយបរាជ័យដើម្បីអនុលោមទៅតាមគោលនយោបាយប្រតិបត្តិផ្ទាល់ខ្លួន និងនិតិវិធីរបស់ខ្លួន។

ការងាររបស់អធិការកិច្ចផ្តោតទៅលើគោលការណ៍ជាគ្រឹះនៃភាពជាឯករាជ សុក្រិតភាព និងមិនលំអៀង។ គោលការណ៍ស្នូលទាំងនេះអាចបង្កឱ្យក្រុមអធិការកិច្ចដើម្បីឆ្លើយទៅនឹងបញ្ហាដែលបានលើកឡើង និងដើម្បីផ្តល់បច្ចេកទេសដ៏ប្រសើរ ការវាយតម្លៃប្រកបឯករាជ ទៅដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារពិភពលោក។

## សម្រាប់ដំណើការស្នើសុំ

បន្ទាប់ពីក្រុមអធិការកិច្ចទទួលបានការស្នើសុំធ្វើអធិការកិច្ច គឺមានដំណើរការដូចខាងក្រោមៈ

- ក្រុមអធិការកិច្ចសម្រេចថាតើសំណើរលើកដំបូងវាសមស្របទៅនឹងការពិចារណារបស់ក្រុមអធិការកិច្ចឬយ៉ាងណា
- ក្រុមអធិការកិច្ចបានចុះលេខសំណើ គឺមាននិតិវិធីរដ្ឋបាលដោយសុចរិតមួយ
- ក្រុមអធិការកិច្ចផ្ញើសំណើទៅថ្នាក់គ្រប់គ្រងធនាគារពិភពលោក ដែលមានរយៈពេល ២១ សប្តាហ៍( ថ្ងៃធ្វើការ) ដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់ដែលធ្វើឡើងដោយអ្នកស្នើរសុំ។
- បន្ទាប់មកទៀតក្រុមអធិការកិច្ចចាប់ផ្តើមរៀបចំធ្វើការវាយតម្លៃដែលមានរយៈពេល ២១សប្តាហ៍ (ថ្ងៃធ្វើការ) ដើម្បីកំណត់អំពីភាពសមស្របណាមួយនៃអ្នកស្នើសុំ និងសំណើរស្នើរសុំ។

[1] សេចក្តីសម្រេចរបស់ IBRD លេខ ៩៣-១០ និង សេចក្តីសម្រេច IDA លេខ ៩៣-៦

- ប្រសិនបើផ្តល់ឱ្យមានការស៊ើបអង្កេតមួយ ហើយក្រុមប្រឹក្សាភិបាលបានអនុម័ត ក្រុមអធិការកិច្ចនិងដឹកនាំឱ្យមានការស៊ើបអង្កេតពេញលេញ ដោយមិនកំណត់ពេលវេលាទេ។
- ប្រសិនបើក្រុមអធិការកិច្ចមិនស្នើឱ្យមានការស៊ើបអង្កេត នោះក្រុមប្រឹក្សានាយកប្រតិបត្តិនៅតែបង្គាប់បញ្ជាឱ្យមានការស៊ើបអង្កេតមួយប្រសិនបើមានការអនុញ្ញាត។
- ៣ ថ្ងៃបន្ទាប់ពីក្រុមប្រឹក្សាភិបាលសម្រេចចិត្តថា តើមានការស៊ើបអង្កេត ឬមិនមានការអង្កេតមួយក្តី របាយការណ៍របស់ក្រុមអធិការកិច្ច (ដោយរួមទាំងការស្នើសុំធ្វើអធិការកិច្ច និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង) គឺត្រូវដាក់ផ្សព្វផ្សាយជាសាធារណៈតាមរយៈវេសាយរបស់ក្រុមអធិការកិច្ច និងលេខាធិការដ្ឋាន មណ្ឌលព័ត៌មានសាធារណៈរបស់ធនាគារពិភពលោក និងការិយាល័យធនាគារពិភពលោកនៅតាមប្រទេស។
- នៅពេលដែលក្រុមអធិការកិច្ចបញ្ចប់ការស៊ើបអង្កេតមួយនោះ ពួកគេនឹងធ្វើការរកឃើញរបស់ខ្លួន និងការសន្និដ្ឋានស្តីពីបញ្ហាដែលបានចោទប្រកាន់នៅក្នុងការស្នើសុំឱ្យធ្វើអធិការកិច្ចទៅក្រុមប្រឹក្សាភិបាល ក៏ដូចជាថ្នាក់គ្រប់គ្រងធនាគារពិភពលោក។
- ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកមានពេល ៦ សប្តាហ៍ ដើម្បីដាក់នូវអនុសាសន៍របស់គេទៅក្រុមប្រឹក្សាភិបាលស្តីអំពីសកម្មភាពដែលធនាគារពិភពលោកនឹងធ្វើ ដើម្បីឆ្លើយតបទៅនឹងការរកឃើញ និងការសន្និដ្ឋានរបស់ក្រុមអធិការកិច្ច។
- បន្ទាប់មកក្រុមប្រឹក្សានឹងធ្វើការសម្រេចចិត្តចុងក្រោយស្តីអំពីថាតើអ្វីដែលគួនឹងធ្វើដោយផ្អែកទៅលើការរកឃើញនិងអនុសាសន៍របស់ថ្នាក់គ្រប់គ្រងធនាគារពិភពលោក។
- ៣ ថ្ងៃបន្ទាប់ពីការសម្រេចចិត្តរបស់ក្រុមប្រឹក្សាពិបាល របាយការណ៍អធិការកិច្ច និងអនុសាសន៍របស់ថ្នាក់គ្រប់គ្រងនឹងដាក់ជូនជាសាធារណៈតាមរយៈវេសាយរបស់អធិការកិច្ច និងលេខាធិការដ្ឋាន វេបសាយគម្រោងមណ្ឌលព័ត៌មានសាធារណៈរបស់ធនាគារពិភពលោក និងមណ្ឌលព័ត៌មានរបស់ខ្លួននៅតាមប្រទេសដែលមានការស៊ើបអង្កេតនេះ។

# សេចក្តីថ្លែងអំណរគុណ

ការរៀបចំរបាយការណ៍នេះនឹងមិនអាចកើតឡើងបានទេប្រសិនបើគ្មានការគាំទ្រ និងការចូលរួមចំណែកដ៏មានតម្លៃពីមនុស្សជាច្រើន។ ក្រុមអធិការកិច្ចសូមអរគុណផងដែរដល់អ្នកបានដាក់សំណើ និងសហគមន៍នានានៅក្រោមគម្រោងនេះដែលបានអនុញ្ញាតឱ្យក្រុមអធិការកិច្ចជួប ។

ក្រុមអធិការកិច្ចសូមសំដែងអំណរគុណផងដែរចំពោះមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននៅប្រទេសកម្ពុជាដែលបានអនុញ្ញាតឱ្យក្រុមអធិការកិច្ចជួប។ ពួកគាត់បានផ្តល់នូវព័ត៌មាន និងហេតុការណ៍ដ៏មានតម្លៃ។ ក្រុមអធិការកិច្ចក៏សូមថ្លែងអំណរអគុណចំពោះការជួយសម្របសម្រួលពីមន្ត្រីធនាគារប្រចាំប្រទេស។

ក្រុមអធិការក៏សូមថ្លែងអំណរគុណចំពោះមន្ត្រីធនាគារពិភពលោកប្រចាំនៅការិយាល័យទីក្រុងវ៉ាស៊ិនតោន និងការិយាល័យប្រចាំប្រទេសកម្ពុជាសម្រាប់ការជួយរៀបចំកម្មវិធីនានា។ ក្រុមអធិការកិច្ចក៏សូមថ្លែងអំណរគុណចំពោះថ្នាក់គ្រប់គ្រង និងមន្ត្រីធនាគារពិភពលោក សម្រាប់ការជួយក្នុងការផ្តល់ឯកសារនានា ផ្តល់ព័ត៌មានដល់ក្រុមអធិការកិច្ច នឹងមានការឆ្លើយតបយ៉ាងរហ័សចំពោះសំណើរជាលាយលក្ខអក្សរ ។ ក្រុមអធិការកិច្ចក៏សូមថ្លែងអំណរគុណចំពោះសមាជិកអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការនៅប្រទេសកម្ពុជា។

ក្រុមអធិការកិច្ចក៏ថ្លែងអំណរគុណចំពោះការផ្តល់ដំបូន្មានឯកទេសដោយលោក ជេហ្វ្រី ផាញ និងសូមកោតសរសើរចំពោះការវិនិច្ឆ័យ និងវិជ្ជាជីវៈដែលលោកតែងតែផ្តល់ជូនជារៀងរាល់ពេល។ ចុងបញ្ចប់ ក្រុមអធិការកិច្ចសូមសំដែងនូវការដឹងគុណ និងការកោតសរសើរដល់សមាជិកនៃលេខាធិការដ្ឋានសម្រាប់ជាធនធានដ៏មានន័យ ដើម្បីរៀបចំការស៊ើបអង្កេតនេះ ជាពិសេស សូមអគុណលោកស្រី ឪលេក បាលាស នាយិការងលេខាធិការប្រតិបត្តិ និងលោកស្រី កាតារីន ឈុង និងលោកស្រី ជែនីហ្វើ ហាច ជាជំនួយការផ្នែកខាងស្រាវជ្រាវ។

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BP | គោលនយោបាយធនាគារ |
| BTO | របាយការណ៍ប្រឡប់មកការិយាល័យវិញ |
| BKL | បឹងកក់ |
| CAS | យុទ្ធសាស្ត្រជំនួយប្រចាំប្រទេស |
| CIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា |
| CLP | ក្រុមប្រឹក្សាគោលនយោបាយដីធ្លី |
| COHRE | មជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ |
| DCA | កិច្ចព្រមព្រៀងឥណទានសម្រាប់ការអភិវឌ្ឍ |
| DfID | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិចក្រភពអង់គ្លេស |
| DPM | ឧបកនាយករដ្ឋមន្ត្រី |
| EA | ការវាយតម្លៃបរិស្ថាន |
| ERM | បេសកកម្មពិនិត្យមើលឡើងវិញសម្រាប់លើកកម្ពស់គម្រោង |
| ESG | គោលការណ៍ណែនាំស្តីពីបរិស្ថាន និងសង្គម |
| GTZ | ភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់ |
| IDA | សមាគម៍អភិវឌ្ឍន៍អន្តរជាតិ |
| LMAP | គម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល |
| LRT | ក្រុមចុះបញ្ជីដីធ្លី |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MLMUPC | ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ |
| MPP | សាលាក្រុងភ្នំពេញ |
| MR | ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង |
| MTR | ការពិនិត្យមើលឡើងវិញពាក់កណ្តាលអាណត្តិគម្រោង |
| NALDR | អាជ្ញាធរជាតិសម្រាប់ដោះស្រាយជម្លោះដីធ្លី |
| NCRUDC | គណៈកម្មាការជាតិសម្រាប់អភិវឌ្ឍន៍តំបន់ និងទីក្រុង និងសំណង់ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| OD | គោលដៅប្រតិបត្តិការណ៍ |
| OP | គោលនយោបាយប្រតិបត្តិការណ៍ |

| | |
|---|---|
| PACP | ការចូលរួមរបស់សហគមន៏សម្រាប់ការយល់ដឹងជាសាធារណៈ |
| PAD | ឯកសារវាយតម្លៃគម្រោង |
| PMO | ការិយាល័យគ្រប់គ្រងគម្រោង |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| ROW | សិទ្ធិចំណើផ្លូវ |
| RPF | ក្របខ័ណ្ឌគោលនយោបាលការតាំងទីលំនៅជាថ្មី |
| RVP | អនុប្រធានប្រចាំតំបន់ |
| SA | ការវាយតម្លៃសង្គម |
| SDR | សិទ្ធិដកប្រាក់ពិសេស (Special Drawing Rights) |
| TOR | មុខងារ និងភារកិច្ច |
| TWG-L | ក្រុមការងារបច្ចេកទេសដីធ្លី |
| UN | អង្គការសហប្រជាជាតិ |
| UNCHS | អង្គការសហប្រជាជាតិទទួលបន្ទុកកម្មវិធីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ/មជ្ឈមណ្ឌលសម្រាប់លំណនៅដ្ឋានប្រជាពលរដ្ឋ (UN HABITAT) |
| UNDP | កម្មវិធីអភិវឌ្ឍន៏អង្គការសហប្រជាជាតិ |
| US$ | ដុល្លារអាមេរិក |

# និដ្ឋភាពទូទៅ

ក្រុមអធិការកិច្ចបានរៀបចំរបាយការណ៍ស៊ើបអង្កេតនេះ ដើម្បីឆ្លើយតបទៅនឹងសំណើធ្វើអធិការកិច្ចដែលបានទទួលនៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៩ ពីមជ្ឈមណ្ឌលសម្រាប់សិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ (COHRE) ដែលបានដាក់សំណើជំនួសឱ្យសហគមន៍ដែលបានអះអាងថា ទទួលរងផលប៉ះពាល់ពីគម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល (ចាប់ពីពេលនេះ សំដៅហៅថា "គម្រោង" ឬ "LMAP") ក្នុងប្រទេសកម្ពុជា ។ សហគមន៍ទាំងនេះ មានមូលដ្ឋាននៅក្នុងតំបន់បឹងកក់ (BKL) នៅក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ម្ចាស់សំណើបានស្នើសុំឱ្យក្រុមអធិការកិច្ចមិនបញ្ចេញឈ្មោះរបស់ប្រជាជនដែលទទួលរងផលប៉ះពាល់ និងភូមិដែលគេរស់នៅ ។ ក្រុមអធិការកិច្ច បានធ្វើការចុះបញ្ជីទៅលើសំណើសុំធ្វើអធិការកិច្ចនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០០៩ ។ ថ្នាក់គ្រប់គ្រងបានផ្តល់ការឆ្លើយតបរបស់ខ្លួនចំពោះសំណើនៅថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

ក្រុមអធិការកិច្ចមួយបានចុះមកធ្វើទស្សនកិច្ច នៅថ្ងៃទី ១៦-១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ដើម្បីធ្វើការកំណត់ទៅលើលក្ខខណ្ឌសមស្របនៃសំណើ ។ ក្រុមអធិការកិច្ចបានដាក់របាយការណ៍ និងអនុសាសន៍របស់ខ្លួនដែលមានលក្ខខណ្ឌសមស្រប ជូនទៅក្រុមប្រឹក្សានាយកប្រតិបត្តិ នៅថ្ងៃទី ២ ខែធ្នូ ឆ្នាំ២០០៩ ។ ក្រុមអធិការកិច្ចបានរកឃើញថា សំណើមានលក្ខខណ្ឌសមស្រប ប៉ុន្តែពុំទាន់ បានផ្តល់អនុសាសន៍នៅពេលនោះ ថាតើត្រូវវិធានាឱ្យមាននូវការស៊ើបអង្កេតនៅឡើយនោះទេ ដោយបានធ្វើការកត់សម្គាល់ ថា គេរំពឹងថានឹងធ្វើការសម្រេចចិត្តត្រឹមថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០១០ ។ យោងតាមទស្សនៈរបស់ក្រុមស៊ើបអង្កេត ទង្វើបែបនេះ នឹងផ្តល់ឱកាសបន្ថែមទៀតដល់ថ្នាក់គ្រប់គ្រង ដើម្បីបង្កើតឱ្យមាននូវកិច្ចសន្ទនាមួយជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍដទៃទៀត ដើម្បីដោះស្រាយបញ្ហាកង្វល់របស់ម្ចាស់សំណើ ។ ក្រុមប្រឹក្សានាយកប្រតិបត្តិបានអនុម័តយល់ព្រមទៅលើអនុសាសន៍របស់ក្រុមអធិការកិច្ច នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០០៩ ក្រោមមូលដ្ឋាននៃការមិនជំទាស់ ។

ក្រុមអធិការកិច្ច បានផ្តល់របាយការណ៍ចុងក្រោយរបស់ខ្លួនអំពីលក្ខខណ្ឌសមស្រប ជូនទៅនាយកប្រតិបត្តិ នៅថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០១០ ។ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា ពុំមានវឌ្ឍនភាពណាមួយដែលត្រូវបានធ្វើឡើង ដើម្បីអនុវត្តសកម្មភាពដែលគេបានស្នើនៅក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ដើម្បីដោះស្រាយបញ្ហាកង្វល់របស់ម្ចាស់សំណើឡើយ ។ ដូច្នេះ ក្រុមអធិការកិច្ចបានផ្តល់អនុសាសន៍ឱ្យគណៈនាយកប្រតិបត្តិអនុម័តយល់ព្រមឱ្យមាននូវការស៊ើបអង្កេត ទៅលើការអះអាង និងបញ្ហាដែលបានលើកឡើងនៅក្នុងសំណើធ្វើអធិការកិច្ច ។ ក្រុមប្រឹក្សានាយកប្រតិបត្តិបានអនុម័តយល់ព្រមទៅលើអនុសាសន៍របស់ក្រុមអធិការកិច្ច ដើម្បីឱ្យមាននូវការស៊ើបអង្កេតមួយដោយក្រុមអធិការកិច្ច នៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០១០ ក្រោមមូលដ្ឋាននៃការមិនជំទាស់ ។

**ការអះអាងសំខាន់ៗដែលបានបង្ហាញជូនក្រុមអធិការកិច្ច :** នៅក្នុងសំណើសុំឱ្យមានការធ្វើអធិការកិច្ច ម្ចាស់សំណើបានចោទប្រកាន់ថា សកម្មភាពក្រោមគម្រោង LMAP ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក បានបណ្តាលឱ្យសហគមន៍បឹងកក់ ដែលមានគ្រួសារប្រមាណ ៤.២៥០គ្រួសារ រងគ្រោះយ៉ាងធ្ងន់ធ្ងរពីការរៀបចំ និងការអនុវត្តគម្រោងនេះ។ ម្ចាស់សំណើបានអះអាងថា ការបណ្តេញចេញ និងព្រឹត្តិការណ៍ពាក់ព័ន្ធនៅក្នុងតំបន់បឹងកក់ មានទំនាក់ទំនងទៅនឹងគម្រោង

ហើយពួកគេត្រូវបានគេបដិសេធចំពោះការវិនិច្ឆ័យទៅលើការទាមទារសិទ្ធិលើកម្មសិទ្ធិរបស់ពួកគេ ក្រោមគម្រោង LMAP ។ ម្ចាស់សំណើបានថ្លែងថា តំបន់បឹងកក់ ត្រូវបានធ្វើការបែងចែកចំណាត់ថ្នាក់ជាថ្មីឡើងវិញ ដើម្បីបង្កលក្ខណៈឱ្យមាននូវការអភិវឌ្ឍ ដោយអ្នកអភិវឌ្ឍន៍ឯកជនមួយ ដែលមិនផ្តល់ឱកាសឱ្យសហគមន៍ ដែលទទួលរងផលប៉ះពាល់ទទួលបាននូវការពិចារណាទៅលើសិទ្ធិដីធ្លីរបស់ពួកគេ ក្រោមគម្រោងនេះឡើយ និងនាំឱ្យឈានទៅដល់ការបង្ខំបណ្តេញពួកគេចេញពីលំនៅដ្ឋាន។ ពួកគេបានអះអាងថា មិនចំពោះថា ស្ថានភាពកម្មសិទ្ធិភាពទៅលើដីធ្លីមានលក្ខណៈដូចម្តេចឡើយ ប្រជាពលរដ្ឋនៅក្នុងតំបន់បឹងកក់ បាននិងកំពុងត្រូវបានបណ្តេញចេញពីលំនៅដ្ឋានរបស់ពួកគេក្នុងលក្ខណៈមួយ ដែលរំលោភបំពានទៅលើគោលនយោបាយរបស់ធនាគារពិភពលោក ស្តីពីការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត និងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ (RPF) ដែលត្រូវបានឯកភាពសម្រាប់គម្រោងនេះ ។

ម្ចាស់សំណើបានអះអាងថា គម្រោង *"មិនបានធ្វើឱ្យកម្មសិទ្ធិដីធ្លីរបស់ពួកគេមានលក្ខណៈផ្លូវការឡើយ"* និងមិនបាន *"ផ្ទេរសិទ្ធិទូទៅរបស់ពួកគេ ក្រោមប្លង់ដីដែលត្រូវបានរៀបចំឱ្យមានលក្ខណៈផ្លូវការ"* ដែលជាហេតុធ្វើឱ្យចុះខ្សោយទៅលើកម្មសិទ្ធិដីធ្លីរបស់ប្រជាជនដែលមានស្រាប់ កាលពីមុន ។ ជាចុងក្រោយ ម្ចាស់សំណើបានអះអាងថា សហគមន៍ដទៃទៀតនៅក្នុងខេត្តរបស់គម្រោង ពុំអាចមានលទ្ធភាពទទួលបានប្លង់ដីនៅក្នុងតំបន់វិនិច្ឆ័យរបស់គម្រោង LMAP ឡើយ ព្រមទាំងត្រូវបានបង្ខំបណ្តេញចេញពីលំនៅដ្ឋានទៀតផង ។ បញ្ហាដែលបានលើកឡើងមានពាក់ព័ន្ធទៅនឹងសំនួរមូលដ្ឋានអំពីសិទ្ធិកាន់កាប់ដីធ្លី និងសន្តិសុខកម្មសិទ្ធិដីធ្លីរបស់សហគមន៍ដែលទទួលរងផលប៉ះពាល់ ។

**គំហើញរបស់ក្រុមអធិការកិច្ចអំពីភាពអនុលោម និងការខូចប្រយោជន៍ :** របាយការណ៍នេះ បង្ហាញអំពីគំហើញរបស់ក្រុមអធិការកិច្ច ក្នុងការឆ្លើយតបទៅនឹងការអះអាងទាំងនេះ ជាពិសេស គឺឆ្លើយតបទៅនឹងបញ្ហា ថាតើការខូចខាតប្រយោជន៍ដែលបានចោទប្រកាន់បណ្តាលមកពីបរាជ័យដ៏ធ្ងន់ធ្ងរ (ទាំងស្រុង ឬ ផ្នែកណាមួយ) របស់ធនាគារពិភពលោកក្នុងការត្រួតពិនិត្យទៅលើគោលនយោបាយ និងនីតិវិធីប្រតិបត្តិរបស់ខ្លួន ដែលពាក់ព័ន្ធទៅនឹងការរៀបចំគម្រោងការវាយតម្លៃ និង/ឬ ការអនុវត្ត ។ គោលនយោបាយដែលពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតនេះ រួមមានការវាយតម្លៃគម្រោងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ការត្រួតពិនិត្យទៅលើគម្រោង ។

យោងតាមការអះអាងថា ព្រឹត្តិការណ៍នៅក្នុងតំបន់បឹងកក់ មានទំនាក់ទំនងទៅនឹងគម្រោង ក្រុមអធិការកិច្ចបានរកឃើញថា តំបន់នោះស្ថិតនៅក្នុងខេត្តគម្រោងមួយ ព្រមទាំងត្រូវបានប្រកាសថាជាតំបន់វិនិច្ឆ័យក្រោមគម្រោង LMAP ដូច្នេះសកម្មភាពដែលទាក់ទងទៅនឹងការផ្ទៀងផ្ទាត់ទៅលើកម្មសិទ្ធិដីធ្លី និងកម្មសិទ្ធិភាពក្រោយការជូនដំណឹងអំពីការវិនិច្ឆ័យ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងគម្រោង ។ ចំណុចនេះ មានសង្គតភាពទៅនឹងជំហររបស់ថ្នាក់គ្រប់គ្រង ។

យោងតាមការអះអាងថា ប្រជាពលរដ្ឋនៅក្នុងតំបន់បឹងកក់ត្រូវបានបដិសេធចំពោះការវិនិច្ឆ័យទៅលើការទាមទារអចលនទ្រព្យរបស់ពួកគេក្រោមគម្រោង ក្រុមអធិការកិច្ចបានធ្វើសេចក្តីសន្និដ្ឋានថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ ត្រូវបានបដិសេធមិនឱ្យទទួលបានដំណើរការវិនិច្ឆ័យសមស្របទៅលើការទាមទារអចលនទ្រព្យរបស់ពួកគេ ។ ក្រុមអធិការកិច្ចមានទស្សនៈយល់ឃើញថា វាជាការត្រឹមត្រូវហើយ ដែលប្រជាពលរដ្ឋរស់នៅក្នុងតំបន់បឹងកក់រំពឹងថា ការទាមទារដីធ្លីរបស់ពួកគេ

មានលក្ខខណ្ឌសមស្រប ដើម្បីធ្វើការពិចារណាក្រោមការផ្តល់ប្លង់ដីដែលមានលក្ខណៈជាប្រព័ន្ធ និងបន្ថែមពីនេះទៀត រាល់ការទាមទារដីធ្លីទាំងអស់នៅក្នុងសង្កាត់ ត្រូវធ្វើការវិនិច្ឆ័យដោយយោងទៅតាមនីតិវិធី និងដំណើរការសម្រាប់វិនិច្ឆ័យទៅលើការទាមទារទ្រព្យសម្បត្តិ ដែលត្រូវបានឯកភាពគ្នា រវាងរាជរដ្ឋាភិបាល ធនាគារពិភពលោក និងដៃគូអភិវឌ្ឍ ដែលគាំទ្រដល់គម្រោង LMAP ។ ក្រុមអធិការកិច្ចបានរកឃើញថា ភាពមិនច្បាស់លាស់នៅក្នុងការរៀបចំគម្រោង ដែលពាក់ព័ន្ធទៅនឹងការកំណត់ទៅលើតំបន់វិនិច្ឆ័យ និងការដោះស្រាយវិវាទរវាងអង្គភាពរដ្ឋ និងបុគ្គលឯកជន ក្នុងអំឡុងពេលនៃដំណើរការវិនិច្ឆ័យ បានរួមចំណែកមួយផ្នែកចំពោះការខូចប្រយោជន៍ដែលម្ចាស់សំណើកំពុងជួបប្រទះ ។ លើសពីនេះទៀត ក្រុមអធិការកិច្ចបានរកឃើញថា ថ្នាក់គ្រប់គ្រងមិនបានធ្វើសកម្មភាពទៅលើព័ត៌មាន នៅពេលដែលគេរាយការណ៍លើកដំបូងអំពីបញ្ហាដែលបានកើតឡើងនៅក្នុងតំបន់បឹងកក់ ជូនដល់ថ្នាក់គ្រប់គ្រង ហើយការត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រងនៅក្នុងលក្ខខណ្ឌនេះ ពុំមានសង្គតភាពទៅនឹងលក្ខខណ្ឌតម្រូវនៃគោលនយោបាយរបស់ធនាគារពិភពលោក ។ ខណៈពេលដែលការត្រួតពិនិត្យនាពេលថ្មីៗនេះរបស់ថ្នាក់គ្រប់គ្រងទៅលើគម្រោង អំពីបញ្ហាដែលសំណើបានលើកឡើង មានភាពអនុលោមទៅនឹងគោលនយោបាយរបស់ធនាគារពិភពលោក ក្រុមអធិការកិច្ចយល់ស្របទៅនឹងការវាយតម្លៃរបស់ម្ចាស់សំណើថា *"ជាក់ស្តែងសកម្មភាពដែលថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកបានអនុវត្ត គឺយឺតពេលពេកទៅហើយ ដើម្បីបង្ការការខូចប្រយោជន៍ដែលកំពុងកើតឡើងនៅពេលនេះ"* ។

យោងតាមការអះអាងថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ ត្រូវបានជម្លៀសដោយហឹង្សាបំពានទៅលើគោលនយោបាយដែលបានឯកភាពគ្នា សម្រាប់ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ក្រុមអធិការកិច្ចបានរកឃើញថា សេចក្តីសម្រេចក្នុងការរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ មានភាពស្របគ្នាទៅនឹងបទប្បញ្ញត្តិនៃគោលនយោបាយដែលអាចយកមកអនុវត្តបាន និងការគ្រប់គ្រងសមស្រប ដើម្បីពង្រីកវិសាលភាពនៃស្ថានភាពដែលគេអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ដែលឆ្លុះបញ្ចាំងអំពីការគិតគូថ្មីៗនៅក្នុងធនាគារពិភពលោក នៅពេលនេះ ទាក់ទងទៅនឹងការអនុវត្តសមស្រប នូវកិច្ចការពារសុវត្ថិភាពរបស់ធនាគារពិភពលោក ។ បើទោះជាដូច្នេះក្តី អាស្រ័យដោយភាពមិនច្បាស់លាស់ ដែលទាក់ទងទៅនឹងរបៀប ដែលគេគួរជម្រុញ និងអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ក្រុមអធិការកិច្ចបានរកឃើញថា ការរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញខ្វះបទប្បញ្ញត្តិមួយចំនួនដែលគេបានរំពឹងទុកនៅក្នុង OD 4.30 ដែលពាក់ព័ន្ធទៅនឹង *"ការរៀបចំគោលការណ៍ ការរៀបចំស្ថាប័ន និងការរៀបចំលក្ខខណ្ឌវិនិច្ឆ័យ"* ។ ក្រុមអធិការកិច្ចបានរកឃើញភស្តុតាងនៅក្នុងកំណត់ហេតុត្រួតពិនិត្យ ដែលថ្នាក់គ្រប់គ្រង នៅក្នុងឱកាសជាច្រើនបានលើកឡើងអំពីបញ្ហាដែលទាក់ទងទៅនឹងការគ្រប់គ្រងដីរដ្ឋ ដែលមានភាពពាក់ព័ន្ធជាសក្តានុពលសម្រាប់ការអនុវត្ត RPF ព្រមទាំងបានកោតសរសើរធនាគារពិភពលោក ចំពោះការបន្តបញ្ហាគោលនយោបាយដ៏លំបាកនេះ នៅក្នុងបរិបទប្រទេសកម្ពុជា ។ បើទោះជាដូច្នេះក្តី ក្រុមអធិការកិច្ចក៏បានរកឃើញករណីបណ្តេញប្រជាពលរដ្ឋចេញពីដីរដ្ឋ ដែលបណ្តាលឱ្យមាននូវការខូចខាតធ្ងន់ធ្ងរចំពោះគ្រួសារដែលទទួលរងផលប៉ះពាល់ ហើយក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ គួរត្រូវបានគេយកមកអនុវត្តនៅក្នុងតំបន់បឹងកក់ ។ ជាទូទៅ ក្រុមអធិការកិច្ចមានទស្សនៈយល់ឃើញថា ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក គួរបានកំណត់រកឃើញបញ្ហាធ្ងន់ធ្ងរនានា ដែលប្រជាជននៅក្នុងតំបន់បឹងកក់ជួបប្រទះតាំងពីដំណាក់កាលដំបូង និងពិចារណារកចំណាត់ការសមស្រប ។ ការខកខានមិនបានអនុវត្តយ៉ាង

ដូច្នេះ ពុំស្របទៅនឹងគោលនយោបាយរបស់ធនាគារពិភពលោកឡើយ ។

យោងតាមការអះអាងថា ដំណើរការផ្ដល់ប្លង់ដីដែលអនុម័តដោយគម្រោង បានធ្វើឱ្យចុះខ្សោយទៅលើសិទ្ធិកម្មសិទ្ធិដីធ្លីដែលមានកាលពីមុន ក្រុមអធិការកិច្ចបានរកឃើញថា ចន្លោះប្រហោងនៃការរៀបចំគម្រោងបានបណ្ដាលឱ្យមាននូវការដកចេញនូវដីធ្លីពីដំណើរការផ្ដល់ប្លង់ដីទៅតាមចិត្តចង់ ហើយបានបដិសេធក្នុងការផ្ដល់ឱកាសដល់ប្រជាពលរដ្ឋទាមទារ និងធ្វើឱ្យមានភាពស្របច្បាប់នូវសិទ្ធិរបស់ពួកគេ ដែលមានស្រាប់កាលពីមុន តាមរយៈការវិនិច្ឆ័យក្រោមគម្រោង LMAP ។ ក្រុមអធិការកិច្ចមានទស្សនៈយល់ឃើញថា ចំណុចនេះផ្ទុយទៅនឹងគោលបំណងរបស់គម្រោងដែលបានចែងសំដៅធ្វើឱ្យប្រសើរឡើងនូវសន្តិសុខកម្មសិទ្ធិដីធ្លី ជាពិសេសគឺសន្តិសុខកម្មសិទ្ធិដីធ្លីសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ និងជាលទ្ធផលក្រុមអធិការកិច្ចបានរកឃើញថា ថ្នាក់គ្រប់គ្រងពុំបានអនុវត្តស្របទៅតាមគោលនយោបាយរបស់ធនាគារពិភពលោក ស្ដីពីការវាយតម្លៃគម្រោង ។ ក្រុមអធិការកិច្ចក៏បានរកឃើញផងដែរថា ពុំមែនគ្រប់វិធានការទាំងអស់ ដែលត្រូវបានរៀបចំឡើងជាពិសេសដើម្បីគាំទ្រដល់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ ត្រូវបានអនុវត្តតាមការគ្រោងទុកឡើយ ។ ថ្នាក់គ្រប់គ្រងមិនបានពិនិត្យតាមដានទៅលើការប្ដេជ្ញាចិត្តរបស់គម្រោងឱ្យបានគ្រប់គ្រាន់ ដើម្បីពង្រឹងការយល់ដឹងសាធារណៈ និងការចូលរួមរបស់សហគមន៍ ធានាឱ្យមាននូវកិច្ចការពារផ្នែកច្បាប់ជូនដល់ប្រជាពលរដ្ឋដែលប្រឈមទៅនឹងហានិភ័យនៃការបណ្ដេញចេញ និងផ្ដល់លទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបាននូវយន្តការដោះស្រាយវិវាទ ដែលចំណុចនេះ ពុំស្របទៅនឹងគោលនយោបាយរបស់ធនាគារពិភពលោក ។ ក្រុមអធិការកិច្ចបានរកឃើញថា កង្វះកិច្ចគាំទ្រសម្រាប់ជនក្រីក្រដែលបណ្ដាលមកពីការអនុវត្តសមាសធាតុជាច្រើនរបស់គម្រោងមិនបានពេញលេញ និងមិនបានគ្រប់គ្រាន់បានធ្វើឱ្យពួកគេមានភាពងាយរងគ្រោះ ចំពោះការទាមទារដីរបស់ពួកគេ ។ នៅក្នុងការឆ្លើយតបរបស់ខ្លួន ថ្នាក់គ្រប់គ្រងបញ្ជាក់ថា សកម្មភាពទាំងនេះ ដែលមានសារៈសំខាន់ចំពោះការអនុវត្តគម្រោងឱ្យបានពេញលេញ ត្រូវបានពន្យាពេល ឬមិនត្រូវបានអនុវត្ត ។

ការទាមទារចុងក្រោយរបស់ម្ចាស់សំណើ គឺសហគមន៍ដទៃទៀតនៅក្នុងតំបន់វិនិច្ឆ័យរបស់គម្រោង LMAP មិនត្រូវបានគេរាប់បញ្ចូលទៅក្នុងដំណើរការវិនិច្ឆ័យ ព្រមទាំងត្រូវបានគេបង្ខំបណ្ដេញចេញពីកន្លែងរស់នៅ ។ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា ការបង្ខំបណ្ដេញចេញពីកន្លែងរស់នៅ ពុំមែនទើបតែកើតឡើងថ្មីនៅក្នុងប្រទេសកម្ពុជាឡើយ ហើយសកម្មភាពនេះ បាននិងបន្តកើតឡើងនៅក្នុងរាជធានីភ្នំពេញ ចាប់តាំងពីមុនពេលរៀបចំគម្រោងម្លេះ ។ ខណៈពេលដែលវិសាលភាពនៃផលប៉ះពាល់អវិជ្ជមានទៅលើគ្រួសារដែលរស់នៅក្នុងតំបន់វិនិច្ឆ័យ ពុំត្រូវបានគេដឹងនៅឡើយ ក្រុមអធិការកិច្ចមានការបារម្ភជាខ្លាំងអំពីប្រជាជនជាច្រើនដែលត្រូវបានបង្ខំបណ្ដេញចេញ ជម្លៀសពីកន្លែងដែលពួកគេរស់នៅ ឬ ស្ថិតក្រោមការគំរាមកំហែងនៃការបណ្ដេញចេញពីកន្លែងរស់នៅ នៅក្នុងតំបន់គម្រោង ។ ក្រុមអធិការកិច្ចបានរកឃើញថា អាស្រ័យដោយខ្វះប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃរឹងមាំមួយសម្រាប់គម្រោង ថ្នាក់ដឹកនាំរបស់ធនាគារពិភពលោក មិនបានដឹងអំពីបញ្ហាគួរឱ្យកត់សម្គាល់ដែលបានកើតឡើងបណ្ដាលមកពីគម្រោង ដែលចំណុចនេះ ក៏ពុំស្របទៅនឹងគោលនយោបាយរបស់ធនាគារពិភពលោកផងដែរ ។

**ការសង្កេតបន្ថែម :** ក្រុមអធិការកិច្ចសូមធ្វើការគូសបញ្ជាក់ថា ក្រុមអធិការកិច្ចចាត់ទុកថាការចូលរួមរបស់ធនាគារពិភពលោក

ទៅលើបញ្ហាដីធ្លីនៅក្នុងប្រទេសកម្ពុជា មានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការអភិវឌ្ឍរបស់ប្រទេស និងមានសង្គតភាពទៅនឹងទស្សនវិស័យអភិវឌ្ឍន៍រយៈពេលវែងរបស់រាជរដ្ឋាភិបាល និងអាណត្តិការងារទូទៅរបស់ធនាគារពិភពលោក ក្នុងការកាត់បន្ថយភាពក្រីក្រ ។

នៅក្នុងបរិបទនេះ និងដោយមិនបន្ទាបសារៈសំខាន់នៃគំហើញរបស់ខ្លួន ក្រុមអធិការកិច្ចសូមកោតសរសើរចំពោះការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងទៅនឹងការស្នើសុំធ្វើអធិការកិច្ច និង ការវាយតម្លៃដោយភាពស្មោះត្រង់របស់ថ្នាក់គ្រប់គ្រងទៅលើបញ្ហាគ្រោះថ្នាក់ និងភាពអនុលោម ។ ក្រុមអធិការកិច្ចយល់ស្របទៅនឹងទស្សនៈរបស់ថ្នាក់គ្រប់គ្រងទៅលើបញ្ហាចម្បងនៃទំនាក់ទំនងរវាងគម្រោង និងការបណ្តេញប្រជាពលរដ្ឋចេញពីតំបន់បឹងកក់ ។ បន្ថែមពីនេះទៀត ក្រុមអធិការកិច្ចបានរកឃើញថា កម្រងសកម្មភាពបែបប្រតិសកម្ម ដែលថ្នាក់គ្រប់គ្រងបានអនុវត្តចាប់ពីខែមករា ឆ្នាំ២០០៩ រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ស្របទៅនឹងបទប្បញ្ញត្តិនៃគោលនយោបាយរបស់ធនាគារពិភពលោក ស្តីពីការត្រួតពិនិត្យគម្រោង ។ ជាពិសេស បេសកកម្មការត្រួតពិនិត្យឡើងវិញសម្រាប់ភាពប្រសើរនៃគម្រោង ដែលត្រូវបានអនុវត្តនៅក្នុងខែមិនា-មេសា ឆ្នាំ២០០៩ មានសារៈសំខាន់ណាស់ក្នុងការគូសបញ្ជាក់ទៅលើកង្វះខាតជាច្រើននៅក្នុងការរៀបចំគម្រោង ការអនុវត្តគម្រោង និងការត្រួតពិនិត្យគម្រោង ។ ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចបានបញ្ជាក់ទៅលើគំហើញ និងធ្វើឱ្យគំហើញកាន់តែមានភាពទូលំទូលាយសម្រាប់បេសកកម្មត្រួតពិនិត្យឡើងវិញសម្រាប់ភាពប្រសើរនៃគម្រោង ។ ក្រុមអធិការកិច្ចសង្ឃឹមថា របាយការណ៍ស៊ើបអង្កេតនឹងរួមចំណែកដល់ការចាប់ផ្តើមនៃការចូលរួមថ្មីមួយ ជាមួយរាជរដ្ឋាភិបាលទៅលើការដោះស្រាយបញ្ហាដែលម្ចាស់សំណើបានលើកឡើង។

ក្រុមអធិការកិច្ចជឿថា ករណីនេះគូសបញ្ជាក់អំពីតម្លៃនៃការមានមាគ៌ាឯករាជ្យនៃប្រភពជំនួយមួយ សម្រាប់ប្រជាជនដែលទទួលរងផលប៉ះពាល់ពីគម្រោង។ ដូចមានរៀបរាប់នៅក្នុងរបាយការណ៍នេះ ការចូលរួមរបស់ម្ចាស់សំណើតាមរយៈដំណើរការរបស់ក្រុមអធិការកិច្ចបានបន្តឱ្យមាននូវការចូលរួមបែបប្រតិសកម្មមួយ ពីថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក និងនាំឱ្យឈានទៅដល់ការត្រួតពិនិត្យឡើងវិញប្រកបដោយភាពប្រុងប្រយ័ត្នទៅលើបញ្ហាធ្ងន់ធ្ងរនានា ដែលបានលើកឡើង ។ លើសពីនេះទៀត ក្នុងលក្ខណៈជាផ្នែកមួយនៃដំណើរការនេះ ថ្នាក់គ្រប់គ្រងបានធ្វើការត្រួតពិនិត្យឡើងវិញមួយតាមមូលដ្ឋាន និងបានកំណត់រកឃើញថា យ៉ាងហោចណាស់មានគ្រួសារចំនួន ២.៦០០គ្រួសារ ទៀត ដែលត្រូវបានបណ្តេញចេញ ឬប្រឈមទៅនឹងការបណ្តេញចេញនៅក្នុងតំបន់គម្រោងគ្របដណ្តប់។

# មាតិកា


អំពីក្រុមអធិការកិច្ច ........ i

សេចក្តីថ្លែងអំណរគុណ ........ iii

ពាក្យបំព្រួញ អក្សរកាត់ និងវាក្យស័ព្ទបច្ចេកទេស ........ iv

ទិដ្ឋភាពទូទៅ ........ vi

មាតិកា........ xi

សង្ខេប ........ xiv

ជំពូកទី១ : សំណើសុំធ្វើអធិការកិច្ច ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង និងដំណើរការស៊ើបអង្កេត ........ ១

ក. ការរៀបចំរបាយការណ៍ ........ ១

ខ. សំណើសុំធ្វើអធិការកិច្ច........ ១

គ. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង........ ៣

១. ការសង្កេតទូទៅ ........ ៣

២. ការឆ្លើយតបទៅនឹងសំណើសុំធ្វើអធិការកិច្ច........ ៥

៣. បញ្ហាពិសេសៗ និងផែនការសកម្មភាព........ ៦

ឃ. ដំណើរការស៊ើបអង្កេត ........ ៧

១. របាយការណ៍បឋមរបស់ក្រុមអធិការកិច្ច ស្តីពីលក្ខខណ្ឌសមស្រប និងលក្ខខណ្ឌសមស្របនៃសំណើ........ ៧

២. របាយការណ៍បញ្ចប់ ស្តីពីលក្ខខណ្ឌសមស្រប ........ ៨

៣. វិធីសាស្ត្រស៊ើបអង្កេត........ ៨

៤. គោលនយោបាយពាក់ព័ន្ធរបស់ធនាគារពិភពលោក ........ ១០

ជំពូកទី២ : គម្រោង បរិបទគម្រោង និងព្រឹត្តិការណ៍នៅក្នុងតំបន់បឹងកក់........ ១៣

ក. ទិដ្ឋភាពទូទៅ........ ១៣

ខ. គម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល (LMAP) ........ ១៣

គ. ទិដ្ឋភាពសំខាន់ៗនៃបរិបទគម្រោង........ ១៦

១. របបកម្មសិទ្ធិដីធ្លី ........ ១៦

២. ការគ្រប់គ្រងដីរដ្ឋ........ ១៩

៣. រចនាសម្ព័ន្ធស្ថាប័ននៃរដ្ឋបាលដីធ្លី........ ២៤

៤. សន្តិសុខកម្មសិទ្ធិដីធ្លីក្នុងរាជធានីភ្នំពេញ ........ ២៥

ឃ. សាវតានៃព្រឹត្តិការណ៍នៅក្នុងតំបន់បឹងកក់ ........ ៣១

១. ប្រវត្តិនៃការតាំងទីលំនៅ នៅក្នុងតំបន់បឹងកក់........ ៣១

២. ប្រភេទកម្មសិទ្ធិដីធ្លីនៅក្នុងតំបន់បឹងកក់........ ៣២

៣. ការផ្ដួចផ្ដើមអភិវឌ្ឍសម្រាប់តំបន់បឹងកក់ ........ ៣៤
៤. ដំណើរការវិនិច្ឆ័យក្រោមគម្រោង ........ ៣៥
៥. ការបង្ខំបណ្ដេញចេញពីតំបន់បឹងកក់ ........ ៣៩
ជំពូកទី៣ : ការវិភាគ និងគំហើញរបស់ក្រុមអធិការកិច្ច ........ ៤៤
ក. ទិដ្ឋភាពទូទៅ ........ ៤៤
ខ. ការអះអាងថាព្រឹត្តិការណ៍នៅក្នុងតំបន់បឹងកក់ មានទំនាក់ទំនងទៅនឹងគម្រោង ........ ៤៥
១. ការអះអាងរបស់ម្ចាស់សំណើ និងការឆ្លើយតបពីថ្នាក់គ្រប់គ្រង ........ ៤៥
២. ការវិភាគរបស់ក្រុមអធិការកិច្ច ........ ៤៥
គ. ការអះអាងថាប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ត្រូវបានត្រូវបានបដិសេធចំពោះការវិនិច្ឆ័យទៅលើការទាមទារអចលនទ្រព្យរបស់ពួកគេក្រោមគម្រោង ........ ៤៧
១. ការអះអាងរបស់ម្ចាស់សំណើ និងការឆ្លើយតបពីថ្នាក់គ្រប់គ្រង ........ ៤៧
២. ការវិភាគរបស់ក្រុមអធិការកិច្ច ........ ៤៩
៣. គំហើញអំពីភាពអនុលោម ........ ៦២
ឃ. ការអះអាងថាប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ត្រូវបានជម្លៀសដោយរំលោភបំពានទៅលើគោល-នយោបាយដែលបានឯកភាពគ្នា សម្រាប់ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ........ ៦៨
១. ការអះអាងរបស់ម្ចាស់សំណើ និងការឆ្លើយតបពីថ្នាក់គ្រប់គ្រង ........ ៦៨
ង. ការអះអាងថាដំណើរការផ្ដល់ប្លង់ដីដែលអនុម័តដោយគម្រោង បានធ្វើឱ្យចុះខ្សោយទៅលើសិទ្ធិកម្មសិទ្ធិដីធ្លីដែលមានកាលពីមុន ........ ៨៤
១. ការអះអាងរបស់ម្ចាស់សំណើ និងការឆ្លើយតបពីថ្នាក់គ្រប់គ្រង ........ ៨៤
២. ការវិភាគរបស់ក្រុមអធិការកិច្ច ........ ៨៦
៣. គំហើញអំពីភាពអនុលោម ........ ៩១
ច. ការអះអាងថា សហគមន៍ដទៃទៀតនៅក្នុងខេត្តគម្រោងត្រូវបានបង្ខំបណ្ដេញចេញពីកន្លែងដែលពួកគេរស់នៅ ........ ៩៥
១. ការអះអាងរបស់ម្ចាស់សំណើ និងការឆ្លើយតបពីថ្នាក់គ្រប់គ្រង ........ ៩៥
២. ការវិភាគរបស់ក្រុមអធិការកិច្ច ........ ៩៦
ជំពូកទី៤ : មេរៀន និងបញ្ហាប្រព័ន្ធ ........ ១០១

ឧបសម្ព័ន្ធ១ : តារាងនៃគំហើញ ........ ១០៤
ឧបសម្ព័ន្ធ២ : ជីវប្រវត្តិ ........ ១១៦

ប្រអប់

ប្រអប់ទី១ : ឧទាហរណ៍នៃគ្រួសារមួយដែលទទួលរងផលប៉ះពាល់ ........................................................................ ៣
ប្រអប់ទី២ : ប្រវត្តិនៃរបបកម្មសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជា* ........................................................................ ១៨
ប្រអប់ទី៣ : ការបារម្ភអំពីការលិចទឹក ដោយសារការចាក់បំពេញបឹងកក់* ........................................................ ៤២

តួលេខ

តួលេខទី១ : ចំនួនប្រជាជនដែលរស់នៅក្នុងតំបន់អនាធិបតេយ្យក្នុងប្រទេសកម្ពុជា និងតួលេខទី២ : ចំនួនប្រជាជនដែលរស់នៅក្នុងតំបន់អនាធិបតេយ្យក្នុងរាជធានីភ្នំពេញ................................................................ ២៩
តួលេខទី៣ : រូបភាពបឹងកក់ថតពីលើ ( ម៉ន លីម ២០០៦) ........................................................................ ៣១

រូបភាព

រូបភាពទី១ : លំនៅដ្ឋានកកកុញនៅក្នុងតំបន់បឹងកក់ ........................................................................ ៣២
រូបភាពទី២ : ផ្ទះបណ្តែតទឹកនៅលើបឹងកក់........................................................................ ៤១
រូបភាពទី៣ : ក្រុមអធិការកិច្ចជួបជាមួយសហគមន៍ដែលទទួលរងផលប៉ះពាល់ នៅក្នុងតំបន់បឹងកក់......................... ៤៧
រូបភាពទី៤ : ការចាក់ខ្សាច់បំពេញបឹងកក់ ........................................................................ ៥៣
រូបភាពទី៥ : តំបន់តាំងទីលំនៅឡើងវិញ - តំណាក់ត្រយឹង ដែលមានចម្ងាយប្រមាណ ២០គីឡូម៉ែត្រពីរាជធានីភ្នំពេញ.. ៨៣
រូបភាពទី៦ : ផ្ទះដែលគ្របដណ្តប់ទៅដោយភក់ ក្នុងអំឡុងពេលនៃការចាក់បំពេញបឹងនាពេលថ្មីៗនេះ , រូបរបស់ BABSEA........................................................................ ៩១

# សង្ខេប

ក្រុមអធិការកិច្ចបានរៀបចំរបាយការណ៍ស៊ើបអង្កេតនេះ ដើម្បីឆ្លើយតបទៅនឹងសំណើសុំឱ្យមានការធ្វើអធិការកិច្ច ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩ ដែលទាក់ទងទៅនឹងគម្រោងដីធ្លី និងរដ្ឋបាលនៅក្នុងប្រទេសកម្ពុជា (ចាប់ពីពេលនេះតទៅ សំដៅហៅថា "LMAP" ឬ "គម្រោង") ។ របាយការណ៍របស់ក្រុមអធិការកិច្ច ត្រូវបានបង្ហាញជា៤ជំពូក ។

# សំណើសុំឱ្យមានការធ្វើអធិការកិច្ច ការឆ្លើយតបពីថ្នាក់គ្រប់គ្រង និងដំណើរការស៊ើបអង្កេត

## សំណើ

សំណើសុំឱ្យមានការធ្វើអធិការកិច្ច ត្រូវបានដាក់ជូនដោយមជ្ឈមណ្ឌលសម្រាប់សិទ្ធិលំនៅដ្ឋាន និង ការបណ្តេញចេញ (COHRE) ជំនួសឱ្យសហគមន៍ដែលទទួលរងផលប៉ះពាល់ពីគម្រោងដីធ្លី និងរដ្ឋបាល នៅក្នុងប្រទេសកម្ពុជា (ចាប់ពីពេលនេះតទៅ សំដៅហៅថា "LMAP" ឬ "គម្រោង") ។ សហគមន៍ទាំងនេះ ដែលរួមមានប្រមាណ ៤.២៥០គ្រួសារ មានមូលដ្ឋាននៅក្នុងតំបន់បឹងកក់ (BKL) នៅក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ពាក្យថា "តំបន់បឹងកក់" តំណាងឱ្យផ្ទៃដីចំនួន ១៣៣ហិកតា រាប់បញ្ចូលទាំងបឹង (ប្រមាណ ៩០ហិកតា) និងតំបន់ជុំវិញ ដែលត្រូវបានជួលទៅឱ្យអ្នកអភិវឌ្ឍឯកជនមួយ ក្នុងឆ្នាំ២០០៧ ។

ការអះអាងទី១នៅក្នុងសំណើ គឺសកម្មភាពស្ថិតក្រោមគម្រោង LMAP ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក បានរួមចំណែកបណ្តាលឱ្យមាននូវគ្រោះថ្នាក់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ ។ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជា មិនបានដឹងអំពីទំនាក់ទំនងរវាងហេតុការណ៍ដែលបានកើតឡើងនៅក្នុងតំបន់បឹងកក់ និងគម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល (LMAP) នោះទេ ។ តាមរយៈការប្រៀបធៀប ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកចាត់ទុកថា ទំនាក់ទំនងនេះពិតជាបានកើតឡើង ដោយយល់ស្របទៅនឹងការអះអាងរបស់ម្ចាស់សំណើ ។

ទី២ ម្ចាស់សំណើអះអាងថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ ត្រូវបានបដិសេធចំពោះសិទ្ធិរបស់ពួកគេ ក្នុងការស្នើសុំឱ្យការទាមទាររបស់ពួកគេ ត្រូវបានពិចារណា និងវិនិច្ឆ័យក្រោមគម្រោង ។ យោងតាមសំណើ បើទោះបីជាសង្កាត់ស្រះចកទាំងមូលត្រូវបានប្រកាសថាជាតំបន់វិនិច្ឆ័យក្រោមគម្រោង LMAP ក៏ដោយ ប្រជាជនត្រូវបានគេប្រាប់ថា ការវិនិច្ឆ័យនៅក្នុងតំបន់បឹងកក់ មិនត្រូវបានធ្វើឡើងឡើយ អាស្រ័យដោយដីនៅក្នុងតំបន់នេះ ស្ថិតនៅក្នុង "តំបន់អភិវឌ្ឍ" ។ ម្ចាស់សំណើជឿថា តំបន់បឹងកក់ ត្រូវបានធ្វើការបែងចែកប្រភេទជាថ្មីឡើងវិញ ដើម្បីបង្កលក្ខណៈឱ្យមាននូវការអភិវឌ្ឍ ដោយ

អ្នកអភិវឌ្ឍន៍ឯកជន ដែលធ្វើឱ្យសហគមន៍ដែលទទួលរងផលប៉ះពាល់ពុំមានឱកាសគ្រប់គ្រាន់ ដើម្បីឱ្យសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេត្រូវបានពិចារណាក្រោមគម្រោង និងនាំឱ្យឈានទៅដល់ការបង្ខំបណ្តេញពួកគេចេញពីកន្លែងរស់នៅរបស់ពួកគេ។

ទី៣ ម្ចាស់សំណើអះអាងថា មិនចំពោះថា ស្ថានភាពកម្មសិទ្ធិភាពទៅលើដីធ្លីមានលក្ខណៈដូចម្តេចឡើយ ប្រជាពលរដ្ឋនៅក្នុងតំបន់បឹងកក់ បាននិងកំពុងត្រូវបានបណ្តេញចេញពីលំនៅដ្ឋានរបស់ពួកគេក្នុងលក្ខណៈមួយ ដែលរំលោភបំពានទៅលើក្របខ័ណ្ឌគោលនយោបាយ ស្តីពីការតាំងទីលំនៅឡើងវិញ (RPF) សម្រាប់គម្រោងនេះ ដែលតម្រូវឱ្យអនុវត្តក្រោមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍ (DCA) ។ គេបានធ្វើការប៉ាន់ប្រមាណផ្សេងៗគ្នាថា ប្រជាពលរដ្ឋច្រើនជាង ១.៥០០គ្រួសារ ត្រូវបានបណ្តេញចេញពីលំនៅដ្ឋានរបស់ពួកគេ ព្រមទាំងមានគ្រួសារច្រើនជាងនេះទៀត ដែលកំពុងស្ថិតក្រោមការគំរាមកំហែងនៃការបណ្តេញចេញ ។ ម្ចាស់សំណើ បានត្អូញត្អែរអំពីការផ្តល់សំណងមិនគ្រប់គ្រាន់ សម្ពាធ និងការគំរាមកំហែង ដើម្បីធ្វើឱ្យប្រជាពលរដ្ឋចាកចេញពីផ្ទះរបស់ពួកគេ និងការលិចផ្ទះដែលបណ្តាលមកពីការចាក់បំពេញបឹងដោយអ្នកអភិវឌ្ឍន៍។

ទី៤ សំណើបានចោទប្រកាន់ថា គម្រោង LMAP ដែលមានបំណងបង្កើតឱ្យមាននូវដំណើរការចុះបញ្ជីដីធ្លីមួយបែបមជ្ឈការ និងផ្លូវការ ដែលផ្អែកលើរបបកម្មសិទ្ធិដីធ្លីទូទៅ ឬមិនផ្លូវការ បានធ្វើឱ្យមានការចុះខ្សោយទៅលើសិទ្ធិកម្មសិទ្ធិដីធ្លីដែលមានស្រាប់កាលពីមុនរបស់ប្រជាពលរដ្ឋ។

ជាចុងក្រោយ យោងតាមម្ចាស់សំណើ មិនត្រឹមតែនៅក្នុងតំបន់បឹងកក់ប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងសហគមន៍តំបន់ទីក្រុង និងជនបទដទៃទៀត រាប់បញ្ចូលសហគមន៍ជនជាតិដើមភាគតិច នៅក្នុងប្រទេសកម្ពុជា ប្រជាពលរដ្ឋមិនអាចទទួលបានប្លង់ដីនៅក្នុងតំបន់វិនិច្ឆ័យរបស់គម្រោង LMAP និង/ឬ យន្តការដោះស្រាយវិវាទក្រោមគម្រោង LMAP ឡើយ ។

## ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង

**ការសង្កេតទូទៅ :** ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង បានធ្វើការកត់សម្គាល់ថា ដោយយោងទៅតាមឯកសារវាយតម្លៃគម្រោង (PAD) គម្រោង LMAP ត្រូវអនុវត្តដោយយោងទៅតាមគោលនយោបាយរបស់ធនាគារពិភពលោក ស្តីពីបរិស្ថាន និងសង្គម ប៉ុន្តែគម្រោងមិនទំនងនឹងបណ្តាលឱ្យមាននូវការតាំងទីលំនៅឡើងវិញ ដោយមិនស្ម័គ្រចិត្តណាមួយឡើយ។ បើទោះជាដូច្នេះក្តី គេបានរៀបចំ RPF និងអ្វីៗជាច្រើនទៀត ដែលគេអាចយកមកអនុវត្តនៅក្នុងព្រឹត្តិការណ៍នៃការបណ្តេញចេញពីរដ្ឋ ដែលបណ្តាលមកពីសកម្មភាពផ្តល់ប្លង់ដីដែលមានលក្ខណៈជាប្រព័ន្ធនៅតាមតំបន់មួយចំនួនតូច ។ ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងបន្តធ្វើការកត់សម្គាល់ទៀតថា សកម្មភាពផ្តល់ប្លង់ដីក្រោមគម្រោងត្រូវបានកំណត់ចែងថា មិនគ្របដណ្តប់ទៅលើអ្នកតាំងទីលំនៅមិនផ្លូវការ ឬ*"អ្នកតាំងទីលំនៅលើដីទំនេរ"* លើដីរដ្ឋឡើយ អាស្រ័យដោយគេមិនបានរំពឹងឱ្យគម្រោងផ្តល់ភាពអចិន្ត្រៃយ៍ទៅលើការតាំងទីលំនៅមិនផ្លូវការបែបនេះទេ ។ ថ្នាក់គ្រប់គ្រង បានពោលអះអាងថា គម្រោង LMAP បានបង្កើតឱ្យមាននូវ *"ប្រយោជន៍អភិវឌ្ឍគួរឱ្យកត់សម្គាល់"* បើទោះជាដូច្នេះក្តី ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា អវត្តមាននៃ

ទិន្នន័យមូលដ្ឋានពាក់ព័ន្ធ ឬ វិធីសាស្ត្រដែលត្រូវបានកំណត់សម្រាប់ប្រមូលទិន្នន័យ រាំងស្ទះដល់ការវាស់ស្ទង់ឱ្យបានត្រឹមត្រូវទៅលើការរីកចម្រើននៅក្នុងបញ្ហាសន្តិសុខកម្មសិទ្ធិដីធ្លី ។

**ការឆ្លើយតបទៅនឹងសំណើសុំធ្វើអធិការកិច្ច :** ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងបានថ្លែងថា បើទោះបីជាតំបន់បឹងកក់មានមូលដ្ឋាននៅក្នុងសង្កាត់ស្រះចកក៏ដោយ តំបន់បឹងកក់មិនត្រូវបានបញ្ចូលទៅក្នុងការវិនិច្ឆ័យទៅលើការទាមទារទ្រព្យសម្បត្តិឡើយ ។ មូលហេតុដែលគេបានលើកឡើង គឺសាលារាជធានីភ្នំពេញ (MPP) បានប្រកាសថា តំបន់បឹងកក់ គឺជាដីសាធារណៈរបស់រដ្ឋ ។ ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា នីតិវិធីដែលត្រូវបានអភិវឌ្ឍក្រោមគម្រោង LMA មិនត្រូវបានគេអនុវត្តតាមឡើយ អាស្រ័យដោយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ ត្រូវបានគេបដិសេធចំពោះឱកាសក្នុងការបង្ហាញអំពីការអះអាងទៅលើកម្មសិទ្ធិដីធ្លីរបស់ពួកគេ និងការចូលរួមនៅក្នុងការឈានទៅដល់ការធ្វើសេចក្តីសម្រេចថា តំបន់បឹងកក់ គឺជាដីសាធារណៈរបស់រដ្ឋ ។ ថ្នាក់គ្រប់គ្រងបានសន្និដ្ឋាននៅក្នុងការឆ្លើយតបរបស់ខ្លួនថា លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការអនុវត្តន៍ RPF ដូចមានកំណត់ចែងនៅក្នុង DCA មានភាពសមស្របទៅនឹងករណីនេះ ដូច្នេះគេគួរបានអនុវត្ត RPF ។

ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងបានធ្វើការកត់សម្គាល់ថា បេសកកម្មជម្រុញការត្រួតពិនិត្យឡើងវិញ (ERM) ត្រូវបានអនុវត្តនៅក្នុងខែមេសា ឆ្នាំ២០០៩ ដែលបានទទួលស្គាល់អំពីភាពខ្វះខាតនៅក្នុងការរៀបចំ និងការអនុវត្តគម្រោង LMAP ។ ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងថ្លែងថា អនុប្រធានប្រចាំតំបន់របស់ធនាគារពិភពលោក (RVP) បានមកធ្វើទស្សនកិច្ចនៅក្នុងរាជធានីភ្នំពេញ ដើម្បីជួបជាមួយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់នៅក្នុង ខែសីហា ឆ្នាំ២០០៩ ។ ជាថ្មីម្តងទៀត អនុប្រធានប្រចាំតំបន់របស់ធនាគារពិភពលោក បានស្នើឱ្យផ្អាកសកម្មភាពបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន ជាបណ្តោះអាសន្ន ដោយយល់ព្រមធ្វើការវិភាជន៍ធនធានមួយចំនួនរបស់ធនាគារពិភពលោក សម្រាប់ការតាំងទីលំនៅឡើងវិញរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់បឹងកក់ និងបានស្នើឱ្យធ្វើការព្យួរគម្រោងរួមគ្នា ខណៈពេលដែលក្របខ័ណ្ឌគោលនយោបាយជាតិ កំពុងត្រូវបានកែលំអ ។ បើទោះជាដូច្នេះក្តី រាជរដ្ឋាភិបាលកម្ពុជាបានស្នើឱ្យលុបចោលឥណទាននៅសេសសល់ដែលមិនទាន់បានដកនៅថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៩ ។

**បញ្ហាពិសេស១ និងផែនការសកម្មភាព :** ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងបានគូសបញ្ជាក់អំពីការបន្តខិតខំដើម្បីដោះស្រាយបញ្ហាកង្វល់របស់ម្ចាស់សំណើ បើទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានលុបចោលឥណទានក៏ដោយ ។ ថ្នាក់គ្រប់គ្រងបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍដទៃទៀតដើម្បីដោះស្រាយបញ្ហាកង្វល់របស់ម្ចាស់សំណើ ។ កិច្ចខិតខំដែលថ្នាក់ដឹកនាំបានស្នើឡើងនៅក្នុងការឆ្លើយតបរបស់ខ្លួន រួមមានការវាយតម្លៃទៅលើផលប៉ះពាល់សង្គមនៃការតាំងទីលំនៅឡើងវិញទៅលើសហគមន៍ដែលទទួលរងផលប៉ះពាល់ ការធានាថា ប្រជាពលរដ្ឋទទួលបានកិច្ចគាំទ្រដូចគ្នា ដោយ RPF ត្រូវបានគេអនុវត្តដើម្បីធ្វើឱ្យប្រសើរឡើងនូវកាលានុវត្តភាពសង្គម និងសេដ្ឋកិច្ច ការដោះស្រាយបញ្ហាកង្វល់អំពីលក្ខខណ្ឌរស់នៅ និងកាលានុវត្តភាពក្នុងការប្រកបរបរចិញ្ចឹមជីវិត នៅក្នុង និងជុំវិញកន្លែងតាំងទីលំនៅឡើងវិញ ការលើកទឹកចិត្តឱ្យរដ្ឋាភិបាលកាត់បន្ថយផលប៉ះពាល់បរិស្ថាននៃការចាក់បំពេញបឹងកក់ ការធ្វើឱ្យប្រសើរឡើងនូវយន្តការដោះស្រាយវិវាទដែលមានស្រាប់ និងសមត្ថភាពរបស់សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការប្រើប្រាស់

យន្តការទាំងនោះ ការជម្រុញឱ្យរដ្ឋាភិបាលចូលរួមនៅក្នុងការពិនិត្យសម្រេច ទៅលើក្របខ័ណ្ឌគោលនយោបាយជាតិមួយស្តីពីការតាំងទីលំនៅឡើងវិញ ការផ្តួចផ្តើមឱ្យមាននូវដំណើរការពិគ្រោះយោបល់មួយ ដើម្បីកំណត់ឡើងវិញទៅលើតួនាទីរបស់ធនាគារពិភពលោក នៅក្នុងប្រទេសកម្ពុជា និងដើម្បីកំណត់វិសាលភាពនៃកិច្ចគាំទ្រ ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល ទាក់ទងទៅនឹងយុទ្ធសាស្ត្រផ្តល់ជំនួយសម្រាប់ប្រទេស (CAS)។

## ដំណើរការស៊ើបអង្កេត

ក្រុមអធិការកិច្ចបានកំណត់នៅក្នុងរបាយការណ៍ និងអនុសាសន៍របស់ខ្លួន ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០០៩ ថា សំណើត្រូវទៅនឹងលក្ខខណ្ឌសមស្របសម្រាប់ការធ្វើអធិការកិច្ច ។ បើទោះជាដូច្នេះក្តី ក្រុមអធិការកិច្ចមិនបានណែនាំឱ្យផ្តល់អនុសាសន៍នៅពេលនោះ ថាតើត្រូវធានាឱ្យមាននូវការស៊ើបអង្កេតមួយនៅឡើយនោះទេ ដោយឡែក គេគួររង់ចាំមើលការវិវឌ្ឍន៍បន្ថែមជាពិសេសអាស្រ័យដោយថ្នាក់គ្រប់គ្រងកំពុងព្យាយាម ចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា និង ដៃគូអភិវឌ្ឍដទៃទៀត ដើម្បីដោះស្រាយបញ្ហាកង្វល់របស់ម្ចាស់សំណើ។ ក្រុមអធិការកិច្ចបានផ្តល់របាយការណ៍ចុងក្រោយរបស់ខ្លួន ស្តីពីលក្ខខណ្ឌសមស្របនៅថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០១០ ដែលនៅក្នុងរបាយការណ៍នេះ គេបានផ្តល់អនុសាសន៍ឱ្យធ្វើការស៊ើបអង្កេត។

**បញ្ហាសំខាន់ៗនៃភាពអនុលោម និងគោលនយោបាយពាក់ព័ន្ធ :** ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចទៅលើការអះអាងរបស់ម្ចាស់សំណើ និងបញ្ហាពាក់ព័ន្ធទៅនឹងភាពអនុលោម បានផ្តោតលើសំនួរសំខាន់ៗខាងក្រោម :

- តើមានទំនាក់ទំនងរវាងការបណ្តេញប្រជាពលរដ្ឋចេញពីតំបន់បឹងកក់ និងគម្រោង ដូចដែលម្ចាស់សំណើបានអះអាងដែរឬទេ?
- តើប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ ត្រូវបានបដិសេធចំពោះការវិនិច្ឆ័យ ទៅលើការទាមទារអចលនទ្រព្យរបស់ពួកគេ ដែរឬទេ? តើភាពមិនច្បាស់លាស់នៅក្នុងការរៀបចំគម្រោងរួមចំណែកបណ្តាលឱ្យខ្វះការវិនិច្ឆ័យទៅលើការអះអាងទ្រព្យសម្បត្តិនៅក្នុងតំបន់បឹងកក់ ដែរឬទេ? តើការត្រួតពិនិត្យគម្រោងជួយដោះស្រាយបញ្ហាដែលម្ចាស់សំណើបានលើកឡើង គ្រប់គ្រាន់ដែរឬទេ?
- តើកង្វះនៃការអនុវត្តន៍ RPF សម្រាប់តំបន់បឹងកក់ ស្របទៅនឹងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍ ដែរឬទេ? តើកង្វះនៃការអនុវត្តន៍នេះ បណ្តាលមកពីចន្លោះប្រហោងនៅក្នុងការរៀបចំ RPF ឬ? តើកត្តានេះ បង្កឱ្យមាននូវផលប៉ះពាល់អវិជ្ជមានទៅលើម្ចាស់សំណើ ដែរឬទេ?
- តើដំណើរការផ្តល់ប្លង់ដី ដែលគម្រោង LMAP បានជ្រើសរើសយកមកប្រើប្រាស់ ធ្វើឱ្យចុះខ្សោយទៅលើសិទ្ធិកម្មសិទ្ធិដីធ្លីដែលមានស្រាប់កាលពីមុនរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់វិនិច្ឆ័យគម្រោង LMAP ដែរឬទេ? តើគម្រោងបានបញ្ចូលប្រព័ន្ធត្រួតពិនិត្យតាមដាន និង វាយតម្លៃគ្រប់ជ្រុងជ្រោយមួយ ទៅលើផលប៉ះពាល់នៃសកម្មភាពគម្រោង ចំពោះក្រុមប្រជាជនក្រីក្រ និងក្រុមដែលបាត់បង់ប្រយោជន៍ដទៃទៀត ដែរឬទេ?
- តើមានសហគមន៍ដទៃទៀត ដែលទទួលរងផលប៉ះពាល់អវិជ្ជមាននៅក្នុងតំបន់គម្រោង ដែរឬទេ? តើការរៀបចំគម្រោងបានលើកឡើងគ្រប់គ្រាន់អំពីហានិភ័យនៃការបង្ខំបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន ដែរឬទេ?

នៅក្នុងការស៊ើបអង្កេត ក្រុមអធិការកិច្ចបានធ្វើការវាយតម្លៃ ថាតើធនាគារពិភពលោកបានអនុវត្តស្របទៅតាម OMS 2.20 ស្តីពីការវាយតម្លៃគម្រោង , OD 4.30 ស្តីពីការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត និង OP/BP 13.05 ស្តីពីការត្រួតពិនិត្យគម្រោង។

# គម្រោង បរិបទគម្រោង និងព្រឹត្តិការណ៍ថ្មីៗនៅក្នុងតំបន់បឹងកក់

## គម្រោង

ក្រុមអធិការកិច្ចទទួលស្គាល់អំពីគំនិតដ៏សំខាន់ដែលជាមូលដ្ឋាននៃការរៀបចំគម្រោង នោះគឺទំនាក់ទំនងរវាងការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខនៃកម្មសិទ្ធិដីធ្លី ។ ក្រុមអធិការកិច្ចក៏បានធ្វើការកត់សម្គាល់ទៅលើការរៀបចំគម្រោងប្រកបដោយភាពមហិច្ឆតាដែលពាក់ព័ន្ធទៅនឹងពិពិធភាពនៃសមាសធាតុចូលរួម និងប្រយោជន៍ដែលគេបានព្យាករណ៍ទុកជាមុន ។ គោលបំណងសំខាន់ៗរបស់គម្រោង រួមមាន :

(១) ការអភិវឌ្ឍន៍ឱ្យមាននូវគោលនយោបាយជាតិគ្រប់គ្រាន់ ក្របខ័ណ្ឌបទដ្ឋានគតិយុត្តិមួយ និងស្ថាប័នសម្រាប់រដ្ឋបាលដីធ្លី

(២) ការផ្តល់ និងការចុះបញ្ជីប្លង់ដីនៅតាមតំបន់ជនបទ និងតំបន់ទីក្រុង នៅក្នុងខេត្តគម្រោងគ្របដណ្តប់

(៣) ការបង្កើតឱ្យមាននូវប្រព័ន្ធរដ្ឋបាលដីធ្លីមួយ ប្រកបដោយភាពសក្តិសិទ្ធិ និងតម្លាភាព។

សមាសធាតុគម្រោងចំនួន៣ (ក្នុងចំណោមសមាសធាតុគម្រោងចំនួន៥) មានសារៈសំខាន់ជាពិសេសចំពោះសំណើសុំធ្វើអធិការកិច្ច :

- សមាសធាតុទី៣ មានគោលបំណងគាំទ្រដល់ការផ្តល់ប្លង់ដី និងការបង្កើតឱ្យមាននូវប្រព័ន្ធចុះបញ្ជីដីធ្លីមួយ
- សមាសធាតុទី៤ ត្រូវបានរៀបចំឡើងដើម្បីពង្រឹងយន្តការដោះស្រាយវិវាទ
- សមាសធាតុទី៥ មានគោលបំណងពង្រឹងការគ្រប់គ្រងដីធ្លីតាមរយៈការរៀបចំឱ្យមាននូវ ផែនទីប្រើប្រាស់ដី និងបែងចែកចំណាត់ថ្នាក់ដី ដែលបង្ហាញអំពីព្រំដែននៃចំណាត់ថ្នាក់ដីផ្សេងៗគ្នា រាប់បញ្ចូលទាំងដីរដ្ឋ ផងដែរ ។

ការផ្តល់ហិរញ្ញប្បទានរបស់ធនាគារពិភពលោកសម្រាប់គម្រោង ក្នុងចំនួនស្មើទៅនឹង ២៣.៤ លានដុល្លាសហរដ្ឋអាមេរិក ត្រូវបានអនុម័ត ក្នុងខែកុម្ភៈ ឆ្នាំ២០០២ ។ ដំបូង កាលបរិច្ឆេទបិទត្រូវបានកំណត់ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៧ ប៉ុន្តែក្រោយមកត្រូវបានពន្យាពេលរហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៩ ។ នៅថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា បានលុបចោលឥណទាននៅសល់ដែលមិនទាន់បានដក ។

## បរិបទ

បរិបទនៃគម្រោងមានការលំបាកជាពិសេស ដែលបរិបទនេះ ក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការរៀបចំគម្រោងផងដែរ ។ ក្រុមអធិការកិច្ចទទួលស្គាល់ថា គេត្រូវយល់អំពីការអះអាងដែលបានលើកឡើងនៅក្នុងសំណើសុំធ្វើអធិការកិច្ច ព្រមទាំងលទ្ធផល និងផលប៉ះពាល់នៃគម្រោង នៅក្នុងបរិបទនេះ ។ ជំពូក២ ផ្តល់សាវតាព័ត៌មានអំពីទិដ្ឋភាពសំខាន់ៗចំនួន៤ :

- កេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ ដែលបង្កើតឱ្យមាននូវការផ្តាច់របបកម្មសិទ្ធិដីធ្លីយ៉ាងគំហុក និងគោលគំនិតប្រកួតប្រជែងគ្នាអំពីរបៀបកំណត់ និងផ្ទៀងផ្ទាត់ទៅលើសិទ្ធិកម្មសិទ្ធិដីធ្លី ។

- កំណែទម្រង់ថ្មីៗនៅក្នុងច្បាប់ភូមិបាល មិនទាន់បានបង្កើតឱ្យមាននូវនីតិវិធី និងការអនុវត្តច្បាប់ច្បាស់លាស់មួយ ដើម្បីកំណត់ថា តើអ្វីទៅជាដីរដ្ឋ និងតើអ្វីទៅដែលគេអាចផ្តល់ប្លង់កម្មសិទ្ធិទៅឱ្យភាគីឯកជន។
- ស្ថាប័នដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងដីធ្លីមានសមត្ថភាពទាប និងខ្វះភាពច្បាស់លាស់ អំពីតួនាទី និងការទទួលខុសត្រូវរវាងតួអង្គស្ថាប័នជាច្រើនដែលពាក់ព័ន្ធ។
- នគរូបនីយកម្មឆាប់រហ័សនៅក្នុងបរិបទនៃកំណើនសេដ្ឋកិច្ចឆាប់រហ័ស និង កំណើនវិនិយោគបរទេសបានបង្កើតឱ្យមាននូវការកើនឡើងនៃអសន្តិសុខកម្មសិទ្ធិដីធ្លី នៅក្នុងតំបន់ទីក្រុង ជាពិសេសគឺនៅក្នុងរាជធានីភ្នំពេញ។

## ព្រឹត្តិការណ៍នៅក្នុងតំបន់បឹងកក់

ផ្នែកចុងក្រោយនៃជំពូកនេះ ផ្តល់នូវប្រវត្តិសាវតាមួយចំនួននៃព្រឹត្តិការណ៍នាពេលថ្មីៗនៅក្នុងតំបន់បឹងកក់ ដែលបណ្តាលឱ្យមាននូវការបង្ខំបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន ដែលជាហេតុជម្រុញឱ្យមានសំណើសុំធ្វើអធិការកិច្ច ។ ដំណើរការការវិនិច្ឆ័យដីធ្លីក្រោមគម្រោង LMAP និងការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន ដែលបណ្តាលមកពីការជួលតំបន់នេះទៅឱ្យអ្នកអភិវឌ្ឍឯកជន ត្រូវបានគូសបញ្ជាក់ដូចខាងក្រោម :

**ប្រវត្តិនៃការតាំងទីលំនៅ :** តំបន់បឹងកក់មានការតាំងទីលំនៅតិចតួច មុនសម័យខ្មែរក្រហម និងត្រូវបានអភិវឌ្ឍនៅពេលដែលមានការកាន់កាប់ទីក្រុងភ្នំពេញឡើងវិញ ក្រោយជំនាន់នោះ ។ នៅឆ្នាំ១៩៩១ នៅពេលដែលប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតសកលរបស់ខ្លួនលើកទី១ ដីភាគច្រើនដែលនៅជុំវិញបឹងកក់ សុទ្ធសឹងតែត្រូវបានគេកាន់កាប់ទាំងស្រុង ។ គ្រួសារជាច្រើននៅក្នុងតំបន់នេះ អះអាងថាពួកគេមានឯកសារដែលបញ្ជាក់អំពីការដែលពួកគេបានរស់នៅក្នុងតំបន់នេះ តាំងពីយូរយាណាស់មកហើយ និងកម្មសិទ្ធិរបស់ពួកគេទៅលើដីធ្លី ។

**ប្រភេទកម្មសិទ្ធិដីធ្លី :** គេមានប្រភេទកម្មសិទ្ធិដីធ្លីជាច្រើនផ្សេងៗគ្នា នៅក្នុង និងជុំវិញតំបន់បឹងកក់ ។ បឹងនេះ ដែលមានកម្ពស់ទឹកទាបបំផុតនៅរដូវប្រាំង ត្រូវបានកំណត់ដោយច្បាប់ភូមិបាល ឆ្នាំ២០០១ ថាជាដីសាធារណៈរបស់រដ្ឋ ។ មួយផ្នែកនៃដីនេះមានខ្សែរថភ្លើងឆ្លងកាត់ ដែលបច្ចុប្បន្នខ្សែរថភ្លើងនោះមិនដំណើរការឡើយ និង តំបន់ដទៃទៀតជុំវិញបឹង ត្រូវបានគេរាយការណ៍ឱ្យដឹងថាធ្លាប់ត្រូវបានប្រើប្រាស់ជាឧទ្យានសាធារណៈរបស់រដ្ឋ និងសួនសត្វ នៅពេលណាមួយ ក្រោយការកាន់កាប់ទីក្រុងឡើងវិញ ។ ពុំមានចំណុចជាក់លាក់អំពីព្រំដែននៃសួនឧទ្យាន និងទម្រង់នៃការតាំងទីលំនៅ ហើយអាជ្ញាធរមិនបានចុះបញ្ជីដីនេះក្នុងនាមជារដ្ឋនៅក្នុងបញ្ជីដីធ្លីឡើយ ។ ចំណុចនេះ បង្ហាញឱ្យឃើញអំពីសេចក្តីត្រូវការឱ្យមាននូវដំណើរការវិនិច្ឆ័យ ដើម្បីដោះស្រាយទៅលើការអះអាងរៀងៗខ្លួនរបស់រដ្ឋ ម្ចាស់កម្មសិទ្ធិបច្ចុប្បន្ន និងដើមបណ្តឹងដទៃទៀត ។

**ការផ្តួចផ្តើមអភិវឌ្ឍ :** តំបន់បឹងកក់ ដែលជាដីនៅក្នុងតំបន់ទីក្រុងមួយកន្លែងដ៏ល្អ និងស្ថិតនៅចំចំណុចកណ្តាលនៃរាជធានីភ្នំពេញ ត្រូវបានគេចាត់ទុកថាល្អមនឹងធ្វើការអភិវឌ្ឍឡើងវិញជាយូរយាណាស់មកហើយ ។ គេបានប្រកាសឱ្យមាននូវការប្រកួតប្រជែងគូរប្លង់ជាលក្ខណៈអន្តរជាតិមួយ ក្នុងឆ្នាំ២០០៤ ។ សំណើដែលបានទទួលជ័យជំនះ រាប់បញ្ចូលទាំងផែនការសម្រាប់ផ្លាស់ប្តូរទីតាំងលំនៅដ្ឋានឡើងវិញ ឱ្យមានលក្ខណៈជាជួរនៅជុំវិញបឹងកក់។ បើទោះជាដូច្នេះក្តី នៅពេលដែលលទ្ធផល

កំពុងត្រូវបានប្រកាស រដ្ឋាភិបាលបានសម្រេចចិត្តធ្វើការអភិវឌ្ឍតំបន់នេះឡើងវិញជាលក្ខណៈពាណិជ្ជកម្ម តាមរយៈក្រុមហ៊ុនអភិវឌ្ឍឯកជនដែលមានឈ្មោះ ស៊ូកាគូ (Shukaku Inc.) ។ នៅថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៧ សាលាក្រុងភ្នំពេញ និងក្រុមហ៊ុន ស៊ូកាគូ បានចុះហត្ថលេខាទៅលើឯកសារជួលមួយច្បាប់ រយៈពេល៩៩ឆ្នាំ ដែលមានទឹកប្រាក់ចំនួន ៧៩លានដុល្លាសហរដ្ឋអាមេរិក សម្រាប់ផ្ទៃដីចំនួន ១៣៣ហិកតា ។ ក្រោយមក រដ្ឋាភិបាលបានអនុម័តទៅលើអនុក្រឹត្យមួយ ដោយផ្លាស់ប្តូរតំបន់បឹងកក់ (រាប់បញ្ចូលទាំងបឹងផងដែរ) ពីដីសាធារណៈរបស់រដ្ឋ ទៅជាដីឯកជនរបស់រដ្ឋ ។

**ការវិនិច្ឆ័យក្រោមគម្រោង LMAP :** ក្នុងខែមិនា ឆ្នាំ២០០៦ សាលាក្រុងភ្នំពេញ បានប្រកាសថា សង្កាត់ស្រះចក ត្រូវបានកំណត់ថាជាតំបន់វិនិច្ឆ័យមួយ សម្រាប់ការផ្តល់ប្លង់ដីដែលមានលក្ខណៈជាប្រព័ន្ធក្រោមគម្រោង LMAP ។ អាស្រ័យដោយស្ថានភាពកម្មសិទ្ធិដីធ្លីនៃតំបន់នេះ មិនទាន់ត្រូវបានកំណត់នៅក្នុងច្បាប់ ប្រជាពលរដ្ឋបានផ្តោតក្តីសង្ឃឹមរបស់ពួកគេ ក្នុងការទាមទារជាផ្លូវការនូវប្លង់ដីរបស់ពួកគេ និង (នៅក្នុងករណីជាច្រើន) ការការពារជីវភាពរស់នៅរបស់ពួកគេ ទៅលើដំណើរការវិនិច្ឆ័យជាផ្លូវការរបស់គម្រោង LMAP ។ ប្រជាពលរដ្ឋជាច្រើនបានអះអាងថា មានឯកសារ "សិទ្ធិកាន់កាប់ដីធ្លី" ដែលត្រូវបានបញ្ជាក់នៅកម្រិត ខណ្ឌ សង្កាត់ ឬ ភូមិ (ជាញឹកញាប់ ស្ថិតនៅក្នុងទម្រង់ជាការចុះហត្ថលេខាទៅលើការផ្ទេរសិទ្ធិទាំងនេះ) ឬការដែលសៀវភៅគ្រួសារ និងវិក្កយបត្រទឹកភ្លើងរបស់ពួកគេ បានផ្តល់ភស្តុតាងអំពីការកាន់កាប់ទៅលើដីធ្លីមុនឆ្នាំ២០០១ ដែលច្បាប់ភូមិបាលបានតម្រូវ ។ យោងតាមនីតិវិធីរបស់គម្រោង LMAP ផែនទីសុរិយោដីមួយត្រូវបានបិតផ្សាយជាសាធារណៈ (ចន្លោះពីថ្ងៃទី ០៤ ខែមករា រហូតដល់ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០០៧) ។ ការបិតផ្សាយជាសាធារណៈអំពីកំណត់ហេតុវិនិច្ឆ័យនេះ បានបង្ហាញត្រឹមតែព្រំប្រទល់ភូមិ ជាមួយនឹងម្ចាស់កម្មសិទ្ធិដែលគេសរសេរថា "មិនស្គាល់" ប៉ុណ្ណោះ ពុំមែនបង្ហាញអំពីដី ឬអចលនទ្រព្យនីមួយៗឡើយ ។

**ការបណ្តេញចេញ :** ម្ចាស់សំណើ និងប្រជាពលរដ្ឋដទៃទៀត បានចាប់ផ្តើមទទួលរងសម្ពាធ ឱ្យផ្លាស់ប្តូរទីលំនៅ និងទទួលយកជម្រើស១ ក្នុងចំណោមជម្រើសចំនួន៣ សម្រាប់ជាសំណង : ១) ថវិកាចំនួន ៨.៥០០ដុល្លាសហរដ្ឋអាមេរិក សម្រាប់ជាសំណងសរុបនៃអចលនទ្រព្យរបស់ពួកគេ ២) ការផ្លាស់ប្តូរទីលំនៅទៅរស់នៅឆ្ងាយពីកណ្តាលទីក្រុង ចម្ងាយជាង ២០គីឡូម៉ែត្រ ជាមួយនឹងថវិកា ៥០០ដុល្លាសហរដ្ឋអាមេរិក ដើម្បីគ្របដណ្តប់ទៅលើថ្លៃចំណាយសម្រាប់ការផ្លាស់ប្តូរទីលំនៅ ឬ ៣) ការសាងសង់ផ្ទះឡើងវិញនៅកន្លែងដដែល ដែលតម្រូវឱ្យប្រជាពលរដ្ឋផ្លាស់ប្តូរទីលំនៅទៅរស់នៅកន្លែងថ្មីមួយ (មានចម្ងាយជាង២០គីឡូម៉ែត្រពីទីក្រុងផងដែរ) រយៈពេល៤ឆ្នាំ ខណៈពេលដែលកន្លែងស្នាក់នៅជំនួសអចិន្ត្រៃយ៍ត្រូវបានសាងសង់នៅក្នុងតំបន់បឹងកក់ ។ សេចក្តីជូនដំណឹងជម្លៀសប្រជាជនលើកចុងក្រោយ ត្រូវបានចេញដោយសាលាក្រុងភ្នំពេញ នៅក្នុងខែមេសា ឆ្នាំ២០០៩ ។ ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ បានរៀបចំពាក្យបណ្តឹងមួយទៅកាន់ក្រុមអធិការកិច្ចសុរិយោដី ព្រមទាំង បានដាក់ពាក្យស្នើសុំអធិបញ្ញាពីតុលាការ ដើម្បីពន្យាពេលការបណ្តេញចេញរហូតដល់សេចក្តីសម្រេចចិត្តមួយត្រូវបានធ្វើឡើង ទៅលើនីត្យានុកូលភាពនៃការបណ្តេញចេញនេះ ។ តុលាការបានបដិសេធក្នុងការចេញអធិបញ្ញា ដោយបានលើកឡើងថា បញ្ហានេះហួសពីដែនសមត្ថកិច្ចរបស់ខ្លួន និងគួរត្រូវបានដោះស្រាយដោយក្រុមអធិការកិច្ចសុរិយោដីវិញ ។ មកទល់នឹងពេលបច្ចុប្បន្ននេះ គេពុំទាន់បានដឹងច្បាស់អំពីចំនួនគ្រួសារពិតប្រាកដដែលត្រូវបានបណ្តេញចេញពីតំបន់បឹងកក់នៅឡើយទេ ។

**ការចាក់បំពេញបឹង និងការលិចលង់ផ្ទះសម្បែង :** ផែនការរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន រាប់បញ្ចូលទាំងការចាក់បំពេញមួយផ្នែកធំនៃបឹងកក់ (ដែលបឹងនេះបានផ្ដល់នូវបរិស្ថានធម្មជាតិដ៏មានតម្លៃ និងជាប្រភពទ្រទ្រង់ជីវភាពរស់នៅសម្រាប់ប្រជាជនជាច្រើន) ។ នៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៨ បើទោះបីជាមានការតវ៉ាពីប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលយ៉ាងណាក្ដី ក្រុមហ៊ុនបានបន្ដបូមខ្សាច់ពីទន្លេសាបទៅក្នុងបឹងកក់ ។ បន្ដិចក្រោយមក សារព័ត៌មានក្នុងស្រុកបានចាប់ផ្ដើមរាយការណ៍អំពីករណីលិចផ្ទះរបស់ប្រជាពលរដ្ឋ និងកុមារមានជំងឺ ដែលបណ្ដាលមកពីការបំពុលនៃសកម្មភាពនេះ។ នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១០ សារព័ត៌មានបានរាយការណ៍អំពីការស្លាប់របស់បុរសអាយុ ៦១ឆ្នាំម្នាក់ ដោយសារការឆក់ចរន្តអគ្គិសនី ដែលបណ្ដាលមកពីការជន់លិចតំបន់នេះ ។ នៅពេលដែលក្រុមអធិការកិច្ចបានចុះធ្វើទស្សនកិច្ចនៅក្នុងខែឧសភា ឆ្នាំ២០១០ មានតែតំបន់លិចទឹកមួយចំនួនតូចប៉ុណ្ណោះដែលនៅសេសសល់ ។ ផ្ទះជាច្រើនខ្នងដែលនៅសេសសល់បានដួលរលំទៅក្នុងទឹក និងផ្ទះដទៃទៀតបានក្លាយទៅជាមិនអាចរស់នៅបាន ។

**លក្ខខណ្ឌនៅឯកន្លែងផ្លាស់ប្ដូរទីលំនៅ :** កិច្ចសម្ភាសន៍ដែលបានធ្វើឡើងនៅឯកន្លែងផ្លាស់ប្ដូរទីលំនៅ បានបង្ហាញឱ្យដឹងថា គ្រួសារដែលបានផ្លាស់ប្ដូរទីលំនៅជាច្រើនមានអារម្មណ៍ថា លំនៅដ្ឋានថ្មីរបស់ពួកគេនៅឆ្ងាយពីគេឯង ដែលកត្តានេះបានបណ្ដាលឱ្យមានការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរទៅលើចំណូលរបស់ពួកគេ ដែលមានកម្រិតទាបស្រាប់ទៅហើយ ។ ជាលទ្ធផល ពួកគេបានសម្រេចចិត្តលក់លំនៅដ្ឋានថ្មីរបស់ពួកគេ ក្នុងតម្លៃដែលពួកគេអាចលក់បាន និងត្រឡប់មកទីក្រុងវិញ ដែលគេអាចជួល ឬស្វែងរកកន្លែងទំនេរដទៃទៀតដើម្បីរស់នៅ ។ យើងអាចមើលឃើញនិន្នាការនេះយ៉ាងច្បាស់លាស់ តាមរយៈលេខទូរស័ព្ទដែលសរសេរនៅលើអគារលំនៅដ្ឋានជាច្រើន ។

## ការវិភាគ និងគំហើញរបស់ក្រុមអធិការកិច្ច

ជំពូកនេះ បង្ហាញអំពីការអះអាងរបស់ម្ចាស់សំណើ និងការឆ្លើយតបពីថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក ព្រមទាំងការវិភាគ និងគំហើញរបស់ក្រុមអធិការកិច្ច ថាតើបញ្ហាគ្រោះថ្នាក់ដែលបានកើតឡើង (ទាំងស្រុង ឬមួយផ្នែក) បណ្ដាលមកពីការដែលធនាគារពិភពលោក ខ្វះការអនុវត្តស្របតាមគោលនយោបាយ និងនីតិវិធីរបស់ខ្លួន ដែរឬទេ។

## ការអះអាងថាព្រឹត្តិការណ៍នៅក្នុងតំបន់បឹងកក់ មានទំនាក់ទំនងទៅនឹងគម្រោង

ម្ចាស់សំណើអះអាងថា មានទំនាក់ទំនងដោយផ្ទាល់ និងផ្លូវការមួយ រវាងព្រឹត្តិការណ៍ដែលបណ្ដាលឱ្យមាននូវការបណ្ដេញប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ពីលំនៅដ្ឋានរបស់ពួកគេ និងសកម្មភាពដែលត្រូវបានអនុវត្តក្រោមគម្រោង ។ ការផ្ទៀងផ្ទាត់ទៅលើទំនាក់ទំនងនេះ មានសារៈសំខាន់សម្រាប់ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចទៅលើការអះអាងដែលកាន់តែមានភាពជាក់លាក់ជាងនេះដទៃទៀត អំពីគ្រោះថ្នាក់ដែលត្រូវបានលើកឡើងនៅក្នុងសំណើ ។

ក្រុមអធិការកិច្ចបានធ្វើការកត់សម្គាល់ថា មានការមិនយល់ស្របគ្នាជាមូលដ្ឋានមួយ រវាងថ្នាក់គ្រប់គ្រងធនាគារពិភពលោក

និងរាជរដ្ឋាភិបាល អំពីទំនាក់ទំនងរវាងព្រឹត្តិការណ៍នៅក្នុងតំបន់បឹងកក់ និងគម្រោង LMAP ។ ទស្សនៈរបស់រដ្ឋាភិបាល គឺការបណ្តេញប្រជាពលរដ្ឋចេញពីតំបន់បឹងកក់ ពុំមែនជាបញ្ហាកង្វល់របស់គម្រោងឡើយ ។ ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកបានធ្វើការកត់សម្គាល់ថា តំបន់បឹងកក់ គឺស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ ដែលត្រូវបានប្រកាសក្រោមគម្រោង ។ ដៃគូអភិវឌ្ឍរបស់គម្រោង LMAP យល់ស្របជាមួយរដ្ឋាភិបាល និងមិនបានមើលឃើញអំពីទំនាក់ទំនងរវាងគម្រោង និងព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងតំបន់បឹងកក់ឡើយ ។

**និយមន័យនៃពាក្យថា តំបន់គម្រោង :** ក្រុមអធិការកិច្ចបានធ្វើការកត់សម្គាល់ថា យោងទៅតាមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍ និង PAD គម្រោង LMAP ត្រូវបានរៀបចំឡើងដើម្បីអនុវត្តនៅក្នុងខេត្ត-ក្រុង ចំនួន១១ រាប់បញ្ចូលទាំងក្រុងភ្នំពេញ ដែលត្រូវបានកំណត់ហៅថា "ខេត្តគម្រោងគ្របដណ្តប់" ។ តំបន់បឹងកក់ មានមូលដ្ឋានស្ថិតនៅក្នុងក្រុងភ្នំពេញ ។ ក្រុមអធិការកិច្ចបន្តកត់សម្គាល់ទៀតថា ពុំមានឯកសារយោង ឬលក្ខខណ្ឌវិនិច្ឆ័យដែលត្រូវបានអភិវឌ្ឍនៅក្នុង PAD ឬ DCA ដើម្បីដកចេញនូវតំបន់មួយចំនួនពីនិយមន័យនៃពាក្យថា "ខេត្តគម្រោងគ្រប់ដណ្តប់" ឡើយ ។

**ការប្រកាសតំបន់បឹងកក់ ថាជាតំបន់វិនិច្ឆ័យ :** សង្កាត់ស្រះចកទាំងមូល ដែលរាប់បញ្ចូលតំបន់បឹងកក់ផងដែរ ត្រូវបានប្រកាសនៅថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០០៦ ថាជាតំបន់វិនិច្ឆ័យក្រោមគម្រោង LMAP ។ ក្រុមអធិការកិច្ចបានធ្វើការកត់សម្គាល់ថា សេចក្តីជូនដំណឹងអំពីការវិនិច្ឆ័យពុំបានលើកលែងតំបន់ណាមួយនៅក្នុងសង្កាត់ស្រះចក ពីដំណើរការវិនិច្ឆ័យ ដែលត្រូវទទួលបានការគាំទ្រពីគម្រោងឡើយ ។

**យោងតាមខ្លឹមសារខាងលើ ក្រុមអធិការកិច្ចបានរកឃើញថា តំបន់បឹងកក់ ស្ថិតនៅក្នុងខេត្តគម្រោងមួយ និងត្រូវបានប្រកាសថាជាតំបន់វិនិច្ឆ័យក្រោមគម្រោង LMAP ដូច្នេះសកម្មភាពដែលទាក់ទងទៅនឹងការផ្ទៀងផ្ទាត់កម្មសិទ្ធិដីធ្លី និងកម្មសិទ្ធិភាព ក្រោយការជូនដំណឹងអំពីការវិនិច្ឆ័យ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងគម្រោងនេះ ។** ចំណុចនេះ មានសង្គតភាពទៅនឹងជំហរបស់ថ្នាក់គ្រប់គ្រង ។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដទៃទៀតដែលគាំទ្រគម្រោង LMAP បានពោលអះអាងថា តំបន់បឹងកក់ គឺជាតំបន់វិវាទ ដូច្នេះតំបន់នេះត្រូវបានដកចេញពីដំណើរការផ្តល់ប្លង់ដីដែលស្ថិតក្រោមគម្រោង LMAP ។ បញ្ហានេះមានពិភាក្សាបន្តនៅក្នុងផ្នែកខាងក្រោម ។

## ការអះអាងថាប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ត្រូវបានបដិសេធចំពោះការវិនិច្ឆ័យនៅលើការទាមទារអចលនទ្រព្យរបស់ពួកគេ ក្រោមគម្រោង

ម្ចាស់សំណើបានអះអាងថា នីតិវិធីរបស់គម្រោង LMAP មិនត្រូវបានគេអនុវត្តតាម ដូច្នេះប្រជាពលរដ្ឋត្រូវបានបដិសេធចំពោះសិទ្ធិរបស់ពួកគេក្នុងការទទួលបានការស៊ើបអង្កេត និង ការវិនិច្ឆ័យសមស្របទៅលើការទាមទារអចលនទ្រព្យរបស់ពួកគេ ។ នៅក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងក៏មានភាពស្របគ្នាទៅនឹងម្ចាស់សំណើផងដែរ ដោយបានថ្លែងថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ មិនត្រូវបានផ្តល់ឱកាសឱ្យបង្ហាញអំពីការទាមទារកម្មសិទ្ធិដីធ្លីរបស់ពួកគេ និងពុំមានភស្តុតាងដែលបញ្ជាក់អំពី ការអនុវត្តន៍ដំណើរការបែបចូលរួមប្រកបដោយតម្លាភាព ដើម្បីកំណត់ទៅលើការបែងចែកចំណាត់ថ្នាក់ដី នៅក្នុង

តំបន់នេះ ។ ដោយឡែក ថ្នាក់ដឹកនាំក៏បានទទួលស្គាល់ផងដែរថា គួរមានការត្រួតពិនិត្យទៅលើបញ្ហាកិច្ចការពារសុវត្ថិភាព និងវិធានការសង្គមដទៃទៀតឱ្យបានខ្លាំងក្លាជាងនេះ។ នៅក្នុងការឆ្លើយតបរបស់ខ្លួន ថ្នាក់គ្រប់គ្រងក៏បានគូសបញ្ជាក់អំពីសកម្មភាពដែលពួកគេគ្រោងនឹងអនុវត្ត ដើម្បីដោះស្រាយស្ថានភាពនេះ។

**ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ - ស្ថានភាពនៃការទាមទារអចលនទ្រព្យរបស់ពួកគេ :** មុនការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាននាពេលថ្មីៗនេះ មានគ្រួសារប្រមាណ ៤.២៥០គ្រួសារ ដែលរស់នៅក្នុងតំបន់បឹងកក់ ។ ដូចបានបញ្ជាក់ពីខាងដើម ប្រជាជនទាំងនេះជាច្រើនគ្រួសារគិតថា ពួកគេមានកម្មសិទ្ធិភាពក្នុងការរស់នៅតំបន់នោះ និងបានអះអាងថាពួកគេមានឯកសារ (ដែលត្រូវបានចុះហត្ថលេខាដោយមេភូមិ ឬ ចៅសង្កាត់) ដែលបញ្ជាក់អំពីការទិញដីធ្លីដែលពួកគេកំពុងរស់នៅ និងបង់ថ្លៃសេវានានា ។ ប្រជាពលរដ្ឋជាច្រើនមានកម្មសិទ្ធិ ផ្ទេរ និងបានទទួលកេរ្តិ៍មរតកដីធ្លីរបស់ពួកគេ ព្រមទាំងទទួលបាននូវភាពស្របច្បាប់នៅក្នុងសង្គមក្នុងកម្រិតមួយ និងការទទួលស្គាល់ពីអាជ្ញាធរពាក់ព័ន្ធ បើទោះបីជាពុំមានប្រព័ន្ធចងក្រងឯកសារជាផ្លូវការមួយទូទាំងប្រទេសក៏ដោយ។

ក្រុមអធិការកិច្ចបន្តធ្វើការកត់សម្គាល់ទៀតថា បើពិនិត្យមើលទៅលើទិដ្ឋភាពសំខាន់ៗ ស្ថានភាពស្របច្បាប់នៃតំបន់បឹងកក់ពុំមានភាពច្បាស់លាស់ និងកំពុងមានវិវាទ ។ មានឯកសារយោងជាច្រើន និងឯកសារយោងមួយចំនួនមានភាពត្រួតស៊ីគ្នាដែលពាក់ព័ន្ធទៅនឹងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ នៅក្នុង និងជុំវិញតំបន់បឹងកក់ និងមានប្រភេទកម្មសិទ្ធិដីធ្លីជាច្រើនផ្សេងៗគ្នា ។

យោងតាមការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ក្នុងអំឡុងពេលនៃបេសកកម្មត្រួតពិនិត្យនៅក្នុងខែមិថុនា ឆ្នាំ២០០៨ ធនាគារពិភពលោកត្រូវបានជូនដំណឹង អំពីការអះអាងរបស់សាលាក្រុងភ្នំពេញថា តំបន់បឹងកក់ គឺជា "ដីសាធារណៈរបស់រដ្ឋ" ជាលទ្ធផល គ្រួសារដែលរស់នៅក្នុងតំបន់នេះ ត្រូវបានដកចេញពីការផ្តល់ប្លង់ដី អាស្រ័យដោយក្រោមច្បាប់ភូមិបាល គេមិនអាចទទួលស្គាល់ការទាមទារឯកជន ដើម្បីទទួលបានកម្មសិទ្ធិភាពស្របច្បាប់ ទៅលើដីសាធារណៈរបស់រដ្ឋឡើយ ។ មានតែព្រំដែនភូមិប៉ុណ្ណោះដែលត្រូវបានកំណត់ព្រំប្រទល់ដោយគម្រោង LMAP ។ ការបង្ហាញជាសាធារណៈនៃកំណត់ហេតុវិនិច្ឆ័យបានបញ្ជាក់អំពីកម្មសិទ្ធិភាពនៅក្នុងតំបន់នេះថា "មិនស្គាល់" នៅលើផែនទីសុរិយោដីដែលរៀបចំដោយក្រុមអធិការកិច្ចរដ្ឋបាល ក្រោមក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)។

ផែនការអភិវឌ្ឍឯកជនទៅលើតំបន់បឹងកក់ បានប្រព្រឹត្តិទៅល្អប្រសើរ មុនពេលការប្រកាសតំបន់នេះថាជាតំបន់វិនិច្ឆ័យក្រោមគម្រោង LMAP ។ នៅក្នុងខែសីហា ឆ្នាំ២០០៥ រយៈពេល៧ខែ មុនពេលសេចក្តីប្រកាសនេះ ទីស្តីការគណៈរដ្ឋមន្ត្រីបានជូនដំណឹងដល់អភិបាលក្រុងភ្នំពេញ អំពីការឯកភាព "ជាគោលការណ៍" របស់រាជរដ្ឋាភិបាលឱ្យក្រុមហ៊ុន ស៊ូកាគូ ធ្វើការអភិវឌ្ឍន៍តំបន់បឹងកក់ ។ នៅថ្ងៃទី ៣០ ខែមករា ឆ្នាំ២០០៧ នាយករដ្ឋមន្ត្រីបានអនុញ្ញាតឱ្យអភិបាលក្រុងភ្នំពេញចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងជួលជាមួយក្រុមហ៊ុន ស៊ូកាគូ ។ កិច្ចព្រមព្រៀងជួលត្រូវបានចុះហត្ថលេខា ក្នុងរយៈពេលជិតមួយឆ្នាំក្រោយការប្រកាសថា សង្កាត់ស្រះចក គឺជាតំបន់វិនិច្ឆ័យមួយក្រោមគម្រោង LMAP និងមុនពេលបញ្ចប់ដំណើរការផ្តល់ប្លង់ដី ។ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៨ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យមួយ ដើម្បីផ្លាស់ប្តូរតំបន់បឹងកក់ពីដីសាធារណៈរបស់រដ្ឋ

មកជាដីឯកជនរបស់រដ្ឋវិញ ។

ក្រុមអធិការកិច្ចកត់សម្គាល់ថា ការជួលតំបន់បឹងកក់សម្រាប់ការអភិវឌ្ឍន៏ឯកជន និង ការបែងចែកចំណាត់ថ្នាក់តំបន់នេះឡើងវិញ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ រដ្ឋាភិបាលបានកំណត់ជាធរមានថា ដីនៅជុំវិញបឹង និងសូម្បីតែបឹង ត្រូវបាត់បង់ការប្រើប្រាស់ដើម្បីប្រយោជន៏ជាសាធារណៈ និងអាចក្លាយជាកម្មវត្ថុសម្រាប់ទាមទារជាកម្មសិទ្ធិឯកជន ។ ការកំណត់ថាដីនេះជាដីឯកជនរបស់រដ្ឋ ដែលអាចត្រូវបានពិចារណាផ្តល់ប្លង់ឯកជនសម្រាប់ដីនេះ ប្រជាពលរដ្ឋ ឬ ម្ចាស់កម្មសិទ្ធិដីធ្លីនៅក្នុងតំបន់នេះ អាចចាត់ទុកខ្លួនឯងថា មានសិទ្ធិក្នុងការទាមទារឱ្យអចលនទ្រព្យរបស់ពួកគេត្រូវបានវិនិច្ឆ័យក្រោមគម្រោង។

**ទស្សនៈរបស់ក្រុមអធិការកិច្ចយល់ឃើញថា ផ្នែកខ្លះនៃតំបន់បឹងកក់ អាចមានលក្ខខណ្ឌសមស្រប ដើម្បីពិចារណាផ្តល់ប្លង់ដីសម្រាប់កម្មសិទ្ធិភាពឯកជន ក្រោមនីតិវិធីវិនិច្ឆ័យរបស់គម្រោង LMAP ។ ក្រុមអធិការកិច្ចយល់ស្របជាមួយថ្នាក់ដឹកនាំថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ ត្រូវបានបដិសេធចំពោះលទ្ធភាពក្នុងការទទួលបានដំណើរការវិនិច្ឆ័យសមស្របមួយ ទៅលើការទាមទារអចលនទ្រព្យរបស់ពួកគេ ។ ក្រុមអធិការកិច្ចរកឃើញថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ មានភាពត្រឹមត្រូវក្នុងការរំពឹងថា ការទាមទារដីធ្លីរបស់ពួកគេមានភាពសមស្រប ដើម្បីឱ្យគេធ្វើការពិចារណាក្រោមយន្តការផ្តល់ប្លង់ដីដែលមានលក្ខណៈជាប្រព័ន្ធ និងបន្ថែមពីនេះទៀត រាល់ការទាមទារដីធ្លីទាំងអស់នៅក្នុងសង្កាត់ត្រូវវិនិច្ឆ័យដោយយោងទៅតាមនីតិវិធី និងដំណើរការវិនិច្ឆ័យទៅលើការទាមទារអចលនទ្រព្យ ដែលត្រូវបានឯកភាព រវាងរដ្ឋាភិបាល ធនាគារពិភពលោក និងដៃគូអភិវឌ្ឍដែលគាំទ្រដល់គម្រោង LMAP ។**

**ការកាត់តំបន់បឹងកក់ចេញពីគម្រោង LMAP ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង :** ក្រុមអធិការកិច្ចកត់សម្គាល់ថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) និងដៃគូអភិវឌ្ឍ បានថ្លែងទៅកាន់ក្រុមអធិការកិច្ចថា តំបន់បឹងកក់ត្រូវបានកាត់ចេញពីដំណើរការវិនិច្ឆ័យ អាស្រ័យដោយស្ថានភាពវិវាទនៃតំបន់នេះ ហើយប្លង់ដី រាប់បញ្ចូលទាំងប្លង់ដីដែលជាកម្មសិទ្ធិរបស់រដ្ឋផងដែរ មិនត្រូវបានផ្តល់ឡើយ ។ ម្ចាស់សំណើ និងអង្គការមិនមែនរដ្ឋាភិបាល អះអាងថា ការដកចេញនូវតំបន់ " វិវាទ" ឬ "មិនច្បាស់លាស់" ពីការផ្តល់ប្លង់ដីដែលមានលក្ខណៈជាប្រព័ន្ធអនុញ្ញាតឱ្យអាជ្ញាធរខេត្ត ឬអាជ្ញាធរក្រុងដែលទទួលបន្ទុកជ្រើសរើសតំបន់វិនិច្ឆ័យ កាត់តំបន់ណាដែលអ្នកមានអំណាច និងអ្នកវិនិយោគបរទេសស្វែងរក (ចង់បាន) ។

មានឯកសារយោងចំនួន២ នៅក្នុង PAD អំពីស្ថានភាពដែលប្លង់ដីអាចមិនត្រូវបានគេផ្តល់ជូន ទី១ ពាក់ព័ន្ធទៅនឹងដីវិវាទ និងទី២ ពាក់ព័ន្ធទៅនឹងការតាំងទីលំនៅមិនផ្លូវការ ។ សំនួរពាក់ព័ន្ធមួយ មានទាក់ទងទៅនឹងដំណើរការបែងចែកចំណាត់ថ្នាក់ដី និងការឈានទៅសម្រេចឱ្យបាននូវការឯកភាពគ្នាក្នុងចំណោមភ្នាក់ងាររដ្ឋ ដែលត្រូវបានកំណត់រកឃើញពីក្នុងចំណោមហានិភ័យចម្បង៧របស់គម្រោង LMAP ។ ចំណុចខាងក្រោមសង្ខេបអំពីការវិភាគរបស់ក្រុមអធិការកិច្ចទៅលើអភិក្រមរបស់គម្រោងចំពោះបញ្ហាដីវិវាទ ការតាំងទីលំនៅមិនផ្លូវការ និងការគ្រប់គ្រងដីរដ្ឋ ។

*វិធីសាស្ត្ររបស់គម្រោង ចំពោះបញ្ហាដីវិវាទ :* ក្រុមអធិការកិច្ចកត់សម្គាល់ថា ពុំមានឯកសារយោងនៅក្នុង PAD ឬ DAC សម្រាប់ការសម្រេចចិត្តជាយុទ្ធសាស្ត្រមួយ ដើម្បីជៀសវាងករណីដីវិវាទ។ ដោយឡែក ក្រុមអធិការកិច្ចបានអានសេចក្តីផ្តើម

របស់ PAD ដែលសង្កត់ធ្ងន់ទៅលើសេចក្តីត្រូវការកាត់បន្ថយកម្រិតនៃទំនាស់ដីធ្លី តាមរយៈការវិនិច្ឆ័យ និងការដោះស្រាយវិវាទ។ ក្រុមអធិការកិច្ចក៏បានកត់សម្គាល់ផងដែរថា ពុំមានការកំណត់និយមន័យអំពីពាក្យថា "ដីវិវាទ" នៅក្នុង PAD, DCA ឬឯកសារគម្រោងដទៃទៀតឡើយ។ ស្រដៀងគ្នានេះដែរ តំបន់ដែល "មានស្ថានភាពមិនច្បាស់លាស់" ក៏ពុំមានកំណត់និយមន័យ នៅក្នុង PAD, DCA ឬឯកសារគម្រោងដទៃទៀតដែរ។

ផ្នែកដែលនិយាយអំពី "ទិដ្ឋភាពចម្រូងចម្រាសដែលអាចកើតឡើង" នៃ PAD ចែងថា *"គម្រោងនឹងមិនផ្តល់ប្លង់ដីនៅក្នុងតំបន់ដែលទំនងនឹងមានវិវាទឡើយ រហូតដល់មានការឯកភាពទៅលើស្ថានភាពនៃដីនោះ"*។ បើទោះបីពុំមានភាពច្បាស់លាស់ក្តី សេចក្តីថ្លែងនេះដែលមាននៅក្នុង PAD ហាក់មានសង្គតភាពទៅនឹងការរៀបចំទូទៅនៃគម្រោង និងវិធីសាស្ត្ររបស់គម្រោង ចំពោះដីវិវាទ មានន័យថាការផ្តល់ប្លង់ដីក្រោមគម្រោង គឺអាស្រ័យទៅលើការដោះស្រាវិវាទដោយជោគជ័យ។ បន្ថែមពីនេះ ដោយពិចារណាឃើញថាដំណើរការកំណត់ព្រំប្រទល់ រវាងដីសាធារណៈ និង ដីឯកជន មិនរមែងតែងមានភាពរលូនឡើយ ដូច្នេះ គម្រោងបានស្រមៃគិតថានឹងជម្រុញឱ្យមានការចូលរួមពីដំណើរការពិគ្រោះយោបល់សាធារណៈដែលមានលក្ខណៈជាប្រព័ន្ធ។

បើទោះជាដូច្នេះក្តី ការបកស្រាយប្រយោគនេះនៅក្នុង PAD ហាក់មានការផ្លាស់ប្តូនៅពេលអនុវត្តគម្រោង។ ការបកស្រាយបច្ចុប្បន្ន ដែលពង្រឹងបន្ថែមដោយគោលដៅអនុវត្តគម្រោងក្នុងការផ្តល់ប្លង់ដីចំនួន១លានប្លង់ គឺគម្រោងនឹងមិនផ្តល់ប្លង់ដីនៅក្នុងតំបន់ដែលទំនងនឹងមានវិវាទ ។ ទស្សនៈនេះហាក់ត្រូវបានចែករំលែកយ៉ាងទូលំទូលាយ ក្នុងចំណោម មន្ត្រីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ បុគ្គលិកគម្រោង និងទីប្រឹក្សា ។ នៅក្នុងជំនួបប្រជុំជាមួយក្រុមអធិការកិច្ច ចំណុចនេះត្រូវបានគេសំដៅប្រៀបធៀបថា "ការបេះផ្លែឈើដែលនៅជិតដៃ" ។

**ក្រុមអធិការកិច្ចបានធ្វើការកត់សម្គាល់ថា អនុក្រឹត្យលេខ៤៦ និងនីតិវិធីវិនិច្ឆ័យដែលត្រូវបានអភិវឌ្ឍក្រោមគម្រោង LMAP ពុំបានបញ្ចូលបទប្បញ្ញត្តិណាមួយដើម្បីកាត់ផ្នែកមួយចំនួននៃតំបន់ ដែលត្រូវបានប្រកាសថាជាតំបន់វិនិច្ឆ័យឡើយ នៅពេលដែលដំណើរការបានចាប់ផ្តើមស្របច្បាប់ ។ ក្រុមអធិការកិច្ចក៏បានកត់សម្គាល់ផងដែរថា ពុំមានឯកសារយោងនៅក្នុងឯកសារគម្រោងសំខាន់ៗណាមួយ អំពីគោលការណ៍សម្រាប់កំណត់ទៅលើ "តំបន់ដែលទំនងនឹងមានវិវាទ" ឬនីតិវិធីអំពីរបៀបកាត់តំបន់បែបនេះ ពីការផ្តល់ប្លង់ដីដែលមានលក្ខណៈជាប្រព័ន្ធឡើយ។**

*វិធីសាស្ត្ររបស់គម្រោងចំពោះការតាំងទីលំនៅមិនផ្លូវការ :* ឯកសារយោងទី២ ចំពោះស្ថានភាពដែលប្លង់ដីអាចមិនត្រូវបានផ្តល់ជូន ត្រូវបានរកឃើញនៅក្នុងកឋាខណ្ឌមួយ នៃឯកសារ PAD ដែលមានចំណងជើងថា "អ្នកតាំងទីលំនៅមិនផ្លូវការ" ដែលបញ្ជាក់អំពីវិធីសាស្ត្ររបស់គម្រោងនៅក្នុងស្ថានភាពដែលមាន "*អ្នកតាំងទីលំនៅមិនផ្លូវការ រាប់បញ្ចូលអ្នកតាំងទីលំនៅលើដីទំនេរ* " ។ នៅក្នុងស្ថានភាពទាំងនេះ គម្រោង "***នឹងមិនផ្តល់ប្លង់ដីឡើយ*** *ក្នុងករណីដែលពុំមានកិច្ចព្រមព្រៀងក្នុងការវិភាជន៍ដីធ្លីទៅឱ្យអ្នកតាំងទីលំនៅមិនផ្លូវការ ឬតាមរយៈការចែករំលែកដីធ្លី និង/ឬ កម្មវិធីប្តូរទីតាំងលំនៅដ្ឋាន* (បញ្ជាក់នៅក្នុងឯកសារប្រភពដើម) " ។ ក្រុមអធិការកិច្ចយល់ថា PAD សំដៅចំពោះជនដែលកាន់កាប់ដីសាធារណៈរបស់រដ្ឋ ថាជាជនដែលពុំមានគុណវុឌ្ឍសម្រាប់ការផ្តល់ប្លង់ដីក្រោមច្បាប់ភូមិបាល ឆ្នាំ២០០១ ។ និយាយដោយឡែក គម្រោងមិនត្រូវបាន

គេមើលឃើញថាជាកម្មវិធីមួយ សម្រាប់ផ្ដល់ភាពអចិន្ត្រៃយ៍ជូនដល់ការតាំងទីលំនៅមិនផ្លូវការនៅលើដីសាធារណៈរបស់រដ្ឋឡើយ ។ ការផ្ដល់ប្លង់ដីនៅក្នុងតំបន់បែបនេះ អាចធ្វើទៅបាន លុះត្រាណាតែរដ្ឋាភិបាលបានជ្រើសរើសពីដំបូងដើម្បីផ្ដល់ដីជូនដល់អ្នកតាំងទីលំនៅមិនផ្លូវការ និងបានចាត់វិធានការដើម្បីផ្ដល់ភាពស្របច្បាប់ទៅលើការកាន់កាប់ដីធ្លីរបស់ពួកគេ ។

**នៅក្នុង PAD ឬកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា សេចក្ដីសម្រេចមិនគាំទ្រដល់ការផ្ដល់ភាពអចិន្ត្រៃយ៍ចំពោះការតាំងទីលំនៅមិនផ្លូវការក្រោមគម្រោង ពុំមានកំណត់និយមន័យផ្លូវការមួយ ទៅលើពាក្យថា "អ្នកតាំងទីលំនៅមិនផ្លូវការ " "ការតាំងទីលំនៅមិនផ្លូវការ " ឬ "ការតាំងទីលំនៅលើដីទំនេរ" ឡើយ ។ ក្រុមអធិការកិច្ចយល់ឃើញថា គោលបំណងបឋមរបស់គម្រោង (ក្នុងករណីអវត្តមានការបែងចែកចំណាត់ថ្នាក់ព្រំប្រទល់ដីច្បាស់លាស់) គឺដើម្បីកំណត់ទៅលើនីត្យានុកូលភាពនៃការទាមទារដីធ្លី រាប់បញ្ចូលការទាមទារដីធ្លីដោយប្រជាពលរដ្ឋ ដែលមើលទៅហាក់បីដូចជាកំពុងកាន់កាប់ដីដោយខុសច្បាប់ តាមរយៈដំណើរការវិនិច្ឆ័យមួយ ។**

PAD រួមមានឯកសារយោងមួយចំពោះកម្មវិធីរបស់ UNCHS/UNDP និងដៃគូអភិវឌ្ឍដទៃទៀត ដើម្បីផ្ដល់សន្តិសុខកម្មសិទ្ធិដីធ្លីនៅក្នុងការតាំងទីលំនៅមិនផ្លូវការ ។ ឯកសារយោងនោះ ទទួលស្គាល់ថា "*ធនាគារពិភពលោក ឬក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និង សំណង់ មិនមានឧត្តមភាពប្រៀបធៀបក្នុងការដោះស្រាយជាមួយអ្នកតាំងទីលំនៅ មិនផ្លូវការ និងអ្នកតាំងទីលំនៅលើដីទំនេរឡើយ ។ ដូច្នេះ គម្រោងគួរគាំទ្រដល់ការអភិវឌ្ឍន៍ក្រុមដែលបច្ចុប្បន្នកំពុងធ្វើការងារនៅក្នុងវិស័យនេះ*"។ **បើទោះបីជាមានការថ្លែងនៅក្នុងឯកសារ PAD ឱ្យធ្វើការសម្របសម្រួលជិតស្និទ្ធជាមួយ កម្មវិធីរបស់ UNCHS/UNDP ដែលធ្វើការងារដោះស្រាយបញ្ហាអ្នកតាំងទីលំនៅមិនផ្លូវការ និងអ្នកតាំងទីលំនៅលើដីទំនេរ ក្រុមអធិការកិច្ចមិនអាចទទួលបានភស្តុតាងនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់ខ្លួនថា គម្រោងបានផ្ដល់ការសម្របសម្រួល ឬកិច្ចគាំទ្របែបនេះ ជូនដល់កម្មវិធី UNCHS/UNDP មុនពេលកម្មវិធីនេះបានបញ្ចប់នៅក្នុងឆ្នាំ២០០៤ ឡើយ ហើយក៏ពុំមានភស្តុតាងណាមួយដែលទទួលបានអំពីការផ្លាស់ប្ដូរវិធីសាស្ត្រចំពោះការតាំងទីលំនៅមិនផ្លូវការ ក្រោយកាលបរិច្ឆេទនេះផងដែរ ។**

*វិធីសាស្ត្ររបស់គម្រោងចំពោះការគ្រប់គ្រងដីរដ្ឋ :* ដោយសារតែដីប្រមាណជា ៨០ ភាគរយនៅក្នុងប្រទេសកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ដោយគ្មានការកំណត់ព្រំប្រទល់ច្បាស់លាស់ រវាងតំបន់ដីសាធារណៈ និងដីឯកជន ការគ្រប់គ្រងរបស់រដ្ឋ គឺជាសមាសធាតុដ៏សំខាន់មួយនៃគម្រោង LMAP ។ ទោះបីជាយ៉ាងណាក៏ដោយ ការវិវត្តនៅតែមានកម្រិតនៅឡើយចំពោះការអនុវត្តសមាសធាតុនេះ ដោយសកម្មភាពនេះត្រូវបានកំណត់ថា "មិនទទួលបានលទ្ធផលគួរជាទី ពេញចិត្ត" ហើយភាពច្រើននៃសកម្មភាពដែលមិនបានអនុវត្ត ត្រូវបានស្នើឡើងឱ្យមានការលុបចោលវិញ នៅខែមករា ឆ្នាំ ២០០៩ ។

ការគ្រប់គ្រង បានកំណត់បញ្ហាអភិបាលកិច្ច និងការលំបាកនៃការសម្រេចបានការព្រមព្រៀងរវាងទីភ្នាក់ងារនានារបស់រដ្ឋាភិបាល ព្រមទាំងក្នុងចំណោមបណ្ដាភាគីពាក់ព័ន្ធផ្សេងទៀតលើដំណើរការបែងចែកចំណាច់ថ្នាក់ធ្លី ក្នុងចំណោមហានិភ័យសំខាន់ៗនៃគម្រោង LMAP ។ PAD បានបញ្ជាក់ថា ហានិភ័យនៃការមិនចុះសម្រុងគ្នាក្នុងអំឡុងពេលដំណើរការ បែងចែកចំណាត់ថ្នាក់ដីអាចលុបបំបាត់បាន តាមរយៈការគាំទ្រដល់ដំណើរការពិគ្រោះយោបល់មួយ ដើម្បីបង្កើតឱ្យមានការយល់ដឹង

ក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល ។ ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង បានកត់សម្គាល់ថា *"ការវិភាគលម្អិតជាងនេះមួយលើបរិបទសេដ្ឋកិច្ចនយោបាយ ទំនងជានឹងបានកំណត់ទស្សនទនេះ ថាមានលក្ខណៈសុទិដ្ឋិនិយមពេក ....."* ។ បេសកកម្មជត្រួតពិនិត្យឡើងវិញសម្រាប់លើកម្ពស់គម្រោង (ERM) បានកត់សម្គាល់ឃើញថា មិនមានការកំណត់ផែនទីផ្លូវការចំពោះដីរដ្ឋ និងបានបញ្ជាក់ថា *"បញ្ហានេះគឺជាប្រភពពិតប្រាកដមួយនៃកង្វល់សម្រាប់បញ្ហាទាំងឡាយដែលស្ថិតនៅក្រោមការគំរាមកំហែងនៃការបណ្តេញចេញ ដោយសារគ្មានផែនទីទាំងនេះ អាជ្ញាធរក្រុងពាក់ព័ន្ធ អាចដកចេញពីការចេញប័ណ្ណកម្មសិទ្ធិចំពោះចំណែកដីណាមួយដែលត្រូវបានវាស់វែង និងស្នើឱ្យមានការវិនិច្ឆ័យពីក្រុមការងារសុរិយោដី ហើយបន្ទាប់មកទើបផ្តល់ប័ណ្ណកម្មសិទ្ធិដល់ដីនោះ ដោយច្បាស់លាស់ក្នុងនាមរដ្ឋ"* ។ ERM បានរកឃើញថា អនុវត្តមាននៃការកំណត់ផែនទីដីរដ្ឋ គឺជាកំហុសមួយយ៉ាងធ្ងន់ធ្ងរសម្រាប់គម្រោង LMAP ក្នុងការជួយដោះស្រាយវិវាទដីធ្លី និងការបង្កើតឱ្យមានសុវត្ថភាពនៃការកាន់កាប់ដីធ្លីដោយជោគជ័យ ។

**ក្រុមអធិការកិច្ចយល់ស្របនឹងគំហើញរបស់ ERM ដែលរកឃើញថា កង្វះនៃការកំណត់ផែនទីសុរិយោដីរបស់រដ្ឋ បានរួមចំណែកបង្កើតឱ្យមានការកំណត់ដីតាមភាពជាក់លាក់ចំពោះដីរបស់រដ្ឋ (ទាំងដីសាធារណៈ និងដីឯកជន) ដោយមិនបានអនុវត្តដំណើរការវិនិច្ឆ័យរបស់គម្រោង LMAP ឡើយ ។**

**គំហើញរបស់ក្រុមអធិការកិច្ចលើភាពអនុលោម ។** ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចផ្តើតសំខាន់លើថាតើភាពខ្សោយនៅក្នុងការរៀបចំគម្រោង (និងកង្វះនៃភាពអនុលោមជាមួយនឹង OMS 2.20 ស្តីពីការវាយតម្លៃគម្រោង) និងការត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រង (និងកង្វះនៃភាពអនុលោមជាមួយនឹង OP/BP 13.05) បានចូលរួមចំណែកចំពោះស្ថានភាពដែលប្រជាពលរដ្ឋដែលមានមានមូលដ្ឋាននៅក្នុងតំបន់បឹងកក់ (BKL) ត្រូវបានបដិសេធមិនឱ្យទទួលបានដំណើរការវិនិច្ឆ័យដ៏ត្រឹមត្រូវមួយចំពោះការទាមទារសិទ្ធិកាន់កាប់របស់ពួកគេឬយ៉ាងណា ។

*ការរៀបចំ និងការវាយតម្លៃគម្រោង ។* ការវិភាគហានិភ័យដែលមាននៅក្នុង PAD កំណត់នូវហានិភ័យទូទៅថាមានលក្ខណៈ *"ធំគួសម"* ។ ហានិភ័យដែល *"រដ្ឋាភិបាលខ្វះការប្តេជ្ញាចិត្តក្នុងការធានាឱ្យយន្តការដោះស្រាយវិវាទអាចដំណើរការទៅបានយ៉ាងមានប្រសិទ្ធភាព និងយុត្តិធម៌"* និងថា *"អង្គភាពរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀត មិនអាចសម្រេចបានការព្រមព្រៀងលើដំណើរការនៃការបែងចែកចំណាត់ថ្នាក់ដី"* ត្រូវបានកំណត់ថាមានលក្ខណៈ *"ធំគួសម"* ។

ការវាយតម្លៃទិដ្ឋភាពសង្គមដែលត្រូវបានរៀបចំឡើងសម្រាប់គម្រោង បានកត់សម្គាល់នូវការលំបាកថា ប្រជាជនសាមញ្ញបានប្រឈមមុខនឹងការពារខ្លួនរបស់ពួកគេដោយជោគជ័យប្រឆាំងនឹងភាគីមានអំណាច ដោយប្រើប្រាស់យន្តការដោះស្រាយវិវាទផ្លូវការ ។

ក្រុមអធិការកិច្ចយល់ឃើញថា ការរៀបចំគម្រោងទទួលស្គាល់ថាមានបញ្ហាប្រឈមទាំងនេះ តាមរបៀបនៃអភិក្រមដែលមានធ្វើសមាហរណកម្មមួយ ដែលពាក់ព័ន្ធនឹងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាលក្ខណៈប្រព័ន្ធ ការដោះស្រាយវិវាទ និងការបែងចែកចំណាត់ថ្នាក់ និងការគ្រប់គ្រងដីរបស់រដ្ឋ ។ ទោះបជាយ៉ាងណាក៏ដោយ ការរៀបចំគម្រោងមិនបានកំណត់ច្បាស់លាស់អំពី

របៀបដែលអ្នកខ្ចី និងថ្នាក់គ្រប់គ្រង មានបំណងចង់ដោះស្រាយហានិភ័យទាំងនេះដែលពាក់ព័ន្ធជាមួយនឹងការរៀបចំគម្រោងថាយ៉ាងណានោះឡើយ ។ បញ្ហាមួយមានការពាក់ព័ន្ធជាពិសេសចំពោះការទាមទាររបស់ម្ចាស់សំណើ ដូចជា ហានិភ័យពាក់ព័ន្ធជាមួយនឹងការអះអាងជាន់គ្នាចំពោះដី ដោយស្ថាប័នសាធារណៈ និងបុគ្គល ។ **ក្រុមអធិការកិច្ចបានរកឃើញថា ការរៀបចំគម្រោងមិនបានកំណត់ច្បាស់លាស់ថាតើគឺជាយុទ្ធសាស្ត្ររបស់គម្រោង ពាក់ព័ន្ធនឹងការកំណត់តំបន់សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិជាលក្ខណៈប្រព័ន្ធ (ឧ. តំបន់វិនិច្ឆ័យ) និងការដោះស្រាយវិវាទរវាងស្ថាប័នរដ្ឋ និងបុគ្គលឯកជន ក្នុងអំឡុងពេលអនុវត្តដំណើរការវិនិច្ឆ័យ ។**

សេចក្តីថ្លែងការណ៍នៅក្នុង PAD ពាក់ព័ន្ធទៅនឹងដីដែលមានវិវាទ ដោយគ្មាននិយមន័យនៃពាក្យណាមួយ និងដំណើរការដែលត្រូវអនុវត្តនីនោះ បាននាំមកនូវការសន្និដ្ឋានដ៏សំខាន់មួយក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗ ក្នុងអំឡុងរយៈពេលនៃការអនុវត្តនីគម្រោង ។ ម្យ៉ាងវិញទៀត បើទោះបីជា គេបានដឹងថា ព្រំប្រទល់នៃដីសាធារណៈរបស់រដ្ឋ មិនទាន់មានភាពច្បាស់លាស់ក៏ដោយ ការរៀបចំគម្រោងមិនបានដាក់បញ្ចូលនូវអ្នកតាំងទីលំនៅមិនផ្លូវការ ឬអ្នកតាំងទីលំនៅលើដីទំនេរពីការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី លើកលែងតែមានការឯកភាពពីរដ្ឋាភិបាល ។

**ក្រុមអធិការកិច្ចបានរកឃើញថា ភាពមិនច្បាស់លាស់ទាំងនេះដែលមាននៅក្នុងការរៀបចំគម្រោង បានចូលរួមចំណែកមួយផ្នែកចំពោះគ្រោះថ្នាក់ដែលម្ចាស់សំណើកំពុងប្រឈមមុខ ។ ជាលទ្ធផល ក្រុមអធិការកិច្ចបានរកឃើញថា បើទោះបីជាហានិភ័យដែលពាក់ព័ន្ធនឹងគម្រោង មិនត្រូវបានកំណត់ដោយត្រឹមត្រូវក៏ដោយ ថ្នាក់គ្រប់គ្រងមិនបានអនុវត្តតាម OMS 2.02 ស្តីពីការវាយតម្លៃគម្រោងទាក់ទិននឹងការដោះស្រាយហានិភ័យទាំងនេះឡើយ ។**

*ការត្រួតពិនិត្យ :* ក្នុងអំឡុងរយៈពេលបីឆ្នាំដំបូងនៃការអនុវត្តនីគម្រោង ពីឆ្នាំ២០០២ ដល់ពាក់កណ្តាលឆ្នាំ២០០៥ របាយការណ៍ត្រួតពិនិត្យបានបង្ហាញឱ្យឃើញថា ការអនុវត្តគម្រោង បានដំណើរការទៅមុខយ៉ាងយឺត ហើយបើទោះបីជាបញ្ហាបានចាប់ផ្តើមកើតឡើងនៅក្នុងផ្នែកមួយចំនួននៃគម្រោងក៏ដោយ ដូចជា ការដោះស្រាយវិវាទ និងការរៀបចំផែនទីដីរដ្ឋ ការកំណត់គម្រោងជាទូទៅ គឺ *"គួរជាទីពេញចិត្ត"* ។ ក៏ប៉ុន្តែ ក្រោយពាក់កណ្តាលឆ្នាំ២០០៥ ការអនុវត្តផ្នែកផ្សេងៗនៃគម្រោងបានក្លាយជាមិនស៊ីសង្វាក់គ្នាទាំងស្រុង ។ ការពិនិត្យមើលឡើងវិញដោយឯករាជ្យមួយដែលត្រូវបានធ្វើឡើងនៅខែមករា ឆ្នាំ២០០៦ បានកត់សម្គាល់ឃើញថា មានបញ្ហាជាច្រើនជាមួយនឹងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងគម្រោង LMAP ។ យោងតាមការពិនិត្យមើលឡើងវិញនេះ *"យ៉ាងហោចណាស់មួយភាគប្រាំនៃគ្រួសារទាំងនេះ (១៩,៦%) ក្នុងតំបន់ចំនួន ១៣ នៃតំបន់វិនិច្ឆ័យទាំងអស់ ដែលបានចុះពិនិត្យ កំពុងទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាលក្ខណៈប្រព័ន្ធ ដែលជារឿយៗ ដោយសារការមិនព្រមចុះបញ្ជីដីធ្លីដែលបានកាន់កាប់ ឬប្រើប្រាស់ជាលក្ខណៈគ្រួសារ"* ។ បន្ទាប់ពីការផ្អាកការអនុវត្តគម្រោងពីខែមិថុនា ឆ្នាំ២០០៦ ដល់ខែកុម្ភៈ ឆ្នាំ២០០៧ បេសកកម្មត្រួតពិនិត្យលើកទី៩ (ពីថ្ងៃទី៣០ ខែឧសភាដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧) បានកត់សម្គាល់ឃើញថា មានការផ្តោតការយល់ចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់ថ្នាក់គ្រប់គ្រង *"លើចំនួនកំណត់មួយនៃសមាសធាតុស្នូល "ចម្បង" នៃគម្រោង"* ហើយមាន *"កង្វះការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់ថ្នាក់គ្រប់គ្រង ចំពោះការទទួលស្គាល់ និងការដោះស្រាយ"* បញ្ហាដែលត្រូវបានកំណត់ប្រកបដោយ

សង្គតិភាព ក្នុងពេលអនុវត្តគម្រោង ។ បេសកកម្មនេះ បានសង្កត់ធ្ងន់ថា ការអនុវត្តគម្រោង LMAP ជាប្រព័ន្ធសមាហរណកម្មដ៏ស្មុគស្មាញមួយ ដែលក្នុងនោះ ផ្នែកទាំងអស់ ត្រូវតែ *"មានប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ដែលដូច្នេះហើយផ្នែកទាំងអស់នេះ គឺជាស្នូល"* ។

**ក្រុមអធិការកិច្ចបានរកឃើញថា ការត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រងទៅលើគម្រោងសម្រាប់រយៈពេលច្រើនឆ្នាំ បានមើលរំលងបញ្ហាសំខាន់ៗនៃវិនិច្ឆ័យលើការទាមទាររបស់ឯកជនលើដីដែលបានទាមទារដោយរដ្ឋ ។ ជាទស្សនៈរបស់ក្រុមអធិការកិច្ច ការមើលរំលងទៅលើបញ្ហាសំខាន់ៗនេះរបស់ថ្នាក់គ្រប់គ្រង បានចូលរួមចំណែកដល់ការកើតឡើងនៃព្រឹត្តិការណ៍នៅក្នុងតំបន់បឹងកក់ និងខូចប្រយោជន៍ដែលម្ចាស់សំណើកំពុងប្រឈមមុខ ។ ការត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រងទៅលើបញ្ហាសំខាន់នេះ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃ OP/BP 13.05 ឡើយ ។**

ឃុំស្រះចកត្រូវបានប្រកាសជាតំបន់វិនិច្ឆ័យមួយនៅខែមីនា ឆ្នាំ២០០៦ ក្នុងពេលដែលគម្រោងបានផ្អាកជាបណ្ដោះអាសន្ន ។ បន្ទាប់ពីគម្រោងបានបើកដំណើរការអនុវត្តន៍វិញនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៧ ក្រុមបេសកកម្មត្រួតពិនិត្យមួយបានចុះធ្វើទស្សនកិច្ចតំបន់បឹងកក់ (ឃុំស្រះចក) នៅខែមិថុនា ឆ្នាំ២០០៨ ។ ក្នុងអំឡុងពេលចុះធ្វើបេសកកម្មនេះ ការិយាល័យគ្រប់គ្រងគម្រោងបានជូនដំណឹងដល់ធនាគារ និងដៃគូអភិវឌ្ឍន៍នានាថា តំបន់បឹងកក់គឺជាដីសាធារណៈរបស់រដ្ឋ ដូច្នេះហើយ ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នេះ មិនមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិឡើយ ។ ក្រុមអធិការកិច្ចកត់សម្គាល់ឃើញថា ថ្នាក់គ្រប់គ្រងមិនបានយល់ដឹងអំពីដំណើរការសម្រាប់ការកំណត់តំបន់វិនិច្ឆ័យឡើយ សូម្បីតែនៅក្នុងរាជធានីភ្នំពេញផងដែរ ។ ក្រុមអធិការកិច្ចក៏បានកត់សម្គាល់ផងដែរថា ថ្នាក់គ្រប់គ្រងមិនបានលើកឡើងនូវកង្វល់ណាមួយជាមួយនឹងអាជ្ញាធររដ្ឋាភិបាលឡើយ ពាក់ព័ន្ធនឹងរបៀបដែលត្រូវដំណើរការដោះស្រាយវិវាទដីវិញតំបន់បឹងកក់ ហើយក៏មិនបានលើកឡើងនូវកង្វល់អំពីការអនុវត្តក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញផងដែរ ។

**ក្រុមអធិការកិច្ចបានរកឃើញថា ថ្នាក់គ្រប់គ្រងខកខានមិនបានចាត់វិធានការតាមការជូនដំណឹងនៅពេលដែលបញ្ហាកើតឡើងនៅក្នុងតំបន់បឹងកក់ ត្រូវបានជម្រាបឱ្យដឹងភ្លាមជាលើកដំបូង និងថា ការត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រងទៅលើបញ្ហានេះ មិនមានសង្គតិភាពជាមួយនឹងលក្ខខណ្ឌតម្រូវនៃ OP/BP 13.05 ។**

គិតចាប់ពីដើមឆ្នាំ២០០៩ នៅពេលមានពាក្យចចាមអារាមថា អាចនឹងមានសំណើដាក់ជូនទៅក្រុមអធិការកិច្ច ធនាគារបានព្យាយាមយ៉ាងខ្លាំងដើម្បីសុំឱ្យរដ្ឋាភិបាលចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងមួយដើម្បីពិនិត្យមើលករណីបឹងកក់ឡើងវិញ ។ ចាប់ពីថ្ងៃទី៣០ ខែមីនា ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៩ ថ្នាក់គ្រប់គ្រងបានបញ្ជូនក្រុមបេសកកម្មការត្រួតពិនិត្យឡើងវិញសម្រាប់លើកកម្ពស់គម្រោង (ERM) សម្រាប់គម្រោងនេះ ។ របាយការណ៍របស់ ERM បានអំពាវនាវឱ្យមានការផ្អាកជាបណ្ដោះអាសន្នសិនចំពោះការបណ្ដេញប្រជាជនចេញនេះ ។ ធនាគារក៏បានដឹកនាំការរៀបចំ និងការចេញសេចក្ដីថ្លែងការណ៍មួយរួមជាមួយនឹងម្ចាស់ជំនួយ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ។

**ក្រុមអធិការកិច្ចបានរកឃើញថា ការត្រួតពិនិត្យនាពេលថ្មីៗនេះរបស់ថ្នាក់គ្រប់គ្រងទៅលើគម្រោង ចំពោះបញ្ហាដែលបានលើកឡើងដោយសំណើ ស្របតាមគោលនយោបាយរបស់ធនាគារស្តីពីការត្រួតពិនិត្យគម្រោង OP/BP 13.05 ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមអធិការកិច្ចបានយល់ស្របជាមួយនឹងការវាយតម្លៃរបស់ម្ចាស់សំណើដែលថា *"មានភស្តុតាងបញ្ជាក់ថា ចំណាត់ការដែលបានធ្វើឡើងដោយថ្នាក់គ្រប់គ្រងរបស់ធនាគារ គឺយឺតយ៉ាវពេកក្នុងការបញ្ចៀសការខូចប្រយោជន៍ដែលពេលនេះកំពុងត្រូវបានធ្វើឡើង"* ។**

## ការអះអាងថាប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ត្រូវបានជម្លៀសដោយរំលោភបំពាន នៅលើគោលនយោបាយដែលបានឯកភាពគ្នាសម្រាប់ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត

ម្ចាស់សំណើបានបញ្ជាក់ថា ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ (RPF) មិនត្រូវបានអនុវត្តនៅក្នុងតំបន់បឹងកក់ឡើយ ដែលជាការរំលោភលើ DAC ដែលបណ្តាលឱ្យមានការខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរចំពោះប្រជាពលរដ្ឋដែលបានបណ្តេញចេញពីដីនេះ ។ ម្ចាស់សំណើបានអះអាងថា កាលៈទេសៈដែលនៅពីក្រោយការបណ្តេញប្រជាពលរដ្ឋចេញ និងលក្ខខណ្ឌនៃតំបន់តាំងទីលំនៅឡើងវិញ មិនមានលក្ខណៈស្តង់ដារដែលបាន ចែងនៅក្នុងគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅឡើងវិញឡើយ ។ ថ្នាក់គ្រប់គ្រងយល់ស្របជាមួយនឹងម្ចាស់សំណើថា ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ គប្បីត្រូវបានអនុវត្តចំពោះការបណ្តេញប្រជាពលរដ្ឋចេញ ដែលបានកើតឡើងនៅក្នុងឃុំស្រះចក ។

**វិសាលភាពនៃក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ ។** ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ (RPF) បានកំណត់នូវស្ថានភាពចំនួនបី នៅពេលដែលប្រជាជនអាចទទួលរងការប៉ះពាល់ជាអវិជ្ជមាន ហើយក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ (RPF) នឹងត្រូវបានយកមកអនុវត្ត ដូច្នេះ ទាមទារឱ្យមានការរៀបចំផែនការតាំងទីលំនៅឡើងវិញជាក់លាក់មួយសម្រាប់:

- ការបណ្តេញប្រជាជនចេញពីដីរដ្ឋចំពោះបុគ្គលដែលបានកាន់កាប់ដីនោះតាំងពីមុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ (កាលបរិច្ឆេទអនុម័តច្បាប់ភូមិបាលថ្មី) បន្ទាប់ពីការផ្តល់ប័ណ្ណកម្មសិទ្ធិដល់ដីនេះ ក្នុងនាមរដ្ឋាភិបាល ។
- ការបណ្តេញប្រជាជនចេញពីដីរដ្ឋ (ប័ណ្ណកម្មសិទ្ធិក្នុងនាមរដ្ឋាភិបាល) ចំពោះបុគ្គល (ដែលបានកាន់កាប់ដីនោះតាំងពីមុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១) ដោយសារតែមានតម្រូវការក្នុងការប្រើប្រាស់ដីនេះ សម្រាប់ការងារស៊ីវិលក្រោមគម្រោង ។
- ការពង្រីកដីចំណីផ្លូវរបស់រដ្ឋដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសិទ្ធិកម្មសិទ្ធិ ។

ក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញថា ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ មិនបានពន្យល់ច្បាស់លាស់អំពីរបៀប និងពេលដែលកិច្ចការទាំងនេះនឹងត្រូវបានអនុវត្តឡើយ ។ មានធាតុផ្សំជាច្រើនដែលនឹងទាមទារឱ្យមានការណែនាំបន្ថែមទៀត ដើម្បីឱ្យធនាគារពិភពលោក និងបុគ្គលិករដ្ឋាភិបាលដែលទទួលបន្ទុកលើការអនុវត្ត និងការត្រួតពិនិត្យគម្រោង

និងសម្រាប់ដៃគូអភិវឌ្ឍន៍ដើម្បីកំណត់អាចអនុវត្តបាននៃក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ ក្នុងស្ថានភាពជាក់ស្តែង ។

ជាក់ស្តែង ក្រុមអធិការកិច្ចបានកំណត់ឃើញនូវភាពខុសគ្នាដ៏សំខាន់មួយក្នុងផ្នែកភាសារវាងក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ និងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ (DCA) អំពីរបៀបដើម្បីយល់ដឹងអំពីការផ្តល់ប័ណ្ណកម្មសិទ្ធិក្នុងនាមរដ្ឋាភិបាល ដែលបង្កើតឱ្យមានការភាន់ច្រឡំ និងឧបសគ្គចំពោះការអនុវត្ត ។ ក្រុមអធិការកិច្ចក៏បានកំណត់ឃើញនូវកង្វះនៃភាពច្បាស់លាស់អំពីបញ្ហាសំខាន់ៗមួយចំនួនដែលរួមមានដូចជា រយៈពេលសម្រាប់ការអនុវត្តក្របខ័ណ្ឌគោលនយោ-បាយតាំងទីលំនៅឡើងវិញ របៀបកំណត់ថានណាខ្លះដែលមានសិទ្ធិទទួលបានការការពារពីក្របខ័ណ្ឌ គោលនយោបាយតាំងទីលំនៅឡើងវិញ និងកង្វះនៃយោងចំពោះលទ្ធភាពនៃការកាត់បន្ថយការតាំងទីលំនៅឡើង វិញមកត្រឹមកម្រិតអប្បបរមាតាមរយៈការអភិវឌ្ឍនៅនឹងកន្លែង និងការចែកដីធ្លីជាដើម ។

OD 4.30 មិនបានដោះស្រាយជាពិសេសចំពោះការតាំងទីលំនៅឡើងវិញដោយស្ម័គ្រចិត្តដែលជាលទ្ធផលនៃការផ្តល់ប័ណ្ណកម្មសិទ្ធិឡើយ ហើយក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញថា ថ្នាក់គ្រប់គ្រងនៅក្នុងគម្រោងនេះ បានសម្រេចចិត្តពង្រីកវិសាលភាពនៃស្ថានភាពដែលគោលនយោបាយនេះ នឹងត្រូវបានយកមកអនុវត្ត ដោយឆ្លុះបញ្ចាំងឱ្យឃើញនូវការគិតថ្មីនៅក្នុងធនាគារពិភពលោក នៅពេលនោះ ពាក់ព័ន្ធនឹងការអនុវត្តឱ្យបានត្រឹមត្រូវនៃកិច្ចការពារសុវត្ថិភាពរបស់ធនាគារពិភពលោក ។ ស្រដៀងគ្នានេះ ដែរ OD 4.30 បានផ្តល់នូវការណែនាំតិចតួចអំពីការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ (RPF) ។

**ក្រុមអធិការកិច្ចបានរកឃើញថា សេចក្តីសម្រេចរៀបចំក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ ស្របទៅនឹងបទប្បញ្ញត្តិនៃគោលនយោបាយជាធរមាន - OD 4.30.។ ក្រុមអធិការកិច្ចបានលើកសរសើរថ្នាក់គ្រប់គ្រងសម្រាប់ការពង្រីកវិសាលភាពនៃស្ថានភាពដែលគោលនយោបាយនេះនឹងត្រូវយកមកអនុវត្ត ដែលបានឆ្លុះបញ្ចាំងឱ្យឃើញនូវការគិតថ្មីនៅក្នុងធនាគារពិភពលោកនៅពេលនោះ ពាក់ព័ន្ធនឹងការអនុវត្តបានត្រឹមត្រូវនៃកិច្ចការពារសុវត្ថិភាពរបស់ធនាគារ ។** ទោះបីជាយ៉ាង ណាក៏ដោយ **ក្រុមអធិការកិច្ចបានរកឃើញថា មានភាពមិនច្បាស់លាស់ជាច្រើនពាក់ព័ន្ធនឹងរបៀប និងពេលវេលាដែលក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញនេះ គួរត្រូវបានចាប់ផ្តើម និងអនុវត្ត ។ ក្រុមអធិការកិច្ចបានរកឃើញថា ការរៀបចំក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ មិនបានស្របតាមបទប្បញ្ញត្តិដែលត្រូវបានរំពឹងទុកនៅក្នុង OD 4.03 ពាក់ព័ន្ធនឹង *"គោលការណ៍រៀបចំផែនការ ការរៀបចំស្ថាប័ន និងលក្ខណៈវិនិច្ឆ័យរៀបចំ" ឡើយ ។***

**ការពិចារណាលើបញ្ហាតាំងទីលំនៅឡើងវិញក្នុងអំឡុងពេលអនុវត្តគម្រោង ។** ក្រុមអធិការកិច្ចយល់ថា ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ មិនត្រូវបានចាប់ផ្តើមអនុវត្តម្តងណាឡើយ ក្នុងអំឡុងពេលអនុវត្តគម្រោង ។ របាយការណ៍ត្រួតពិនិត្យសម្រាប់គម្រោង មិនបានរាយការណ៍អំពីការដាក់បញ្ចូលអ្នកជំនាញកិច្ចការពារសុវត្ថិភាពម្នាក់នៅក្នុង

បេសកកម្មត្រួតពិនិត្យណាមួយឡើយ លើកលែងតែបេសកកម្មលើកទីមួយដែលបានធ្វើឡើងកាលពីខែឧសភា ឆ្នាំ២០០២ ។ បេសកកម្មត្រួតពិនិត្យជាច្រើនបានសន្និដ្ឋានថា ពុំធ្លាប់មានស្ថានភាពណាមួយដែលតម្រូវឱ្យមានការអនុវត្តកិច្ចការពារសង្គម និងបរិស្ថាន រួមបញ្ចូលទាំងក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញទេ ដែលជាក់ស្តែងដោយគ្មានការត្រួតពិនិត្យដោយយកចិត្តទុកដាក់ណាមួយទៅលើបញ្ហានេះឡើយ ។ ប្រការនេះ ហាក់ដូចជាផ្អែកលើការសន្មត់ *ជាមុន* ថា គម្រោង LMAP បានអនុវត្តតាមរបៀបមួយដែលនឹងតម្រូវឱ្យមានការអនុវត្តក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ ជាជាងការវាយតម្លៃលើស្ថានភាពតាមវិស័យ ។

**ក្រុមអធិការកិច្ចបានរកឃើញថា ការយកចិត្តទុកដាក់របស់ថ្នាក់គ្រប់គ្រងទៅលើផលប៉ះពាល់ផ្នែកសង្គមនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី រួមទាំងការបណ្តេញប្រជាជនចេញនាពេលអនាគត មិនមានលក្ខណៈជាប្រព័ន្ធ និងទទួលរងការប៉ះពាល់ដោយសារការខ្វះការយកចិត្តទុកដាក់ពីសំណាក់អ្នកជំនាញការពារសុវត្ថិភាពសង្គម ។ វាជាបញ្ហាកង្វល់ដែលបេសកកម្មត្រួតពិនិត្យជាច្រើនបានសន្និដ្ឋានថា មិនធ្លាប់មានស្ថានភាពដែលតម្រូវឱ្យមានការអនុវត្តកិច្ចការពារសង្គម និងបរិស្ថាន រួមទាំងក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ ដែលជាក់ស្តែងដោយគ្មានការត្រួតពិនិត្យដោយយកចិត្តទុកដាក់ណាមួយទៅលើបញ្ហានេះឡើយ ។ ក្រុមអធិការកិច្ចបានរកឃើញនូវភស្តុតាងនៅក្នុងឯកសារត្រួតពិនិត្យថា ថ្នាក់គ្រប់គ្រងបានលើកឡើងនូវបញ្ហាដែលពាក់ព័ន្ធនឹងការរៀបចំដែនដីរបស់រដ្ឋជាច្រើនលើកច្រើនសារ ដែលមានការទាក់ទិនជាសក្តានុពលសម្រាប់ការអនុវត្តក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ។ ក្រុមអធិការកិច្ចបានកោតសរសើរដល់ ធនាគារពិភពលោកសម្រាប់ការបន្តដោះស្រាយបញ្ហាគោលនយោបាយដ៏លំបាកនេះ នៅក្នុងបរិបទប្រទេសកម្ពុជា ដែលមានលក្ខណៈរសើប និងស្មុគស្មាញផ្នែកនយោបាយយ៉ាងខ្លាំង ។ ទោះបីជាយ៉ាងណាក៏ដោយ ការបន្តតាមដានលើបញ្ហាទាំងនេះ មិនបានគ្រប់គ្រាន់នោះឡើយ ហើយបានរួមចំណែកបង្កើតឱ្យមានបញ្ហានៅក្នុងដំបន់បឹងកក់ថែមទៀតផង។ ប្រការនេះមិនស្របតាមបទប្បញ្ញត្តិនៃ OP/BP 13.05 ស្តីពីការត្រួតពិនិត្យគម្រោង ។**

***ភាពអាចអនុវត្តនៃក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញនៅក្នុងករណីតំបន់បឹងកក់។*** ដោយផ្អែកលើការអង្កេតខាងលើ ក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញថា ការបណ្តេញប្រជាជនចេញកើតចេញពីដីរដ្ឋ ដូច្នេះ ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ គប្បីតែបានយកមកអនុវត្តនៅក្នុងតំបន់បឹងកក់ ។ ជាងនេះទៅទៀត ក្រុមអធិការកិច្ចក៏បានកត់សម្គាល់ផងដែរថា ផែនការអភិវឌ្ឍន៍ថ្មីៗសម្រាប់តំបន់បឹងកក់ បង្ហាញថា ចំណីផ្លូវដែលមានស្រាប់សម្រាប់ខ្សែផ្លូវរថភ្លើងដែលរត់កាត់តំបន់នេះ នឹងត្រូវបានពង្រីក និងថា ផ្លូវដែលមានស្រាប់នឹងមានសិទ្ធិពង្រីកផងដែរ ដែលប្រការទាំងនេះក៏អាចនាំឱ្យមានការបណ្តេញប្រជាជនចេញបន្ថែមទៀតផងដែរ ដូច្នេះហើយទើបមានការអំពាវនាវឱ្យមានការអនុវត្តក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញនេះ ។

វាហាក់បីដូចជាមានភស្តុតាងបញ្ជាក់ច្បាស់ពីការពិនិត្យមើលឡើងវិញលើរបាយការណ៍ត្រួតពិនិត្យថា ព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងតំបន់បឹងកក់តាំងពីឆ្នាំ២០០៧ មក មិនត្រូវបានធនាគារពិភពលោកចាត់ទុកថា មានលក្ខណៈធ្ងន់ធ្ងរឡើយ និងមានការពាក់ ព័ន្ធដោយផ្ទាល់ជាមួយនឹងគម្រោង រហូតទាល់តែពេលក្រោយៗទៀត នៅចុងឆ្នាំ២០០៨ និងដើមឆ្នាំ២០០៩

ពេលដែលអង្គការមិនមែនរដ្ឋាភិបាល ចាប់ផ្តើមលើកឡើងនូវកង្វល់របស់ពួកគេជាមួយនឹងបុគ្គលិកធនាគារ ហើយការបណ្តេញប្រជាពលរដ្ឋនៃសហគមន៍ផ្សេងទៀតនៅក្នុងរាជធានីភ្នំពេញកំពុងកើតមានឡើង ។ ទើបតែនៅក្នុងរយៈពេលដែលនាំឱ្យមានការដាក់សំណើសុំឱ្យមានការធ្វើអធិការកិច្ច ដែលធនាគារពិភពលោកមានការយល់ និងទទួលស្គាល់ថា ការបណ្តេញប្រជាជនចេញពីតំបន់បឹងកក់ ត្រូវបានភ្ជាប់ទៅជាមួយនឹងសកម្មភាពអនុវត្តគម្រោង LMAP និងថា ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញត្រូវតែយកមកអនុវត្តចំពោះការបណ្តេញចេញប្រជនពលរដ្ឋតំបន់បឹងកក់ ។

**ក្រុមអធិការកិច្ចបានរកឃើញថា ការខកខានរបស់ថ្នាក់គ្រប់គ្រងក្នុងការធានាឱ្យមានការអនុវត្តក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ មិនបានអនុវត្តតាម OD 4.30 និង OP/BP 13.05ស្តីពីការត្រួតពិនិត្យគម្រោងឡើយ ។**

**ដំណើរការតាំងលំនៅឡើងវិញដោយស្ម័គ្រចិត្ត ។** ក្នុងអំឡុងពេលចុះធ្វើអធិការកិច្ចដល់ទីតាំងរបស់ខ្លួន ក្រុមអធិការកិច្ចបានទទួលសក្ខីកម្មជាច្រើនពីប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ដោយសារគម្រោង (PAPs) ដោយពួកគាត់បានរៀបរាប់អំពីដំណើរការតាំងទីលំនៅឡើងវិញថា វាមិនបំពេញតាមស្តង់ដារដែលចែងនៅក្នុងក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញទាល់តែសោះ ។ ពុំមានដំណើរការពិគ្រោះយោបល់ និងបែបចូលរួមឡើយ បើទោះបីជាការងារស៊ីវិលបានចាប់ផ្តើមយ៉ាងយូរពេលដែលវាអាចធ្វើឱ្យមានដំណើរការតាំងទីលំនៅឡើងវិញត្រូវបានគេអនុវត្តដោយទទួលបានលទ្ធផលគួរជាទីពេញចិត្ត ហើយប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ដោយសារគម្រោងត្រូវបានបង្ខំឱ្យរួសរើលំនៅដ្ឋានរបស់ពួកគេចេញដោយមិនបានឆ្លងកាត់នីតិវិធីបណ្តឹងសាទុក្ខណាមួយឡើយ ។

ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ ចែងជាទូទៅអំពីអ្នកដែលមានសិទ្ធិទទួលបានសំណងតាម គោលនយោបាយដែលក្នុងនោះរួមបញ្ចូលទាំងប្រជាពលរដ្ឋដែលបាត់បង់ដី និងសំណងលំនៅដ្ឋាន ប្រជាជនដែលបាត់បង់ដីកសិកម្ម អ្នកជួលដែលបានជួលផ្ទះ ឬដី និងប្រជាជនដែលបាត់បង់អាជីវកម្ម ។ ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ ក៏បញ្ជាក់ផងដែរថា សំណងនេះ នឹងត្រូវបានផ្តល់ឱ្យជាចំណាយជួសជុលការខូចខាត ។

ក្រុមអធិការកិច្ច បានចុះពិនិត្យមើលទីតាំង តាំងទីលំនៅឡើងវិញ ដែលប្រជាពលមួយចំនួនមកពីតំបន់បឹងកក់ បានប្តូរលំនៅដ្ឋានទៅរស់នៅទីនោះ និងបានអង្កេតឃើញថា ស្ថានភាពនៃទីតាំងនេះ មិនល្អបានដល់កម្រិតស្តង់ដារដូចមានចែងនៅក្នុងគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅឡើងវិញដោយស្ម័គ្រចិត្តឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ការត្អូនត្អែរជាចម្បងនោះគឺថា ទីតាំងតាំងទីលំនៅឡើងវិញនេះ ស្ថិតនៅឆ្ងាយពេកពីប្រភពចំណូលមុនរបស់ពួកគាត់ ហើយគ្មានឱកាសរកប្រាក់ចំណូលជំនួសគ្រប់គ្រាន់ នៅជិតតំបន់នេះឡើយ ។

ជម្រើសទីបីដែលបានផ្តល់ឱ្យលំនៅដ្ឋានថ្មីនៅនឹងកន្លែង ដោយក្រុមអភិវឌ្ឍន៍ ត្រូវបានបដិសេធមិនទទួលយកដោយប្រជាពលរដ្ឋ ដោយសារតែពួកគាត់នឹងត្រូវបានតម្រូវឱ្យរើចេញទៅជួលផ្ទះស្នាក់នៅរយៈពេលបួនឆ្នាំ ដោយចំណាយថវិកាខ្លួនឯង ហើយដោយសារតែពួកគាត់មិនជឿជាក់ថា ក្រុមហ៊ុនអភិវឌ្ឍន៍ នឹងគោរពតាមការសន្យារបស់ពួកគេ បន្ទាប់ពីផុតរយៈពេលបួនឆ្នាំនោះ ។

ការខូចប្រយោជន៍ដែលប្រជាជនបានទទួលរងប៉ះពាល់ ដោយសារការបណ្តេញចេញនេះ និងការបណ្តេញចេញជាបន្តបន្ទាប់ ដែលមិនគោរពតាមស្តង់ដារដែលមានចែងនៅក្នុងក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ ត្រូវបានមើលឃើញយ៉ាងច្បាស់ដោយក្រុមអធិការកិច្ច ។ ក្រុមអធិការកិច្ចមិនបានរកឃើញកំណត់ត្រាណាមួយដែលថា ថ្នាក់គ្រប់គ្រងធនាគារពិភពលោក បានលើកយកបញ្ហានេះ ទៅពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាល ឬបុគ្គលិកគម្រោងឡើយ រហូតទាល់តែឆ្នាំ២០០៩ នៅពេលដែលស្ថានការណ៍នេះ បានក្លាយជាធ្ងន់ធ្ងររហូតដល់មិនអាចដោះស្រាយបានទៅហើយ ។

**ជាទូទៅ ក្រុមអធិការកិច្ចយល់ឃើញថា ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក គួរតែបានពិនិត្យឃើញបញ្ហាខូចប្រយោជន៍ទាំងឡាយដែលប្រឈមមុខដោយប្រជាពលរដ្ឋរស់នៅក្នុងតំបន់បឹងកក់បានឆាប់ជាងនេះ និងបានពិចារណាអំពីចំណាត់ការសមស្របនានា ។ ការខកខានមិនបានធ្វើបែបនេះ មិនបានអនុលោកតាមគោលនយោបាយរបស់ធនាគារស្តីពីការត្រួតពិនិត្យគម្រោងឡើយ ។**

**ក្រុមអធិការកិច្ចបានរកឃើញថា ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ ជាទូទៅ ស្របតាម OD 4.30 ។ ទោះបីជាយ៉ាងណាក៏ដោយ កង្វះនៃការណែនាំទៅលើសកម្មភាពស្តារចំណូល ដែលយោងតាមក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ គួរតែត្រូវបានចែងលម្អិតនៅក្នុងផែនការតាំងទីលំនៅឡើងវិញ ។**

**ក្រុមអធិការកិច្ចបានរកឃើញថា ដំណើរការអនុវត្តន៍ការបណ្តេញប្រជាជនចេញពីតំបន់បឹងកក់ កម្រិតនៃប្រាក់សំណង និងស្តង់ការរបស់ទីតាំងតាំងទីលំនៅឡើងវិញ មិនស្របតាមគោលការណ៍ដែលបានដាក់ចេញដោយក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ និងបទប្បញ្ញត្តិពាក់ព័ន្ធនៃ OD 4.30 ឡើយ ។**

## ការអះអាងថា ដំណើរការផ្តល់ប្លង់ដីដែលអនុម័តដោយគម្រោង បានធ្វើឱ្យចុះខ្សោយទៅលើសិទ្ធិកម្មសិទ្ធិដីធ្លីដែលមានកាលពីមុន

ការអះអាងរបស់ម្ចាស់សំណើនេះ ពាក់ព័ន្ធនឹងឥទ្ធិពលនៃគម្រោងស្តីពីសិទ្ធិកម្មសិទ្ធិដីធ្លីដែលមានកាលពីមុន ។ ជាក់ស្តែង ម្ចាស់សំណើបានអះអាងថា *"ការដាក់ចេញនូវដំណើរការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធវិមជ្ឈការ និងផ្លូវការទូទាំងប្រទេសក្រោមគម្រោង LMAP បានធ្វើឱ្យខ្សោយទៅលើការទទួលស្គាល់ប្រព័ន្ធកាន់កាប់តាមទម្លាប់នៅក្នុងប្រទេសកម្ពុជា ។ ដោយសារតែប្រជាពលរដ្ឋរស់នៅតំបន់បឹងកក់ មិនអាចផ្ទេរសិទ្ធិកាន់កាប់តាមទម្លាប់របស់ពួកគេ ទៅជាប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការក្រោមគម្រោង LMAP គម្រោងមិនត្រឹមតែមិនបានធ្វើឱ្យសិទ្ធិកាន់កាប់របស់ពួកគេទៅជាផ្លូវការប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងបានធ្វើឱ្យខ្សោយទៅលើស្ថានភាពកម្មសិទ្ធិកាន់កាប់កាលពីមុនរបស់ពួកគេថែមទៀតផង"* ។

*ជាការឆ្លើយតបទៅនឹងបញ្ហានេះ ថ្នាក់គ្រប់គ្រងបានបញ្ជាក់ថា ខ្លួន "មិនដឹងច្បាស់អំពីរបៀបដែលពាក្យសិទ្ធិកាន់កាប់តាមទម្លាប់ កំពុងត្រូវបានប្រើប្រាស់ឡើយ"* ។ ថ្នាក់គ្រប់គ្រងបានឱ្យដឹងថា លក្ខណៈពិសេសសំខាន់មួយនៃច្បាប់ភូមិបាលឆ្នាំ២០០១ បង្ហាញឱ្យឃើញថា សិទ្ធិកម្មសិទ្ធិ ត្រូវបានទទួលស្គាល់ថាអាចផ្ទេរទៅជាប័ណ្ណកម្មសិទ្ធិផ្លូវការបាន ប្រសិនបើបើលក្ខខណ្ឌជាក់

លាក់មួយចំនួន ត្រូវបានបំពេញ ។ ថ្នាក់គ្រប់គ្រងបានកត់សម្គាល់ឃើញថា ការផ្តល់ប័ណ្ណកម្មសិទ្ធិ គួរតែពង្រឹងដល់សិទ្ធិកម្មសិទ្ធិដែលអាចទទួលបានយោងតាមច្បាប់ភូមិបាល ។ ទោះបីជាយ៉ាងណាក៏ដោយ ថ្នាក់គ្រប់គ្រងបានបញ្ជាក់ថា *"សិទ្ធិដែលមានកាលពីមុន អាចត្រូវបានធ្វើឱ្យខ្សោយ តាមរយៈដំណើរការមួយដែលមានបញ្ហា ដែលមានបញ្ជាក់ជាភស្តុតាងយ៉ាងច្បាស់ដូចជាក្នុងករណីបណ្តេញប្រជាជនចេញពីតំបន់ស្រះចក ដោយការខ្វះការអនុវត្តប្រកបដោយតម្លាភាព សេចក្តីសម្រេចផ្អែកលើលក្ខណៈវិនិច្ឆ័យ និងខ្វះការសម្រេចដែលអាចពិនិត្យឡើងវិញបាន ដោយសារថានៅនៅមានសំនួរដែលសួរថាតើដីនោះគឺជាដីសធារណៈរបស់រដ្ឋឬយ៉ាងណា"* ។

**ឥទ្ធិពលនៃគម្រោងលើសុវត្ថភាពសិទ្ធិកាន់កាប់ ។** គោលបំណងមួយដែលបានចែងនៃគម្រោង គឺត្រូវផ្តល់សំណងសម្រាប់កង្វះភាពច្បាស់លាស់ និងការធ្វើឱ្យធ្លាក់ចុះសុវត្ថភាព ដែលបានផ្តល់ឱ្យដោយប្រព័ន្ធកាន់កាប់ដោយគ្មានការគ្រប់គ្រង តាមរយៈការផ្តល់ តាមលទ្ធភាព នូវប័ណ្ណកម្មសិទ្ធិចុះបញ្ជីផ្លូវការ ដែលនឹងត្រូវបានធានាដោយរដ្ឋ ដូចមានចែងនៅក្នុងមាត្រា ១ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ។ គិតត្រឹមឆ្នាំ២០០៩ គម្រោង LMAP បានចុះបញ្ជី និងផ្តល់ប័ណ្ណកម្មសិទ្ធិបានជាង ១,១ លានក្បាលដី ។ ក៏មានភស្តុតាងបញ្ជាក់ផងដែរថា ព្រំប្រទល់ភាគច្រើន ចាត់ទុកប័ណ្ណកម្មសិទ្ធិថ្មីថាជាការបោះជំហានទៅមុខមួយជំហាន ។ **ក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញថា គម្រោងពិតជាបានផ្តល់ប្រយោជន៏ដល់ប្រជាជនប្រហែល ១ លានគ្រួសារ ដោយគ្មានការសង្ស័យឡើយ និងទទួលស្គាល់សមិទ្ធផលដ៏សំខាន់នេះរបស់គម្រោង LMAP ។**

**សិទ្ធិកម្មសិទ្ធិដែលមានកាលពីមុនបានស្ថិតនៅក្រោមសម្ពាធអស់រយៈពេលជាយូរមកហើយ ។** ក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញថា កម្រិតនៃសុវត្ថភាពដែលបានផ្តល់ឱ្យដោយប្រព័ន្ធកាន់កាប់ដីធ្លីជាលក្ខណៈប្រពៃណី ទម្លាប់ ឬលក្ខណៈក្រៅប្រព័ន្ធផ្សេងទៀត ជាពិសេស នៅតាមតំបន់ប្រជុំជន បានធ្លាក់ចុះយ៉ាងខ្លាំង ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ មក ។ មានឧទាហរណ៏ជាច្រើនដែលអ្នកភូមិ និង ប្រជាជនក្រីក្រតាមប្រជុំជនដែលរស់នៅលើដីក្រោមទម្រង់សិទ្ធិកាន់កាប់លក្ខណៈប្រពៃណី ទម្លាប់ ឬទម្រង់ពាក់ព័ន្ធផ្សេងទៀត ត្រូវបានរំលោភយកដីរបស់ពួកគេដោយបុគ្គល ក្រុម ឬអង្គការមានអំណាចដែលជារឿយៗ មានការប្រើអំពើហិង្សា ឬការគំរាមកំហែងប្រើអំពើហិង្សា និងថា ទម្លាប់អនុវត្តន៏បែបនេះ ត្រូវបានរីកសាយភាយទាំងនៅ តាមតំបន់ជនបទ និងតំបន់ប្រជុំជនអស់រយៈពេលជាច្រើនឆ្នាំហើយ ។ ស្ថានភាពនេះ ត្រូវបានគេដឹងជាទូទៅមុនពេលដែលគម្រោងនេះត្រូវបានរៀបចំឡើង ហើយក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញថា ឯកសារវាយតម្លៃគម្រោង (PAD) ទទួលស្គាល់យ៉ាងច្បាស់នូវបញ្ហានេះ និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធ ។

ដូចដែលបានកត់សម្គាល់ខាងលើ ករណីតំបន់បឹងកក់ បង្ហាញថា ប្រជាពលរដ្ឋជាច្រើនបានចាត់ទុកខ្លួនឯងថាជាម្ចាស់ដី និងមានឯកសារបញ្ជាក់ពីកម្មសិទ្ធិថែមទៀតផង ។ ដីដែលត្រូវបានកាន់កាប់ ផ្ទេរ និងផ្តល់ជាមរតកតាមរយៈរបបកាន់កាប់មួយចំនួនអស់រយៈពេលជាច្រើនឆ្នាំហើយ ហើយការកាន់កាប់ ការផ្ទេរ និងការផ្តល់ជាមរតកនេះ បានធ្វើឡើងដោយមានភាពស្របច្បាប់ផ្នែកសង្គម និងការទទួលស្គាល់ដោយអាជ្ញាធរពាក់ព័ន្ធ នឹងម្ចាស់ដី បើទោះបីជាគ្មានប្រព័ន្ធរៀបចំឯកសារផ្លូវការថ្នាក់ជាតិក៏ដោយ ។

**វិធានការដើម្បីការពារក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះ ៖** ការយល់ដឹងកាន់តែទំលំទូលាយជាងមុនអំពីការអះអាងនេះ គឺថា ប្រជាជនជាច្រើនដែលទាមទារនូវសិទ្ធិកម្មសិទ្ធិដែលមានកាលពីមុនដោយផ្អែកលើប្រព័ន្ធកាន់កាប់ដីធ្លីតាមទម្លាប់ ឬមិនផ្លូវការផ្សេងទៀត ជាពិសេស ក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះ មិនទាន់បានទទួលប្រយោជន៍ពីគម្រោងនេះ តាមរបៀបមួយដែលបានចែងពីដំបូងឡើយ ពីព្រោះពួកគេត្រូវបានកាត់ចេញពីដំណើរការ ឬមានភាពខ្វះចន្លោះនៅក្នុងរបៀបដែលគម្រោងត្រូវបានអនុវត្ត ។ ក្រុមអធិការកិច្ចបានរកឃើញនូវភាពខ្សោយសំខាន់ៗ នៅក្នុងការរៀបចំគម្រោង និងការអនុវត្តគម្រោង ពាក់ព័ន្ធនឹងវិធានការការពារក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះដែលអាស្រ័យលើសិទ្ធិកាន់កាប់តាមទម្លាប់ ឬមិនផ្លូវការផ្សេងទៀត ។

ឯកសារវាយតម្លៃគម្រោង (PAD) ទទួលស្គាល់ថា *"រដ្ឋទំនងជាមិនបានដឹងអំពីចំនួន ទីតាំង និងព្រំប្រទល់នៃដីស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនឡើយ ។ ជាក់ស្តែង ភាគច្រើននៃដីទាំងនោះ មិនត្រូវបានវាស់វែង ធ្វើផែនទី ឬផ្តល់ប័ណ្ណកម្មសិទ្ធិឡើយ"* ។ ឯកសារវាយតម្លៃគម្រោង សំដៅដល់ចំនួនកើនឡើងនៃប្រជាជនគ្មានដីធ្លី ដោយសារការលក់ដោយមានការបង្ខិតបង្ខំ ឬដោយទទួលបានតម្លៃថ្លៃ និងចំនួនវិវាទដីធ្លីយ៉ាងច្រើន ។ បើទោះបីជាគម្រោងត្រូវបានរៀបចំឡើងក្នុងបរិបទនេះក៏ដោយឯកសារវាយតម្លៃគម្រោង បានរួមបញ្ចូលនូវការយោងដែលមិនច្បាស់លាស់ និងភាន់ច្រឡំមួយចំពោះ *"ដីនៅតំបន់ដែលទំនងជាមានវិវាទ"* ដូចបានរៀបរាប់បញ្ជាក់លម្អិតខាងលើស្រាប់ ។ ក្រុមអធិការកិច្ចបានទទួលព័ត៌មានពីប្រភពជាច្រើនថា នៅពេលដីដែលមិនទាន់មានការកំណត់ច្បាស់ ត្រូវបានអះអាងថាជាដីរដ្ឋ ដីនោះត្រូវបានចាត់ទុកថាជាប្រភេទដីមានវិវាទ និងត្រូវបានកាត់ចេញពីដំណើរការវិនិច្ឆ័យក្រោមគម្រោងនេះ ។ ជាលទ្ធផល ដូចដែលបានកើតឡើងនៅក្នុងតំបន់បឹងកក់ ប្រជាជនមិនត្រូវបានផ្តល់ឱ្យនូវឱកាសក្នុងការទាមទារសិទ្ធិកម្មសិទ្ធិរបស់ពួកគេឡើយ ។ **ក្រុមអធិការកិច្ចបានរកឃើញថា កំហុសនៅក្នុងការរៀបចំគម្រោង បាននាំឱ្យមានការកាត់ចេញដីដោយអយុត្តិធម៌ពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ និងថា ប្រការនេះបានធ្វើឱ្យប្រជាជន ជាពិសេស ប្រជាជនដែលក្រីក្រ និងងាយរងគ្រោះ បាត់បង់ឱកាសក្នុងការទាមទារ និងធ្វើឱ្យផ្លូវការនូវសិទ្ធិកាន់កាប់ដែលមានកាលពីមុនរបស់ពួកគេ តាមរយៈដំណើរការវិនិច្ឆ័យ ក្រោមគម្រោង LMAP ។**

ការរៀបចំគម្រោងក៏បានកាត់ចេញនូវការតាំងទីលំនៅមិនផ្លូវការ/ការតាំងទីលំនៅលើដីទំនេរ ពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិក្រោមគម្រោងនេះ លើកលែងតែរដ្ឋាភិបាលយល់ព្រមផ្តល់ដីនោះឱ្យធ្វើការចុះបញ្ជីដល់អ្នកតាំងទីលំនៅក្រៅផ្លូវការទាំងនោះប៉ុណ្ណោះ ។ តាមរយៈការធ្វើបែបនេះ **ក្រុមអធិការកិច្ចបានរកឃើញថា ថ្នាក់គ្រប់គ្រងមិនបានទទួលស្គាល់ថា ពាក្យដូចជា "អ្នកតាំងទីលំនៅលើដីទំនេរ" និង "ការតាំងទីលំនៅមិនផ្លូវការ" នៅតែមិនទាន់មានលក្ខណៈជាក់លាក់ឡើយ រហូតទាល់តែត្រូវបានកំណត់ជាក់លាក់ តាមរយៈដំណើរការវិនិច្ឆ័យ ។**

**កំហុសនៅក្នុងការរៀបចំគម្រោងទាំងនេះ បានធ្វើឱ្យមានការលំបាកសម្រាប់ថ្នាក់គ្រប់គ្រងធនាគារ ដើម្បីសម្រេចបាននូវគោលបំណងដែលបានចែងនៃគម្រោង ពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ និងការផ្តល់សុវត្ថិភាពលើសិទ្ធិកាន់កាប់សម្រាប់ប្រជាជនក្រីក្រ ដូច្នេះហើយ មិនស្របតាម OMS 2.20 ។** គួរកត់សម្គាល់ថា នៅក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសជាច្រើន

ទៀត ប្រជាជនដែលរស់នៅក្នុងតំបន់បែបនេះ ជាទូទៅ ជាប្រជាជនដែលក្រីក្របំផុត និងងាយរងគ្រោះបំផុត ទាក់ទិននឹងការប្រឈមមុខនឹងការបណ្តេញចេញ និងការរំលោភតាមរូបភាពផ្សេងទៀត ។

សមាសធាតុសំខាន់ៗដែលត្រូវបានដាក់បញ្ចូលនៅក្នុងគម្រោងនេះ ដើម្បីគាំទ្រដល់ប្រជាជនដែលងាយរងគ្រោះ គឺ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណៈ និងការផ្តល់លទ្ធភាពទទួលបានជំនួយផ្នែកច្បាប់ និងយន្តការដោះស្រាយវិវាទសម្រាប់ប្រជាជនក្រីក្រ ។ ស្រដៀងគ្នានេះដែរ ដោយមានការគាំទ្ររបស់គម្រោងដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងដីរដ្ឋ (ផ្នែកទី៥) បានចាត់ទុកថាជាមធ្យោបាយមួយក្នុងការវិនិច្ឆ័យការអះអាងដែលមានភាពចម្រូងចម្រាសរវាងរដ្ឋ និងបុគ្គលឯកជន។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានទទួលនៅក្នុងការឆ្លើយតបទៅលើការគ្រប់គ្រង ផ្នែកទាំង នេះមិនត្រូវបានអនុវត្តដូចដែលបានរំពឹងទុកឡើយ ។

**ក្រុមអធិការកិច្ចបានរកឃើញថា មិនមែនរាល់វិធានការដែលត្រូវបានរៀបចំឡើងជាពិសេសដើម្បីគាំទ្រដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះ ត្រូវបានអនុវត្តតាមផែនការទាំងអស់ឡើយ ។ ក្រុមអធិការកិច្ចបានរកឃើញថា ថ្នាក់គ្រប់គ្រងមិនបានតាមដានបានគ្រប់គ្រាន់ទៅលើការប្តេជ្ញាចិត្តរបស់គម្រោង ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមរបស់សហគមន៍ ធានាឱ្យមានការការពារផ្នែកច្បាប់សម្រាប់ប្រជាជនដែលទទួលរងហានិភ័យនៃការបណ្តេញចេញ និងផ្តល់លទ្ធភាពគ្រប់គ្រាន់ដើម្បីទទួលបានយន្តការដោះស្រាយវិវាទ ។ ប្រការនេះ មិនស្របតាម OP/BP 13.05 ឡើយ ។**

## ការអះអាងថា សហគមន៍ដទៃទៀត
## នៅក្នុងខេត្តគម្រោងត្រូវបានបង្ខំបណ្តេញចេញពីកន្លែងដែលពួកគេរស់នៅ

ការអះអាងចុងក្រោយរបស់ម្ចាស់សំណើរគឺថា *"តំបន់បឹងកក់ មិនមែនជាករណីដាក់ដោយឡែកតែមួយនោះទេ"* និងថា *"សហគមន៍នៅតាមទីប្រជុំជន តំបន់ជនបទ និងជនជាតិដើមភាគតិច ទូទាំងប្រទេសកម្ពុជា មិនមានលទ្ធភាពទទួលបានការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និង/ឬយន្តការដោះស្រាយវិវាទ ក្រោមគម្រោង LMAP ដូច្នេះហើយ មិនមានលទ្ធភាពក្នុងការធានានូវសិទ្ធិកម្មសិទ្ធិដីធ្លីរបស់ពួកគេ ក្រោមប្រព័ន្ធផ្លូវការ ដែលបានរៀបចំឡើងដោយគម្រោង LMAP ។ សហគមន៍មួយចំនួនក្នុងចំណោមសហគមន៍ទាំងនេះ បានប្រឈមមុខនឹងអសន្តិសុខលើសិទ្ធិកាន់កាប់ និងការបង្ខំឱ្យបណ្តេញចេញពីកន្លែងដែលពួកគេរស់នៅកាន់តែច្រើនឡើងៗ ។"*

ថ្នាក់គ្រប់គ្រងបានគូសបញ្ជាក់នូវចំណាត់ការក្នុងការដោះស្រាយកង្វល់ទាំងនេះ ដោយកត់សម្គាល់ថា *"ក្រុមការងារកំពុងប្រមូលព័ត៌មានដើម្បីកំណត់នូវករណីសក្តានុពលផ្សេងទៀតរបស់សហគមន៍ ដែលអាចត្រូវបានបណ្តេញចេញពីតំបន់វិនិច្ឆ័យដោយគ្មានការអនុវត្តក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ"* ។ ថ្នាក់គ្រប់គ្រងបានបញ្ជាក់ថា *គិតត្រឹមថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ ករណីធំៗចំនួនប្រាំបី ត្រូវបានកំណត់ ដែលពាក់ព័ន្ធនឹងភូមិចំនួន ១០ (ឬ ផ្នែកនៃភូមិទាំង នោះ)"* ។

**ការបណ្តេញចេញដោយបង្ខំនៅក្នុងប្រទេសកម្ពុជា ៖** ការបណ្តេញចេញដោយបង្ខំ គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាចម្បងៗ ដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដែលបានប៉ះពាល់ដល់ប្រជាជនរាប់ពាន់គ្រួសារ ទូទាំងប្រទេស ទាំងនៅតំបន់ប្រជុំជន និងតំបន់ជនបទ ដែលភាគច្រើនជាប្រជាពលរដ្ឋដែលរស់នៅក្នុងភាពក្រីក្រ ។ គម្រោងអភិវឌ្ឍន៏នានា នាំមកនូវការបណ្តេប្រជាជនចេញពីកន្លែងដែលពួកគេធ្លាប់រស់នៅ ជាពិសេស តំបន់ប្រជុំជន និងតំបន់ពាក់កណ្តាលប្រជុំជន ។ យោងតាមរបាយការណ៏វាយតម្លៃភាពក្រីក្រឆ្នាំ២០០៦ របស់ធនាគារពិភពលោក ចន្លោះពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៣ សាលារាជធានីភ្នំពេញ បានបង្ខំបណ្តេញប្រជាជន ១១.០០០ គ្រួសារ ដែលភាគច្រើនជាប្រជាជនក្រីក្ររស់នៅកណ្តាលរាជធានី ឬនៅតំបន់ក្បែរកណ្តាលរាជធានី ។ យោងតាមអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) ប្រជាជនប្រមាណ ១៥០.០០០ នាក់ ទូទាំងប្រទេស ត្រូវបានគេដឹងថាកំពុងរស់នៅប្រឈមនឹងហានិភ័យនៃការបណ្តេញចេញដោយបង្ខំពីកន្លែងដែលពួកគេធ្លាប់រស់នៅ ។

ប្រទេសកម្ពុជាគឺជាភាគីមួយនៃសន្ធិសញ្ញាអន្តរជាតិដែលទទួលស្គាល់សិទ្ធិទទួលបានកន្លែងស្នាក់នៅគ្រប់គ្រាន់ ។ គណៈកម្មាធិការត្រួតពិនិត្យការអនុវត្តសន្ធិសញ្ញាទាំងនេះ បានសម្តែងនូវកង្វល់ចំពោះការបង្ខំបណ្តេញប្រជាជនចេញពីកន្លែងដែលពួកគេធ្លាប់រស់នៅ និងភាពមិនត្រូវគ្នា *តាំងពីតំបូង* ជាមួយនឹងលក្ខខណ្ឌនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងនេះ ។ យោងតាមប្រភពផ្សេងៗ ការបង្ខំបណ្តេញប្រជាជនចេញពីកន្លែងដែលពួកគេធ្លាប់រស់នៅបានឈានដល់កម្រិតវិបត្តិនៅក្នុងឆ្នាំ ២០០៩ ដែលពេលនោះ ការបង្ខំបណ្តេញប្រជាជនចេញពីកន្លែងដែលពួកគេធ្លាប់រស់នៅបានកើតឡើងចំពោះប្រជាជនប្រមាណ ២៧.០០០ នាក់ ក្នុងឆ្នាំ២០០៩ ។ នៅខែមករា ឆ្នាំ២០០៩ អ្នកជំនាញឯករាជ្យម្នាក់របស់អង្គការសហប្រជាជាតិ បានហៅការការបង្ខំបណ្តេញប្រជាជនកម្ពុជាចេញពីកន្លែងដែលពួកគេធ្លាប់រស់នៅថាជា *"ការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្ស"* និងបានអំពាវនាវឱ្យមានការសងសំណងខូចខាតសម្រាប់ការបាត់បង់ផ្ទះសម្បែង និងការផ្តល់ទីលំនៅជម្រើសដល់ពួកគេវិញ ។

**ក្រុមអធិការកិច្ចកត់សម្គាល់ថា ការបណ្តេញចេញដោយបង្ខំមិនមែនជារឿងថ្មីទេនៅប្រទេសកម្ពុជា ហើយដូចដែលត្រូវបានកត់សម្គាល់ដោយការវិនិច្ឆ័យភាពក្រីក្រនៅប្រទេសកម្ពុជារបស់ធនាគារពិភពលោកដែរ កំពុងតែមានជាបន្តនៅរាជធានីភ្នំពេញ តាំងពីមុនពេលរៀបចំគម្រោង ។ ដោយសារគម្រោងបានបញ្ចូលបញ្ហាតាំងទីលំនៅក្នុងទីក្រុងសំខាន់ ដូចជារាជធានីភ្នំពេញជាដើម នៅក្នុងចំណោមគម្រោងខេត្តរបស់ខ្លួន គម្រោងនេះជាហានិភ័យចំពោះកេរ្តិ៍ឈ្មោះដ៏សំខាន់សម្រាប់ធនាគារពិភពលោក ។ ក្រុមអធិការកិច្ចកត់សម្គាល់ថា ការបង្កើតគម្រោងមិនបានលើកឡើងនូវបញ្ហា និងហានីយចំពោះកេរ្តិ៍ឈ្មោះដ៏សំខាន់នេះអោយបានគ្រប់គ្រាន់ទេ ។**

**ការតាមដានដំណើរការផ្តល់ប្លង់ដីរបស់គម្រោង ។** មានការលើកឡើងនូវបញ្ហាកង្វល់ នៅក្នុងពេលអនុវត្ត LMAP ដែលទាក់ទងនឹងតម្លាភាព និងគណនេយ្យភាព នៅក្នុងប្រព័ន្ធ និងនីតិវិធីផ្តល់ប្លង់ដី នៅដើមឆ្នាំ២០០៥ ។ ជាលទ្ធផល ការពិនិត្យមើលឡើងវិញ (ការពិនិត្យមើលឡើងវិញដោយឯករាជ្យ) ត្រូវបានធ្វើឡើង នៅចន្លោះខែវិច្ឆិកា ឆ្នាំ២០០៥ និងខែមករា ឆ្នាំ២០០៦ ដោយផ្តោតគោលដៅទៅលើខេត្តនៃគម្រោងទាំង ១១ ដែលការផ្តល់កម្មសិទ្ធិដីលក្ខណៈជាប្រព័ន្ធដោយ LMAP កំពុងតែត្រូវបានធ្វើ ។ ការពិនិត្យមើលឡើងវិញកត់សម្គាល់ថា *"ពុំមានព័ត៌មានអំពីសិទ្ធិ និងការអនុញ្ញាតដែលអាចមានក្នុងការ*

*ទាមទារកម្មសិទ្ធិ (ជាពិសេស ទ្រព្យសម្បត្តិរបស់រដ្ឋ) តាមរយៈការប្រឆាំងនឹងការទាមទារដីរបស់រដ្ឋ ត្រូវបានផ្តល់អោយឡើយ* ***ដែលការគ្មានព័ត៌មាននេះហាក់ដូចជាប៉ះពាល់ ("យ៉ាងធ្ងន់ធ្ងរ" និង) យ៉ាងអាក្រក់ យ៉ាងហោចណាស់ដល់ ១ ភាគ ៥ (១៩,៦%) នៃគ្រួសារ ទាំងអស់ ដែលគំហើញប្រភេទនេះត្រូវបានរកឃើញនៅក្នុងតំបន់វិនិច្ឆ័យស្រុកដែលត្រូវបានទៅធ្វើទស្សនកិច្ចចំនួន ១៣ ក្នុងចំណោម ១៩"*** (សង្កត់ធ្ងន់ទៅលើប្រភពដើម) ។

ដោយយោងតាមការពិនិត្យមើលឡើងវិញ ពុំមានមូលហេតុដែលមានឯកសារបញ្ជាក់សម្រាប់ការបដិសេធមិនផ្តល់ប្លង់ដី ឬការចុះបញ្ជីដី ត្រូវបានផ្តល់ដល់គ្រួសារឡើយ ។ លើសពីនេះទៀត ការពិនិត្យមើលឡើងវិញគូសបញ្ជាក់ថា ការយកពន្ធជាទូទៅចំពោះដីបម្រុងរបស់រដ្ឋ ហាក់ដូចជាមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើគោលបំណង និងគោលដៅរបស់ LMAP ។ ការពិនិត្យមើលឡើងវិញរាយការណ៍ថា ២០% នៃសហគមន៍ដែលត្រូវបានពិគ្រោះយោបល់ មានអារម្មណ៍ថា ពួកគេបាន *"បាត់បង់"* ដីរបស់ពួកគេមួយចំនួន ដោយសារតែការទាមទាររបស់រដ្ឋ ។ ដូចនៅក្នុងករណីតំបន់បឹងកក់ដែរ ការពិនិត្យមើលឡើងវិញបានកត់សម្គាល់នូវឧប្បត្តិហេតុដែលគ្រួសារត្រូវបានគេប្រាប់ថា ពួកគេកំពុងរស់នៅលើដីមានវិវាទ ដែលជា *"ដីរបស់រដ្ឋ"* ។ ម្យ៉ាងវិញទៀត របាយការណ៍កត់សម្គាល់ថា ព័ត៌មានមិនត្រូវបានផ្តល់ដល់គ្រួសារ ទាក់ទងនឹងសិទ្ធិដែលអាចមានរបស់ពួកគេក្នុងការទទួលបានសំណងចំពោះផលប៉ះពាល់អវិជ្ជមាន ដូចដែលបានណែនាំនៅក្នុងការធានាសង្គមដែលអាចអនុវត្តបានចំពោះ LMAP ឡើយ ។

**ទោះបីជាមានគំហើញច្បាស់លាស់នៃការពិនិត្យមើលឡើងវិញឯករាជ្យ និងគំហើយឡើងវិញនៅក្នុងរបាយការណ៍ត្រួតពិនិត្យការគ្រប់គ្រង ដែលបញ្ជាក់នូវភាពមិនគ្រប់គ្រាន់នៃយន្តការដោះស្រាយវិវាទ ជាពិសេស នៅពេលភាគីកាន់អំណាចចូលពាក់ព័ន្ធក៏ដោយ ថ្នាក់គ្រប់គ្រងធនាគារមិនបានចាត់វិធានការច្បាស់លាស់ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមានទាំងនេះឡើយ ។** លើសពីនេះទៀត **ការពិនិត្យមើលឡើងវិញនូវរបាយការណ៍ត្រួតពិនិត្យបង្ហាញថា ពុំមានប្រព័ន្ធតាមដាន និងវាយតម្លៃ សម្រាប់គម្រោងឡើយរហូតដល់ឆ្នាំ២០០៧ ។ ក្រុមអធិការកិច្ចរកឃើញថា ដោយសារកង្វះខាតនូវប្រព័ន្ធតាមដាន និងវាយតម្លៃដ៏រឹងមាំសម្រាប់គម្រោង ថ្នាក់គ្រប់គ្រងធនាគារមិនបានដឹងអំពីបញ្ហាសំខាន់ដែលកើតចេញពីគម្រោងឡើយ ។ ចំណុចនេះមិនឆ្លើយតបទៅនឹង OP/BP 13.05 ទេ ។**

**សកម្មភាពថ្មីៗរបស់ថ្នាក់ដឹកនាំ ។** ក្រោយការចុះបញ្ជីសំណើសុំធ្វើអធិការកិច្ចដោយក្រុមអធិការកិច្ច នៅខែធ្នូ ឆ្នាំ២០០៩ ថ្នាក់គ្រប់គ្រងធនាគារបានធ្វើការស្រាវជ្រាវដល់មូលដ្ឋានមានកំណត់ ដើម្បីស្វែងយល់ថាតើមានភាពត្រូវគ្នារវាងការបណ្តេញដែលបានរាយការណ៍ដោយ NGOs និងប្រព័ន្ធផ្សព្វផ្សាយ និងតំបន់ផ្តល់កម្មសិទ្ធិដីមានលក្ខណៈជាប្រព័ន្ធ ក្រោម LMAP ដែរឬទេ ។ ការពិនិត្យមើលឡើងវិញបានរកឃើញថា ក្រៅពីការបណ្តេញចេញពីតំបន់បឹងកក់ គ្រួសារជាង ២.៦០០ គ្រួសារ ត្រូវបានបណ្តេញចេញ ឬផ្លាស់ប្តូរទីលំនៅដោយបង្ខំ ឬកំពុងប្រឈមមុខនឹងការបណ្តេញចេញនៅក្នុងភូមិ ក្រោយពេលចាប់ផ្តើមដំណើរការវិនិច្ឆ័យក្រោម LMAP ។

ដោយសារការបណ្តេញចេញជាច្រើនហាក់ដូចជាមានការពាក់ព័ន្ធនឹងប្រជាជនដែលរស់នៅលើដីរបស់រដ្ឋ ដែលទាមទារដោយរដ្ឋាភិបាល RPF មិនត្រូវបានអនុវត្តឡើយ ហើយក្នុងករណីភាគច្រើន ប្រជាជនដែលទទួលផលប៉ះពាល់មិនបានទទួលនូវ

សំណងឡើយ ឬបានទទួលសំណងមិនត្រូវតាម OD 4.30 ស្តីពីការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ។ ការពិនិត្យមើលឡើងវិញជាទូទៅបានបញ្ជាក់ នូវឧប្បត្តិហេតុជាច្រើននៃការទាមទាររបស់ NGOs ក្នុងស្រុក ។

**ក្រុមអធិការកិច្ចកត់សម្គាល់ថា ទោះបីជាមានឯកសារជាច្រើនដែលបញ្ជាក់ថា មានចំនួនគ្រួសារជាច្រើនបានទទួលផលប៉ះពាល់ជាអវិជ្ជមានក៏ដោយ កម្រិតនៃផលប៉ះពាល់អវិជ្ជមានទៅលើគ្រួសារដែលរស់នៅក្នុងតំបន់វិនិច្ឆ័យមិនត្រូវបានដឹងឡើយ ។ ក្រុមអធិការកិច្ចមានការព្រួយបារម្ភជាទីបំផុតអំពីចំនួនដ៏ច្រើននៃប្រជាជនដែលត្រូវបានបណ្តេញចេញ ផ្លាស់ប្តូរទីលំនៅដោយបង្ខំ ឬកំពុងទទួលការគំរាមកំហែងនៃការបណ្តេញចេញនៅក្នុងតំបន់នៃគម្រោង ។**

## មេរៀន និងបញ្ហាប្រព័ន្ធ

ការស៊ើបអង្កេតនេះ បានបង្ហាញឱ្យឃើញនូវបញ្ហាមានលក្ខណៈជាប្រព័ន្ធនៃភាពអាស្រ័យយ៉ាងទូលំទូលាយទៅនឹងប្រតិបត្តិការរបស់ធនាគារ ។ ជំពូកនេះពិភាក្សាអំពីបញ្ហាចំនួនបី ដែលក្រុមអធិការកិច្ចយល់ថាមានសារៈសំខាន់ជាពិសេស : ការគ្រប់គ្រងហានិភ័យ ការផ្តល់កម្មសិទ្ធិដីជាអភិក្រមឯកសារតែមួយ និងបញ្ហាប្រឈមនៃគម្រោងគ្រប់គ្រងដីធ្លីនិងរដ្ឋបាល ។ យើងសង្ឃឹមថា ការពិភាក្សានេះអាចផ្តល់ជាមេរៀនដែលអាចជួយពង្រឹងអនុលោមភាពនៃគោលនយោបាយនាពេលអនាគត និងប្រសិទ្ធភាពនៃការអភិវឌ្ឍជាទូទៅ ។

**ការគ្រប់គ្រងហានិភ័យ ។** ការបង្កើតគម្រោងបឋមបានគ្រោងនូវយុទ្ធសាស្រ្តពហុផ្នែក រាប់ទាំងធាតុផ្សំនានា ដើម្បីដោះស្រាយបញ្ហានៃការគាំទ្រប្រជាជនក្រីក្រ និងងាយរងគ្រោះ នៅក្នុងដំណើរការវិនិច្ឆ័យ និងបានបង្កើនតម្លាភាព និងភាពអាចព្យាករណ៍បាននៅក្នុងការកំណត់ដីរបស់រដ្ឋ ។ ទោះបីជាយ៉ាងណាក៏ដោយ PAD បានទទួលស្គាល់ថា មានហានិភ័យខ្ពស់ ឬច្រើនពាក់ព័ន្ធនឹងការសន្មតជាច្រើន ដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់សម្រាប់ការសម្រេចគោលបំណងដែលបានលើកឡើង ។ ឧទាហរណ៍ PAD បញ្ជាក់ថា មានហានិភ័យជា "ច្រើន" ដែលថា រដ្ឋាភិបាលនៅខ្វះការប្តេជ្ញាចិត្តក្នុងការធានាថា យន្តការដោះស្រាយវិវាទមានដំណើរការយ៉ាងមានប្រសិទ្ធភាព និងត្រឹមត្រូវ ហើយកំណត់ថា ជាវិធានការកាត់បន្ថយហានិភ័យដែលថា *"គម្រោងនឹងត្រូវបានកាត់បន្ថយ ប្រសិនបើការប្តេជ្ញាចិត្តធ្វើឱ្យមានដំណើរការដោះស្រាយវិវាទដោយត្រឹមត្រូវ មានមិនគ្រប់គ្រាន់ទេ"* ។

ដូចត្រូវបានរាយការណ៍នៅក្នុងជំពូកទី ៣ ស្រាប់ ធាតុសំខាន់ទាំងអស់នៃយុទ្ធសាស្រ្តគម្រោងដែលគេចង់បាន ដើម្បីកាត់បន្ថយហានិភ័យនេះ ត្រូវបានពន្យារពេលនៅក្នុងការអនុវត្ត ត្រូវបានអនុវត្តមួយផ្នែក ឬមិនទាន់ចាប់ផ្តើម ។ មិនតែប៉ុណ្ណោះ ដោយមានការលើកទឹកចិត្តយ៉ាងសកម្មពីថ្នាក់ដឹកនាំ គម្រោងបានបោះជំហានដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែង សំដៅសម្រេចគោលដៅទាក់ទងនឹងការផ្តល់កម្មសិទ្ធិដី ។ ចំណុចនេះបានបញ្ចូលក្នុងចំណោមចំណុចផ្សេងទៀតនូវការដាក់បញ្ចូលការបើកប្រាក់បៀវត្សរ៍ ដោយផ្អែកលើសមត្ថភាពដល់បុគ្គលិក ។ ដោយពិចារណាដល់ដំណើរការបច្ចុប្បន្ននៅក្នុងធនាគារ ដើម្បីណែនាំអភិក្រមផ្សេងគ្នា ចំពោះការផ្តល់កម្ចីវិនិយោគ ដោយផ្អែកលើការវិនិច្ឆ័យហានិភ័យ បទពិសោធន៍របស់ LMAP គឺជាមេរៀនយ៉ាងសំខាន់ ។

ជាដំបូង ការរៀបចំគម្រោង LMAP ត្រូវបានគាំទ្រដោយការវិនិច្ឆ័យ (ពោលគឺជាការវិនិច្ឆ័យខាងសង្គម) ទៅលើផ្នែកសេដ្ឋកិច្ចនយោបាយនៃការគ្រប់គ្រងដីធ្លី នៅក្នុងប្រទេសកម្ពុជា និងត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងហានិភ័យដែលពាក់ព័ន្ធ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងយល់ដឹង វាច្បាស់ណាស់ថា ពុំមានកម្មសិទ្ធិពេញលេញក្នុងចំណោមភាគីពាក់ព័ន្ធនៃអភិក្រមពហុផ្នែក ដែលត្រូវបានបង្កើតឡើងឡើយ ។ អ្វីដែលមើលទៅដូចជាសមហេតុផលនៅក្រដាសបែរជាមិនមែនជាការពិត។

ក្រុមអធិការកិច្ចជឿថា ធនាគារពិភពលោកមានតួនាទីអភិវឌ្ឍន៍សំខាន់នៅក្នុងការផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការមានហានិភ័យខ្ពស់ ប៉ុន្តែ បទពិសោធន៍របស់ LMAP បង្ហាញនូវគ្រោះថ្នាក់នៃការឆ្លើយតបទៅនឹងហានិភ័យ ដោយបង្កើតគម្រោងយ៉ាងស្មុគស្មាញបំផុត ។ ក្រុមអធិការកិច្ចបានរកឃើញថា ធាតុផ្សំថ្មីៗត្រូវបានបន្ថែម នៅក្នុងដំណើរការរៀបចំ ដោយមិនខ្វល់អំពីភាពច្បាស់លាស់ ថាតើផ្នែកផ្សេងៗត្រូវបានសន្មត់ថាមានទំនាក់ទំនងជាធម្មតាដោយរបៀបណា និងដោយមិនមានការពិចារណាជិតដល់អំពីសមិទ្ធលទ្ធភាពនៃវិធីសាស្ត្រទាំងមូលឡើយ ។

ទីពីរ ការត្រួតពិនិត្យគម្រោង LMAP មិនបានដឹងឱ្យបានគ្រប់គ្រាន់អំពីហានិភ័យដែលពាក់ព័ន្ធឡើយ ។ ក្រុមអធិការកិច្ចបានរកឃើញថា ដូចត្រូវបានកត់សម្គាល់នៅក្នុងជំពូកមុនដែរ អ្នកជំនាញខាងសង្គមមិនត្រូវបានដាក់បញ្ចូលទៅក្នុងបេសកកម្មត្រួតពិនិត្យឡើយ ទោះបីជាមានការលើកឡើងនូវបញ្ហាកង្វល់នៅក្នុង PAD ទាក់ទងនឹងការធានាផលប្រយោជន៍របស់ប្រជាជនក្រីក្រ និងងាយរងគ្រោះក៏ដោយ ។ សញ្ញាព្រមានពីអ្នកសង្កេតការណ៍ឯករាជ្យហាក់ដូចជាមិនត្រូវបានយកចិត្តទុកដាក់ ។ កម្មវិធីសម្រាប់ការតាមដានផលប៉ះពាល់បានចាប់ផ្តើមយ៉ាងយឺតយ៉ាវបំផុត ហើយការសិក្សាមូលដ្ឋានទីក្រុងបានបញ្ចប់នៅឆ្នាំ២០០៧ - ប្រាំឆ្នាំក្រោយពេលគម្រោងបានចាប់ផ្តើម ។ ក្រុមអធិការកិច្ចមិនអាចរកឃើញនូវកំណត់ត្រារបស់ថ្នាក់ដឹកនាំដែលតវ៉ានឹងការពន្យឺតដំណើរការផ្តល់កម្មសិទ្ធិដីឡើយ ដោយរង់ចាំការវិវត្តទៅមុខលើធាតុផ្សំផ្សេងទៀត ដែលមានការយឺតយ៉ាវ ។

ក្រុមអធិការកិច្ចទទួលស្គាល់ថា កត្តាជាច្រើនដែលហួសពីលទ្ធភាពគ្រប់គ្រងរបស់ថ្នាក់ដឹកនាំបានចូលរួមចំណែកធ្វើឱ្យមានភាពមិនប្រក្រតីនៅក្នុងវិវត្តទៅមុខនេះ ប៉ុន្តែចំណុចនេះមិនអាចពន្យល់ ឬដោះសារអំពីកង្វះខាតយ៉ាងច្បាស់លាស់នូវយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យដ៏រឹងមាំមួយសម្រាប់គម្រោងឡើយ ។ ដោយសារតែយុទ្ធសាស្ត្រដែលមានតាំងពីពេលចាប់ផ្តើមប្រតិបត្តិការណ៍មក ការលំបាកតាមក្រោយនៃគម្រោងប្រហែលជាមានតិចតួច ។

**ការផ្តល់កម្មសិទ្ធិដីជាអភិក្រមឯកសារតែមួយ។** ស្របនឹងគម្រោងគ្រប់គ្រងដីធ្លីសហសម័យផ្សេងទៀតជាច្រើន LMAP ត្រូវបានអះអាងថាជាមធ្យោបាយក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងជាមធ្យោបាយក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការកែលម្អ សុវត្ថិភាពកម្មសិទ្ធិដីធ្លីសម្រាប់ប្រជាជនក្រីក្រ និងងាយរងគ្រោះ ។ ទោះបីជាយ៉ាងណាក៏ដោយ មេរៀនពី LMAP និងការស៊ើបអង្កេតដែលទាក់ទងនឹងដីធ្លីផ្សេងទៀត បង្ហាញថា ការផ្តល់កម្មសិទ្ធិដីតែឯងមិនអាចត្រូវបានរំពឹងថានឹងសម្រេចគោលបំណងនៃគោលនយោបាយសង្គម និងសេដ្ឋកិច្ចផ្សេងៗទាំងនេះ នៅក្នុងបរិបទជាច្រើនឡើយ ។

បើតាមទស្សនៈរបស់អ្នកជំនាញរបស់ក្រុមអធិការកិច្ច វាត្រូវបានបង្ហាញថាមានប្រសិទ្ធភាពនៅក្នុងតំបន់ដែលការប្រជែងយកដីធ្លីមានកម្រិតទាបខ្លាំង និងដែលវិវាទនៅមានកម្រិត ប៉ុន្តែមិនមានប្រសិទ្ធភាព និងនៅក្នុងកាលៈទេសៈខ្លះ គ្មានផលិតភាពនៅក្នុងការបង្កើនសុវត្ថិភាពកម្មសិទ្ធិដីធ្លី នៅក្នុងតំបន់ដែលតម្លៃដីធ្លីមានការកើនឡើងយ៉ាងខ្លាំង និងដែលចំណុចនេះអាចទាក់ទាញចំណាប់អារម្មណ៍អាក្រក់ ។

ក្រុមអធិការកិច្ចបានរកឃើញថា ភាពមិនច្បាស់លាស់នៅក្នុងការបង្កើតគម្រោង និងលទ្ធផលត្រូវបានលើកឡើងនៅក្នុងការសិក្សាងករាជ្យ ព្រមទាំងនៅក្នុងរបាយការណ៍ត្រួតពិនិត្យរបស់បុគ្គលិកមួយចំនួន គ្រាន់តែពីរបីឆ្នាំក្រោយពេលគម្រោងចាប់ផ្តើមប៉ុណ្ណោះ ។ សញ្ញាព្រមានទាំងនេះហាក់ដូចជាមិនត្រូវបានយកចិត្តទុកដាក់ឡើយ រហូតទាល់តែបញ្ហាតំបន់បឹងកក់ក្លាយជាបញ្ហាដាស់ស្មារតី ។ មិនត្រឹមតែមិនពិនិត្យមើលមេរៀននេះឡើងវិញនៅពេលវាកើតឡើងប៉ុណ្ណោះទេ គម្រោងបែរជាផ្តោតកាន់តែខ្លាំងឡើងៗទៅអភិក្រមឯកសារតែមួយ ដែលវាស់វែងភាពជោគជ័យ លើផ្នែកចំនួននៃកម្មសិទ្ធិដីដែលបានផ្តល់ ។ ឥទ្ធិពលនៃអភិក្រមនេះក្នុងផ្នែកកាត់បន្ថយភាពក្រីក្រ ដែលជាគោលបំណងទីពីរ មិនដែលត្រូវបានស៊ើបអង្កេតឱ្យបានម៉ត់ចត់ឡើយ ។ មេរៀនប្រតិបត្តិការមួយគឺថា ការពិនិត្យមើលឡើងវិញប្រចាំត្រីមាសប្រហែលជាបានបញ្ចូលការពិនិត្យមើលឡើងវិញយ៉ាងតឹងរ៉ឹងនូវគោលបំណង និងការបង្កើតគម្រោង ។

ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍របស់ LMAP មិនគួរបំបាក់ទឹកចិត្តធនាគារពិភពលោកមិនឱ្យធ្វើប្រតិបត្តិការនៅក្នុងតំបន់ទីក្រុងឡើយ ទោះបីជាបទពិសោធន៍នេះស្នើឡើងថា ត្រូវយកចិត្តទុកដាក់ខ្លាំងនៅក្នុងការបង្កើតគម្រោង និងកម្មវិធីដែលងាយទទួលផលប៉ះពាល់នៅក្នុងបរិបទមូលដ្ឋានក៏ដោយ ។ ប្រការនេះអនុវត្តជាពិសេសចំពោះគម្រោងដែលពាក់ព័ន្ធនឹង ការកែលម្អប្រសិទ្ធភាព និងសមភាពនៃទីផ្សារដីធ្លី និងលំនៅដ្ឋាននៅក្នុងតំបន់នគរូបនីយកម្មឆាប់រហ័ស ។

**បញ្ហាប្រឈមនៃគម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល ។** ដូចដែលក្រុមអធិការកិច្ចបានកត់សម្គាល់នៅក្នុងរបាយការណ៍ថ្មីរបស់ខ្លួនស្តីពីប្រទេសប៉ាណាម៉ា - គម្រោងរដ្ឋបាលដីធ្លីផងដែរស្រាប់ ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចអំពីគម្រោងទាំងពីរនេះបានគូសបញ្ជាក់នូវហានិភ័យដែលទាក់ទងនឹងគម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល ដោយបង្ហាញថា គម្រោងដីធ្លីមានភាពស្មុគស្មាញ និងពិបាកក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព និងតែងតែមានលក្ខណៈអាចជជែករកខុសត្រូវបានខាងនយោបាយ ។ ការចូលរួមនាពេលអនាគតនៅក្នុងគម្រោងទាំងនេះនឹងទទួលបានពីការគាំទ្រផ្នែកបច្ចេកទេសដែលត្រូវបានពង្រឹង នូវការវិនិច្ឆ័យមានលក្ខណៈជាប្រព័ន្ធបន្ថែមទៀតនៃហានិភ័យខាងប្រតិបត្តិការ និងហានិភ័យដែលមានលក្ខណៈសេដ្ឋកិច្ចនយោបាយ ព្រមទាំងវិភាជន៍របស់បុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ និងធនធាន ។

**ការសង្កេតបន្ថែម ៖** ក្រុមអធិការកិច្ចសូមធ្វើការគូសបញ្ជាក់ថា ក្រុមអធិការកិច្ចចាត់ទុកថាការចូលរួមរបស់ធនាគារពិភពលោកទៅលើបញ្ហាដីធ្លីនៅក្នុងប្រទេសកម្ពុជា មានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការអភិវឌ្ឍរបស់ប្រទេស និងមានសង្គតភាពទៅនឹងទស្សនវិស័យអភិវឌ្ឍរយៈពេលវែងរបស់រាជរដ្ឋាភិបាល និងអាណត្តិការងារទូទៅរបស់ធនាគារពិភពលោក ក្នុងការកាត់បន្ថយភាពក្រីក្រ ។

នៅក្នុងបរិបទនេះ និងដោយមិនបន្ទាបសារៈសំខាន់នៃគំហើញរបស់ខ្លួន ក្រុមអធិការកិច្ចសូមកោតសរសើរចំពោះការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងទៅនឹងការស្នើសុំធ្វើអធិការកិច្ច និងការវាយតម្លៃដោយភាពស្មោះត្រង់របស់ថ្នាក់គ្រប់គ្រងទៅលើបញ្ហាខូចប្រយោជន៍ និងភាពអនុលោម ។ ក្រុមអធិការកិច្ចយល់ស្របទៅនឹងទស្សនៈរបស់ថ្នាក់គ្រប់គ្រងទៅលើបញ្ហាចម្បងនៃទំនាក់ទំនងរវាងគម្រោង និងការបណ្តេញប្រជាពលរដ្ឋចេញពីតំបន់បឹងកក់ ។ បន្ថែមពីនេះទៀត ក្រុមអធិការកិច្ចបានរកឃើញថា កម្រងសកម្មភាពបែបប្រតិសកម្ម ដែលថ្នាក់គ្រប់គ្រងបានអនុវត្តចាប់ពីខែមករា ឆ្នាំ២០០៩ រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ស្របទៅនឹងបទប្បញ្ញត្តិនៃគោលនយោបាយរបស់ធនាគារពិភពលោក ស្តីពីការត្រួតពិនិត្យគម្រោង ។ ជាពិសេសបេសកកម្មត្រួតពិនិត្យឡើងវិញសម្រាប់លើកកម្ពស់គម្រោង ដែលត្រូវបានអនុវត្តនៅក្នុងខែមិនា-មេសា ឆ្នាំ២០០៩ មានសារៈសំខាន់ណាស់ក្នុងការគូសបញ្ជាក់ទៅលើកង្វះខាតជាច្រើននៅក្នុងការរៀបចំគម្រោង ការអនុវត្តគម្រោង និងការត្រួតពិនិត្យគម្រោង ។ ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចបានបញ្ជាក់ទៅលើគំហើញ និងធ្វើឱ្យគំហើញកាន់តែមានភាពទូលំទូលាយសម្រាប់បេសកកម្មត្រួតពិនិត្យឡើងវិញសម្រាប់លើកកម្ពស់គម្រោង ។ ក្រុមអធិការកិច្ចសង្ឃឹមថា របាយការណ៍ស៊ើបអង្កេតនឹងរួមចំណែកដល់ការចាប់ផ្តើមនៃការចូលរួមថ្មីមួយ ជាមួយរាជរដ្ឋាភិបាលទៅលើការដោះស្រាយបញ្ហាដែលម្ចាស់សំណើបានលើកឡើង ។

ក្រុមអធិការកិច្ចជឿថា ករណីនេះគូសបញ្ជាក់អំពីតម្លៃនៃការមានមាគ៌ាឯករាជ្យនៃប្រភពជំនួយមួយ សម្រាប់ប្រជាជនដែលទទួលរងផលប៉ះពាល់ពីគម្រោង ។ ដូចមានរៀបរាប់នៅក្នុងរបាយការណ៍នេះ ការចូលរួមរបស់ម្ចាស់សំណើតាមរយៈដំណើរការរបស់ក្រុមអធិការកិច្ចបានបន្តឱ្យមាននូវការចូលរួមបែបប្រតិសកម្មមួយ ពីថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក និងនាំឱ្យឈានទៅដល់ការត្រួតពិនិត្យឡើងវិញប្រកបដោយភាពប្រុងប្រយ័ត្នទៅលើបញ្ហាធ្ងន់ធ្ងរនានា ដែលបានលើកឡើង ។ លើសពីនេះទៀត ក្នុងលក្ខណៈជាផ្នែកមួយនៃដំណើរការនេះ ថ្នាក់គ្រប់គ្រងបានធ្វើការត្រួតពិនិត្យឡើងវិញមួយតាមមូលដ្ឋាន និងបានកំណត់រកឃើញថា យ៉ាងហោចណាស់មានគ្រួសារចំនួន ២.៦០០គ្រួសារ ទៀត ដែលត្រូវបានបណ្តេញចេញ ឬប្រឈមទៅនឹងការបណ្តេញចេញនៅក្នុងតំបន់គម្រោង ។

# ជំពូក ១ : សំណើសុំចុះធ្វើអធិការកិច្ច ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង និង ដំណើរការអង្កេតតាមដាន

## ក. រចនាសម្ព័ន្ធនៃរបាយការណ៍

១. របាយការណ៍របស់ក្រុមអធិការកិច្ចចែកចេញជាបួនជំពូក។ ជំពូកនេះ ធ្វើការសង្ខេបពីការទាមទាររបស់ម្ចាស់សំណើ និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកទៅលើការទាមទារនេះ និងធ្វើការកត់សម្គាល់ពីដំណើរការអង្កេតតាមដាន និងសំណួរគន្លឹះរបស់ក្រុមអធិការកិច្ច ដែលគិតបញ្ចូលក្នុង និងទាក់ទងនឹងគោលនយោបាយធនាគារពិភពលោក។ ជំពូក២ បង្ហាញពីគម្រោងរៀបរាប់ពីបរិបទប្រវត្តិសាស្ត្រនៃបញ្ហាកម្មសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជា និងសង្ខេបជាចំនុចៗនូវព្រឹត្តិការណ៍ជុំវិញតំបន់បឹងកក់ (BKL) ដែលនាំឱ្យមានការស្នើសុំធ្វើអធិការកិច្ច។ តាមគោលនយោបាយនេះ ជំពូក ៣ បង្ហាញពីការវិភាគ និងលទ្ធផលស្រាវជ្រាវរបស់ក្រុមអធិការកិច្ច ស្តីពីការទាមទាររបស់ម្ចាស់សំណើ ហើយជំពូក៤ ធ្វើការបូកសរុបនូវការតាមដានតាមលំដាប់លំដោយ និងចុងក្រោយទាក់ទងនឹងបញ្ហាគោរពប្រតិបត្តិ និងបញ្ហាគ្រោះថ្នាក់ដែលបានត្រួតពិនិត្យ ក្នុងរបាយការណ៍នេះ។

## ខ. ការស្នើសុំឱ្យធ្វើអធិការកិច្ច

២. ម្ចាស់សំណើតំណាងឱ្យសហគមន៍ពីតំបន់បឹងកក់ក្នុងសង្កាត់ស្រះចក ក្រុងភ្នំពេញ។ ពាក្យ«តំបន់ស្រះចក» តំណាងឱ្យដីទំហំ១៣៣ ហិកតា រួមមានដីបឹង (ប្រហែល៩០ហិកតា) និងតំបន់ជុំវិញ ដែលក្នុងឆ្នាំ២០០៧ បានជួលឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ឯកជនមួយ។ ជារួម ពួកគេបានចោទថា សមាជិកនៃសហគមន៍ទាំងនេះទទួលរងនូវការខូចខាតជាទម្ងន់ ដែលផ្សារភ្ជាប់ទៅនឹងការរៀបចំអនុវត្តគម្រោង LMAP ហើយអះអាងថាក្តីបារម្ភរបស់ពួកគេត្រូវ ដោះស្រាយជាបន្ទាន់ ដើម្បីជៀសវាងការខូចខាតបន្តទៀត ។ ការទាមទារជាក់លាក់ដែលលើកឡើងក្នុងសំណើត្រូវបានសង្ខេបដូចខាងក្រោម។

៣. ផ្អែកតាមសំណើ អ្នករស់នៅតំបន់បឹងកក់ត្រូវបានបដិសេធចំពោះការវិនិច្ឆ័យទៅលើការទាមទារទ្រព្យសម្បត្តិរបស់ពួកគេក្រោមគម្រោង LMAP ។ សេចក្តីជូនដំណឹងមួយចេញផ្សាយថា សង្កាត់នេះនឹងក្លាយជាតំបន់កំណត់វិនិច្ឆ័យប្រើសម្រាប់គោលបំណងចុះបញ្ជីដីធ្លីក្រោមគម្រោង LMAP។ ដូច្នេះ អ្នករស់នៅសហគមន៍បឹងកក់ស្នើសុំថា ការទាមទារដីធ្លីរបស់ពួកគេ ត្រូវទទួលការស៊ើបអង្កេត ដូចដែលបានផ្តល់ឱ្យដោយនីតិវិធីច្បាប់បង្កើតឡើងក្រោម LMAP និងអនុម័តដោយរដ្ឋាភិបាលកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ម្ចាស់សំណើអះអាងថាពួក គេត្រូវបានបដិសេធនូវការអំពាវនាវឱ្យមានការស៊ើបអង្កេតក្នុងការទាមទារដីរបស់ពួកគេ ដែលដីទាំងនោះស្ថិតក្នុងតំបន់អភិវឌ្ឍន៍។ សំណើរបានរៀបរាប់ថា ក្នុងខែដដែល ឆ្នាំ២០០៧ ការកាត់ត្រាកំណត់ការវិនិច្ឆ័យមានបិទ ផ្សាយនៅសង្កាត់ កិច្ចសន្យាជួលត្រូវ

បានចុះហត្ថលេខារវាងក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន និងសាលាក្រុង ដោយរួម បញ្ចូលសង្កាត់ដែលម្ចាស់សំណើកំពុងរស់នៅ។

៤. ម្ចាស់សំណើក៏អះអាងដែរថា អ្នករស់នៅតំបន់បឹងកក់ត្រូវបានជម្លៀសចេញដោយមានការរំលោភបំពានទៅលើគោលនយោបាយព្រមព្រៀងសម្រាប់ការតាំងទីលំនៅថ្មីដោយពុំមានការស្ម័គ្រចិត្ត។ ពួកគេបន្តទៀតថា អ្នករស់នៅក្នុងសហគមន៍ទាំងនេះ ចាប់ផ្តើមប្រឈមនឹងសម្ពាធ និងការគម្រាមឱ្យចាកចេញពីតំបន់នេះនៅពេលដែលក្រុមហ៊ុនអភិវឌ្ឍន៍បានចាប់ផ្តើមដំណើរការក្នុងឆ្នាំ២០០៨ ហើយថានៅឆ្នាំបន្ទាប់ គ្រួសារជាច្រើនទទួល បានសេចក្តីជូនដំណឹងបណ្តេញចេញជាផ្លូវការដោយកំហិតក្នុងរយៈពេលមួយសប្តាហ៍ដើម្បីទទួលជម្រើសសំណងមួយក្នុងចំណោមបី។ ជម្រើសទាំងនេះមានៈ (១)សំណងរូបិយវត្ថុ (២)ការផ្លាស់ទៅទីតាំងថ្មី មានចម្ងាយ២០គីឡូម៉ែត្រ (៣)ការតាំងលំនៅនៅនឹងកន្លែង ជាបណ្តោះអាសន្ន ខណៈដែលកំពុងរង់ចាំបញ្ចប់ ការសាងសង់លំនៅដែលមានរយៈពេល៤ឆ្នាំ។ ពួកគេសង្កត់ធ្ងន់ថា គ្រួសាររាប់រយត្រូវបានបណ្តេញចេញពីដីរបស់ពួកគេ និងបង្ខំឱ្យទទួលយក "សំណងមិនគ្រប់គ្រាន់ក្រោមលក្ខខណ្ឌបង្ខិតបង្ខំ"។ ម្ចាស់សំណើតវ៉ាថា មិនថាមានកម្មសិទ្ធិដីធ្លីឬអត់ អ្នករស់នៅទីនោះត្រូវបាន និងកំពុងបន្តបានគេបណ្តេញចេញ ដោយបំពានខុសពី គោលនយោបាយសង្គម និងបរិស្ថានរបស់ធនាគារពិភពលោក ពោលគឺក្របខណ្ឌគោលនយោបាយ ស្តីពីការតាំងទីលំនៅឡើងវិញ (RPF) ដែលតម្រូវឱ្យអនុវត្តដោយកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ (DCA).

៥. លើសពីនេះទៀត ម្ចាស់សំណើអះអាងថា LMAP ដែលស្វែងរកការបង្កើតដំណើរការចុះបញ្ជីដីធ្លីជាលក្ខណៈផ្លូវការ និងប្រមូលផ្តុំបានបណ្តាលឱ្យសិទ្ធិអំណាចកាន់កាប់ដីធ្លីរបស់ម្ចាស់កម្មសិទ្ធិដីដើមថយចុះ។ សំណើបញ្ជាក់ថា "ដំណើរការកំណត់វិនិច្ឆ័យ [ទាក់ទងនឹងកិច្ចព្រមព្រៀងនៃការជួលរវាងសាលាក្រុង និងក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន] យ៉ាងហោចណាស់ បានបណ្តាលឱ្យមានការកំណត់តាមស្ថានភាពដីដែលជាដីរដ្ឋកាន់កាប់។"

៦. ជាចុងបញ្ចប់ ម្ចាស់សំណើអះអាងថា មិនត្រឹមតែនៅតំបន់បឹងកក់ តំបន់ក្នុងក្រុងផ្សេងៗទៀត និងសហគមន៍ជនជាតិដើមនៅទីជនបទទូទាំងកម្ពុជាមិនអាចប្រើសិទ្ធិដីធ្លី និង/ឬយន្តការដោះស្រាយជម្លោះគោរពតាមគម្រោង LMAP ឡើយ ហើយដូច្នេះ មិនអាចធានានូវសិទ្ធិកាន់កាប់ដីធ្លីក្រោមប្រព័ន្ធផ្លូវការបង្កើតឡើងដោយគម្រោង LMAP។ តាមរយៈម្ចាស់សំណើ សមាសធាតុរណបរបស់ LMAP មួយចំនួននៅតែខ្វះចន្លោះ ទោះជាបានអនុវត្តរយៈពេល៧ ឆ្នាំហើយក៏ដោយ។ ទាំងនេះរួមមាន ការចូលរួមរបស់សហគមន៍ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ (PACP) ជំនួយផ្លូវច្បាប់ និងយន្តការដោះស្រាយជម្លោះ ដូចដែលស្តែងចេញក្នុងគម្រោងដើម្បី ធានាថាសិទ្ធិរបស់ប្រជាជនដែលទទួលរងផលប៉ះពាល់ ត្រូវបានគោរព តាមរយៈដំណើរការចុះបញ្ជី និងកំណត់វិនិច្ឆ័យសិទ្ធិប្រើប្រាស់ព័ត៌មាន និងឱកាសចូលរួម។

៧. ម្ចាស់សំណើបញ្ជាក់ថា ពួកគេស្វាគមន៍ដល់កិច្ចខំប្រឹងប្រែងរបស់ធនាគារពិភពលោកចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០៩ ប៉ុន្តែកត់សម្គាល់ ថា "ផលអាក្រក់ដែលបណ្តាលមកពីការគ្រប់គ្រងគម្រោងមិនបានល្អគ្រប់គ្រាន់រយៈពេល ៧ ឆ្នាំ នៅមិនទាន់មានភាពធូរស្រាលនៅឡើយតាមរយៈកិច្ចប្រឹងប្រែងថ្មីៗរបស់ធនាគារពិភពលោក"។

៨. អ្នកដែលទទួលរងផលប៉ះពាល់មួយចំនួនជារឿយៗ បង្ហាញពីក្តីបារម្ភរបស់ពួកគេដោយពាក្យពេជន៍ពិតៗទៅលើ ក្រុមអធិការកិច្ចដោយផ្ទាល់។ ប្រអប់ទី១ បង្ហាញពីឧទាហរណ៍នៃសម្លេងគ្រួសារទទួលរងផលប៉ះពាល់។

## គ. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង

### ១. ការអង្កេតទូទៅ

៩. ក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង បានកត់សម្គាល់ថា តាមរយៈឯកសារវាយតម្លៃគម្រោង (PAD) "ការបណ្តេញការតាំងទីលំនៅថ្មីឡើងវិញដោយខ្វះការព្រមព្រៀង ឬការទទួលយកដី មិនត្រូវបានរំពឹងទុកក្នុងគម្រោងទេ"។ ប៉ុន្តែគេបានបន្ថែមទៀតថា DCA បានបញ្ជាក់ថា គម្រោង LMAP នឹងដាក់អនុវត្តតាមគោលនយោបាយសង្គម និងបរិស្ថានរបស់ធនាគារពិភពលោក រួមមានការអនុវត្ត RPF បន្ទាប់ពីការបណ្តេញចេញពីដីរដ្ឋ ដែលបណ្តាលមកពីសកម្មភាពផ្តល់ប្លង់ដីដែលមានលក្ខណៈជាប្រព័ន្ធ និងមិនទៀងទាត់ ។ ថ្នាក់គ្រប់គ្រង បានបញ្ជាក់ថា RPF នឹងដាក់ចេញការអនុវត្តនៅកន្លែងដែល *"(ក) មានការបណ្តេញចេញពីដីរដ្ឋចំពោះបុគ្គលដែលបានមករស់នៅទីនោះមុន ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលជា កាលបរិច្ឆេទនៃការអនុម័តច្បាប់ដីធ្លី ឆ្នាំ២០០១ បន្ទាប់ពីការផ្តល់កម្មសិទ្ធិដីបែបនេះក្នុងឈ្មោះរដ្ឋ (ខ) ការបណ្តេញចេញពីដីដែលបានផ្តល់កម្មសិទ្ធិក្នុងឈ្មោះរដ្ឋ ចំពោះបុគ្គលដែលបានរស់នៅ ទីនោះមុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដោយសារតម្រូវការប្រើប្រាស់ដីបែបនេះសម្រាប់ប្រើប្រាស់ក្នុងកិច្ចការស៊ីវិលតាមគម្រោង និង (គ) ការដែលរដ្ឋពន្យារពេលចំពោះការទាមទារសិទ្ធិចំណីផ្លូវ (ROW) ដែលបង្កឱ្យមាននូវផលប៉ះពាល់អវិជ្ជមាន ទៅលើសិទ្ធិកាន់កាប់។»*[២]

| **ប្រអប់ទី១: ឧទាហរណ៍នៃគ្រួសារមួយដែលរងផលប៉ះពាល់** |
| --- |
| គ្រួសាររបស់ខ្ញុំបានប្តូរទីលំនៅមកបឹងកក់នៅពេលដែលខ្ញុំនៅជាក្មេងតូចកាលពីឆ្នាំ ១៩៨២។ រហូតមកទល់ឆ្នាំមុន ខ្ញុំស្ទើរតែបានរស់នៅទីនោះពេញមួយជីវិតខ្ញុំ។ ឪពុករបស់ខ្ញុំ ធ្វើការនៅផ្លូវដែក ហើយក្រសួងសាធារណៈការ និងដឹកជញ្ជូនចង់ឱ្យបុគ្គលិកទាំងអស់រស់នៅជិតស្ថានីយហេតុនេះពួកគេបានស្នើឱ្យបុគ្គលិកគ្រប់រូបផ្លាស់ទីលំនៅទៅតាំង ទីនៅទីនោះ។ ផ្ទះរបស់យើងធ្លាប់ស្ថិតនៅលើបឹងពាក់កណ្តាលលើដីពាក់កណ្តាល។ យើងសង់វាដោយដៃយើងផ្ទាល់ ហើយយើងជឿជាក់ថា យើងជាម្ចាស់។ ខ្ញុំមាន ឯកសារបញ្ជាក់ពីការតាំងលំនៅរបស់យើង។ បន្ទាប់មកយើងទទួលបានដំណឹងថា រាជរដ្ឋាភិបាលបានជួលដីតំបន់នេះឱ្យទៅក្រុមហ៊ុនដែលបានរៀបចំគម្រោងអភិវឌ្ឍន៍ទីនេះ។ យើងចាប់ផ្តើមព្រួយបារម្ភ។ ពួកគេចេញជាលិខិតមួយប្រាប់យើងថា តំបន់នេះ នឹងត្រូវអភិវឌ្ឍ ហើយអ្នករស់នៅទីនេះ អស់សង្ឃឹម។ ពួកគេតែងតែគំរាមកំហែងប្រជាជន។ ជាទូទៅ ប៉ូលីស និងទាហានបានមកជាមួយពួកគេ។ ប៉ូលីសប្រដាប់ដោយអាវុធដែលជួលដោយក្រុមហ៊ុន ក៏ចុះមកសហគមន៍យើងដែរ។<br><br>ខ្ញុំធ្លាប់បានចូលរួមអង្គប្រជុំនៅសាលាខណ្ឌម្តង។ នៅអំឡុងពេលប្រជុំ អាជ្ញាធរលើកឡើងមិនឈប់ថា តំបន់នេះត្រូវបានជួល ហើយដូច្នេះអ្នកទាំងអស់គ្នា គួរតែជ្រើសរើសរវាងជម្រើសបីដែលមានសម្រាប់ពួកខ្លួន។ ប៉ុន្តែជម្រើសនៃការអភិវឌ្ឍនៅនឹងកន្លែងមិនមានភាព |

[២] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង, ¶៣១។

ច្បាស់លាស់សម្រាប់ពួកគេ ហើយអាជ្ញាធរនិយាយថា ប្រសិនពួកគេជ្រើសរើសជម្រើសនេះ ពួកគេនៅតែត្រូវទៅរស់នៅកន្លែងណាមួយផ្សេងទៀតសិន រយៈពេល ៣ ទៅ៥ឆ្នាំ។ គេប្រាប់យើងថា នៅពេលដែលក្រុមហ៊ុន បញ្ចប់ការអភិវឌ្ឍ យើងអាចត្រឡប់មករស់នៅវិញបាន។ ខ្ញុំ និងគ្រួសាររបស់ខ្ញុំ មិនជឿលើអាជ្ញាធរឡើយ ព្រោះយើងបានឃើញពីអ្វីដែលបានកើតឡើងលើសហគមន៍ផ្សេងៗ។ ប្រជាជនផ្តល់យោបល់ដល់អាជ្ញាធរមូលដ្ឋានថា ពួកគេអាចស្នាក់នៅក្នុងតំបន់នេះក្នុងអំឡុងពេលដំណើរការសាងសង់ ហើយរើទៅរស់នៅផ្ទះថ្មី នៅពេលការសាងសង់ចប់។ អាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនមិនបាន យល់ព្រមលើយោបល់នេះទេ។

បន្ទាប់មកពួកយើង ត្រូវបានបណ្តេញចេញ។ ប្រជាជន បានព្យាយាមស្នាក់នៅតំបន់នេះ ដូច្នេះអាជ្ញាធរមូលដ្ឋានបានបង្ខំឱ្យយើងចាកចេញ។ គ្រួសារខ្ញុំ គឺជាគ្រួសារចុងក្រោយដែលចាកចេញក្នុងសហគមន៍របស់យើង។ ចុងក្រោយ យើងក៏យល់ព្រមទទួល "សំណង"។ ប្រសិនបើយើង មិនចាកចេញដោយខ្លួនឯងទេ ពួកគេនឹងបញ្ជូនសមត្ថកិច្ចមកកម្ចាត់យើងចេញ។ ប្រជាជនមាន ការភ័យខ្លាចថា ប្រសិនបើពួកគេមិនរុះរើផ្ទះរបស់ពួកគេដោយខ្លួនឯងទេ ផ្ទះទាំងនេះនឹងត្រូវបំផ្លាញចោល ហើយពួកគេគ្មានអ្វីនៅសេសសល់ឡើយ។ យើងមានការភ័យខ្លាច ហើយបង្ខំចិត្តចាកចេញដើម្បីអាចរក្សាទុកទ្រព្យសម្បត្តិរបស់យើង។ ខ្ញុំមានអារម្មណ៍ក្រៀមក្រំពន់ពេកក្រៃក្នុងការរុះរើលំនៅដ្ឋានដែលខ្ញុំរស់នៅ ជិតមួយជីវិតរបស់ខ្ញុំ។ ខ្ញុំមានការខឹងសម្បាយ៉ាងខ្លាំង ចំពោះអាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុននេះ។

ជាមួយនឹងទឹកប្រាក់ ៨000 ដុល្លារសហរដ្ឋអាមេរិក ឪពុកម្តាយរបស់ខ្ញុំ បានទិញដីនៅចោមចៅជាយក្រុងភ្នំពេញ។ ខ្ញុំមិនបាន ឃើញពួកគេញ៉ឹកញាប់ដូចពីមុនឡើយ។ កាលពីមុន យើងធ្លាប់រស់នៅយ៉ាងមានសុភមង្គល។ ឥឡូវមនុស្សជាច្រើនដែលស្និទ្ធស្នាលនឹងខ្ញុំ រស់នៅឆ្ងាយពីខ្ញុំ។ ផ្ទះដែលឪពុកម្តាយខ្ញុំរស់នៅពុំមែនជាជម្រើសសម្រាប់ពួកយើងទេ ពីព្រោះវានៅឆ្ងាយ ហើយក្មេងៗទាំងអស់រៀននៅឯទីក្រុង។ ហើយ នៅទីនោះក៏គ្មានមណ្ឌលសុខភាពទៀតផង។

បច្ចុប្បន្ន ខ្ញុំជួលបន្ទប់តូចមួយ ៣៥ ដុល្លារ ក្នុងមួយខែ។ ខ្ញុំរស់នៅជាមួយប្រពន្ធខ្ញុំ។ មនុស្សជាច្រើនផ្សេងទៀតពីភូមិរបស់ខ្ញុំក៏រើ មកជួលផ្ទះនៅទីនេះដែរ។ ពីមុននៅពេលយើងមានផ្ទះផ្ទាល់ខ្លួន យើងមិនចាំបាច់បង់ថ្លៃជួលផ្ទះឡើយ។ ប៉ុន្តែឥឡូវយើងត្រូវបង់ឈ្នួលផ្ទះ បន្ថែមពីលើការចំណាយគ្រប់យ៉ាង។

១០. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងបានកត់សម្គាល់បន្ថែមទៀតថា ផ្អែកតាម PAD *"គម្រោងនឹងមិនផ្តល់កម្មសិទ្ធិដីធ្លីនៅតំបន់ដែលជម្លោះទំនងជាកើតឡើងរហូតដល់មានការព្រមព្រៀងគ្នាពីស្ថានភាពកម្មសិទ្ធិដី"*[៣] លើសពីនេះ កម្មវិធីផ្តល់កម្មសិទ្ធិក្រោមគម្រោងនេះមានចែងថា មិនរួមបញ្ចូលអ្នកតាំងទីលំនៅមិនផ្លូវការ ឬ "អ្នកតាំងលំនៅខុសច្បាប់" លើដីរដ្ឋ ពីព្រោះគម្រោងនេះមិនបានគិតពីការរៀបចំការតាំងលំនៅមិន ផ្លូវការបែបនេះទេ។[៤]

១១. ថ្នាក់គ្រប់គ្រងជំទាស់ថាគម្រោង LMAP បានបង្កើតឱ្យមាននូវ *"ផលប្រយោជន៍អភិវឌ្ឍន៍គួរឱ្យកត់សម្គាល់"* ខណៈវាជួយដល់ការស្ថាបនាប្រព័ន្ធរដ្ឋបាលដីធ្លីជឿនលឿន ដោយផ្តួចផ្តើមគំនិតចុះបញ្ជី និងការផ្តល់កម្មសិទ្ធិដែលចំណាយតិចចំពោះក្បាលដីមានចំនួនច្រើនជាងមួយលាន។ យ៉ាងណាមិញ ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា កង្វះវិធីសាស្ត្រប្រមូលទិន្នន័យ និងស្ថិតិពាក់ព័ន្ធទាំងឡាយបានរាំងស្ទះដល់ការវាស់វែងត្រឹមត្រូវនៃការកែលម្អសុវត្ថិភាពកាន់កាប់ដីធ្លី។

[៣] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ¶៣៥។

[៤] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង¶៣៦។

## ២. ការឆ្លើយតបនៅនឹងសំណើចុះអធិការកិច្ច

១២. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងថ្លែងថា សង្កាត់ស្រះចកក្នុងទីក្រុងភ្នំពេញត្រូវបានប្រកាសថា ជាតំបន់កំណត់វិនិច្ឆ័យ "ក្នុងខែឧសភា ឆ្នាំ ២០០៦"[៥] និងក្រោយមកត្រូវកំណត់ព្រំដែនជាមួយនឹងលទ្ធផលផ្សាយ ជាសាធារណៈក្នុងខែ មករា/កុម្ភៈ ឆ្នាំ ២០០៧។ ថ្វីបើមានទីតាំងនៅក្នុងសង្កាត់ស្រះចក តំបន់បឹងកក់ គឺមិនបានរួមបញ្ចូលក្នុងការកំណត់ព្រំដែនទេ។ មូលហេតុដែលផ្តល់ជូន គឺថាសាលាក្រុងភ្នំពេញ (MPP) បានប្រកាសថា តំបន់បឹងកក់ គឺជាដីសាធារណៈរបស់រដ្ឋ ហើយថាច្បាប់ដីធ្លីមិនអនុញ្ញាតឱ្យមានសិទ្ធិកាន់កាប់ ដីសាធារណៈរបស់រដ្ឋឡើយ។

១៣. ថ្នាក់គ្រប់គ្រងកត់សម្គាល់ថា ទោះជាមានការអះអាងថាតំបន់បឹងកក់ជាដីសាធារណៈរបស់រដ្ឋ គម្រោងសម្រាប់ការអភិវឌ្ឍបែបឯកជននៃតំបន់នេះ បានចាប់ផ្តើមក្នុងឆ្នាំ២០០៥ ហើយឈានដល់កម្រិតកំពូលក្នុង ខែ កុម្ភៈឆ្នាំ ២០០៧ ដោយមានការចុះហត្ថលេខាលើកិច្ចសន្យាជួលតំបន់បឹងកក់រយៈពេល ៩៩ ឆ្នាំ រវាងសាលា ក្រុង និងក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន។ ក្នុងខែ សីហា ឆ្នាំ ២០០៨ សាលាក្រុងចេញអនុក្រឹតផ្ទេរតំបន់នេះពីដី សាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ។ ថ្នាក់គ្រប់គ្រងថាអ្នករស់នៅក្នុងតំបន់តម្រូវប្រាប់ឱ្យរើទីលំនៅ និងផ្តល់ជម្រើសមួយក្នុងចំណោមបីដើម្បីទទួលយកបន្ទាប់ពីកាលកំណត់សម្រាប់រើទីលំនៅផុតកំណត់។ ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា ចាប់ពីខែ សីហា ឆ្នាំ ២០០៨មក "មានសម្ពាធបន្ថែមទៅលើការរើទីលំនៅ" មកលើអ្នករស់នៅក្នុងតំបន់នៅពេលក្រុមហ៊ុនអភិវឌ្ឍន៍បានចាប់ផ្តើមចាក់បំពេញបឹង អាស្រ័យហេតុនេះបង្កឱ្យមានការខូចខាតរចនាសម្ព័ន្ធ និងជន់លិចលំនៅដ្ឋានក្បែរនោះ។[៦] ហេតុនេះ ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា អ្នករស់នៅតំបន់បឹងកក់ត្រូវបដិសេធន៍ចោលនូវឱកាសដាក់បង្ហាញបណ្តឹងទាមទារដីកម្មសិទ្ធិរបស់ពួកគេ។ ថ្នាក់គ្រប់គ្រងក៏ប្រាប់ដែរថា "គ្មានភស្តុតាងឯណាស្តីអំពីដំណើរការប្រកបដោយតម្លាភាព ការចូលរួម និងការពិនិត្យឡើងវិញ ត្រូវបានប្រើប្រាស់ក្នុងការកំណត់ចំណាត់ថ្នាក់នៃដីជាដីសាធារណៈរដ្ឋឡើយ"។[៧]

១៤. ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា សង្កាត់ស្រះចកជាតំបន់កំណត់វិនិច្ឆ័យ ដែលការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ ត្រូវបានអនុវត្ត ហើយទោះជាគ្មានសិទ្ធិផ្លូវការណាចំពោះរដ្ឋត្រូវបានចេញ ការជួលដីដែលចុះហត្ថលេខាជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន អាចចាត់ទុកជាការកំណត់តាមការជាក់ស្តែងនៃដីដែលជាដីសាធារណៈរបស់រដ្ឋ។ ថ្នាក់គ្រប់គ្រងសន្និដ្ឋានក្នុងការឆ្លើយតបរបស់ខ្លួនថា ដូចនេះលក្ខខ្ខិកៈសម្រាប់ការអនុវត្តនៃ RPF ដូចដែលកំណត់នៅក្នុង DCA អាចបំពេញបាន ហើយដោយហេតុនេះ RPFគួរតែត្រូវបានយកមកប្រើប្រាស់។

១៥. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងកត់សម្គាល់ថា បេសកកម្មពិនិត្យឡើងវិញសម្រាប់លើកកម្ពស់គម្រោង (ERM) មួយត្រូវបានអនុវត្តក្នុងខែ មេសា ឆ្នាំ ២០០៩ ដែលទទួលសារភាពថា ភាពខ្វះខាតក្នុងការរៀបចំ និងការអនុវត្ត

[៥] នៅក្នុងការស៊ើបអង្កេត ក្រុមអធិការកិច្ចទទួលបានច្បាប់ចម្លងនៃសេចក្តីជូនដំណឹង ដែលចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០០៦។

[៦] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង¶៤៨។

[៧] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង¶៥០។

គម្រោង LMAP បានបណ្តាលឱ្យមានការកាត់ផ្តាច់រវាង ការចេញកម្មសិទ្ធិដីធ្លីតាមគម្រោង និងការបន្តកើតឡើងគ្រោះថ្នាក់ក្នុងការទទួលបានកម្មសិទ្ធិដីធ្លីរបស់អ្នកក្រ។ ERM ក៏បានរាយការណ៍ផងដែរថា អាជ្ញាធរមូលដ្ឋានកំពុងតែបដិសេធ ដីក្នុងតំបន់កំណត់ វិនិច្ឆ័យពីការទទួលបានកម្មសិទ្ធិដោយមិនគោរពតាមនីតិវិធីត្រឹមត្រូវដូចជាការអនុញ្ញាតឱ្យទទួលបានព័ត៌មាន និងយន្តការដោះស្រាយវិវាទ។

១៦. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងបញ្ជាក់ថា អនុប្រធានប្រចាំតំបន់របស់ធនាគារពិភពលោក (RVP) បានមកកាន់ទីក្រុងភ្នំពេញដើម្បី ជួបជាមួយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ក្នុងខែ សីហា ឆ្នាំ ២០០៩។ អនុប្រធានប្រចាំតំបន់នេះអះអាងជាថ្មី នូវសំណើព្យួរទុក បណ្តោះអាសន្ននៃការបណ្តេញចេញ ដែលផ្តល់ជូនដើម្បីចែកចាយធនធានធនាគារពិភពលោកសម្រាប់ការតាំងទីលំនៅថ្មីរបស់អ្នករស់នៅក្នុងតំបន់បឹងកក់ ហើយបានស្នើឱ្យមានការព្យួររួមគ្នាមួយនៃគម្រោងខណៈពេលក្របខ័ណ្ឌគោលនយោបាយជាតិត្រូវបានកែលម្អ។ បើទោះជាដូច្នេះក្តី រាជរដ្ឋាភិបាលកម្ពុជាបានស្នើឱ្យលុបចោលប្រាក់ឥណទានទៅសេសសល់ដែល មិនទាន់បានដក នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

## ៣. ច្រកចេញពិសេស និងផែនការសកម្មភាព

១៧. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងសង្ខេបជាចំនុច៧នូវកិច្ចប្រឹងប្រែងបន្តបន្ទាប់ ដើម្បីដោះស្រាយក្តីបារម្ភរបស់ម្ចាស់សំណើ ទោះជាមានការលុបចោលនូវកម្ចីដោយរដ្ឋាភិបាលក៏ដោយ។ ថ្នាក់គ្រប់គ្រងសង្កត់ធ្ងន់ពីសារៈសំខាន់នៃកិច្ចសហការ ជាមួយរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ផ្សេងទៀតក្នុងការដោះស្រាយក្តីបារម្ភរបស់ម្ចាស់សំណើដោយថ្លែងថា:

> *វានឹងធ្វើការជាមួយរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍទៅលើការធានាថា សហគមន៍ដែលតាំងទីថ្មីពីតំបន់បឹងកក់ នឹងទទួលបានការគាំពារក្នុងលក្ខណៈមួយដែលស្របគ្នានឹងក្របខណ្ឌគោលនយោបាយតាំងទីលំនៅថ្មីឡើងវិញ ហើយវានឹងបន្តជួយរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍក្នុងការធានាថាសហគមន៍ដែលត្រូវតាំងទីថ្មីនៅពេលអនាគតនឹងទទួល បានប្រយោជន៍ពីគោលនយោបាយតាំងទីលំនៅថ្មីមួយដែលបំពេញតាមបទដ្ឋានសមរម្យ និងចេញពីយន្តការដោះស្រាយជម្លោះឯករាជ្យ និងយុត្តិធម៌។*

១៨. កិច្ចប្រឹងប្រែងដាក់ស្នើដោយថ្នាក់គ្រប់គ្រងក្នុងការឆ្លើយតបមានរួមបញ្ចូលការវាយតម្លៃផលប៉ះពាល់ផ្នែកសង្គមនៃការតាំងទីលំនៅថ្មីទៅលើសហគមន៍ទទួលរងផលប៉ះពាល់ ការធានាថាប្រជាជនទទួលបានការគាំពារជាមូលដ្ឋានដូចគ្នាដែរ ដែល RPF បានអនុវត្តដើម្បីបង្កើនឱកាសសម្រាប់សង្គម និងសេដ្ឋកិច្ច ការដោះស្រាយកង្វល់ទាក់ទងនឹងស្ថានភាពរស់នៅ និងឱកាសរកស៊ីចិញ្ចឹមជីវិតនៅក្នុង និងជុំវិញតំបន់តាំងទីលំនៅថ្មី ការលើកទឹកចិត្តរដ្ឋាភិបាលឱ្យកាត់បន្ថយផលប៉ះពាល់បរិស្ថានក្នុងការចាក់បំពេញបឹងកក់ ការកែលម្អយន្តការដោះស្រាយជម្លោះដែលមាន និងសមត្ថភាពរបស់សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការប្រើប្រាស់យន្តការទាំងនេះ ជួយរដ្ឋាភិបាលឱ្យចូលរួមបញ្ចប់ក្របខណ្ឌគោលនយោបាយតាំងទីលំនៅថ្មីជាតិមួយ ការផ្តួចផ្តើមដំណើរការពិគ្រោះយោបល់ ដើម្បីកំណត់ឡើងវិញនូវតួនាទីរបស់ធនាគារពិភពលោកក្នុងប្រទេស កម្ពុជា និងដើម្បីកំណត់តំបន់ទទួលការគាំពារ និងសហប្រតិបត្តិការជាមួយរដ្ឋាភិបាលទាក់ទងនឹងយុទ្ធសាស្ត្រផ្តល់ជំនួយសម្រាប់ប្រទេស (CAS)។

## ឃ. ដំណើរការអង្កេតតាមដាន

### ១. របាយការណ៍បំពេញលក្ខខណ្ឌដំបូង និងលក្ខខណ្ឌបំពេញនៃសំណើរបស់ក្រុមអធិការកិច្ច

១៩. ដូចដែលបានបង្កើតឡើងក្នុងសេចក្ដីសម្រេចខាងដើម ក្រុមអធិការកិច្ចបានកំណត់ថា តើសំណើសុំអធិការកិច្ចបំពេញតាមលក្ខន្តិកៈដែលមានចែងក្នុងសេចក្ដីសម្រេច និងក្នុងការបំភ្លឺបន្តបន្ទាប់ក្នុងឆ្នាំ ១៩៩៩ បានគ្រប់គ្រាន់ដែរឬទេ។

២០. ដើម្បីធ្វើការកំណត់បែបនេះ ក្រុមអធិការកិច្ចត្រួតពិនិត្យឡើងវិញនូវសំណើ និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ហើយធ្វើការចុះដល់តំបន់គម្រោង។ ក្រុមរបស់ក្រុមអធិការកិច្ចមួយបានមកកាន់កម្ពុជាក្នុងចន្លោះថ្ងៃទី ១៦ ដល់ ១៩ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងអំឡុងពេលពួកគេស្នាក់នៅទីនេះ ក្រុមរបស់ក្រុមអធិការកិច្ចនេះបានជួបជាមួយអង្គការតំណាងម្ចាស់សំណើហត្ថលេខីនៃសំណើចុះអធិការកិច្ច និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ទាំងឡាយ អង្គការមិនមែនរដ្ឋាភិបាលដែលដំណើរការនៅកម្ពុជា មន្ត្រីរដ្ឋាភិបាល ថ្នាក់គ្រប់គ្រងធនាគារពិភពលោកនៅកម្ពុជា បុគ្គលិកធនាគារពិភពលោកដទៃទៀត ព្រមទាំងតំណាងដៃគូរសហការណ៍របស់ធនគារពិភពលោក និងម្ចាស់ជំនួយផ្សេងទៀត។ ក្រុមអធិការកិច្ចក៏បានចុះទៅមើលសហគមន៍ដែលម្ចាស់សំណើរស់នៅ និងកន្លែងតាំងទីលំនៅថ្មីដែលប្រជាពលរដ្ឋទទួលរងផលប៉ះពាល់មួយចំនួន ដែលបានជ្រើសរើសជម្រើសផ្លាស់ទីលំនៅកំពុងរស់នៅ។

២១. ថ្នាក់គ្រប់គ្រងបានបង្ហាញពីការតាំងចិត្តរបស់ខ្លួនក្នុងការផ្ដួចផ្ដើមកិច្ចពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ដទៃទៀតក្នុងបំណងបង្កើតសកម្មភាពច្បាស់លាស់ ដើម្បីដោះស្រាយក្ដីកង្វល់នៃសហគមន៍ដែលប្រឈមនឹងការបណ្ដេញចេញ និងការតាំងទីលំនៅថ្មីដោយខ្វះការព្រមព្រៀង។ ផ្អែកតាមការបង្ហាញនេះ និងដើម្បីយុត្តិធម៌សម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ក្រុមអធិការកិច្ចបានសម្រេចជៀសវាងការបញ្ចប់មុខងាររបស់ខ្លួននៅពេលនោះថា តើបញ្ហានៃការខូចខាត និងការមិនគោរពតាមដែលលើកឡើងក្នុងសំណើសមនឹងនាំឱ្យមានការស៊ើបអង្កេតឬអត់។

២២. ក្រុមអធិការកិច្ចបានកំណត់ក្នុងរបាយការណ៍ និងអនុសាសន៍របស់ខ្លួន ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០០៩ ថាសំណើបំពេញទៅតាមលក្ខន្តិកៈសម្រាប់ការចុះអធិការកិច្ច។ ប៉ុន្តែ ក្រុមអធិការកិច្ចផ្ដល់អនុសាសន៍ដល់គណៈនាយកប្រតិបត្តិថា ខ្លួនយល់ព្រមតាមសំណើរបស់ក្រុមអធិការកិច្ចក្នុងការបញ្ចៀសឱ្យផុតពីការចេញអនុសាសន៍ក្នុងពេលនោះថាតើអធិការកិច្ចប្រាកដជានឹងអនុវត្ត តែបែរជារង់ចាំដំណើការបន្តទៀត ជាពិសេសដោយសារថ្នាក់គ្រប់គ្រងកំពុងព្យាយាមបង្កើតកិច្ចពិភាក្សាជាមួយរដ្ឋាភិបាលដើម្បីដោះស្រាយកង្វល់នៃម្ចាស់សំណើ។ ដោយពិចារណាទៅលើភាពបន្ទាន់នៃស្ថានភាព ក្រុមអធិការកិច្ចយល់ព្រមធ្វើសេចក្ដីសម្រេចចុងក្រោយមុនថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ២០០១ ថាតើគួរផ្ដល់អនុសាសន៍ឱ្យមានអធិការកិច្ចដែរឬទេ។

២៣. គណៈនាយកអនុម័តអនុសាសន៍របស់ក្រុមអធិការកិច្ចនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៩ ក្រោមមូលដ្ឋាននៃការមិនជំទាស់។

## ២. របាយការណ៍បំពេញលក្ខខណ្ឌចុងក្រោយ

២៤. បន្ទាប់ពីប្រគល់របាយការណ៍បំពេញលក្ខខណ្ឌទីមួយ ក្រុមអធិការកិច្ចនៅតែបន្តទំនាក់ទំនងជាមួយថ្នាក់គ្រប់គ្រង និង តំណាងនៃម្ចាស់សំណើពីការអភិវឌ្ឍក្នុងប្រទេសកម្ពុជាទាក់ទងនឹងស្ថានភាពម្ចាស់សំណើ និងកិច្ចប្រឹងប្រែងរបស់ធនាគារពិភពលោក ដើម្បីដោះស្រាយកង្វល់របស់ពួកគេ។

២៥. ថ្នាក់គ្រប់គ្រងបានប្រាប់ទៅក្រុមអធិការកិច្ច ថាខ្លួនបានផ្តួចផ្តើមកិច្ចពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជា និងកត់សម្គាល់ពីការប្តេជ្ញាចិត្ត និងសន្ទុះជម្រុញក្នុងការពង្រឹងគោលនយោបាយតាំងទីលំនៅថ្មីឡើងវិញរបស់ប្រទេសនេះ។ ទោះបីយ៉ាងណា ទាំងថ្នាក់គ្រប់គ្រង ទាំងអ្នកតំណាងនៃម្ចាស់សំណើចង្អុលបង្ហាញថាគ្មានដំណើរការណាបានធ្វើឡើងច្បាស់លាស់ឡើយ ដើម្បីអនុវត្តសកម្មភាពជាក់លាក់ ដែលធានាថា "*សហគមន៍ដែលតាំងទីថ្មីពីតំបន់បឹងកក់ នឹងទទួលការគាំពារក្នុងលក្ខណៈមួយដែលស្របគ្នានឹងក្របខណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញដែលបានព្រមព្រៀង*"។[៨]

២៦. ក្រុមអធិការកិច្ចកត់សម្គាល់ថា សកម្មភាពបានអនុវត្តក្នុងលក្ខណៈមួយ ដែលអាចដោះស្រាយកង្វល់របស់ម្ចាស់សំណើបានគ្រប់គ្រាន់។ ថ្វីបើបានរួមបញ្ចូលជាសកម្មភាពជាក់ស្តែងក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ក្រុមអធិការកិច្ចមិនអាចបញ្ជាក់បានថា មានដំណើរការក្នុងការវាយតម្លៃផលប៉ះពាល់សង្គមនៃសហគមន៍បឹងកក់ ដែលតាមរយៈម្ចាស់សំណើ អាចបង្កើតជាជំហានបន្តក្នុងការដោះស្រាយកង្វល់របស់ពួកគេបានទេ។ ក្រុមអធិការកិច្ចត្រូវបានប្រាប់ឱ្យដឹងថា ស្ថានភាពរបស់ម្ចាស់សំណើភាគច្រើននៅដដែរក្នុងពេលប្រគល់សំណើសុំចុះអធិការកិច្ចរបស់ពួកគេក្នុងខែ កញ្ញា ឆ្នាំ ២០០៩ និងការមកកាន់កម្ពុជារបស់ក្រុមអធិការកិច្ចនៅខែ វិច្ឆិការ ឆ្នាំ២០០៩។

២៧. ក្រុមអធិការកិច្ចបានប្រគល់របាយការណ៍បំពេញលក្ខខណ្ឌចុងក្រោយនៅថ្ងៃទី ៣១ ខែ មិនា ឆ្នាំ២០១០។ ដើម្បីឱ្យស្របជាមួយរបាយការណ៍បំពេញលក្ខខណ្ឌ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០០៩ ក្រុមអធិការកិច្ចកំណត់ថា សំណើបំពេញទៅតាមតម្រូវការលក្ខខណ្ឌសម្រាប់ការចុះអធិការកិច្ច។ ក្រុមអធិការកិច្ចបានផ្តល់អនុសាសន៍ថា គណៈនាយកប្រតិបត្តិអនុញ្ញាតឱ្យមានការស៊ើបអង្កេតចំពោះកង្វល់ដែលលើកឡើងក្នុងសំណើ ដោយដកស្រង់យកបញ្ហាសំខាន់៧នៃការគោរពតាម និងការខូចខាតលើកឡើងដោយម្ចាស់សំណើ ដែលគ្រាន់តែអាចធ្វើការវាយតម្លៃបានជាផ្នែកនៃការស៊ើបអង្កេតប៉ុណ្ណោះ។

២៨. នៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០១០ គណៈនាយកប្រតិបត្តិអនុម័តអនុសាសន៍របស់ក្រុមអធិការកិច្ចសម្រាប់ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចមួយ ក្រោមមូលដ្ឋាននៃការមិនជំទាស់។

## ៣. វិធីសាស្ត្រស៊ើបអង្កេត

[៨] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង¶៧៦

២៩. ការផ្តោតសំខាន់នៃការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ច គឺការកំណត់ ថាតើធនាគារពិភពលោកបានអនុលោមទៅតាមគោលនយោបាយ និងនិតិវិធីរបស់ខ្លួនដែរឬទេ ក្នុងការរៀបចំវាយតម្លៃ និងអនុវត្តគម្រោង LMAP ហើយ ថាតើប្រសិនបើមានការមិនអនុលោមណាមួយត្រូវបានរកឃើញ នោះវានឹងបង្កឬក៏ទំនងជានឹងបង្កការខូចខាត ដែលបានពោលអះអាង ដោយម្ចាស់សំណើសម្រាប់ការស៊ើបអង្កេត ដែរឬទេ។

៣០. ក្រុមអធិការកិច្ចបានធ្វើការស៊ើបអង្កេតដែលចែកជាពីរផ្នែកមួយដឹកនាំដោយសមាជិកក្រុមអធិការកិច្ច Alf Jerve ដែលជាអ្នកដើរតួជាអធិការនាំមុខសម្រាប់ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ច។ ផ្នែកទីមួយពាក់ព័ន្ធនឹងការស្រាវជ្រាវលម្អិតក្នុងកំណត់ត្រាធនាគារពិភពលោកទាក់ទងនឹងគម្រោង និងការត្រួតពិនិត្យធំទូលាយនៃឯកសារគម្រោងដែលពាក់ព័ន្ធ។ ផ្នែកទីពីរតម្រូវឱ្យមានការស្វែងរកព័ត៌មានពិត ដែលចុះទៅដល់តំបន់អនុវត្តគម្រោង និងសម្ភាសន៍ជាមួយបុគ្គលិកពាក់ព័ន្ធក្នុងគម្រោង។ ក្រុមអធិការកិច្ចបានចាត់ឱ្យ Geoffrey K. Payne ទីប្រឹក្សាផ្នែកអភិវឌ្ឍន៍ទីក្រុង និងលំនៅដ្ឋានដែលមានបទពិសោធន៍ និងចំណេះដឹងទូលំទូលាយក្នុងបញ្ហាអភិវឌ្ឍន៍ និងដីក្រុងនៅកម្ពុជា ជួយដល់ការស៊ើបអង្កេត។

៣១. ក្រុមអធិការកិច្ចដែលមានប្រធានក្រុមអធិការកិច្ច លោក Roberto Lenton សមាជិកគណៈកម្មាធិការ លោក Alf Jerve អនុលេខាប្រតិបត្តិ Dilek Barlas និងទីប្រឹក្សាជំនាញការ លោក Geoffrey K. Payne បានមកកាន់ទីក្រុងភ្នំពេញ ប្រទេសកម្ពុជាក្នុងចន្លោះថ្ងៃទី ២២ ដល់ ២៧ ខែ ឧសភា ឆ្នាំ២០១០។ ទីប្រឹក្សា របស់ក្រុមអធិការកិច្ច លោក Geoffrey K. Payne បានបន្តការស្នាក់នៅរបស់លោករហូតដល់ថ្ងៃទី ២៩ ខែ ឧសភា ដើម្បីចុះមើលទីតាំងនៃការតាំងលំនៅថ្មី និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ដែលបានជ្រើសរើសជម្រើសផ្លាស់លំនៅ។ ក្នុងអំឡុងពេលទស្សនកិច្ច ក្រុមអធិការកិច្ចបានជួបជាមួយមន្ត្រីរដ្ឋាភិបាល បុគ្គលិកធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា និងសមាជិកសង្គមស៊ីវិលដែលចាប់អារម្មណ៍ទៅលើបញ្ហាអង្កេតតាមដាននេះ។

៣២. ក្នុងអំឡុងពេលស៊ើបអង្កេត ក្រុមអធិការកិច្ចបានកំណត់ និងពិនិត្យឡើងវិញយ៉ាងយកចិត្តទុកដាក់រាល់ឯកសារទាក់ទងនឹងករណីដែលម្ចាស់សំណើ បុគ្គលិកធនាគារពិភពលោក និងប្រភពផ្សេងទៀត បានផ្តល់ជូនក្រុមអធិការកិច្ច។ ក្រុមអធិការកិច្ច ក៏បានវិភាគទៅលើភស្តុតាងផ្សេងទៀតដែលប្រមូលបានក្នុងពេលចុះដល់កន្លែង ឬបើមិនដូច្នោះទេ ក្នុងការស្រាវជ្រាវរបស់ខ្លួន ក្រុមអធិការកិច្ចបានពិនិត្យឡើងវិញនូវការទាមទារលើកឡើងនៅក្នុងសំណើ ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះការទាមទារទាំងនេះ និងគោលនយោបាយប្រតិបត្តិដែលពាក់ព័ន្ធរបស់ធនាគារពិភពលោក។

៣៣. របាយការណ៍នេះបង្ហាញពីលទ្ធផលនៃការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចទាក់ទងនឹងបញ្ហាលើកឡើងដោយម្ចាស់សំណើក្នុងសំណើសុំចុះអធិការកិច្ច។

៣៤. **សំណួរគន្លឹះសម្រាប់ការស៊ើបអង្កេត** ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចទៅលើការទាមទាររបស់ម្ចាស់សំណើ និងបញ្ហាពាក់ព័ន្ធនៃការគោរពតាមដោយផ្តោតទៅលើសំណួរសំខាន់៧ខាងក្រោម ដែលត្រូវបានពិចារណាលម្អិតក្នុង

ជំពូក៣:

ក. តើមានទំនាក់ទំនងរវាងការបណ្តេញប្រជាពលរដ្ឋចេញពីតំបន់បឹងកក់ និងគម្រោង ដូចដែលម្ចាស់សំណើបានអះអាង ដែរឬទេ?

ខ. តើប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បឹងកក់ ត្រូវបានបដិសេធចំពោះការវិនិច្ឆ័យ ទៅលើការទាមទារអចលនទ្រព្យរបស់ពួកគេដែរឬទេ? តើភាពមិនច្បាស់លាស់នៅក្នុងការរៀបចំគម្រោងរួមចំណែកបណ្តាលឱ្យខ្វះការវិនិច្ឆ័យទៅលើការអះអាងទ្រព្យសម្បត្តិនៅក្នុងតំបន់បឹងកក់ ដែរឬទេ? តើការត្រួតពិនិត្យគម្រោងជួយដោះស្រាយបញ្ហាដែលម្ចាស់សំណើបានលើកឡើងគ្រប់គ្រាន់ដែរឬទេ?

គ. តើកង្វះនៃការអនុវត្ត RPF សម្រាប់តំបន់បឹងកក់ ស្របទៅនឹងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ដែរឬទេ? តើកង្វះនៃការអនុវត្តនេះ បណ្តាលមកពីចន្លោះប្រហោងនៅក្នុងការរៀបចំ RPF ឬ? តើកត្តានេះ បង្កឱ្យមាននូវផលប៉ះពាល់អវិជ្ជមានទៅលើម្ចាស់សំណើ ដែរឬទេ?

ឃ. តើដំណើរការផ្តល់ប្លង់ដីដែលគម្រោង LMAP បានជ្រើសរើសយកមកប្រើប្រាស់ ធ្វើឱ្យចុះខ្សោយសិទ្ធិកាន់កាប់ដីធ្លីពីមុនដែលមានស្រាប់របស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់វិនិច្ឆ័យគម្រោង LMAP ដែរឬទេ? តើគម្រោងបានបញ្ចូលប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយមួយ ទៅលើផលប៉ះពាល់នៃសកម្មភាពគម្រោង ចំពោះក្រុមប្រជាជនក្រីក្រ និងក្រុមដែលបាត់បង់ប្រយោជន៍ដទៃទៀត ដែរឬទេ?

ង. តើមានសហគមន៍ដទៃទៀត ដែលទទួលរងផលប៉ះពាល់អវិជ្ជមាននៅក្នុងតំបន់ដែលគ្របដណ្តប់ដោយគម្រោង ដែរឬទេ? តើការរៀបចំគម្រោងបានលើកឡើងគ្រប់គ្រាន់អំពីហានិភ័យនៃការបង្ខំបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន ដែរឬទេ?

## ៤. គោលនយោបាយរបស់ធនាគារពិភពលោកដែលពាក់ព័ន្ធ

៣៥. តាមគម្រោងនេះ ក្រុមអធិការកិច្ចវាយតម្លៃថា តើធនាគារពិភពលោកអនុលោមតាមគោលនយោបាយ និងនិតិវិធីដំណើរការនៅក្នុងសំណើ ដែរឬទេ :

OMS ២.២០ ការវាយតម្លៃគម្រោង

OD ៤.៣០ ការតាំងទីលំនៅថ្មីឡើងវិញដែលខ្វះការព្រមព្រៀង

OP/BP ១៣.០៥ ការគ្រប់គ្រងគម្រោង

៣៦. **OMS ២.២០ អំពីការវាយតម្លៃគម្រោង** គោលនយោបាយធនាគារពិភពលោកអំពីការវាយតម្លៃគម្រោងមានខមាត្រាសម្រាប់វាយតម្លៃគម្រោងនៃបណ្តាលគម្រោងដែលមានហានិភ័យខ្ពស់។ កថាខណ្ឌ១៧ នៃ OMS ២.២០ សង្កត់ធ្ងន់ទៅលើតម្រូវការនៃ *"ការវាយតម្លៃទៅលើចំនុចរសើបនៃលទ្ធភាពរបស់គម្រោងក្នុងការផ្លាស់ប្តូរប៉ារ៉ាម៉ែត្រសំខាន់ៗរបស់គម្រោង"* ហើយចំពោះគម្រោងដែលមានហានិភ័យខ្ពស់ *"គេចង់បានឱ្យមាននូវលក្ខណៈច្រើនទៀត លើហានិភ័យ តាមរយៈការវិភាគហានិភ័យជាផ្លូវការ"*។ លើសពីនេះ គោលនយោបាយធនាគារពិភពលោកនេះ

បានចែងថា *"ប្រសិនបើការវាយតម្លៃកំណត់ថា គម្រោងទំនងជាមានហានិភ័យខ្ពស់ក្នុងលក្ខខណ្ឌសង្គម ប៉ុន្តែមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការសន្និដ្ឋានច្បាស់លាស់មួយ នោះគួរតែមានការពិចារណាទៅលើគម្រោងសិក្សាជាមុន ឬការពន្យារពេលគម្រោង រហូតទាល់តែមានព័ត៌មានគ្រប់គ្រាន់"* ហើយថា *"មានលក្ខណៈបត់បែនខាងក្នុងគ្រប់គ្រាន់សម្រាប់ការផ្លាស់ប្តូរ ការរៀបចំ ដើម្បីឆ្លើយតបទៅនឹងព័ត៌មានវប្បធម៌សង្គមដែលទទួលបានក្នុងអំឡុងពេលអនុវត្ត"*។[៩]

៣៧. **OD ៤.៣០អំពីការតាំងទីលំនៅថ្មីឡើងវិញដែលខ្វះការព្រមព្រៀង** នៅទីណាដែលគម្រោងឧបត្ថម្ភដោយធនាគារពិភពលោកពាក់ព័ន្ធនឹងការតាំងទីលំនៅថ្មីឡើងវិញដែលខ្វះការព្រមព្រៀង OD ៤.៣០ ចែងថានៅទីនោះគួរជៀសវាង ឬកាត់បន្ថយឱ្យនៅតិចបំផុតនូវភាពអាចកើតមានរឿង ដោយស្វែងរកនូវជម្រើសផ្សេងទៀតរបស់គម្រោងដែលអាចមាន។ ទីណាដែលការរុះរើចេញមិនអាចជៀសវាងបាន *"ការតាំងទីលំនៅថ្មីឡើងវិញដែលខ្វះការព្រមព្រៀងគួរត្រូវបានគិតទុក និងអនុវត្តជាកម្មវិធីអភិវឌ្ឍន៍ដោយអ្នកឱ្យតាំងទីលំនៅថ្មីផ្តល់ធនធាន និងឱកាសវិនិយោគគ្រប់គ្រាន់ ដើម្បីចែករំលែកផលប្រយោជន៍ពីគម្រោង»*។[១០] OD ក៏តម្រូវដែរថា អ្នកត្រូវរុះរើគួរត្រូវបានពិគ្រោះយោបល់ឱ្យបានម៉ត់ចត់ និងគួរទទួលបានឱកាសចូលរួមរៀបចំគម្រោង និងអនុវត្តសកម្មភាពតាំងទីលំនៅថ្មីឡើងវិញ។ OD ចែងថា នៅពេលការរុះរើមិនអាចជៀសវាងបាន *"តម្រូវឱ្យមានផែនការ កាលវិភាគ និងថវិកានៃការតាំងទីលំនៅឡើងវិញលម្អិតមួយ"* ហើយបន្តទៀតថា *"គម្រោងតាំងទីលំនៅថ្មីឡើងវិញគួរត្រូវបានបង្កើតឡើងជុំវិញយុទ្ធសាស្ត្រ និងសំណើផ្សេងៗក្នុងបំណងកែលម្អ ឬយ៉ាងហោចណាស់ស្តារឡើងវិញនូវមូលដ្ឋាន សេដ្ឋកិច្ចសម្រាប់អ្នកតាំងទីលំនៅថ្មីទាំងនោះ"*។[១១]

៣៨. OD ៤.៣០ មិនមានសេចក្តីយោងជាក់លាក់ចំពោះស្ថានភាព ដែលក្របខណ្ឌគោលនយោបាយតាំងទីលំនៅថ្មីឡើងវិញជាជាងផែនការសកម្មភាពតាំងទីលំនៅថ្មីឡើងវិញជាក់លាក់ អាចរៀបចំជាលក្ខខណ្ឌមួយនៃការវាយតម្លៃ (ទិដ្ឋភាពនៃគោលនយោបាយនេះ គឺមានលក្ខណៈអភិវឌ្ឍន៍ជាងក្នុងOP ៤.១២ បច្ចុប្បន្ន)។ យ៉ាងណាក៏ដោយ OD ៤.៣០ ចែង ថាក្នុងបរិបទនៃកម្ចីវិនិយោគតាមផ្នែក *"ដែលតម្រូវការតាំងទីលំនៅថ្មីឡើងវិញជាក់លាក់នៃអនុគម្រោងនីមួយៗមិនដឹងជាមុន អ្នកខ្ចីនឹងត្រូវយល់ព្រមតាមគោលនយោបាយតាំងទីលំនៅថ្មីឡើងវិញ គោលការណ៍រៀបចំផែនការការរៀបចំស្ថាប័ន និងលក្ខន្តិកៈរៀបចំដែលបំពេញតាមគោលនយោបាយ និងតម្រូវការធនាគារពិភពលោកដែលជាលក្ខខណ្ឌនៃកម្ចី។ ការប៉ាន់ស្មាន គួរតែធ្វើឡើងទៅលើប្រជាជនសរុបដែលត្រូវរើលំនៅ និងថ្លៃចំណាយទៅលើការតាំងទីលំនៅថ្មីឡើងវិញទាំងមូល ព្រមទាំងការវាយតម្លៃទៅលើទីតាំងសម្រាប់តាំងទីលំនៅថ្មីដែលបានដាក់។ អនុគម្រោង ក្នុងកម្ចីវិនិយោគ តាមផ្នែកគួរត្រូវបានត្រួតពិនិត្យដោយភ្នាក់ងារអនុវត្តន៍ដើម្បីធានាបានភាពស្របគ្នាទៅ*

---

[៩] OMS ២.២០, ¶ ៦១.

[១០] OD ៤.៣០, ¶៣ (b).

[១១] OD ៤.៣០, ¶ ៤.

*នឹងទិសដៅនេះ និងត្រូវទទួលបានការយល់ព្រមពីធនាគារពិភពលោក*"។[១២]

៣៩. **OP/BP ១៣.០៥ អំពីការគ្រប់គ្រងគម្រោង** គោលនយោបាយធនាគារពិភពលោក អំពីការគ្រប់គ្រងគម្រោងកត់សម្គាល់ថា ក្នុងនាមជាភ្នាក់ងារអភិវឌ្ឍន៍ ធនាគារពិភពលោកចូលចិត្តជួយប្រទេសជាសមាជិកក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍ដែលមាននិរន្តរភាព។ កឋាខណ្ឌទី២ នៃគោលនយោលបាយចែងថា ការគ្រប់គ្រងគម្រោង រួមមានការតាមដាន ការត្រួតពិនិត្យឡើងវិញដើម្បីវាយតម្លៃ ការធ្វើរបាយការណ៍ និងសកម្មភាពជំនួយផ្នែកបច្ចេកទេសដើម្បី:

ក. *ធានាថា តើអ្នកខ្ចីកំពុងអនុវត្តគម្រោងដោយយកចិត្តទុកដាក់តាមពេលកំណត់ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ស្របទៅតាមកិច្ចព្រមព្រៀងស្របច្បាប់*

ខ. *កំណត់បញ្ហាដែលកើតឡើងភ្លាមៗក្នុងអំឡុងពេលអនុវត្ត និងផ្តល់អនុសាសន៍ដល់អ្នកខ្ចីនូវមធ្យោបាយដោះស្រាយបញ្ហាទាំងនោះ*

គ. *ផ្តល់អនុសាសន៍ឱ្យមានការផ្លាស់ប្តូរនូវគោលគំនិតគម្រោង*

ឃ. *កំណត់ហានិភ័យគន្លឹះសម្រាប់និរន្តរភាពគម្រោង និងផ្តល់អនុសាសន៍ដល់អ្នកខ្ចីនូវយុទ្ធសាស្ត្រ និងសកម្មភាពគ្រប់គ្រងហានិភ័យ (...)* ។

៤០. BP ១៣.០៥ ពន្យល់បន្ថែមលម្អិតអំពីបទប្បញ្ញត្តិទាំងនេះក្នុងកម្រិតប្រតិបត្តិ សម្រាប់បុគ្គលិកធនាគារពិភពលោក។ គេចែងថា ក្នុងអំឡុងពេលអនុវត្តគម្រោង ក្នុងចំណោមសកម្មភាពផ្សេងៗ បុគ្គលិកធនាគារពិភពលោកធ្វើការតាមដានទៅលើ ដំណើរការនៃគម្រោងគ្រប់ជ្រុងជ្រោយផ្អែកតាមគោលដៅអភិវឌ្ឍន៍ និងសន្ទស្សន៍តាមដានការអនុវត្ត ធ្វើការធានាពីកម្រិតនៃការគោរពតាមកិច្ចសន្យាឥណទាន រួមមានកិច្ចសន្យាដែលទាក់ទងនឹងការការពារ ថែរក្សាសង្គម និងបរិស្ថាន និងធ្វើការវាយតម្លៃហានិភ័យសម្រាប់ការអនុវត្តគម្រោងប្រកបដោយជោគជ័យជាប្រចាំ។

---

[12] OD ៤.៣០, ¶ ២៦.

# ជំពូក ២ : គម្រោង បរិបទរបស់គម្រោង និងព្រឹត្តិការណ៍ក្នុងតំបន់បឹងកក់

## ក. ស្ថានភាពទូទៅ

៤១. ជំពូកនេះនឹងមានការរៀបរាប់ពីគម្រោង និងការបញ្ជាក់ពីគំនិតសំខាន់ៗដែលឆ្លុះបញ្ចាំងពីការរៀបចំគម្រោងនេះ ពោលគឺ ទំនាក់ទំនងរវាងការកាត់បន្ថយភាពក្រីក្រ និងសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដី។ ជំពូកនេះក៏នឹងបង្ហាញផងដែរពីមហិច្ឆតានៃគម្រោង ដែលមានមហិច្ឆិតា ពោលគឺមានសមាសភាពគម្រោង និងផលប្រយោជន៍រំពឹងទុកដ៏ច្រើនសន្ធឹកសន្ធាប់។

៤២. បរិបទនៃគម្រោងនេះមានភាពរកាំរកូស ដូចដែលបានឆ្លុះបញ្ចាំងក្នុងការរៀបចំគម្រោងនេះ។ ក្រុមអធិការកិច្ច ក៏បានយល់ស្របដែលថាការប្តឹងតវ៉ាដើម្បីស្នើសុំឱ្យមានការត្រួតពិនិត្យឡើងវិញ និងលទ្ធផលរំពឹងទុក និងផលប៉ះពាល់នានា របស់គម្រោងឱ្យគេយល់ទាំងអស់គ្នាក្នុងបរិបទនេះ។ ជំពូកនេះនឹងផ្តល់នូវព័ត៌មានទូទៅផ្អែកលើទិដ្ឋភាព៤ គឺ :

- ប្រវត្តិនៃរឿងរ៉ាវដែលបង្ករអោយមានទាំងភាពរាំងស្ទះគួរអោយសង្វេគដល់របបកម្មសិទ្ធិ និងការខ្វែងគំនិតគ្នាលើនិយមន័យ និងការកំណត់កម្មសិទ្ធិស្របច្បាប់។
- កំណែទម្រង់នានាថ្មីៗនេះលើច្បាប់ស្តីពីដីធ្លី មិនមានមូលដ្ឋានច្បាប់ច្បាស់លាស់ និងមិនទាន់មានការអនុវត្តសមស្របដើម្បីកំណត់ថាតើអ្វីជាដីរដ្ឋ និងដីណាអាចផ្តល់កម្មសិទ្ធិអោយភាគីឯកជន។
- បរិធាននៃការគ្រប់គ្រងដីធ្លី ត្រូវរងគ្រោះដោយការខ្វះខាតសមត្ថភាព ការខ្វះខាតភាពច្បាស់លាស់លើតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ន និងដៃគូពាក់ព័ន្ធនានា។
- ការធ្វើនគរូបនីកម្មលឿនហួសហេតុ ក្នុងបរិបទនៃការរីកចំរើនខ្លាំងផ្នែកសេដ្ឋកិច្ច និងការកើនឡើងនៃការវិនិយោគបរទេស បានធ្វើអោយមានអស្ថេរភាពផ្នែកកម្មសិទ្ធិដីក្នុងតំបន់ប្រជុំជន ជាពិសេសគឺនៅក្នុងទីក្រុងភ្នំពេញ។

៤៣. ចំណែកចុងក្រោយនៃជំពូកនេះផ្តល់នូវសាវតាមួយចំនួនពីព្រឹត្តិការណ៍ក្នុងតំបន់បឹងកក់ ដែលនាំអោយមានការបណ្តេញចេញ ដោយបង្ខិតបង្ខំនិងនាំអោយមានការស្នើសុំអោយមានការត្រួតពិនិត្យនេះ។ ដោយផ្អែកលើឯកសារដែលមាន និងបទសំភាសន៍នានា ជំពូកនេះក៏មានរៀបរាប់ផងដែរពីរបៀបនៃការវិនិច្ឆ័យលើបញ្ហាដីធ្លី ក្រោមបរិបទនៃគម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល និងការបណ្តេញចេញក្រោយពីតំបន់នោះត្រូវបានជួលទៅឱ្យអ្នកវិនិយោគឯកជន។ ជំពូកនេះក៏មានរូបថតនានា ដែលបញ្ហាញពីស្ថានភាពនៅពេលដែល ក្រុមអធិការកិច្ចបានចុះទៅធ្វើទស្សនកិច្ចនៅតំបន់នោះ។

## ខ. គម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល (LMAP)

៤៤. គម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាលនេះ (“គម្រោងនេះ”) មានគោលបំណងក្នុងការគាំទ្រដល់គោលដៅចំបង របស់យុទ្ធសាស្ត្រជំនួយក្នុងប្រទេស (CAS) ឆ្នាំ ២០០០ របស់ធនាគារពិភពលោកក្នុងការ “*កសាងមូលដ្ឋានគ្រឹះសំរាប់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព*” តាមរយៈ (១) អភិបាលកិច្ចល្អរួមមានរដ្ឋបាលសាធារណៈមួយដែលមានប្រសិទ្ធភាព និងគណនេយ្យភាព ព្រមទាំងក្របខ័ណ្ឌច្បាប់និងប្រព័ន្ធយុត្តិធម៌ដែលគួរឱ្យ

ជឿជាក់បានក្នុងការការពារសិទ្ធិជាមូលដ្ឋានរបស់ មនុស្ស និងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និង (២) ផ្តល់សិទ្ធិកាន់តែច្រើនឡើងដល់អ្នកក្រីក្រក្នុងការទទួលបាននូវសេវាមូលដ្ឋានផ្នែកសង្គម និងឱកាសផ្នែកសេដ្ឋកិច្ចនានា ។

៤៥. យុទ្ធសាស្ត្រជំនួយក្នុងប្រទេស (CAS) ឆ្នាំ ២០០០ នេះបានបង្ហាញពីភាពខ្វះខាតក្នុងការទទួលបាននូវកម្មសិទ្ធិដីធ្លីដែលជាកត្តា ចំបងនាំទៅរកភាពក្រីក្រនៅតំបន់ជនបទ និងភាពខ្វះខាតនូវឱកាសទទួលបានប្រាក់ចំណូល ហើយមានលើកឡើងផងដែរថា ប្រទេសកម្ពុជានៅពុំទាន់មានក្របខ័ណ្ឌក្នុងការគ្រប់គ្រងដីធ្លីគ្រប់គ្រាន់នៅឡើយទេ ។ កំណែទម្រង់នានាដើម្បីកំណត់អោយបាន ច្បាស់ពីច្បាប់ស្តីពីដីធ្លី ផែនការប្រើប្រាស់ដីធ្លី និងការធ្វើ ឬ ការផ្តល់កម្មសិទ្ធដីធ្លីក៏ត្រូវបាន លើកឡើងមកពិចារណាដោយ ក្រុម អ្នកចូលរួមចំបង៧នាឱកាសនៃការពិគ្រោះយោបល់ដើម្បីបង្កើតនូវយុទ្ធសាស្ត្រ ជំនួយក្នុងប្រទេស (CAS) នេះឡើង ។[១៣]

៤៦. គម្រោងនេះមានគោលបំណងគាំទ្រដល់ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់សម្រាប់រដ្ឋបាល និងការគ្រប់គ្រងដីធ្លី និងការកសាង សមត្ថភាពស្ថាប័នរបស់រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ខេត្តក្រុង ដើម្បីកត់ត្រា និងគាំពារសិទ្ធិកាន់កាប់ដីធ្លី ។ លើសពីនេះទៅទៀត គម្រោងនេះមានគោលបំណងជួយដល់រដ្ឋាភិបាល ដោយមានការសហការជាមួយនឹងសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីបង្កើតក្របខ័ណ្ឌគោលនយោបាយស្តីពីដីធ្លីជាមូលដ្ឋានមួយ ដែលធានាឱ្យមានសិទ្ធិស្មើគ្នាក្នុងការកាន់កាប់ដីធ្លី ដើម្បីបង្កើន ឱកាសផ្នែកសេដ្ឋកិច្ច ជាពិសេសសម្រាប់ជនក្រីក្រ និងក្រុមប្រជាជនដែលងាយរងគ្រោះដទៃទៀត ។ គម្រោងនេះក៏មានបំណង ជួយសម្របសម្រួលការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពផងដែរ ។[១៤]

៤៧. ជាពិសេសទៅទៀត ដោយយោងលើកិច្ចព្រមព្រៀងឥណទានសម្រាប់ការអភិវឌ្ឍ គម្រោងនេះនឹងជួយដល់អ្នកខ្ចីដើម្បី "*ធ្វើអោយប្រសើរឡើងនូវស្ថេរភាពនៃកម្មសិទ្ធដីធ្លី និងលើកកំពស់ដល់ការបង្កើតឡើងនូវទីផ្សារដីធ្លីដែលមានប្រសិទ្ធភាព*" ហើយគោលបំណងរបស់គម្រោងនេះត្រូវបានបង្កើតឡើងដូចតទៅ : "*(១) ការបង្កើតឡើងនូវគោលនយោបាយជាតិគ្រប់គ្រាន់ (២) ការចុះឈ្មោះ និងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីក្នុងតំបន់ប្រជុំជន និងជនបទ ក្នុងតំបន់ដែលបានចែងក្នុងគម្រោង ព្រមទាំង (៣) ការបង្កើតឡើងនូវប្រព័ន្ធរដ្ឋបាលដីធ្លីដែលមានតម្លាភាព និងប្រសិទ្ធិភាព ។*"[១៥]

៤៨. គោលបំណងទាំងនេះគឺត្រូវសម្រេចអោយបានតាមរយៈសមាសភាព ៥ គឺ : (១) ការបង្កើតក្របខ័ណ្ឌគតិយុត្តិ និងគោល នយោបាយដីធ្លី (២) អភិវឌ្ឍស្ថាប័ន (៣) កម្មវិធីផ្តល់កម្មសិទ្ធិដីធ្លី និងការបង្កើតប្រព័ន្ធចុះបញ្ជីដីធ្លី

---

[១៣] យុទ្ធសាស្ត្រជំនួយក្នុងប្រទេស (CAS) ឆ្នាំ ២០០០ ទំព័រ ៦ ប្រអប់ទី ៣

[១៤] គម្រោងនេះដើរដំណាលគ្នានឹងសកម្មភាពទាំងឡាយ ដែលគាំទ្រដោយគម្រោង North East Village Development ដែលកំពុងដំណើរការដោយ មានជំនួយឧបត្ថម្ភពីសមាគមអភិវឌ្ឍអន្តរជាតិ និងគម្រោងជីវចម្រុះ និងសេចក្តីស្នើគម្រោងព្រៃឈើ និងសេចក្តីស្នើគម្រោងរដ្ឋបាលមូលដ្ឋាន និង ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទ ។ PDA ទំព័រ ២

[១៥] កិច្ចព្រមព្រៀងឥណទានសម្រាប់ការអភិវឌ្ឍ (Development Credit Agreement - DCA) (គម្រោងគ្រប់គ្រងដីធ្លី និង រដ្ឋបាល) រវាងព្រះរាជាណាចក្រកម្ពុជា និងសមាគមអភិវឌ្ឍអន្តរជាតិ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០២ ។

រួមទាំង តំបន់ប្រជុំជន និងជនបទ ក្នុង ១១ ខេត្ត និងក្រុងភ្នំពេញ (៤) ពង្រឹងយន្តការក្នុងការដោះស្រាយទំនាស់ និង (៥) ការគ្រប់គ្រងដីធ្លី។

៤៩. ចំណុចសំខាន់ជាពិសេសដែលទាក់ទងដល់ការស្នើសុំឱ្យធ្វើអធិការកិច្ចនេះ គឺទាក់ទងនឹងសមាសភាព ទី ៣ ទី ៤ និង ទី ៥ នៃគម្រោងនេះ។

- សមាសភាពទី ៣ មានគោលបំណងក្នុងការគាំទ្រការចេញកម្មសិទ្ធិដីធ្លី និងការបង្កើតឡើងនូវប្រព័ន្ធនៃការចុះបញ្ជីដីធ្លី មួយដែលប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។
- សមាសភាពទី ៤ មានគោលបំណងពង្រឹងយន្តការដោះស្រាយទំនាស់តាមរយៈការកសាងសមត្ថភាពអោយ គណៈកម្មការសុរិយោដីជាតិ និងផ្តល់ការគាំទ្រដល់គណៈកម្មការសុរិយោដីនេះនៅថ្នាក់ខេត្ត។ នៅក្រោមសមាសភាពនេះដែរ អង្គការក្រៅរដ្ឋាភិបាលនានាត្រូវជាប់កិច្ចសន្យាក្នុងការផ្តល់នូវជំនួយផ្នែកច្បាប់ជូនចំពោះប្រជាជនក្រីក្របំផុតក្នុងទំនាស់ ដីធ្លី។
- សមាសភាពទី ៥ នៃគម្រោងនេះផ្តល់នូវការរៀបចំផែនទីចំណាត់ថ្នាក់ដីធ្លី និងការប្រើប្រាស់ដីធ្លី តាមរយៈ *inter alia* ដែលមានន័យថាជានីតិវិធីក្នុងការចាត់ថ្នាក់លើប្រភេទផ្សេងៗនៃដី និងការរៀបចំផែនទីចំណាត់ ថ្នាក់ដីធ្លីសម្រាប់ខេត្តនិមួយៗ ដែលបង្ហាញពីព្រំដែនសីមារបស់ប្រភេទផ្សេងៗនៃដី។

៥០. ក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ ទទួលខុសត្រូវលើការអនុវត្តគម្រោងនេះ។ ការិយាល័យគ្រប់គ្រងគម្រោង នេះត្រូវបានបង្កើតឡើងនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់នេះ។ អភិបាលខេត្តនានាដែលនៅក្នុងក្រសួងមហាផ្ទៃ ទទួលខុសត្រូវក្នុងការប្រកាសជាសាធារណៈពីទីតាំង និងតំបន់ដែលនឹងមានការអនុវត្តធ្វើកម្មសិទ្ធិដីធ្លីជាប្រព័ន្ធ (ដែលយើងហៅថា ជាតំបន់ត្រូវវិនិច្ឆ័យ)។

៥១. គម្រោងនេះត្រូវបានជួយឧបត្ថម្ភជាថវិកាមួយភាគដោយឥណទានរបស់សមាគមអភិវឌ្ឍអន្តរជាតិ (IDA) ក្នុងទឹកប្រាក់សរុប ចំនួន ដប់ប្រាំបួនលាន បីសែន សិទ្ធិដកប្រាក់ពិសេស (SDR ១៩,៣០០,000) ដែលស្មើនឹងប្រហែលជា ២៣,៤ លានដុល្លា អាមេរិក។ ម្ចាស់ជំនួយដទៃទៀត (ដែលហៅថា "ដៃគូអភិវឌ្ឍ" ក្នុងរបាយការណ៍នេះ) ក៏បានចូល រួមជួយគាំទ្រដល់គម្រោងនេះ ដែរ ដូចជាប្រទេសអាល្លឺម៉ង់ តាមរយៈអង្គការ GTZ (the Deutsche Gesellschaft für Technische Zusammenarbeit GmbH-GTZ) រដ្ឋាភិបាលប្រទេសហ្វាំងឡង់ ប្រទេសកាណាដា តាមរយៈភ្នាក់ងារកាណាដាសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIDA)។ ធនាគារអភិវឌ្ឍអាស៊ី មិនបានចូលរួមផ្តល់ហិរញ្ញប្បទាន ដល់គម្រោងនេះទេ តែបានផ្តល់ការគាំទ្រយ៉ាងសំខាន់លើផ្នែកគ្រប់គ្រងដែនដី តាមរយៈការផ្តល់ហិរញ្ញប្បទានដល់ការពិនិត្យឡើងវិញ និងការធ្វើសេចក្តីព្រាងអនុក្រិត្យ និងបទដ្ឋានគតិយុត្តិនានាដែល ចាំបាច់ក្នុង

ការអនុវត្តច្បាប់ស្តីពីដីធ្លី ផ្តល់ការបណ្តុះបណ្តាលលើច្បាប់ស្តីពីដីធ្លីនេះ និងផ្សព្វផ្សាយព័ត៌មានស្តីពីគោលនយោបាយថ្មីៗច្បាប់ និងនីតិវិធីនានា ដល់ប្រជាពលរដ្ឋ។[១៦]

៥២. ឥណទានត្រូវបានយល់ព្រមផ្តល់ដោយក្រុមប្រឹក្សានាយកប្រតិបត្តិ នៅខែកុម្ភៈ ឆ្នាំ ២០០២ ហើយចូលជាធរមាន នៅខែ មិថុនា ឆ្នាំ ២០០២។ កាលបរិច្ឆេទបិទគម្រោងត្រូវបានកំណត់ជាដំបូងនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយ ត្រូវបានពន្យាពេលដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩។ នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជាក៏បានផ្អាក់ឈប់ទទួលឥណទានដែលនៅសេសសល់មិនទាន់ចាយ។

៥៣. គម្រោងនេះត្រូវបានគិតទុកមុនថាជាដំណាក់កាលទី ១ នៃកម្មវិធីផែនការរយៈពេលវែងមួយ យ៉ាងហោចណាស់ប្រហែល ១៥ ឆ្នាំ ដែរ។[១៧] លទ្ធផលដែលបានគ្រោងទុករយៈពេលវែងរបស់គម្រោងនេះមានដូចខាងក្រោម ៖[១៨]

ក. ស្ថេរភាពនៃកម្មសិទ្ធិដីធ្លីត្រូវបានលើកកំពស់តាមរយៈការផ្តល់កម្មសិទ្ធិដីចំនួន ១ លាន ប័ណ្ណប្លង់ដី។

ខ. ការវិនិយោគកើនឡើង ទាំងវិនិយោគក្នុងស្រុក និងវិនិយោគបរទេស តាមរយៈភាពងាយស្រួលក្នុងការទទួលបាន នូវឥណទាន និងការបង្កើតនូវបរិយាកាសវិនិយោគមួយដែលមានមាំមួន ឋិតថេរ និងអាចព្យាករបាន។

គ. ប្រសិទ្ធភាពកាន់តែខ្ពស់ក្នុងការប្រើប្រាស់ដីធ្លី ដោយសារតែការអភិវឌ្ឍនៃទីផ្សារដីធ្លី ទាំងក្នុងតំបន់ជនបទ និងតំបន់ ប្រជុំជន។

ឃ. ការប្រមូលពន្ធបានច្រើន និងផែនការប្រើប្រាស់ដីធ្លីបានល្អប្រសើរជាងមុន តាមរយៈព័ត៌មានដែលអាចយកបានពី បញ្ជីដីធ្លី ប្រព័ន្ធសុរិយោដី និងនីតិវិធីនៃការចុះបញ្ជីដីធ្លី ដែលមានភាពល្អប្រសើរជាងមុន។

ង. ការគ្រប់គ្រងធនធានធម្មជាតិដែលមានភាពល្អប្រសើរជាងមុន តាមរយៈផ្នែកឯកជនដែលវិនិយោគលើវិធានការ នានាក្នុងការអភិរក្សដី និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

## គ. និន្នាភាពចំបងៗនៃបរិបទគម្រោង

### ១. របបកម្មសិទ្ធិ

៥៤. ដោយឆ្លុះបញ្ចាំងពីអតីតភាពដ៏វឹកវររបស់ប្រទេស និងប្រវត្តិនៃការមានធនធានដីលើសលប់ បើធៀបនឹងចំនួនប្រជាជនសរុប ការកំណត់ព្រំប្រទល់ដីនៅមានភាពជាអ្នកមានសិទ្ធអាស្រ័យផលលើដីអ្នកដទៃ ជាពិសេសនៅតាមតំបន់ជនបទ។ ជាលទ្ធផល ប្រជាជនភាគច្រើនជឿថា បើសិនជាពួកគេស្នាក់នៅលើដីណា ដែលគ្មានបញ្ហា ឬគ្មានទំនាស់នោះទេ ដីនោះនឹងអាច ក្លាយជាដីរបស់ពួកគេដោយស្របច្បាប់ បើទោះជាពួកគេ គ្មានឯកសារ ឬប័ណ្ណកម្មសិទ្ធិដីក៏ដោយ។

[១៦] PAD, ទំព័រ ០៧

[១៧] PAD, ទំព័រ ០២

[១៨] PAD, ទំព័រ ១៤

៥៥. ការអនុវត្តជាទម្លាប់ពីមុនមកលើកម្មសិទ្ធិតាមរយៈការប្រើប្រាស់ដីឱ្យមានផលិតភាព មានន័យថាអ្នក ប្រើប្រាស់ដីនោះ អាចទទួលបាននូវភាពគ្រប់គ្រាន់សម្រាប់តម្រូវការប្រចាំថ្ងៃ ហើយអាចជៀសផុតពីទំនាស់ ជាមួយនឹងសិទ្ធិរួមរបស់សហគមន៍។ តាមរយៈផ្នែកបច្ចេកទេស នេះមានន័យថាដីទាំងអស់ជាកម្មសិទ្ធិរបស់ រដ្ឋ ឬរបស់ព្រះមហាក្សត្រ តែការអនុវត្តជាក់ស្តែងគឺដី នោះជាកម្មសិទ្ធិរបស់អ្នកដែលប្រើប្រាស់វាក្នុងផលិតកម្ម។[១៩] វិធីសាស្ត្រក្នុងការគ្រប់គ្រងដែនដីដែលមិនមានមូលដ្ឋានច្បាប់ត្រឹមត្រូវនេះ អាចដំណើរការបានល្អតែ នៅក្នុងប្រទេសដែលប្រជាជនប្រហែល ៤-៥ លាននាក់ និងដែលមានដង់ស៊ីតេទាប។

៥៦. ក្នុងរយៈពេល ១០០ឆ្នាំ រវាងឆ្នាំ ១៨៨៤-១៩៨៩ រដ្ឋបាលដីធ្លីត្រូវបានធ្វើឡើងក្រោមច្បាប់ខុសៗគ្នា ជាច្រើន និងប្រព័ន្ធអភិបាលកិច្ច ដែលរួមមានការបញ្ចូលគ្នានូវប្រភេទជាច្រើន ដែលថ្មីៗនេះគេប្រើវិធីឯកជន ភាវូបនីយ-កម្ម។ តាំងពីឆ្នាំ ១៩៨៩ មក ដោយមានការវិនិយោគយ៉ាងខ្លាំងក្លា និងការណែនាំពីសហគមន៍អន្តរជាតិ គេក៏ចាប់ផ្តើមព្យាយាមប្រើប្រាស់ស្តង់ដារ និងបទដ្ឋានអន្តរជាតិក្នុងការគ្រប់គ្រងដែនដី និងការវិនិច្ឆ័យ។ ក្នុងមួយផ្នែកនៃកំណែទម្រង់នេះ ផ្ទៃដី ២,៥ លានហិកតាត្រូវបានចែកនិងផ្តល់ អោយម្ចាស់កម្មសិទ្ធិឯកជន ចំណែកឯ ៨0 ភាគរយនៃផ្ទៃដីក្នុងប្រទេសកម្ពុជាសរុបត្រូវបានរក្សាទុកជាដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ក្រោយប្រតិបត្តិការកំណែទម្រង់រួចមក។[២០]

៥៧. ក៏ប៉ុន្តែ ទោះជាមានការចាប់ផ្តើមប្រើប្រាស់រចនាសម្ព័ន្ធស្របច្បាប់ជាផ្លូវការក្នុងគ្រប់គ្រងរដ្ឋបាលដីធ្លីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិយ៉ាងណាក៏ដោយ ក៏នៅតែមានការប្រើប្រាស់វិធីសាស្ត្រជាទម្លាប់ពីមុនមករបស់ ប្រជាជនជនបទក្នុងការរកកម្មសិទ្ធិដី នៅពេលដែលពួកគេមកនៅទីប្រជុំជន។ ការអនុវត្ត២ប្រភេទផ្សេងគ្នា ក្នុងរដ្ឋបាលដីធ្លីនេះនៅតែបន្តក្នុងពេលបច្ចុប្បន្ននេះ ទោះជាកម្មសិទ្ធិឯកជនបានកំពុងតែវាយលុកលើតំបន់ ដែលគ្រប់គ្រងដោយការប្រើប្រាស់ការបញ្ចូលគ្នានៃសិទ្ធិជាទម្លាប់ប្រពៃណី ឬ សិទ្ធិដោយការប្រើប្រាស់។

៥៨. ការវាយតម្លៃផ្នែកសង្គមកិច្ចលើគម្រោងនេះបានកំណត់ថាការវិវត្តន៍នៃទីផ្សារដីធ្លីមានភាពយឺតយ៉ាវ និង មិនស្មើគ្នា ដែលជា ហេតុនាំអោយមានការចាប់យកដីត្រូវបានធ្វើឡើងមុនពេលការស្វែងរកកម្មសិទ្ធិស្របច្បាប់លើដីដែលបាន ចាប់យកហើយនោះ។[២១] លើសពីនេះទៅទៀត ការវាយតម្លៃផ្នែកសង្គមកិច្ចនេះបានថ្លែងថាការចាប់ផ្តើមឡើងវិញនៃប្រព័ន្ធទីផ្សារសេរី "*បានបង្កើតអោយ មានបញ្ហាអស្ថេរភាពផ្នែកកម្មសិទ្ធិដីធ្លីដល់ប្រជាជនជាច្រើន។ កាលណាមានអាជីវកម្មភាវូបនីយកម្មកាន់តែខ្ពស់ មានអស្ថេរភាព កាន់តែច្រើនឡើងចំពោះប្រជាជនដែលមិនបានចូលរួមជា*

[១៩] កម្មសិទ្ធិដី : យកពងមាន់ទៅជល់នឹងថ្ម? ដោយលោក Van Acker ។ Cambodia Development Review, Vol. 3, (3). Cambodia Development Research Institute, Phnom Penh. 1999.

[២០] ឯកសារវាយតម្លៃគម្រោង : គម្រោងនៃការបែងចែកដីសម្រាប់អភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។ របាយការណ៍ធនាគារពិភពលោក។ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៨។

[២១] ការវាយតម្លៃផ្នែកសង្គមកិច្ចលើដីធ្លីនៅប្រទេសកម្ពុជា : ការចុះកម្មសិក្សានៅទីវាល រៀបចំឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រះរាជាណាចក្រកម្ពុជា។ ឯកសាររបស់វិទ្យាស្ថានអភិវឌ្ឍធនធានកម្ពុជា, រាជធានីភ្នំពេញ ឆ្នាំ ២០០១, ទំព័រ ៧

*សកម្មក្នុងទីផ្សារនោះ។*[២២] ជាក់ស្តែង ការត្រួតពិនិត្យឡើងវិញថ្មីៗនេះ ទៅលើច្បាប់ស្តីពីដីធ្លី ដែលបានចាប់ផ្តើម នៅឆ្នាំ ១៩៨៩ ក្នុងគោលបំណងដើម្បីអោយច្បាប់នេះកាន់តែមានន័យទូលំទូលាយ និង មានភាពពេញលេញជាមុន បានធ្វើអោយមានទំនាស់រវាងកម្មសិទ្ធិ និងរបបសិទ្ធិ ដែលជាផ្នែកមួយនៃរឿងរ៉ាវដ៏ស្មុកស្មាញនៅក្នុង ប្រទេស (សូមអានក្នុងប្រអប់ខាងក្រោម)

## ប្រអប់ ២ : ប្រវត្តិនៃរបបកម្មសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជា *

ប្រវត្តិនៃរដ្ឋបាលដីធ្លីក្នុងប្រទេសកម្ពុជាឆ្លុះបញ្ចាំងពីការប្រើប្រាស់ប្រភេទផ្សេងៗក្នុងការគ្រប់គ្រង និងប្រើប្រាស់ជាផលប្រយោជន៍ ក្នុងការបំពេញដល់ការត្រួតត្រាលើផ្ទៃប្រទេស រួចបន្ទាប់មកលើធនធានដែលមាននៅលើដីនោះ។ ប្រវត្តិលំហូរឡើងចុះនៃ ប្រជាជនវៀតណាម សៀម បារាំង និង បន្ទាប់មកប្រជាជនសូវៀតនិងអាមេរិច បានជះឥទ្ធិពលលើប្រទេសកម្ពុជាសព្វថ្ងៃនេះ។ នេះមានន័យថាមានវិធីសាស្ត្រជាច្រើនក្នុងការគ្រប់គ្រងដីដែលផ្អែកលើគ្រប់មូលដ្ឋានតាមទីត្យានុកូលប្រពៃណី ដែលបង្ករឱ្យ មានភាពស្មុគស្មាញក្នុងការប្រតិបត្តិមូលដ្ឋានច្បាប់នៃរដ្ឋបាលដីធ្លីអន្តរជាតិជាពិសេសខាងផ្នែកអឺរ៉ុបខាងលិច។

រហូតដល់សតវត្សទី ១៩ ប្រទេសកម្ពុជាស្ថិតក្រោមការត្រួតត្រានៃប្រទេសជិតខាងដូចជា ថៃ និង វៀតណាម ដែលនាំមកនូវ អស្ថេរភាពក្នុងប្រព័ន្ធមជ្ឈការនៃរដ្ឋបាលដីធ្លី ឬកម្មសិទ្ធកាន់កាប់ដីធ្លី។ ជាឧទាហរណ៍ ប្រទេសវៀតណាមបានបញ្ចូលតំបន់ជុំវិញ ទន្លេមេគង្គនៅចុងសតវត្សទី១៧ ហើយបានចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធរដ្ឋបាលដីធ្លី ដែលខ្ចីទាំងស្រុងពីចក្រពត្តិនិយមចិន។ ភាពខ្វះ ខាតរដ្ឋាភិបាលរឹងមាំលើការគ្រប់គ្រងដែនដីកម្ពុជាសព្វថ្ងៃ មានន័យថាដីជារបស់អ្នកណាដែលអាចទាមទារយកបាន ប៉ុន្តែក្នុងការ អនុវត្តន៍ជាក់ស្តែងប្រជាពលរដ្ឋអាចលក់ដីរបស់ពួកគេដោយសេរី និងអាចធ្វើកសិកម្មលើដីទាំងនោះតាមដែលអាចធ្វើទៅបាន។ ដោយចំនួនប្រជាពលរដ្ឋតិច នោះម្ចាស់កសិកម្មអាចផ្លាស់ទី ពីតំបន់មួយទៅតំបន់មួយទៀត ហើយទាមទារធ្វើជាម្ចាស់កម្មសិទ្ធិ លើតំបន់ដីដែលបានប្រើប្រាស់ហើយ ដោយមិនបានបំពេញបែបបទ ឬមិនមានឯកសារត្រឹមត្រូវ។ មួយភាគធំនៃប្រជាពលរដ្ឋកម្ពុជា ពិសេសអ្នកដែលមិនអាចឈានទៅរករដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ទម្រង់នៃការគ្រប់គ្រងបែបពាក់កណ្តាលផ្លូវការ នៃការចាត់ការ និងរៀបចំដីធ្លីត្រូវបានបន្តរហូតដល់បច្ចុប្បន្ន។

មធ្យោបាយកាន់តែត្រឹមត្រូវនៃរដ្ឋបាលដីធ្លី ត្រូវបានបង្ខំអោយប្រជាពលរដ្ឋធ្វើតាម ក្រោយការគ្រប់គ្រងនៃរដ្ឋាភិបាលកម្ពុជា និង ក្រោមអាណាព្យាបាលបារាំង។ កិច្ចព្រមព្រៀងស្តីពីដីធ្លីថ្មីមួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៨៨៤ (ទោះបីជាមិនបានប្រតិបត្តិពេញលេញរហូតដល់ឆ្នាំ ១៩១២ ដោយមានការតស៊ូ ពី អ្នកជួលដីកសិកម្ម) តាមមគ្គុទេសទីត្យានុកូល សំរាប់រដ្ឋបាលដី និង ការចាប់ផ្តើមការផ្តល់កម្មសិទ្ធិដីអោយទៅជាទ្រព្យសម្បត្តិឯកជន។

តាំងពីពេលនោះមក បារាំងបានបញ្ចូលប្រព័ន្ធនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ភាគច្រើន សំរាប់ដំណាំកៅស៊ូ និងដំណាំផ្សេងៗ។ កម្រិតនៃប្រព័ន្ធទីត្យានុកូល និងច្បាប់ម្ចាស់កម្មសិទ្ធិ មានន័យថាដីដែលមិនទាន់មានមនុស្សនៅ ត្រូវចាត់ទុកថាជាដីទំនេរ ហើយអាច អនុញ្ញាតឱ្យប្រជាពលរដ្ឋលក់ដីរបស់គេបាន ហើយរើទៅក្នុងព្រៃបន្ត ហើយអាចទាមទារជាម្ចាស់កម្មសិទ្ធនៅដីថ្មីនោះទៀត។ ជាលទ្ធផលនៃការកើនឡើងនៃពាណិជ្ជកម្មកសិកម្ម និងទំនាក់ទំនងនៃប្រព័ន្ធសម្បទានសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៣០ ភាគច្រើន នៃដីដែលផ្តល់ផ្លែផ្កាទំហំតូចត្រូវបានចែកជាច្រើនចំណែកតិចជាង៥ហិចតានិងការដាំដំណាំខ្នាតធំត្រូវបាន ចាប់ផ្តើមឡើង។

ប្រព័ន្ធនៃសិទ្ធិឯកជនលើទ្រព្យសម្បត្តិ បានបន្តក្រោយពីការទទួលឯករាជ្យពីបារាំងឆ្នាំ ១៩៥៣ និង ជំរឿនប្រជាជនកាលពីឆ្នាំ ១៩៦២ បាន បង្ហាញថាមានគ្រួសារធ្វើកសិកម្មជាង ៨០០.០០០ គ្រួសារដែលមាន ៨៤ ភាគរយជាម្ចាស់កម្មសិទ្ធិតែមួយគត់ (ពោលគឺមិនមែនជាអ្នក

[២២] ការវាយតម្លៃផ្នែកសង្គមកិច្ច, ទំព័រ ១០

ជួលដី និងមិនមែនជាអ្នកប្រវាស់កសិផលទេ)។ ប៉ុន្តែប្រព័ន្ធរដ្ឋបាលដីធ្លីនេះ ចាប់ផ្តើមធ្វើឱ្យការគ្មានដី កើនឡើង ដោយគ្រួសារតូចៗជាច្រើនជាប់ជំពាក់បំណុលយ៉ាងខ្លាំង និងត្រូវបានបង្ខំអោយលក់ដីដើម្បីសងបំណុលពួកគេ។ បញ្ហានេះកាន់តែខ្លាំងឡើង ចាប់តាំងពីសង្គ្រាមរវាងវៀតណាម និងអាមេរិក ក្នុងអំឡុងពេលដែលតំបន់ធំៗត្រូវបានទំលាក់ គ្រាប់បែក ពិសេសគឺតាមបណ្តោយព្រំដែនកម្ពុជាវៀតណាម។ ស្ទើរតែ២លាននាក់នៃចំនួនប្រជាជន ប្តូរលំនៅពីតំបន់ព្រំដែន ទៅក្រុងផ្សេងៗទៀត និង ពិសេសគឺ ទីក្រុងភ្នំពេញ។

ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ឆ្នាំ ១៩៧៥-១៩៧៩ គំនិតនៃកម្មសិទ្ធិឯកជនត្រូវបានលុបបំបាត់ ហើយ របបនោះការពារ សិទ្ធិផ្តាច់ការនៃរដ្ឋអំណាចដែលជាម្ចាស់រាល់ដីធ្លីទាំងអស់ និង រាល់អចលនទ្រព្យទាំងឡាយ។ ភាគច្រើននៃ ម្ចាស់ដី និងបញ្ជីសុរិយោដី ត្រូវបានបំផ្លិចបំផ្លាញ ហើយ រដ្ឋាភិបាលបង្ខំប្រជាជន អោយទៅជាក្រុមការងារសហករណ៍។ ក្នុងកំឡុងពេលនៃរបបនេះប្រជាជនប្រមាណ ១-៣ លាននាក់បានស្លាប់ដោយសារតែអត់អាហារ និងការគៀបសង្កត់ពីរដ្ឋ។

ខណៈពេលដែលដីទាំងអស់ បន្តកាន់កាប់ដោយរដ្ឋ ហើយស្ថិតក្នុងអំឡុងពេលដែល វៀតណាមជះឥទ្ធិពលដល់ការ ធ្លាក់ចុះនៃរបប ខ្មែរក្រហម (១៩៧៩-៨៩) គំនិតផ្លាស់ប្តូរចាប់ផ្តើមវិលថយក្រោយ ចំពោះការបញ្ចូលគ្នានៃការប្រើប្រាស់សិទ្ធិជាប្រវត្តិសាស្រ្ត ដើម្បីបង្កើតសិទ្ធិដីធ្វើកសិកម្ម ដីលំនៅដ្ឋាន និងដីឯកជនដែលទទួលស្គាល់នៅក្រោមប្រព័ន្ធគ្រប់គ្រងច្បាប់។ ជាលទ្ធផល ទាំងម្ចាស់ កម្មសិទ្ធិត្រឹមត្រូវ និងពាក់កណ្តាលត្រឹមត្រូវសុទ្ធសឹងតែប្រើប្រព័ន្ធសិទ្ធិនៃរដ្ឋបាលដី ដែលប្រតិបត្តិជាមួយការគ្រប់គ្រងត្រឹមត្រូវ ក្នុងតំបន់ក្រុង និងបន្ទាប់មកទៀត ក្នុងតំបន់ជនបទនានា។

*ប្រអប់ទី ២ យោងតាមប្រភពសំខាន់ៗមួយចំនួន ដូចជា រដ្ឋធម្មនុញ្ញថ្មីនៃប្រទេសកម្ពុជា ចាប់ពីសង្គ្រាមស៊ីវិល ទៅការបាក់បែកប្រជាធិបតេយ្យ សំគាល់ដោយ ការពិនិត្យទៅលើច្បាប់ស្តីពីសិទ្ធិមនុស្ស នៃប្រទេស កូឡុំប៊ី លេខ ២៦ ទំព័រ ៤៥-១១០ និង កំណែទម្រង់ច្បាប់ និងការទទួលស្គាល់សិទ្ធិជារួម នៃ ទុរគ្គតជន នៃដីធ្លី និង វប្បធម៌នៃការរស់រានមានជីវិត។ សិទ្ធិដីធ្លីរួមគ្នា នៃទុរគ្គតជនអាស៊ី ដោយលោក ស៊ីមូលុន ម៉ានីឡា ដោយ ធានាគារអភិវឌ្ឍន៍អាស៊ី។ និង ការផ្លាស់ប្តូរនៃប្រជាពលរដ្ឋ នៅកម្ពុជា និង បញ្ហា សំរាប់ការអភិវឌ្ឍន៍ និង ការកាត់បន្ថយភាពក្រីក្រ ដោយលោក ដាស់វ៉ាម៉ា ជី.អិល . ការអភិវឌ្ឍន៍ព្រឹត្តប័ត្រ ឆ្នាំ ២០០៣ លេខ ៦២ ទំព័រ ៧៤-៨០។*

## ២. ការរៀបចំដែនដីរបស់រដ្ឋ

៥៩. **គោលនយោបាយរៀបចំដែលដីជាតិ ឆ្នាំ ១៩៨៩ :** តាមរយៈគោលនយោបាយនេះ រដ្ឋាភិបាលបានកំណត់ថាកម្មសិទ្ធិដីធ្លីទាំងអស់ដែលបានបង្កើតឡើងមុនឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់ទៀតឡើយ ហើយដីទាំងអស់ក្នុងផ្ទៃប្រទេសគឺជាទ្រព្យសម្បត្តិរបស់រដ្ឋ។ គោលនយោបាយនេះជាលទ្ធផលបានធ្វើឱ្យមានការចាប់ផ្តើមឡើងវិញក្នុងការអនុវត្តប្រព័ន្ធថ្មីមួយ។[២៣] ក្នុងកិច្ចប្រឹងប្រែងមួយដើម្បីដោះស្រាយផលប៉ះពាល់ជាអវិជ្ជមាននៃគោលការណ៍សមោហាភាពនិយមរបស់របបខ្មែរក្រហម គោលនយោបាយ ឆ្នាំ ១៩៨៩ នេះបានបញ្ជាក់ពីសិទ្ធិដើម្បីកាន់កាប់ និងប្រើប្រាស់ដីធ្លី និងសិទ្ធិក្នុងការលក់ដីរដ្ឋសំរាប់ការតាំងលំនៅដ្ឋាន និងការធ្វើអាជីវកម្មនានា។ គោលនយោបាយនេះបានបែងចែកដីជាបីប្រភេទគឺ : (១) ដីសំរាប់សាងសង់លំនៅដ្ឋាន (មិនត្រូវធំជាង ២.000 មែត្រការេឡើយ),

[២៣] សេចក្តីណែនាំស្តីពីការអនុវត្តគោលនយោបាយនៃការប្រើប្រាស់ និងការរៀបចំដែនដី ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី លេខ ០៣ សណន។ ឯកសារៀបចំឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៨៩។ អត្ថបទទី ១ នៃច្បាប់ដីធ្លី ឆ្នាំ ១៩៩២ ក៏បានថ្លែងថា "រដ្ឋមិនទទួលស្គាល់កម្មសិទ្ធិទ្រព្យសម្បត្តិដីធ្លីដែលបានធ្វើរួចមុនឆ្នាំ ១៩៧៩ ឡើយ។"

(២) ដីកសិកម្មសំរាប់ផលិតកម្មធុនតូច (មិនត្រូវធំជាង ៥.000 ហិកតាឡើយ), និង (៣) ដីសម្បទានសំរាប់ប្រើប្រាស់លើវិស័យកសិកម្ម និងពាណិជ្ជកម្មនានា (ធំជាង ៥.000 ហិកតា) ។[២៤]

៦0. ក្នុងចំណោមប្រភេទទាំងបីនេះ សិទ្ធិកាន់កាប់ឯកជនអាចទទួលបានសំរាប់ការយកទៅសង់ធ្វើលំនៅដ្ឋាន (ប្រភេទទី ១) ។ សំរាប់ប្រភេទទី ២ និងទី ៣ គេមានតែសិទ្ធិក្នុងការប្រើប្រាស់ និងសិទ្ធិជាម្ចាស់ គ្រប់គ្រងផ្តាច់មុខលើក្បាលដីនេះប៉ុណ្ណោះ ។[២៥] ដីដែលនៅទំនេរលើសពីរយៈពេល ៣ ឆ្នាំ នឹងត្រូវជារបស់រដ្ឋវិញ ។[២៦]

៦១. **ច្បាប់ដីធ្លីឆ្នាំ ១៩៩២** : អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ (ហៅកាត់ថា UNTAC) បានប្រកាស ឱ្យប្រើច្បាប់ដីធ្លីឆ្នាំ ១៩៩២ ដែលបានចែងពីគោលការច្បាប់ និងស្តង់ដារអន្តរជាតិ ក្នុងការប្រើប្រាស់និងកាន់កាប់ដីធ្លី ដោយយោងទៅ លើការយល់ដឹងច្បាស់មួយដែលថា "*ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិពេញលេញក្នុងការកាន់កាប់ និងប្រើប្រាស់ដីធ្លី ។*"[២៧] តែក្នុងការអនុវត្តជាក់ស្តែង ច្បាប់នេះតែងតែត្រូវបានបំភ្លេចចោល ឬប្រើប្រាស់មិនសមស្រប ដើម្បីកេងយកប្រយោជន៍ដោយមន្ត្រី ។[២៨] ភាពមិនស៊ីគ្នារវាងទ្រឹស្តីច្បាប់ និងការអនុវត្តក្នុងទីក្រុងភ្នំពេញ និងនៅកន្លែងដទៃទៀងបាននាំអោយមានការអំពាវនាវកាន់តែខ្លាំង ឡើងក្នុងការស្វែងរកតម្លាភាពពីសំណាក់ប្រជាជនក្នុងតំបន់ប្រជុំជន ដើម្បីយកឈ្នះលើកំណែទម្រង់ធំៗដែលមានលក្ខណៈជាប្រព័ន្ធទាំងនេះ ។

៦២ ទោះជាមានការធ្វើឯកជនភាវូបនីយកម្មលើដីនិងទ្រព្យសម្បត្តិរដ្ឋតាមរយៈច្បាប់ស្តីពីដីធ្លីឆ្នាំ ២00២ យ៉ាងខ្លាំងក្លាយ៉ាងណាក៏ដោយ វិសមភាពបានបន្តកាន់តែច្រើនឡើងដែលជាបញ្ហាក្នុងតំបន់មូលដ្ឋាន ហើយភាពខ្វះខាតនិងអត់ដីក្នុងតំបន់ប្រជុំជននានាក៏កាន់តែកើនឡើងខ្លាំងដែរគួរអោយទោមនស្ស ។ ផលប៉ះពាល់ដោយផ្ទាល់នៃគំនិតផ្តួចផ្តើមក្នុងការបែងចែកដីធ្លី រវាងឆ្នាំ ១៩៨៩ និង ១៩៩៨ លើការកាត់បន្ថយភាពក្រីក្រ គឺមានការពិបាកក្នុងការគណនាជា

---

[២៤] សេចក្តីណែនាំស្តីពីការអនុវត្តគោលនយោបាយនៃការប្រើប្រាស់ និងការរៀបចំដែនដី ខែ មិថុនា ឆ្នាំ ១៩៨៩ ។

[២៥] ទិដ្ឋភាពផ្នែកសង្គមកិច្ចនៃកំណែទម្រង់ដីធ្លី និងរដ្ឋបាលដីធ្លី នៅក្នុងសមាជជាតិ FIG ឆ្នាំ២០១០ ស្តីពីកំណែទម្រង់ដីធ្លី និងការជួបនឹងផលវិបាក នានា : ការកសាងសមត្ថភាព ។ ក្រុងស៊ីដនី ប្រទេសអូស្ត្រាលី, លោក សុវណ្ណ (២០១០) ថ្ងៃ ១១-១៥ ខែ មេសា ឆ្នាំ ២០១០ និង លោក Williams, S. (១៩៩៩) ។ "ការត្រួតពិនិត្យសេចក្តីព្រាងផ្នែកនីតិកម្មដែនដីក្នុងប្រទេសកម្ពុជា ក្នុងគម្រោងនៃការសិក្សាពីដីក្នុងប្រទេសកម្ពុជា ធ្វើនៅទីក្រុងភ្នំពេញ" ។ (ឯកសារមិនទាន់បានបោះពុម្ព)

[២៦] កំណែទម្រង់ច្បាប់ និងការទទួលស្គាល់ពីសិទ្ធិតំបន់របស់ប្រជាជនដែលជាជនជាតិភាគតិច ក្នុងសិទ្ធិមានដី និងវប្បធម៌ដើម្បីរស់នៅសមស្រប : សិទ្ធិលើដីធ្លីក្នុងតំបន់របស់ប្រជាជនដែលជាជនជាតិភាគតិចក្នុងទ្វីបអាស៊ី ។ ក្រុងមានីឡា, ធនាគារអភិវឌ្ឍអាស៊ី, Simbolon, I. ឆ្នាំ ២00៩ ទំព័រ ៧៣ ។

[២៧] ច្បាប់ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩២ ស្តីពីដីធ្លី អត្ថបទលេខ ២ ។

[២៨] *សិទ្ធិមនុស្សនៅកម្ពុជា : មុខមាត់ខាងក្រៅនៃស្ថេរភាព* ។ សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សនៅកម្ពុជា (ហៅកាត់ថា LICADHO) ឆ្នាំ ២00៦ ។ គេហទំព័រអេឡេចត្រូនិច http://www.licadho-cambodia.org/reports.php?perm=86, p.3.

តួលេខ ទោះជាមនុស្សភាគច្រើនបាននៅតែប្រកែកថា ការអភិវឌ្ឍទាំងនេះបានធ្វើអោយស្ថានភាពរបស់អ្នកក្រីក្រកាន់តែដុនដាបឡើងៗ។[២៩]

៦៣. **ច្បាប់ដីធ្លីឆ្នាំ ២០០១** : ច្បាប់ដីធ្លីឆ្នាំ ២០០១ ត្រូវបានអនុម័តដោយមួយផ្នែកធំផ្អែកលើការពិតមួយដែលថា ដំណើរវិវឌ្ឍន៍ ទៅរកការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច ចាំបាច់ត្រូវការប្រព័ន្ធនៃសិទ្ធិកាន់កាប់ដីដ៏រឹងប៉ឹងមួយក៏ដូចជាការដែលត្រូវតែមានការចាត់ចែង និងគ្រប់គ្រងដែនដីដែលមានភាពល្អប្រសើរជាងមុន។ ដោយឆ្លុះបញ្ចាំងពីប្រព័ន្ធចាស់ៗ ច្បាប់បានទទួលស្គាល់ពីកម្មសិទ្ធិ ៣ ប្រភេទ លើដីនៅក្នុងប្រទេសកម្ពុជាគឺ : ទ្រព្យសម្បត្តិជាសាធារណៈរបស់រដ្ឋ (ឧទាហរណ៍ដូចជា ព្រៃឈើ តំបន់ការពារ) សម្រាប់ការអភិរក្សធនធាន ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ សម្រាប់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច និងទ្រព្យសម្បត្តិឯកជន (ដូចជា ដីសំរាប់ការប្រកបរបរកសិកម្ម និងធ្វើជាលំនៅដ្ឋាន)។ នៅក្នុងកម្មសិទ្ធិនៃប្រភេទទ្រព្យសម្បត្តិឯកជននេះ កម្មសិទ្ធិអាចជារបស់បុគ្គលម្នាក់ របស់ភូមិ ឬដោយសហកម្មសិទ្ធិ។ ការបែងចែកឡើងវិញភាគច្រើនគឺមានលក្ខណៈជាការផ្តល់ជាដីសម្បទាន ដែលជា ការផ្តល់នៅខាងក្រៅច្បាប់ និងនិយតកម្មនានា ដូចជាច្បាប់ស្តីពីដីធ្លីឆ្នាំ ២០០២ ជាដើម ហើយគេស្មានទុករួចហើយថានៅចុងឆ្នាំ ១៩៩០ ច្រើនជាង ១ ភាគ ៣ នៃសហគមន៍ជនបទត្រូវបានបណ្តេញចេញពីដីរបស់ពួកគេ ដោយសារតែការផ្តល់សម្បទានដី និង សម្បទានព្រៃឈើ។[៣០]

៦៤. ប្រភេទទាំង ៣នៃដីនេះផ្តល់ជាក្របខ័ណ្ឌបច្ចុប្បន្ននេះសំរាប់ឆ្លើយនូវសំណួរផ្អែកច្បាប់នានាលើការអភិវឌ្ឍ និងសិទ្ធិប្រើប្រាស់ដី ទាំងក្នុងតំបន់ជនបទ និងប្រជុំជន។ ដូច្នេះហើយ ច្បាប់នេះ និងអនុក្រឹត្យដែលកើតឡើងបន្តបន្ទាប់បង្កើតបានជាមូលដ្ឋានចំបងមួយសម្រាប់វាយតម្លៃសិទ្ធិ និងអំណាចក្នុងការទទួលបានដីក្នុងប្រទេសកម្ពុជា។ ចំនុចសំខាន់ៗរបស់ច្បាប់នេះត្រូវបានលើកយកមក ពិភាក្សាដើម្បីផ្តល់ជាគំនិតក្នុងការវិភាគរបស់អធិការកិច្ច ក្នុងជំពូកទី ៣។

***តើអ្វីជាដីសាធារណៈរបស់រដ្ឋ?*** យោងតាមមាត្រាទី ១២ : "*រដ្ឋគឺជាម្ចាស់នៃទ្រព្យសម្បត្តិទាំងអស់ដែលមានក្នុងផ្ទៃប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដូចដែលបានរៀបរាប់ក្នុងមាត្រាទី ៥៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ និងលើទ្រព្យសម្បត្តិទាំងឡាយដែលគ្មានម្ចាស់ ឬគ្មានអ្នកទទួលមរតក*" នេះមានន័យថា "*ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋគឺត្រូវ*

---

២៩ សូមអាន *ការពិនិត្យមើលលើប្រភពបន្ទាប់បន្សំដែលទាក់ទងនឹងកម្មសិទ្ធិដី និងបញ្ហាទទួលសិទ្ធិ ។* ភ្នំពេញ : គម្រោងដីធ្លីកម្ពុជារបស់អង្គការ Oxfam (របស់ចក្រភពអង់គ្លេស)

៣០ *ការបង្កើតបណ្តុំទិន្នន័យពីកម្មសិទ្ធិដីក្នុងប្រទេសកម្ពុជា* : ភ្នំពេញ, កម្ពុជា ដោយលោក Ballard, B. ឆ្នាំ ២០០៦។ គេហទំព័រអេឡិចត្រូនិច : http://www.fao.org/docrep/009/a0306t/A0306T08.htm

*ចាត់ក្នុងប្រភេទបំរុងទុក* "[៣១] ក៏ប៉ុន្តែ ច្បាប់មិនបានចែងច្បាស់ទេថាដីទាំងអស់ក្នុងប្រទេសកម្ពុជាជាដីសាធារណៈរបស់រដ្ឋ នោះទេ។

មាត្រាទី ១៥ បានកំណត់និយមន័យនៃប្រភេទទ្រព្យសម្បត្តិដែលចូលក្នុងប្រភេទជាទ្រព្យសម្បត្តិ*សាធារណៈ*របស់រដ្ឋ ដោយបញ្ចូលទាំងទ្រព្យសម្បត្តិទាំងឡាយណាដែលមានដើមកំណើតធម្មជាតិ ដូចជាព្រៃឈើ ផ្លូវទឹកដែលអាចចរាចរបាន បឹងធម្មជាតិ ច្រាំងទឹកស្ទឹងទន្លេ និងឆ្នេរសមុទ្រ ព្រមទាំងទ្រព្យសម្បត្តិទាំងឡាយណាដែលត្រូវបានបង្កើតឡើងជាពិសេស សម្រាប់ការប្រើប្រាស់ទូទៅ ដូចជាកំពង់ផែ ផ្លូវរថភ្លើង ស្ថានីយរថភ្លើង និងព្រលានយន្តហោះ ហើយនឹងទ្រព្យសម្បត្តិ ទាំងឡាយណាដែលបង្កើតឡើងសំរាប់ជាប្រយោជន៍រួម សំរាប់ការប្រើប្រាស់រួម ទាំងភាពជាធម្មជាតិ ទាំងក្រោយការ បង្កើតរួច ដូចជា ផ្លូវថ្នល់ ផ្លូវដែក ផ្លូវរទេះគោក្របី ផ្លូវដើរ សួនច្បារ សួនកំសាន្តសាធារណៈ និងដីបម្រុងទុកជាដើម។ នេះមានន័យថាប្រភេទដែលសេសសល់នៃដី ដែលមិនបានរាប់បញ្ចូលក្នុងប្រភេទដែលបានបញ្ជាក់ខាងលើទេនោះ គឺ ជា ដី*សាធារណៈរបស់រដ្ឋ* ទាំងអស់។

សេចក្តីណែនាំស្តីពីស្ថានភាពផ្នែកច្បាប់របស់ដីរដ្ឋក៏មានចែងក្នុងអនុក្រឹត្យចុះឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋផងដែរ ដែលមាត្រា ៣ ក្នុងអនុក្រឹត្យនោះបានចែងថា "*ចំណែកដីនីមួយៗរបស់រដ្ឋនឹងត្រូវចុះក្នុងបញ្ជីជាដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ។*"[៣២] ក៏ប៉ុន្តែអនុក្រឹត្យនេះមិនបានកំណត់ពីស្ថានភាពផ្នែកច្បាប់របស់ដីរដ្ឋមុនពេញនៃការចុះបញ្ជីនោះទេ។ មាត្រា ១២ បានចែងថា "*ប្រសិនបើការកំណត់អត្តសញ្ញាណ និងការធ្វើផែនទីដីរដ្ឋមិនទាន់បានបញ្ចប់ទេនោះ គណៈកម្មការខេត្តក្រុងគ្រប់គ្រងដីរដ្ឋខេត្តក្រុង នឹងធ្វើការស៊ើបអង្កេតពីការអះអាងដែលមិនចុះសម្រុងគ្នារវាងស្ថាប័ននានា ឬ អាជ្ញាធរដែនដី ហើយនឹងផ្តល់ឱកាសដល់សាធារណៈជនដើម្បីផ្តល់មតិលើការធ្វើចំណាត់ថ្នាក់នេះ ។*"[៣៣]

***តើដីណាដែលអាចកាន់កាប់បានជាឯកជននិងស្របច្បាប់?*** មាត្រា ៦ បានចែងថា "*មានតែការកាន់កាប់ដែលស្របច្បាប់ ប៉ុណ្ណោះដែលអាចនាំទៅដល់ការទទួលបានកម្មសិទ្ធិ* "។ ដូច្នេះបើការកាន់កាប់ពីដំបូងធ្វើឡើងដោយមិនស្របច្បាប់នោះ អ្នកកាន់កាប់នោះមិនអាចនឹងក្លាយជាម្ចាស់កម្មសិទ្ធិបានទេ។ ដើម្បីឱ្យស្របច្បាប់ មាត្រា ៣៨ បានចែងថា "*ដើម្បីក្លាយជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិអចលនវត្ថុណាមួយ ការកាន់កាប់ត្រូវធ្វើឡើងដោយគ្មានភាពមន្ទិល គ្មានអំពើហិង្សា អាចដឹងឮជាសាធារណៈ ដោយជាប់លាប់ និងដោយសុចរិត* "។ ក៏ប៉ុន្តែ មាត្រា ៣០ បានចែងថា "*អ្នកណា ក៏ដោយ មុនការប្រកាសអោយប្រើច្បាប់នេះរយៈពេលលើសពី ៥ ឆ្នាំ ដែលបានកាន់កាប់លើអចលនទ្រព្យមួយដែលគ្មាន ទំនាស់ជាមួយអ្នកណាម្នាក់ទៀត អាចមានសិទ្ធិដើម្បីសុំធ្វើជាម្ចាស់កម្មសិទ្ធិស្របច្បាប់*

---

[៣១] យោងលើ *ការសំរេចបានគោលបំណងគោលនយោបាយនៃការអភិវឌ្ឍ ច្បាប់ យុត្តិធម៌ និងកម្រងអត្ថបទស្តីពីការអភិវឌ្ឍ* ដោយធនាគារពិភពលោក នៅទីក្រុងវ៉ាស៊ីនតោន ឌី ស៊ី។

[៣២] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ ១១៨, មាត្រា ៣

[៣៣] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ ១១៨, មាត្រា ១២ (គ)

*លើអចនលទ្រព្យនោះ* " (មានការបញ្ជាក់បន្ថែម)។ ដូច្នេះស្ថានភាពផ្នែកច្បាប់នៃការកាន់កាប់ដំបូង គឺជាគន្លឹះសំខាន់ដើម្បីពិចារណាក្នុងការវាយតម្លៃ លើភាពដែលអាចទទួលបានប័ណ្ណកម្មសិទ្ធិ។

៦៥. ក្នុងការរៀបចំដើម្បីចាប់ផ្តើមរបបប្រជាធិបតេយ្យពហុបក្សក្នុងឆ្នាំ ១៩៩៣ គណបក្សនយោបាយជាច្រើនបានចាប់ផ្តើមធ្វើយុទ្ធនាការដើម្បីរកសំលេងឆ្នោតដើម្បីគាំទ្រគណបក្សខ្លួន។ មុនពេលបោះឆ្នោត មនុស្សភាគច្រើនបាននាំគ្នាកាន់កាប់ដីរដ្ឋដែលនៅទំនេរ មិនទាន់បានកំណត់ត្រឹមត្រូវ និងមិនទាន់បានចុះបញ្ជី។ អ្នកតាំងលំនៅដ្ឋានលើដីទាំងនោះទទួលបានឯកសារមួយចំនួនដែល បង្ហាញថាពួកគេមានការអនុញ្ញាតិដើម្បីកាន់កាប់ដីដែលពួកគេបានសាងសង់លំនៅដ្ឋានរួចនោះ។ វាគឺជាឯកសារទាំងអស់នេះហើយ ដែលបង្កើតបានជាមូលដ្ឋាននៃការទាមទារនានាដែលអ្នកតាំងលំនៅដ្ឋានទាំងនោះអាចមានសិទ្ធិទទួលបានការចែកនូវប័ណ្ណកម្មសិទ្ធិ យោងទៅលើច្បាប់។

៦៦. អ្នកកាន់កាប់ដីដែលចាត់ទុកថាជាដីសាធារណៈរបស់រដ្ឋមិនអាចត្រូវបានពិចារណាដើម្បីផ្តល់ជូននូវកម្មសិទ្ធិបានទេ។ ក៏ប៉ុន្តែ នេះជាការសន្មត់ដែលគិតថាដីទាំងអស់ត្រូវបានចុះបញ្ជីជាផ្លូវការរួចហើយជាដីសាធារណៈរបស់រដ្ឋ *នៅពេលនៃការកាន់កាប់បានធ្វើឡើង*។[៣៤] នេះបានលើកជាសំណួរមួយចំនួនរួមមាន ថាតើព្រុំដីរបស់ទីកន្លែងសាធារណៈដូចជាសួនច្បារ គួរតែត្រូវកំណត់ឱ្យបានច្បាស់លាស់ ធ្វើវាស់វែង និងចុះបញ្ជីឱ្យបានមុនការកាន់កាប់ណាមួយដែរឬទេ។ ប្រសិនបើដីទាំងនេះត្រូវបានកំណត់ច្បាស់ លាស់ហើយបានចុះបញ្ជីត្រឹមត្រូវ ដីទាំងនោះគឺអាចត្រូវរាប់បញ្ចូលជាដីសាធារណៈរបស់រដ្ឋត្រឹមត្រូវហើយ ហើយការកាន់កាប់ណា មួយក្រោយការកំណត់ និងចុះបញ្ជីនេះ នឹងត្រូវចាត់ទុកថាជាការខុសច្បាប់។ ក៏ប៉ុន្តែ ប្រសិនបើកន្លែងមួយ *មិនទាន់បាន*ធ្វើសង្កេតវាស់វែង កត់ត្រាទុក ឬចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋទេនេះ វាអាចត្រូវបានចាត់ទុកថាជាដីឯកជនរបស់រដ្ឋ ដែលជាហេតុនាំអោយការ កាន់កាប់ដំបូងនេះស្របច្បាប់ និងព្រមទាំងអាចទទួលបានកម្មសិទ្ធិផងដែរ។

### *តើពេលណាដែលដីសាធារណៈរបស់រដ្ឋអាចត្រូវចាត់ថ្នាក់អោយក្លាយជាដីឯកជនរបស់រដ្ឋ?*

នេះជាបញ្ហាទាក់ទងនឹង មូលដ្ឋានដែលនាំដល់ការអាចប្រែក្លាយដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ។ មាត្រា ៤៣ នៃច្បាប់ស្តីពីដីធ្លីឆ្នាំ ២០០១ បានចែងថា "*គ្មានករណីណាមួយដែលទ្រព្យសម្បត្តិរបស់រដ្ឋអាចត្រូវយកជាកម្មសិទ្ធិបានទេ។ ស្ថានភាពនៃអ្នកដែលកាន់កាប់ដីដែលជាទ្រព្យសម្បត្តិរបស់រដ្ឋគឺប្រឈមនឹងការដកហូតយកវិញ ឬការខុសច្បាប់ ប្រសិនបើការកាន់កាប់ នោះមិនមានការអនុញ្ញាត្តិទៅតាមលក្ខណៈណាមួយស្របតាមច្បាប់នេះ។*"។

យោលតាមមាត្រា ១៦ បានចែងថា "*ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋគឺមិនអាចលក់បានទេ ហើយក៏គ្មានការចេញផ្តល់ ជាកម្មសិទ្ធិអោយអ្នកណាម្នាក់ឡើយ។* " ក៏ប៉ុន្តែមាត្រានេះបន្តចែងថា "*ពេលដែលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋបាត់បង់តម្លៃនៃការប្រើប្រាស់របស់សាធារណៈជន វាអាចត្រូវចុះបញ្ជីជាទ្រព្យសម្បត្តិ*

[៣៤] ប្រភេទនៃដីដែលរួមបញ្ចូលជាដីសាធារណៈរបស់រដ្ឋគឺត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា ១៥ នៃច្បាប់នេះ។

*ឯកជនរបស់រដ្ឋទៅតាមច្បាប់ដោយ មានការផ្ទេរឈ្មោះពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ* "។[៣៥] មាត្រា ១៧ បន្តថែងថា ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋអាចលក់បាន ផ្លោះប្តូរបាន បែងចែក ឬផ្ទេរសិទ្ធិបាន។ យោងតាមមាត្រា ១៧ ទ្រព្យទាំងនេះ អាចជួលបាន ហើយល័ក្ខខ័ណ្ឌ និងនីតិវិធីនានាក្នុងការលក់ ឬជួល និងគ្រប់គ្រងទាំងឡាយទៅលើ ទ្រព្យសម្បត្តិឯកជន របស់រដ្ឋនេះត្រូវចែងដោយអនុក្រឹត្យ។

## ៣. ប្រព័ន្ធស្ថាប័ននៃរដ្ឋបាលដីធ្លី

៦៧. ការទទួលខុសត្រូវលើរដ្ឋបាលដីធ្លី សិទ្ធិកាន់កាប់ដី និងសិទ្ធិលើទ្រព្យសម្បត្តិនានាក្នុងប្រទេសកម្ពុជា គឺត្រូវចែករំលែករវាងស្ថាប័នមួយចំនួន ហើយអាណត្តិរបស់ស្ថាប័ននីមួយៗទាំងនេះតែងតែត្រួតស៊ីគ្នា។ ក្រសួងរៀបចំដែនដីនគរូបនីកម្ម និងសំណង់ (ករដនស) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៩។ ក្រសួងថ្មីមួយនេះដែលមានការទទួលខុសត្រូវដ៏ច្រើនសន្ធឹកសន្ធាប់ កំពុងតែរៀបចំកសាងសមត្ថភាពស្ថាប័ន និងជំនាញវិជ្ជាជីវៈ ដោយមានការជួយឧបត្ថម្ភពីភ្នាក់ងារផ្តល់ជំនួយជាច្រើនផងដែរ។ ក្រសួងមានតួនាទីដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌដីរដ្ឋ និងសម្របសម្រួលសកម្មភាពរបស់ស្ថាប័នរដ្ឋនិងក្រសួងពាក់ព័ន្ធផ្សេងទៀតដែលត្រួតត្រាលើដីរដ្ឋ ឬប្រើប្រាស់ដីរដ្ឋ តែក្រសួងមិនមានតួនាទីជាអ្នកគ្រប់គ្រង ឬជាម្ចាស់លើដីរដ្ឋដែលសេសសល់ ឬមិនទាន់ចុះបញ្ជីនោះទេ។ តួនាទីនេះគឺប្រគល់ឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកំពុងជួបប្រទះបញ្ហាប្រឈមជាច្រើនក្នុងការទទួលបានពត៌មាន និងមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទី និងការងារនេះអោយមានប្រសិទ្ធភាពនៅឡើយ។ ជាលទ្ធផលគេអាចសន្និដ្ឋានបានថា ការគ្រប់គ្រងការរៀបចំដែនដីដោយក្រសួង និងស្ថាប័នពាក់ព័ន្ធ លើដីរដ្ឋនៅខ្សោយនៅឡើយ។

៦៨. ក្នុងឆ្នាំ ១៩៩៤ រដ្ឋាភិបាលបានបង្កើតគណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍតំបន់ ទីក្រុងនិងសំណង់ ដែលបានបន្តធ្វើការបង្កើតការិយាល័យកិច្ចការទីក្រុងក្នុងមជ្ឈមណ្ឌលនៃទីប្រជុំជននីមួយៗ។[៣៦] បន្ថែមលើនេះ ដីរដ្ឋមួយភាគធំត្រូវបានយកកាន់កាប់ដោយក្រសួង និងស្ថាប័នរដ្ឋ ជាពិសេសមួយផ្នែកធំគឺដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងការពារជាតិ។ ក្នុងករណីជាច្រើនទៀត ក្រសួងទាំងនេះក៏នៅមិនទាន់ច្បាស់ខ្លួនឯងផងថាតើដីអ្វីដែលគេកំពុងតែកាន់កាប់។

៦៩. ក្រៅពីក្រសួងទាំងនេះ រដ្ឋបាលមូលដ្ឋាន ដូចជាសាលាក្រុងភ្នំពេញជាដើម មានភារកិច្ចគ្រប់គ្រងដីនៅថ្នាក់មូលដ្ឋាន។ តួនាទីទាំងនេះ គឺប្រតិបត្តិដោយនាយកដ្ឋានសុរិយោដី និងការិយាល័យកិច្ចការទីក្រុង។ សាលាខេត្តក្រុង និង

---

[៣៥] ច្បាប់ស្តីពីដីធ្លីឆ្នាំ ២០០១ មាត្រា ១៦

[៣៦] *ការរៀបចំដែនដីទីក្រុង និងតំបន់ជុំវិញទីក្រុង :* ឧទាហរណ៍ពីក្រុងក្នុងខេត្តនៃប្រទេសកម្ពុជា. សមាជនៃការស្ទង់មតិនៅអាស៊ីអាគ្នេយ៍ ដោយ លោក Bandar Seri Begawan, ប្រទេស Brunei Darussalam. Mund, J-P., Symann, R. & Seang, T.P. ឆ្នាំ 2005

អភិបាលខេត្តក្រុងមានភារកិច្ច រាយការណ៍ជូនក្រសួងមហាផ្ទៃ ថ្វីបើអភិបាលក្រុងរាជធានីភ្នំពេញក៏អាចរាយការណ៍ជូនដល់នាយករដ្ឋមន្ត្រីផងដែរ។

៧០. ជាចុងក្រោយ ស្ថាប័ន ២ ផ្សេងទៀតមានភារកិច្ចក្នុងផ្នែកមួយក្នុងរដ្ឋបាលដីធ្លី។ គណៈកម្មការសុរិយោដី ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០២ គឺជាបច្ចេកទេសត្រូវទទួលធ្វើការសម្របសម្រួលទំនាស់ដីធ្លីដែលចេះតែកើនឡើង។ អាជ្ញាធរជាតិសម្រាប់ ដោះស្រាយជំលោះដីធ្លីដែលទើបតែនឹងបង្កើតឡើងថ្មីៗនេះថែមទៀតនោះមានអំណាច និងសមត្ថកិច្ចជាច្រើនដែលស្ទួនគ្នា និងមាន ទំនាស់យុត្តាធិការជាមួយនឹងស្ថាប័នទាំង ២ ខាងលើ ហើយបានធ្វើឱ្យនីតិវិធីនៃការវិនិច្ឆ័យមានការយឺតយ៉ាវ។

៧១. លទ្ធផលនៃរចនាសម្ព័ន្ធស្ថាប័ននេះ និងកត្តានានាដទៃទៀត ធ្វើអោយមានការសិក្សាមួយដែលបានលើកឡើងពីបញ្ហាប្រឈម ជាច្រើនរបស់ការធ្វើផែនការអោយមានបានរលូន និងមានប្រសិទ្ធិភាព :[៣៧]

ក. ក្របខ័ណ្ឌគតិយុត្តិមិនច្បាស់លាស់ និងការបែងចែកភារកិច្ច និងតួនាទីលើការរៀបចំដែនដី និងនគរូបនីយកម្ម។

ខ. ការខ្វែងគំនិតគ្នាផ្នែកច្បាប់ក្នុងស្ថាប័នលើដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ដែលនាំអោយមានទំនាស់ និង ប្រជាជនបាត់បង់ជំនឿលើសមត្ថភាពរបស់រដ្ឋាភិបាល។

គ. ការទន្ទ្រានយកដីដែលមិនទាន់ចុះបញ្ជី និងផ្លាស់ប្តូរនានា ដើម្បីយកផលប្រយោជន៍ផ្នែកអាជីវកម្មក្នុងស្រុក និងបរទេស ដែលធ្វើអោយទំនាស់ដីធ្លីក្នុងតំបន់ជុំវិញទីក្រុងដែលមានស្រាប់កាន់តែរីករាលដាលធំឡើង។

ឃ. ការកើនឡើងយ៉ាងលឿននៃចំនួនប្រជាជនក្នុងទីក្រុងភ្នំពេញ និងនៅក្នុងតំបន់ប្រជុំជននៃខេត្តមួយចំនួនទៀត បាននាំឱ្យមានការឆ្លើយតបផ្នែកគោលនយោបាយគ្មានតុល្យភាព និងការបំភ្លេចពីឱកាសដែលផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍ នៃបណ្តាញទីប្រជុំជនរបស់ជាតិមួយ។

## ៤. សុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីក្នុងទីក្រុងភ្នំពេញ

៧២. ជាមួយនឹងផ្ទៃដីសរុបប្រហែល ១៨១.០០០ គីឡូម៉ែត្រការេ ប្រជាជនកម្ពុជា ភាគច្រើននៅតាមជនបទ។ មានតែប្រហែលជា ២០ ភាគរយប៉ុណ្ណោះនៃចំនួនប្រជាជនសរុបប្រហែល ១៥ លាននាក់នេះ រស់នៅក្នុងតំបន់ប្រជុំជន។[៣៨] ក៏ប៉ុន្តែអត្រានៃកំណើននៃតំបន់ទីប្រជុំជនត្រូវបានរំពឹងទុកថានឹងកើនឡើងខ្ពស់ ពោលគឺប្រហែលដល់ ២៤ ភាគរយ

---

[៣៧] *ការកំណត់/កំណត់ព្រំប្រទល់/ការធ្វើចំណាត់ថ្នាក់ដីរដ្ឋនិងគម្រោងព្រៃឈើអចិន្ត្រៃយ៍* ដោយលោក John Bruce នៅឆ្នាំ ២០០៨។

[៣៨] យោលលើការិយាល័យប្រជាជន នៃនាយកដ្ឋានសេដ្ឋកិច្ច និងកិច្ចការសង្គមកិច្ចរបស់អគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ (២០០៩)។ ព្រឹត្តប័ត្រនគរូបនីយកម្មពិភពលោក : ទិន្នន័យប្រជាជនដែលបានពិនិត្យឡើងវិញនៅឆ្នាំ ២០០៩។ គេហទំព័រអេឡិចត្រូនិច : http://esa.un.org/wup2009/unup/p2k0data.asp. ។ ក៏ប៉ុន្តែ ការសិក្សាមួយរបស់លោក Ray D. Bollman នៅឆ្នាំ ២០០៩ បានគណនា ឃើញថា ៤៨ ភាគរយនៃប្រជាជនកម្ពុជាគឺ "កំពុងបែរឆ្ពោះនៅរកការរស់នៅក្នុងការតាំងទីលំនៅនៅទីប្រជុំជន" ថ្វីបើគ្មានការបញ្ជាក់ច្បាស់លាស់ ពីការតាំងលំនៅនេះក៏ដោយ។

នៅទីក្រុង ក្នុងឆ្នាំ ២០១៥ និង ៣០ ភាគរយ នៅឆ្នាំ ២០២០។[៣៩] នេះមានន័យថាប្រជាជនក្នុងទីក្រុងបានកើនឡើង ២ ដងក្នុងកំឡុងពេលតែ ១៥ ឆ្នាំ ប៉ុណ្ណោះ។ ពេល ដែលប្រជាជនកាន់តែច្រើនឡើងបានមករស់នៅទីក្រុង ដើម្បីស្វែងរកឱកាសផ្នែកសេដ្ឋកិច្ច សំពាធលើដីនៅទីក្រុងកាន់តែមានភាព ធ្ងន់ធ្ងរឡើងៗ ហើយការប្រកួតប្រជែងលើរឿងដីនេះកាន់តែមានភាពខ្លាំងក្លាឡើងៗ។

៧៣. តំបន់ក្នុងក្រុងភ្នំពេញមានប្រហែល ៣៧៥ គីឡូម៉ែត្រការេ។ ទីក្រុងនេះត្រូវបានបែងចែកតាមផ្នែករដ្ឋបាលជា ៧ ខ័ណ្ឌ ដែលរួមមាន ៧៦ សង្កាត់។ ខ័ណ្ឌចំនួន ៤ ស្ថិតក្នុងទីប្រជុំជនគ្របដណ្តប់លើផ្ទៃដីប្រហែល ២៨ គីឡូម៉ែត្រការេ ហើយ ខ័ណ្ឌ ៣ ទៀតនៅ ព័ទ្ធជុំវិញក្រុង ដែលរួមមាន ៣៤៧ គីឡូម៉ែត្រការេ។[៤០]

៧៤. ក្នុងរបបខ្មែរក្រហម (១៩៧៦-១៩៧៩) ប្រជាជនទាំងអស់ត្រូវបានបណ្តេញចេញពីទីក្រុងភ្នំពេញ។ ពេលដែលរបបនេះត្រូវវាយប្រហារដោយកងកំលាំងយោធាវៀតណាម នៅឆ្នាំ ១៩៧៩ ជនភៀសខ្លួនទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យមកយកលំនៅដ្ឋាននៅទីក្រុងឡើងវិញនៅដើមឆ្នាំ ១៩៨០ គឺពេលដែលមានការអភិវឌ្ឍផែនការនីតិសម្បទាសម្រាប់ទីក្រុងភ្នំពេញឡើងវិញ។[៤១] រចនាសម្ព័ន្ធរូបវ័ន្តមូលដ្ឋាននៃទីក្រុងចាស់ត្រូវបានកសាងឡើងវិញដោយមានជំនួយបច្ចេកទេសពីប្រទេសវៀតណាម និងម្ចាស់ជំនួយ ដទៃទៀត។

៧៥. ក្នុងឆ្នាំ ១៩៨៩ គេមិនដែលលេចឮពីភាពខុសច្បាប់នៃការសង់លំនៅដ្ឋានលើដីទំនេរនៅក្នុងទីក្រុងនោះទេ ពីព្រោះថា រដ្ឋាភិបាលបានអនុវត្តគោលនយោបាយអនុញ្ញាត្តិអោយអ្នកចំនូលថ្មីមកទីក្រុងធ្វើការតាំងលំនៅដោយសេរីនៅលើផ្ទះដែលនៅទំនេរ និងនៅលើដីដែលនៅទំនេរ។ តែដល់ឆ្នាំ ១៩៩៤ ប្រជាជនប្រហែល ១២០.០០០ នាក់ ឬប្រហែល ១២-១៥ ភាគរយនៃចំនួន ប្រជាជនក្នុងទីក្រុងទាំងអស់ បានមករស់នៅលើដីដោយគ្មានការអនុញ្ញាត្តិ។[៤២] យោលលើការវាយតម្លៃលើផ្នែកសង្គមកិច្ចរបស់ គម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល (LMAP) នៅឆ្នាំ ២០០១ គេប៉ាន់ស្មានថា "*ប្រជាជនទាំងនេះអាចមានលើសពី ១៧៥.០០០ នាក់ ដែលមានការតាំងលំនៅរាយប៉ាយលើ ២០*

---

[៣៩] វិទ្យាស្ថានស្ថិតិជាតិកម្ពុជា នៃក្រសួងផែនការ (២០០៥)។ *របាយការណ៍ពីការធ្វើជំរឿនប្រជាជន ឆ្នាំ ២០០៤។* ភ្នំពេញ និង Kamayana, P., ក្នុងសុន្ទរកថាបើកសិក្ខាសាលាពិគ្រោះយោបល់មួយស្តីពីការអភិវឌ្ឍទីក្រុងរបស់ប្រទេសកម្ពុជា : ការវាយតម្លៃវិស័យ យុទ្ធសាស្ត្រ និងផែនការ បន្ទាប់ នៅសណ្ឋាគារ សាន់វេ នៃទីក្រុងភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១០ (http://www.adb.org/Documents/Speeches/2010/sp2010023.asp) ។

[៤០] របាយការណ៍នៃគម្រោងនៃការសិក្សាកម្មវិធីការផ្តល់កម្មសិទ្ធិដីក្នុងប្រទេសកម្ពុជា : ដំនាក់កាលទីក្រុង ទី ២ (សេចក្តីព្រាង)។ វិទ្យាស្ថានអភិវឌ្ឍធនធានកម្ពុជា សហការជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយលោក Ballard, B និងលោក Runsinarith, P. ភ្នំពេញ កម្ពុជា ខែ សីហា ឆ្នាំ ២០០៧ ទំព័រ ៤៩។

[៤១] *ការយល់ដឹងពីទីក្រុងនៅអាស៊ី : ភ្នំពេញ។* URC ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ភ្នំពេញ លោក Crosbie, D., ឆ្នាំ ២០០៤

[៤២] *សេចក្តីស្នើកម្មវិធីរយ:ពេល ១២ ខែ។* ក្រុមទីប្រជុំជន ភ្នំពេញ ឆ្នាំ ១៩៩៤។

*តំបន់សំណង់អាណាធិបតេយ្យ និងសង្កាត់ក្រីក្រ*"។[៤៣] ក្នុងរយៈពេល ៥ ឆ្នាំ គឺពីឆ្នាំ ២០០០-២០០៤ ចំនួនប្រជាជនក្នុងក្រុងភ្នំពេញ បានកើនឡើងប្រមាណជា ៣០០.០០០ នាក់ ។ បញ្ហានៃការកើនឡើងដោយគ្មានការ គ្រោងទុងនេះ គឺបានធ្វើអោយធ្ងន់ឡើងដោយការកើនឡើងដល់ទៅ ៤ ភាគរយ ជារៀងរាល់ឆ្នាំនៅក្នុងទីក្រុង រីឯការកើនឡើងទូទាំងប្រទេសមានតែត្រឹម ២,៥ ភាគរយប៉ុណ្ណោះ។[៤៤]

៧៦. ដោយសារតែមានតម្រូវការដីកើនឡើងតាមការត្រូវការរបស់ប្រជាជនដែលចេះតែកើន និងដោយសារគោលដីអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងការវិនិយោគ ក៏មានចលនាកាន់តែច្រើនឡើងៗនៃការបណ្តេញចេញដោយបង្ខំពីសំណង់អាណាធិបតេយ្យក្នុងទីក្រុង ភ្នំពេញអោយទៅតំបន់ចំងាយ ២០ គីឡូម៉ែត្រ ឬឆ្ងាយជាងនេះពីទីក្រុង។[៤៥] ជាមួយនឹងសំពាធពីអ្នកសាងសង់នានា ចាំបាច់មានការរើទីលំនៅកាន់តែច្រើនឡើងៗដើម្បីផ្តល់ឱកាសដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈអោយកាន់តែប្រសើរឡើង។[៤៦] ដីត្រូវបានជួលបន្តក្នុងតំបន់ទីក្រុងដែលរដ្ឋ និងសាលាក្រុងបានខំប្រឹងអភិវឌ្ឍដើម្បីប្រែក្លាយអោយសមជាប្រទេសរីកចំរើនមួយ។[៤៧] ក៏ប៉ុន្តែ មធ្យោបាយដើម្បីសម្រេចបាននូវគោលបំណងនេះ ត្រូវទទួលការរិះគន់យ៉ាងខ្លាំង ដោយសារតែការអនុវត្តមិនបានគិតគូរ ដល់អ្នកក្រីក្រដែលមានចំនួនច្រើន ហើយគិតតែទ្រព្យសម្បត្តិក្នុងដៃរបស់អ្នកមានអំណាចមួយក្តាប់តូច។ ជាសរុប គេប៉ាន់ស្មានថា ការបណ្តេញចេញដោយបង្ខំពីទីក្រុងភ្នំពេញ និងនៅកន្លែងផ្សេងទៀតបានប៉ះពាល់លើពលរដ្ឋច្រើនជាង ២៧.០០០ នាក់ ក្នុងឆ្នាំ ២០០៧។

៧៧. ភាពតានតឹងដោយការបណ្តេញចេញដោយបង្ខំអោយផ្លាស់ប្តូរទីលំនៅទាំងនេះ ជារឿយៗបាននាំអោយមានទំនាស់ហឹង្សា ជាច្រើនកើតឡើងលើបញ្ហាដីធ្លី។ ជាពិសេស ដីដែលសន្ទឹងតាមបណ្តោយមាត់ទន្លេក្នុងក្រុងភ្នំពេញ ដែលគេស្គាល់ជាទន្លេបាសាក់ បានត្រូវប្រែក្លាយពីដីទំនេរក្នុងឆ្នាំ ១៩៨៩ អោយទៅជាលំនៅដ្ឋានឬស្សី ផ្ទះធ្វើពីឈើ

---

[៤៣] *ការវាយតម្លៃលើផ្នែកសង្គមកិច្ច : ការសិក្សានៅទីវាល* រៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រះរាជាណាចក្រកម្ពុជា វិទ្យាស្ថានអភិវឌ្ឍធនធានកម្ពុជា ភ្នំពេញ ដោយលោក Sovannarith, S., Sopheap, R., Utey, U., Rathmony, S., Ballard, B., and Acharya, S ខែ ធ្នូ ឆ្នាំ ២០០១។

[៤៤] *ការយល់ដឹងពីទីក្រុងនៅអាស៊ី : ទីក្រុងភ្នំពេញ*។ ឆ្នាំ ២០០៤។

[៤៥] ប្រព័ន្ធធនាគារដែលមានកម្រិតបានធ្វើអោយមានការសន្សំដើម្បីយលទៅទីដីកាន់តែច្រើនឡើង។ ការវិនិយោគពីប្រទេសកូរ៉េ ចិន សង្ហបូរី និង ម៉ាឡេស៊ី យ៉ាងប្រញ៉ឹកបានធ្វើអោយតម្លៃដីកើនឡើងយ៉ាងខ្ពស់ ដែលក្នុងនោះដីទីក្រុងល្អៗកើនឡើងដល់នៅ ៣០-៥០ ភាគរយជារៀងរាល់ឆ្នាំ។ សូមអាន *នយោបាយនៃអ្វីៗដែលអាចធ្វើបាន : ការរស់នៅក្នុងទីក្រុងភ្នំពេញ*។ ឯកសារដែលបានបង្ហាញនៅសាលាសាលា Goldsmiths នៃសកលវិទ្យាល័យ London. ទីក្រុង London. គេហទំព័រអេឡិចត្រូនិច : http://www.n-aerus.net/web/sat/workshops/2006/papers/abdoumaliq.pdf

[៤៦] *គម្រោងបរិស្ថានសម្រាប់អភិវឌ្ឍសហគមន៍ក្នុងទីក្រុងភ្នំពេញ*។ មជ្ឈមណ្ឌលឯកសារទីក្រុង និងក្រសួងការបរទេស និងពាណិជ្ជកម្ម។ ភ្នំពេញ ឆ្នាំ ២០០៣។

[៤៧] *ការលើកកំពស់ស្ថេរភាពសិទ្ធិដីធ្លីសម្រាប់អ្នកក្រីក្រក្នុងទីក្រុងភ្នំពេញ នៃប្រទេសកម្ពុជា : ករណីសិក្សាបែបវិភាគ* អង្គការលំនៅដ្ឋានអន្តរជាតិ លេខ ២៨ (២) ដោយលោក Khemro, B.H.S. & Payne, G. ឆ្នាំ ២០០៤ ទំព័រ ១៨១-២០១។ សូមអាន *ការសិក្សាពី Land Availability for City Development in Phnom Penh Metropolitan Area*. Asian Coalition for Housing Rights, Phnom Penh. Sophy, E. ឆ្នាំ ២០០២។

និងប្រក់ស្បូវដែលសរុបមានប្រហែលជា ២.៧០០ គ្រួសារ។[៤៨] ការរីកចំរើនរបស់ទីក្រុងក្នុងទសវត្សឆ្នាំ ១៩៩០ មានលក្ខណៈលឿនតាមរបៀបការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច តែមានលក្ខណៈមិនផ្លូវការ ដូចជាការតាំងលំនៅតាមដងទន្លេបាសាក់ និងតំបន់បឹងកក់ជាដើម[៤៩] ដែលទាំងនេះត្រូវបានជ្រើសរើសជាទី តាំងសម្រាប់ការអភិវឌ្ឍ ដោយគ្មានការផ្តល់ការយល់ព្រមពីសំណាក់គ្រួសារដែលតាំងលំនៅនៅទីនោះបច្ចុប្បន្ន ហើយពួកគេភាគច្រើនបានអះអាងថាមានឯកសារមួយចំនួនដែលអាចឱ្យពួកគេអាចទាមទាររកសិទ្ធិកាន់កាប់ដីបាន។

៧៨. ការបណ្តេញចេញទាំងបង្ខំចំនួន ២ ដងថែមទៀតថ្មីៗនេះគឺមានអំពើហឹង្សាកើតឡើង ហើយធនាគារពិភពលោកបានចេញសេចក្តីថ្លែងការណ៍រួមមួយជាមួយនឹងដៃគូអភិវឌ្ឍដទៃទៀត ព្រមទាំងមានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលនានាផង ដោយធ្វើការទាមទារសុំការផ្អាកការបណ្តេញចេញទាំងនោះ។ នៅខែ មករា ឆ្នាំ ២០០៩ កងនគរបាលប្រដាប់អាវុធបានបង្ខិតបង្ខំបណ្តេញ គ្រួសារដែលនៅតំបន់ប្រជុំជនមួយក្នុងទីក្រុងភ្នំពេញ ដែលមានឈ្មោះថា ដីក្រហម។ មានរបាយការណ៍មកថា *"ជាង ៣០០គ្រួសារ (អ្នកជួល និងអ្នកលក់ក្នុងផ្សារ) ត្រូវបានបណ្តេញចេញទាំងបង្ខំពីតំបន់ដីក្រហម ហើយពួកគាត់ត្រូវគេអោយបោះជំរំជាបណ្តោះ អាសន្នក្នុងស្ថានភាពដ៏គួរឱ្យអាណោត នៅតំបន់ដំណាក់ត្រយឹង ដែលនៅជាយក្រុងភ្នំពេញ : ចេញឆ្ងាយពីការងាររបស់គេ ឆ្ងាយពីសេវាកម្មសុខាភិបាល និងសាលារៀន ពោលគឺពួកគាត់ត្រូវគេយកទៅបោះបង់ចោលក្រោយពេលបណ្តេញចេញពីលំនៅដ្ឋានរបស់ពួកគាត់"*។[៥០] ក្រោយមកក្នុងខែ កក្កដា ឆ្នាំ ២០០៩ ដដែលនោះ សហគមន៍នៅក្នុងក្រុមលេខ ៧៨ ក៏ត្រូវបណ្តេញចេញដោយ បង្ខំទៀត។ ដើមឡើយនៅក្នុងឆ្នាំ ២០០៤ សហគមន៍មួយដែលមាន ១៤៦ គ្រួសារ គឺក្រុមលេខ ៧៨ បានខំប្រឹងទាំងបរាជ័យដើម្បី ស្នើសុំកម្មសិទ្ធិលើដី ដែលមានលំនៅដ្ឋានរបស់ពួកគេ។ ចាប់ពីឆ្នាំ ២០០៦ មក សហគមន៍នេះបានទទួលប្រកាសដំណឹងចំនួន ៦ ដង ដើម្បីអោយពួកគេចេញពីលំនៅដ្ឋានរបស់ពួកគេ ហើយគ្រួសារខ្លះបានសុខចិត្តចុះចេញដោយសារសំពាធនោះ។ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩ ប្រកាសដំណឹងចុងក្រោយមួយបានចេញដើម្បីបណ្តេញ គ្រួសារដែលនៅសេសសល់ពេលនោះប្រហែលជា ៨០ គ្រួសារ។ សហគមន៍នោះបានប្រឹងប្រែងម្តងទៀតដើម្បីប្តឹងតវ៉ារកច្បាប់ទល់នឹងប្រកាសបណ្តេញពួកគាត់ចេញនោះ ក៏នៅតែគ្មានប្រយោជន៍អ្វីដែរ។ តាមរយៈរបាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលមួយបានអោយដឹងថា ពាក្យបណ្តឹងទាំង

---

[៤៨] សមាគម ADHOC ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (២០០៧)។ *របាយការណ៍ស្ថានភាពសិទ្ធិមនុស្ស* ធ្វើនៅភ្នំពេញ ទំព័រទី ៣។

[៤៩] តំបន់បឹងកក់នេះសរសេរខុសៗគ្នាក្នុងភាសាអង់គ្លេស ខ្លះសរសេរជា Boeung Kak, ខ្លះទៀត Boeung Kok និងខ្លះទៀត Boeng Kak។ របាយការណ៍នេះសរសេរជា Boeung Kak។

[៥០] របាយការណ៍សកម្មភាពរបស់អង្គការ LICADHO : ការការពារ និងការលើកកំពស់សិទ្ធិមនុស្សនៅកម្ពុជា រាយការណ៍ក្នុងកំឡុងពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ LICADHO ទំព័រ ២៧

នោះនៅរង់ចាំក្នុង សាលាដំបូងក្រុង និងគណៈកម្មការសុរិយោដីនៅឡើយទេ តែពួកគាត់ត្រូវបានគេបណ្តេញចេញដោយបង្ខំនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩។[៥១]

៧៩. នៅបច្ចុប្បន្ននេះមានការតាំងលំនៅដ្ឋានមិនផ្លូវការជាង ៥០០ កន្លែងផ្សេងទៀត នៅក្នុងនិងជុំវិញទីក្រុងភ្នំពេញ នៅលើទាំងដីឯកជន និងដី សាធារណៈរបស់រដ្ឋ។[៥២] ការសិក្សាជាមូលដ្ឋានមួយលើទីប្រជុំជនដែលធ្វើឡើងដោយគម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល (LMAP) បានញែកដាច់ការតាំងលំនៅដ្ឋានមិនផ្លូវការជា ៣ ប្រភេទ : "(១) *ការតាំងលំនៅលើដីឯកជនរបស់រដ្ឋ ដែលចាត់ទុកជាទ្រព្យ សម្បត្តិរបស់ក្រសួង (២) ការតាំងលំនៅលើដីសាធារណៈរបស់រដ្ឋ ដែលចាត់ទុកជាដីសំរាប់សេវាសាធារណៈ ដូចជាស្ថានីយរថភ្លើង សួនច្បារ បឹង ទន្លេ ស្ទឹង និងព្រៃឈើដែលដីទាំងនេះមានប្រហែល ៣០ ភាគរយ នៃតំបន់អភិវឌ្ឍនៅភ្នំពេញ, និង (៣) ការតាំង លំនៅលើដីឯកជន ដែលមានប្រហែល ៦៥ ភាគរយនៃការតាំងលំនៅដ្ឋានមិនផ្លូវការសរុប។*"[៥៣] ដូចមានបង្ហាញនៅក្នុងរូបភាពទី ១ និងទី ២ ខាងក្រោម ប្រជាជននៅក្នុងសំណង់អាណាធិបតេយ្យនៅទីក្រុងភ្នំពេញ និងទូទាំងប្រទេសគឺត្រូវបានប៉ាន់ស្មានថានឹង កើនឡើងយ៉ាងខ្លាំងនៅឆ្នាំ ២០២០។




*ប្រភព : លំនៅដ្ឋានអង្គការសហប្រជាជាតិ (២០០៥)។ "និន្នាការប្រជាជននៅក្នុងសំណង់អាណាធិបតេយ្យតាមប្រទេស ពីឆ្នាំ ១៩៩៩-២០២០ ក្នុងសេណារីយ៉ូការពារនិងលើកកំពស់នានា។ ការប៉ាន់ស្មានពីសំណង់អាណាធិបតេយ្យដំបូង។" សេចក្តីព្រាង។ កម្មវិធីអង្គការសហប្រជាជាតិដើម្បីការសង់លំនៅដ្ឋាន, ក្រុង Nairobi និង Heinenon (២០០៨) ដកស្រង់ពី SUPF (២០០៣) សាលាក្រុងភ្នំពេញ (២០០៥)*

---

[៥១] *គ្មានចំណេងជើង : អស្ថេរភាពកម្មសិទ្ធិដីធ្លី និងអសមភាពវិស័យដីធ្លីក្នុងប្រទេសកម្ពុជា* ដោយ Bridges Across Borders South East
Asia (BABSEA), Centre on Housing Rights and Evictions (COHRE), Jesuit Refugee Services (JRS), ទំព័រ ៣៨ ។

[៥២] មជ្ឈមណ្ឌលធនធានទីក្រុង (២០០២)។ *ការសិក្សាស្តីពីការផ្លាស់ប្តូរលំនៅដ្ឋានរបស់សហគមន៍ក្រីក្រក្នុងទីប្រជុំជនក្នុងក្រុងភ្នំពេញ។* Asian
Coalition for Housing Rights: ភ្នំពេញ និង ការកើនឡើងនៃស្ថេរភាពកម្មសិទ្ធិដី និងជម្រើសនានាក្នុងការតាំងលំនៅដ្ឋានថ្មីក្នុងទីក្រុងភ្នំពេញ : របាយការណ៍ឆ្នាំ ២០០៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សាលាក្រុងភ្នំពេញ លំនៅដ្ឋានអង្គការសហប្រជាជាតិ និងអង្គការ GTZ នៅកម្ពុជា។

[៥៣] Baseline Study Urban Phase II, p. 38.

៨០. ក្នុងខែ ឧសភា ឆ្នាំ ២០០៣ នាយករដ្ឋមន្ត្រីបានប្រកាសពីបំណងរបស់រដ្ឋាភិបាលក្នុងការធ្វើអោយប្រសើរឡើងនូវទីតាំងនៃ លំនៅដ្ឋានមិនផ្លូវការ (តំបន់សំណង់អាណាធិបតេយ្យ)ចំនួន ១០០ ជារៀងរាល់ឆ្នាំក្នុងក្រុងភ្នំពេញរយៈពេល ៥ ឆ្នាំ។[៥៤] ការផ្តួច ផ្តើមដ៏មានមហិច្ឆិតានេះបានធ្វើអោយសហគមន៍ដែលរស់នៅក្នុងលំនៅដ្ឋានទាំងនោះមានក្តីសង្ឃឹមឡើងវិញថា ស្ថាប័នរដ្ឋាភិបាល ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននឹងយកវិធីសាស្ត្រជួយគាំទ្រពួកគាត់ដើម្បីលើកកំពស់ស្ថានភាពកម្មសិទ្ធិដីធ្លីរបស់ពួកគាត់ដើម្បី ឱ្យអាចមានទំនុកចិត្តជាប្រជាជនពេញលេញនិងអាចធ្វើការកែលម្អផ្ទះគាត់ និងបរិស្ថានជុំវិញអោយកាន់តែល្អប្រសើរជាងមុន។ ក៏ប៉ុន្តែការផ្តួចផ្តើមដ៏វិជ្ជមាននេះមិនបានចេញជារូបរាងនៅឡើយទេ។ ក្រៅពីឧទាហរណ៍មួយដែលយើងឃើញពីគម្រោងកែលម្អ លំនៅដ្ឋានរបស់គ្រួសារដែលប្តឹងទាមទារកម្មសិទ្ធិផ្ទះបណ្តោះអាសន្នរបស់គាត់ទៅជាផ្ទះអចិន្ត្រៃយ៍ ដូចក្នុងករណីគម្រោងនៅតំបន់បូរីកីឡាជាដើមនោះ[៥៥] គេមិនទាន់ឃើញមានកំណត់ច្បាស់លាស់ពីគោលនយោបាយនៃការផ្លាស់ប្តូរទីលំនៅណាមួយឬជម្រើស ចែករំលែកដីធ្លីសំរាប់ការអភិវឌ្ឍនៅឡើយទេ។

៨១. ការខ្វះខាតនូវគោលនយោបាយជាតិនៃការផ្លាស់ប្តូរទីលំនៅ ដែលទទួលស្គាល់និងការពារតម្រូវការស្របច្បាប់នៃក្រុមប្រជាជនដែលងាយទទួលរងគ្រោះបំផុត ព្រមជាមួយនឹងការខ្វះខាតនូវការធ្វើផែនការអោយបានត្រឹមត្រូវ និងការសហការរវាងអ្នកពាក់ព័ន្ធទាំងអស់ បាននាំអោយមានផលប៉ះពាល់ជាអវិជ្ជមានជាច្រើនលើផ្នែកសង្គមកិច្ច ហើយការបណ្តេញចេញទាំងបង្ខំនានា បានធ្វើអោយមានការបំផ្លេចបំផ្លាញយ៉ាងច្រើនទាំងផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច។[៥៦] ដោយសារតែសិទ្ធិទទួលបានដីដែលស្របច្បាប់ និងមានតម្លៃសមរម្យ ជាបុរេល័ក្ខខ័ណ្ឌសម្រាប់ការអភិវឌ្ឍ វាជាបញ្ហាចំបងមួយដែលម្ចាស់ជំនួយបានធ្វើការយ៉ាងសកម្មអស់ជាច្រើនក្នុងការគាំទ្រដល់ទាំងរដ្ឋាភិបាលថ្នាក់ជាតិនិងមូលដ្ឋាន និងផ្នែកក្រៅរដ្ឋាភិបាលជាច្រើនដទៃទៀត។

---

[៥៤] នេះជាលទ្ធផលនៃកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលមួយហៅថាមូលនិធិសម្រាប់ការអភិវឌ្ឍជនក្រីក្រក្នុងទីក្រុងដោយរួមមានការគាំទ្រយ៉ាងសកម្មពី Asian Coalition of Housing Rights ។

[៥៥] គម្រោងចែកដីនៅតំបន់បូរីកីឡាគឺមានទីតាំងនៅចំស្តាតចាស់ក្នុងកណ្តាលរាជធានីភ្នំពេញ។ ក្នុងផ្ទៃដីសរុប ១៤ ហិកតា មានតែ ២ ហិកតាប៉ុណ្ណោះដែលត្រូវរក្សាទុកធ្វើជាផ្ទះល្វែងជូនដល់អ្នកដែលមានលំនៅដ្ឋាននៅទីនោះ។ អាជ្ញាធរនានាបានប្រកាសថាទីតាំងនោះគឺជារបស់ក្រសួង អប់រំ យុវជន និងកីឡា ក៏ប៉ុន្តែដូចដីក្នុងតំបន់បូរីកីឡាដែរ គ្រួសារនៅទីនោះ ភាគច្រើនអាចមានសិទ្ធិស្របច្បាប់ដើម្បីទាមទារយកកម្មសិទ្ធិក្នុងការកាន់កាប់ទ្រព្យសម្បត្តិពីព្រោះពួកគេអាចចូលក្នុងល័ក្ខខ័ណ្ឌទាំង ៥ ក្នុងការទទួលបានសិទ្ធិស្របច្បាប់ដើម្បីកាន់កាប់ ដូចចែងក្នុងច្បាប់ដីធ្លីឆ្នាំ ២០០១។ ទោះជាមានគ្រួសារភាគច្រើននិយាយថាគេសប្បាយចិត្ត ជាមួយនឹងលំនៅដ្ឋានថ្មីរបស់ពួកគេក៏ដោយមានរបាយការណ៍ថាគម្រោងនោះ បានមានការសម្រុះសម្រួលជាច្រើនដោយខ្វះតម្លាភាព មានការរំលោភបំពាន និងការកេងប្រវ័ញ្ចលើតម្លៃយ៉ាងច្រើន។ ជាលទ្ធផលនៃនីតិវិធីនៃ ការប្រតិបត្តិនិងការត្រួតពិនិត្យមិនគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ មានគ្រួសារម្ចាស់ដើមនៅតំបន់បូរីកីឡាតិចតួចបំផុតដែលទទួលបានសិទ្ធិរស់នៅលើអាគារសាងសង់ថ្មីនៅនោះ។ 'From "Squatters" to Citizens? Slum Dwellers, Developers, Land Sharing and Power in Phnom Penh, Cambodia. Rabé, P. 2009. Doctoral dissertation (DPPD), University of Southern California page 399)

[៥៦] ការលើកម្ពស់សុវត្ថិភាពកម្មសិទ្ធិដីធ្លីនៅទីក្រុងភ្នំពេញឆ្នាំ ២០០៤។

គេឃើញច្បាស់ហើយថា មានការរីកចំរើនក៏ពិតមែន តែនៅមានកន្លែងដែលអាចគួរត្រូវបញ្ជាក់ពីផ្លូវច្បាប់ បញ្ញានីតិវិធី និងការអនុវត្តជាដើមដើម្បីការពារ ឱ្យប្រជាជនភាគច្រើនអាចទទួលបានស្ថេរភាពមូលដ្ឋាន ទទួលបាន សិទ្ធិ និងយុត្តិធម៌លើអ្វីដែលត្រូវធ្វើទៅលើពួកគេ។

## ឃ. សាវតានៃព្រឹត្តិការណ៍នៅតំបន់បឹងកក់

### ១. ប្រវត្តិនៃការតាំងលំនៅនៅតំបន់នោះ

៨២. នៅដើមសតវត្សថ្មីនេះ តំបន់បឹងកក់លាតសន្ធឹងលើផ្ទៃដីប្រមាណ ៩០ ហិកតា (សូមមើលរូបភាពទី ១)។ នៅរបបខ្មែរក្រហម តំបន់ជុំវិញនោះមានភូមិចិញ្ចឹមត្រីតូចមួយនៅផ្នែកខាងលិច តែមានប្រជាជនដែលរស់នៅទីនោះតិចតួចបំផុតរហូតដល់ ក្រោយការរំដោះក្រុងភ្នំពេញមកវិញក្រោយរបបខ្មែរក្រហមបានបញ្ចប់។[៥៧] ពេលដែលប្រជាជនបានត្រឡប់មករស់នៅក្នុងក្រុងភ្នំពេញ និងតំបន់ប្រជុំជនឯទៀតវិញ អ្នកដែលមានគំនិតផ្ដួចផ្ដើមខ្ពស់បំផុត ឬក៏អ្នកដែលមានទំនាក់ទំនងល្អ អាចចាប់យកដីយ៉ាងលឿន និងទទួលបានកម្មសិទ្ធិលើទ្រព្យសម្បត្តិដែលមានតម្លៃខ្ពស់បំផុត។ ពេលដែលដីទាំងនេះត្រូវចុះបញ្ជី អ្នកចំណាកស្រុកដែលត្រឡប់មកភូមិករវិញពីតំបន់ព្រំដែន ដែលមិនមានទំនាក់ទំនង ឬគ្មានអំណាច ពួកគាត់មិនអាចតវ៉ាយកទ្រព្យសម្បត្តិដើមរបស់គាត់វិញបានទេ ហើយថែមទាំងត្រូវគេបង្ខំអោយចាកចេញទៅរកទីលំនៅថ្មីណាដែលគេអាចទៅរកបាន។ ជាមួយនឹងការកើនឡើង យ៉ាងខ្ពស់នៃចំនួនអ្នកមករស់នៅក្នុងទីក្រុង ទីលំនៅស្របច្បាប់ត្រូវបានគេចាប់យកអស់ ហើយគ្រួសារជាច្រើនត្រូវគេបង្ខំអោយ ចាកទៅរកទីកន្លែងដែលមានដីទំនេរ។




**រូបភាពទី ៣ : រូបភាពពីលើអាកាសនៃតំបន់បឹងកក់ (ម៉ាន លីម ២០០៦)**

[៥៧] តំបន់ដីសើមនៅទីប្រជុំជន និងផែនការទីក្រុង : ករណីសិក្សាតំបន់ដីសើមនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ដោយលោក អ៊ុន ចាក់ត្រី ឆ្នាំ ២០០៩ ទំព័រ ២៤ និង ៣៥។

៨៣. ពេលដែលការសង់លំនៅដ្ឋានកាន់តែមានលំនឹងឡើង ក្នុងពេញមួយទសវត្សឆ្នាំ ១៩៨០ ស្ថានភាពក៏កាន់តែមានភាពតានតឹងឡើងៗជាងមុន ជាពិសេសនៅពេលដែលប្រជាជនខ្លះបានទាមទារថាសាលាក្រុងត្រូវទទួលខុសត្រូវលើការបែងចែកដីសំរាប់សង់លំនៅដ្ឋានក្នុងតំបន់នោះ។ ប្រជាពលរដ្ឋម្នាក់បាននិយាយទទូចថា ក្នុងឆ្នាំ ១៩៨៥ គាត់បានសាលាក្រុងអោយមករស់នៅតំបន់នេះ ក្រោយពីពេលដែលកន្លែងដែលគាត់នៅពីមុនមកនោះត្រូវបានអាជ្ញាធរយកទៅធ្វើជាសួនកំសាន្តសប្បាយមួយ។ គាត់ក៏ត្រូវបានផ្តល់ ជូននូវដីមួយកន្លែងហើយគេប្រាប់គាត់ថាគាត់អាចរស់នៅទីនោះ "បានមួយរយៈ" ក៏ប៉ុន្តែនោះគឺជាង ២០ ឆ្នាំមកហើយ។ ជាដំបូង គាត់គ្រាន់តែសាងសង់ខ្ទមតូចមួយប៉ុណ្ណោះ តែយូរៗទៅគាត់បានសាងសង់បន្ថិចម្តងៗរហូតបានដល់ ៣ អាគារក្នុងដីដ៏តូចមួយ។ គាត់បានបន្តថានាយករដ្ឋមន្ត្រីបាននិយាយថាប្រសិនបើអ្នករស់នៅកន្លែងណាមួយលើសពី ៥ ឆ្នាំ អ្នកអាចទទួលបានប័ណ្ណកម្មសិទ្ធិលើដីនោះ។ គាត់មានឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងសៀវភៅគ្រួសារពីកន្លែងចាស់មក តែគ្មានប័ណ្ណកម្មសិទ្ធិ។

៨៤. នៅឆ្នាំ ១៩៩១ ពេលដែលប្រទេសជាតិកំពុងរៀបចំការបោះឆ្នោតជាលើកដំបូងរបស់ខ្លួន ដីភាគច្រើននៅជុំវិញបឹងនេះត្រូវបានគេនៅពេញទៅហើយ។[៥៨] មានការតំណាលប្រាប់រឿងរ៉ាវដែលគណៈបក្សនយោបាយនានាក្នុងការស្វែងរកសន្លឹកឆ្នោតរបស់ខ្លួន បានលើកទឹកចិត្តអោយប្រជាជនទៅនៅទីនោះនិងសាងសង់លំនៅដ្ឋានក្នុងតំបន់នោះ ហើយប្រជាជនរស់នៅទីនោះបាននិយាយថា ពួកគាត់មានឯកសារគ្រប់គ្រាន់ដែលបញ្ជាក់ថាពួកគាត់អាចទទួលបានកម្មសិទ្ធិក្នុងការកាន់កាប់ដីដែលកំពុងនៅ (សូមអាន ប្រអប់លេខ ១ ក្នុងជំពូក ១)។ គ្រួសារជាច្រើនបាន តវ៉ាថាពួកគេមានឯកសារដែលបញ្ជាក់ពីកម្មសិទ្ធិ រីឯគ្រួសារដទៃទៀតមានឯកសារដែលពួកគេនិយាយថាត្រូវបានផ្តល់ឱ្យដោយអាជ្ញាធរមូលដ្ឋាននានាក្នុងកំឡុងឆ្នាំ ១៩៩០ តាមរយៈប្រព័ន្ធកម្មសិទ្ធិដែល "មិនផ្លូវការ" រួមមានការ ចេញជាលេខផ្ទះ សៀវភៅគ្រួសារ កិច្ចសន្យាកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចសន្យាលក់ដីដែលមានសាក្សីជាផ្លូវការផង។



**រូបភាពទី ១ ផ្ទះសម្បែងដ៏ចង្អៀតនៅក្នុងតំបន់បឹងកក់**

---

[៥៨] *ការលើកកំពស់ស្ថេរភាពសិទ្ធិដីធ្លីសម្រាប់អ្នកក្រីក្រក្នុងទីក្រុងភ្នំពេញ នៃប្រទេសកម្ពុជា : ករណីសិក្សាបែបវិភាគ* ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភ្នាក់ងារសម្រាប់ការអភិវឌ្ឍ (ប្រទេសអង់គ្លេស) ដោយលោក បេងហុង សុជាតិខេមរ៉ូ និង លោក Payne, G ឆ្នាំ ២០០៤ ទំព័រ ១៦។

៨៥. ការសិក្សាស្ទង់មតិមួយធ្វើឡើងដោយមជ្ឈមណ្ឌលធនធានទីក្រុង នៅទីក្រុងភ្នំពេញក្នុងចុងឆ្នាំ ២០០១ បានបង្ហាញឱ្យឃើញថា ស្ទើរតែ ៧០ ភាគរយនៃគ្រួសារទាំងនោះចង់បន្តរស់នៅក្នុងតំបន់នោះទៀត ហើយអាចមានឱកាសដើម្បីកែលម្អផ្ទះ សម្បែងរបស់ពួកគេ។[៥៩] ក្នុងកំឡុងចុងឆ្នាំ ១៩៩០ តំបន់នេះក្លាយជាតំបន់ពេញនិយមមួយសំរាប់ភ្ញៀវទេសចរណ៍បរទេស ដែលជាពិសេសភ្ញៀវទេសចរណ៍បរទេសកាបូបស្ពាយដែលមានថវិកាតិចតួច និងមានផ្ទះសំណាក់ដែលធ្វើលើទំរឈើនៅពីលើទឹកបឹង និងខ្លះទៀតនៅលើមាត់ទឹក។ ជាមួយនឹងតម្លៃស្នាក់នៅប្រហែល ៣-១០ ដុល្លាអាមេរិកក្នុងមួយយប់ ផ្ទះសំណាក់ទាំងនោះអាច ផ្តល់ការស្នាក់អាស្រ័យក្នុងបរិស្ថានតែមួយ ទោះជាមានមូសតែនេះជាការផ្តល់នូវប្រភពចំនូលមួយយ៉ាងសំខាន់សំរាប់ប្រជាជននៅទីនោះ។ ភ្ញៀវទេសចរណ៍បរទេសទាំងនោះក៏បានរីករាយនឹងការប្រើប្រាស់នូវសេវានានាផ្សេងទៀតនៅទីនោះផងដែរ ដូចជាបារ និង ភោជនីយដ្ឋាន ក៏ដូចជាមានផ្សារផងដែរ។ ច្បាស់ណាស់ ចាប់ពីសតវត្សថ្មីនេះមកដល់ មានការមករស់នៅតំបន់នៅជុំវិញបឹងនេះយ៉ាងណែនណាន់តាន់តាប់ ហើយទ្រព្យសម្បត្តិជាច្រើនត្រូវបានកែលម្អដោយម្ចាស់នៅទីនោះ។

## ២. ប្រភេទនៃកម្មសិទ្ធិដីនៅតំបន់នោះ

៨៦. ប្រភេទនៃកម្មសិទ្ធិដីនៅតំបន់បឹងកក់ និងជុំវិញតំបន់នោះមានផ្សេងៗគ្នាជាច្រើនប្រភេទ។ ក្នុងនាមជាបឹងធម្មជាតិមួយ បឹងនេះត្រូវបានកំណត់ដោយមាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ជាទ្រព្យសម្បត្តិរបស់រដ្ឋ និងក្នុងមាត្រា ១៥ នៃច្បាប់ដីធ្លីឆ្នាំ ២០០១ ជាដីសាធារណៈរបស់រដ្ឋ។ ខុសពីស្ទឹង ដែលមាត់ស្ទឹងក៏ត្រូវបានកំណត់ថាជាដីសាធារណៈរបស់រដ្ឋដែរនោះ ប្រកាសពាក់ព័ន្ធ មួយ[៦០] បានកំណត់បរិវេណរុំព័ទ្ធបឹងនៅរដូវដែលមានទឹកតិចបំផុតក្នុងខែប្រាំង។ រាល់ដីនៅពីលើនេះត្រូវបានកំណត់ថាជាដីឯកជន របស់រដ្ឋ លើកលែងតែវាអាចប្រើប្រាស់ជាផលប្រយោជន៍សាធារណៈ។ ដូច្នេះអ្នកកាន់កាប់ដីក្នុងតំបន់ទាំងនេះអាចមានសិទ្ធិទទួល បាននូវការផ្តល់សិទ្ធិកាន់កាប់ស្របច្បាប់បាន។

៨៧. ផ្នែកខាងត្បូងនៃដីបឹងនេះគឺលាតសន្ធឹងដោយខ្សែផ្លូវរថភ្លើងដែលមិនដំណើរការ។ ទោះជាដីដែលបំរុងទុកធ្វើផ្លូវរថភ្លើងនេះ ត្រូវបានចាត់ទុកដោយស្របច្បាប់ថាជាដីសាធារណៈរបស់រដ្ឋក៏ដោយ ប៉ុន្តែផ្លូវរថភ្លើងទាំងនោះមិនដំណើរការជាយូរឆ្នាំមកហើយ ហើយគេអាចចាត់ទុកថាបាត់បង់ផលប្រយោជន៍សាធារណៈទៅហើយ។ ដូច្នេះដីនោះអាចត្រូវចាត់ទុកថាជាដីឯកជនរបស់រដ្ឋ និង អាចឱ្យគេយកកាន់កាប់បាន។ មានភស្តុតាងពីករណីសិក្សានានា (សូមអានប្រអប់លេខ ២) ដែលថាអាជ្ញាធររាជាយស្ម័យយាន ខ្លួនឯងផ្ទាល់ក៏បានលើកទឹកចិត្តឱ្យបុគ្គលិករបស់ខ្លួនចាប់យកដីដែលនៅជិតបរិវេណផ្លូវរថភ្លើងនេះផងដែរនៅក្នុងកំឡុងដើមឆ្នាំ ១៩៨០ សំរួលអោយការសង់ផ្ទះនៅជិត

---

[៥៩] ការសិក្សាពីការផ្លាស់លំនៅដ្ឋានរបស់សហគមន៍ក្រីក្រក្នុងតំបន់ប្រជុំជន ក្នុងទីក្រុងភ្នំពេញ។ មជ្ឈមណ្ឌលធនធានទីក្រុង។ ភ្នំពេញឆ្នាំ ២០០២។

[៦០] ប្រកាសលេខ ៤២ ដ.ន.ស. ប.ក. ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកំណត់ ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។

កន្លែងធ្វើការ។ អ្នករស់នៅទីនោះជាច្រើនអ្នកបានបង្ហាញថាខ្លួនមានឯកសារដែលគាំទ្រដល់ ការទាមទាររបស់ពួកគេ ហើយដែលបង្ហាញថាពួកគេអាចទទួលបានប័ណ្ណកម្មសិទ្ធិ ជាពិសេសប្រសិនបើពួកគេបានរស់នៅលើដីនោះ អស់រយៈពេលជាង ៥ ឆ្នាំមុនពេលច្បាប់ដីធ្លីឆ្នាំ ២០០១ បានចូលជាធរមាន។

៨៨. ជាចុងបញ្ចប់ តំបន់ដទៃទៀតនៅជុំវិញបឹងកក់នេះមានគេរាយការណ៍ថាត្រូវបានប្រើប្រាស់ជាសួនច្បារសាធារណៈ និងធ្វើជា សួនសត្វផងនៅពេលណាមួយនោះ ក្រោយពេលដែលទីក្រុងភ្នំពេញបានរំដោះរួចពីឆ្នាំ ១៩៧៩ មក។ ពេលដែលសួនច្បារត្រូវគិតថា ជាដីសាធារណៈរបស់រដ្ឋ នេះអាស្រ័យលើមានការពិនិត្យ និងចុះបញ្ជីរួចត្រឹមត្រូវ។ ក្នុងករណីតំបន់បឹងកក់ ចំណុចជាក់លាក់ពី បរិវេណរបស់សួនច្បារ និងនិន្នាការនៃការសង់លំនៅដ្ឋាន គឺមិនមានទេ ហើយអាជ្ញាធរនានាមិនបានចុះបញ្ជីដីនោះអោយជាដីរដ្ឋនៅឡើយទេ។ នេះគឺបញ្ជាក់ម្តងទៀតហើយថា ដីដែលមិនទាន់ច្បាស់លាស់គឺដីឯកជនរបស់រដ្ឋ រហូតដល់មាននីតិវិធីនៃការវិនិច្ឆ័យ សមស្របមួយធ្វើឡើងដើម្បីដោះស្រាយបញ្ហានៃការប្រកាសរបស់រដ្ឋ ការប្តឹងតវ៉ាពីអ្នកកាន់កាប់ដីបច្ចុប្បន្ន និងអ្នកប្តឹងដទៃទៀត។

## ៣. ការផ្តួចផ្តើមក្នុងការអភិវឌ្ឍសំរាប់តំបន់នេះ

៨៩. ក្នុងឆ្នាំ ២០០៣ ការព្យាករណ៍ពីស្ថេរភាពកម្មសិទ្ធិដីយូរអង្វែង និងការកែលម្អបរិស្ថានខាងក្រៅត្រូវបានធ្វើឡើងយ៉ាងខ្លាំងក្លា ដោយប្រជាជនរស់នៅក្នុងតំបន់បឹងកក់នេះ ព្រមទាំងសំណង់អាណាធិបតេយ្យនានាជាច្រើនកន្លែងទៀតក្នុងទីក្រុងភ្នំពេញ។ បន្ទាប់ពីមានការប្រឹងប្រែងក្នុងការអភិវឌ្ឍសហគមន៍យ៉ាងលឿនដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក រាជរដ្ឋាភិបាលបានប្រកាសថា នឹងសំរេចធ្វើការកែលម្អសំណង់អាណាធិបតេយ្យទាំង ៥០០ កន្លែង ក្នុងក្រុងភ្នំពេញ ហើយសន្យាថានឹងធ្វើឱ្យបានក្នុងកំឡុងពេល ៥ ឆ្នាំ។ ផ្នែកមួយនៃតំបន់បឹងកក់ក៏ត្រូវបានជ្រើសរើសធ្វើជាករណីសិក្សានៅក្នុងកម្មវិធីកែលម្អនេះដែរ។ ការអភិវឌ្ឍទាំងនេះបង្កើតអោយ ប្រជាជនក្នុងតំបន់នោះមានក្តីសង្ឃឹមកើនឡើងថាពួកគេនឹងអាចមានកម្មសិទ្ធិលើដីគាត់ស្របច្បាប់ និងអាចវិនិយោគបន្ថែមក្នុងការកែលម្អលំនៅដ្ឋាន និងបរិស្ថានរស់នៅជុំវិញរបស់ពួកគេ។

៩០. បន្ទាប់មក ក្នុងឆ្នាំ ២០០៤ ការប្រកួតប្រជែងផ្នែកគំរូប្លង់អន្តរជាតិមួយត្រូវបានប្រកាសឡើងដើម្បីជ្រើសរើសសំណើដែលល្អបំផុតសំរាប់អភិវឌ្ឍតំបន់នេះ។[៦១] យោងលើខ្លឹមសារសង្ខេបរបស់ការប្រកួតប្រជែង(ការដេញថ្លៃ?)នេះមានសំណើដែលនឹងធ្វើឱ្យតំបន់បឹងនេះក្លាយជាតំបន់ "អត្តសញ្ញាណ" ពិសេស ដែលនឹងធ្វើអោយទីក្រុងភ្នំពេញមានរូបភាពជា "គុជនៃទ្វីបអាស៊ី"។ ខ្លឹមសារសង្ខេបនៃសំណើរនោះក៏បានបង្ហាញពីក្តីសង្ឃឹមផងដែរថានឹងមានការធ្វើផែនការដែលប្រកបដោយស្តង់ដារខ្ពស់ បញ្ចូលអត្តសញ្ញាណនៃប្រទេសកម្ពុជាជាមួយនឹងកេរ្តិ៍ឈ្មោះអន្តរជាតិ

---

៦១ ការប្រកួតប្រជែននេះត្រូវបានគ្រប់គ្រងរួមគ្នាដោយក្រុមហ៊ុនពិគ្រោះយោបល់មួយ និងសាលាក្រុងភ្នំពេញនៃរាជរដ្ឋាភិបាល។ ព័ត៌មានស្តីពីការ ពិភាក្សាជាពិស្តារលើសំណើរប្រកួតប្រជែងនេះមាននៅ Huybrechts, E. 2004. Boeng Kak: Projet d'aménagement urbain. Phnom Penh: Ambassade de France au Cambodge: service de coopération et d'action culturelle.

ដោយមានការស្ថាបនាឡើងវិញនូវទិដ្ឋភាពដើម និងឱ្យទៅជាកន្លែងកំសាន្ត ដោយស្វែងរកជម្រើសក្នុងការសាងសង់លំនៅដ្ឋានប្រកបដោយស្តង់ដារ តាមរយៈការអភិវឌ្ឍឡើងវិញ និងការរុះរើទីតាំង ក្នុងតំបន់ក្បែរបឹង ។

៩១. ក្នុងខែ មេសា ឆ្នាំ ២០០៧ សំណើរដែលឈ្នះការប្រកួតប្រជែងផ្នែកគំរូប្លង់អន្តរជាតិនោះត្រូវបានលើកយកទៅបង្ហាញនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការណែនាំអោយគិតគូរពីតម្រូវការការងាររបស់ប្រជាជនតាំងលំនៅខុសច្បាប់នៅទីនោះ ផ្លូវរថភ្លើងថ្នាក់អន្តរជាតិថ្មីមួយនឹងត្រូវសាងសង់ ព្រមទាំងមានអាគារទីស្តីការគណៈរដ្ឋមន្ត្រីថ្មីមួយនឹងត្រូវសាងសង់ផងដែរនៅក្បែរបឹងនោះ ។ បន្ទាប់ពីនោះមករដ្ឋាភិបាលក៏បានផ្តល់អំណាចដល់សាលាក្រុងភ្នំពេញក្នុងការរៀបចំគម្រោងអភិវឌ្ឍមួយ និងបង្កើតឱ្យមានផែនការមួយដើម្បីបញ្ចូលក្នុងផែនការមេឆ្នាំ ២០២០ ដែលកំពុងឋិតក្នុងដំណាក់កាលនៃការរៀបចំ ។[៦២] ចំនុចគន្លឹះនានា ក្នុងការឈ្នះបានសំណើរនេះរួមមាន :[៦៣]

- ធ្វើអាទិភាពឱ្យបឹងនេះមានតួនាទីជាសួតបៃតងនៃទីក្រុង និងធានាអោយមានតំបន់សួនច្បារមួយសំរាប់សាធារណៈជននៅជុំវិញបរិវេណនោះ ។
- បង្កើតឱ្យមានប្រព័ន្ធទឹកស្អាត និងកែលម្អផ្លូវទឹកធម្មជាតិមួយដែលតភ្ជាប់បឹងជាមួយនឹងផ្នែកដទៃទៀតនៃទីក្រុង ។
- មានផែនការសំរាប់ការផ្លាស់ប្តូរទីលំនៅសំរាប់គ្រួសារនៅទីនោះដើម្បីបិទតំបន់ជុំវិញបឹងនោះ ។
- មានការបង្កើតឡើងនូវការផ្សារភ្ជាប់រវាងការអភិវឌ្ឍដែលបានស្នើឡើងនេះជាមួយនឹងកន្លែងសំខាន់ៗដទៃទៀងដែល នៅជុំវិញបរិវេណទីប្រជុំជន (ដូចជាមណ្ឌលកីឡាអូឡាំពិច ផ្សារធំថ្មី តំបន់វត្តភ្នំ កំពូលអង់តែនទូលគោក និងស្ថានីយរថភ្លើ) ។

៩២. ក៏ប៉ុន្តែ ក្រោយពីការប្រកាសលទ្ធផលពីការប្រកួតប្រជែងផ្នែកគំរូប្លង់អន្តរជាតិសំរាប់តំបន់បឹងកក់នោះ រដ្ឋាភិបាលបានសំរេចធ្វើការអភិវឌ្ឍតំបន់នោះ នៅលើមូលដ្ឋានជាការសហការណ៍ជាមួយនឹងអ្នកសាងសង់ឯកជនមួយហៅថា ក្រុមហ៊ុន Shukaku ។ នៅថ្ងៃទី ០៦ ខែ កុម្ភះ ឆ្នាំ ២០០៧ MPP និង Shukaku បានចុះហត្ថលេខាជួលក្នុងរយៈពេល ៩៩ ឆ្នាំ ក្នុងតម្លៃ ៧៩ លានដុល្លា សហរដ្ឋអាមេរិក លើផ្ទៃដី ១៣៣ ហិកតា រួមទាំងបឹងនោះផងដែលបច្ចុប្បន្ននេះកំពុងតែត្រូវបានចាក់ដីបំពេញ ។ រដ្ឋាភិបាលក៏បាន ចេញអនុក្រឹត្យមួយដើម្បីកែប្រែតំបន់នោះឱ្យទៅជាដីឯកជនរបស់រដ្ឋ ។[៦៤] នេះគឺកាន់តែធ្វើឱ្យយើងឃើញច្បាស់ថា រាជ រដ្ឋាភិបាលបោះបង់ចោលសំណើដែលឈ្នះក្នុងការប្រកួតប្រជែងផ្នែកគំរូប្លង់អន្តរជាតិ ដែលគេហៅថា "ប្លង់គុជ" ហើយចាប់យកនូវដៃគូថ្មីខាងលើ ។

## ៤. នីតិវិធីវិនិច្ឆ័យក្រោមគម្រោងនេះ

---

[៦២] "គម្រោងក្រុងគុជរបស់អាស៊ី" ចុះក្នុងកាសែតភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៧) និង "ក្នុងពាក្យសំដីរបស់ពួកគេ : ទស្សនវិស័យ ឆ្នាំ ២០២០" ចុះក្នុងកាសែតភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨)

[៦៣] Boeng Kak: Projet d'aménagement urbain (ឆ្នាំ ២០០៤)

[៦៤] អនុក្រឹត្យលេខ ១០៨ សអ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨ ស្តីពីការប្រែក្លាយទីតាំងបឹងកក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអោយទៅ ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

៩៣. នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៦ សាលាក្រុងភ្នំពេញបានប្រកាសថាសង្កាត់ស្រះចកនឹងត្រូវជ្រើសរើសជាតំបន់ការងារដើម្បីធ្វើការផ្តល់ប័ណ្ណកម្មសិទ្ធិតាមរយៈប្រព័ន្ធរបស់គម្រោង MPP ។[៦៥] នេះបានធ្វើអោយគ្រួសាររស់នៅទីនោះមានក្តីសង្ឃឹមថាការទាមទាររបស់ពួកគេនឹងត្រូវគេយកទៅពិចារណា ហើយពេលដែលក្រុមគម្រោង LMAP ចាប់ផ្តើមធ្វើការនៅខែដដែលនោះដើម្បីស្រង់ទិន្នន័យនិងធ្វើការវាស់វែង គ្រួសារនៅតំបន់បឹងកក់បានស្នើសុំឱ្យមានការទទួលស្គាល់នូវការទាមទាររបស់ពួកគេទៅលើ ដីរបស់ពួកគេរៀងៗខ្លួន ។

៩៤. មួយភាគធំនៃគ្រួសារនៅទីនោះបានបញ្ជាក់ថាពួកគាត់មានឯកសារបញ្ជាក់ពីទាំងថ្នាក់ ខ័ណ្ឌ សង្កាត់ និងភូមិពី "សិទ្ធិកាន់កាប់" (ភាគច្រើនក្នុងទម្រង់ជាហត្ថលេខាលើលិខិតផ្ទេរសិទ្ធិ) ឬថាសៀវភៅគ្រួសារ និងវិក័យប័ត្របង់ប្រាក់ថ្លៃភ្លើងគឺជាភស្តុតាងពីការបានរស់នៅក្នុងតំបន់នោះចាប់ពីមុនឆ្នាំ ២០០១ ដែលស្របនឹងច្បាប់ដីធ្លី។ ដោយសារតែស្ថានភាពនៃកម្មសិទ្ធិលើដីតំបន់នោះមិនទាន់បានកំណត់ក្នុងច្បាប់ក៏ដោយ គ្រួសារទាំងនោះបានរក្សាក្តីសង្ឃឹមរបស់ពួកគេលើការប្តឹងតវ៉ារកប័ណ្ណកម្មសិទ្ធិ ហើយក្នុងករណីទាំងអស់ ពួកគេខំប្រឹងការពារលំនៅដ្ឋានរបស់ពួកគេក្នុងនីតិវិធីវិនិច្ឆ័យរបស់គម្រោង LMAP ។ គម្រោងនេះត្រូវបានផ្អាក់ដំណើរដោយធនាគារពិភពលោកនៅក្នុង ១ ខែក្រោយមក នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦ ដោយសារតែមានបញ្ហាលទ្ធកម្ម និងអភិបាលកិច្ចក្នុងការអនុវត្តគម្រោង ។

៩៥. ស្របតាមនីតិវិធីរបស់គម្រោង LMAP ផែនទីសុរិយោដីត្រូវតែដាក់បង្ហាញជូនសាធារណៈជន (នៅចន្លោះថ្ងៃទី ០៤ ខែ មករា ដល់ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៧) ការដាក់បង្ហាញជូនសាធារណៈជននេះបង្ហាញតែពីព្រំដែន និងបរិវេណភូមិប៉ុណ្ណោះ ដែល "គ្មានឈ្មោះម្ចាស់" និងមិនមានផែនទីដីឡូនីមួយៗឡើយ ដែលនេះបានបង្កឱ្យមានការបារម្ភជាខ្លាំងពីអ្នកស្រុក ។ គ្រួសារទាំង នោះនិយាយថាពេលពួកគេស្នើឱ្យមានការស៊ើបអង្កេតលើការ ទាមទាររបស់ពួកគេ ការស្នើសុំរបស់ពួកគេត្រូវបានបដិសេធ ដោយមានមូលហេតុថាពួកគេកំពុងរស់នៅក្នុង "តំបន់អភិវឌ្ឍ"។ ការភ័យខ្លាចដែលថាពួកគេនឹងមិនអាចមានកម្មសិទ្ធិ ស្របច្បាប់លើដីលំនៅដ្ឋានរបស់ពួកគេ ត្រូវបានបង្ហាញកាន់តែច្បាស់ នៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ នៅពេលដែលមានការប្រកាស ថារដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជួលជាមួយក្រុមហ៊ុន Shukaku ។

៩៦. ក្រោយបន្តិចមកក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ នោះ នៅក្នុងការជួបប្រជុំក្នុងសហគមន៍មួយ មានប្រជាជន ៣០០ គ្រួសារបានជួបជុំ ដើម្បីបង្ហាញជាសាធារណៈអំពីការឈឺចាប់របស់ពួកគេ លើការសម្រេចចិត្តរបស់សាលាក្រុងក្នុងការជួលដី ១៣៣ ហិកតាទៅឱ្យការអភិវឌ្ឍផ្នែកពានិជ្ជកម្ម ។ សារព័ត៌មានបានរាយការណ៍ថាមានប្រធានភូមិម្នាក់បាននិយាយថា គ្រួសារទាំងអស់មិនត្រូវភ័យក្លាយ ឬព្រួយបារម្ភអ្វីទាំងអស់ពីព្រោះថា "នឹងគ្មានអ្នកណាម្នាក់នឹងត្រូវបង្ខំឱ្យចេញពីតំបន់នោះទេព្រោះរដ្ឋាភិបាលមាន គោលនយោបាយមិនបណ្តេញចេញដោយបង្ខំទេ ។"[៦៦] នៅថ្ងៃទី ១៣ ខែ

[៦៥] សេចក្តីប្រកាសពីតំបន់ការងារផ្ញើពីសាលាក្រុងភ្នំពេញជូនទៅអភិបាលខ័ណ្ឌដូនពេញ លេខ ៨៣ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៦ ។

[៦៦] កាសែត ខាំបូឌាដេលី ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៧ ទំព័រ ១៧ ។

មីនា ឆ្នាំ ២០០៧ សាលាក្រុងភ្នំពេញបានចេញសេចក្តីថ្លែងការណ៍មួយ ហើយផ្តល់ដំណឹងជូនសាធារណៈជនជាពិសេសគ្រួសារដែលនៅតំបន់បឹងកក់ ឱ្យដឹងថាក្នុងកិច្ចសន្យាជួលដែល ចុះហត្ថលេខាជាមួយក្រុមហ៊ុន Shukaku នោះ គឺនឹងគ្មានការផ្លាស់ប្តូរទីលំនៅដ្ឋានរបស់ប្រជាជននៅតំបន់នោះអោយទៅទីតាំង ផ្សេងក្រៅក្រុងភ្នំពេញនោះទេ។ នៅក្នុងសេចក្តីថ្លែងការណ៍នេះដែរ សាលាក្រុងបានធានាយ៉ាងម៉ឺងម៉ាត់ថាគម្រោងអភិវឌ្ឍក្នុងតំបន់ បឹងកក់នេះនឹងត្រូវអនុវត្តទៅបានដោយមានការពិគ្រោះជាមួយនឹងក្រុមគ្រួសាររស់នៅក្នុងតំបន់នោះ។[៦៧]

**តារាង ១ : ព្រឹត្តិការណ៍តាមកាលបរិច្ឆេទនៅក្នុងតំបន់បឹងកក់ ទាក់ទងនឹងគម្រោង LMAP**

| កាលបរិច្ឆេទ | ព្រឹត្តិការណ៍ / សកម្មភាព |
|---|---|
| ខែ សីហា ឆ្នាំ ២០០៥ | ទីស្តីការគណៈរដ្ឋមន្ត្រីផ្តល់ដំណឹងដល់អភិបាលក្រុងភ្នំពេញពីកិច្ចព្រមព្រៀង "ជាគោលការណ៍" ជាមួយក្រុមហ៊ុន Shukaku ក្នុងការអភិវឌ្ឍតំបន់បឹងកក់ |
| ថ្ងៃ ៣ មករា ២០០៦ | ទីស្តីការគណៈរដ្ឋមន្ត្រីផ្តល់ដំណឹងដល់អភិបាលក្រុងភ្នំពេញពីកិច្ចសន្យា ជាមួយ ក្រុមហ៊ុន Shukaku ក្នុងការអភិវឌ្ឍតំបន់បឹងកក់ |
| ថ្ងៃ ៣១ មករា ២០០៦ | សេចក្តីប្រកាសដាក់ក្រុងភ្នំពេញជាតំបន់ការងារសំរាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិក្រោយគម្រោង LMAP |
| ខែ ឧសភា ២០០៦ - ខែ មករា ២០០៧ | LMAP LRTs បានធ្វើការស្ទង់មតិ និងវិនិច្ឆ័យក្នុងតំបន់សង្កាត់ស្រះចក។ គ្រួសារក្នុងតំបន់បឹងកក់បានស្នើសុំអោយមានការទទួលស្គាល់លើការប្តឹងទាមទារសិទ្ធិលើដីឡូរបស់ពួកគេ |
| ថ្ងៃ ៦ មិថុនា ២០០៦ | ការផ្អាកគម្រោង |
| ថ្ងៃ ៤ មករា-ថ្ងៃ ០២ កុម្ភះ ២០០៧ | ការបង្ហាញជាសាធារណៈពីទីតាំងចុះបញ្ជី ដែលបង្ហាញពីព្រំដែន និងបរិវេណភូមិនីមួយៗ (តែមិនមានឈ្មោះម្ចាស់កម្មសិទ្ធិ) |
| ថ្ងៃ ៥ ខែ មករា ២០០៧ | ការផ្អាកគម្រោងត្រូវបានលើកលែង- គម្រោងបន្តការអនុវត្ត |
| ថ្ងៃ ៦ ខែ មករា ២០០៧ | កិច្ចសន្យាជួលតំបន់បឹងកក់បានចុះហត្ថលេខារវាង MPP និងក្រុមហ៊ុនអភិវឌ្ឍឯកជន |
| ថ្ងៃ ១៣ ខែ មីនា ២០០៧ | សេចក្តីថ្លែងការណ៍ពីសាលាក្រុងភ្នំពេញដើម្បីជូនដំណឹងថាគ្រួសាររស់នៅតំបន់បឹងកក់ នឹងមិនត្រូវរុះរើទីលំនៅដ្ឋានរបស់ពួកគេឡើយ |
| ថ្ងៃ ៣១ ខែ ធ្នូ ២០០៧ | ការពន្យាពេលបិទគម្រោងពី ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ |
| ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៨ | ក្នុងកំឡុងពេលបេសកកម្មទៅត្រួតពិនិត្យតំបន់បឹងកក់ ថ្នាក់គ្រប់គ្រងត្រូវបានជំរាបដោយ PMO ថាតំបន់បឹងកក់គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូច្នេះគ្រួសាររស់នៅតំបន់នោះមិនអាចមានសិទ្ធទទួលបានប័ណ្ណកម្មសិទ្ធិទេ។ |
| ថ្ងៃ ២៤ កក្កដា ២០០៨ | សំបុត្រពីនាយកដ្ឋានរៀបចំដែនដីក្រុងភ្នំពេញជូន MPP ដោយរៀបរាប់ពីបរិវេណនៃ "តំបន់អភិវឌ្ឍ" |
| ខែ សីហា ឆ្នាំ ២០០៨ | គ្រួសាររស់នៅក្នុង "តំបន់អភិវឌ្ឍ" ត្រូវបានទទួលសំពាធឱ្យរុះរើទីលំនៅ។ សំណង់ដែលមានស្ថេរភាព |

[៦៧] សេចក្តីថ្លែងការណ៍របស់សាលាក្រុងភ្នំពេញ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៧។

| | |
|---|---|
| | កម្មសិទ្ធិទាបបំផុត ហើយដែលសង់លើឈើនៅលើបឹងបានចាប់ផ្តើមរើចេញពីទីនោះ។ |
| ខែ សីហា ឆ្នាំ ២០០៨ | ការចាប់ផ្តើមលុបដីក្នុងបឹង និងការអភិវឌ្ឍតំបន់នោះដោយក្រុមហ៊ុនឯកជន |
| ថ្ងៃ ០៧ សីហា ២០០៨ | ការកែចំណាត់ថ្នាក់ដីនោះអោយទៅជា "ដីឯកជនរបស់រដ្ឋ" |
| ខែ មករា ដល់ ខែ សីហា ឆ្នាំ ២០០៩ | អង្គការក្រៅរដ្ឋាភិបាលនានានាំយកការព្រួយបារម្ភពីតំបន់បឹងកក់នេះមកជូនថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក |
| ថ្ងៃ ២៤ មករា ២០០៩ | ការបណ្តេញចេញដោយបង្ខំនៅសហគមន៍ដីក្រហម |
| ថ្ងៃទី ១-១០ ខែ មេសា ២០០៩ | LMAP ERM ក្នុងប្រទេសកម្ពុជា |
| ខែ មេសា ដល់ ខែ សីហា ឆ្នាំ ២០០៩ | ថ្នាក់គ្រប់គ្រងធនាគារពិភពលោកពិភាក្សាលទ្ធផលនៃការសិក្សា និងការរកឃើញនានា ជាមួយនឹងរាជរដ្ឋាភិបាល |
| ថ្ងៃទី ៩ ខែ មេសា ២០០៩ | សំបុត្រពីអង្គការក្រៅរដ្ឋាភិបាលនានាជូនដល់ "ក្រុមប្រឹក្សាភិបាលរបស់ក្រុមធនាគារពិភពលោក" មានភ្ជាប់ជាមួយនូវសេចក្តីព្រៀងរបាយការណ៍សំងាត់ដែលមានបញ្ជីសំណួរ ដែលរួមមានសេចក្តីយោងមួយដើម្បីស្នើសុំអោយមានគណៈកម្មការស៊ើបអង្កេត។ |
| ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ | ធនាគារពិភពលោកបានចេញសេចក្តីថ្លែងការណ៍រួមមួយជាមួយនឹងគ្រប់ដៃគូអភិវឌ្ឍន៍ដទៃទៀត ដើម្បីសុំអោយមានបញ្ឈប់នូវការបណ្តេញចេញដោយបង្ខំនូវប្រជាជនក្រីក្រក្នុងតំបន់ប្រជុំជននៅកម្ពុជា |
| ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ | ការបណ្តេញចេញសហគមន៍ក្រុម ៧៨ ដោយបង្ខំ |
| ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩ | សេចក្តីប្រកាសលើកទី ១ ជាផ្លូវការបណ្តេញចេញពីលំនៅដ្ឋាន ជូនអោយក្រុមគ្រួសារនៅក្នុងតំបន់បឹងកក់ក្នុងភូមិ ២ និង ភូមិ ៤។ |
| ថ្ងៃទី ២៧-២៨ ខែ សីហា ឆ្នាំ ២០០៩ | ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ធនាគារពិភពលោកធ្វើទស្សនៈកិច្ចមកប្រទេសកម្ពុជាដើម្បីពិភាក្សាពីគម្រោង LMAP រួមមានទាំងការផ្អាកគម្រោងរួមគ្នាមួយផង |
| ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៩ | ក្រុមអធិការកិច្ចទទួលបានសេចក្តីស្នើសុំអោយមានការស៊ើបអង្កេត។ |
| ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៩ | រដ្ឋាភិបាលបានលប់ចោលមិនទទួលយកការទូទាត់ចំណាយដែលនៅសេសសល់ពីឥណទានរបស់គម្រោង LMAP |
| ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៩ | ធនាគារពិភពលោកឆ្លើយតបនឹងសំបុត្រនៃការលប់ចោលនោះ ដែលថ្នាក់គ្រប់គ្រងបានរំលឹកដល់រដ្ឋាភិបាលពីកាតព្វកិច្ចរបស់រដ្ឋាភិបាលដែលនៅមិនទាន់បានបំពេញក្នុងគម្រោងនោះរបស់រដ្ឋាភិបាល |

## ៥. ការបណ្តេញចេញដោយបង្ខំពីតំបន់បឹងកក់

៩៧. គ្រួសាររស់នៅតំបន់នោះក៏ចាប់ផ្តើមទទួលសំពាធក្នុងការផ្លាស់ប្តូរលំនៅដ្ឋាន និងទទួលយកជម្រើស ១ ក្នុងចំណោមជម្រើស ៣ គឺ :

- ក. ប្រាក់សរុបចំនួន ៨.៥០០ ដុល្លាសហរដ្ឋអាមេរិកសំរាប់ជាសំណងសរុបលើទ្រព្យសម្បត្តិរបស់ពួកគេ។
- ខ. ផ្លាស់ទីលំនៅទៅ តំបន់ដំណាក់ត្រយឹង (ជាង ២០ គីឡូម៉ែត្រនៅក្រៅក្រុង និងទីប្រជុំជន) និងទទួលបានប្រាក់ចំនួន ៥០០ ដុល្លាសហរដ្ឋអាមេរិក ដើម្បីចំណាយលើការផ្លាស់ទីតាំងនេះ។ ឬ
- គ. ធ្វើការសាងសង់ផ្ទះឡើងវិញ ដោយគ្រួសារទាំងនោះត្រូវផ្លាស់ទៅរស់នៅក្នុងតំបន់ត្រពាំងអញ្ចាញ (ចំងាយជាង ២០ គីឡូម៉ែត្រ ពីក្រុងភ្នំពេញដែរ) ក្នុងរយៈពេល ៤ ឆ្នាំសិន ពេលដែលផ្ទះរបស់ពួកគេត្រូវបានសាងសង់ថ្មីនៅលើតំបន់បឹងកក់។

៩៨. ជម្រើសទី ៣ គឺនឹងធ្វើអោយអ្នករស់នៅជាន់ផ្ទាល់ដីអោយទៅក្នុងផ្ទះល្វែង។ ជម្រើសនេះគឺត្រូវបានបដិសេធទាំងស្រុងពីសំណាក់គ្រប់គ្រួសារទាំងអស់ មួយផ្នែកដោយសារតែពួកគេមិនចង់រស់នៅក្នុងផ្ទះល្វែងលើជាន់មិនផ្ទាល់ដីទេ ព្រោះនឹងបាត់បោះឱកាស សំរាប់ឱ្យពួកគេដែលភាគច្រើនធ្វើអាជីវកម្មតាមផ្ទះដើម្បីរក្សាចំនូលសំរាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ គ្រួសារទាំងនោះក៏ មានក្តីបារម្ភជាខ្លាំងដែរពីការផ្លាស់លំនៅបណ្តោះអាសន្នរយៈពេល ៤ ឆ្នាំ ទៅកន្លែងដែលអាចជះឥទ្ធពលជាអវិជ្ជមានដល់ភាពជិត ស្និតក្នុងសហគមន៍ និងការរកចំនូលរបស់គាត់។ ក៏ប៉ុន្តែមូលហេតុដែលល្អមួយទៀតគឺពួកគាត់បាត់បង់ជំនឿទាំងស្រុងទៅលើអ្នកសាងសង់ ដែលថានឹងផ្តល់អោយផ្ទះថ្មីលើតំបន់នេះនៅពេលដែលពួកគាត់ចាកចេញហើយនោះ។ យោងតាមគ្រួសារមួយចំនួន អាជ្ញាធរនានា បានខិតខំយ៉ាងសកម្មក្នុងការរារាំងមិនអោយគ្រួសារទាំងនោះជ្រើសរើសយកជម្រើសទី ៣ នេះទេ។ ក៏មាន របាយការណ៍ផងដែរថាទឹកប្រាក់ពិតប្រាកដ ដែលបានផ្តល់ជូនក៏មានភាពខុសគ្នាពីគ្រួសារមួយទៅគ្រួសារមួយដែរ ពោលគឺគ្រួសារភាគច្រើនបានទទួលទឹកប្រាក់តិចជាង ៨.៥០០ ដុល្លាអាមេរិកដែលបានសន្យានោះ។

៩៩. ជម្រើសដែលអាចឋិតថេរបានសំរាប់គ្រួសារទាំងនោះគឺទទួលយកសាច់ប្រាក់សរុបហើយផ្លាស់ចេញពីកន្លែងនោះដោយចំណាយផ្ទាល់ខ្លួន ឬការទទួលផ្ទះល្វែងមួយនៅតំបន់លំនៅដ្ឋានដែលគេប្តូរឱ្យ។ ជម្រើសទី ១ បានធ្វើឱ្យមានការខឹងសម្បារជាខ្លាំងដោយសារតែទឹកប្រាក់សរុបនោះវាតិចតួចពេក។ ភស្តុតាងជាច្រើនបានបញ្ជាក់ពីតម្លៃដីនៅតំបន់បឹងកក់នេះបានកើនឡើងដល់ ៣០០០ ដុល្លាអាមេរិកក្នុងមួយម៉ែត្រការេ ដែលបង្ហាញថាដីគ្រួសារដែលមានទំហំ ៥០ ម៉ែត្រការេអាចទាមទារបានតាមតម្លៃទីផ្សារចំនួន យ៉ាងហោច ១៥០០០០ ដុល្លាអាមេរិកដែរ ដោយមិនគិតពីតម្លៃសម្ភារៈដទៃទៀតទេ ហើយដីធំជាងនេះ នឹងអាចទទួលបានរឹតតែ ច្រើនជាងនេះ។ ក្នុងបរិបទនេះ ៨០០០ ដុល្លាអាមេរិកមិនអាចគ្រប់ទិញផ្ទះស្រដៀងគ្នានេះនៅក្នុង ឬជិតក្រុងណាមួយបានទេ។ មានតែគ្រួសារទាំងនេះត្រូវបង្ខំចិត្តទៅនៅតំបន់ឆ្ងាយក្នុងជនបទ ដែលភាគច្រើនពួកគេមិនស្គាល់អ្នកណាម្នាក់ ហើយនឹងត្រូវចាប់ផ្តើមកសាងជីវិតនិងការរស់នៅរបស់ពួកគាត់សារជាថ្មី។

១០០. នៅក្នុងស្ថានភាពបែបនេះ វាមិនគួរភ្ញាក់ផ្អើលទេ ដែលគ្រួសារភាគច្រើនបានយល់ថាពួកគេគ្មានជម្រើសអ្វីក្រៅពីទទួលយកជម្រើសទី ៣ ដើម្បីផ្លាស់លំនៅដ្ឋានជាបណ្តោះអាសន្នទៅនៅតំបន់ដំណាក់ត្រយឹងនោះ។ មនុស្សភាគច្រើននិយាយថាគេមាន អារម្មណ៍មិនអាចតវ៉ាជំទាស់ខ្លាំងក្លា ឬចូលរួមធ្វើបាតុកម្មបានទេ ព្រោះថាពួកគេឬគ្រួសាររបស់ពួកគេធ្វើការនៅក្នុងសាលាក្រុងដែរ ហើយភ័យខ្លាចបាត់បង់ទាំងការងារ និងផ្ទះសំបែងរបស់ពួកគេ។ គ្រួសារទាំងនោះរាយការណ៍មកថា ក្រុមនគរបាល និងបុគ្គលិក ក្រុមហ៊ុនបានមកធ្វើការរំខានដល់ពួកគេជាបន្តបន្ទាប់ដើម្បីឱ្យកំលាំងតវ៉ារបស់ពួកគេចុះខ្សោយ ហើយគ្រួសារខ្លះទៀតត្រូវបាន បង្ខំឱ្យរុះរើផ្ទះរបស់ពួកគេដោយខ្លួនឯងព្រមទាំងយំមិនឈប់។

១០១. ក្នុងឆ្នាំនោះ ស្ថានភាពកាន់តែមិនមានភាពច្បាស់លាស់ថែមទៀត ហើយការប្រកាសបណ្តេញចេញចុងក្រោយបានចេញដោយសាលាក្រុងភ្នំពេញនៅខែ មេសា ឆ្នាំ ២០០៩។ សហគមន៍ក៏បានរៀបចំឯកសារប្តឹងទៅគណៈកម្មការសុរិយោដីក៏ដូចជាដាក់ ទៅតុលាការក្នុងពេលតែមួយនោះដែរដើម្បីផ្អាកការបណ្តេញចេញនេះរហូតដល់មានការសំរេចចិត្តលើភាពស្របច្បាប់របស់រឿងនេះ។ តុលាការបានបដិសេធមិនចេញលិខិតបញ្ជា ដោយបញ្ជាក់ថាបញ្ហានេះវាហួសពីសមត្ថកិច្ចរបស់តុលាការ ហើយគួរតែត្រូវឱ្យដោះស្រាយដោយគណៈកម្មការសុរិយោដី។

១០២. នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩ ជាង ១៥០ គ្រួសារក្នុងភូមិ២ និង ភូមិ៤ ក្នុងតំបន់បឹងកក់បានទទួលប្រកាសជាផ្លូវការលើកទី ១ ដើម្បីអោយពួកគេចេញពីលំនៅដ្ឋាន ដែលក្រោយមកការបណ្តេញចេញនោះក៏បានធ្វើឡើង។ មកដល់បច្ចុប្បន្ននេះ ចំនួនគ្រួសារសរុបដែលត្រូវបណ្តេញចេញពីផ្ទះសំបែងក្នុងតំបន់បឹងកក់នោះមិនមានចំនួនច្បាស់លាស់ទេ ទោះជាមានប្រភពខ្លះប៉ាន់ស្មាន ថាមានពី ៩៥០ ទៅ ១២០០ គ្រួសារ ហើយខ្លះទៀតថារហូតដល់ ២០០០ គ្រួសារ ហើយមាន ២០០០ គ្រួសារផ្សេងទៀតកំពុងឋិតនៅក្រោមការគំរាមកំហែង។ គ្រួសារជាច្រើនបានត្រូវបង្ខំឱ្យចាកចេញពីផ្ទះនៅតាមជាយបឹង នៅពេលដែលទឹកចាប់ផ្តើម ឡើងកំពស់ក្រោយពីមានការចាក់ដីបំពេញបឹងនោះដោយក្រុមហ៊ុនសាងសង់ (សូមអានប្រអប់លេខ ៣ ខាងក្រោមស្តីពីការបារម្ភពី ទឹកជំនន់)។

១០៣. បទសំភាសន៍ជាមួយនឹងអ្នកនៅកន្លែងសំរាប់ផ្លាស់លំនៅដ្ឋានរួច ជាមួយនឹងភស្តុតាងជារូបភាពពីលេខទូរស័ព្ទ នៅលើអាគារជាច្រើនបានអោយយើងដឹងថា គ្រួសារភាគច្រើនដែលរើលំនៅដ្ឋានរបស់ពួកគេ គឺពីព្រោះតែផ្ទះរបស់ពួកគេនៅឆ្ងាយពីម៉ុកន្លែងសង់ថ្មី និងដោយសារតែសំណង់នៅទីនោះគ្មានគុណភាព ដែលជាលទ្ធផលនឹងកាត់បន្ថយប្រាក់ចំនូលគាត់តែតិចតួចស្រាប់ហើយនោះ។ ជាលទ្ធផល ពួកគេបានលក់ផ្ទះនោះយកប្រាក់តាមតម្លៃដែលអាចទទួលបាន ហើយត្រឡប់ចូលមកទីក្រុងវិញ ដើម្បីជួលផ្ទះគេ ឬរកដីទំនេរណាដើម្បីរស់នៅ។ អ្នកដទៃទៀតបានរកឃើញកន្លែងស្នាក់នៅក្នុងផ្នែកដទៃទៀតនៃទីក្រុង តាមរយៈការជួយគាំទ្រផ្នែក សង្គមកិច្ចពីបងប្អូន និងអ្នកជិតខាង។



**រូបភាពទី ២ ៖ ផ្ទះលិចទឹកក្នុងតំបន់បឹងកក់**

## ប្រអប់ទី ៣ . កម្រលនៃការជន់លិច ពីការចាក់បំពេញ ទំនប់បឹងកក់

( ទំនប់បឹងកក់ជាបឹងមួយដ៏សំខាន់ ក្នុងចំនោមបឹងទាំង៧ជុំវិញទីក្រុងភ្នំពេញ។ យោងតាម លោក ម៉ូលីវ៉ាន បឹងនេះប្រើជាអាងទឹក ធម្មជាតិសំរាប់ទឹកភ្លៀងហួសកំណត់ ក្នុងអំឡុងពេលរដូវមូសុង តាំងតែពីទីក្រុង ត្រូវបានរកឃើញ ក្នុងឆ្នាំ ១៤៣១ ដោយមហាក្សត្រចៅ ពញាយ៉ាត ក្រោយពេលដែលស្តេចជាច្រើនអង្គ បានបោះបង់ចោល ក្រុងអង្គរ។ ទំនប់នេះមានមុខងារ ជាអាងស្តុក ទឹកជំនន់ និង ទឹកច្រើនហួសកំណត់ ត្រូវបានបង្ហូរតាមព្រែកជីក ហៅថា ព្រែក ត្រឡប់ទៅទន្លេ។ លោក **ម៉ានយ៉ីន** បាននិយាយថា តាំងពីពាក់កណ្តាលរហូតដល់ចុងទសវត្សឆ្នាំ ១៩២០ ទំនប់បឹងកក់បានក្លាយជា ប្រព័ន្ធដ៏ជិតមួយសំរាប់បែងចែកអាងស្តុកទឹក ទន្លេ។ ព្រែកជីកពីមុនដែលត្រូវបានភ្ជាប់ពីទន្លេសាប សំរាប់ការបង្ហូរទឹកជំនន់ដែលបានបំពេញ និង ត្រូវបានជំនួសដោយ ផ្លូវទឹក ជាច្រើន។

យោងតាមប្រភពអជ្ញាធរមួយអោយដឹងថា រហូតមកទល់ឆ្នាំថ្មីៗនេះ បឹងនេះនៅតែភ្ជាប់ទៅប្រព័ន្ធបឹង នៃតំបន់ជាយក្រុងនានា តាមភាគខាងជើង។ សំណើរដែលផ្តួចផ្តើមគម្រោងសំរាប់ផែនការមេទីក្រុងភ្នំពេញដែលត្រូវបានរៀបចំក្នុងឆ្នាំ ២០០៥ បានបង្ខាំង ការភ្ជាប់តាមព្រែកតូចមួយ ទៅកាន់ព្រែកដទៃទៀត ដែលប្រើជា អាងស្តុកទឹកជំនន់ជា ទៀងទាត់ សំរាប់តំបន់ជាយក្រុងប៉ែក ខាងជើង។ គំនិតនេះ មិនត្រូវបានគេយកទៅបញ្ចូលក្នុងគម្រោងទេ ហើយព្រែកជីកដែលមានហើយ ទំនងជាត្រូវបានបង្ខាំងក្នុង ពេលថ្មីៗនេះ។ គេនិយាយថា ពេលដែលបឹងនេះមាននាទីជា *"ប្រព័ន្ធបង្ហូរទឹករបស់ក្រុងភ្នំពេញដែលមានភាពស្មុគស្មាញមួយ... ទំហំនៃការទទួលទឹកបានគឺតិចតួចជាងតំបន់នោះផ្ទាល់"* ដែលមានន័យថាវាមិនអាចបង្ហូរទឹកដែលច្រើនហួសហេតុនៅក្នុងរដូវមូសុង ដែលមានជារៀងរាល់ឆ្នាំនោះបានទេ។ យ៉ាងណាក៏ដោយ បឹងនេះផ្តល់អោយនូវបរិស្ថានធម្មជាតិ ដ៏មានតំលៃ និង ស្រូបទាញទឹក ដែលលើសពេលភ្លៀងធំក្នុងតំបន់បានយ៉ាងឆាប់ ព្រមទាំងផ្តល់អោយនូវភាពស្រស់ស្អាត និង ប្រភពនៃការចិញ្ចឹមជីវិតសំរាប់មនុស្ស ជាច្រើន។

គម្រោងដែលបានរៀបចំឡើងដោយក្រុមហ៊ុន Shukaku រួមមានការចាប់ផ្តើមចាក់បំពេញដីខ្សាច់ពីទន្លេចូលទៅក្នុងផ្នែកជាច្រើននៃបឹងនេះ ដែលបានចាប់ផ្តើមនៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ទោះជាមានការប្តឹងតវ៉ាពីគ្រួសាររស់នៅទីនោះយ៉ាងណាក៏ដោយ។ ក្រោយពីនោះមក សារព័ត៌មានក្នុងស្រុកក៏បានចាប់ផ្តើមផ្សព្វផ្សាយព័ត៌មានពីករណីនៃការលិចលង់ផ្ទះសំបែង និងការឈឺថ្កាត់របស់ក្មេងៗ ដោយមូលហេតុពីការបំពុលនានា ។ ការចាក់ដីបំពេញបឹងនេះបានធ្វើអោយផ្ទះដែលនៅសល់ពីការបណ្តេញចេញរំលំនៅក្នុងទឹក និងផ្ទះដទៃទៀតមិនអាចរស់នៅបានទេ។ មានរបាយការណ៍ដែរថាមានមនុស្សត្រូវឆក់ខ្សែភ្លើងផង។

ថ្មីៗនេះ ជាមួយនឹងការប៉ះទង្គិចនៃរដូវមូសុង មានរបាយការណ៍ពីបញ្ហាទឹកជំនន់កាន់តែកើនឡើង បង្ហាញថា ប្រព័ន្ធបង្ហូរទឹក ត្រូវបានរងការប៉ះពាល់។ ក្នុងថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ កាសែត ខែមបូឌ៊ែរ ដេលី បានរាយការណ៍ថា ភ្លៀងបានហូរទៅ ក្នុងអាងទឹកសំអុយ ដែលជាទឹកដែលមានពេញដោយសំរាមពោរពាស។ លំនៅដ្ឋានដែលកំពុងរស់នៅពីក្រោយជញ្ជាំងប៉េតុងជុំវិញ វិហារឥស្លាម ក្នុងតំបន់ គឺគ្មានជំរើស ប៉ុន្តែ ត្រូវលុយទឹកត្រឹមជង្គង់ ក្នុងតំបន់មួយចំនួន។

ការបោះពុម្ពចេញដោយអង្គការក្រៅរដ្ឋាភិបាលនានាក្នុងថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ ២០១០ បាននិយាយថា *"រង្វាស់ទឹកក្នុង តំបន់ បឹកកក់ដែលសេសសល់ក្រោយការបន្តចាក់បំពេញដោយខ្សាច់ បានកើនឡើងតាំងពីមានការប៉ះទង្គិចនៃរដូវវស្សាក្នុងប្រទេសកម្ពុជា ធ្វើអោយមានការរិះគន់ ក្នុងខែសីហាថ្មីៗនេះ។ តាំងពីថ្ងៃទី ២២ដល់២៥ ខែ សីហា ផ្នែកធំៗនៃភូមិជាច្រើនបានជន់លិច ហើយជះឥទ្ធិពលដល់ជាង ១០០០ គ្រួសារ។ អ្នកស្រុកត្រូវលុយទឹកដល់ត្រឹមជង្គង់ និងចង្កេះ ជាមួយនឹងទឹកកង្វក់ទៅផ្ទះ ខណៈដែលមានគ្រួសារខ្លះត្រូវរកជំរកថ្មីទាំងបង្ខំដោយសារតែផ្ទះរបស់ពួកគាត់មិនអាចនៅបានដោយទឹកជន់លិច។ សហគមន៍ទាំង នោះបានទាមទារអោយអាជ្ញាធរផ្អាកការចាក់បំពេញបឹង ហើយពង្រីងទ្វារទំនប់បង្ហូរទឹក។ កាលពីសប្តាហ៍មុន មានភ្លៀងតិចដែល ការជន់លិចក៏ថយ ហើយក៏រិតទឹកក៏ទាប ប៉ុន្តែដើម្បីធ្វើអោយប្រសើរ*

*ឡើងសំរាប់ការបង្ហូរទឹក អាជ្ញាធរអនុញ្ញាតអោយចាក់បំពេញ ត្រឹមកន្លះថ្ងៃរួចបន្តទៅថ្ងៃបន្ទាប់ទៀត ។ អ្នកស្រុកបានរាយការណ៏ទៀតថា របងទ្វាទំនប់បានបិទក្នុងពេលចាក់បំពេញដើម្បីការពារ ខ្សាច់ហូរទៅក្រៅបឹង និងសំរាមស្ទះនៅទ្វាបង្ហូរបណ្តាលអោយកកស្ទះការហូរ ។ បើមានភ្លៀងធំ នោះ ទឹកជំនន់នៅតែកើតមាន ។*

*ព័ត៌មាន និង ការស្រង់ពាក្យក្នុងប្រអប់ទី៣ គឺយោងតាមប្រភពមួយចំនួនដូចខាងក្រោម លោក ម៉ុលីវ៉ាន់ ២០០៣នៃ ទីក្រុងខ្មែរទំនើប បោះពុម្ភនៅ ភ្នំពេញ កម្ពុជា បោះពុម្ភដោយ វ៉ាន់ មូលីវ៉ាន់ និងរ៉ៃយំ ទំព័រ ១៤៧-១៥១ ។ លោក ម៉ាន់ យីន ២០០៦ នៃ ការផ្លាស់ប្តូរ បរិស្ថាន និង ការទាមទារដី នៅជុំវិញតំបន់បឹងកក់ក្នុងទីក្រុងភ្នំពេញ សារណាណ៏ថ្នាក់អនុបណ្ឌិត នៅវិទ្យាស្ថានអាស៊ីនៃបច្ចេកវិទ្យានៃ សាលា បរិស្ថាន ធនធាន និង ការអភិវឌ្ឍន៏ ប្រទេសថៃ ។ ប៉ែនបាម និង ខាដឌីស ២០០៨ នៃ ការប្រមាណលើការបង្ហូរទឹក និងការជន់ លិច. បោះពុម្ភចេញពី កំលាំងកិច្ចការសិទ្ធិមនុស្ស និង ស្ថានឆ្លងព្រំដែនកម្ពុជា ។*

# ជំពូកទី៣ : របកគំហើញ និងការវិភាគរបស់ក្រុមអធិការកិច្ច

## ក). និដ្ឋភាពទូទៅ

១០៤. ជំពូកនេះបង្ហាញអំពីបណ្តឹងតវ៉ានានារបស់អ្នកស្នើសុំទាំងឡាយ រួមជាមួយនឹងការឆ្លើយតបនានារបស់ថ្នាក់គ្រប់គ្រងធនាគារ ព្រមទាំងរបកគំហើញ និងការវិភាគរបស់អធិការកិច្ចអំពីបញ្ហាដែលបង្កឱ្យមានការខូចខាតទាំងស្រុង ឬផ្នែកខ្លះមកពីធនាគារមិនអនុវត្តតាមគោលនយោបាយ និងនីតិវិធីនានារបស់ខ្លួន។ ជំពូកនេះត្រូវបានរៀបចំដោយផ្អែកតាមបណ្តឹងតវ៉ារបស់អ្នកស្នើសុំសំខាន់ៗចំនួន៥ ដែលត្រូវបានសង្ខេបដូចខាងក្រោម។ សម្រាប់បណ្តឹងតវ៉ានីមួយៗនៃការតវ៉ាទាំង៥នេះ ជាដំបូង ក្រុមអធិការកិច្ចធ្វើការសង្ខេបអំពីការតវ៉ា និងឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ហើយបន្ទាប់មក បង្ហាញអំពីរបកគំហើញ និងការវិភាគរបស់ខ្លួន។

១០៥. ការតវ៉ាទី១ គឺថា ព្រឹត្តិការណ៍នានានៅតំបន់បឹងកក់ ត្រូវបានជាប់ពាក់ព័ន្ធទៅនឹងគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ ការកំណត់នៃការជាប់ពាក់ព័ន្ធគ្នានេះ គឺជាមូលដ្ឋានសម្រាប់ការស៊ើបអង្កេត និងការវិភាគរបស់អធិការកិច្ចទៅលើការតវ៉ារបស់អ្នកស្នើសុំផ្សេងៗទៀត។ អធិការកិច្ចកត់សម្គាល់ឃើញថា ថ្នាក់គ្រប់គ្រងរបស់ធនាគារបានទទួលស្គាល់រួចមកហើយថា ការជាប់ទាក់ទងគ្នានេះត្រូវបានបង្ហាញនៅក្នុងកិច្ចព្រមព្រៀងជាមួយនឹងការតវ៉ារបស់អ្នកស្នើសុំ។

១០៦. ការតវ៉ាទី២ គឺថា ប្រជាពលរដ្ឋតំបន់បឹងកក់ត្រូវបានបដិសេធក្នុងការវិនិច្ឆ័យទាមទារកម្មសិទ្ធិរបស់ខ្លួន ក្រោមក្របខ័ណ្ឌនៃគម្រោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លី។ អ្នកស្នើសុំបានលើកឡើងថា នីតិវិធីនានានៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី មិនត្រូវបានអនុវត្តតាមទេ ហេតុនេះ សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទាមទារឱ្យធ្វើការស៊ើបអង្កេត និងវិនិច្ឆ័យដីធ្លីរបស់ពួកគេ ឱ្យបានត្រឹមត្រូវ ត្រូវបានបដិសេធ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋលើកឡើងថា ដីធ្លីរបស់ខ្លួនត្រូវបានរៀបចំឡើងវិញ សម្រាប់លទ្ធភាពអភិវឌ្ឍន៍ដោយអ្នកអភិវឌ្ឍន៍ឯកជន ដែលដកហូតឱកាសរបស់ខ្លួនក្នុងការតវ៉ាទាមទារនូវសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរបស់ខ្លួន ហើយដែលឈានដល់ការបណ្តេញពួកគេចេញដោយបង្ខំដោយគ្មានដំណើរការសមរម្យ។

១០៧. ការតវ៉ាទី៣ គឺថា ប្រជាពលរដ្ឋបឹងកក់ត្រូវបានបង្ខំឱ្យផ្លាស់ប្តូរទីកន្លែងដោយរំលោភទៅលើគោលនយោបាយនានា ដែលបានព្រមព្រៀងសម្រាប់ការតាំងទីលំនៅជាថ្មីដោយស្ម័គ្រចិត្ត។ អ្នកស្នើសុំលើកឡើងថា នៅក្នុងការរំលោភទៅនឹងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍នេះ ក្របខ័ណ្ឌគោលនយោបាយនៃការតាំងទីលំនៅជាថ្មីមិនត្រូវបានគោរពតាមទេ នៅក្នុងតំបន់បឹងកក់ ហេតុនេះបណ្តាលឱ្យអន្តរាយយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋដែលបានបណ្តេញចេញពីដីធ្លីរបស់ខ្លួន។ អ្នកស្នើសុំលើកឡើងថា កាលៈទេសៈនៃការបណ្តេញចេញដែលបានធ្វើឡើង និងស្ថានភាពនានានៃទីកន្លែងតាំងទីលំនៅជាថ្មី មិនសមស្របទៅតាមស្តង់ដារដែលកំណត់នៅក្នុងគោលនយោបាយរបស់ធនាគារស្តីពីការតាំងទីលំនៅជាថ្មីនោះទេ ព្រមទាំងលើកឡើងថា ពួកគេទទួលរងនូវការឈឺចាប់ និងបន្សល់ទុកនូវហានិភ័យធំធេង-ភាពអន្តរាយយ៉ាងក្រៃលែង។

១០៨. ការតវ៉ាទី៤ គឺថា កិច្ចដំណើរការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីដែលអនុម័តដោយគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ធ្វើឱ្យចុះខ្សោយដល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការកាន់កាប់ដីធ្លីរបស់ខ្លួនដែលមានកន្លងមក។ អ្នកស្នើសុំលើកឡើង

ថា គម្រោងមិនត្រឹមតែបរាជ័យក្នុងការធ្វើឱ្យសិទ្ធិកាន់ដីធ្លីរបស់ប្រជាពលរដ្ឋជាផ្លូវការ តាមរយៈការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យខូចដល់ឋានៈរបស់ប្រជាពលរដ្ឋក្នុងការកាន់កាប់ដីធ្លីរបស់ខ្លួននាបច្ចុប្បន្ន។

១០៩. ចុងក្រោយ : អ្នកស្នើសុំលើកឡើងថា មិនត្រឹមតែនៅក្នុងតំបន់បឹងកក់ប៉ុណ្ណោះទេ ប៉ុន្តែក៏មានសហគមន៍ដទៃផ្សេងទៀតនៅក្នុងខេត្តគោលដៅគម្រោងត្រូវបានបណ្តេញចេញដោយបង្ខំ។ អ្នកស្នើសុំលើកឡើងថា ទីប្រជុំជន ទីជនបទ និងសហគមន៍ជនជាតិដើមភាគតិចផ្សេងៗទៀតនៅទូទាំងប្រទេសកម្ពុជា មិនមានលទ្ធភាពទទួលបាននូវការផ្តល់ប័ណ្ណសម្គាល់ សិទ្ធិកាន់កាប់ដីធ្លី និងឬយន្តការដោះស្រាយទំនាស់ដែលស្ថិតក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី និងមិនទទួលបានសុវត្ថិភាពចំពោះសិទ្ធិកាន់កាប់ដីធ្លីរបស់ខ្លួន ក្រោមប្រព័ន្ធផ្លូវការដែលរៀបចំដោយគម្រោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លីនោះទេ។

## ខ). ការលើកឡើងថា ព្រឹត្តិការណ៍នានានៅតំបន់បឹងកក់ត្រូវបានជាប់ពាក់ព័ន្ធនឹងគម្រោង

### ១. ការលើកឡើងរបស់អ្នកស្នើសុំ និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង

១១០. អ្នកស្នើសុំលើកឡើងថា *"សហគមន៍បឹងកក់បាននិងកំពុងទទួលរងនូវផលប៉ះពាល់អវិជ្ជមានពីគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី"* ឬនិយាយម្យ៉ាងទៀតថា មានការជាប់ពាក់ព័ន្ធដោយផ្ទាល់ និងផ្លូវការរវាងព្រឹត្តិការណ៍នានាដែលនាំឱ្យមានការបណ្តេញចេញប្រជាពលរដ្ឋដែលរស់នៅតំបន់បឹងកក់ ជាមួយនឹងសកម្មភាពនានាដែលអនុវត្តក្រោមក្របខ័ណ្ឌគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ ការពិនិត្យផ្ទៀងផ្ទាត់នៃការជាប់ពាក់ព័ន្ធនេះ គឺជាការចាំបាច់សម្រាប់ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចឱ្យកាន់តែស៊ីជម្រៅថែមទៀត ទៅលើភាពអន្តរាយជាក់លាក់នានាដែលលើកឡើង ហើយត្រូវបានវិភាគនៅក្នុងជំពូកនេះ ដូចខាងក្រោម។

១១១. ថ្នាក់គ្រប់គ្រងនៅក្នុងការឆ្លើយតបរបស់ខ្លួនលើកឡើងថា *"តំបន់វិនិច្ឆ័យស្រះចកគឺជាតំបន់ដែលគម្រោងត្រូវរៀបចំផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីជាប្រព័ន្ធ"* [៦៨] ដូច្នេះហើយ នីតិវិធីនានាសម្រាប់ការវិនិច្ឆ័យជាប្រព័ន្ធ និងសេចក្តីណែនាំនានាស្តីពីបរិស្ថាន និងសង្គម ដែលបានព្រមព្រៀងសម្រាប់គម្រោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ត្រូវតែអនុវត្តតាម។

### ២. ការវិភាគរបស់ក្រុមអធិការកិច្ច

១១២. ក្រុមអធិការកិច្ចកត់សម្គាល់ឃើញថា មានការមិនឯកភាពគ្នាមួយរវាងថ្នាក់គ្រប់គ្រងរបស់ធនាគារ និងរដ្ឋាភិបាលអំពីភាពជាប់ពាក់ព័ន្ធគ្នារវាងព្រឹត្តិការណ៍នានានៅក្នុងតំបន់បឹងកក់ ជាមួយនឹងគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ ទស្សនៈរបស់រដ្ឋាភិបាលគឺថា ការបណ្តេញចេញដែលកើតមានឡើងនៅក្នុងតំបន់បឹងកក់មិនពាក់ព័ន្ធនឹងគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីទេ។ ដូចបានកត់សម្គាល់ខាងលើ ថ្នាក់គ្រប់គ្រងរបស់ធនាគារកត់សម្គាល់ថា តំបន់បឹងកក់គឺស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ ដែលបានប្រកាសនៅក្នុងគម្រោង ដូចនេះ ព្រឹត្តិការណ៍នានាដែលពាក់ព័ន្ធនឹងការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីដល់ប្រជាពលរដ្ឋ ត្រូវជាប់ពាក់ព័ន្ធទៅនឹងគម្រោង។ ដៃគូអភិវឌ្ឍន៍នានានៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីឯកភាពជាមួយរដ្ឋាភិបាល ហើយមិនទទួលស្គាល់នូវភាពជាប់ពាក់ព័ន្ធគ្នារវាងគម្រោងជាមួយនឹងព្រឹត្តិការណ៍នានា នៅតំបន់បឹងកក់នោះទេ។

១១៣. ចំពោះហេតុផលនេះ ក្រុមអធិការកិច្ចបានធ្វើការសិក្សាវាយតម្លៃឯករាជ្យដោយខ្លួនឯងផ្ទាល់ទៅលើស្ថានភាពនេះ។

---

[៦៨] ការឆ្លើយតបរបស់គណៈគ្រប់គ្រង ទំព័រទី២២។

ការសិក្សាវាយតម្លៃនេះត្រូវបានអនុវត្តនៅបីកម្រិត។ កម្រិតទី១ គឺសំណួរពាក់ព័ន្ធនឹងគោលការណ៍ច្បាប់ថាតើតំបន់បឹងកក់ស្ថិតនៅក្នុងការកំណត់ជាខេត្តគោលដៅគម្រោង នៅក្នុងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ និងឯកសារវិនិច្ឆ័យគម្រោង ដែលត្រូវបានពិភាក្សានៅក្នុងផ្នែកនេះ។ ផ្នែក"គ" និង"ឃ"នៃជំពូកនេះ រួមមាន ការសិក្សាវាយតម្លៃរបស់ក្រុមអធិការកិច្ច ថាតើនីតិវិធីនានារបស់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីបានផ្តល់ ឬអនុញ្ញាតិសម្រាប់ការកាត់ចេញពីការវិនិច្ឆ័យជាប្រព័ន្ធនូវតំបន់ណាមួយ ដូចជាតំបន់បឹងកក់ជាដើម (ផ្នែក"គ") និងថាតើសុវត្ថិភាពបរិស្ថាន និងសង្គម-ក្របខ័ណ្ឌគោលនយោបាយនៃការតាំងទីលំនៅថ្មីក្នុងករណីជាក់លាក់ - ត្រូវបានអនុវត្តតាមដែរឬទេ (ផ្នែក"ឃ")។

១១៤. **ការកំណត់តំបន់គោលដៅគម្រោង :** ក្រុមអធិការកិច្ចកត់សម្គាល់ឃើញថា យោងតាមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ និងឯកសារវិនិច្ឆ័យគម្រោង គម្រោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លីត្រូវបានរៀបចំឡើងសម្រាប់អនុវត្តនៅក្នុងខេត្ត ក្រុងចំនួន១១ ដែលបានកំណត់ជា "ខេត្តគោលដៅគម្រោង" រួមទាំងរាជធានីភ្នំពេញ ដែលអាចធ្វើការវិសោធនកម្មបានតាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងធនាគារ[៦៩]។ តំបន់បឹងកក់ គឺស្ថិតនៅក្នុងរាជធានីភ្នំពេញ។ លើសពីនេះទៀត ក្រុមអធិការកិច្ចកត់សម្គាល់ថា មិនមានសេចក្តីបញ្ជាក់ ឬលក្ខណៈវិនិច្ឆ័យណាមួយ ដែលបានរៀបចំនៅក្នុងឯកសារវិនិច្ឆ័យគម្រោង ឬនៅក្នុងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ក្នុងការដកចេញតំបន់ណាមួយពី"ខេត្តគោលដៅគម្រោងដែលបានកំណត់ឡើយ។ ដូចនេះ ជាគោលការណ៍ គម្រោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លីអាចអនុវត្តនៅក្នុងផ្នែកណាមួយនៃរាជធានីភ្នំពេញ ដែលជាតំបន់គោលដៅសម្រាប់កម្មវិធីផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីនៅថ្នាក់ជាតិ ដំណាក់កាលទី១។ ឯកសារវិនិច្ឆ័យគម្រោងបានកំណត់ចំណុចគោលដៅចំនួន១៩៨.000ក្បាលដី ដែលត្រូវធ្វើអង្កេត និងវិនិច្ឆ័យនៅរាជធានីភ្នំពេញចាប់ពីឆ្នាំ២00២ដល់ឆ្នាំ២00៧[៧០]។

១១៥. **ការប្រកាសបឹងកក់ជាតំបន់វិនិច្ឆ័យ :** សង្កាត់ស្រះចកទាំងមូល រួមទាំងតំបន់បឹងកក់ ដែលមានគ្រួសារចំនួនប្រមាណ៤.២៥0គ្រួសារ រួមទាំងអ្នកស្នើសុំនានា ត្រូវបានប្រកាសនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២00៦ ថាជាតំបន់វិនិច្ឆ័យក្រោមក្រាបខ័ណ្ឌនៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ យោងតាមការប្រកាសផ្សព្វផ្សាយនៃតំបន់វិនិច្ឆ័យ *"ក្រុមប្រតិបត្តិគម្រោងត្រូវអនុវត្តនីតិវិធីវិនិច្ឆ័យជាប្រព័ន្ធ ដែលរួមមានការកំណត់ព្រំប្រទល់ ការវាស់វែង និងការវិនិច្ឆ័យក្បាលដី..... និង ត្រូវចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី"*[៧១]។ ក្រុមអធិការកិច្ចកត់សម្គាល់ឃើញថា ការប្រកាសផ្សព្វផ្សាយតំបន់វិនិច្ឆ័យ ពុំបានលើកលែងតំបន់ណាមួយក្នុងសង្កាត់ស្រះចកចេញពីដំណើរការវិនិច្ឆ័យ ដែលត្រូវគាំទ្រដោយគម្រោងឡើយ។

១១៦. **ផ្អែកតាមខាងលើនេះ ក្រុមអធិការកិច្ចរកឃើញថា តំបន់បឹងកក់គឺស្ថិតនៅក្នុងខេត្តគោលដៅគម្រោង និងត្រូវបានប្រកាសសម្រាប់វិនិច្ឆ័យក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ហេតុនេះ សកម្មភាពនានាដែលទាក់ទងនឹងការពិនិត្យផ្ទៀងផាត់នៃការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី និងភាពជាម្ចាស់ដីធ្លី សកម្មភាពនានា**

---

[៦៩] យោងតាមតារាងទី៦នៃកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ និងឯកសារភ្ជាប់ទី២ ដល់ឧបសម្ព័ន្ធទី២នៃឯកសារវាយតម្លៃគម្រោង ខេត្តគោលដៅគម្រោងដែលបានផ្តួចផ្តើមដំបូង គឺខេត្តតាកែវ ភ្នំពេញ ព្រៃវែង កណ្តាល កំពង់ស្ពឺ ព្រះសីហនុ កំពង់ធំ កំពង់ចាម កំពត សៀមរាប និងបាត់ដំបង។ ក្រោយមកតំបន់គោលដៅគម្រោងត្រូវបានពង្រីកដល់១៤ខេត្ត។

[៧០] ឯកសារវិនិច្ឆ័យគម្រោង ទំព័រទី៤៣

[៧១] ព្រះរាជាណាចក្រកម្ពុជា រាជធានីភ្នំពេញ លេខ៨៣ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២00៦។

**ក្រោយពីការប្រកាសផ្សព្វផ្សាយតំបន់វិនិច្ឆ័យត្រូវជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងគម្រោង។**
ទាំងនេះស្របជាមួយនឹងជំហររបស់ថ្នាក់គ្រប់គ្រង។ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាដែលគាំទ្រគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី អះអាងថា តំបន់បឹងកក់ គឺជាតំបន់ទំនាស់ ដូចនេះត្រូវដកចេញពីដំណើរការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ បញ្ហានេះត្រូវពិភាក្សាជាបន្តនៅក្នុងផ្នែកខាងក្រោម។



រូបភាពទី៣ : ក្រុមក្រុមអធិការកិច្ចជួបជាមួយសហគមន៍ដែកទទួលរងនូវផលប៉ះពាល់នៅតំបន់បឹងកក់

## គ). ការលើកឡើងថា ប្រជាពលរដ្ឋបឹងកក់បានបដិសេធនូវការវិនិច្ឆ័យដីធ្លីរបស់ខ្លួន ក្រោមក្របខ័ណ្ឌគម្រោង

### ១. ការលើកឡើងរបស់អ្នកស្នើសុំ និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង

១១៧. សំណើសុំធ្វើអធិការកិច្ចផ្អែកលើការយល់ឃើញថា តំបន់បឹងកក់គឺជាផ្នែកមួយនៃតំបន់ដែលប្រកាសជាតំបន់វិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ហើយនីតិវិធីនានាដែលបង្កើតឡើងក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីត្រូវបានអនុវត្តតាម។ អ្នកស្នើសុំលើកឡើងថា នីតិវិធីគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីមិនត្រូវបានអនុវត្តតាមទេ ហេតុនេះប្រជាពលរដ្ឋត្រូវបានបដិសេធសិទ្ធិរបស់ពួកគេក្នុងការទាមទារឱ្យធ្វើការអង្កេត និងវិនិច្ឆ័យទ្រព្យសម្បត្តិរបស់ខ្លួនឱ្យបានត្រឹមត្រូវ។

១១៨. យោងតាមសំណើ *"ប្រជាពលរដ្ឋលើកឡើងថា នៅពេលពួកគេបានស្នើសុំឱ្យធ្វើការអង្កេតទៅលើដីធ្លីរបស់ខ្លួន សំណើរបស់ពួកគេត្រូវបានបដិសេធដោយសំអាងលើហេតុផលថា ពួកគេរស់នៅក្នុងតំបន់អភិវឌ្ឍន៍។ កិច្ចដំណើរការនេះងាកចេញពីនីតិវិធីច្បាប់ ដែលបានរៀបចំដោយគម្រោង និងបានអនុម័យដោយរាជរដ្ឋាភិបាលកម្ពុជា[៧២]"*។

១១៩. យោងតាមសំណើ ប្រជាពលរដ្ឋតំបន់បឹងកក់ជាច្រើន *"ចាត់ទុកថា ខ្លួនជាម្ចាស់ដី"* និងមានឯកសារនានាជាច្រើន ដែល

[៧២] សំណើសុំធ្វើអធិការកិច្ច ទំព័រទី១។

បញ្ជាក់ថា ខ្លួនបានរស់នៅក្នុងតំបន់នេះជាយូរលង់មកហើយ និងឬគ្រួសារមួយចំនួនបង្កើតភាពជាម្ចាស់តាមទម្លាប់។ យ៉ាងហោចណាស់ក្នុងចំណោមភាគច្រើននៃប្រជាពលរដ្ឋរស់នៅបឹងកក់ មានការរំពឹងទុកមួយថា ដំណើរការវិនិច្ឆ័យដីធ្លីជាប្រព័ន្ធក្រោមក្របខ័ណ្ឌគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី នឹងអាចផ្តល់ជាផ្លូវការនូវសិទ្ធិកាន់កាប់ភោគៈ ឬសិទ្ធិកាន់កាប់ដីធ្លីតាមទម្លាប់។

១២០. អ្នកស្នើសុំលើកឡើងថា ដំណើរការវិនិច្ឆ័យដីធ្លីដែលបានអនុវត្តនៅសង្កាត់ស្រះចក *"បានចាប់ផ្តើមការលើកឡើងនូវការការពារ..........ប្រឆាំងនឹងការរំលោភបំពានទៅលើប្រជាពលរដ្ឋ"*[៧៣] ។ យោងតាមកិច្ចព្រមព្រៀងជួលរវាងក្រុងជាមួយនឹងអ្នកអភិវឌ្ឍន៍ឯកជន អ្នកស្នើសុំលើកឡើងថា *"យ៉ាងហោចណាស់ ដំណើរការវិនិច្ឆ័យដីធ្លីបានផ្តល់នូវការកំណត់ មួយទោះស្របច្បាប់ ឬមិនស្របច្បាប់ នៃឋានៈ/ប្រភេទរបស់ដីដែលជាដីរបស់រដ្ឋ"*[៧៤] ។

១២១. អ្នកស្នើសុំលើកឡើងថា *"ក្នុងខែកក្កដា ឆ្នាំ២០០៨ នៅក្នុងអំឡុងពេលបេសកកម្មត្រួតពិនិត្យគម្រោងជាប្រចាំ បុគ្គលិកធនាគារពិភពលោកបានចុះពិនិត្យសង្កាត់ស្រះចក និងបានដឹងអំពីបញ្ហាទាក់ទងនឹងដំណើរការវិនិច្ឆ័យដីធ្លី និងដឹងអំពីការបណ្តេញប្រជាពលរដ្ឋចេញតំបន់ដែលពួកគេរស់នេះ ដែលកំពុងធ្វើការរងចាំដោះស្រាយ។ COHRE មិនបានដឹងអំពីការចាត់វិធានការរបស់ធនាគារពិភពលោក បន្ទាប់ពីបេសកកម្មនេះ"*[៧៥] ។

១២២. នៅក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងទៅនឹងចំណុចខាងលើ យល់ព្រមជាមួយនឹងអ្នកស្នើសុំ ដោយលើកឡើងថា *"ថ្នាក់គ្រប់គ្រងបានសន្និដ្ឋានថា នីតិវិធីត្រឹមត្រូវពុំត្រូវបានអនុវត្តតាមនៅក្នុងការវិនិច្ឆ័យនៃសង្កាត់ស្រះចកទេ"*[៧៦] ។ យោងតាមការឆ្លើយតបនេះ មានន័យថា ប្រជាពលរដ្ឋនៃតំបន់បឹងកក់មិនត្រូវបានផ្តល់ឱកាសដើម្បីបង្ហាញនូវការតវ៉ារបស់ខ្លួនអំពីសិទ្ធិភោគីលើដីធ្លីរបស់ខ្លួន និងមិនមានភស្តុតាងដែលបង្ហាញថា ដំណើរការដែលមានការចូលរួមប្រកបដោយតម្លាភាព ត្រូវបានអនុវត្តក្នុងការកំណត់ចំណាត់ថ្នាក់ដីធ្លីនៅក្នុងតំបន់នេះឡើយ។ ថ្នាក់គ្រប់គ្រងក៏កត់សម្គាល់ឃើញថា *ដំណើរការដែលត្រូវបានចាប់ផ្តើមក្រោមក្របខ័ណ្ឌគម្រោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ជាមួយនឹងការវិនិច្ឆ័យតំបន់ ពុំត្រូវបានអនុវត្តពេញលេញទេ បើយោងតាមនីតិវិធីនានាដែលបានព្រមព្រៀង"*[៧៧] ។

១២៣. ថ្នាក់គ្រប់គ្រងលើកឡើងថា *"យោងតាមព័ត៌មានដែលផ្តល់ដោយបុគ្គលិកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅខែមិថុនា ឆ្នាំ២០០៨ នៅក្នុងភូមិនានានៅជុំវិញបឹងកក់ នៅក្នុងអំឡុងពេលដំណើរការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី បានកំណត់តែព្រំប្រទល់ភូមិប៉ុណ្ណោះ និងមិនបានកំណត់ព្រំប្រទល់ក្បាលដីនីមួយៗនោះទេ។ ភាពជាម្ចាស់នៅក្នុងតំបន់នេះត្រូវបានសរសេរនៅក្នុងកំណត់ត្រាសុរិយោដីថា* ***"មិនដឹង"*** *។ ការចាត់ចំណាត់ថ្នាក់បែបនេះជាទូទៅ ត្រូវបានប្រើប្រាស់ចំពោះដីសាធារណៈរបស់រដ្ឋ ដែលបានជួបប្រទះនៅក្នុងអំឡុងពេលដំណើរការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ក៏ដូចជានៅពេលដីមានទំនាស់ដែលមិនអាចដោះស្រាយបាននៅកម្រិតមូលដ្ឋាននៅក្នុងអំឡុង*

---

[៧៣] សំណើសុំធ្វើអធិការកិច្ច ទំព័រទី៣។

[៧៤] សំណើសុំធ្វើអធិការកិច្ច ទំព័រទី៣។

[៧៥] សំណើសុំធ្វើអធិការកិច្ច ទំព័រទី៣។

[៧៦] ការឆ្លើយតបរបស់គណៈគ្រប់គ្រង ទំព័រទី២១។

[៧៧] ការឆ្លើយតបរបស់គណៈគ្រប់គ្រង ទំព័រទី៣៥។

*ពេលដំណើរការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី*[៧៨] ។

១២៤. ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា ក្រឡេកមើលទៅក្រោយវិញ *"ការត្រួតពិនិត្យសុវត្ថិភាព និងវិធានការសង្គមដទៃទៀត គួរតែខ្លាំងក្លាជាងនេះ...... និងទទួលស្គាល់ថា បើយោងតាមបេសកកម្មសុវត្ថិភាពថ្មីៗនេះ នៅពាក់កណ្តាលឆ្នាំ២០០៩ ការធ្វើរបាយការណ៍ត្រួតពិនិត្យអំពីបញ្ហាសុវត្ថិភាពនានា គួរត្រូវបានកែលម្អ"*[៧៩] ។

១២៥. នៅក្នុងការឆ្លើយតបរបស់ខ្លួន ថ្នាក់គ្រប់គ្រងក៏បានលើកឡើងនូវសកម្មភាពនានា ដែលពួកគេបានគ្រោងដើម្បីដោះស្រាយស្ថានភាព។ ថ្នាក់គ្រប់គ្រងកត់សម្គាល់ថា ទំនាក់ទំនងនានារវាងធនាគារ និងរដ្ឋាភិបាល ត្រូវបានខូចខាតដោយសារការកើតឡើងជុំវិញព្រឹត្តិការណ៍បឹងកក់ ហើយថា រដ្ឋាភិបាលបានលើកឡើងជាថ្មីឡើងវិញនូវការមិនឯកភាពរបស់ខ្លួនអំពីការជាប់ពាក់ព័ន្ធគ្នារវាងគម្រោង និងការបណ្តេញចេញនានានៃតំបន់បឹងកក់។ រដ្ឋាភិបាលបានលុបចោលគម្រោងនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ដោយសារការមិនឯកភាពគ្នានេះ។ ទោះបីយ៉ាងដូចនេះក៏ដោយ ថ្នាក់គ្រប់គ្រងរបស់ធនាគារបានគូសបញ្ជាក់ដល់រដ្ឋាភិបាលថា កាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ នៅតែមានដដែល រហូតដល់ការទូទាត់ឥណទានបានធ្វើឡើងចប់សព្វគ្រប់ ប៉ុន្តែរដ្ឋាភិបាលមិនឯកភាពទៅលើការអនុវត្តវិធានការដែលស្នើឡើងដោយថ្នាក់គ្រប់គ្រងរបស់ធនាគារ។

# ២. ការវិភាគរបស់ក្រុមអធិការកិច្ច

## (ក). គ្រួសាររស់នៅតំបន់បឹងកក់ ‒ ស្ថានភាពនៃការតវ៉ាទាមទារទ្រព្យសម្បត្តិរបស់ពួកគេ

១២៦. ដូចដែលបានរៀបរាប់នៅក្នុងជំពូកខាងដើម មុនពេលមានការបណ្តេញចេញ និងការបូមដីចាក់បំពេញនាពេលថ្មីៗកន្លងមកនេះ មានគ្រួសារចំនួនរាប់ពាន់គ្រួសាររស់នៅក្នុងតំបន់បឹងកក់ក្នុងទីក្រុងភ្នំពេញ។ ភាគច្រើននៃគ្រួសារទាំងនេះគិតថា ពួកគេមានកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ទៅលើដីទាំងនេះ ព្រមទាំងប្រកាសថាពួកគេមានឯកសារបញ្ជាក់ពីការទិញដីព្រមទាំងវិក័យបត្រទិញដីទាំងនេះផងដែរ។ ដីត្រូវបានកាន់កាប់ ផ្ទេរសិទ្ធ និងទទួលមរតក ព្រមទាំងមានការទទួលស្គាល់ត្រឹមត្រូវតាមច្បាប់ និងដោយអាជ្ញាធរ និងអ្នកប្រើប្រាស់ពាក់ព័ន្ធ ទោះបីជាមិនទាន់មានឯកសារទទួលស្គាល់ដោយប្រព័ន្ធផ្លូវការរបស់ជាតិក៏ដោយ។ គ្រួសារជាច្រើនរស់នៅក្រៅតំបន់ដែលមានគូសបន្ទាត់កម្រិតទឹកខ្ពស់ ហើយខ្លះទៀតរស់នៅតំបន់ចន្លោះបន្ទាត់កម្រិតទឹកទាប និងខ្ពស់ និងខ្លះទៀតរស់នៅលើផ្ទះនៅក្នុងតំបន់ដែលមានកម្រិតបន្ទាត់ទឹកទាបនៃបឹង។

១២៧. ក្រុមអធិការកិច្ចកត់សម្គាល់ថា ទិដ្ឋភាពសំខាន់នៃស្ថានភាពច្បាប់នៅតំបន់បឹងកក់ មិនមានភាពច្បាស់លាស់ ព្រមទាំងមានវិវាទច្រើន។ មានការអះអាងបញ្ជាក់ថាមានតំបន់ត្រួតស៊ីគ្នាខ្លះជាមួយនឹងដីសាធារណៈ និងឯកជនរបស់រដ្ឋនៅក្នុងតំបន់ខាងក្នុង និងជុំវិញបឹងកក់ និងប្រភេទកម្មសិទ្ធិខុសគ្នាមួយចំនួន។ បឹងនេះគឺជាបឹងធម្មជាតិ ដែលបានកំនត់នៅក្នុងមាត្រាទី៥៨នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ថាជាទ្រព្យសម្បត្តិរបស់រដ្ឋ និងនៅក្នុងមាត្រាទី១៥នៃច្បាប់ភូមិបាលឆ្នាំ២០០១

---

[៧៨] ការឆ្លើយតបរបស់គណៈគ្រប់គ្រង ទំព័រទី២០។

[៧៩] ការឆ្លើយតបរបស់គណៈគ្រប់គ្រង ទំព័រទី៣៣។

ថាជាដីសាធារណៈរបស់រដ្ឋ ។ វិធានច្បាប់ពាក់ព័ន្ធ (ប្រកាស)[៨០] បញ្ជាក់ថាព្រំប្រទល់របស់បឹងត្រូវបានកំណត់ដោយខ្សែបន្ទាត់ទឹកទាបបំផុតនៅរដូវប្រាំង ហើយមិនមានច្បាប់ណាមួយ ដែលបានរៀបចំឡើងបម្រុងទុកដោយឡែកចំពោះបឹងឡើយ។ ជាលទ្ធផល ដីដែលមានទីតាំងស្ថិតនៅចន្លោះរវាងបន្ទាត់ទឹកទាបបំផុត នៅរដូវប្រាំង និងខ្ពស់បំផុតនៅរដូវវស្សា ត្រូវបានកំណត់ថាជាដីឯកជនរបស់រដ្ឋ លើកលែងតែមានការប្រើប្រាស់ជាសាធារណៈ ឬមានប្រយោជន៍ដល់សាធារណៈ។ ផ្អែកទៅលើការកំណត់នេះ ក្រុមអធិការកិច្ចមានការកត់សម្គាល់ថា រាល់ទ្រព្យសម្បត្តិដែលបានសាងសង់នៅលើសសរខ្ពស់ផុតពីទឹកនៅក្នុងតំបន់បឹងអាចចាត់ទុកថាស្ថិតនៅលើដីសាធារណៈរបស់រដ្ឋ។

១២៨. មាត្រាទី១៧នៃច្បាប់ភូមិបាលចែងថា ទ្រព្យសម្បត្តិដែលបានចាត់ចំណាត់ថ្នាក់ថាជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងនិតិបុគ្គលសាធារណៈ អាចលក់ដោះដូរ បែងចែក ឬក៏ផ្ទេរកម្មសិទ្ធិបាន ដូចដែលបានកំណត់ដោយច្បាប់។ ផ្អែកទៅលើមូលដ្ឋាននេះ តំបន់ដែល ស្ថិតនៅចន្លោះរវាងខ្សែបន្ទាត់ទឹកទាបនិងខ្ពស់ អាចមានសិទ្ធិក្នុងការចេញប័ណ្ណសម្គាល់កម្មសិទ្ធិផ្លូវការទៅឱ្យភាគីឯកជន ឬក៏និតិបុគ្គលសាធារណៈបាន។

១២៩. មានការចែងខុសៗគ្នានៅក្នុងច្បាប់ ដែលបានយកមកអនុវត្តចំពោះករណីដីពាក់ព័ន្ធទៅនឹងសិទ្ធិផ្លូវ ចំពោះផ្លូវរថភ្លើងកាត់តាមតំបន់បឹងកក់។ មាត្រាទី១២ នៃច្បាបភូមិបាលឆ្នាំ១៩៩២ចែងថា ដីបម្រុងទុកសម្រាប់ផ្លូវរថភ្លើង គឺជាសម្បត្តិសាធារណៈរបស់រដ្ឋ។ ការចែងដូចគ្នានេះ ក៏បានបញ្ជាក់ផងដែរនៅក្នុងមាត្រាទី១៥នៃច្បាប់ភូមិបាលឆ្នាំ២០០១ ហើយត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសលេខ៤២ ដែលបានដាក់បញ្ចូលដីទាំងអស់ក្នុងចំងាយ២០ម៉ែត្រពីអ័ក្សផ្លូវនៅក្នុងទីក្រុង ទីរួមខេត្ត និងតំបន់ទីប្រជុំជន[៨១] ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ មានភស្តុតាងពីករណីសិក្សាជាច្រើន (សូមមើលជំពូកទី១ប្រអប់លេខ១) ដែលអជ្ញាធរអោយស្វ័យយានខ្លួនឯង លើកទឹកចិត្តឱ្យកម្មកររបស់ខ្លួនចាប់យកដីនៅក្បែរផ្លូវរថភ្លើង ចាប់តាំងពីដើមឆ្នាំ១៩៨០ ដើម្បីឱ្យពួកគេអាចរស់នៅក្បែរកន្លែងធ្វើការងាររបស់គេ។ ភាគច្រើននៃអ្នកចាប់យកដីទាំងនេះ គឺជាតំណាងប្រជាពលរដ្ឋ និងគ្រួសារ ដែលបានស្នើឡើងនៅក្នុងក្រុមអធិការកិច្ច បានបញ្ជាក់ថាមានប័ណ្ណសម្គាល់សិទ្ធកាន់កាប់ ដែលបញ្ជាក់ថាពួកគេអាចមានសិទ្ធិទទួលការពិចារណាសម្រាប់ការផ្តល់ប័ណ្ណសម្គាល់កម្មសិទ្ធបាន ជាពិសេសចំពោះអ្នកដែលបានកាន់កាប់ដីនោះច្រើនជាងប្រាំឆ្នាំ មុនពេលការអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១។

១៣០. ចុងបញ្ចប់ តំបន់ផ្សេងៗទៀតនៅជុំវិញបឹង ត្រូវបានរាយការណ៍ថាបានប្រើប្រាស់ជាសួនច្បារសាធារណៈ ព្រមទាំងសួនសត្វនៅតាមចំណុចមួយចំនួន បន្ទាប់ពីសាលាក្រុងបានកាន់កាប់តំបន់នេះចាប់តាំងពីឆ្នាំ១៩៧៩មក។ សួនច្បារសាធារណៈ បានកំណត់នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ថាជាដីសាធារណៈរបស់រដ្ឋ ហេតុដូចនេះរាល់ការចាប់យកដីទាំងនេះចាត់ទុកថាខុសច្បាប់[៨២]។ ក្រុមអធិការកិច្ចកត់សម្គាល់ឃើញថា មិនមានសួនច្បារសាធារណៈនៅសេសសល់ទៀតឡើយ ហើយមិនមានភាពច្បាស់លាស់ថាតើព្រំប្រទល់របស់វានៅទីណាឡើយ។ ដោយហេតុថាតំបន់ទាំងនេះមិនមានការវាស់វែង និងចុះបញ្ជីជាសម្បត្តិរបស់រដ្ឋនៅឡើយ ហើយលើសពីនេះទៅទៀត ដីទាំងនេះបានបាត់បង់មុខងារ

---

[៨០] ប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី១០ ខែមិនា ២០០៦ ស្តីពីការកំនត់ ការធ្វើផែនទី និងការចាត់ចំណាត់ថ្នាក់ដីរដ្ឋ ។

[៨១] ប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី១០ ខែមិនា ២០០៦ ស្តីពីការកំនត់ ការធ្វើផែនទី និងការចាត់ចំណាត់ថ្នាក់ដីរដ្ឋ ទំព័រទី៨ ។

[៨២] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រាទី ១៥ ។

ប្រើប្រាស់ជាសួនច្បារសាធារណៈអស់ទៅហើយ ហេតុដូច្នេះតំបន់នេះអាចចាត់ទុកថាជាដីសាធារណៈរបស់រដ្ឋបាន។ នៅក្នុងករណីនេះ ប្រជាពលរដ្ឋ និងគ្រួសារដែលជាម្ចាស់បានកាន់កាប់ដីទាំងនេះស្របទៅតាមមាត្រានៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ អាចមានសិទ្ធិទទួលបានការទាមទាររបស់គេសម្រាប់ការពិចារណាផ្តល់ប័ណ្ណសម្គាល់កម្មសិទ្ធិបាន ។

១៣១. **ទស្សនៈរបស់ក្រុមអធិការកិច្ចយល់ឃើញថា ផ្នែកមួយចំនួននៃតំបន់បឹងកក់ អាចមានសិទ្ធិទទួលបានការពិចារណាផ្តល់ប័ណ្ណសម្គាល់កម្មសិទ្ធិសម្រាប់កម្មសិទ្ធិឯកជន ស្ថិតក្រោមគោលការណ៍វិនិច្ឆ័យនៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី**។ ដូចបានបញ្ជាក់ខាងដើម តំបន់បឹងកក់ ត្រូវបានប្រកាសថាជាតំបន់វិនិច្ឆ័យនៅក្រោមក្របខ័ណ្ឌគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីតាំងពីឆ្នាំ២០០៦។

## (ខ). ការចាត់ចំណាត់ថ្នាក់ដីឡើងវិញ និងកិច្ចព្រមព្រៀងជួលជាមួយអ្នកអភិវឌ្ឍឯកជន

១៣២. ក្រុមអធិការកិច្ចបានដឹងថា ក្នុងកំឡុងពេលអនុវត្តគម្រោង រដ្ឋាភិបាលបានធ្វើចំណាត់ថ្នាក់ដីឡើងវិញនូវតំបន់ជុំវិញបឹងកក់ឱ្យទៅជាដីសាធារណៈរបស់រដ្ឋ រួមទាំងតំបន់ដែលរស់នៅដោយគ្រួសារដែលបានតវ៉ា។ ក្រុមអធិការកិច្ចក៏បានដឹងផងដែរថា ស្របពេលជាមួយគ្នានេះដែរ ក៏មានការរៀបចំផែនការដោយឡែក ដើម្បីជួលដីនេះទៅឱ្យអ្នកអភិវឌ្ឍន៏ឯកជន។ ក្រុមអធិការកិច្ចបានធ្វើពិនិត្យលើទង្វើទាំងនេះ នៅក្នុងក្របខ័ណ្ឌនានារបស់គម្រោងដែលបានរៀបចំឡើង ដើម្បីធានាឱ្យមានការពិចារណាត្រឹមត្រូវលើការទាមទារកម្មសិទ្ធពីគ្រួសារទាំងឡាយ ដែលរស់នៅលើដីទាំងនេះ ស្របទៅតាមគោលនយោបាយរបស់ធនាគារពិភពលោក។

១៣៣. សម្រាប់គោលបំណងនេះ ការពិនិត្យឡើងវិញសង្ខេបលើបរិបទក្របខណ្ឌគតិយុត្តិនានា មានសារៈសំខាន់ជាទីបំផុត។ មាត្រាទី១៥នៃច្បាប់ភូមិបាលឆ្នាំ២០០១ បានរៀបចំបញ្ជីប្រភេទទ្រព្យសម្បត្តិនានា ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ ទាំងនេះរួមបញ្ចូលទាំងទ្រព្យសម្បត្តិដែលមានប្រភពដើមពីធម្មជាតិ រួមទាំងតំបន់សម្រាប់ការធ្វើនាវាចរណ៍ និងតំបន់បណ្តែតទឹក និងបឹងធម្មជាតិផងផងដែរ ។ ដោយហេតុដូចនេះបឹងធម្មជាតិដូចជាបឹងកក់ផ្អែកតាមនិយមន័យគឺជាដីសាធារណៈរបស់រដ្ឋ ទោះបីជាតំបន់ ជុំវិញបឹងនៅមិនទាន់បានកំណត់នៅក្នុងច្បាប់ក៏ដោយ ។ ផ្អែកតាមមាត្រាទី១៦ ចែងថាដីសាធារណៈរបស់រដ្ឋ អាចក្លាយជាគោលដៅនៃការកាន់កាប់ ឬប្រើប្រាស់បណ្តោះអាសន្នបាន ទោះបីជាមាត្រាទី១៨នៃអនុក្រឹត្យលេខ១២៩ បានបញ្ជាក់ថា ការជួលដីសាធារណៈរបស់រដ្ឋមិនអាចមានរយៈពេលលើសពី១៥ឆ្នាំបាន និងមិនអាចធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ឬក៏ផ្លាស់ប្តូរមុខងាររបស់វា នៅក្នុងការផ្តល់សេវាកម្មសាធារណៈបានក៏ដោយ[៨៣] ។ មាត្រាទី១៦ នៃច្បាប់ភូមិបាលក៏បានចែងផងដែរថា *"នៅពេលដែលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋបាត់បង់មុខងារប្រើប្រាស់សម្រាប់ជាផលប្រយោជន៍សាធារណៈ ទ្រព្យសម្បត្តិទាំងនោះអាចចាត់បញ្ចូលក្នុងបញ្ជីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដោយច្បាប់ស្តីពីការផ្ទេរទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ"*[៨៤] ។

---

[៨៣] អនុក្រឹត្យលេខ១២៩ស្តីពីបែបបទ និងនិតិវិធីសម្រាប់ការធ្វើចំណាត់ថ្នាក់ទ្រពសម្បត្តិសាធារណៈរបស់រដ្ឋ និងនិតិបុគ្គលសាធារណៈឡើងវិញ ។

[៨៤] ច្បាប់ភូមិបាលឆ្នាំ២០០១ ។

១៣៤. ទោះជាយ៉ាងណាក៏ដោយ មាត្រាទី៣គ នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងដីរដ្ឋ[៨៥] តម្រូវថា "ចំណែកដីនីមួយៗរបស់រដ្ឋត្រូវតែចុះបញ្ជីនៅក្នុងបញ្ជីដីធ្លីជាដីសាធារណៈឬឯកជនរបស់រដ្ឋ"។ មាត្រាទី១៣សំដៅទៅលើការធ្វើចំណាត់ថ្នាក់ដីឡើងវិញថា*"ជាការផ្លាស់ប្ដូរ ឋានានុក្រមរបស់ដីដែលបានចុះបញ្ជីជាដីសាធារណៈ និងឯកជនរបស់រដ្ឋរួចហើយ"*។ មាត្រាទី៤នៃព្រះរាជក្រឹត្យ[៨៦] ក៏បានចែងផងដែរថា " ការផ្ទេរទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនិតិបុគ្គលសាធារណៈអាចធ្វើទៅបានតែចំពោះទ្រព្យសម្បត្តិដែលបានចុះបញ្ជីជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋរួចហើយតែប៉ុណ្ណោះ"។ ដូចនេះ ដីអាចធ្វើចំណាត់ថ្នាក់ឡើងវិញពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ បន្ទាប់ពីដីទាំងនេះត្រូវបានចុះបញ្ជីជាដីរបស់រដ្ឋនៅក្នុងបញ្ជីដីធ្លីជាមុនសិន *"បើមិនដូច្នេះទេលុះត្រាតែត្រូវបានផ្ដល់ឱ្យ ដោយច្បាប់"*[៨៧]។ ការធ្វើចំណាត់ថ្នាក់ដីប្រភេទនេះឡើងវិញ ដាច់ខាតត្រូវតែអនុលោមទៅតាមមាត្រាទី១៦នៃច្បាប់ភូមិបាលផងដែរ។ ក្រុមអធិការកិច្ច កត់សំគាល់ឃើញថា គោលបំណងសំខាន់នៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី បានធ្វើការងារចុះបញ្ជីដីទាំងនេះផងដែរ ។

១៣៥. យោងទៅតាមការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ក្នុងអំឡុងពេលបេសកកម្មនាខែមិថុនា ឆ្នាំ២០០៨ ធនាគារពិភពលោកបានជម្រាបជូនដំណឹងថា សាលាក្រុងភ្នំពេញបានប្រកាសថា តំបន់បឹងកក់គឺជាដីសាធារណៈរបស់រដ្ឋ ហេតុដូចនេះគ្រួសារនៅក្នុងតំបន់នេះ ត្រូវបានដកចេញពីការផ្ដល់ប័ណ្ណសម្គាល់កម្មសិទ្ធិ ដោយសារការផ្ដល់ប័ណ្ណសម្គាល់កម្មសិទ្ធិមិនអាចធ្វើទៅបាននៅក្រោមច្បាប់ភូមិបាល ក្នុងការការពារឯកជនទាមទារកម្មសិទ្ធិស្របច្បាប់លើដីសាធារណៈរបស់រដ្ឋបាន។ ជាងនេះទៅទៀត ថ្នាក់គ្រប់គ្រងបានគូសបញ្ជាក់ថា *"គេមិនបានទទួលភស្តុតាងនានាដើម្បីគាំទ្រដល់សាលាក្រុងក្នុងការអះអាងថា តំបន់បឹងកក់គឺជាដីសាធារណៈរបស់រដ្ឋឡើយ"*[៨៨] ។

១៣៦. ផ្អែកទៅតាមការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង មានតែព្រំប្រទល់ភូមិតែប៉ុណ្ណោះដែលបានកំណត់ដោយគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈស្ដីពីលទ្ធផលនៃការធ្វើវិនិច្ឆ័យដី បង្ហាញថាភាពជាម្ចាស់លើតំបន់ទាំងនោះ គឺមិនទាន់បានដឹងនៅឡើយនៅលើផែនទីសុរិយោដី ដែលរៀបចំដោយគណៈកម្មាការរដ្ឋបាលក្រោមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ថ្នាក់គ្រប់គ្រងបានកត់សំគាល់ថា ព័ត៌មានទាំងនេះគ្រាន់តែជាការធ្វើចំណាត់ថ្នាក់ដីជាទូទៅ ដែលប្រើប្រាស់សម្រាប់តែដីសាធារណៈរបស់រដ្ឋ និងសម្រាប់ដីដែលមានគោលដៅទំនាស់ដែលមិនអាចដោះស្រាយបាននៅនឹងមូលដ្ឋានក្នុងកំឡុងពេលដំណើរការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិតែប៉ុណ្ណោះ[៨៩] ។

១៣៧. ដូចដែលបានកត់សម្គាល់នៅក្នុងជំពូកទី២នៃរបាយការណ៍នេះ ទោះបីជាតំបន់បឹងកក់ត្រូវបានប្រកាសថាជាដីសាធារណៈរបស់រដ្ឋដោយរដ្ឋាភិបាល ហើយជាលទ្ធផលប្រជាពលរដ្ឋត្រូវបានជម្រាបជូនដំណឹងថាពួកគេគ្មានសិទ្ធិធ្វើកម្មសិទ្ធលើ

---

[៨៥] អនុក្រឹត្យលេខ ១១៨: អនុក្រឹត្យស្ដីពីការគ្រប់គ្រងដីរដ្ឋ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ។

[៨៦] ព្រះរាជក្រឹត្យស្ដីពី " គោលការណ៍ និងការផ្ដល់ការផ្ទេរទ្រពសម្បត្តិសាធារណៈរបស់រដ្ឋ និងនិតិបុគ្គលសាធារណៈបណ្ដោះអាសន្ន " ថ្ងៃទី៣ ខែសីហា ២០០៦ ។

[៨៧] ibid, មាត្រាទី ១៤ ។

[៨៨] ការឆ្លើយតបពីអ្នកគ្រប់គ្រង ទំព័រទី ១៩។

[៨៩] ការឆ្លើយតបរបស់អ្នកគ្រប់គ្រង ទំព័រទី ២១ ។

ទ្រព្យសម្បត្តិទាំងនោះក៏ដោយ ក៏ប៉ុន្តែផែនការសម្រាប់អភិវឌ្ឍឯកជនលើតំបន់បឹងកក់បានមានដំណើរការដោយរលូនតាំងពីមុនពេលដែលមានការប្រកាសតំបន់នេះ ថាជាតំបន់វិនិច្ឆ័យនៅក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីទៅទៀត។ នាខែសីហា ឆ្នាំ២០០៥ រយៈពេល៧ខែមុនការប្រកាស តំបន់វិនិច្ឆ័យនៃតំបន់បឹងកក់នាខែមិនា ឆ្នាំ២០០៦ ការិយាល័យនៃទីស្តីការគណៈរដ្ឋមន្ត្រី បានជូនដំណឹងទៅអភិបាលរាជធានីភ្នំពេញថា ជាគោលការណ៍ រដ្ឋាភិបាលឯកភាពឱ្យក្រុមហ៊ុនស៊ូកាគូ ធ្វើការអភិវឌ្ឍនៅតំបន់បឹងកក់។ លិខិតក៏បានយោងទៅលើការសម្រេចចិត្ត របស់រដ្ឋាភិបាល ដើម្បីបង្កើតក្រុមការងារ “ ធ្វើការសិក្សាស៊ីជម្រៅលើផែនការមេ ដែលបានសិក្សារៀបចំដោយអ្នកបច្ចេកទេស និង ផែនការអភិវឌ្ឍរបស់ក្រុមហ៊ុន” ដែលក្រុមហ៊ុនបានធ្វើការសិក្សា ព្រមទាំងតម្រូវការសម្រាប់ “ការធ្វើសកម្មភាពដោះស្រាយបញ្ហា កាន់កាប់ដីខុសច្បាប់ជាបណ្តើរៗ ដោយផ្អែកលើបទពិសោធន៍កន្លងមក” [៩០] ។



**រូបភាពទី ៤: ខ្សាច់ត្រូវបានគេបូមដាក់ក្នុងបឹងកក់**

១៣៨. នាថ្ងៃទី៣ ខែមករា ឆ្នាំ២០០៦ ការិយាល័យនៃទីស្តីការគណៈរដ្ឋមន្ត្រី បានជូនដំណឹងទៅអភិបាលរាជធានីភ្នំពេញថា រដ្ឋាភិបាលឯកភាព “ឱ្យក្រុមហ៊ុនស៊ូកាគូអភិវឌ្ឍតំបន់បឹងកក់ដោយរក្សាទុកផ្ទៃបឹង១០ហិកតា” និង “ឱ្យសាលាក្រុងធ្វើការសិក្សាជាមួយនឹងក្រុមហ៊ុន ព្រមទាំងប្រើប្រាស់បទពិសោធន៍កន្លងមក ធ្វើការដោះស្រាយជាបណ្តើរៗជាមួយនឹងអ្នកកាន់កាប់ដីមិនស្របច្បាប់ និងដំណើរការបូមដីចាក់បំពេញសម្រាប់គោលដៅអភិវឌ្ឍតំបន់[៩១] ។ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧ សម្តេចនាយករដ្ឋមន្ត្រីបានអនុញ្ញាតឱ្យអភិបាលរាជធានីភ្នំពេញចុះហត្ថលេខាលើកិច្ចព្រមព្រៀង

[៩០] លិខិតលេខ១២៧៤ ស.ជ.ណ របស់ការិយាល័យនៃទីស្តីការគណៈរដ្ឋមន្ត្រី ចេញខែសីហា ឆ្នាំ២០០៥ ដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទី ស្តីការគណៈរដ្ឋមន្ត្រី ជូនទៅឯកឧត្តមអភិបាលរាជធានីភ្នំពេញ ។

[៩១] លិខិតលេខ០១ ស.ជ.ណ របស់ការិយាល័យនៃទីស្តីការគណៈរដ្ឋមន្ត្រីចេញថ្ងៃទី៣ ខែមករា ២០០៦ ដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទី ស្តីការគណៈរដ្ឋមន្ត្រី ជូនទៅឯកឧត្តមអភិបាលរាជធានីភ្នំពេញ ។

ជួលជាមួយក្រុមហ៊ុនស៊ូកាគូ[៥២] ។ កិច្ចសន្យាជួលរយៈពេល៩៩ឆ្នាំរវាងសាលាក្រុងភ្នំពេញ និងក្រុមហ៊ុនអភិវឌ្ឍឯកជនស៊ូកាគូ បានចុះហត្ថលេខានាថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៧ បន្ទាប់ពីការប្រកាសតំបន់បឹងកក់ជាតំបន់វិនិច្ឆ័យធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីរយៈពេលជិតមួយឆ្នាំក្រោយមក។ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨ រដ្ឋាភិបាលបានចេញអនុក្រឹត្យកែប្រែតំបន់នេះ (រួមទាំងបឹងផងដែរ)ពីដីសាធារណៈរបស់រដ្ឋ ទៅជាដីឯកជនរបស់រដ្ឋ[៥៣] ។

១៣៩. អង្គការមិនមែនរដ្ឋាភិបាលនានា ដែលធ្វើការងារពាក់ព័ន្ធទៅនឹងបញ្ហាដីធ្លីនៅក្នុងប្រទេសកម្ពុជា និងអ្នកគាំទ្រទៅដល់អ្នកតវ៉ាស្នើសុំ បានចោទសួរពីសុពលភាពនៃការផ្ទេរតំបន់បឹងកក់ពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋដោយសារមូលហេតុមួយចំនួន។ ពួកគេបានលើកឡើងថាបឹងកក់គឺជាបឹងធម្មជាតិ ផ្អែកតាមនិយមន័យគឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដោយសារតែធម្មជាតិដើមរបស់វា ហើយដោយហេតុដូចនេះមិនគួរជាគោលដៅសម្រាប់ការផ្ទេរទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋឡើយ។ ជាងនេះទៅទៀត ពួកគេបានកត់សម្គាល់ឃើញថា ដីសាធារណៈរបស់រដ្ឋអាចធ្វើការចាត់ចំណាត់ថ្នាក់ឡើងវិញបានតែក្នុងករណីដែលវាបានបាត់បង់ នូវការប្រើប្រាស់ជាសាធារណៈតែប៉ុណ្ណោះ ហើយបឹងកក់គឺជាប្រព័ន្ធស្តុកទឹកភ្លៀងធម្មជាតិដ៏ធំមួយក្នុងទីក្រុងភ្នំពេញ ដែលមិនទាន់បានបាត់បង់លទ្ធភាពប្រើប្រាស់សម្រាប់គោលបំណងសាធារណៈនៅឡើយ[៥៤] ។

១៤០. ក្រុមអធិការកិច្ចក៏បានកត់សម្គាល់ឃើញផងដែរថា តាមរយៈការជួលតំបន់បឹងកក់ឱ្យទៅក្រុមហ៊ុនអភិវឌ្ឍឯកជន និងការចាត់ចំណាត់ថ្នាក់ តំបន់នេះឡើងវិញពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ រាជរដ្ឋា ភិបាលបានកំណត់សម្រេចប្រកបដោយប្រសិទ្ធិភាពថា ដីនៅជុំវិញបឹង និងបឹងខ្លួនឯងតែម្តង បានបាត់បង់ផលប្រយោជន៍ប្រើប្រាស់សាធារណៈហើយអាចក្លាយទៅជាគោលដៅសម្រាប់ទទួលបានកម្មសិទ្ធិទ្រព្យសម្បត្តិឯកជន។ តាមរយៈការកំណត់ដីនេះឱ្យទៅជាដីឯកជនរបស់រដ្ឋ ពលរដ្ឋដែលរស់នៅ ឬកាន់កាប់ដីនៅតំបន់នោះ អាចពិចារណាខ្លួនឯងយ៉ាងសមហេតុផលថាមានសិទ្ធិទាមទារឱ្យមានការការពារស្របច្បាប់ ។

១៤១. **ក្រុមអធិការកិច្ចយល់ស្របជាមួយនឹងថ្នាក់គ្រប់គ្រងថា អ្នកតាំងទីលំនៅនៅក្នុងតំបន់បឹងកក់ ត្រូវបានបដិសេធដល់ការទទួលបានដំណើរការនៃការធ្វើវិនិច្ឆ័យ ដើម្បីទាមទារសិទ្ធិលើទ្រព្យសម្បត្តិរបស់ពួកគេ ។ ក្រុមបានរកឃើញថា អ្នកតាំងទីលំនៅនៅក្នុងតំបន់បឹងកក់ បានបញ្ជាក់ក្នុងក្តីសង្ឃឹមថា ការទាមទារដីធ្លីរបស់ពួកគេ មានសិទ្ធិទទួលបានការគិតគូរពិចារណានៅក្រោមការធ្វើប័ណ្ណកម្មសិទ្ធជាប្រព័ន្ធ ហើយជាងនេះទៅទៀត រាល់ការទាមទារដីទាំងអស់នៅក្នុងឃុំបានទទួលការធ្វើវិនិច្ឆ័យស្របជាមួយនឹងនិតិវិធី និងដំណើរការសម្រាប់ការធ្វើវិនិច្ឆ័យលើ**

---

[៥២] លិខិតអនុញ្ញាតិលេខ១០ ស.ប.ត នៃរាជរដ្ឋាភិបាលកម្ពុជា ចេញថ្ងៃទី៣០ ខែមករា ២០០៧ ។

[៥៣] អនុក្រឹត្យលេខ ១០៨ ស.ង ស្តីពីការផ្ទេរទីតាំងបឹងកក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ចុះថ្ងៃទី៧ សីហា ២០០៨ ។

[៥៤] United, BABSEA,COHRE,JRS,2009.P.60,61.

**ការទាមទារកាន់កាប់ទ្រព្យសម្បត្តិ ដូចដែលបានឯកភាពរវាងរដ្ឋាភិបាល ធនាគារពិភពលោក និងដៃគូអភិវឌ្ឍនានា ដែលគាំទ្រដល់គម្រោងគ្រប់គ្រង និងបែងចែកដី ។**

## (គ). ការកាត់តំបន់បឹងកក់ចេញបន្ទាប់ពីការប្រកាសតំបន់វិនិច្ឆ័យនៅក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

១៤២. បញ្ហាពាក់ព័ន្ធដែលបានធ្វើការពិចារណាដោយក្រុមអធិការកិច្ចគឺ តើការកាត់ចេញតំបន់បឹងកក់ពីគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីក្នុងកំឡុងពេលនៃការអនុវត្តគម្រោង មានភាពស៊ីសង្វាក់គ្នាជាមួយនឹងការរៀបចំគម្រោងនិងកាតាព្វកិច្ចនានានៅក្រោមក្របខ័ណ្ឌគម្រោងដែរឬទេ។

១៤៣. ក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញថា ទាំងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដៃគូអភិវឌ្ឍន៍មានទស្សនៈគិតថា ដំណើរការដែលបានអនុលោមនៅក្នុងតំបន់បឹងកក់ មិនបានបំពានទៅលើកាតាព្វកិច្ចរបស់ភាគីខ្ចីនៅក្រោមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍដែរឬយ៉ាងណា។ ពួកគេបានគូសបញ្ជាក់ជូនដល់ក្រុមអធិការកិច្ចថា តំបន់បឹងកក់ត្រូវបានកាត់ចេញពីដំណើរការធ្វើវិនិច្ឆ័យតំបន់ ដោយសារតែស្ថានភាពទំនាស់ដី ហើយដោយហេតុដូចនេះ ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិ រួមកម្មសិទ្ធិដីរដ្ឋក៏មិនត្រូវបានទទួលការយល់ព្រមឡើយ។ ពួកគេបានធ្វើការពន្យល់ ដោយផ្អែកលើសេចក្តីថ្លែងការរបស់ឯកសារវិនិច្ឆ័យគម្រោងថា "គម្រោងនឹងមិនអាចផ្តល់ប័ណ្ណសម្គាល់កម្មសិទ្ធិដីនៅតំបន់ដែលទំនាស់ទំនងជាមិនអាចដោះស្រាយបានឡើយ"[៥៥] ។ ម៉្យាងវិញទៀត អ្នកស្នើសុំតវ៉ា និងអង្គការមិនមែនរដ្ឋាភិបាលបានទាមទារថា ការកាត់ចេញតំបន់ដែលមានទំនាស់ ឬមិនច្បាស់លាស់ ពីការផ្តល់ប័ណ្ណសម្គាល់កម្មសិទ្ធិលក្ខណៈជាប្រព័ន្ធបានអនុញ្ញាតិឱ្យអាជ្ញាធរខេត្ត ក្រុង ដែលទទួលខុសត្រូវនៅក្នុងការជ្រើសរើសតំបន់វិនិច្ឆ័យ ជ្រើសរើសកាត់ចេញតំបន់នេះដោយលំអៀងទៅតាមអ្នកមានអំណាច និង អ្នកវិនិយោគបរទេស[៥៦] ។

១៤៤. ក្រុមអធិការកិច្ចបានបែងចែកការវិភាគលើបញ្ហានេះជា៤ផ្នែកដែលមានទំនាក់ទំនងគ្នាៈ និតិវិធីនៃការធ្វើវិនិច្ឆ័យគម្រោង វិធីសាស្ត្ររបស់គម្រោងចំពោះដីដែលមានទំនាស់ វិធីសាស្ត្រគម្រោងចំពោះការមកតាំងទីលំនៅមិនស្របច្បាប់ និងវិធី សាស្ត្រគម្រោងចំពោះការគ្រប់គ្រងដីរដ្ឋ។ ផ្នែកនិមួយៗត្រូវបានលើកយកមកពិភាក្សាដូចខាងក្រោមៈ

- **និតិវិធីនៃការធ្វើវិនិច្ឆ័យគម្រោង**

១៤៥. ឯកសារជំនួយស្មារតីសម្រាប់ការអនុវត្តគម្រោងបានពន្យល់ថា ការធ្វើវិនិច្ឆ័យ "គឺជាដំណើរការបញ្ជាប់ និងផ្លូវការ ដែលកំណត់ពីសិទ្ធិដែលមានស្រាប់ទៅលើចំណែកដីណាមួយ ដោយមិនធ្វើឱ្យមានការផ្លាស់ប្តូរសិទ្ធិដែលមានស្រាប់ លើ

[៥៥] PAD, ទំព័រ ២៤ ។

[៥៦] មានការអះអាងនៅក្នុងការសិក្សានាពេលថ្មីៗនេះថា ការកាត់ចេញតំបន់ដែលមានទំនាស់ ឬមិនច្បាស់លាស់ ពីការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិដី លក្ខណៈជាប្រព័ន្ធ "បានអនុញ្ញាតិឱ្យអជ្ញាធរខេត្ត ក្រុង ដែលទទួលខុសត្រូវនៅក្នុងការជ្រើសរើសតំបន់វិនិច្ឆ័យ ជ្រើសរើសកាត់ចេញតំបន់នេះ ដោយ មានភាពលំអៀងទៅតាមអ្នកមានអំណាច និងអ្នកវិនិយោគបរទេស" ។ "ការធ្វើប័ណ្ណសំគាល់កម្មសិទ្ធដីនៅប្រទេសកម្ពុជាៈ ការធ្វើឱ្យអសមធម៌មាន ការយល់ព្រម" ស្ពានឆងកាត់ព្រំ ប្រទល់ប្រទេសកម្ពុជា-ការពិនិត្យឡើងវិញមួយឆ្នាំ២០០៩ Bugalski, N and Pred, D. (2009) ។

ចំណែកដីនោះ ឬមួយក៏បង្កើត នូវសិទ្ធិថ្មីផ្សេងទៀតឡើយ" ។ ការធ្វើវិនិច្ឆ័យ "ក៏ជាការកំណត់សម្រេចផងដែរថាតើបុគ្គលណាអាចមានសិទ្ធិប្រតិបត្តិសិទ្ធិទាំងនោះ ព្រមទាំងកត្តាកំណត់ទាំងឡាយដែលសិទ្ធិទាំងនោះមាននៅក្នុងការអនុវត្តច្បាប់ និងក្របខណ្ឌគតិយុត្តិ ដែលលទ្ធផលនៃការធ្វើការវិនិច្ឆ័យ គឺជារបាយការណ៍ដីពេញលេញ ដែលមានភាពជាក់លាក់ បញ្ចប់ និងធានារ៉ាប់រងដោយរដ្ឋ"[៩៧] ។

១៤៦. អនុក្រឹត្យលេខ៤៦ "ស្តីពីនីតិវិធីបង្កើតក្រមផែនទីសុរិយោដី និងការចុះបញ្ជីដី" បង្កើតឡើងនូវនីតិវិធីគតិយុត្តិសម្រាប់ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិដីលក្ខណៈជាប្រព័ន្ធ នៅក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ មាត្រាទី២ ដែលរួមមានសេចក្តីប្រកាសស្តីពីការធ្វើវិនិច្ឆ័យតំបន់ចែងថា "អភិបាលខេត្ត/ក្រុង ត្រូវតែប្រកាសតំបន់ និងព្រំប្រទល់ជាតំបន់សម្រាប់ការធ្វើវិនិច្ឆ័យ ។ ការធ្វើសេចក្តី សម្រេចចិត្តទាំងឡាយនៅក្រោមមាត្រានេះ ត្រូវតែកំនត់ពីទីតាំង និងដែនកំណត់តំបន់វិនិច្ឆ័យ ដោយប្រើប្រាស់ផែនទី ឬដោយការ ពិពណ៌នា ឬដោយប្រើមធ្យោបាយទាំងពីរ"[៩៨] ។ ក្រុមយល់ឃើញថា មានការរៀបចំផ្សព្វផ្សាយតំបន់វិនិច្ឆ័យទៅតាមព្រំប្រទល់ឃុំ ទោះបីជាអនុក្រឹត្យលេខ៤៦ មិនបានបញ្ជាក់ពីអ្វីមួយដែលជាផលវិបាកពីការអនុវត្តបែបនេះក៏ដោយ ។

១៤៧. ក្រោយពេលដែលតំបន់ណាមួយត្រូវបានប្រកាសថាជាតំបន់វិនិច្ឆ័យ អនុក្រឹត្យបញ្ជាក់ពីនីតិវិធីដែលទាមទារឱ្យគ្រប់ចំណែកដីទាំងអស់នៅក្នុងតំបន់ត្រូវតែធ្វើការវិនិច្ឆ័យ។ មាត្រាទី៩ បានគូសបញ្ជាក់ថា: មន្ត្រីកំនត់ព្រំប្រទល់ដីត្រូវតែទទួលការណែនាំដោយអ្នកគ្រប់គ្រង ស៊ើបអង្កេតពិនិត្យពិច័យរាល់គ្រប់ឯកសារដែលមាន ព្រមទាំងភស្តុតាងព័ត៌មានជាលាយល័ក្ខអក្សរ និងផ្ទាល់មាត់ទាំងអស់ ទាក់ទងទៅនឹងសិទ្ធិពាក់ព័ន្ធទៅនឹងចំណែកដីនិមួយៗនៅក្នុងតំបន់វិនិច្ឆ័យ ហើយត្រូវធ្វើការកត់ត្រាសិទ្ធិនៃចំណែកដីនិមួយៗទាំងនេះ"[៩៩] (បន្ថែមការផ្តោតការយកចិត្តទុកដាក់) ។

១៤៨. ក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញថា អនុក្រឹត្យលេខ៤៦ និងនីតិវិធីសម្រាប់ការធ្វើវិនិច្ឆ័យតំបន់ ដែលបានបង្កើតឡើងក្រោមគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីមិនបានដាក់បញ្ចូលល័ក្ខខ័ណ្ឌសម្រាប់ការកាត់ចេញចំណែកនានានៃតំបន់វិនិច្ឆ័យដែលបានប្រកាសឡើយ ក្រោយពេលដំណើរការបានចាប់ផ្តើមជាផ្លូវការ។ ការប្រជែងទាមទារណាមួយចំពោះដីនេះ ត្រូវតែដោះស្រាយនៅក្នុងដំណើរការ ឬ មួយក៏បញ្ជូនទៅគណៈកម្មាការសុរិយោដីជាតិ ឬក៏ទៅតុលាការដើម្បីធ្វើការដោះស្រាយ (យោងមាត្រា១២ និង១៤ នៃអនុក្រឹត្យលេខ ៤៦)[១០០] ។ យោងទៅតាមអ្នកស្នើសុំ

[៩៧] ឯកសារជំនួយស្មារតីអនុវត្តគម្រោង ផ្នែកទី១: ការធ្វើការវិនិច្ឆ័យតំបន់ និងផ្នែកទី២: ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ។

[៩៨] រាជរដ្ឋាភិបាល លេខ ៤៦ អ.ន.ក.បក ចុះថ្ងៃទី៣១ ខែឧសភា២០០២ មាត្រាទី ២ ។

[៩៩] អនុក្រឹត្យលេខ ៤៦ ស្តីពីនីតិវិធីសម្រាប់ការបង្កើតក្រមផែនទីសុរិយោដី និងការចុះបញ្ជីដី ចេញថ្ងៃទី៣១ ខែឧសភា ២០០៩ មាត្រា ៩ ។

[១០០] ក្នុងកំឡុងពេលនៃការធ្វើអង្កេត ឯកសារតែមួយគត់ដែលក្រុមរកឃើញទាក់ទងទៅនឹងការកាត់ចេញពីតំបន់វិនិច្ឆ័យ ទាក់ទងទៅនឹងសង្កាត់ទន្លេ បាសាក់ ចេញថ្ងៃទី៦ តុលា ២០០៩ ។ ឯកសារនេះ គឺជាឯកសារពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទៅប្រធានគណៈកម្មាការរដ្ឋបាល ក្រុងភ្នំពេញ ដែលបញ្ជាក់ពីការកាត់ចេញតំបន់ចំនួនប្រាំពីរតំបន់ពីការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិដីលក្ខណៈជាប្រព័ន្ធ។ មូលហេតុសំខាន់នៃការកាត់ចេញ តំបន់ទាំងនេះ គឺលក្ខណៈស្មុគ្រស្មាញសម្រាប់ដំណើរការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលក្ខណៈជាប្រព័ន្ធ។ កំណត់សំគាល់បានគូសបញ្ជាក់ថា នៅតំបន់ខ្លះ ប្រជាពលរដ្ឋបានមកចាប់យកដី ហើយសង់លំនៅដ្ឋានបណ្តោះអាសន្ននៅលើដីរដ្ឋ (ក្រសួងកសិកម្ម តំបន់ចំការមន) ហើយនៅកន្លែងខ្លះទៀត ប្រជាពលរដ្ឋសង់លំនៅដ្ឋានបណ្តោះអាសន្ននៅលើដីវត្តអារាម្យ ហើយនៅកន្លែងខ្លះទៀតពលរដ្ឋចូលមកចាប់យកដី ហើយរស់នៅជាន់លើ និងជាន់ ក្រោម (អាគារ) ។ ទាក់ទងទៅនឹង

ដែលបានសម្អាតសន់ដោយក្រុម ការទាមទារទ្រព្យសម្បត្តិពីអ្នករស់នៅតំបន់បឹងកក់ មិនដែលបានទទួលការគិតគូរពិចារណាឡើយ ។ បញ្ហានេះក៏បានដឹងដោយអ្នកគ្រប់គ្រងផងដែរ[១០១] ។

- **វិធីសាស្ត្រគម្រោងចំពោះដីដែលមានទំនាស់**

១៤៩. មានសេចក្តីសំអាងពីរនៅក្នុងឯកសារវិនិច្ឆ័យគម្រោង ចំពោះស្ថានភាព ដែលមិនអាចចេញប័ណ្ណសំគាល់កម្មសិទ្ធិដីបាននៅក្រោមគម្រោង។ សេចក្តីសំអាងទីមួយ (ពិភាក្សានៅទីនេះ)ពាក់ព័ន្ធទៅនឹងទំនាស់ដីធ្លី ហើយសេចក្តីសំអាង ទីពីរ (ពិភាក្សានៅជំពូកបន្ទាប់) ទាក់ទងទៅនឹង ការតាំងទីលំនៅមិនស្របច្បាប់ ។

១៥០. យោងតាមឯកសារវិនិច្ឆ័យគម្រោង បញ្ហានៃការកើនឡើងនូវទំនាស់លើបញ្ហាដីគឺជាបញ្ហាគន្លឹះដែលកើតឡើង នៅខណៈពេលនៃការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រសម្រាប់គម្រោង។ មានមូលហេតុមួយចំនួន "មូលហេតុចម្បងគឺភាពមិនច្បាស់លាស់លើព្រំប្រទល់ដីនៅ ក្រោមការត្រួតពិនិត្យរបស់អង្គភាពរដ្ឋ ឬបុគ្គលឯកជនខុសៗគ្នា"[១០២] ។ ឯកសារវិនិច្ឆ័យគម្រោងបកស្រាយថា ដីកំពុងត្រូវបានកាន់កាប់នៅក្នុងដៃអ្នកមានឥទ្ធិពល និងអ្នកមានអំណាច ឬអង្គភាព និងអ្នកដែលមានលទ្ធភាពចាយថវិកាក្រៅផ្លូវការ ជាពិសេសនៅក្នុងតំបន់ដែលមានសក្តានុពលទេសចរណ៍ ការកាប់ឈើ ឧស្សាហកម្ម ឬការអភិវឌ្ឍទីក្រុង"[១០៣] ។ នៅពេលពិពណ៌នាពី "ជម្រើសយុទ្ធសាស្ត្រ" ដែលបញ្ជាក់ពីការរៀបចំគម្រោងដែលបានលើកឡើងដោយឯកសារវិនិច្ឆ័យគម្រោង *"ការអនុវត្តជាដំណាក់បន្តបន្ទាប់"* (គម្រោងបានប្រមើលមើលថាក្នុងមួយដំណាក់កាលៗត្រូវមានរយៈពេល៥ឆ្នាំ សម្រាប់កម្មវិធីជាតិរយៈពេល១០-១៥ឆ្នាំ) "ការបង់ថវិកាសម្រាប់ការចេញប័ណ្ណសំគាល់កម្មសិទ្ធ" និង "ការគាំទ្រអង្គការមិនមែន រដ្ឋាភិបាលដើម្បីអនុវត្តសកម្មភាពទាក់ទងទៅនឹងការចូលរួមពីសហគមន៍"[១០៤] ។

១៥១. ក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញថា មិនមានសេចក្តីបញ្ជាក់នៅក្នុងផ្នែកនៃឯកសារវិនិច្ឆ័យគម្រោង ឬ DCA នេះទេ នៅក្នុងការសម្រេចជាយុទ្ធសាស្ត្រ ដើម្បីជៀសវាងពីទំនាស់ដីធ្លី ។ ផ្ទុយទៅវិញ ក្រុមអធិការកិច្ចបានអានសេចក្តីផ្តើម របស់ឯកសារវិនិច្ឆ័យគម្រោង ដើម្បីផ្តោតការយកចិត្តទុកដាក់លើសេចក្តីត្រូវការក្នុងការកាត់បន្ថយកម្រិតនៃទំនាស់លើបញ្ហាដីធ្លីតាមរយៈដំណើរការធ្វើវិនិច្ឆ័យតំបន់ និងការដោះស្រាយជម្លោះ។ ក្រុមអធិការកិច្ចក៏បានកត់សំគាល់ឃើញ ផងដែរថា នៅក្នុងឯកសារវិនិច្ឆ័យគម្រោង, DCA ឬក៏ឯកសារផ្សេងៗទៀត មិនមានការឱ្យនិយមន័យពន្យល់ពីទំនាស់ ដីធ្លីឡើយ។

១៥២. ផ្នែកស្តីពី "លទ្ធភាពដែលនាំឱ្យមានទិដ្ឋភាពវាទប្បដិវាទ" នៃឯកសារវិនិច្ឆ័យគម្រោងបានគូសបញ្ជាក់ថា: *ការចាត់ចំណាត់ថ្នាក់ដី និងការកំនត់ព្រំប្រទល់រវាងដែនសាធារណៈ និងឯកជន ព្រមទាំងសម្រាប់ដីដែលស្ថិតនៅក្នុងដែន*

---

(តំបន់ពីរក្នុងចំនោមតំបន់ទាំងនោះ) មានការជូនដំណឹងជាលាយល័ក្ខអក្សរ ដោយរដ្ឋាភិបាលអនុញ្ញាតិឱ្យក្រុម ហ៊ុនទិញដីទៅតាមតម្លៃដែលបានព្រមព្រាងគ្នា ។

[១០១] ការឆ្លើយតបពីអ្នកគ្រប់គ្រង ទំព័រ១៩ ។

[១០២] PAD ទំព័រទី ៥ ។

[១០៣] PAD ទំព័រទី ៥ ។

[១០៤] PAD ទំព័រទី ៨ ។

*សាធារណៈតំបន់ដែលស្ថិតនៅក្រោមការត្រួតត្រារបស់អង្គភាពរដ្ឋផ្សេងៗគ្នា ជាទូទៅមានការលំបាក ហើយបង្កើនឱ្យមាន វិវាទនៅក្នុងរយៈពេលខ្លី ។* ***គម្រោងនឹងមិនចេញប័ណ្ណសំគាល់កម្មសិទ្ធិដី នៅក្នុងតំបន់ណាដែលមានទំនាស់ឡើយ រហូតដល់ ពេលដែលមានការឯកភាពទៅលើល័ក្ខខណ្ឌរបស់ដីនេះ ។*** *គម្រោងនឹងគាំទ្រដល់ដំណើរការពិគ្រោះយោបល់សាធារណៈជាប្រព័ន្ធ ដើម្បីជួយជ្រោមជ្រែងឱ្យមានការព្រមព្រៀងគ្នាសម្រាប់ការពិភាក្សា និងធានាឱ្យមានការបន្ត ពិភាក្សា និងពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល។ មានការរំពឹងទុកផងដែរថា ដីមួយចំនួន ដែលបច្ចុប្បន្នស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋ (ប្រហែល៨០ភាគរយនៃផ្ទៃដីសរុប) និងប្តូរទៅជាដែនឯកជន។ ការធ្វើបែបនេះនឹងដោះលែងធនធានរដ្ឋឱ្យមានការគ្រប់គ្រងដីប្រសើរជាង ដែលបច្ចុប្បន្នកំពុងបន្តនៅក្រោមការត្រួតត្រារបស់រដ្ឋ*[១០៥] *(ការគូស បញ្ជាក់បន្ថែម)* ។

១៥៣. ទោះបីជាសេចក្តីថ្លែងការនៅក្នុងឯកសារវិនិច្ឆ័យគម្រោង មិនមានភាពច្បាស់លាស់ក៏ដោយ ប៉ុន្តែវាហាក់បីដូចជាមានលក្ខណៈស្របគ្នាជាមួយនឹងការរៀបចំគម្រោង និងវិធីសាស្ត្រចំពោះទំនាស់ដីធ្លី ហើយជាការពិត ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិដីនៅក្រោមការគាំទ្ររបស់គម្រោង គឺអាស្រ័យទៅលើភាពជោគជ័យនៃការដោះស្រាយទំនាស់។ ការពិចារណាទៅលើដំណើរការកំណត់ព្រំប្រទល់រវាងដីសាធារណៈ និងឯកជន ជានិច្ចកាលមិនបានប្រព្រឹត្តទៅដោយរលូននោះទេ គម្រោងបានប្រមើលមើលពីតម្រូវការឱ្យមានដំណើរការពិគ្រោះយោបល់ជាសាធារណៈជាប្រព័ន្ធផងដែរ។ គម្រោង ដូចដែលបានកត់សំគាល់នៅក្នុងកថាខ័ណ្ឌខាងលើរំពឹងថា ដំណើរការនេះនឹងជួយសម្រួលឱ្យមានការព្រមព្រៀងរួមគ្នាជាធ្លុងមួយក្នុងការធ្វើសេចក្តីសម្រេចចិត្ត ព្រមទាំងការធានាឱ្យមានការបន្តពិភាក្សា និងពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ក៏ដូចជាការដាក់បញ្ចូលគោលដៅពង្រឹងយន្តការសម្រាប់ការដោះស្រាយទំនាស់ចូល ទៅក្នុងផែនការសមាភាគផងដែរ (សមាសភាគទី៤)។ ជាងនេះទៅទៀត គម្រោងក៏ដាក់បញ្ចូលការគាំទ្រដល់ការធ្វើចំណាត់ថ្នាក់ និងការកំណត់ព្រំប្រទល់រវាងដែនសាធារណៈ និងឯកជនព្រមទាំងការបង្កើតសមត្ថភាពសម្រាប់ការគ្រប់គ្រងដីនៅក្នុងផែនការសមាសភាគផងដែរ (សមាសភាគទី៥)។ អ្នកគ្រប់គ្រងធនាគារពិភពលោកមួយចំនួន ក៏បានគូសបញ្ជាក់ប្រាប់ដល់ក្រុមផងដែរថា ភាសារដែលបានសរសេរនៅក្នុងឯកសារវិនិច្ឆ័យគម្រោង មិនមានបំណងផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការដកចេញនូវតំបន់ដែលមានទំនាស់ ពីការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិដីរបស់គម្រោងនោះទេ។ តាមពិត ការរៀបចំគម្រោងជាទូទៅ និងដំណើរការវិនិច្ឆ័យតំបន់ដែលមានស្រាប់បានឆ្លុះបញ្ចាំងនូវទស្សនៈផ្ទុយគ្នា ។

១៥៤. ទោះជាយ៉ាងណាក៏ដោយ ការបកស្រាយកថាខណ្ឌសំខាន់ខាងលើនៅក្នុងឯកសារវិនិច្ឆ័យគម្រោង ជាពិសេសសេចក្តីថ្លែងការទាក់ទងទៅនឹងដីដែលមានទំនាស់ ហាក់បីដូចជាមានការផ្លាស់ប្តូរក្នុងពេលអនុវត្តគម្រោង។ បច្ចុប្បន្ន ការបកស្រាយនេះបានយកមកពង្រឹងអនុវត្តបន្ថែម ដើម្បីសម្រេចគោលដៅរបស់គម្រោងក្នុងការផ្តល់ប័ណ្ណសំគាល់កម្មសិទ្ធិឱ្យបានមួយលានប័ណ្ណនោះ គឺមានន័យយ៉ាងសាមញ្ញថា គម្រោងនឹងមិនធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិដី នៅតំបន់ដែលទំនងជាមានទំនាស់កើតឡើងឡើយ។ ទស្សនៈនេះ ហាក់បីដូចជាមានការយល់ដឹងយ៉ាងទូលំទូលាយដូចគ្នាទាំងរដ្ឋាភិបាល ដៃគូអភិវឌ្ឍ បុគ្គលិកគម្រោង និងទីប្រឹក្សា។ នៅក្នុងអង្គប្រជុំជាមួយនឹងក្រុមអធិការកិច្ច មានអ្នកមួយចំនួនបាន

[១០៥] PAD ទំព័រទី ២៤ ។

បញ្ជាក់ថា "ការធ្វើរបៀបនេះវាហាក់បីដូចជាការបេះផ្លែឈើដែលនៅទាប១ជិតដៃតែប៉ុណ្ណោះ" ។ ទោះជាយ៉ាងណាក៏ដោយ **ក្រុមបានកត់សំគាល់ឃើញថា មិនមានការកំណត់បញ្ជាក់នៅក្នុងឯកសារគម្រោងគ្រឹះ ស្តីពីគោលការណ៍សម្រាប់ការកំណត់តំបន់ដែលអាចមានទំនាស់ ឬនិតិវិធីសម្រាប់ការកាត់ចេញតំបន់ទាំងនេះពីការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិ ដីលក្ខណៈជាប្រព័ន្ធឡើយ ។**

- វិធីសាស្រ្តគម្រោងសម្រាប់ដោះស្រាយការតាំងលំនៅស្ថានមិនស្របច្បាប់

១៥៥. ចំណុចយោងទីពីរចំពោះស្ថានភាពដែលមិនអាចចេញកម្មសិទ្ធដីធ្លី គឺត្រូវបានកំណត់នៅក្នុងប្រយោគដែលមានចំណងជើង" អ្នកតាំងលំនៅស្ថានក្រៅផ្លូវច្បាប់" ដែលបានកំណត់អំពីវិសាស្រ្តគម្រោនៅក្នុងស្ថានភាពនៃទីកន្លែងដែលមាន" អ្នកតាំងទីលំនៅក្រៅផ្លូវច្បាប់ រួមបញ្ចូលទាំងអ្នករស់នៅមិនស្របតាមផ្លូវច្បាប់"។ នៅក្នុងស្ថានភាពបែបនេះ យោងទៅតាមឯកសារវិនិច្ឆ័យគម្រោងគម្រោង នឹងមិនចេញកម្មសិទ្ធិឱ្យចំពោះទីកន្លែងណាដែលមិនទាន់មានកិច្ចព្រមព្រៀងបែងចែកដីឱ្យទៅអ្នកដែលរស់នៅមិនស្របច្បាប់ ឬតាមរយៈកម្មវិធីការចែករំលែងដី ឬបែងចែកដីឡើងវិញ"[១០៦] ។ ការ ឆ្លើយតបរបស់គណៈគ្រប់គ្រងបានឆ្លើយតបថា ឯកសារវិនិច្ឆ័យគម្រោងបានធ្វើឱ្យមានភាពច្បាស់លាស់ហើយថាគម្រោង ដែលគាំទ្រដល់ដំណើរការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិ នឹងមិនចេញប័ណ្ណសម្គាល់កម្មសិទ្ធិឱ្យទៅអ្នកតាំងលំនៅ ឬអ្នករស់ នៅមិនស្របច្បាប់នៅលើដីរដ្ឋ[១០៧] ។

១៥៦. ក្រុមអធិការកិច្ចបានកត់សម្គាល់ថា សេចក្ដីសម្រេចចិត្តមិនគាំទ្រដល់និយតកម្មនៃការតាំងទីលំនៅស្ថានមិនស្របច្បាប់ក្រោមក្របខ័ណ្ឌនៃគម្រោង មិនត្រូវបានធ្វើឱ្យបានសម្រេចឡើយ នៅក្នុងបរិបទនៃឯកសារវិនិច្ឆ័យគម្រោង ឬកិច្ចព្រមព្រៀងឥណទានគម្រោង រួមជាមួយនឹងការកំណត់និយមន័យនៃពាក្យ "អ្នកទាំងទីលំនៅមិនស្របច្បាប់" ការតាំងទីលំនៅមិនស្របច្បាប់ ឬ"អ្នករស់នៅមិនស្របច្បាប់"។ ពាក្យទាំងនេះ ក៏ហាក់ដូចជាមិនឱ្យមានកំណត់និយមន័យជាផ្លូវច្បាប់ និងគោលនយោបាយរបស់កម្ពុជាផងដែរ។ សេចក្ដីព្រាងគោលយោបាយជាតិស្ដីពីការរៀបចំផ្ទះសម្បែង បានធ្វើឱ្យមានតម្រូវការសម្រាប់ការបង្កើត "នីតិវិធីមួយសម្រាប់ដោះស្រាយបញ្ហានៃការតាំងទីលំនៅស្ថានបណ្ដោះអាសន្ននៅលើដីដែលមានការកាន់កាប់ដោយមិនស្របច្បាប់នៅក្នុងតំបន់ទីក្រុង និងទីប្រជុំជន"។ ក្រុមអធិការកិច្ចបានយល់ឃើញថា ចំពោះពាក្យទាំងនេះ នៅក្នុងបរិបទនៃឯកសារវិនិច្ឆ័យគម្រោង គឺសំដៅទៅលើប្រជាពលរដ្ឋដែលកំពុងកាន់កាប់ដីសាធារណៈរបស់រដ្ឋ ជាអ្នកដែលមិនមានលក្ខណៈសម្បត្តិ សម្រាប់ការចេញឱ្យនូវប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លីក្រោមក្របខ័ណ្ឌនៃច្បាប់ដីធ្លីឆ្នាំ២០០១។ និយាយម្យ៉ាងទៀត គម្រោងក៏មិនត្រូវបានកំណត់ថាជាកម្មវិធីមួយសម្រាប់ធ្វើនិយតកម្ម (ធ្វើឱ្យមានលក្ខណៈស្របច្បាប់)នៃការតាំងទីលំនៅស្ថាននៅលើដីសាធារណៈរបស់រដ្ឋឡើយ។ កម្មសិទ្ធិដីធ្លីនៅក្នុងតំបន់បែបនេះ អាចកើតមានឡើង បើសិនជារដ្ឋាភិបាលបានធ្វើការជ្រើសរើសពីដំបូងក្នុងការផ្តល់ ដីដល់អ្នកតាំងទីលំនៅមិនស្របច្បាប់ ហើយបានចាត់វិធានការជាជំហាន១នានាក្នុងការធ្វើឱ្យមានភាពស្របច្បាប់នៃការកាន់កាប់របស់ពួកគេ។ ម្យ៉ាងវិញទៀត ក្រុមអធិការកិច្ចក៏បានយល់ឃើញថាគោលបំណងជាចម្បងរបស់គម្រោងគឺ ក្នុងខណៈដែលអវត្តមាននៃការធ្វើចំណាត់ថ្នាក់ដីធ្លីច្បាស់លាស់ គម្រោងនឹងកំណត់ភាពស្របច្បាប់នៃបណ្ដឹងតវ៉ានានាអំពី

---

[១០៦] ឯកសារវិនិច្ឆ័យគម្រោងទំព័រទី២៤

[១០៧] ឯកសារវិនិច្ឆ័យគម្រោងទំព័រទី២២

ដីធ្លី រួមបញ្ចូលទាំងប្រជាពលរដ្ឋ ដែលទំនងជាអ្នកកាន់កាប់ដីធ្លីដោយមិនស្របច្បាប់ តាមរយៈដំណើរការវិនិច្ឆ័យមួយ។

១៥៧. ទោះបីជាគម្រោងមិនបានគិតគូរអំពីការចេញប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លីឱ្យអ្នកតាំងទីលំនៅដោយមិនស្របច្បាប់ក៏ដោយ ក៏ក្រុមអធិការកិច្ចយល់ឃើញថាបញ្ហាទាំងនេះមិនមែនមានន័យថា ជាការដាក់កម្រិតកំណត់សម្រាប់អ្នកតាំងទីលំនៅដោយមិនស្របច្បាប់ឡើយ តែវានឹងធ្វើការមានការវិនិច្ឆ័យទៅលើបណ្តឹងតវ៉ារបស់ពួកគេ។ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា ការបំផ្លិចបំផ្លាញឯកសារកំណត់ត្រាដីធ្លីនានានៅក្នុងសម័យខ្មែរក្រហម និងការខ្វះខាតប្រព័ន្ធមុខងារគ្រប់គ្រងដីធ្លីនៅក្នុងបណ្តាឆ្នាំដែលមានភាពច្របូកច្របល់នៃការចូលកាន់កាប់ឡើងវិញនៅភ្នំពេញ បានធ្វើឱ្យនាយកដ្ឋាន និងទីភ្នាក់ងាររដ្ឋនានា ព្រមទាំងបុគ្គលនានាខ្វះនូវកម្មសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់។ ដោយសារមូលហេតុនេះ គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីត្រូវបានរៀបចំបង្កើតឡើង ដើម្បីគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងនូវការធ្វើ ចំណាត់ថ្នាក់ការរៀបចំផែនទីដីរដ្ឋ ដើម្បីពង្រឹងដល់សុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងទីផ្សារដីធ្លី ព្រមទាំងការពារកុំឱ្យមានជម្លោះដីធ្លី និងដោះស្រាយជម្លោះដីធ្លី។

១៥៨. ក្រុមអធិការកិច្ចបានកត់សម្គាល់ឃើញនូវចំណុចយោងនៅក្នុងឯកសារវិនិច្ឆ័យគម្រោងនៃកម្មវិធី UNCHS/UNDP និងដៃគូអភិវឌ្ឍន៍ដទៃទៀតក្នុងការផ្តល់សុវត្ថិភាពនៃការកាន់កាប់ដីធ្លីចំពោះការតាំងទីលំនៅដោយមិនស្របច្បាប់។ ចំណុចយោងនេះទទួលស្គាល់ថាទាំងធនាគារពិភពលោក និងទាំងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនមានភាពមានប្រៀបនៃការដោះស្រាយបញ្ហាជាមួយអ្នកតាំងទីលំនៅមិនស្របច្បាប់ និងអ្នករស់នៅមិនស្របច្បាប់ឡើយ។ ដូចនេះ វាជាការប្រសើរសម្រាប់គម្រោងផ្តល់ការគាំទ្រដល់ក្រុមអភិវឌ្ឍន៍ដែលកំពុងធ្វើការក្នុងកិច្ចការនេះ[១០៨]។ ឧបសម្ព័ន្ធ ទី២នៃឯកសារវិនិច្ឆ័យគម្រោង ដ៏បានសរសេរផងដែរថា បន្ទាប់ពីការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រនៅទីប្រជុំជន[១០៩] បានព្រមព្រៀងថា គម្រោងនឹងធ្វើការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយក្រុមអភិវឌ្ឍន៍នានា ដែលធ្វើការនៅក្នុងកម្មវិធីការតាំងទីលំនៅស្ថានដោយមិនស្របច្បាប់។ ទោះបីសេចក្តីថ្លែងការនេះឯកសារវិនច្ឆ័យគម្រោង ឱ្យមានការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយកម្មវិធី UNCHS/UNDP ក្នុងការធ្វើការដោះស្រាយជាមួយអ្នកតាំងទីលំនៅស្ថានដោយមិនស្របច្បាប់ និងអ្នករស់នៅដោយមិនស្របច្បាប់ក៏ដោយ ក៏ក្រុមអធិការកិច្ចមិនអាចទទួលបាននូវភស្តុតាងណាមួយ នៅក្នុងអំឡុងពេលនៃការចុះស៊ើបអង្កេត ដែលបង្ហាញថាមានការសម្របសម្រួល និងគាំទ្រត្រូវបានផ្តល់ឱ្យដោយគម្រោងទៅកម្មវិធី UNCHS/ UNDP មុនពេលដែលគម្រោងនេះត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០០៤ ហើយក៏មិនមានភស្តុតាងដែល ត្រូវបានទទួលអំពីការផ្លាស់ប្តូរវិធីសាស្ត្រសម្រាប់ដោះស្រាយបញ្ហាការតាំងទីលំនៅដោយមិនស្របច្បាប់ផងដែរ បន្ទាប់ពីពេលនេះមក។

- **វិធីសាស្ត្រគម្រោងចំពោះការគ្រប់គ្រងដីរដ្ឋ**

១៥៩. គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីបានដាក់បញ្ចូលការគ្រប់គ្រងដីរដ្ឋជាសមាសភាគទី៥របស់គម្រោង។ សមាសភាគនេះបានគិតគូរអំពីការរៀបចំនីតិវិធីដើម្បីកំណត់ចំណាត់ថ្នាក់ដីធ្លី រៀបចំផែនទីតាមរូបថតពីលើ ផែនទីរូបភាពដែលអាច

[១០៨] ឯកសារវិនិច្ឆ័យគម្រោង ទំព័រទី២០

[១០៩] ឯកសារវិនិច្ឆ័យគម្រោង ឧបសម្ព័ន្ធទី២ ទំព័រទី៨៧

បញ្ហាបាន និងការរៀបចំសម្រាប់ខេត្តគោលដៅរបស់គម្រោងនីមួយៗនូវផែនទីចំណាត់ថ្នាក់ដីធ្លី ដែលបង្ហាញអំពីព្រំប្រទល់នៃព្រៃឈើ តំបន់ការពារ និងដីធ្លីដែលស្ថិតនៅក្រោមការប្រើប្រាស់របស់ឯកជន សាធារណៈ និងសម្បទាន។ ដោយហេតុថា នៅកម្ពុជាមានដីធ្លីប្រមាណ៨០%ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ដោយមិនបានកំណត់អំពីព្រំប្រទល់រវាងកម្មសិទ្ធិដីធ្លីសាធារណៈ និងឯកជន ដូច្នេះការគ្រប់គ្រងដីរដ្ឋគឺជាសមាសភាគដ៏សំខាន់នៃគម្រោងបែងចែក និងគ្រប់គ្រងដីធ្លី។ ទោះជាយ៉ាងណាក៏ដោយ ក៏មានការរីកចម្រើនតិចតួចបំផុតនៅក្នុងការអនុវត្តសមាសភាគនេះ។ ការអនុវត្តសមាសភាគនេះ ត្រូវបានទទួលការវាយតម្លៃថាមិនមានការពេញចិត្ត ហើយសកម្មភាពដែលមិនបានអនុវត្តជាច្រើនត្រូវបានស្នើសុំឱ្យលុបចោលនៅក្នុងខែមករា ឆ្នាំ២០០៩[១១០]។

១៦០. នៅក្នុងការឆ្លើយតបរបស់ខ្លួន ថ្នាក់គ្រប់គ្រងបានទទួលស្គាល់ថា សមាសភាគនេះត្រូវបានដាក់បន្ថែមទៅក្នុងគម្រោងនៅក្នុងដំណាក់ការចុងក្រោយនៃការរៀបចំនៃគម្រោង ហើយខ្វះការរៀបចំលម្អិតបើប្រៀបធៀបទៅនឹងសមាសភាគផ្សេងទៀតរបស់គម្រោង។ ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងបានកត់សម្គាល់ថា " ចំពោះការរៀបចំគម្រោង កាលណាមើលស្រាលលើបញ្ហា និងភាពមានហានិភ័យរបស់វា នោះនឹងធ្វើឱ្យមានការគិតគូរមិនត្រូវចំពោះភាពស្មុគស្មាញ និងចរិកលក្ខណៈនយោបាយនៃការគ្រប់គ្រងដីរដ្ឋ" ។ ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងក៏បានបន្ថែមថា " ការខ្វះផែនការលម្អិតសម្រាប់ការសម្របសម្រួលអន្តរក្រសួង និងអន្តរភ្នាក់ងារ បានធ្វើឱ្យមាននូវចរិកលក្ខណៈពហុមុខនៃរបៀបវារៈគ្រប់គ្រងដីរដ្ឋ ព្រមទាំងធ្វើឱ្យភាពសាំញ៉ាំផ្នែកបច្ចេកទេស និងផ្នែកនយោបាយក្លាយទៅជាគុណវិបត្តិរបស់គម្រោង[១១១]។

១៦១. បញ្ហាអភិបាលកិច្ច និងការលំបាកក្នុងការធ្វើឱ្យមានការឯកភាពគ្នាក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត លើដំណើរការនៃការធ្វើចំណាត់ថ្នាក់ដីធ្លីត្រូវបានកំណត់ថាជាហានិភ័យចម្បងនៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ ដូចការកត់សម្គាល់ពីខាងលើនៅក្នុងផ្នែក " ចំណុចនានាដែលនឹងអាចមានបញ្ហាប្រទើសប្រទែងគ្នា " នៃឯកសារវិនិច្ឆ័យគម្រោងបានថ្លែងថា " ដីដែលត្រូវធ្វើចំណាត់ថ្នាក់ និងការកំណត់ព្រំប្រទល់រវាងកម្មសិទ្ធឯកជន និងសាធារណៈ និងសម្រាប់ដីស្ថិតនៅក្នុងកម្មសិទ្ធិសាធារណៈ តំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃអង្គភាពនានារបស់រដ្ឋបាលភិបាល ជារឿយៗនឹងមានការលំបាក "[១១២] ។ ឯកសារវិនិច្ឆ័យគម្រោងបានផ្តល់យោបល់ថា ហានិភ័យនៅក្នុងការមិនមានការឯកភាពគ្នាក្នុងអំឡុងពេលនៃការធ្វើចំណាត់ថ្នាក់ដី នឹងទទួលបានជោគជ័យដោយការគាំទ្រដល់កិច្ចដំណើរការប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាគោលនយោបាយដី ក្នុងការកសាងការឯកភាពគ្នាក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាល។ ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងបានកត់សម្គាល់ថា " ការវិភាគកាន់តែលម្អិតលើបរិបទសេដ្ឋកិច្ចនយោបាយ នឹងអាចកំណត់បាននូវទិដ្ឋភាពដែលមានលក្ខណៈសុទិដ្ឋិនិយម[១១៣] ។

១៦២. បេសកកម្មពិនិត្យឡើងវិញបានកត់សម្គាល់ឃើញអំពីអវត្តមាននៃការរៀបចំផែនទីផ្លូវការនៃដីរដ្ឋ និងបានថ្លែងថា "

[១១០] អនុស្សារណៈ (បេសកកម្មទី១១ ធ្វើនៅខែមករា ឆ្នាំ២០០៩) ទំព័រ១២ និង១២

[១១១] MR ប្រយោគទី៦៨ ទំព័រ៣១

[១១២] ឯកសារវិនិច្ឆ័យគម្រោង ទំព័រទី២៤

[១១៣] MR ប្រយោគទី៣៤ ទំព័រ១២

នេះគឺជាប្រភពនៃបញ្ហាចំពោះអ្នកទាំងឡាយណាដែលស្ថិតនៅក្រោមការគំរាមកំហែងនៃការបណ្តេញចេញ ពីព្រោះអវត្តមាននៃផែនទីនេះ អាជ្ញាធរពាក់ព័ន្ធនានារបស់ក្រុងអាចដកកម្មសិទ្ធិចេញពីដីចំណែកណាមួយដែលបានធ្វើការអង្កេត និងស្នើសុំសម្រាប់ការវិនិច្ឆ័យដោយក្រុមចុះបញ្ជីដីធ្លី ហេតុដូច្នេះហើយ កម្មសិទ្ធិកាន់កាប់ដីធ្លីនឹងស្ថិតនៅក្រោមឈ្មោះដីរដ្ឋ"[១១៤] ។ ក្រុមបេសកកម្មពិនិត្យឡើងវិញបានកំណត់ឃើញអំពីអវត្តមាននៃការរៀបចំផែនទីរដ្ឋនេះថា ជាការខ្វះខាតដ៏សំខាន់មួយសម្រាប់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ក្នុងការធ្វើឱ្យបានជោគជ័យ និងជួយក្នុងការដោះស្រាយជម្លោះដីធ្លី និងសុវត្ថិភាពដីធ្លី ។

១៦៣. ក្រុមវាយតម្លៃបានយល់ស្របជាមួយការរកឃើញរបស់បេសកកម្មពិនិត្យឡើងវិញ ដែលបានកត់សម្គាល់ឃើញថាការខ្វះការរៀបចំផែនទីដីរដ្ឋបានចូលរួមចំណែកធ្វើឱ្យមានការលំបាកក្នុងការកំណត់ដីរដ្ឋ (សាធារណៈ និងឯកជន) ដោយមិនអនុវត្តតាមកិច្ចដំណើរការវិនិច្ឆ័យរបស់គម្រោងបែងចែក និងគ្រប់គ្រងដីធ្លី" ។

## ៣. របកគំហើញចំពោះការអនុវត្តតាមគោលការណ៍

១៦៤. ការវិភាគរបស់អធិការកិច្ច បានផ្តោតយកចិត្តទុកដាក់ទៅលើបញ្ហាថាតើការគ្រប់គ្រងរបស់ធនាគារបានអនុវត្តតាមនីតិវិធី និងគោលនយោបាយប្រតិបត្តិការរបស់ធនាគារពាក់ព័ន្ធនឹងគម្រោងនេះ ហើយបើសិនជាមិនបានអនុវត្តតាមថាតើការមិនអនុវត្តតាមបែបនេះបានចូលរួមចំណែកក្នុងការនិយាយចោទប្រកាន់មិនល្អនៅក្នុងសំណើយ៉ាងដូចម្តេច ។ ការវិភាគត្រូវបានបែងចែកជាពីរចំណុចនៃការចូលរួមពាក់ព័ន្ធរបស់ការគ្រប់គ្រងគម្រោង រួមមានការរៀបចំ ការវាយតម្លៃ និងការត្រួតពិនិត្យមើល ។

១៦៥. ការរៀបចំនិងការវាយតម្លៃ : ដូចបានកត់សម្គាល់របស់ថ្នាក់គ្រប់គ្រងធនាគារ គម្រោងរៀបចំដែនដី និង និងរដ្ឋបាលដីធ្លី បើតាមការរៀបចំគម្រោង គឺវាមានលក្ខណៈស្មុគស្មាញ និងមានមហិច្ឆិតាធំក្នុងការអនុវត្ត ដែលមានបំណងដោះស្រាយពហុបញ្ហាជាបន្តបន្ទាប់គ្នានៅក្នុងការគ្រប់គ្រង និងចាត់ចែងដីធ្លី បន្ទាប់ពីមានការបំផ្លិចបំផ្លាញនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ គោលដៅរួមរបស់គម្រោង គឺកាត់បន្ថយភាពក្រីក្រ លើកកម្ពស់សុវត្ថិភាពសង្គម និងជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ។ គោលបំណងជាក់លាក់របស់គម្រោង គឺកែលំអសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លី និងលើកកម្ពស់កិច្ចអភិវឌ្ឍន៍នៃទីផ្សារដីធ្លីប្រកបដោយភាពស័ក្តិសិទ្ធ ។ ដើម្បីធ្វើឱ្យសម្រេចបាននូវគោលបំណងទាំងនេះ គម្រោងបានដាក់បញ្ចូលសមាសភាគរៀបចំបង្កើតគោលនយោបាយដី និងក្របខ័ណ្ឌគតិយុត្ត គាំទ្រដល់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន រៀនចំបង្កើតប្រព័ន្ធចុះបញ្ជីដីធ្លី ពង្រឹងយន្តការដោះស្រាយទំនាស់ ធ្វើចំណាត់ថ្នាក់ដីធ្លីសម្រាប់ការគ្រប់គ្រងការប្រើប្រាស់ដីផ្សេងៗគ្នា និងអនុវត្តការផ្តល់កម្មសិទ្ធិដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ[១១៥] ។

១៦៦. OMS ២.២០ ស្តីពីការវាយតម្លៃគម្រោង ប្រយោគទី១៧ បានកំណត់ថា " ការវាយតម្លៃ ជាធម្មតាត្រូវដាក់បញ្ចូលនូវការសិក្សាលើភាពដែលអាចដឹងបាននៃលទ្ធភាពដែលអាចអនុវត្តបានរបស់គម្រោង ដើម្បីធ្វើការផ្លាស់ប្តូរនូវប៉ារ៉ាម៉ែត្ររបស់គម្រោង ជាមួយនឹងការការវិនិច្ឆ័យស្តីពីលទ្ធភាពនៃការប្រែប្រួលដែលអាចកើតឡើងចេញពីប៉ារ៉ាម៉ែត្រ

[១១៤] បេសកកម្មត្រួតពិនិ ត្យដើម្បីពង្រឹងឡើងវិញ ឆ្នាំ២០០៩ ប្រយោគទី១៥ ទំព័រទី៦

[១១៥] ឯកសារវិនិច្ឆ័យគម្រោង ទំព័រទី៨

មូលដ្ឋាន" ហើយក៏បានបន្ថែមថា " សម្រាប់គម្រោងដែលមានហានភ័យខ្ពស់ ត្រូវធ្វើចំណាត់ថ្នាក់ហានភ័យតាមរយៈការវិភាគហានភ័យ។ ក្នុងករណីចាំបាច់ ការវាយតម្លៃត្រូវដាក់បញ្ចូលអនុសាសន៍ពាក់ព័ន្ធទៅនឹងវិធានការការពារដែលត្រូវអនុវត្តដើម្បីកាត់បន្ថយហានភ័យ" ។ ខណៈមានការកត់សម្គាល់បែបនេះក៏ដោយ ក៏ការកំណត់វិសាលភាព និងការស៊ីជម្រៅនៃការវិភាគហានភ័យ ជានិច្ចការបង្ហាញ ជាសញ្ញានូវការលំបាក់នៃការវិនិច្ឆ័យ ដូចនេះគណៈកម្មារយល់ឃើញថា ធ្នាក់គ្រប់គ្រងគម្រោងនេះ មិនបានផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការដោះស្រាយហានភ័យនៅក្នុងពេលនៃការរៀបចំគម្រោង។

១៦៧. ការវិភាគហានភ័យដែលមាននៅក្នុងឯកសារវិនិច្ឆ័យគម្រោងបានដាក់ពិន្ទុលើហានភ័យទូទៅថាជា "ហានភ័យខ្ពស់គួរសម"[១១៦]។ ផ្អែកតាមឯកសារវិនិច្ឆ័យគម្រោង ហានភ័យ " ខ្ពស់" ជាហានភ័យ ដែលអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជាមិន អាចកែលំអបាន ដែលអាចជះផលប៉ះពាល់លើលទ្ធភាពរបស់គម្រោងក្នុងការធ្វើសម្រេចបាននូវគោលបំណងរបស់ខ្លួន។ លើសពីនេះ ហានភ័យ " ខ្ពស់គួរសម " គឺជាហានភ័យដែលរដ្ឋាភិបាលខ្វះឆន្ទៈក្នុងការធានាថាយន្តការដោះស្រាយទំនាស់ប្រព្រឹត្តទៅ ប្រកបដោយភាពស័ក្តសិទ្ធ និងយុត្តិធម៌ និងដែលអង្គភាពរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀតមិនអាចមានលទ្ធភាព ធ្វើឱ្យមានភាពឯកភាពគ្នាលើកិច្ចដំណើរការចំណាត់ថ្នាក់ដីធ្លី។

១៦៨. ការសិក្សាវាយតម្លៃផ្នែកសង្គមដែលបានរៀបចំឡើងសម្រាប់គម្រោង បានបង្ហាញថាទំនាស់ដីធ្លីបានកើនឡើង នៅពេលដែលតម្លៃដីធ្លីឡើងថ្លៃ ហើយជាពិសេស គឺនៅក្នុងតំបន់ដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍន៍ ដូចជាដីនៅជិតផ្លូវ ដីនៅជិតទីប្រជុំជន ឬនៅជិតផ្សារ។ ការសិក្សាវាយតម្លៃក៏បន្តកត់សម្គាល់ឃើញថាប្រជាពលរដ្ឋធម្មតា ជួបប្រទះនូវការលំបាក ក្នុងការការពារខ្លួនឯងឱ្យបានជោគជ័យ ជាមួយនឹងភាគីមានអំណាច ដោយប្រើប្រាស់យន្តការដោះស្រាយទំនាស់តាមផ្លូវការ។

១៦៩. ក្នុងទស្សនៈរបស់គណៈកម្មារយល់ឃើញថា ការរៀបចំគម្រោងបានទទួលស្គាល់បញ្ហាប្រឈមទាំងនេះក្នុងលក្ខណៈជាបញ្ហាចម្រុះគ្នាមួយ ដែលពាក់ព័ន្ធទៅនឹងការផ្តល់ប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ ការដោះស្រាយជម្លោះ ការគ្រប់គ្រង និងធ្វើចំណាត់ថ្នាក់ដីរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ក៏ការរៀបចំគម្រោងមិនបានធ្វើការឆ្លុះបញ្ចាំងឱ្យបានគ្រប់គ្រាន់លើហានភ័យនានាដែលអាចកើតមានឡើង។ បញ្ហាជាក់លាក់មួយដែលពាក់ព័ន្ធទៅ នឹងបណ្តឹងតវ៉ា គឺហានភ័យដែលពាក់ព័ន្ធទៅ នឹងបណ្តឹងតវ៉ាដីជាន់គ្នាដែលធ្វើឡើងដោយភ្នាក់ងាររដ្ឋ និងបុគ្គលឯកជន។ ដូចបានកត់សម្គាល់ពីខាងលើ បញ្ហានេះបានកត់សម្គាល់យ៉ាងច្បាស់លាស់នៅក្នុងឯកសារវិនិច្ឆ័យគម្រោង ប៉ុន្តែឯកសារមិនបានកំណត់ឱ្យបានច្បាស់លាស់អំពីកិច្ចដំណើរការសម្រាប់ដោះស្រាយហានភ័យទាំងនេះ។ ផ្ទុយទៅវិញ គណៈកម្មារបានរកឃើញថាការរៀបចំគម្រោងមិនបានបង្ហាញច្បាស់ អំពីអ្វីដែលគម្រោងត្រូវមានយុទ្ធសាស្ត្រ ទាំងសម្រាប់ការកំណត់តំបន់សម្រាប់រៀបចំកម្មសិទ្ធិដីធ្លីជាលក្ខណៈប្រព័ន្ធ (តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យ) និងការដោះស្រាយចម្លោះដីធ្លីរវាងអង្គភាពរដ្ឋ និងបុគ្គលឯកជននៅក្នុងអំឡុងពេលនៃកិច្ចដំណើរការវិនិច្ឆ័យ។

[១១៦] ឯកសារវិនិច្ឆ័យគម្រោង ទំព័រទី២៤

១៧០. បន្ថែមលើសពីនេះទៀត ខ្លឹមសារនៃឯកសារវិនិច្ឆ័យគម្រោងទាក់ទងនឹងដីធ្លីដែលមានទំនាស់[117] មិនបានកំណត់អំពីល័ក្ខខ័ណ្ឌ និងនីតិវិធីដែលតម្រូវឱ្យអនុវត្តតាមឡើយ ដែលជាហេតុនាំឱ្យមានការយល់ឃើញខុសៗគ្នា ក្នុងចំណោមអ្នកពាក់ព័ន្ធនានា នៅក្នុងអំឡុងពេលអនុវត្តគម្រោង។ ជាងនេះទៅទៀត ទោះបីជាគេដឹងថា ព្រំប្រទល់ដីសាធារណៈរបស់រដ្ឋមិនត្រូវបានកំណត់ក៏ដោយ ក៏ការរៀបចំគម្រោងបានដកអ្នកតាំងទីលំនៅមិនស្របច្បាប់ចេញពីបញ្ជីអ្នក ដែលត្រូវទទួលបានប្លង់ដី។ នៅពេលទទួលបានការឯកភាពពីរាជរដ្ឋាភិបាល បញ្ហានានាដែលនៅសេសសល់នឹងត្រូវដោះស្រាយតាមរយៈកម្មវិធី UNCHS (UNHABITAT)។ **គណៈកម្មារបានរកឃើញថា ភាពមានន័យមិនច្បាស់លាស់នៅក្នុងការរៀបចំគម្រោងនេះ គឺជាផ្នែកមួយដែលបង្កឱ្យមានភាពអន្តរាយ ដូចដែលក្រុមអ្នកតវ៉ាទាមទារកំពុងជួបប្រទះនាពេលបច្ចុប្បន្ននេះ។ ហេតុដូច្នេះហើយគណៈកម្មាររកឃើញថា ទោះបីជាហានីភ័យដែលជាប់ពាក់ព័ន្ធជាមួយនឹងគម្រោងត្រូវបានកំណត់បានត្រឹមត្រូវក៏ដោយ ក៏ថ្នាក់គ្រប់គ្រងគម្រោងមិនបានអនុវត្តឱ្យស្របតាមចំណុច ២.២០ នៃ OMS ស្តីអំពីការសិក្សាវាយតម្លៃគម្រោង ដែលបានបញ្ជាក់អំពីការដោះស្រាយហានីភ័យទាំងនេះឡើយ។**

១៧១. **ការត្រួតពិនិត្យ :** ក្នុងអំឡុងឆ្នាំដំបូងៗនៃការអនុវត្តគម្រោង ពីឆ្នាំ២០០២ ដល់ពាក់កណ្តាលឆ្នាំ២០០៥ របាយការណ៍ត្រួតពិនិត្យបានបង្ហាញឱ្យឃើញថា ទោះបីជាការអនុវត្តគម្រោងមានភាពយឺតយ៉ាវ ហើយមានបញ្ហាមួយចំនួនបានកើតមានឡើងទាក់ទងនឹងការអនុវត្តសមាសភាពជាក់លាក់នានារបស់គម្រោង ដូចជាការដោះស្រាយទំនាស់ និងការធ្វើផែនទីដីធ្លីរបស់រដ្ឋជាដើមក៏ដោយ ក៏ការវាយតម្លៃទូទៅឃើញថាគម្រោងនេះទទួលបាននូវការពេញចិត្តផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីពាក់កណ្តាលឆ្នាំ២០០៥មក ការអនុវត្តសមាសភាពនានារបស់គម្រោងដែលតម្រូវឱ្យមានសង្គតិភាពជាមួយគ្នា បែរជាមានភាពមិនប្រក្រតីទៅវិញ។ បន្ទាប់មក ការអនុវត្តគម្រោងត្រូវបានផ្អាកជាបណ្តោះអាសន្នចាប់ពីខែមិថុនា ឆ្នាំ២០០៦ ដល់ខែកុម្ភៈ ឆ្នាំ២០០៧ ដោយសារមានបញ្ហាទាក់ទងនឹងការអនុវត្តកិច្ចសន្យាគម្រោង។ តាមលទ្ធផលនៃ "ការពិនិត្យទូទៅលើស្ថានភាពគម្រោង" (ហៅថា ការពិនិត្យទូទៅ) ដែលជាផ្នែកមួយនៃបេសកកម្មត្រួតពិនិត្យលើកទី៩ (ថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី៨ មិថុនា ឆ្នាំ២០០៧) បានធ្វើការ បញ្ជាក់យ៉ាងច្បាស់អំពីបញ្ហានានាដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោង។

១៧២. ការពិនិត្យទូទៅ បានធ្វើការកត់សម្គាល់ឃើញថា នៅពេលដែលថ្នាក់ដឹកនាំគម្រោងផ្តោតការយកចិត្តទុក ដាក់ខ្លាំងពេកលើចំណុចផ្នែក និងសមាសភាពសំខាន់ៗរបស់គម្រោងដែលបានកំណត់នោះ នឹងនាំឱ្យមានការខ្វះចន្លោះក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើការទទួលយក និងដោះស្រាយបញ្ហាដែលបានកំណត់តាមលំដាប់លំដោយនៅក្នុងអំឡុងពេលអនុវត្តគម្រោង។ ការពិនិត្យទូទៅក៏បានធ្វើការសង្កត់ធ្ងន់លើការអនុវត្តគម្រោងរៀបចំដែនដីនិងរដ្ឋបាលដីធ្លីដែលជាប្រព័ន្ធចម្រុះ និងស្មុគស្មាញមួយ ដែលគ្រប់ផ្នែកទាំងអស់ត្រូវតែ "*ធ្វើឱ្យបានប្រសិទ្ធិភាពខាងប្រតិបត្តិការ ហើយផ្នែកទាំងអស់នោះត្រូវតែជាផ្នែកសំខាន់* "[118]។ លទ្ធផលសម្រាប់ការគ្រប់គ្រងដីធ្លីរបស់រដ្ឋ

---

[117] ឯកសារវិនិច្ឆ័យគម្រោង ទំព័រ ២៤

[118] "ការពិនិត្យទូទៅលើស្ថានភាពគម្រោង" ឧបសម្ព័ន្ធទី៧ នៃការពិនិត្យគម្រោង និងបេសកកម្មត្រួតពិនិត្យលើកទី៩របស់ម្ចាស់ជំនួយចម្រុះ (៣០ ឧសភា ដល់ ៨ មិថុនា ឆ្នាំ២០០៧)

ទាក់ទងនឹងការដោះស្រាយទំនាស់ត្រូវបានគេរកឃើញថា "*មានភាពមិនពេញចិត្ត*" និង "*មានភាពមិនពេញចិត្តខ្លះៗ*"។ ការដោះស្រាយទំនាស់នៅមានភាពខ្វះចន្លោះ ពិសេសករណីទំនាស់ដែលមានភាពស្មុគស្មាញ និងមានភាគីពាក់ព័ន្ធច្រើនចូលរួម និងករណីទំនាស់ដែលជាប់ពាក់ព័ន្ធ ជាមួយរដ្ឋ ឬ "*អ្នកមានអំណាច*"។

១៧៣. ការត្រួតពិនិត្យទូទៅក៏បានកំណត់ផងដែរ អំពីតម្រូវការសម្រាប់ដោះស្រាយបញ្ហានានាក្រោមការអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដូចជា "បញ្ហាបញ្ជីប្លង់ដីធ្លីដែលមិនទាន់បានបែងចែក ភាពគ្មានវឌ្ឍនភាពនៅក្នុងតំបន់ទីប្រជុំជន ការរៀបចំរចនាសម្ព័ន្ធផ្នែកស្ថាប័នឡើងវិញរបស់ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ភាពយឺតយ៉ាវកាន់តែខ្លាំងឡើងក្នុងការចុះបញ្ជីដីធ្លី កម្រិតទំនាស់ធំៗកើតឡើងមុនពេលមកដល់គណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លី និងបញ្ហាពាក់ព័ន្ធនឹងកម្រិតសមស្របផ្នែកអភិបាលកិច្ចល្អ" ជាដើម។ លើសពីនេះទៀត ការត្រួតពិនិត្យទូទៅក៏បានកត់សម្គាល់ឃើញផងដែរថា គម្រោងត្រូវតែធ្វើការដោះស្រាយឱ្យបានយ៉ាងសកម្មលើការសិក្សាអំពីទិន្នន័យដើមផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច ការសិក្សាអំពីផលប៉ះពាល់បន្ទាប់ពីអនុវត្ត និងការសិក្សាតាមដានត្រួតពិនិត្យផ្សេងៗទៀត ព្រមទាំងទទួលនូវយោបល់ត្រឡប់ពីសង្គមស៊ីវិល ដែលនឹងផ្តល់ព័ត៌មានសំខាន់ៗសម្រាប់ជាមូលដ្ឋានរបស់ថ្នាក់ដឹកនាំក្នុងការធ្វើសេចក្តីសម្រេច ហើយដែលជាភាពរីកចម្រើនរបស់គម្រោង និងកម្មវិធី។ ទោះបីជាមានអនុសាសន៍ទាំងនេះក៏ដោយ ក៏ការអនុវត្តគម្រោងត្រូវបានបន្ត ហើយកាលបរិច្ឆេទបញ្ចប់គម្រោងក៏ត្រូវបានពន្យាពេលផងដែរ។

១៧៤. ទោះជាយ៉ាងណាក៏ដោយ មុនពេលមានកំណត់សម្គាល់ខាងលើ កាលពីខែកុម្ភៈ ឆ្នាំ២០០៦ មាន "ការត្រួតពិនិត្យដោយឯករាជ្យមួយអំពីបញ្ហាគណនេយ្យភាព និងតម្លាភាព" (ហៅថា ការត្រួតពិនិត្យដោយឯករាជ្យ) របស់គម្រោង ដោយបានធ្វើការកត់សម្គាល់អំពីបញ្ហាទាក់ទងនឹងការរៀបចំប្លង់ដី និងគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ ផ្អែកតាមលទ្ធផលនៃការពិនិត្យដោយឯករាជ្យនេះ *យ៉ាងហោចណាស់មានគ្រួសារចំនួនមួយ ភាគប្រាំ (១៩.៦%) នៅក្នុងតំបន់ទាំង១៣ ដែលបានចុះសិក្សាបានទទួលផលប៉ះពាល់ជាអវិជ្ជមានពីដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ដែលជាទូទៅបញ្ហានេះកើតឡើងតាមរយៈការបដិសេធក្នុងការចុះបញ្ជីដីធ្លីដែលបានសាងសង់ទីលំនៅ ឬបានប្រើប្រាស់*"[១១៩]។ ដោយផ្អែកតាមលទ្ធផលនៃការធ្វើសម្ភាសន៍ តាមគ្រួសារសម្រាប់ការត្រួតពិនិត្យដោយឯករាជ្យនេះ បង្ហាញឱ្យឃើញថា "*ក្រុមកំណត់ព្រំដីរបស់គម្រោងក៏បានធ្វើការបដិសេធក្នុងការចុះបញ្ជីដីធ្លីឱ្យប្រជាពលរដ្ឋ នៅពេលមានបណ្តឹងជំទាស់ ឬនៅពេលដែល មានការកាន់កាប់លើដីធ្លីរបស់រដ្ឋ*"[១២០]។

១៧៥. ការត្រួតពិនិត្យដោយឯករាជ្យក៏បានធ្វើកំណត់សម្គាល់ផងដែរ អំពីការផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ដល់គ្រួសារប្រជាពលរដ្ឋអំពីដំណើរការ និងនីតិវិធីនៃការចុះបញ្ជីដីធ្លីជាប្រព័ន្ធនេះ។ យោងតាមលទ្ធផលនៃការត្រួតពិនិត្យដោយឯករាជ្យបង្ហាញឱ្យឃើញថា "អ្នកទទួលផលដែលបានស្ទើឡើង មិនបានដឹងព័ត៌មានទាក់ទងនឹង "អ្នកណាជាអ្នកធ្វើ? ធ្វើអ្វី? ធ្វើនៅកន្លែងណា? ធ្វើពេលណា? ហេតុអ្វីបានជាគេធ្វើ? គេធ្វើយ៉ាងដូចម្តេច? ធ្វើសម្រាប់អ្នកណា? ព្រម

[119] "ការត្រួតពិនិត្យដោយឯករាជ្យអំពីបញ្ហាគណនេយ្យភាព និងតម្លាភាពនៅក្នុងការចុះបញ្ជីដីធ្លីជាប្រព័ន្ធ, ប្រព័ន្ធ និងនីតិវិធីរបស់គម្រោងគ្រប់គ្រងរដ្ឋបាល និងដីធ្លី (LMAP), តំបន់មានទំនាស់, Declan O'lerary ខែកុម្ភៈ ឆ្នាំ២០០៦, ទំព័រ ii"

[120] ការត្រួតពិនិត្យដោយឯករាជ្យ ទំព័រ ១៤

ទាំងបញ្ហាផ្សេងៗទៀតទាក់ទងនឹងការចុះបញ្ជីដីធ្លីជាប្រព័ន្ធនេះ"[១២១] ។ ជាងនេះទៀត ការត្រួតពិនិត្យដោយឯករាជ្យក៏បានបង្ហាញបន្ថែមទៀតថា គ្រួសារប្រជាពលរដ្ឋក៏មិនបានទទួលព័ត៌មានគ្រប់គ្រាន់អំពី "*បញ្ហាសំខាន់ទាក់ទងនឹងសំណងទូទាត់/ការព្រមព្រៀងនៅពេលដែលដីរបស់ពួកគេដែលស្នើ សុំចុះបញ្ជីនេះមានទំនាស់ជាមួយរដ្ឋ*"[១២២] ។ ការសិក្សាដោយឯករាជ្យបានលើកឡើងថា ព័ត៌មានអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសំណងទូទាត់ ដូចដែលបានគូសបញ្ជាក់នៅក្នុងឯកសារសុវត្ថិភាពសង្គម ដែលទទួលបានការព្រមព្រៀងដោយរាជរដ្ឋាភិបាល និងដែលត្រូវអនុវត្តក្នុងគម្រោងនេះ មិនបានរៀបចំឱ្យបានសមស្របឡើយ[១២៣] ។

១៧៦. បន្ទាប់ពីតំបន់បឹងកក់ ត្រូវបានប្រកាសថាជាតំបន់វិនិច្ឆ័យរបស់គម្រោងកាលពីខែមីនា ឆ្នាំ២០០៦ គម្រោងបានប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពសម្រាប់រយៈពេលបួនឆ្នាំ។ ការអនុវត្តគម្រោងក្នុងរយៈពេលវែងដ៏សមស្របនេះ គឺជាការអនុវត្តសាកល្បងក្នុងការរៀបចំគម្រោង និងការរៀបចំនីតិវិធីអនុវត្ត ព្រមទាំងជាការអនុវត្តសាកល្បង ជាពិសេសលើការដោះស្រាយបញ្ហាដែលរាំងស្ទះ និងហានីភ័យនានា។ ចំណុចទី ១០.០៥ នៃ OP បានបង្ហាញថា ការត្រួតពិនិត្យគម្រោងគប្បីធ្វើការកំណត់បញ្ហាដែលនឹងកើតមានឡើងនៅ ក្នុងអំឡុងពេលអនុវត្តគម្រោង និងផ្តល់ជាអនុសាសន៍ដល់រដ្ឋាភិបាលក្នុងការរកវិធីសាស្ត្រ ដើម្បីដោះស្រាយបញ្ហាទាំងនោះ" និង "ផ្តល់អនុសាសន៍ដើម្បីធ្វើការផ្លាស់ប្តូរការរៀបចំគម្រោងបើអាចធ្វើបានឱ្យសមស្រប ទៅនឹងការវិវត្តន៍របស់គម្រោង ឬតាមកាលៈទេសៈនៃការផ្លាស់ប្តូរ" ព្រមទាំង "កំណត់អំពីហានិភ័យចម្បងៗ ដើម្បីធានាឱ្យមាននិរន្តរភាពគម្រោង និងផ្តល់អនុសាសន៍អំពីយុទ្ធសាស្ត្រសមស្របសម្រាប់គ្រប់គ្រងហានីភ័យ និងវិធានការនានាសម្រាប់សម្រាប់រាជរដ្ឋាភិបាលដែលជាអ្នកទទួលប្រាក់កម្ចីពីធនាគារពិភពលោក"។

១៧៧. គណៈកម្មាររកឃើញថា ការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំគម្រោងក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ បានមើលរំលងនូវបញ្ហាសំខាន់ៗ ដែលជាបណ្តឹងតវ៉ាជាលក្ខណៈឯកជនដែលបានធ្វើការវិនិច្ឆ័យទៅលើដីធ្លីដែលរដ្ឋបានអះអាង ថាជាដីរបស់រដ្ឋ។ ក្រុមបេសកកម្មយល់ឃើញថា ភាពបរាជ័យក្នុងការគ្រប់គ្រងនេះ បានចូលរួមចំណែកក្នុងការបង្កើតឱ្យមានព្រឹត្តិការណ៍នានាដែលកើតឡើងក្នុងដំបន់បឹងកក់ ព្រមទាំងនាំឱ្យមានភាពអន្តរាយនានា ដែលអ្នកតវ៉ាកំពុងជួបប្រទះនាពេលបច្ចុប្បន្ន។ ការត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រងលើបញ្ហាចម្បងៗទាំងនេះ មិនបានឆ្លើយតបទៅនឹងការទាមទារក្នុងចំណុច ១៣.០៥នៃ OP/BP ។

១៧៨. សង្កាត់ស្រះចក ត្រូវបានប្រកាសថាជាតំបន់វិនិច្ឆ័យ ក្នុងអំឡុងពេលផ្អាកគម្រោងជាបណ្តោះអាសន្ន។ បន្ទាប់ពីចាប់ផ្តើមអនុវត្តឡើងវិញកាលពីខែកុម្ភៈ ឆ្នាំ២០០៧ បេសកកម្មត្រួតពិនិត្យបានធ្វើឡើងនៅតំបន់បឹងកក់ (សង្កាត់ស្រះចក) នៅក្នុងខែមិថុនា ឆ្នាំ២០០៨។ នៅក្នុងពេលបេសកម្មត្រួតពិនិត្យនេះ ការិយាល័យគ្រប់គ្រងគម្រោងបានជំរាបទៅធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍នានាថា បឹងកក់ គឺជាដីសាធារណៈរបស់រដ្ឋ ដូច្នេះប្រជាពលរដ្ឋមិនមានសិទ្ធិទទួលបានប្លង់ដីឡើយ។ គណៈកម្មារបានកត់សម្គាល់ឃើញថា ថ្នាក់ដឹកនាំ គម្រោងមិនបានដឹងអំពី

---

121 ការត្រួតពិនិត្យដោយឯករាជ្យ ទំព័រ ១៦

122 ការត្រួតពិនិត្យដោយឯករាជ្យ ទំព័រ ១៦

123 ការត្រួតពិនិត្យដោយឯករាជ្យ ទំព័រ iii

តំបន់វិនិច្ឆ័យឡើយ ទោះបីជាតំបន់នោះស្ថិតនៅក្នុងរាជធានីភ្នំពេញក៏ដោយ ។ គណៈកម្មាធិការក៏បានរកឃើញផង ដែរថា ថ្នាក់ដឹកនាំគ្រប់គ្រងគម្រោងមិនបានលើកឡើងអំពីបញ្ហាណាមួយ ជាមួយនឹងអាជ្ញាធររបស់រដ្ឋាភិបាលអំពីនីតិវិធី ដោះស្រាយទំនាស់ដែលកើតមានឡើងក្នុងតំបន់បឹងកក់ ដែលមានប្រជាពលរដ្ឋពាក់ព័ន្ធច្រើនជា៤០០០គ្រួសារនោះ ឡើយ ហើយក៏មិនបានលើកឡើងពីបញ្ហានៃការអនុវត្ត ក្របខ័ណ្ឌគោលនយោបាយនៃសងសំណងទូទាត់ដែរ ។

១៧៩. រយៈពេលប្រហែល០៦ខែ បន្ទាប់បេសកកម្មត្រួតពិនិត្យនេះ នៅក្នុងខែមករា ឆ្នាំ២០០៩ កងនគរបាលប្រដាប់ ដោយអាវុធបានបណ្តេញប្រជាពលរដ្ឋប្រមាណ៤០០គ្រួសារយ៉ាងព្រៃផ្សៃចេញពីសហគមន៍ដីក្រហម ។ នៅត្រង់ចំណុច នេះ អង្គការមិនមែនរដ្ឋាភិបាលនានាបានចាប់ផ្តើមពិភាក្សាជាមួយថ្នាក់ដឹកនាំធនាគារពិភពលោក និងបានលើកឡើងពី បញ្ហានានាទាក់ទងនឹងការគំរាមបណ្តេញប្រជាពលរដ្ឋនៅតាមសហគមន៍ផ្សេងៗទៀត ដូចជាសហគមន៍ក្រុមទី៧៨ ដូចដែលបានឃើញតាមលំដាប់លំដោយនៃព្រឹត្តិការនៅក្នុងជំពូកទី២នៃរបាយការណ៍នេះ ។ ធនាគារពិភពលោក ត្រូវ ការពេលវេលាប្រមាណជិត០៤ឆ្នាំ បន្ទាប់ពីមានការប្រកាសថា សង្កាត់ស្រះចក គឺជាតំបន់វិនិច្ឆ័យដើម្បីកំណត់ ឱ្យប្រាកដអំពីភាពអន្តរាយនានា ដែលប្រជាពលរដ្ឋបានទទួល និងភាពជាក់ស្តែងនៃស្ថានភាពនោះ ។

១៨០. ក្រុមបេសកកម្មរកឃើញថា ថ្នាក់ដឹកនាំគម្រោងមិនបានចាត់វិធានការក្នុងការផ្សព្វផ្សាយព័ត៌មាន នៅពេលដែល មានបញ្ហាកើតឡើងនៅក្នុងតំបន់បឹងកក់ ដែលជាបញ្ហាដំបូងដែលត្រូវយកចិត្តទុកដាក់ ហើយការត្រួត ពិនិត្យរបស់ ថ្នាក់ដឹកនាំនៅក្នុងបញ្ហានេះ មិនមានសង្គតិភាពជាមួយនឹងការទាមទារត្រង់ចំណុច ១៣.០៥ នៃ OP/BP ។

១៨១. ចាប់តាំងពីដើមឆ្នាំ២០០៩ នៅពេលដែលមានការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការស្នើសុំនានាអាចធ្វើឡើង បាន ដល់ក្រុមអធិការកិច្ច ធនាគារពិភពលោកបានព្យាយាមយ៉ាងយកចិត្តទុកដាក់ក្នុងការជំរុញឱ្យរដ្ឋាភិបាល ធ្វើការពិនិត្យ មើលឡើងវិញលើករណីទំនាស់ដីធ្លីនៅតំបន់បឹងកក់ ។ ក្នុងអំឡុងខែមករា និងកុម្ភៈ ឆ្នាំ២០០៩ ក្រុមការងារបាន ជំរុញឱ្យមានកិច្ចប្រជុំពិភាក្សាជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពិភាក្សាអំពីការព្រួយបារម្ភរបស់ពួកគេទាក់ ទងនឹងគម្រោង ។ ថ្នាក់ដឹកនាំលើកឡើងថា នៅពេលដែលប្រាកដថា "មានភាព ច្បាស់លាស់ក្នុងការពន្លឿននូវដំណើរ ការបណ្តេញប្រជាពលរដ្ឋ"នោះនឹងមាន"ប្រតិកម្មទាន់ពេលវេលា" ។ ថ្នាក់ដឹកនាំចាត់វិធានការជាច្រើនដើម្បី ឆ្លើយតប ទៅនឹងបញ្ហាដែលបានលើកឡើង ។ ដោយយោងតាមការ ឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ក្នុងចំណោមចំណាត់ការ ទាំងនេះ "ថ្នាក់គ្រប់គ្រងបានជួបជាច្រើនដងជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ហើយក៏បានផ្ញើរ លិខិតជាច្រើនផងដែរទៅរាជរដ្ឋាភិបាល ដោយស្នើសុំឱ្យមានការបង្អាក់ជាបណ្តោះអាសន្នក្នុងការបណ្តេញប្រជា ពលរដ្ឋនេះ"[១២៤] ។

១៨២. ចាប់ពីថ្ងៃទី៣០ ខែមីនា ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៩ ថ្នាក់គ្រប់គ្រងបានបញ្ជូនក្រុមបេសកកម្មត្រួតពិនិត្យ សម្រាប់គម្រោង ។ របាយការណ៍ស្តីពី ERM បានអំពាវនាវម្តងទៀត ដើម្បីឱ្យមានការផ្អាកជាបណ្តោះអាសន្ន ក្នុងការ បណ្តេញប្រជាពលរដ្ឋ ។ ធនាគារពិភពលោកក៏បានឈានមុខក្នុងការរៀបចំ នឹងចេញផ្សាយនូវសេចក្តីប្រកាស ព័ត៌មានជាសាធារណៈជាមួយនឹងម្ចាស់ជំនួយចំនួន១០ផ្សេងទៀត កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ។ ដោយ យោងតាមថ្នាក់គ្រប់គ្រង សេចក្តីប្រកាសព័ត៌មាននេះ បន្ទាប់មកក៏បានទទួលនូវការគាំទ្រពីសំណាក់អង្គការមិន

124 ការឆ្លើយតបរបស់ថ្នាក់ដឹកនាំ ទំព័រ២៤

មែនរដ្ឋាភិបាលជាតិ អន្តរជាតិជាង៦០អង្គការផងដែរ។ ធនាគារពិភពលោក ក៏បានបង្កើតក្រុមបេសកកម្មដើម្បីសុវត្ថិភាពនៅក្នុងអំឡុងថ្ងៃទី៣ ដល់ទី៥ ខែសីហា ឆ្នាំ២០០៩ ព្រមទាំងមានទស្សន កិច្ចនៅរាជធានីភ្នំពេញពីសំណាក់អនុប្រធានប្រចាំតំបន់ ចាប់ពីថ្ងៃទី២៧ ដល់២៨ ខែសីហា ដើម្បីជួបជាមួយមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល កម្ពុជា[១២៥] ។

១៨៣. ក្រុមអធិការកិច្ចរកឃើញអំពីការគ្រប់គ្រងបច្ចុប្បន្នរបស់ថ្នាក់ដឹកនាំគម្រោងថា បញ្ហាដែលលើកឡើងតាមការស្នើសុំបានអនុវត្តតាមគោលនយោបាយរបស់ធនាគារអំពីការគ្រប់គ្រងគម្រោងចំណុច១៣.០៥នៃOP/BP ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ក្រុមអធិការកិច្ចឯកភាពជាមួយការតម្លៃរបស់អ្នកតវ៉ាថា "*វាជាកត្តាតាងដែលថាចំណាត់ការរបស់គណៈគ្រប់គ្រងធនាគារពិភពលោកមានភាពយឺតយ៉ាវពេក ក្នុងការទប់ស្កាត់ភាពអន្តរាយដែលបានកើតមានរួចមកហើយ*" ។

## ឃ. អះអាងថា ប្រជាជនរស់នៅក្នុងតំបន់បឹងកក់ត្រូវបានគេផ្លាស់ទីលំនៅ ដោយរំលោភលើគោលនយោបាយដែលបានព្រមព្រៀងស្តីពីការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត

### ១. ការអះអាងរបស់អ្នកស្នើសុំ និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង

១៨៤. អ្នកស្នើសុំអះអាងថា (ត្រឹមខែ កញ្ញា ឆ្នាំ ២០០៩) "ប្រជាជនជាង ៩០០ គ្រួសារ នៅបឹងកក់ ត្រូវបានបោសសំអាតពីតំបន់នេះ ដោយពុំបានវិនិច្ឆ័យត្រឹមត្រូវទៅលើសិទ្ធិដីធ្លីរបស់ពួកគេឡើយ ។ ដោយគ្មានការការពារផ្នែកច្បាប់ណាមួយ គ្រួសារទាំងនេះបានទទួលសំណងមិនគ្រប់គ្រាន់ក្រោមលក្ខខណ្ឌនៃការបង្ខិតបង្ខំ"[១២៦] ។ យោងតាមសំណើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩ ប្រជាជនជាង ១៦០ គ្រួសារ នៅក្នុងតំបន់បឹងកក់ ត្រូវបានជូនដំណឹងអំពីការបណ្តេញចេញលើកទីមួយ ។ ពួកគេត្រូវបានផ្តល់ជម្រើសមួយក្នុងចំណោមជម្រើសសំណងចំនួនបីដែត្រូវទទួលយកក្នុងរយៈ ពេលមួយសប្តាហ៍ :

- ប្រាក់សរុបចំនួន ៨.៥០០ ដុល្លារអាមេរិក
- លំនៅដ្ឋានមួយខ្នងនៅក្នុងតំបន់តាំងទីលំនៅឡើងវិញចម្ងាយប្រហែល ២០ គីឡូម៉ែត្រពីតំបន់បឹងកក់ (ដំណាក់ទ្រយឹង) ឬ
- លំនៅដ្ឋាននៅនឹងកន្លែងក្នុងតំបន់បឹងកក់ ដែលនឹងតម្រូវឱ្យមានការរើទីលំនៅបណ្តោះអាសន្នរយៈពេលបួនឆ្នាំរង់ចាំការបញ្ចប់រួចរាល់ផ្ទះថ្មីនៅក្នុងតំបន់បឹងកក់ (ការផ្តល់ជូននេះ រួមបញ្ចូលទាំងការរើទីលំនៅបណ្តោះអាសន្នទៅកាន់តំបន់មួយផ្សេងទៀត ដែលមានចម្ងាយប្រហែល ២០ គីឡូម៉ែត្រពីកណ្តាលក្រុងផងដែរ - ត្រពាំងអញ្ចាញ) ។

---

125 ការឆ្លើយតបរបស់ថ្នាក់ដឹកនាំ ទំព័រ២៥

១២៦ សំណើសុំអធិការកិច្ច ទំព័រទី ៥

១៨៥. អ្នកស្នើសុំកត់សម្គាល់ថា កិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍ (DCA) បានប្រមើលមើលពីលទ្ធភាព ដែលថា ការបណ្តេញចេញអាចប្រព្រឹត្តទៅនៅក្រោមគម្រោង ហើយជាលទ្ធផល បានអនុញ្ញាតឱ្យមានការអនុវត្ត គោលការណ៍ ណែនាំផ្នែកបរិស្ថាន និងសង្គមដែលរួមបញ្ចូលក្របខ័ណ្ឌគោលនយោបាយសីពីការតាំងទីលំនៅឡើងវិញ (RPF) ។ អ្នកស្នើសុំបានបញ្ជាក់ថា ដោយរំលោភលើកិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍ ក្របខ័ណ្ឌ គោលនយោបាយស្តីពីការ តាំងទីលំនៅឡើងវិញ មិនត្រូវបានអនុវត្តនៅក្នុងតំបន់បឹងកក់ឡើយ ដោយបណ្តាលឱ្យ មានការខូចខាតធ្ងន់ធ្ងរចំពោះប្រជាជន ដែលត្រូវបណ្តេញចេញពីតំបន់នោះ ។ អ្នកស្នើសុំអះអាងថា កាលៈទេសៈនៃ ការបណ្តេញចេញ និងស្ថានភាពនៃកន្លែងតាំងទីលំ នៅឡើងវិញ មិនបានបំពេញតាមបទដ្ឋាន ដែលមានចែងនៅក្នុង គោលនយោបាយរបស់ធនាគារពិភពលោក ស្តីពីការតាំង ទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ។

១៨៦. ក្នុងការឆ្លើយតបរបស់ខ្លួន ថ្នាក់គ្រប់គ្រងបានអះអាងថា កិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍ តម្រូវឱ្យ មានការអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ នៅក្នុងហេតុការណ៍ នៃការបណ្តេញចេញ ពីដីរបស់រដ្ឋក្រោមសមាសធាតុគម្រោង ដែលចែងអំពីការផ្តល់កម្មសិទ្ធិជាលក្ខណៈប្រព័ន្ធ និងដាច់ដោយដុំ[១២៧] ។ ថ្នាក់គ្រប់គ្រងបញ្ជាក់ថា សមាសធាតុផ្តល់កម្មសិទ្ធិនៃគម្រោង ដោយសារការកំហិតផ្នែកហិរញ្ញវត្ថុ ស្ថាប័ន បច្ចេកវិទ្យា និងសមត្ថភាពមនុស្ស ត្រូវបានរៀបចំឡើងដើម្បីអនុវត្តតាមលំដាប់លំដោយ នៅក្នុងតំបន់វិនិច្ឆ័យដែលបានជ្រើសរើស មុនគេ រួចបន្ទាប់មក បន្តទៅកាន់ទីតាំងដទៃទៀតនៅពេលទីតាំងដំបូង ត្រូវបានបញ្ចប់រួចរាល់។ ថ្នាក់គ្រប់គ្រងបញ្ជាក់ បន្ថែមទៀតថា ក្របខ័ណ្ឌ គោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ត្រូវអនុវត្តតាមលំដាប់លំដោយដូចគ្នា ។ ដូច្នេះ ថ្នាក់គ្រប់គ្រងបញ្ជាក់ ថាវា *"ត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់ ប៉ុន្តែដោយប្រយោល"* ថានឹងមានតំបន់ ដែលគម្រោងមិនមានភាពសកម្ម និងថា ក្របខ័ណ្ឌគោលនយោបាយ ស្តីពីការតាំងទីលំនៅឡើងវិញនឹងមិនអនុវត្ត ឡើយ[១២៨] ។

១៨៧. ទាក់ទងជាក់លាក់ទៅនឹងតំបន់បឹងកក់ ថ្នាក់គ្រប់គ្រងយល់ស្របជាមួយអ្នកស្នើសុំថា ក្របខ័ណ្ឌគោលនយោបាយស្តីពី ការតាំងទីលំនៅឡើងវិញគួរត្រូវបានអនុវត្តចំពោះការផ្លាស់ទីលំនៅដែលកើតឡើងនៅក្នុងសង្កាត់ស្រះចក ។ ដូចមាន បញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើង វិញ នឹងត្រូវអនុវត្តនៅក្នុងករណីនៃការបណ្តេញចេញពីដីរដ្ឋដោយសារសកម្មភាពគម្រោង ហើយផែនការសកម្មភាព តាំងទីលំនៅឡើងវិញ ជាក់លាក់នៅនឹងកន្លែង គួរត្រូវបានរៀបចំឡើងសម្រាប់ការពិនិត្យឡើងវិញ និងការឯកភាព ពីធនាគារពិភពលោក ។ ថ្នាក់គ្រប់គ្រងយល់ស្របជាមួយអ្នកស្នើសុំថា ទោះបីជាមិនទាន់មានភាពច្បាស់លាស់ថា តើតំបន់បឹងកក់ ត្រូវបានប្រគល់កម្មសិទ្ធិជូនរដ្ឋឬយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងជួលដែលរដ្ឋាភិបាលផ្តល់ឱ្យអ្នក អភិវឌ្ឍន៍ឯកជនទៅលើដីនោះក្នុងឆ្នាំ ២០០៧ បង្កើតបានជាការកំណត់តាមព្រឹត្តន័យថា ដីនេះគឺជាដីរបស់រដ្ឋ ។ តាមទស្សនៈរបស់ថ្នាក់គ្រប់គ្រង : *"ការច្រានចោលការអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើង វិញ ចំពោះការបណ្តេញចេញនៅក្នុងតំបន់វិនិច្ឆ័យនៃគម្រោង ដោយសារដំណើរការវិនិច្ឆ័យហាក់ដូចជាមិនត្រូវបាន*

[១២៧] វត្ថុបំណង និងស្ថានភាពនៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ត្រូវបានរៀបរាប់ និងវិភាគក្នុងផ្នែកខាងក្រោម ។
[១២៨] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង កថាខ័ណ្ឌ ៣២

*អនុវត្តតាមរហូតដល់ទីបញ្ចប់ ហើយពុំមានកម្មសិទ្ធិផ្លូវការណាមួយត្រូវបានចេញក្នុងឈ្មោះរបស់រដ្ឋ គឺផ្ទុយទៅនឹងគោលបំណងដែលនៅពីក្រោយការអភិវឌ្ឍរបស់ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍ*[១២៩] ។

១៨៨. នៅក្នុងការឆ្លើយតបរបស់ខ្លួន ថ្នាក់គ្រប់គ្រងសំដៅដល់គោលជំហររបស់រដ្ឋាភិបាល ដែលអះអាងថា តំបន់បឹងកក់មិនមែនជាកម្មសិទ្ធិរបស់គម្រោងទេ ដោយសារដីបឹងកក់មិនត្រូវបានផ្តល់កម្មសិទ្ធិជូនរដ្ឋដោយ LMAP ។ ទោះបីជាថ្នាក់គ្រប់គ្រងជំទាស់ទៅនឹងការអះអាងនេះ ដោយសារហេតុផលដែលកត់សម្គាល់នៅក្នុងកថាខណ្ឌមុនក៏ដោយ ខ្លួនក៏ទទួលស្គាល់ថា *"កង្វះភាពជាក់លាក់នៅក្នុងឯកសារគម្រោង និងអវត្តមាននៃកិច្ចពិភាក្សាលម្អិតអំពីកិច្ចប្រឹងប្រែងរបស់ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ទោះជាក្នុងអំឡុងនៃការរៀបចំក្តី ឬការអនុវត្តក៏ក្តី អាចចូលរួមចំណែកចំពោះការយល់ដឹងរបស់រដ្ឋាភិបាលអំពីកាតព្វកិច្ចរបស់ខ្លួន"*[១៣០] ។ ថ្នាក់គ្រប់គ្រងក៏បានបញ្ជាក់ថា រហូតដល់ព្រឹត្តិការណ៍បឹងកក់បានកើតឡើង ទាំងថ្នាក់គ្រប់គ្រង ទាំងក្រសួងរៀបចំដែនដីមិនបានពិចារណាថា ទោះបីជាដំណើរការផ្តល់កម្មសិទ្ធិមិនមានភាពពេញលេញក៏ដោយ វិធានការនានាអាចធ្វើឡើងនៅក្នុងតំបន់វិនិច្ឆ័យ ដែលអាចអំពាវនាវឱ្យមានការអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ។

១៨៩. ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា ប្រជាជននៅក្នុងតំបន់បឹងកក់ ត្រូវបានរងសម្ពាធអោយរើទីលំនៅ និងថា ពុំមានដំណើរការពិគ្រោះយោបល់ ឬចរចាគ្រប់គ្រាន់អំពីការរើទីលំនៅឡើយ ។ ទាក់ទងទៅនឹងសំណងដែលផ្តល់ជូនប្រជាជន ថ្នាក់គ្រប់គ្រងបញ្ជាក់ថា : *"កញ្ចប់ដែលបានស្នើឡើងហាក់ដូចជាមិនសមមូលទៅនឹងអ្វីដែលប្រជាជនត្រូវទទួលបាន ប្រសិនបើក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញត្រូវបានអនុវត្ត"*[១៣១] ។ ទោះបីជាយ៉ាងណាក្តី ថ្នាក់គ្រប់គ្រង កត់សម្គាល់ថា ដោយសារនីតិវិធីដែលកំណត់នៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ មិនត្រូវ បានអនុវត្ត ការវាយតម្លៃជាក់លាក់អំពីភាពយុត្តិធម៌ និងភាពគ្រប់គ្រាន់នៃកញ្ចប់ដែលផ្តល់ឱ្យ មិនអាចធ្វើឡើងបានទេ។

១៩០. ការឆ្លើយតបក៏រៀបរាប់លម្អិតផងដែរអំពីកិច្ចប្រឹងប្រែងថ្មីៗពីសំណាក់ថ្នាក់គ្រប់គ្រងក្នុងការចូលរួមនៅក្នុងកិច្ចពិភាក្សាជាមួយរដ្ឋាភិបាលអំពីបញ្ហានៃការបណ្តេញចេញនៅក្នុងតំបន់ទីក្រុង ។ កិច្ចពិភាក្សានេះ រួមមាន ការផ្អាកការបណ្តេញចេញដោយរង់ចាំគោលនយោបាយជាតិស្តីពីការតាំងទីលំនៅឡើងវិញ និងការកែលម្អ លក្ខខណ្ឌនៃកន្លែងតាំងទីលំនៅឡើងវិញ។ ជាពិសេស ថ្នាក់គ្រប់គ្រងបានផ្តល់ការគាំទ្ររបស់ខ្លួន ដើម្បីកែលម្អលក្ខខណ្ឌ រស់នៅ និងជីវភាពរបស់ប្រជាជនមកពីតំបន់បឹងកក់ ដែលជ្រើសរើសតាំងទីលំនៅឡើងវិញនៅតំបន់ក្រៅទីក្រុង ភ្នំពេញ ។

## ២. ការវិភាគរបស់ក្រុមអធិការកិច្ច និងគំហើញអំពីភាពអនុលោម

---

[១២៩] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង កថាខ័ណ្ឌ ៥១

[១៣០] ទំព័រទី ៥២

[១៣១] ទំព័រទី ៧៥

១៩១. **ការគ្របដណ្តប់នៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ :** យោងតាម ភា៤ "ខណៈពេលដែលគ្មានការបណ្តេញចេញ ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ឬការទទួលដី មិនត្រូវបានរំពឹងទុកជាមុននៅក្រោមគម្រោងទេនោះ ក្របខ័ណ្ឌគោលនយោបាយមួយត្រូវបានបង្កើតឡើងដើម្បីការពារប្រជាជន ដែលអាចទទួលរងផលប៉ះពាល់អវិជ្ជមានពីប្រភពដែលអាចកើតមានចំនួនបី"[១៣២] ។ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញដែលត្រូវគ្នា កំណត់ស្ថានភាពចំនួនបីនៅពេលប្រជាជនអាចទទួលរងផលប៉ះពាល់អវិជ្ជមាន ហើយក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញនឹងអនុវត្ត ដោយតម្រូវឱ្យមានការរៀបចំផែនការតាំងទីលំនៅឡើងវិញជាក់លាក់នៅនឹងកន្លែង :

១. ការបណ្តេញចេញពីដីរដ្ឋចំពោះបុគ្គលទាំងឡាយណាដែលកាន់កាប់ដីនោះមុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ (កាលបរិច្ឆេទនៃការអនុម័តច្បាប់ភូមិបាលថ្មី) បន្ទាប់ពីការផ្តល់កម្មសិទ្ធិចំពោះដីនោះក្នុងឈ្មោះរបស់រដ្ឋ ។

២. ការបណ្តេញចេញពីដីរដ្ឋ (ត្រូវបានផ្តល់កម្មសិទ្ធិក្នុងឈ្មោះរបស់រដ្ឋ) ចំពោះបុគ្គលទាំងឡាយណា (ដែលកាន់កាប់ដីនោះមុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១) ដោយសារតម្រូវការក្នុងការប្រើដីនោះសម្រាប់ការងារស៊ីវិលនៅក្រោមគម្រោង ។

៣. ការពង្រីកចំណីផ្លូវដោយរដ្ឋ ដែលប៉ះពាល់ជាអវិជ្ជមានចំពោះសិទ្ធិកាន់កាប់ដី ។

១៩២. ការពិនិត្យឡើងវិញលើឯកសាររៀបចំគម្រោងបានបង្ហាញថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ដើមឡើយត្រូវបានរៀបចំឡើង ដើម្បីអនុវត្តតែក្នុងករណីនៃការតាំងទីលំនៅឡើងវិញរបស់ប្រជាជនដែលរស់នៅលើដី ដែលនឹងត្រូវបានសាងសង់អាគារការិយាល័យ ឬការងារស៊ីវិលផ្សេងទៀតដែលផ្តល់ហិរញ្ញប្បទានដោយគម្រោង (ឧទាហរណ៍ ស្ថានភាពទីពីរខាងលើ) ។ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា កិច្ចពិភាក្សា ផ្ទៃក្នុងក្នុងចំណោមបុគ្គលិកធនាគារពិភពលោក អំពីភាពអាចអនុវត្តបាននៃគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត នៅក្នុងគម្រោងរដ្ឋបាលដីធ្លី បាននាំក្រុមការងារគម្រោង អោយពង្រីកវិសាលភាពនៃក្របខ័ណ្ឌគោលនយោបាយ ស្តីពីការតាំងទីលំនៅឡើងវិញ ដើម្បីគ្របដណ្តប់ប្រជាជនដែលកាន់កាប់ដីសាធារណៈ និងដែលនឹងត្រូវបណ្តេញចេញ ដោយសារការផ្តល់កម្មសិទ្ធិដីនោះជូនរដ្ឋ ។ បុគ្គលិកធនាគារពិភពលោកមួយចំនួនបានកត់សម្គាល់ថា ទោះបីជាគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត នឹងមិនត្រូវបានបង្កើតឡើងក្នុងករណីវិវាទដីធ្លីរវាងភាគីឯកជនក៏ដោយ ក៏គោលនយោបាយនេះនឹងអនុវត្តចំពោះទំនាស់ ដែលពាក់ព័ន្ធភាគីឯកជនដែលរស់នៅលើដីរដ្ឋ ។

១៩៣. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងក៏បានបញ្ជាក់ថា ការបន្ថែមនេះចំពោះកិច្ចពិភាក្សាដែលឆ្លុះបញ្ចាំងដោយក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញនៅក្នុងធនាគារពិភពលោក នៅក្នុងបរិបទនៃការរៀបចំគោលនយោ-បាយថ្មីស្តីពីការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ឡឹភ ៤.១២ច និងថា គម្រោងក្របខ័ណ្ឌគោលនយោបាយ

[១៣២] ភា៤ ទំព័រទី ២០

ស្តីពីការតាំងទីលំនៅឡើងវិញ គឺជាក្របខ័ណ្ឌស្តីពីការតាំងទីលំនៅឡើងវិញដំបូងគេបង្អស់នៅក្នុងធនាគារពិភពលោក ដើម្បីឆ្លុះបញ្ចាំងអភិក្រមនេះ ពោលគឺ គោលនយោបាយនេះនឹងអនុវត្តចំពោះការផ្លាស់ទីលំនៅរបស់ប្រជាជនដែលរស់នៅលើដីដែលត្រូវបានកំណត់ថាជាដីរដ្ឋ និងត្រូវបានផ្តល់កម្មសិទ្ធិក្នុងឈ្មោះរបស់រដ្ឋ តាមរយៈដំណើរការវិនិច្ឆ័យ ។

១៩៤. **ក្រុមអធិការកិច្ចរកឃើញថា សេចក្តីសម្រេចក្នុងការរៀបចំ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ មានភាពអនុលោមទៅតាមបទប្បញ្ញត្តិនៃគោលនយោបាយដែលពាក់ព័ន្ធ - វ៉ីឱ ៤.៣០ ។ ក្រុមអធិការកិច្ចកោតសរសើរថ្នាក់គ្រប់គ្រងដែលបានពង្រីកយ៉ាងទូលំទូលាយចំពោះស្ថានភាពជាច្រើន ដែលគោលនយោបាយគួរនឹងអនុវត្ត ដោយឆ្លុះបញ្ចាំងការគិតថ្មីៗនៅក្នុងធនាគារពិភពលោក នាពេលនោះ ទាក់ទងទៅនឹងការអនុវត្តយ៉ាងត្រឹមត្រូវនូវការការពាររបស់ធនាគារពិភពលោក ។**

១៩៥. ទោះបីជាយ៉ាងណាក៏ដោយ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅ ឡើងវិញ ខ្វះការពន្យល់សមស្របអំពីរបៀប និងពេលវេលាដែលក្របខ័ណ្ឌគោលនយោបាយនេះនឹងត្រូវ បានបង្កើតឡើង។ ពុំមានស្ថានភាពណាមួយក្នុងចំណោមស្ថានភាពទាំងបីដែលបង្កើតឡើង ត្រូវបានអមដោយអត្ថបទពន្យល់ឡើយ។ ខណៈដែលកិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍមានភាពច្បាស់លាស់ និងភ្ជាប់កាតព្វកិច្ចនៅក្នុងបទប្បញ្ញត្តិរបស់វា ទាក់ទងទៅនឹងកាតព្វកិច្ចរបស់អ្នកខ្ចីប្រាក់ក្នុងការអនុវត្តគម្រោង ស្របតាមគោលការណ៍ណែនាំផ្នែកបរិស្ថាន និងសង្គម រួមមាន ក្របខ័ណ្ឌគោលនយោបាយស្តីពី ការតាំងទីលំនៅឡើងវិញ កង្វះភាពច្បាស់លាស់អំពីការអនុវត្តជាក់ស្តែងនៃក្របខ័ណ្ឌគោលនយោបាយ ស្តីពីការតាំងទីលំនៅឡើងវិញ មានភាពគួរឱ្យកត់សម្គាល់ជាពិសេស ដែលបណ្តាលឱ្យមានភាពមិនប្រាកដប្រជា និងការមិនព្រមព្រៀងគ្នាអំពីភាពអាចអនុវត្តបានរបស់វា ។ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ហាក់ដូចជាត្រូវបានរៀបចំឡើងជាដំបូងសម្រាប់តែស្ថានភាពទីពីរប៉ុណ្ណោះ (ការបណ្តេញចេញក្នុងករណីការងារស៊ីវិលដែលផ្តល់ហិរញ្ញប្បទានដោយគម្រោង) ចំណែកឯស្ថានភាពទីមួយ និងទីបីត្រូវបានបញ្ចូល នៅក្នុងដំណាក់កាលក្រោយៗនៃការរៀបចំគម្រោង និងដោយគ្មានការពិចារណាពេញលេញ ដោយធនាគារពិភពលោក ឬរដ្ឋាភិបាលកម្ពុជា អំពីឥទ្ធិពលជាក់ស្តែងនៃស្ថានភាពទាំងនេះឡើយ ។

១៩៦. ទាក់ទងទៅនឹងស្ថានភាពទីមួយ ដែលជាស្ថានភាពអនុវត្តយ៉ាងជាក់លាក់ចំពោះព្រឹត្តិការណ៍នៅបឹងកក់ មានសមាសធាតុជាច្រើនដែលនឹងតម្រូវឱ្យមានការណែនាំបន្ថែម ដើម្បីឱ្យធនាគារពិភពលោក និងបុគ្គលិករដ្ឋាភិបាលទទួលខុសត្រូវចំពោះការអនុវត្ត និងការគ្រប់គ្រងគម្រោង និងដៃគូអភិវឌ្ឍន៍ ដើម្បីកំណត់ភាពអាចអនុវត្តបាននៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញនៅក្នុងករណីជាក់ស្តែង ។

១៩៧. *របៀបដែលត្រូវយល់ដឹងអំពី "ការផ្តល់កម្មសិទ្ធិក្នុងឈ្មោះរបស់រដ្ឋ" ?* ក្រុមអធិការកិច្ចកត់សម្គាល់ថា បទប្បញ្ញត្តិនេះដែលត្រូវបានបញ្ជាក់នៅក្នុងស្ថានភាពទីមួយនៃឯកសារក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុង ភាឱ មិនត្រូវបានរាប់បញ្ចូលនៅក្នុងអត្ថបទពាក់ព័ន្ធនៃកិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍឡើយ ។ កិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍចែងថា :

*...អ្នកខ្ចីប្រាក់ត្រូវចាត់វិធានការទាំងនេះតាមការចាំបាច់ ដើម្បីធានាថា : ១៤ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញត្រូវបានអនុវត្តគួរជាទីពេញចិត្តចំពោះសមាគម រួមទាំង នៅក្នុងការអនុវត្តការងារស៊ីវិលទាំងឡាយណានៅក្រោមផ្នែក ខ(ក) នៃគម្រោង ឬនៅក្នុងព្រឹត្តិការណ៍នៃការបណ្តេញចេញពីដីរដ្ឋ ឬការពង្រីកចំណីផ្លូវក្រោមផ្នែក គ(ខ) និង (គ) នៃគម្រោង...* ឱ្យការសង្កត់ធ្ងន់ត្រូវបានបន្ថែមឧ[១៣៣] ។

១៩៨. ដូចមានកត់សម្គាល់ខាងលើ កិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍ ដែលជាឯកសារភ្ជាប់កាតព្វកិច្ចផ្លូវ ច្បាប់សម្រាប់គម្រោង មិនរួមបញ្ចូលរបាយការណ៍អំពីភាពអាចអនុវត្តបាននៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញទាក់ទងទៅនឹង *"ការផ្តល់កម្មសិទ្ធិក្នុងឈ្មោះរបស់រដ្ឋ"* ។ ក្រុមអធិការកិច្ចមិនបានដឹងថាតើភាពខុសគ្នាបន្តិចបន្តួចនេះ គឺជាចេតនា ឬជាការមើលរំលងនោះទេ ប៉ុន្តែវាចង្អុលបង្ហាញអំពីភាពខុសគ្នារវាង កិច្ចព្រមព្រៀងស្តីពីឥណទាន សម្រាប់ការអភិវឌ្ឍ និងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ។ រដ្ឋាភិបាលសំដៅដល់ការប្រើ ពាក្យនៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ និងកត់សម្គាល់ថា ក្របខ័ណ្ឌគោលនយោបាយស្តីពី ការតាំងទីលំនៅឡើងវិញមិនត្រូវបានអនុវត្តឡើយ ដោយសារពុំមានការផ្តល់កម្មសិទ្ធិក្នុងឈ្មោះរបស់រដ្ឋនៅក្នុងតំបន់ បឹងកក់ ។

១៩៩. ខណៈដែល PAD បានប្រមើលមើលយ៉ាងច្បាស់ថា ការវិនិច្ឆ័យដីក៏រួមបញ្ចូលនូវការទាមទារទាក់ទងនឹងដីរដ្ឋ PAD សង្កត់ធ្ងន់ថា វាត្រូវការរយៈពេលយូរ មុនពេលដីរដ្ឋទាំងអស់ត្រូវបានចាត់ចំណាត់ថ្នាក់ និងផ្តល់កម្មសិទ្ធិត្រឹមត្រូវ ។ ដូច្នេះ ដំណើរការវិនិច្ឆ័យរបស់ LMAP នឹងបញ្ជាក់អះអាងថាតើដីណាមួយគឺជាដីរដ្ឋ ដែលអាចបណ្តាលឱ្យមានការបណ្តេញចេញ ប៉ុន្តែក្នុងគ្រប់ករណីទាំងអស់មិនទំនងជាបញ្ចប់ដំណើរការអំពី "ការផ្តល់កម្មសិទ្ធិក្នុងឈ្មោះរបស់រដ្ឋ" ។ ក្រុមអធិការកិច្ចកត់សម្គាល់ថា ពុំមានគោលការណ៍ណែនាំពាក់ព័ន្ធណាមួយនៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញទាក់ទងទៅនឹងស្ថានភាពនេះឡើយ ។ ដូចបានកត់សម្គាល់ផងដែរនៅក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ពុំមាន *"សេចក្តីសម្រេចដែលមានតម្លាភាព ផ្អែកលើលក្ខណៈវិនិច្ឆ័ និងអាចពិនិត្យឡើងវិញបាន អំពីថាតើដីមានទំនាស់គឺជាដីសាធារណៈរបស់រដ្ឋឬយ៉ាងណានោះទេ"*[១៣៤] ។

២០០. *តើថិរវេលាសុពលភាពសម្រាប់ការអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ មានរយៈពេលប៉ុន្មាន ?* ការផ្តល់កម្មសិទ្ធិចំពោះដីធ្លីក្នុងឈ្មោះរបស់រដ្ឋមិនសុទ្ធតែនាំមកនូវការបណ្តេញចេញភ្លាមៗចំពោះប្រជាជនពីដីនោះឡើយ ។ រដ្ឋអាចសម្រេចចិត្តផ្តល់ដីខ្លះ ឬទាំងអស់សម្រាប់កម្មវិធីតាំងទីលំនៅឡើងវិញក្រៅផ្លូវការ ឬអាចពន្យារពេលការបណ្តេញចេញសម្រាប់រយៈពេលមិនកំណត់មួយ ។ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញមិនផ្តល់គោលការណ៍ណែនាំណាមួយអំពីភាពអាចអនុវត្តបាន និងលក្ខខណ្ឌតម្រូវរបស់ខ្លួនឡើយ បើពិចារណាអំពី

---

[១៣៣] កិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍ កថាខ័ណ្ឌ ១១៤ នៃតារាងឧបសម្ព័ន្ធ ៤

[១៣៤] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង កថាខ័ណ្ឌ ៥៤

សេណារីយ៉ូផ្សេងនេះ ។ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញគួសបញ្ជាក់ថា សំណង ការតាំងទីលំនៅឡើងវិញ និងការស្តារនីតិសម្បទាឡើងវិញត្រូវតែបញ្ចប់រួចរាល់ មុនពេលធនាគារពិភពលោកអាចចេញការឯកភាពចំពោះកិច្ចសន្យាសម្រាប់ការងារស៊ីវិល ប៉ុន្តែ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញមិនបានគូសបញ្ជាក់អំពីលក្ខខណ្ឌតម្រូវស្រដៀងគ្នាណាមួយ នៅក្នុងករណីដែលការបណ្តេញចេញកើតមានឡើង ពីព្រោះដីត្រូវបានផ្តល់កម្មសិទ្ធិក្នុងឈ្មោះរបស់រដ្ឋ ។ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ពុំមានភាពច្បាស់លាស់អំពីថាតើពេលណា ក្នុងអំឡុងដំណើរការផ្តល់កម្មសិទ្ធិ ផែនការតាំងទីលំនៅឡើងវិញគួរត្រូវបានរៀបចំឡើង និងដាក់ជូនធនាគារពិភពលោកដើម្បីអនុម័តឡើយ ។

២០១. *តើត្រូវកំណត់ថាតើអ្នកណាមានសិទ្ធិស្របច្បាប់ចំពោះការការពារក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញយ៉ាងដូចម្តេច?* ស្ថានភាពទីមួយសន្មតថា ដីទំនាស់គឺជាដីស្របច្បាប់របស់រដ្ឋ ដែលប្រហែលជានឹងត្រូវកំណត់តាមរយៈដំណើរការវិនិច្ឆ័យដី ។ ប្រការនេះបង្កប់ន័យថា ប្រជាជនដែលទាមទារសិទ្ធិកាន់កាប់ត្រូវបានបដិសេធសិទ្ធិទាំងនេះ និងអាចត្រូវបានបណ្តេញចេញដោយស្របច្បាប់ ។ ស្ទើរតែច្បាស់ណាស់ថា ប្រជាជនដែលពាក់ព័ន្ធ មានប្រវត្តិតាំងទីលំនៅខុសៗគ្នា ។ អ្នកខ្លះចាប់ផ្តើមតាំងទីលំនៅមុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ហើយអ្នកខ្លះចាប់ផ្តើមតាំងទីលំនៅក្រោយនេះ ។ ស្ថានភាពទីមួយហាក់ដូចជាបង្កប់ន័យថា មានតែប្រជាជនដែលអាចបញ្ជាក់អំពីការកាន់កាប់ដីមុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ប៉ុណ្ណោះនឹងមានសិទ្ធិទទួលបានការការពារនៅក្រោមក្របខ័ណ្ឌគោល-នយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានការណែនាំណាមួយនៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញអំពីថាតើត្រូវកំណត់ភាពមានសិទ្ធិយ៉ាងដូចម្តេចឡើយ ។ ជាងនេះទៅទៀត ការគ្របដណ្តប់របស់កិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍ មានភាពទូលំទូលាយជាងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ត្រង់ថា កិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍមិនតម្រូវឱ្យបុគ្គលទាំងឡាយចាំបាច់ត្រូវតែកាន់កាប់ដីរដ្ឋមុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដើម្បីទទួលបានអត្ថប្រយោជន៍ នៅក្រោមក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញនោះទេ ។

**២០២.** *តើអាចមានជម្រើសផ្សេងក្រៅពីការបណ្តេញចេញឬទេ?* ក្រុមអធិការកិច្ចកត់សម្គាល់ថា ស្ថានភាពទីមួយ តាមពិតទៅហាក់ដូចជាទាក់ទងទៅនឹង "អ្នកតាំងទីលំនៅក្រៅផ្លូវការ" ពោលគឺប្រជាជនដែលត្រូវបានកំណត់ថា ពុំមានសិទ្ធិស្របច្បាប់ចំពោះដីដែលពួកគេកាន់កាប់ ដោយសារពួកគេកាន់កាប់ដីសាធារណៈរបស់រដ្ឋ ។ បទពិសោធន៍ជាអន្តរជាតិសំដៅដល់យុទ្ធសាស្ត្រជម្រើសផ្សេងៗ ដើម្បីដោះស្រាយការតាំងទីលំនៅក្រៅផ្លូវការ ដែលការរើទីលំនៅគឺជាយុទ្ធ-សាស្ត្រមួយ ។ ពុំមានការយោងនៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ចំពោះលទ្ធភាពនៃជម្រើសផ្សេងទៀត ឧទាហរណ៍ ការអភិវឌ្ឍ និងការបែងចែកដីនៅនឹងកន្លែង ។ ទោះបីជា ភាខ គូសបញ្ជាក់អំពីអភិក្រមដែលឯកភាពជាមួយរដ្ឋាភិបាល *"ក្នុងករណីអ្នកតាំងទីលំនៅក្រៅផ្លូវការ រួមទាំងអ្នកតាំងទីលំនៅខុសច្បាប់"*

ក៏ដោយ[១៣៥] ក៏ពុំមានការយោងនៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ចំពោះអភិក្រមនេះ និងរបៀបដែលវាទាក់ទងទៅនឹងការអនុវត្តស្ថានភាពទីមួយឡើយ ។

២០៣. **ក្រុមអធិការកិច្ចរកឃើញថា មានភាពមន្ទិលជាច្រើនទាក់ទងទៅនឹងរបៀបដែលក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញគួរត្រូវបានបង្កើតឡើង និងអនុវត្ត ។ ក្រុមអធិការកិច្ចរកឃើញថា ការរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ មានការខ្វះខាតបទប្បញ្ញត្តិដែលរំពឹងទុកនៅក្នុង OD ៤.៣០ ទាក់ទងទៅនឹង *"គោលការណ៍ធ្វើផែនការ ការរៀបចំស្ថាប័ន និងលក្ខណៈវិនិច្ឆ័យនៃការរៀបចំប្លង់"* ។**

២០៤. **ការពិចារណាអំពីបញ្ហាតាំងទីលំនៅឡើងវិញក្នុងអំឡុងពេលអនុវត្តគម្រោង ។** ក្រុមអធិការកិច្ចយល់ឃើញថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ មិនដែលត្រូវបានបង្កើតឡើងក្នុងអំឡុងពេលអនុវត្តគម្រោងឡើយ ។ ដូច្នេះ ការស៊ើបអង្កេតក៏បានផ្តោតផងដែរទៅលើហេតុផលដែលអាចមានសម្រាប់បញ្ហានេះ ។ គេបានរៀបចំជាឯកសារយ៉ាងច្រើនថា ទំនាស់ដីធ្លីរវាងរដ្ឋ និងប្រជាជន មានការកើនឡើងចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០ (សូមមើលកិច្ចពិភាក្សាបន្ថែមនៅក្នុងផ្នែក ង ខាងក្រោម) ។ ដោយសារហេតុផលនេះ គេរំពឹងថា បញ្ហានៃការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត និងការអនុវត្តដែលអាចធ្វើឡើងចំពោះក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ នឹងតម្រូវឱ្យមានការពិចារណាពីក្រុមការងាររបស់ LMAP ក៏ដូចជាថ្នាក់គ្រប់គ្រង ក្នុងអំឡុងពេលជាច្រើនឆ្នាំនៃការអនុវត្តគម្រោង ។

២០៥. ក្រុមអធិការកិច្ចរកឃើញថា បញ្ហានានាទាក់ទងទៅនឹងដីរដ្ឋ និងការតាំងទីលំនៅឡើងវិញ ត្រូវបានដោះស្រាយជាចម្បង នៅក្នុងកិច្ចពិភាក្សាក្នុងអំឡុងបេសកកម្មត្រួតពិនិត្យលើកទីមួយ និងទីពីរ (ខែ ឧសភា និងខែ តុលា ឆ្នាំ ២០០២) ។ ក្នុងអំឡុងបេសកកម្មលើកទីមួយ ធនាគារពិភពលោកបានលើកឡើងអំពីបញ្ហាលទ្ធភាព នៃការតាំងទីលំនៅឡើងវិញ ធ្វើឡើងនៅក្នុងទីតាំងសម្រាប់អាគារដែលបានស្នើឡើងសម្រាប់ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម

---

[១៣៥] កិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍទទួលស្គាល់ថា *"ទាំងធនាគារពិភពលោក ទាំងក្រសួងរៀបចំដែនដី ពុំមានឧត្តមភាពប្រៀបធៀប ក្នុងការដោះស្រាយអ្នកតាំងទីលំនៅក្រៅផ្លូវការ និងអ្នកតាំងទីលំនៅខុសច្បាប់ឡើយ ។ ជាការប្រសើរជាងសម្រាប់គម្រោងក្នុងការគាំទ្រក្រុមការងារអភិវឌ្ឍន៍ ដែលបច្ចុប្បន្នកំពុងធ្វើការនៅតាមមូលដ្ឋាន"* ។ កិច្ចព្រមព្រៀងស្តីពីឥណទានសម្រាប់ការអភិវឌ្ឍបានគូសបញ្ជាក់ថា *"កិច្ចព្រមព្រៀងត្រូវបាន ធ្វើឡើងជាមួយក្រសួង ទំនាក់ទំនង អំពីអភិក្រមដែលត្រូវប្រើប្រាស់នៅក្នុងករណីអ្នកតាំងទីលំនៅក្រៅផ្លូវការ រួមទាំង អ្នកតាំងទីលំនៅខុសច្បាប់ ។ គម្រោង : (ក) នឹងចេញប័ណ្ណកម្មសិទ្ធិដី ប្រសិនបើមានកិច្ចព្រមព្រៀងដោយរដ្ឋាភិបាលក្នុងការផ្តល់ដី ដែលត្រូវចុះបញ្ជីជូនអ្នកតាំងទីលំនៅក្រៅផ្លូវការ ។ (ខ) នឹងសម្របសម្រួលការផ្តល់សេវា និងការផ្តល់កម្មសិទ្ធិដី នៅពេលសាលាក្រុងកំពុងធ្វើការជាមួយក្រុមអភិវឌ្ឍន៍ ដើម្បីផ្តល់ដីជូនអ្នកតាំងទីលំនៅក្រៅ ផ្លូវការ តាមរយៈ កម្មវិធីចែករំលែកដី និង/ឬកម្មវិធីរើទីលំនៅ ផ្អែកលើគោលការណ៍ UNCHS និង (គ) នឹងមិនចេញប័ណ្ណកម្មសិទ្ធិ ប្រសិនបើពុំមានកិច្ចព្រមព្រៀងក្នុងការបែងចែកដីដល់អ្នកតាំងទីលំនៅក្រៅផ្លូវការ ឬតាមរយៈការចែករំលែកដី និង/ឬកម្មវិធីរើទីលំនៅ ។ គម្រោងនេះ បានបង្កើតនីតិវិធីសម្រាប់ត្រួតពិនិត្យ និងពិគ្រោះយោបល់ ដើម្បីធានាថា លក្ខខណ្ឌខាងលើត្រូវបានឯកភាព មុនពេលផ្តល់សេវាចុះបញ្ជី និងផ្តល់កម្មសិទ្ធិដីធ្លី"* ។ (PAD ទំព័រទី ២០)

និងសំណង់ (MLMUPC) ហើយឯកសារជំនួយស្មារតីគូសបញ្ជាក់ថា រដ្ឋាភិបាលនឹងធ្វើជំរឿនប្រជាជនដែលរស់នៅទីនោះ និងដាក់របាយការណ៍ជូនធនាគារពិភពលោកត្រឹមខែ កញ្ញា ឆ្នាំ ២០០២ ។ ក្រុមអធិការកិច្ចពុំបានរកឃើញឯកសារយោងណាមួយ អំពីរបាយការណ៍នេះឡើយ នៅក្នុងកំណត់ត្រាត្រួតពិនិត្យបន្តបន្ទាប់ ។

២០៦. បេសកកម្មលើកទីពីរ សង្កត់ធ្ងន់ទៅលើតម្រូវការក្នុងការកំណត់អាទិភាពការងារគោលនយោបាយទាក់ទងទៅនឹងការគ្រប់គ្រងដីរបស់រដ្ឋ ។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ១ជឡភច នឹងផ្តោតទៅលើវិស័យគោល-នយោបាយចំនួនប្រាំ ដែលក្នុងនោះរួមមាន ១ច ការចេញកម្មសិទ្ធិដីសម្រាប់ចិញ្ចើមផ្លូវថ្នល់ និងផ្លូវទឹក និង ១ច ការចុះបញ្ជីដីរដ្ឋ ដែលពាក់ព័ន្ធដោយផ្ទាល់សម្រាប់ការបកស្រាយស្ថានភាពក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ។ កង្វល់នានា ជាពិសេស កង្វក់ទាក់ទងនឹងការផ្តល់កម្មសិទ្ធិចំណីផ្លូវ ក្លាយជាប្រធានបទមួយនៅក្នុងអំឡុងបេសកកម្មត្រួតពិនិត្យលើកទីបីផងដែរ ។ ឯកសារជំនួយស្មារតីទីបីកត់សម្គាល់ថា បេសកកម្មនេះបានគូសបញ្ជាក់ថា គោលការណ៍ណែនាំផ្នែកសង្គម និងបរិស្ថានដែលបានឯកភាព ការពារសិទ្ធិរបស់បុគ្គលទាំងឡាយណាដែលកាន់កាប់ដីតាមចិញ្ចើមផ្លូវ មុនពេលរដ្ឋាភិបាលចេញបទបញ្ជាស្តីពីចំណីផ្លូវ ។ ដោយកត់សម្គាល់បញ្ហានេះម្តងទៀតនៅក្នុងឯកសារជំនួយស្មារតីទីបួនពីខែ មករា ឆ្នាំ ២០០៤ ថ្នាក់គ្រប់គ្រងបានបន្ថែមថា គោលនយោបាយស្តីពីការការផ្តល់កម្មសិទ្ធិចំពោះចិញ្ចើមថ្នល់ នឹងត្រូវបង្កើតឡើង និងអនុម័តដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងថា គោលនយោបាយនេះ ព្រមទាំងសេចក្តីព្រាងសារាចរមួយ នឹងត្រូវដាក់ជូននាយករដ្ឋមន្ត្រីត្រឹមថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៤ ។ បេសកកម្មលើកទីប្រាំ (បេសកកម្មពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិក្នុងខែ តុលា ឆ្នាំ ២០០៤) បានរាយការណ៍ថា កន្លងមកពុំមានការផ្តល់កម្មសិទ្ធិណាមួយចំពោះការពង្រីកចំណីផ្លូវឡើយ ហើយសារាចរនេះកំពុងស្ថិតក្រោមការរៀបចំប៉ុន្តែមិនទាន់បានបញ្ចប់នៅឡើយទេ ។

២០៧. ជាផ្នែកមួយនៃការរៀបចំបេសកកម្មពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិក្នុងខែ តុលា ឆ្នាំ ២០០៤ កម្រងសំណួរមួយស្តីពីការការពារត្រូវបានបង្កើតឡើង។ ការឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងសំណួរនានាមានភាពច្បាស់លាស់ ។ ឯកសារនេះគូសបញ្ជាក់ថា *"រដ្ឋាភិបាលមិនទាន់បានកំណត់គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងដីរដ្ឋនៅឡើយទេ"* និងថា *"LMAP ពុំមានអាណត្តិអនុវត្តការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តឡើយ ។ បច្ចុប្បន្ន LMAP ចូលរួមតែនៅក្នុងការផ្តល់កម្មសិទ្ធិដោយស្ម័គ្រចិត្តប៉ុណ្ណោះ ។ ក្នុងករណីមានជម្លោះកើតឡើងរវាងភាគីណាមួយ ការផ្តល់កម្មសិទ្ធិមិនត្រូវបានធ្វើឡើងឡើយ រហូតទាល់តែមានដំណោះស្រាយចំពោះបញ្ហានោះ"* ។ រដ្ឋាភិបាលក៏ប្រកាន់ជំហរច្បាស់លាស់ថា *"LMAP ពុំមានសិទ្ធិចេញសំណងក្នុងទម្រង់ណាមួយដែលបណ្តាលមកពីការរើទីលំនៅរបស់ប្រជាជនចេញពីចិញ្ចើមផ្លូវឡើយ ។ មានតែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ុណ្ណោះដែលមានយុត្តាធិការធ្វើការលើបញ្ហាទាំងនេះ"* ។

២០៨. ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិបានគូសបញ្ជាក់ថា ពុំមានផលប៉ះពាល់អវិជ្ជមានផ្នែកសង្គមនៃគម្រោងឡើយ ហើយក៏ពុំមានការពិចារណាណាមួយ ត្រូវបានធ្វើឡើងសម្រាប់គម្រោងដែលអាចធ្វើឱ្យប៉ះពាល់ដល់បរិស្ថានដែរ ។

របាយការណ៍នេះក៏រំលឹកដល់រដ្ឋាភិបាលដោយផ្ទាល់ថា *"ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញគ្រប់គ្រងលើរាល់ការយកដី ដែលបណ្តាលឱ្យប៉ះពាល់ដល់ប្រជាជន..."*[១៣៦] ។ នៅក្នុងឯកសារជំនួយស្មារតីក្រោយៗ គេកត់សម្គាល់ថា សេចក្តីព្រាងអនុក្រឹតសម្រាប់ការចុះបញ្ជីផ្លូវថ្នល់ និងដីដែលនៅជាប់ផ្លូវថ្នល់ បានពន្យារពេល ។ បញ្ហានៃការការពារ និងចិញ្ចើមផ្លូវ ត្រូវបានរួមបញ្ចូលគ្នានៅក្នុងអ្វីដែលត្រូវបានពណ៌នាថាជា "ការពិនិត្យឡើងវិញដោយឯករាជ្យលើច្បាប់ទាក់ទងនឹងដីធ្លី" ។ មកត្រឹមបេសកកម្មត្រួតពិនិត្យលើកទី ៩ មានការរីកចម្រើនតិចតួចទៅលើការសិក្សាដោយឯករាជ្យលើដំណោះស្រាយក្រៅផ្លូវការអំពីការប្រើប្រាស់ដី ។

២០៩. ក្នុងអំឡុងបេសកកម្មត្រួតពិនិត្យលើកទីប្រាំបួន ក្នុងខែ មិថុនា ឆ្នាំ ២០០៧ ឯកសារជំនួយស្មារតីរាយការណ៍ថា *"គម្រោងមិនទាន់បានទទួល និងមិនរំពឹងទុកអំពីការតវ៉ាណាមួយចំពោះការបណ្តេញចេញ ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ឬការធ្វើលទ្ធកម្មដី ដែលជាលទ្ធផលនៃការផ្តល់កម្មសិទ្ធិឡើយ"* ។ ឯកសារជំនួយស្មារតីបានបន្តគូសបញ្ជាក់ថា *"ដូចដែលត្រូវបានរៀបចំ មានតែដីគ្មានទំនាស់ប៉ុណ្ណោះនឹងត្រូវបានចេញប័ណ្ណកម្មសិទ្ធិជូន ចំណែកឯដីផ្សេងៗទៀត នឹងត្រូវដោះស្រាយជាដំបូងដោយភាគីពាក់ព័ន្ធ និង/ឬតាមរយៈស្ថាប័នពាក់ព័ន្ធ មុនពេលប័ណ្ណកម្មសិទ្ធិត្រូវបានចេញជូន"* ។ យោងតាមឯកសារជំនួយស្មារតី ទោះបីជាមិនមានការទទួលបានការតវ៉ាណាមួយក៏ដោយ ក៏ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ត្រូវបានរៀបចំឡើងសម្រាប់គម្រោងដែលផ្តល់គោលការណ៍ណែនាំនានាសម្រាប់បុគ្គលដែលទទួលរងផលប៉ះពាល់ពីគម្រោង *"ប្រសិនបើត្រូវបានតម្រូវ"* ។ ពុំមានសេចក្តីលម្អិតបន្ថែមអំពីថាតើពេលណាប្រការនេះកើតឡើងនោះទេ ពោលគឺការផ្តល់ការពិនិត្យចំពោះស្ថានភាពនានានៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ។ ឯកសារជំនួយស្មារតីបានរាយការណ៍ជាថ្មីម្តងទៀតអំពីភាពអនុលោមតាមគោលការណ៍ណែនាំផ្នែកបរិស្ថាន និងសង្គមនៃគម្រោង ។

២១០. របាយការណ៍ត្រួតពិនិត្យសម្រាប់គម្រោង មិនបានរាយការណ៍អំពីការដាក់បញ្ចូលអ្នកជំនាញផ្នែកការពារ ទៅក្នុងបេសកកម្មណាមួយក្នុងចំណោមបេសកកម្មត្រួតពិនិត្យទាំងនេះឡើយ លើកលែងតែបេសកកម្មលើកទីមួយក្នុងខែឧសភា ឆ្នាំ ២០០២ ។ ការលើកឡើងបន្ទាប់តែម្តងគត់អំពីការដាក់បញ្ចូលការពិនិត្យឡើងវិញលើការការពារ រួមទាំងអ្នកជំនាញផ្នែកការពារ គឺធ្វើឡើងក្នុងអំឡុងពេលរៀបចំបេសកកម្មត្រួតពិនិត្យលើកទី ១០ និងទី ១១ ។ ដូចមានបង្ហាញនៅក្នុងបញ្ជីឈ្មោះអ្នកចូលរួមសម្រាប់បេសកកម្ម អ្នកជំនាញដែលត្រូវបានកំណត់ថា នឹងចូលរួមនៅក្នុងបេសកកម្មត្រួតពិនិត្យលើកទី ១០ និងទី ១១ ទីបញ្ចប់បែរជាមិនបានចូលរួមនៅក្នុងបេសកកម្មនោះទៅវិញ ។

២១១. **ក្រុមអធិការកិច្ចរកឃើញថា ការយកចិត្តទុកដាក់របស់ថ្នាក់គ្រប់គ្រងចំពោះផលវិបាកផ្នែកសង្គមនៃការផ្តល់កម្មសិទ្ធិដីរួមទាំងការបណ្តេញចេញដែលអាចកើតមាន ពុំមានលក្ខណៈជាប្រព័ន្ធទេ និងទទួលរងកង្វះការយកចិត្តទុកដាក់ពីសំណាក់អ្នកជំនាញផ្នែកការពារសង្គម ។ វាគឺជាក្តីកង្វល់ដែលបេសកកម្មត្រួតពិនិត្យជាច្រើនបានសន្និដ្ឋានថា ពុំមានស្ថានភាពណាមួយដែលតម្រូវឱ្យមានការអនុវត្តការការពារផ្នែកសង្គម និងបរិស្ថានឡើយ រួមទាំង ក្របខ័ណ្ឌ**

[១៣៦] ឯកសារជំនួយស្មារតីទី ៦ ឧបសម្ព័ន្ធ ឃ ការការពារផ្នែកសង្គម ថ្ងៃទី ២៧ ខែ កញ្ញា - ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤

**គោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ប្រសិនបើគ្មានការត្រួតពិនិត្យយ៉ាងល្អិតល្អន់អំពីបញ្ហាទេនោះ ។ ក្រុមអធិការកិច្ចរកឃើញភស្តុតាងនៅក្នុងកំណត់ត្រាត្រួតពិនិត្យដែលថ្នាក់គ្រប់គ្រង នៅក្នុងឱកាសជាច្រើន បានលើកបញ្ហាអំពីការគ្រប់គ្រងដីរដ្ឋដែលអាចពាក់ព័ន្ធ សម្រាប់ការអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ។ ក្រុមអធិការកិច្ចបានកោតសរសើរធនាគារពិភពលោក ដែលបានតាមដានបញ្ហាគោលនយោបាយដ៏ពិបាកនេះ នៅក្នុងបរិបទកម្ពុជា ដែលមានភាពរសើបផ្នែកនយោបាយ និងស្មុគស្មាញ ។ ប៉ុន្តែ ការតាមដានបញ្ហាទាំងនេះ មិនមានលក្ខណៈគ្រប់គ្រាន់ទេ និងរួមចំណែកបង្កឱ្យមានបញ្ហាទាំងឡាយនៅក្នុងតំបន់បឹងកក់ ។ ប្រការនេះមិនមានភាពអនុលោមជាមួយបទប្បញ្ញត្តិនៃ OP/BP ១៣.០៥ ស្តីពីការត្រួតពិនិត្យគម្រោងឡើយ ។** ទោះបីជាក្រុមអធិការកិច្ចបានរកឃើញថា អ្នកជំនាញផ្នែកដីធ្លីផ្សេងៗគ្នាយ៉ាងហោចណាស់ចំនួន ១៧ រូប បានធ្វើដំណើរមកប្រទេសកម្ពុជា ជាផ្នែកនៃបេសកកម្មត្រួតពិនិត្យផ្សេងៗរបស់គម្រោងក៏ដោយ ក៏បញ្ហាទាំងនេះមិនដែលត្រូវបានដោះស្រាយឡើយ ។

២១២. **ភាពអាចអនុវត្តបាននៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញនៅក្នុងករណីតំបន់បឹងកក់ ។** ទាក់ទងទៅនឹងបញ្ហាថាតើស្ថានភាពនៅតំបន់បឹងកក់ស្ថិតនៅក្រោមស្ថានភាពមួយ ឬច្រើន ដែលកំណត់ដោយស្ថានភាពនៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញឬយ៉ាងណា ក្រុមអធិការកិច្ចបានរកឃើញថា ផ្អែកលើការអង្កេតខាងលើការបណ្តេញចេញពីដីរដ្ឋត្រូវបានធ្វើឡើង និងថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ គួរត្រូវបានអនុវត្តនៅក្នុងតំបន់បឹងកក់ ។ ជាងនេះទៅទៀត ក្រុមអធិការកិច្ចបានកត់សម្គាល់ថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញពុំបានបង្ហាញភាពខុសគ្នាអំពីភាពអាចអនុវត្តបានរបស់វា រវាងដីឯកជនរបស់រដ្ឋ និងដីសាធារណៈរបស់រដ្ឋ ដូច្នេះហើយ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ គួរត្រូវបានអនុវត្តនៅក្រោមគម្រោង ឡាំភ ដោយមិនគិតអំពីលក្ខណៈផ្លូវច្បាប់នៃដីរដ្ឋដែលមានទំនាស់ឡើយ ។

២១៣. ក្រុមអធិការកិច្ចក៏បានកត់សម្គាល់ថា ស្ថានភាពទីបី ដែលមានបញ្ជាក់នៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ក៏ហាក់ដូចជាអនុវត្តផងដែរ ។ ការអភិវឌ្ឍកាលពីពេលថ្មីៗ និងផែនការសម្រាប់តំបន់បឹងកក់ បានបង្ហាញថា ចំណីផ្លូវដែលមានស្រាប់សម្រាប់ផ្លូវរថភ្លើងកាត់តាមតំបន់នេះ នឹងត្រូវពង្រីក និងថា ផ្លូវថ្នល់ដែលមានស្រាប់ក៏នឹងត្រូវបានពង្រីកផងដែរ ។

២១៤. ក្រុមអធិការកិច្ចយល់ឃើញថា ការបកស្រាយរបស់រដ្ឋាភិបាលអំពីភាពអាចអនុវត្តបាននៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ គឺថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ មិនត្រូវបានបង្កើតឡើងនៅក្នុងករណីតំបន់បឹងកក់ឡើយ ដោយសារដីនេះមិនត្រូវបានផ្តល់កម្មសិទ្ធិក្នុងឈ្មោះរបស់រដ្ឋ ។ ដូចបានកត់សម្គាល់ខាងដើមនៅក្នុងជំពូកនេះ ថ្នាក់គ្រប់គ្រងបានគូសបញ្ជាក់ថា ដំណើរការវិនិច្ឆ័យពេញលេញមិនត្រូវបានអនុវត្តសម្រាប់តំបន់បឹងកក់ឡើយ ហើយថា LMAP ក៏មិនបានចូលរួមដោយផ្ទាល់នៅក្នុងការចេញប័ណ្ណកម្មសិទ្ធិណាមួយជូនរដ្ឋ ឬទីភ្នាក់ងារសាធារណៈណាមួយសម្រាប់ដីនៅក្នុងតំបន់បឹងកក់ដែរ ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមអធិការកិច្ច យល់

ស្របជាមួយថ្នាក់គ្រប់គ្រង និងអ្នកស្នើសុំថា ដោយសាររដ្ឋាភិបាលចាត់វិធានការផ្លូវការ ដើម្បីធ្វើនិយតកម្ម ផ្នែកនានានៃតំបន់បឹងកក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ ការកំណត់ដីនោះជាដីរបស់រដ្ឋបានកើតឡើង នៅក្នុងការអនុវត្តជាក់ស្តែង ។ ដូច្នេះ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញគួរត្រូវបានអនុវត្ត ហើយផែនការតាំងទីលំនៅឡើងវិញសម្រាប់តំបន់បឹងកក់ គួរត្រូវបានរៀបចំឡើងឱ្យបានទាន់ពេលវេលា មុនការបណ្តេញចេញ ដែលបណ្តាលមកពីសកម្មភាពគម្រោងដែលត្រូវបានអនុវត្ត ។

២១៥. វាហាក់ដូចជាមានភាពច្បាស់លាស់ពីការពិនិត្យឡើងវិញលើរបាយការណ៍ត្រួតពិនិត្យថា ព្រឹត្តិការណ៍ទាំងឡាយដែលបានលាតត្រដាងនៅក្នុងតំបន់បឹងកក់ចាប់តាំងពីឆ្នាំ ២០០៧ មិនត្រូវបានធនាគារពិភពលោកមើលឃើញថាជាបរាជ័យដ៏ធ្ងន់ធ្ងរនៃគម្រោង រហូតដល់ពេលយ៉ាងយូរក្រោយមក នៅចុងឆ្នាំ ២០០៨ និងដើមឆ្នាំ ២០០៩ នៅពេលអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានចាប់ផ្តើមលើកឡើងអំពីកង្វល់របស់ពួកគេជាមួយបុគ្គលិកធនាគារពិភពលោក ហើយការបណ្តេញចេញចំពោះសហគមន៍ផ្សេងៗទៀតនៅទីក្រុងភ្នំពេញកំពុងកើតមានឡើង ។ ថ្នាក់គ្រប់គ្រងបានបញ្ជាក់នៅក្នុងការឆ្លើយតបថា ក្នុងខែ មិថុនា ឆ្នាំ ២០០៨ បេសកកម្មពហុម្ចាស់ជំនួយ រួមទាំង បុគ្គលិកធនាគារពិភពលោកបានធ្វើទស្សនកិច្ចទៅកាន់តំបន់បឹងកក់ និងត្រូវបានជូនដំណឹងដោយបុគ្គលិកគម្រោងថា នៅក្នុងតំបន់បឹងកក់ ប្រជាជនពុំបានទទួលប័ណ្ណកម្មសិទ្ធិឡើយ ពីព្រោះដីនោះគឺជាដីសាធារណៈរបស់រដ្ឋ ។ ថ្នាក់គ្រប់គ្រងបានបន្ថែមទៀតថា ទោះបីព័ត៌មានអំពីការជួលដីទៅឱ្យអ្នកអភិវឌ្ឍន៍ឯកជនត្រូវបានគេដឹងញ្ចក៏ដោយ *"ពុំមានអ្នកណាម្នាក់ ទោះជាមកពីធនាគារពិភពលោក ឬដៃគូអភិវឌ្ឍន៍ក្តី បានរកឃើញទំនាក់ទំនងរវាងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តដែលអាចកើតមានឡើង និងគម្រោងនៅពេលនោះឡើយ"*[១៣៧] ។

២១៦. ទាល់តែក្នុងរយៈពេលឈានដល់ការបង្ហាញសំណើសុំអធិការកិច្ច ទើបធនាគារពិភពលោកយល់ និងទទួលស្គាល់ថាការបណ្តេញចេញនៅក្នុងតំបន់បឹងកក់មានជាប់ទាក់ទងទៅនឹងសកម្មភាពអនុវត្តន៏របស់ LMAP និងថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ នឹងត្រូវបានអនុវត្តចំពោះការផ្លាស់ទីលំនៅរបស់ប្រជាជននៅតំបន់បឹងកក់ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលធនាគារពិភពលោកលើកយករឿងនេះដាក់ជូនរដ្ឋាភិបាល និងបានស្នើការផ្អាករួមគ្នាចំពោះការបើកប្រាក់ រដ្ឋាភិបាលបានលុបចោលសមតុល្យនៃឥណទានដែលមិនទាន់បើកនៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

**២១៧. ក្រុមអធិការកិច្ចបានរកឃើញថា បរាជ័យរបស់ថ្នាក់គ្រប់គ្រងក្នុងការធានាឱ្យមានការអនុវត្តក្របខ័ណ្ឌគោល-នយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ពុំអនុលោមតាម OD ៤.៣០ និង OP/BP ១៣.០៥ ស្តីពីការត្រួតពិនិត្យគម្រោង ។**

[១៣៧] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង កថាខ័ណ្ឌ ៥៥

២១៨. **ដំណើរការនៃការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត :** ដូចបានកត់សម្គាល់ខាងលើ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ គឺជាក្របខ័ណ្ឌមួយដែលបង្ហាញអំពីគោលការណ៍ និងនីតិវិធីដែលត្រូវអនុវត្តតាម ដើម្បីផ្តល់សំណង និងជួយប្រជាជនដែលអាចត្រូវបានផ្លាស់ទីលំនៅក្រោមគម្រោងនេះ ដោយមានគោលបំណងធានាថាពួកគេអាចកែលម្អ ឬយ៉ាងហោចណាស់ស្តារជីវភាពរស់នៅរបស់ខ្លួនបាន ។ នៅក្នុងស្ថានភាពដែលក្របខ័ណ្ឌគោល-នយោបាយស្តីពីការតាំងទីលំនៅឡើងវិញត្រូវបានបង្កើតឡើង ផែនការសកម្មភាពស្តីពីការតាំងទីលំនៅឡើងវិញជាក់លាក់នៅនឹងកន្លែង (RAP) នឹងត្រូវតែរៀបចំឡើង ។ យោងតាមក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ផែនការតាំងទីលំនៅឡើងវិញអាចជាផែនការមួយផ្នែក ឬទាំងស្រុង អាស្រ័យលើចំនួនប្រជាជនដែលរងផលប៉ះពាល់ ដែលមានចំនួនតិចជាង ឬច្រើនជាង ២០០ ។

២១៩. ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ បង្ហាញអំពីគោលការណ៍សម្រាប់ដំណើរការរៀបចំផែនការសកម្មភាពតាំងទីលំនៅឡើងវិញ និងសម្រាប់ការអនុវត្តការបណ្តេញចេញ និងការរើទីលំនៅ ។ គោលការណ៍សំខាន់ៗក្នុងចំណោមគោលការណ៍ទាំងនេះ គឺ :

- ការពិគ្រោះយោបល់ក្នុងទម្រង់ជាកិច្ចប្រជុំថ្នាក់ភូមិ មុនពេលដំណើរការវិនិច្ឆ័យចាប់ផ្តើម ដើម្បីកំណត់ផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរផ្នែកសង្គមដែលអាចមានពីសកម្មភាពផ្តល់កម្មសិទ្ធិដី ។
- ការអង្កេតជាមូលដ្ឋានមួយដែលគ្របដណ្តប់គ្រប់គ្រួសារទាំងអស់ ដែលទទួលរងផលប៉ះពាល់ នឹងត្រូវធ្វើឡើង ។
- ប្រជាជនដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង (PAP) ចូលរួមនៅគ្រប់ដំណាក់កាលផ្សេងៗនៃការធ្វើផែនការ និងការអនុវត្ត ។
- ប្រជាជនដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង នឹងត្រូវបានជូនដំណឹងត្រឹមត្រូវអំពីបទប្បញ្ញត្តិនៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញនៅឯកិច្ចប្រជុំសាធារណៈនានា ។
- ការរៀបចំកាលវិភាគសម្រាប់សំណង និងការស្តារនីតិសម្បទា ដែលត្រូវបញ្ចប់រួចរាល់ជាទីពេញចិត្ត មុនពេលធនាគារពិភពលោកផ្តល់ការយល់ព្រម ។
- ក្រោយពីការផ្តល់សំណង ប្រជាជននីមួយៗដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ត្រូវចុះហត្ថលេខាលើលិខិតទទួលយក ។
- ប្រជាជនដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង មានលទ្ធភាពទទួលបាននីតិវិធីបណ្តឹងសារទុក្ខក្នុងមូលដ្ឋានដោយឥតគិតថ្លៃ ។

២២០. ដើម្បីត្រៀមយថាភាពនៃការអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ គេបានគូសបញ្ជាក់ថាសមត្ថភាពផ្នែកស្ថាប័ននឹងត្រូវតែអភិវឌ្ឍនៅក្នុងគម្រោង តាមរយៈ :

- ការបណ្តុះបណ្តាលបុគ្គលិកគម្រោងអំពីបញ្ហាតាំងទីលំនៅឡើងវិញ ។

- ការបង្កើតក្រុមការងារពិសេសនៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត ដើម្បីណែនាំ និងពិនិត្យតាមដានសកម្មភាពតាំងទីលំនៅឡើងវិញ ។
- ការធានាថា បញ្ហាតាំងទីលំនៅឡើងវិញ គឺជាផ្នែកមួយនៃការពិនិត្យតាមដានគម្រោងជាទៀងទាត់ ។

២២០. ក្រុមអធិការកិច្ចបានដឹងអំពីការពិតដែលថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញមិនដែលត្រូវបានបង្កើតឡើងជាផ្លូវការនៅក្នុងករណីតំបន់បឹងកក់នោះទេ ដូច្នេះហើយ ថ្នាក់គ្រប់គ្រងគម្រោងមិនបានចូលរួមនៅក្នុងដំណើរការនៃការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយក្រុមអធិការកិច្ចពុំបានរកឃើញភស្តុតាងណាមួយនៃកិច្ចប្រឹងប្រែងរបស់គម្រោង ដើម្បីបង្កើតសមត្ថភាពផ្នែកស្ថាប័ន ទូទៅក្នុងការដោះស្រាយបញ្ហានៃការតាំងទីលំនៅឡើងវិញ ដូចមានបង្ហាញខាងលើឡើយ ក្នុងករណីដែលក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញនឹងត្រូវបានបង្កើតឡើង ។ ថ្នាក់គ្រប់គ្រងក៏បានកត់សម្គាល់អំពី *"អវត្តមានយ៉ាងច្បាស់ នៃកិច្ចពិភាក្សាលម្អិតអំពីការសម្រេចបាននៅក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ក្នុងអំឡុងពេលរៀបចំ ឬក្នុងអំឡុងពេលអនុវត្តន៍"*[១៣៨] ។

២២១. ដូចមានពណ៌នានៅក្នុងជំពូកទី ២ ក្រុមអធិការកិច្ច នៅក្នុងអំឡុងការចុះទស្សនកិច្ចតាមមូលដ្ឋានរបស់ខ្លួន បានទទួលសក្ខីភាពជាច្រើនពីប្រជាជនដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ដោយរៀបរាប់អំពីដំណើរការនៃការតាំងទីលំនៅឡើងវិញ ដែលមិនបំពេញតាមបទដ្ឋានរំពឹងទុកនៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ឬឆ្លុះបញ្ចាំងអំពីបទដ្ឋានដែលទទួលស្គាល់យ៉ាងទូលំទូលាយជាអន្តរជាតិឡើយ (ដូចជា បទដ្ឋានដែលមានចែងនៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សដែលពាក់ព័ន្ធ) ។ ពុំមានដំណើរការបែបពិគ្រោះយោបល់ និងបែបចូលរួមឡើយ ការងារស៊ីវិលបានចាប់ផ្តើមជាយូរយា មុនដំណើរការតាំងទីលំនៅឡើងវិញត្រូវបានអនុវត្តគួរជាទីពេញចិត្ត ហើយប្រជាជនដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ទទួលរងនូវសម្ពាធក្នុងការចាកចេញពីផ្ទះសម្បែងរបស់ពួកគេដោយគ្មានសិទ្ធិទទួលបាននីតិវិធីបណ្តឹងសារទុក្ខណាមួយឡើយ ។

២២២. **ភាពមានសិទ្ធិដែលផ្តល់ជូនប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅពីតំបន់បឹងកក់:** ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ជាទូទៅ បង្ហាញអំពីអ្នកណាមានសិទ្ធិទទួលបានសំណង ។ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ រួមបញ្ចូលប្រជាជនដែលបាត់បង់ដី និងរចនាសម្ព័ន្ធលំនៅដ្ឋាន ប្រជាជនដែលបាត់បង់ដីកសិកម្ម អ្នករស់នៅដែលបានជួលផ្ទះ ឬដី និងប្រជាជនដែលបាត់បង់អាជីវកម្ម ។ ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញបានកំណត់ប្រភេទផ្សេងៗទៀតនៃសំណង ផ្អែកលើប្រភេទនៃការបាត់បង់ ។

២២៣. ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញក៏បានគូសបញ្ជាក់ថា សំណងនឹងត្រូវបានផ្តល់ជូន តាមតម្លៃផ្លាស់ប្តូរ ដែលត្រូវបានកំណត់ថាជា *"ចំនួនទឹកប្រាក់ដែលគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរទ្រព្យសម្បត្តិដែលបាត់បង់ និងតម្លៃមុខរបរ ។ នៅក្នុងការវាយតម្លៃនេះ ការរំលស់ថ្លៃរចនាសម្ព័ន្ធ និងទ្រព្យសម្បត្តិ មិនគួរត្រូវបានពិចារណា ។*

[១៣៨] ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង កថាខ័ណ្ឌ ៩២

*សម្រាប់ការបាត់បង់ដែលមិនអាចវាយតម្លៃ ឬទូទាត់សំណងយ៉ាងងាយស្រួលជាទឹកប្រាក់ ការព្យាយាមនានាត្រូវបានធ្វើឡើងដើម្បីបង្កើតលទ្ធភាពទទួលបានធនធាន និងឱកាសរកចំណូលសមមូល និងដែលអាចទទួលយកបានផ្នែកវប្បធម៌"* ។ យោងតាមក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ នៅពេលដែលច្បាប់ក្នុងស្រុកមិនអាចបំពេញតាមបទដ្ឋាននៃសំណងតាមតម្លៃផ្លាស់ប្តូរគ្រប់ចំនួន សំណងត្រូវបានបំពេញបន្ថែមដោយវិធានការបន្ថែមដែលចាំបាច់ដើម្បីបំពេញតាមបទដ្ឋាននៃតម្លៃផ្លាស់ប្តូរ ។

២២៥. ដោយឡែក សំណងដែលត្រូវផ្តល់ជូន រួមមាន :

- សំណងតាមតម្លៃផ្លាស់ប្តូរសម្រាប់ផ្ទះសម្បែង និងរចនាសម្ព័ន្ធដែលទទួលរងផលប៉ះពាល់ដទៃទៀត ដោយមិនកាត់បន្ថយថ្លៃរំលស់ ឬសម្ភារៈដែលបានស្រោចស្រង់សម្រាប់ផ្ទះសម្បែង និងរចនាសម្ព័ន្ធដទៃទៀតឡើយ ។
- សម្រាប់ដីកសិកម្ម សំណងជាដី សម្រាប់ដីដែលមានសមត្ថភាពផលិតសមមូល ។
- ការផ្លាស់ប្តូរទីតាំង/ដីលំនៅដ្ឋានដែលមានទំហំសមមូល ដែលអាចទទួលយកបានចំពោះប្រជាជនដែលទទួលផលប៉ះពាល់ ។
- ការផ្ទេរ និងប្រាក់ឧបត្ថម្ភសម្រាប់ការរស់រាន ប្រសិនបើសមស្រប ។

២២៦. ក្រុមអធិការកិច្ចបានកត់សម្គាល់ថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ក្នុងចំណោមគោលការណ៍ និងវត្ថុបំណងរបស់វា រៀបរាប់អំពីសិទ្ធិក្នុងការស្តារមធ្យោបាយចិញ្ចឹមជីវិត ប៉ុន្តែពុំបានផ្តល់ព័ត៌មានលម្អិតអំពីជម្រើសរកចំណូល ដែលអាចមានចំពោះប្រជាជន ដែលត្រូវបានផ្លាស់ទីលំនៅឡើយ ។ ក្នុងករណីដែលហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដូចជា សាលារៀន រោងចក្រ ប្រភពទឹក ផ្លូវថ្នល់ ប្រព័ន្ធលូ ឬបណ្តាញផ្គត់ផ្គង់អគ្គិសនី ទទួលរងការខូចខាត គម្រោងត្រូវធានាថា ការខូចខាតទាំងនេះនឹងត្រូវស្តារ និងជួសជុលឡើងវិញតាមករណីនីមួយៗ ដោយសហគមន៍ពុំរ៉ាប់រងលើចំណាយឡើយ យោងតាមក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ។

២២៧. ក្រុមអធិការកិច្ចបានចុះទស្សនកិច្ចទីកន្លែងតាំងទីលំនៅឡើងវិញ ដែលប្រជាជនខ្លះមកពីតំបន់បឹងកក់ត្រូវបានរើទីលំនៅ ។ ក្រុមអធិការកិច្ចក៏បានឃើញថា ស្ថានភាពទីតាំងមានបទដ្ឋានទាបជាងយ៉ាងច្រើន ប្រៀបទៅនឹងគោល-នយោបាយស្តីពីការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តរបស់ធនាគារពិភពលោក ។ ទោះបីជាមានសាលារៀន មន្ទីរពេទ្យ អគ្គិសនី និងទឹកក៏ដោយ ក៏មានការត្អូញត្អែរអំពីលទ្ធភាពទទួលបានសេវាទាំងនេះផងដែរ ។ ទោះបីជាយ៉ាងណាក្តី ការត្អូញត្អែរចម្បងគឺថា ទីកន្លែងតាំងទីលំនៅឡើងវិញនៅឆ្ងាយពេកពីប្រភពរកចំណូលមុនរបស់ពួកគេ និងពុំមានឱកាស រកចំណូលផ្សេងគ្រប់គ្រាន់នៅឯ ឬក្បែរទីកន្លែងតាំងទីលំនៅឡើងវិញ ។ ផ្សារមួយផ្តល់នូវសេវា និង មធ្យោបាយចិញ្ចឹម ជីវិតជាមូលដ្ឋាន ប៉ុន្តែចំណូល ជាទូទៅ មានចំនួនទាបជាងខ្លាំង ដោយសារប្រជាជនភាគច្រើនត្រូវបង្ខំចិត្តចំណាយពេលវេលាយ៉ាងច្រើន និងធនធានខ្សត់ខ្សោយទៅលើការធ្វើដំណើរទៅកាន់កន្លែងធ្វើការនៅទីក្រុង ។

២២៨. ប្រជាជនជាច្រើនក៏បានត្អូញត្អែរអំពីគុណភាព និងប្លង់លំនៅដ្ឋានដែលផ្ដល់ឱ្យ ។ ដោយសារវាជាផ្ទះល្វែង ពួកគេមិនអាចពង្រីកចំហៀងផ្ទះបានឡើយ ហើយដោយសារផ្ទះទាំងនេះពុំមានគ្រឹះរឹងមាំ គេមិនអាចសង់បន្ថែមជាន់ទីពីរបាននោះទេ ។ ជាចុងក្រោយ ប្រជាជនជាច្រើនមិនត្រូវបានផ្ដល់ឱ្យនូវកម្មសិទ្ធិពេញលេញចំពោះផ្ទះថ្មីរបស់ពួកគេឡើយ ហើយប្រជាជនខ្លះមិនប្រាកដអំពីថាតើពួកគេកាន់កាប់សិទ្ធិស្នាក់នៅប្រភេទអ្វីឡើយ ។ ក្រុមអធិការកិច្ចត្រូវបានជូនដំណឹងថា គ្រួសារជាច្រើនបានចាកចេញពីទីកន្លែងតាំងទីលំនៅឡើងវិញ ហើយបានត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ ដើម្បីស្តារជីវភាពរបស់ខ្លួន ហើយផ្ទះជាច្រើនខ្នងដែលមានដាក់ផ្លាក "សម្រាប់លក់" និងលេខទូរស័ព្ទ គឺជាសក្ខីភាពនៃកង្វះប្រជាប្រិយភាពនៃតំបន់របស់គ្រួសារដែលតាំងទីលំនៅឡើងវិញ ។

២២៩. ភស្តុតាងនៃរឿងរ៉ាវខ្លីៗបានបង្ហាញថា តម្លៃលក់ឡើងវិញនៃផ្ទះល្វែងនៅក្នុងតំបន់តាំងទីលំនៅឡើងវិញ ក្នុងករណីខ្លះ ទាបត្រឹម ៦០០០ ដុល្លារអាមេរិក ។ តម្លៃនេះទាបជាង ៨.០០០ ដុល្លារអាមេរិក ដែលត្រូវបានផ្ដល់ជូនចំពោះប្រជាជនទាំងឡាយដែលទទួលយកសំណង ហើយសំណងនេះទៀតសោត គឺមានតម្លៃទាបជាងទីផ្សារយ៉ាងខ្លាំងនៅក្នុងកណ្ដាលក្រុងភ្នំពេញ ដែលដីត្រូវបានរាយការណ៍ថាមានតម្លៃខ្ពស់រហូតដល់ ៣.០០០ ដុល្លារអាមេរិកក្នុងមួយម៉ែត្រការ៉េ ។ ប្រការនេះឆ្លុះបញ្ចាំងអំពីតម្លៃទីផ្សារប្រហែល ១៥០.០០០ ដុល្លារអាមេរិក សម្រាប់ដីដែលមានទំហំ ៥០ ម៉ែត្រការ៉េនៅក្នុងតំបន់បឹងកក់ ។ ភាពខុសគ្នានេះជួយពន្យល់អំពីកម្រិតដែលប្រជាជនមានអារម្មណ៍ថា ពួកគេត្រូវបានបោកប្រាស់ចំពោះសិទ្ធិរបស់ខ្លួន ។

២៣០. ជម្រើសទីបីដែលផ្ដល់ជូនដោយអ្នកអភិវឌ្ឍន៍ គឺការទទួលយកផ្ទះថ្មីនៅនឹងកន្លែងដែលមានប្រភេទស្រដៀងទៅនឹងផ្ទះល្វែងនៅកន្លែងអភិវឌ្ឍន៍ឡើងវិញមួយទៀត ដែលគេស្គាល់ថា បុរីកីឡា ។ ទោះបីជាយ៉ាណាក៏ដោយ ប្រជាជននៅ តំបន់បឹងកក់បានបដិសេធជម្រើសនេះ មួយផ្នែក ដោយសារពួកគេមិនចូលចិត្តប្លង់បុរីកីឡា ប៉ុន្តែភាគច្រើន ដោយសារពួកគេចាំបាច់ត្រូវរើចេញរយៈពេលបួនឆ្នាំទៅរស់នៅផ្ទះជួល ដោយចំណាយផ្ទាល់ខ្លួន និងមិនទុកចិត្តអ្នកអភិវឌ្ឍន៍ក្នុងការគោរពតាមការសន្យារបស់ពួកគេ ក្រោយពីផុតរយៈពេលនោះ ។



**រូបភាពទី ៥ : កន្លែងតាំងទីលំនៅឡើងវិញ ដំណាក់ទ្រយឹង ចម្ងាយប្រហែល ២០ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ**

២៣១. ថ្នាក់គ្រប់គ្រងបានគូសបញ្ជាក់នៅក្នុងការឆ្លើយតបរបស់ខ្លួនថា ទោះបីជាខ្លួនមិនអាចឈានដល់ការសន្និដ្ឋានអំពីភាពគ្រប់គ្រាន់នៃកញ្ចប់ដែលផ្តល់ដោយរដ្ឋាភិបាលក៏ដោយ ក៏ប្រជាជនដូចជាទទួលបានតិចជាង ប្រសិនបើសិនគេអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ។ ក្រុមអធិការកិច្ចក៏បានដឹងក្នុងអំឡុងបេសកកម្មថា ប្រជាជនដែលទទួលរងផលប៉ះពាល់មួយចំនួនយល់ព្រមទទួលយកទឹកប្រាក់សរុប និងចាកចេញពីទីតាំង ។ ពុំមានយន្តការតាមដានពួកគេ ត្រូវបានបង្កើតឡើងឡើយ ។ ប្រជាជនជាច្រើនដែលត្រូវបានបណ្តេញចេញ អះអាងថា ពួកគេមិនទាំងបានទទួលភាពមាន សិទ្ធិពេញលេញរបស់ខ្លួនផង ។

២៣២. ការខូចខាតដែលប្រជាជនទទួលរងដោយសារការបណ្តេញចេញ និងការផ្លាស់ទីលំនៅក្រោយមក ដែលមិនបំពេញតាមបទដ្ឋាន ដែលមានចែងនៅក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ គឺមានភាពច្បាស់លាស់ចំពោះក្រុមអធិការកិច្ច។ ក្រុមអធិការកិច្ចពុំបានរកឃើញកំណត់ត្រាណាមួយថា ថ្នាក់គ្រប់គ្រងធនាគារពិភពលោកបានលើកឡើងអំពីបញ្ហានេះជាមួយរដ្ឋាភិបាល ឬបុគ្គលិកគម្រោងឡើយ រហូតដល់ឆ្នាំ ២០០៩ នៅពេលស្ថានភាពមានភាពធ្ងន់ធ្ងរដែលមិនអាចជួសជុលបាន ។ ក្រុមអធិការកិច្ចបានដឹងថា មានប្រជាជនជាង ៦៨០០ គ្រួសារដែលត្រូវបានបណ្តេញចេញ ផ្លាស់ទីលំនៅ ឬស្ថិតក្រោមការគំរាមកំហែងនៃការបណ្តេញចេញនៅក្នុងខេត្តនានានៃគម្រោង ។

២៣៣. **ជាទូទៅ ក្រុមអធិការកិច្ចយល់ឃើញថា ថ្នាក់គ្រប់គ្រងធនាគារគួរបានរកឃើញបញ្ហាធ្ងន់ធ្ងរ ដែលជួបប្រទះដោយប្រជាជននៅតំបន់បឹងកក់បានឆាប់ជាងនេះ និងពិចារណាអំពីវិធានការសមស្រប ។ ការខកខានមិនបានធ្វើបែបនេះ មិនបានអនុលោមតាមគោលនយោបាយស្តីពីការត្រួតពិនិត្យគម្រោងរបស់ធនាគារពិភពលោកឡើយ ។**

២៣៤. **ក្រុមអធិការកិច្ចរកឃើញថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ជាទូទៅ មានភាពអនុលោមតាម OD 4.30 ។ ប៉ុន្តែ មានកង្វះការណែនាំអំពីសកម្មភាពស្តារនីតិសម្បទាឡើងវិញ និងសកម្មភាពស្តារចំណូល ដែលយោងតាមក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ គួរត្រូវបានពន្យល់លម្អិតនៅក្នុងផែនការតាំងទីលំនៅឡើងវិញ ។**

២៣៥. **ក្រុមអធិការកិច្ចរកឃើញថា ដំណើរការនៃការអនុវត្តការបណ្តេញចេញនៅក្នុងតំបន់បឹងកក់ កម្រិតនៃសំណង និងបទដ្ឋាននៃទីកន្លែងតាំងទីលំនៅឡើងវិញ មិនអនុវត្តតាមគោលការណ៍ដែលមានចែងដោយក្របខ័ណ្ឌគោលនយោបាយ ស្តីពីការតាំងទីលំនៅឡើងវិញ និងបទប្បញ្ញត្តិពាក់ព័ន្ធនៃ OD 4.30 ។**

## ខ. អះអាងថា ដំណើរការផ្តល់កម្មសិទ្ធិដែលអនុម័តដោយគម្រោងធ្វើឱ្យទន់ខ្សោយដល់សិទ្ធិ កាន់កាប់ដីដែលមានពីមុន

### ១. ការអះអាងរបស់អ្នកស្នើសុំ និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង

២៣៦. អ្នកស្នើសុំអះអាងថា *"ការណែនាំអំពីដំណើរការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ នៅថ្នាក់កណ្តាល និងជាផ្លូវការ ក្រោម LMAP បានធ្វើឱ្យទន់ខ្សោយចំពោះការទទួលស្គាល់ប្រព័ន្ធកាន់កាប់ដីជាប្រពៃណីនៅក្នុងប្រទេសកម្ពុជា ។ ដោយសារប្រជាជននៅតំបន់បឹងកក់ មិនអាចផ្ទេរសិទ្ធិជាប្រពៃណីរបស់ខ្លួនទៅជាប័ណ្ណកម្មសិទ្ធិដីផ្លូវការក្រោម LAMP គម្រោង មិនត្រឹមតែបរាជ័យក្នុងការធ្វើឱ្យមានលក្ខណៈផ្លូវការចំពោះការកាន់កាប់ដីរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអន់ថយដល់ស្ថានភាពកាន់កាប់ដីដែលមានពីមុនទៀតផង"* ។

២៣៧. ជាភស្តុតាងបន្ថែមទៀត អ្នកស្នើសុំកត់សម្គាល់ថា *"យោងតាមមាត្រា ២៤៨ នៃច្បាប់ភូមិបាលកម្ពុជា ឆ្នាំ ២០០១ រហូតទាល់តែតំបន់ណាមួយត្រូវបានគ្របដណ្តប់ដោយផែនទីលិបិក្រមសុរិយោដី ហើយសិទ្ធិលើកម្មសិទ្ធិត្រូវបានធានា នោះពុំមានទង្វើណាមួយដែលរារាំងអចលនទ្រព្យរបស់អ្នកកាន់កាប់ស្របច្បាប់ ត្រូវបានអនុញ្ញាតឡើយ ។ មាត្រា ២៤៨ ផ្តល់នូវការការពារសិទ្ធិកាន់កាប់ដីស្របច្បាប់ចំពោះប្រជាជនដែលរស់នៅក្នុងតំបន់ទាំងឡាយណា ដែលមិនទាន់គ្របដណ្តប់ដោយផែនទីលិបិក្រម ។ ដំណើរការវិនិច្ឆ័យដែលបានកើតឡើងនៅក្នុងសង្កាត់ស្រះចក រួមទាំងការបង្កើតផែនទីលិបិក្រមសុរិយោដី បានជំរុញដល់ការលើកកម្ពស់ការការពារ ដែលផ្តល់ដោយមាត្រា ២៤៨ ប្រឆាំងទៅនឹងការ ប៉ះពាល់ដល់ប្រជាជន រួមទាំង តាមរយៈការបណ្តេញចេញ"* ។

២៣៨. នៅក្នុងការឆ្លើយតបរបស់ខ្លួន ថ្នាក់គ្រប់គ្រងបានបញ្ជាក់ថា *"វាមិនមានភាពប្រាកដប្រជាអំពីថាតើពាក្យ "សិទ្ធិជាប្រពៃណី" កំពុងត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច"* ។ យោងតាមថ្នាក់គ្រប់គ្រង លក្ខណៈពិសេសគន្លឹះមួយនៃច្បាប់ភូមិបាល ឆ្នាំ ២០០១ បង្ហាញថា សិទ្ធិកាន់កាប់ត្រូវបានទទួលស្គាល់ថាអាចផ្លាស់ប្តូរទៅជាប័ណ្ណកម្មសិទ្ធិផ្លូវការបាន ប្រសិនបើលក្ខខណ្ឌមួយចំនួនត្រូវបានបំពេញ ។ ថ្នាក់គ្រប់គ្រងបានកត់សម្គាល់ថា ការផ្តល់ប័ណ្ណកម្មសិទ្ធិ គួរតែពង្រឹងសិទ្ធិកាន់កាប់ ដែលអាចទទួលស្គាល់បានក្រោមច្បាប់ភូមិបាល ។ ប៉ុន្តែថ្នាក់គ្រប់គ្រងបានបញ្ជាក់ថា *"សិទ្ធិដែលមានពីមុនអាចត្រូវបានធ្វើឱ្យប៉ះពាល់ដោយដំណើរការដែលមានភាពខ្វះចន្លោះ ដែលអាចមើលឃើញច្បាស់នៅក្នុងករណីនៃការវិនិច្ឆ័យចំពោះសង្កាត់ស្រះចក រួមទាំង អវត្តមាននៃសេចក្តីសម្រេចចិត្តដែលមានតម្លាភាព ផ្អែកលើលក្ខណៈវិនិច្ឆ័យ និងអាចពិនិត្យឡើងវិញបាន អំពីថាតើដីទំនាស់ គឺជាដីសាធារណៈរបស់រដ្ឋឬយ៉ាងណា"* ។ ថ្នាក់គ្រប់គ្រងបានកត់សម្គាល់ថា អ្នកកាន់កាប់យូរអង្វែង ដែលគ្មានសិទ្ធិកាន់កាប់មានសុពលភាពនៅក្រោមច្បាប់ភូមិបាល ប្រហែលជាមិនអាចទទួលបាននូវប័ណ្ណកម្មសិទ្ធិឡើយ ប្រសិនបើដំណើរការផ្តល់កម្មសិទ្ធិសន្និដ្ឋានថា ពួកគេមិនមានសិទ្ធិដែលអាចទទួលស្គាល់ស្របច្បាប់ទៅលើដីដែលពួកគេកំពុងកាន់កាប់ ប្រសិនបើដីនោះត្រូវបានកំណត់ថាជាដីរដ្ឋ ។ ថ្នាក់គ្រប់គ្រងបានបញ្ជាក់ថា ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ *"ត្រូវបានរៀបចំឡើង ក្នុងចំណោមក្របខ័ណ្ឌផ្សេងទៀត ដើម្បីអនុវត្តចំពោះប្រជាជនដែលត្រូវបានបណ្តេញចេញដោយសារដីត្រូវបាន "ផ្តល់កម្មសិទ្ធិក្នុងនាមរបស់រដ្ឋ"* ។

២៣៩. ថ្នាក់គ្រប់គ្រងមិនយល់ស្របជាមួយអ្នកស្នើសុំដែលថា ការរៀបចំផែនទីលិបិក្រមសុរិយោដី បានធ្វើឱ្យប្រជាជននៅតំបន់បឹងកក់កាន់តែមានភាពងាយរងគ្រោះចំពោះការបណ្តេញចេញ ។ ថ្នាក់គ្រប់គ្រងបានបញ្ជាក់ថា ខ្លួន *"បកស្រាយការការពារដែលមានចែងនៅក្នុងមាត្រា ២៤៨ ថានៅតែមានភាពសមស្រប រហូតទាល់តែផែនទីលិបិក្រមសុរិយោដី ត្រូវបានបញ្ចប់រួចរាល់ យោងតាមដំណើរការដែលបានកំណត់ ដែលពាក់ព័ន្ធនឹង ក្នុងចំណោម ប្រការផ្សេងទៀត ការបង្ហាញជាសាធារណៈនូវផែនទីដែលបានស្នើឡើង ការវិនិច្ឆ័យពេញលេញទៅលើសិទ្ធិឱកាស សម្រាប់ការបញ្ចេញយោបល់ សិទ្ធិទទួលបានដំណោះស្រាយចំពោះទំនាស់ និងការសម្រេចចុងក្រោយអំពីកម្មសិទ្ធិ"* ។ ទោះជាយ៉ាងណាក៏ ដោយយោងតាមថ្នាក់គ្រប់គ្រង នៅក្នុងករណីពិសេសនេះ *"វាមានភាពខ្វះចន្លោះធំដុំនៅក្នុងដំណើរការដែលត្រូវបានអនុវត្ត"* ។

២៤០. ថ្នាក់គ្រប់គ្រងបានបញ្ជាក់ថា ខ្លួន *"មិនបានដឹងអំពីភស្តុតាងដែលថា រដ្ឋាភិបាលពឹងផ្អែកលើការលើកកម្ពស់ការការពារ នៅក្នុងមាត្រា ២៤៨ ជាមូលដ្ឋានសម្រាប់សេចក្តីសម្រេចចិត្ត ឬវិធានការរបស់ខ្លួនទាក់ទងទៅនឹងតំបន់បឹងកក់ឡើយ"* ។ ទោះជាយ៉ាងណា ថ្នាក់គ្រប់គ្រងបានសារភាពថា ប្រការដែលការបង្កើតផែនទីមិនត្រូវបានអមដោយដំណើរការវិនិច្ឆ័យ ពេញលេញ *"បានធ្វើឱ្យប្រជាជនដែលអាចមានសិទ្ធិកាន់កាប់ចាញ់ប្រៀប"* ។

## ២. ការវិភាគរបស់ក្រុមអធិការកិច្ច

២៤១. ក្រុមអធិការកិច្ចបានកត់សម្គាល់ថា ការអះអាងរបស់អ្នកស្នើសុំដែលត្រូវបានកំណត់មិនពេញលេញ អាចត្រូវបានគេយល់ជាការចោទប្រកាន់ថា នីតិវិធីផ្លូវការដែលកំពុងត្រូវបានអនុម័តសម្រាប់ការផ្តល់កម្មសិទ្ធិដី ជាលក្ខណៈប្រព័ន្ធនៅក្រោម LMAP ធ្វើឱ្យចុះខ្សោយដល់សិទ្ធិមានពីមុនដែលត្រូវបានទទួលស្គាល់ ។ ការយល់ដឹងកាន់តែទូលំទូលាយអំពីការអះអាងនេះ គឺថា ប្រជាជនជាច្រើនដែលទាមទារសិទ្ធិមានពីមុន ផ្អែកលើប្រព័ន្ធកាន់កាប់ជាប្រពៃណី ឬក្រៅផ្លូវការផ្សេងទៀត ជាពិសេស ប្រជាជនក្រីក្រ និងងាយរងគ្រោះ មិនបានទទួលផលប្រយោជន៍ពីគម្រោង តាមរបៀបដែលត្រូវបានប្រមើល មើលពីដំបូងឡើយ ដោយសារពួកគេ ត្រូវបានផាត់ចេញពីដំណើរការនេះ ឬមានភាពខ្វះចន្លោះចំពោះវិធីអនុវត្តដំណើរការ ។

២៤២. ការវិភាគរបស់ក្រុមអធិការកិច្ចទៅលើការទាមទារនេះ គឺផ្អែកលើគោលការណ៍ចំនួនបី : សិទ្ធិដែលមានពីមុនត្រូវបានទទួលស្គាល់នៅក្នុងនីតិវិធីរបស់ LMAP, LMAP បានផ្តល់ការធានាការកាន់កាប់សម្រាប់ប្រជាជនជាច្រើន និងសិទ្ធិ ដែលមានពីមុនស្ថិតនៅក្រោមសម្ពាធអស់រយៈពេលយ៉ាងយូរ ។

២៤៣. **សិទ្ធិដែលមានពីមុនត្រូវបានទទួលស្គាល់នៅក្នុងនីតិវិធីរបស់** LMAP **។** ដំណើរវិនិច្ឆ័យរបស់ LMAP ដែលមានចែងនៅក្នុងសៀវភៅណែនាំអំពីការចុះបញ្ជីដីធ្លីរបស់ LMAP ត្រូវបានបង្កើតឡើងឈរលើមូលដ្ឋាននៃច្បាប់ភូមិបាល ឆ្នាំ ២០០១ ។ សៀវភៅណែនាំអំពីការចុះបញ្ជីដីធ្លីបង្ហាញអំពីដំណើរការនៃការកំណត់ការទាមទារចំពោះដី

ទាំងអស់នៅក្នុងតំបន់វិនិច្ឆ័យ រួមទាំង ដីសាធារណៈ និងដីឯកជន ។ នៅក្នុងឯកសារចែកចាយសម្រាប់កិច្ចប្រជុំថ្នាក់ភូមិ គេបានបញ្ជាក់ថា *"ជម្លោះដីធ្លីកើតមានជាញឹកញាប់នៅក្នុងប្រទេសកម្ពុជា ដោយសារមូលហេតុជាច្រើន ។ ជម្លោះសំខាន់ៗ ក្នុងចំណោមជម្លោះទាំងនេះ គឺភាពមិនច្បាស់លាស់អំពីព្រំប្រទល់ដីដែលស្ថិតក្រោមការត្រួតត្រារបស់ស្ថាប័នរដ្ឋផ្សេងៗ និងបុគ្គលឯកជន"*[១៣៩] ។ មន្ត្រីវិនិច្ឆ័យត្រូវកោះប្រជុំនីតិបុគ្គល និងរូបវ័ន្តបុគ្គល ដែលមានផលប្រយោជន៍នៅក្នុងដីវិនិច្ឆ័យ ដើម្បីបន្យល់អំពីមូលដ្ឋានច្បាប់សម្រាប់បណ្តឹងទាមទារការកាន់កាប់ ។

២៤៤. ការកោះប្រជុំនេះ រួមមាន ការពន្យល់អំពីភាពខុសគ្នារវាងដីសាធារណៈ និងឯកជន ដែល *"ជាបញ្ហាទាក់ទងនឹងដីជាជាងម្ចាស់ដី"*[១៤០] ។ សៀវភៅណែនាំនេះគូសបញ្ជាក់អំពីមាត្រា ១៥ នៃច្បាប់ភូមិបាល ដែលកំណត់យ៉ាងទូលំទូលាយចំពោះដីសាធារណៈរបស់រដ្ឋ ខណៈដែលទទួលស្គាល់ថា មាត្រានេះ *"តែឯង ពុំមានភាពគ្រប់គ្រាន់សម្រាប់ឱ្យគេដឹងថាតើទ្រព្យសម្បត្តិជាក់លាក់អ្វីខ្លះត្រូវបានកំណត់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។ ឧទាហរណ៍ តើច្រាំងទន្លេដែលអាចធ្វើនាវាចរណ៍បានបញ្ចប់នៅត្រង់ណា ? តើគ្រប់តំបន់ដែលមានដើមឈើ សុទ្ធតែជា "ព្រៃឈើ" ហេតុដូច្នេះ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឬយ៉ាងណា ? បញ្ហាទាំងនេះសុទ្ធតែតម្រូវឱ្យមានច្បាប់ និង/ឬបទបញ្ជាអំពីការកំណត់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ សៀវភៅណែនាំនេះនឹងត្រូវបានធ្វើបច្ចុប្បន្នភាពនៅពេលបទប្បញ្ញត្តិច្បាប់ទាំងនេះត្រូវបានអនុម័តរួចភ្លាម ។ ទោះជាយ៉ាងណាក៏ដោយ លក្ខណៈវិនិច្ឆ័យមួយចំនួនក្នុងចំណោមលក្ខណៈ វិនិច្ឆ័យទាំងនេះដែលបង្កើតឡើងនៅក្នុងមាត្រា ១៥ នៃច្បាប់ភូមិបាល មានភាពច្បាស់លាស់ និងអនុញ្ញាតឱ្យមានការវិនិច្ឆ័យដោយផ្ទាល់ទៅលើលក្ខណៈ "សាធារណៈ" នៃដី ។ ទ្រព្យសម្បត្តិដែលធ្វើគ្រប់គ្រងដោយរដ្ឋ និងអចលនទ្រព្យមួយចំនួន ជាញឹកញាប់ អាចត្រូវបានវិនិច្ឆ័យដោយផ្ទាល់ថាមានលក្ខណៈ "សាធារណៈ""*[១៤១] ។

២៤៥. ក្រុមអធិការកិច្ចបានកត់សម្គាល់ថា នីតិវិធីវិនិច្ឆ័យផ្លូវការរបស់ LMAP ទទួលស្គាល់សិទ្ធិដែលមានពីមុន ដូចមានចែងនៅក្នុងច្បាប់កម្ពុជា ។ ប៉ុន្តែ ក្រុមអធិការកិច្ចក៏បានកត់សម្គាល់ ដូចមានបង្ហាញនៅក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងផងដែរថា អាចមានករណីនៃ *"ភាពខ្វះចន្លោះធំដុំ"* នៅក្នុងការអនុវត្តដំណើរការ LMAP (សូមមើលខាងក្រោម) ដែលជាបញ្ហាទាក់ទងនឹងទំនួលខុសត្រូវក្នុងការត្រួតពិនិត្យរបស់ធនាគារពិភពលោក ។

២៤៦. ទាក់ទងនឹងការអះអាងរបស់អ្នកស្នើសុំដែលថា ការបង្កើតផែនទីលិបិក្រមសុរិយោដីនៅក្នុងសង្កាត់ស្រះចក បានលើកកម្ពស់ការការពារ ដែលមានផ្តល់ជូននៅក្នុងមាត្រា ២៤៨ នៃច្បាប់ភូមិបាល ក្រុមអធិការកិច្ច បានយល់ស្របជាមួយថ្នាក់គ្រប់គ្រងថា ពុំមានភស្តុតាងណាមួយត្រូវបានទទួល ដែលបញ្ជាក់ថា រដ្ឋាភិបាលកំពុងពឹងផ្អែកលើការលើកម្ពស់ការការពារនៅក្នុងមាត្រា ២៤៨ ជាមូលដ្ឋានសម្រាប់សេចក្តីសម្រេចចិត្ត និងវិធានការរបស់ខ្លួន ទាក់ទង

---

[១៣៩] សៀវភៅណែនាំអំពីការចុះបញ្ជីដីធ្លីរបស់ ឡាំភ ទំព័រទី ១

[១៤០] បិដ ទំព័រទី ៩០

[១៤១] បិដ ទំព័រទី ៩១

នឹងតំបន់បឹងកក់ឡើយ ។ ប៉ុន្តែ ក្រុមអធិការកិច្ចក៏យល់ស្របជាមួយ ថ្នាក់គ្រប់គ្រងផងដែរថា ការបង្កើតផែនទីដោយគ្មានដំណើរការ វិនិច្ឆ័យត្រឹមត្រូវបានធ្វើឱ្យប្រជនជន ដែលអាចមានសិទ្ធិកាន់កាប់ដីមានភាពចាញ់ប្រៀប ។

២៤៧. **LMAP បានផ្តល់ការធានាការកាន់កាប់ដីសម្រាប់ប្រជាជនជាច្រើន ។** គោលបំណងមួយដែលត្រូវបានបញ្ជាក់នៃគម្រោង គឺការផ្តល់សំណងចំពោះកង្វះភាពច្បាស់លាស់ និងការធានាថយចុះ ដែលផ្តល់ដោយប្រព័ន្ធកាន់កាប់ដីក្រៅផ្លូវការ តាមរយៈការផ្តល់ ប្រសិនបើអាច ប័ណ្ណកម្មសិទ្ធិចុះបញ្ជីដែលនឹងត្រូវធានាដោយរដ្ឋ ដូចមានចែងនៅក្នុងមាត្រា ១ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១ ។ PAD បានរៀបរាប់លម្អិតអំពីទំនាក់ទំនងបណ្តោះអាសន្នរវាងការផ្តល់កម្មសិទ្ធិ និងការកាត់បន្ថយភាពក្រីក្រ ដោយកត់សម្គាល់ថា : *"អ្នកទទួលផលដែលរំពឹងទុក សុទ្ធតែក្រីក្រ និងងាយរងគ្រោះ ចំពោះការបណ្តេញចេញពីដីដែលពួកគេរស់នៅ និងធ្វើកសិកម្ម ។ ការផ្តល់ឱ្យពួកគេនូវប័ណ្ណកម្មសិទ្ធិដែលមានការធានា នឹងជួយកាត់បន្ថយយ៉ាងខ្លាំងចំពោះហានិភ័យនៃការបាត់បង់ដីដែលពួកគេប្រឈមនាពេលបច្ចុប្បន្ន"*[១៤២] ។

២៤៨. ត្រឹមឆ្នាំ ២០០៩ LMAP បានចុះបញ្ជី និងផ្តល់កម្មសិទ្ធិចំពោះដីជាង ១,១ លានក្បាលដី ។ **ក្រុមអធិការកិច្ចបានកត់សម្គាល់ថា គម្រោងបានផ្តល់ផលប្រយោជន៍យ៉ាងច្បាស់ដល់ប្រជាជនជាង ១ លានគ្រួសារ និងទទួលស្គាល់សមិទ្ធផលដ៏សំខាន់នេះរបស់ LMAP ។** ក៏មានភស្តុតាងផងដែរ ថាអ្នកទទួលផលភាគច្រើន ចាត់ទុកប័ណ្ណកម្មសិទ្ធិថ្មី ថាជាជំហានមួយឆ្ពោះទៅមុខ ។ ការអង្កេតទៅលើតំណាងប្រជាជនចំនួន ១.២៣៦ គ្រួសារ នៅក្នុងតំបន់វិនិច្ឆ័យ ដែលត្រូវបានប្រកាសចំនួន ១៩ កន្លែង នៅក្នុងខេត្តគោលដៅចំនួន ១១ ដែលបានធ្វើឡើង ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០០៥ ដល់ខែ មករា ឆ្នាំ ២០០៦ បានរកឃើញថា *"គ្រួសារភាគច្រើន (៨៣%) ដែលបានទទួលប័ណ្ណកម្មសិទ្ធិបានបញ្ជាក់ថា ពួកគេមានការសប្បាយ ចិត្តជាងដែលបានទទួលប័ណ្ណកម្មសិទ្ធិ ព្រមទាំងមានអារម្មណ៍កាន់តែមានសុវត្ថិភាព"*[១៤៣] ។

២៤៩. **សិទ្ធិដែលមានពីមុនស្ថិតក្រោមសម្ពាធអស់រយៈពេលយ៉ាងយូរ ។** ក្រុមអធិការកិច្ចបានកត់សម្គាល់ថា កម្រិតនៃការទទួលស្គាល់ប្រព័ន្ធកាន់កាប់ដី (និងការកាប់ការប់ដែលពាក់ព័ន្ធ) ជាប្រពៃណី ខុសប្លែកគ្នាយ៉ាងខ្លាំងក្នុងចំណោមតំបន់នានា ។ ទោះជាយ៉ាងណាក៏ដោយប្រព័ន្ធទាំងនេះហាក់ដូចជាត្រូវបានធ្វើឱ្យទន់ខ្សោយតាមពេលវេលា ។

២៥០. ករណីតំបន់បឹងកក់ បានបង្ហាញថា ប្រជាជនជាច្រើនចាត់ទុកខ្លួនឯងជាម្ចាស់ដី និងកាន់កាប់ឯកសារដែលបញ្ជាក់អំពីកម្មសិទ្ធិ ។ ពួកគេសំដៅដល់ឯកសារ និងកិច្ចព្រមព្រៀង ដែលចុះហត្ថលេខាដោយប្រធានភូមិ ឬចៅសង្កាត់ ដែលបញ្ជាក់អំពីការទិញដី ឬការទូទាត់ប្រាក់ ។ ដូចមានកត់សម្គាល់នៅក្នុងជំពូកទី ២ ដីត្រូវបានកាន់កាប់ ផ្ទេរ និងស្នងបន្ត តាមរយៈប្រព័ន្ធកាន់កាប់ដីមួយចំនួនអស់រយៈពេលជាច្រើនឆ្នាំ ហើយប្រព័ន្ធទាំងនេះបានទទួលភាពស្របច្បាប់ និងការទទួលស្គាល់ផ្នែកសង្គមមួយកម្រិតពីសំណាក់អាជ្ញាធរពាក់ព័ន្ធ និងអ្នកប្រើប្រាស់ ទោះបីជាខ្វះប្រព័ន្ធផ្លូវ

[១៤២] ភាឌខ ទំព័រទី ១០

[១៤៣] ការពិនិត្យឡើងវិញដោយឯករាជ្យលើតម្លាភាព និងគណនេយ្យភាព ខែ កុម្ភៈ ឆ្នាំ ២០០៦ ទំព័រទី ១១

ការថ្នាក់ជាតិនៃការចេញឯកសារ ។ ការសិក្សាមួយរបស់ LMAP ដែលធ្វើឡើងក្នុងឆ្នាំ ២០០៧ ដែលបានអង្កេតលើប្រជាជនរស់នៅក្នុងក្រុង និងជាយក្រុងចំនួន ១៦៦៣ គ្រួសារ នៅទីក្រុងភ្នំពេញ បានបង្ហាញថា គ្រួសារទាំងឡាយ *"ពឹងផ្អែកទៅលើ ទម្រង់ឯកសារផ្សេងៗជាច្រើន ។ ដូចនៅក្នុងតំបន់ជនបទដែរ គ្រួសារទាំងនេះហាក់ដូចជា ចូលចិត្តពឹងផ្អែកលើឯកសារ ក្រៅផ្លូវការ... ប្រការនេះ រួមមាន ឯកសារអង្កេតដីធ្លី (៥០.២%) និងបង្កាន់ដៃសម្រាប់ការប្រើប្រាស់ជាលិខិតបញ្ជាក់ (២២.៨%) ស្មើនឹងដីសរុបចំនួន ៧៣% ដែលទទួលស្គាល់ជាផ្លូវការ ប៉ុន្តែពុំមានឯកសារស្របច្បាប់"*[១៤៤] ។

២៥១. ការសិក្សាបានបង្ហាញថា មានគ្រួសារតែ ៥.៤% ប៉ុណ្ណោះបានរាយការណ៍ថាមានលិខិតបញ្ជាក់ផ្លូវការ ។ គ្រួសារក្នុងចំនួនដ៏តិចតួចនេះ ដែលមានឯកសារពេលលេញអំពីការកាន់កាប់ដីរបស់ពួកគេ ឆ្លុះបញ្ចាំងអំពីកម្រិតតិចតួច ដែលការិយាល័យសុរិយោដីនៅក្នុងប្រទេសកម្ពុជា អាចចុះបញ្ជីដីធ្លី ហើយពិតណាស់គឺជាហេតុផលចម្បងសម្រាប់ការបង្កើតគម្រោង LMAP ដើម្បីវាយតម្លៃជាផ្លូវការ តាមរយៈការវិនិច្ឆ័យ កម្រិតដែលសិទ្ធិទាំងនេះធ្វើឱ្យអ្នកកាន់កាប់ដីមានសិទ្ធិទទួលបានការផ្តល់កម្មសិទ្ធិដី ។

២៥២. នៅក្នុងតំបន់ជនបទ ការសិក្សានានាបង្ហាញថា ប្រហែលពីរភាគបីនៃបណ្តឹងទាមទារដីឯកជន មិនអាចត្រូវបានគាំទ្រដោយឯកសារប្រភេទណាមួយឡើយ ។ ការសិក្សាជាមូលដ្ឋានអំពីតំបន់ជនបទ ដែលធ្វើឡើងក្នុងឆ្នាំ ២០០៤ សម្រាប់ LMAP[១៤៥] បានរកឃើញថា ប្រហែល ៦២.៧% នៃដីកសិកម្មដែលគ្របដណ្តប់នៅក្នុងតំបន់អង្កេតមិនដែលមានការចុះ បញ្ជីឯកសារប្រភេទណាមួយឡើយ ។ ក្នុងចំណោមដីដែលបានចុះបញ្ជីឯកសារ ៦១.៦% មានបង្កាន់ដៃសម្រាប់ការប្រើប្រាស់ជាលិខិតបញ្ជាក់ ចំណែកឯ ១៤.៩% ទៀត មានឯកសារស៊ើបអង្កេតការអង្កេតដី ។ មានតែ ៨.១% ប៉ុណ្ណោះ មានលិខិតបញ្ជាក់កម្មសិទ្ធិដី ឬប័ណ្ណកម្មសិទ្ធិជាក់ស្តែង ។ ៦.៣% ទៀតពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឯកសារ ប្រភេទផ្សេងៗទៀត ។ ការប្រើប្រាស់ឯកសារក្រៅផ្លូវការ មានសង្គតិភាពចំពោះការកាន់កាប់ដីគ្រប់ទំហំទាំងអស់ ។

២៥៣. ក្នុងការវាយតម្លៃភស្តុតាងដែលមាន វាជាការប្រត្យក្សដែលថា មានឧទាហរណ៍ជាច្រើន ដែលក្នុងនោះ អ្នកភូមិ និងប្រជាជនក្រីក្រតាមទីក្រុងដែលរស់នៅក្រោមទម្រង់កាន់កាប់ដីជាលក្ខណៈប្រពៃណីបែបបុរាណ ឬទម្រង់ពាក់ព័ន្ធផ្សេងៗ ត្រូវបានដកហូតដីរបស់ខ្លួនដោយបុគ្គល ក្រុម ឬអង្គភាពមានអំណាច ដែលជាញឹកញាប់មានការប្រើអំ

---

[១៤៤] *គម្រោងអង្កេតជាមូលដ្ឋាននៃកម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីកម្ពុជា : របាយការណ៍ចុងក្រោយ : ដំណាក់កាលទីក្រុង* (សេចក្តីព្រាង) វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា (CDRI) ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) Ballard, B and Runsinarith, P. ភ្នំពេញ កម្ពុជា ខែ សីហា ឆ្នាំ ២០០៧ ទំព័រទី ៤៩

[១៤៥] *កម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីកម្ពុជា : របាយការណ៍ចុងក្រោយនៃគម្រោងអង្កេតជាមូលដ្ឋាន : ដំណាក់កាលជនបទ* (សេចក្តីព្រាង) វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា (CDRI) ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) Ballard, B and Sovannarith, S ។ ភ្នំពេញ កម្ពុជា ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រទី ix-x

ពើហិង្សា ឬការគំរាមប្រើអំពើហិង្សា និងថា ទម្លាប់អនុវត្តន៍ទាំងនេះបានរីករាលដាល ទាំងក្នុងតំបន់ជនបទ ទាំងក្នុងតំបន់ទីក្រុង អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ អង្គការមិនមែនរដ្ឋាភិបាលជំនួយផ្នែកច្បាប់កម្ពុជា[១៤៦] មួយបានអះអាងថា ពួកគេកំពុងដោះស្រាយរឿងក្ដីសរុបចំនួន៩០ ករណី តាងនាមឱ្យប្រជាជនចំនួន ៩.៦០៣ គ្រួសារ ដែលតំណាងឱ្យប្រជាជន ចំនួន ៤៩.៩៣៦ នាក់ នៅក្នុងរយៈពេល ៨ ខែដំបូងនៃឆ្នាំ ២០០១ តែមួយគត់[១៤៧] ។ ក៏មានរបាយការណ៍ជាច្រើន ផងដែរដែលកត់ត្រាអំពីករណីនៃការបណ្ដេញចេញចំពោះអ្នកភូមិ និងប្រជាជន ដែលភាគច្រើន នៅក្នុងតំបន់ទីក្រុង ដោយពុំទទួលបានដំណើរការសមស្រប ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មកទល់ពេលបច្ចុប្បន្ន (សូមមើលផ្នែក ច នៃជំពូកនេះ) ។

២៥៤. ភស្តុតាងបានបង្ហាញថា បញ្ហានេះកើតឡើងដោយសារសម្ពាធកើនឡើងទៅលើដីសម្រាប់ការប្រើប្រាស់ផ្នែកកសិកម្ម ពាណិជ្ជកម្ម និងលំនៅដ្ឋាន ជាពិសេស នៅតំបន់ទីក្រុង និងជាយក្រុង ដែលកំណើនប្រជាជនមានល្បឿនឆាប់រហ័ស ។ យោងតាមការអង្កេតជាមូលដ្ឋានសម្រាប់តំបន់ទីក្រុង *"តម្លៃដីបានកើនឡើង ទោះបីជា ជាទូទៅ ពុំមានប័ណ្ណកម្មសិទ្ធិដីក៏ដោយ"* ។ ការអង្កេតនេះបានលើកឡើងអំពីទីភ្នាក់ងារអចលនទ្រព្យមួយដែលបានបញ្ជាក់ថា *"ក្នុងអំឡុងរយៈពេល ពីឆ្នាំ ២០០០ ដល់ ២០០៧ តម្លៃដីបានកើនឡើងរៀងរាល់ឆ្នាំ... តំបន់មួយចំនួនក្នុងចំណោមតំបន់ដែលមានការប្រកួត ប្រជែង នឹងអាចរកប្រាក់ចំណេញជាង បានកើនឡើងរហូតដល់ ៣០ - ៨០%"*[១៤៨] ។ នៅក្នុងបរិបទនេះហើយ ដែល ការប្រកួតប្រជែងដីធ្លីបាននាំមកនូវការបណ្ដេញចេញដ៏រាលដាល ។

២៥៥. របាយការណ៍មួយដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមួយក្រុម ដែលធ្វើការទៅលើបញ្ហាកាន់កាប់ដី បានកត់សម្គាល់ថា *"ការចាប់យកដី និងការបណ្ដេញចេញដោយបង្ខំ កំពុងរួមចំណែកធ្វើឱ្យភាពគ្មានដីធ្លីកើនឡើង វិសមភាពក្នុងការកាន់កាប់ដី និងគ្រួសារក្រីក្រទទួលរងការផ្លាស់ទីលំនៅទៅកាន់តំបន់ដែលគ្មានលក្ខខណ្ឌរស់នៅគ្រប់គ្រាន់"*[១៤៩] ។ មានភស្តុតាងជាច្រើនថា ភ្នាក់ងាររដ្ឋាភិបាលថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋានបានបដិសេធមិនទទួលស្គាល់សិទ្ធិកាន់កាប់ដីរបស់ប្រជាជនជាច្រើន ជាពិសេស នៅក្នុងតំបន់ទីក្រុង ដែលមានឯកសារបញ្ជាក់ថា ការកាន់កាប់ដី របស់ពួកគេស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ភូមិបាល ឆ្នាំ ២០០១ និងថា ពួកគេអាចមានការអះអាងរឹងមាំចំពោះ កម្មសិទ្ធិដីយោងតាមការវិនិច្ឆ័យ ។

---

[១៤៦] ជំនួយផ្នែកច្បាប់នៃកម្ពុជា ១ឡាជេច បង្កើតឡើងក្នុងឆ្នាំ ១៩៩៥ គឺជាអង្គការមិនមែនរដ្ឋាភិបាល ជំនួយផ្នែកច្បាប់កម្ពុជា ។ *ជំនួយផ្នែកច្បាប់នៃកម្ពុជា "ស្ថានភាពនៃករណីបណ្ដឹងដីធ្លីធំៗ : សរុបករណីបណ្ដឹងដីធ្លីទូទៅសម្រាប់រយៈពេលប្រាំបីខែដំបូង ឆ្នាំ ២០០១"* ខែ តុលា ឆ្នាំ ២០០១ ។

[១៤៧] គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ជំនួយផ្នែកច្បាប់នៃកម្ពុជា បានបន្ត ឬបញ្ចប់រួចរាល់នូវករណីបណ្ដឹងដីធ្លីធំៗចំនួន ៥៨ ករណី តាងនាមឱ្យប្រជាជន ចំនួន ៤៧.១៤៨ នាក់ រួមទាំង អង្គការមិនមែនរដ្ឋាភិបាលចំនួន ២ ដែលរួមគ្នាពាក់ព័ន្ធទៅនឹងដីចំនួន ១៨.៦៤០ ហិចតា ។

[១៤៨] *គម្រោងអង្កេតជាមូលដ្ឋាននៃកម្មវិធីផ្ដល់កម្មសិទ្ធិដីធ្លីកម្ពុជា : របាយការណ៍ចុងក្រោយ : ដំណាក់កាលទីក្រុង"* ទំព័រទី ៦១ ។

[១៤៩] *គម្រោងអង្កេតជាមូលដ្ឋាននៃកម្មវិធីផ្ដល់កម្មសិទ្ធិដីធ្លីកម្ពុជា : របាយការណ៍ចុងក្រោយ : ដំណាក់កាលទីក្រុង"* ទំព័រទី ១៧ ។

២៥៦. ផ្អែកតាមភស្តុតាងខាងលើ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា កម្រិតនៃការធានាដែលផ្តល់ដោយប្រព័ន្ធកាន់កាប់ដីតាមបែបបុរាណ ជាប្រពៃណី ឬក្រៅផ្លូវការផ្សេងៗទៀត ជាពិសេសនៅតំបន់ទីក្រុង បានថយចុះយ៉ាងខ្លាំងចាប់តាំងពីដើម ទសវត្សឆ្នាំ ១៩៩០ ។ ស្ថានភាពនេះត្រូវបានគេដឹងឮជាទូទៅ មុនពេលគម្រោងត្រូវបានបង្កើតឡើង ហើយ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា PAD ទទួលស្គាល់យ៉ាងច្បាស់លាស់ចំពោះបញ្ហានេះ ព្រមទាំងបញ្ហាប្រឈមដែលពាក់ព័ន្ធ ។ ទោះបីជាយ៉ាងណាក្តី ដូចមានរៀបរាប់លម្អិតបន្ថែមខាងក្រោម ក្រុមអធិការកិច្ចបានរកឃើញចំណុចខ្សោយសំខាន់ៗនៅ ក្នុងការបង្កើត និងអនុវត្តគម្រោងទាក់ទងទៅនឹងវិធានការ ក្នុងការការពារក្រុមក្រីក្រ និងក្រុមងាយរងគ្រោះ ដែលពឹងផ្អែកទៅលើសិទ្ធិកាន់កាប់ដីជាប្រពៃណី ឬ ក្រៅផ្លូវការផ្សេងទៀត ។



**រូបភាពទី ៦ : ផ្ទះដែលគ្របដណ្តប់ដោយភក់ក្នុងអំឡុងការចាក់បំពេញបឹងកក់នាពេលថ្មីៗ ។ រូបភាពផ្តល់ជូនដោយ BABSEA**

## ៣. គំហើញអំពីភាពអនុលោម

២៥៧. គំហើញរបស់ ក្រុមអធិការកិច្ចអំពីភាពអនុលោម ត្រូវបានរៀបចំជាពីរផ្នែក ផ្នែកទីមួយ ផ្តោតទៅលើដំណាក់កាលរៀបចំ និងវាយតម្លៃ ហើយផ្នែកទីពីរ ផ្តោតទៅលើការត្រួតពិនិត្យ ។

២៥៨. **ការរៀបចំ និងការវាយតម្លៃ :** ក្រុមអធិការកិច្ចបានពិនិត្យមើលចំណុចខ្សោយចំនួនពីរនៃការរៀបចំគម្រោងដែលអាច រួមចំណែកជាសក្តានុពលចំពោះការធ្វើឱ្យស្ថានភាពរបស់ប្រជាជនក្រីក្រ និងងាយរងគ្រោះកាន់តែមានលក្ខណៈធ្ងន់ធ្ងរ នៅក្នុងតំបន់ LMAP ដូចជា ភាពមិនប្រាកដប្រជាអំពីរបៀបដោះស្រាយ តំបន់ដែលមានបណ្តឹងទាមទារដីជម្លោះរវាង រដ្ឋ និងបុគ្គលឯកជន និងរបៀបដែលការតាំងទីលំនៅក្រៅផ្លូវការ ត្រូវបានដោះស្រាយនៅក្នុងការរៀបចំគម្រោង ។

២៥៩. *របៀបដែល "ដីទំនាស់" ត្រូវបានដោះស្រាយនៅក្នុងការរៀបចំគម្រោង* ។ ទោះបីជាដីប្រហែល ៨០% ត្រូវបានប៉ាន់ស្មានថាជាដីរបស់រដ្ឋក៏ដោយ PAD ទទួលស្គាល់ថា *"រដ្ឋហាក់ដូចជាមិនដឹងអំពីបរិមាណ ទីតាំង និងព្រំប្រទល់ដីដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួនឡើយ ។ ជាការច្បាស់លាស់ ដីជាច្រើនមិនត្រូវបានធ្វើអង្កេតគូសផែនទី ឬផ្តល់*

*កម្មសិទ្ធិឡើយ"*[១៥០] ។ PAD បានកត់សម្គាល់អំពីភាពខុសគ្នារវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ និងបាន បង្ហាញថា ដីឯកជនរបស់រដ្ឋអាចត្រូវបានលក់ និង *"ត្រូវបានរាយការណ៍ជាញឹកញាប់ថាបានលក់ដោយក្រសួងនានា និង ទីភ្នាក់ងាររបស់រដ្ឋជាលក្ខណៈពិសេស ដោយប្រាក់ចំណូលមិនបានបង្វិលចូលរតនាគារសម្រាប់ផលប្រយោជន៍ សាធារណៈឡើយ"*[១៥១] ។ PAD សំដៅដល់ចំនួនប្រជាជនគ្មានដីដែលកើនឡើងដោយសារការលក់ដោយបង្ខំ ឬការ លក់ដោយសារទាល់ច្រក និងចំនួនដ៏ខ្ពស់នៃទំនាស់ដីធ្លី ។

២៦០. PAD ក៏បានកត់សម្គាល់ថា *"មានការលើកឡើងថា ភ្នាក់ងាររដ្ឋ ដូចជា យោធា និងបុគ្គលដែលពាក់ព័ន្ធនឹងនយោបាយ បានដកហូតដីរបស់ប្រជាជន ដែលកំពុងត្រូវបានសម្រួល* ***ដោយសារកង្វះការទទួលស្គាល់ជាផ្លូវការនូវសិទ្ធិលើដីទាំងនោះ"***[១៥២] (មានការបញ្ជាក់បន្ថែម) ។ តាមពិត នៅពេលរៀបចំ និងវាយតម្លៃគម្រោង មានភស្តុតាងសន្ធឹកសន្ធាប់អំពី ការគំរាមកំហែងបណ្តេញចេញ ឬការរើទីលំនៅដោយបង្ខំចំពោះប្រជាជន ។ PAD ក៏សំដៅដល់ចំនួនដ៏ខ្ពស់នៃជម្លោះ ដីធ្លីនៅក្នុងប្រទេសកម្ពុជា ដោយសារមូលហេតុជាច្រើន និងកត់សម្គាល់ថា មូលហេតុចម្បងនៃជម្លោះទាំងនេះ *"គឺភាពមិនប្រាកដប្រជាអំពីព្រំប្រទល់ដីដែលស្ថិតក្រោមការត្រួតត្រារបស់ស្ថាប័នរដ្ឋផ្សេងៗ និង បុគ្គលឯកជន"*[១៥៣] ។

២៦១. ទោះបីជាគម្រោងត្រូវបានរៀបចំឡើងនៅក្នុងបរិបទនេះក៏ដោយ ក៏ PAD បានរួមបញ្ចូលសេចក្តីយោងមិនច្បាស់លាស់ និងធ្វើឱ្យភាន់ច្រឡំចំពោះ *"ដីនៅក្នុងតំបន់ដែលទំនាស់ទំនងជាកើតមានឡើង"* និងបានបញ្ជាក់ថា គម្រោងនេះនឹងមិនផ្តល់កម្មសិទ្ធិដល់ដីទាំងនេះទេ លុះត្រាតែកិច្ចព្រមព្រៀងត្រូវបានសម្រេចស្តីពីស្ថានភាពនៃដីនោះ ។ ទោះបីជាការទទួលស្គាល់ការលំបាកក្នុងការបែងចែកចំណាត់ថ្នាក់ដី និងកំណត់ព្រំប្រទល់រវាងដីសាធារណៈ និងឯកជនក៏ដោយ ការរៀបចំគម្រោងបានរំពឹងថា ទិដ្ឋភាពទំនាស់ដ៏សំខាន់នៃគម្រោងនឹងត្រូវបានដោះស្រាយតាមរយៈការពិគ្រោះយោបល់ជាសាធារណៈ ។ ដូចមានពិភាក្សាលម្អិតនៅក្នុងផ្នែក ខ នៃជំពូកនេះ នៅក្នុងអំឡុងពេលអនុវត្តគម្រោង របាយការណ៍ PAD នេះ ក្នុងរយៈពេលអនុវត្តគម្រោងបានបកស្រាយក្នុងការផាត់ចេញដីទំនាស់ ។ បញ្ហានេះមានលក្ខណៈកាន់តែ ធ្ងន់ធ្ងរនៅពេលដីទំនាស់ត្រូវបានអះអាងជាដីរដ្ឋ និងកំណត់លក្ខណៈជាដីជម្លោះ ហើយប្រជាជននៅក្នុងតំបន់នោះត្រូវ បានបដិសេធនូវឱកាសក្នុងការទាមទារសិទ្ធិកាន់កាប់របស់ខ្លួន ដោយសារការផាត់ចេញដីនេះពីដំណើរការវិនិច្ឆ័យនៅក្រោមគម្រោង ។

---

[១៥០] PAD ទំព័រទី ៤

[១៥១] PAD ទំព័រទី ៤

[១៥២] PAD ទំព័រទី ៥

[១៥៣] PAD ទំព័រទី ៥

២៦២. នៅក្នុងបរិយាកាសដែលពុំមានការបែងចែកចំណាត់ថ្នាក់ដីធ្លី និងពុំមានការធ្វើផែនទី ដើម្បីកំណត់ព្រំដែននៃប្រភេទដីផ្សេងៗ ជាពិសេស រវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ការរៀបចំគម្រោងនេះបានឈានដល់ការកំណត់ដី តាមទំនើងចិត្ត ហើយតាមព្រឹត្តន័យជាដីសាធារណៈរបស់រដ្ឋ ។ ជាលទ្ធផល ប្រជាជនដែលរស់នៅលើដីទាំងនេះត្រូវបានប្រកាសថា ជាអ្នកតាំងទីលំនៅក្រៅផ្លូវការ/អ្នកតាំងទីលំនៅខុសច្បាប់ និងត្រូវបានផាត់ចេញពីដំណើរការផ្តល់កម្មសិទ្ធិក្រោមគម្រោង ។

២៦៣. **ក្រុមអធិការកិច្ចបានរកឃើញថា ចំណុចខ្វះខាតនៅក្នុងការរៀបចំគម្រោងបាននាំទៅរកការផាត់ចេញតាមទំនើងចិត្តចំពោះដីពីដំណើរការផ្តល់កម្មសិទ្ធិ និងថា ប្រការនេះបានបដិសេធប្រជាជន ជាពិសេស ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ នូវឱកាសក្នុងការទាមទារ និងធ្វើឱ្យមានលក្ខណៈផ្លូវការចំពោះសិទ្ធិដែលមានពីមុនរបស់ពួកគេតាមរយៈដំណើរការវិនិច្ឆ័យក្រោម LMAP ។**

២៦៤. *របៀបដែល "ការតាំងទីលំនៅក្រៅផ្លូវការ" ត្រូវបានដោះស្រាយនៅក្នុងការរៀបចំគម្រោង* ។ ការរៀបចំគម្រោងបានផាត់អ្នកតាំងទីលំនៅក្រៅផ្លូវការ/អ្នកតាំងទីលំនៅខុសច្បាប់ចេញពីដំណើរការផ្តល់កម្មសិទ្ធិក្រោមគម្រោង លុះត្រាតែរដ្ឋាភិបាលយល់ព្រមអនុញ្ញាតឱ្យដីនោះទទួលបានការចុះបញ្ជីចំពោះអ្នកតាំងទីលំនៅក្រៅផ្លូវការ ។ PAD បានកត់សម្គាល់ថា គម្រោងនឹងមិនចេញប័ណ្ណកម្មសិទ្ធិជូនឡើយ ប្រសិនបើពុំមានកិច្ចព្រមព្រៀងដើម្បីបែងចែកដីជូនអ្នកតាំង ទីលំនៅក្រៅផ្លូវការ ឬតាមរយៈកម្មវិធីបែងចែកដី និង/ឬកម្មវិធីរើទីលំនៅ ។ ដូចមានពិភាក្សាលម្អិតនៅក្នុងផ្នែក ខ នៃជំពូកនេះ ការផ្តល់ការធានាចំពោះការកាន់កាប់ដល់អ្នកតាំងទីលំនៅខុសច្បាប់ គឺជាកម្មវិធីរបស់ UNCHS/ UNDP, DfID និង Cities Alliance ។ កិច្ចប្រឹងប្រែងទាំងនេះស្ថិតក្រោមដំណើរការនៅក្នុងឆ្នាំដំបូងៗនៃគម្រោង ប៉ុន្តែត្រូវបានបញ្ឈប់ក្នុងឆ្នាំ ២០០៤ ហើយមិនត្រូវបានជំនួសវិញឡើយ ។ ជាលទ្ធផលដូចត្រូវបានទទួលស្គាល់ ដោយថ្នាក់គ្រប់គ្រង *"សម្រាប់រយៈពេល ៥ ឆ្នាំ ចុងក្រោយ ពុំមានកម្មវិធីណាមួយ ដើម្បីធ្វើនិយតកម្មការកាន់កាប់ដី នៅក្នុងតំបន់តាំងទីលំនៅក្រៅផ្លូវការ តាមរបៀបណាមួយដែលនឹងអនុញ្ញាតឱ្យពួកគេទទួលបានការផ្តល់កម្មសិទ្ធិនៅក្រោមគម្រោងឡើយ"* ។

២៦៥. **ក្រុមអធិការកិច្ចរកឃើញថា ថ្នាក់គ្រប់គ្រងបានខកខានក្នុងការទទួលស្គាល់ថា ពាក្យ ដូចជា "អ្នកតាំងទីលំនៅខុសច្បាប់" និង "តំបន់តាំងទីលំនៅក្រៅផ្លូវការ" មានលក្ខណៈលម្អៀង លុះត្រាតែត្រូវបានកំណត់ពិតប្រាកដ តាមរយៈដំណើរការវិនិច្ឆ័យ ។** គេគួរកត់សម្គាល់ថា នៅក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងទៀត ពាក្យទាំងនេះ ជាញឹកញាប់ តំណាងឱ្យក្រុមជនក្រីក្រ និងងាយរងគ្រោះបំផុត ទាក់ទងទៅនឹងការប្រឈមចំពោះការបណ្តេញចេញ និងទម្រង់ ផ្សេងទៀតនៃការរំលោភបំពាន ។ **ភាពខ្វះចន្លោះទាំងនេះនៅក្នុងការរៀបចំគម្រោង ធ្វើឱ្យថ្នាក់គ្រប់គ្រងធនាគារពិភពលោកមានការលំបាកក្នុងការសម្រេចវត្ថុបំណងដែលបានកំណត់នៃគម្រោង ទាក់ទងទៅនឹងការកាត់បន្ថយភាពក្រីក្រ និងការផ្តល់ការធានាចំពោះការកាន់កាប់ដីសម្រាប់ប្រជាជនក្រីក្រ ហេតុដូច្នេះហើយ ភាពខ្វះចន្លោះទាំង នេះមិនអនុលោមតាម OMS 2.20 ឡើយ ។**

២៦៦. **ការត្រួតពិនិត្យ :** ក្រុមអធិការកិច្ចទទួលស្គាល់ថា វត្ថុបំណងចម្បងនៃគម្រោង គឺការការពារក្រុមជនងាយរងគ្រោះ ខណៈពេលណែនាំអំពីប្រព័ន្ធ "ទំនើប" ដែលមានតម្លាភាពនៃការគ្រប់គ្រង និងការកាន់កាប់ដី ។ សមាសធាតុសំខាន់ៗ ដែលត្រូវបានណែនាំនៅក្នុងគម្រោង ដើម្បីគាំទ្រប្រជាជនងាយរងគ្រោះ គឺការពង្រឹងការយល់ដឹងជាសាធារណៈ និងការផ្ដល់លទ្ធភាពទទួលបានជំនួយផ្នែកច្បាប់ និងយន្តការដោះស្រាយវិវាទសម្រាប់ជនក្រីក្រ ។ ស្រដៀងគ្នានេះដែរ ការគាំទ្រក្រោមគម្រោងចំពោះការកែលម្អការគ្រប់គ្រងដីរដ្ឋ (សមាសធាតុទី ៥) ត្រូវបានមើលឃើញថា ជាមធ្យោបាយដ៏សំខាន់មួយក្នុងការវិនិច្ឆ័យបណ្ដឹងទាមទាររវាងរដ្ឋ និងបុគ្គលឯកជន ។ ដូចត្រូវបានទទួលស្គាល់នៅក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង សមាសធាតុទាំងនេះមិនត្រូវបានអនុវត្តតាមការរំពឹងទុកឡើយ ។

២៦៧. *ការគាំទ្រពិសេសសម្រាប់ប្រជាជនក្រីក្រ* ។ សមាសធាតុរងនៃការយល់ដឹងជាសាធារណៈ និងការចូលរួមរបស់សហគមន៍ (PACP) មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការជូនដំណឹង និងធ្វើឱ្យសាធារណជនកម្ពុជាចូលរួមនៅក្នុងដំណើរការចុះបញ្ជី និងដំណើរការវិនិច្ឆ័យ ។ ទោះបីជាមានការព្យាយាមច្រើនលើកច្រើនសារក៏ដោយ ក៏គម្រោងនេះពុំបានចុះកិច្ចសន្យាជាមួយអង្គការមិនមែនរដ្ឋាភិបាលឱ្យគាំទ្រការអនុវត្តកម្មវិធីយល់ដឹងជាសាធារណៈ និងការចូលរួមរបស់សហគមន៍ឡើយ ទោះបីជាគេទទួលស្គាល់ថា ការជ្រើសរើសអង្គការមិនមែនរដ្ឋាភិបាល មានសារៈសំខាន់ជាសារវ័ន្ត សម្រាប់កែលម្អប្រសិទ្ធភាពនៃដំណើរការ PACP ។ ថ្នាក់គ្រប់គ្រងទទួលស្គាល់ភាពខ្វះចន្លោះនៃការរៀបចំគម្រោង ក្នុងការរំពឹងឱ្យរដ្ឋាភិបាលចុះកិច្ចសន្យាជាមួយអង្គការសង្គមស៊ីវិល និងកត់សម្គាល់ថា អង្គការមិនមែនរដ្ឋាភិបាលមិនចង់ចូលរួមនៅក្នុងកិច្ចសន្យាជាមួយក្រសួង និងថា ពុំមានដំណោះស្រាយដែលមានប្រសិទ្ធភាពណាមួយត្រូវបានរកឃើញឡើយ ។

២៦៨. គម្រោងនេះមិនបានចុះកិច្ចសន្យាជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្ដល់ជំនួយផ្នែកច្បាប់ដល់ជនងាយរងគ្រោះក្រោមយន្តការដោះស្រាយវិវាទឡើយ ។ យោងតាមថ្នាក់គ្រប់គ្រង ក្រសួងមិនទទួលបានជោគជ័យក្នុងការផ្ដល់កិច្ចសន្យា ដើម្បីពង្រីក LMAP ក្រោយពីគម្រោងសាកល្បងមួយជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ។ ថ្នាក់គ្រប់គ្រង ទទួលស្គាល់ថា *"ជម្រើសផ្សេងៗក្រៅពីការជ្រើសរើសអង្គការមិនមែនរដ្ឋាភិបាល ដោយប្រើប្រាស់ធនធានឥណទាន គួរត្រូវបានពិចារណានៅដំណាក់កាលអនុវត្តន៍"* ។

២៦៩. *ការគ្រប់គ្រងដីរដ្ឋ* ។ ដូចគ្នានេះដែរ ផ្នែកសម្រាប់គ្រប់គ្រងដីធ្លី គឺបានអនុវត្តខ្លះៗតែប៉ុណ្ណោះ។ ទន្ទឹមនឹងពេលដែលរដ្ឋាភិបាល បានបង្កើតក្របខ័ណ្ឌច្បាប់កែលម្អមួយសម្រាប់កំណត់ដីធ្លី ការអនុវត្តរបស់ខ្លួនមានភាពរីកចំរើនយឺតខ្លាំង និងហាក់ដូចជាមិនអនុវត្ត ជាប្រព័ន្ធដូចអ្វីដែលបានចែងនៅក្នុងគម្រោងពេលដែលគេតាក់តែងដំបូង។ រហូតមកដល់ពេលដែលថ្នាក់គ្រប់គ្រងរៀបចំឯកសារឆ្លើយតបនេះ គ្មានខេត្ត ស្រុក ឬឃុំ ណាមួយ មានផែនទីកំណត់ដីធ្លីដែលបង្ហាញពីព្រំប្រទល់ និងប្រភេទដីនៅក្រោមការប្រើប្រាស់ជាសាធារណៈ។ ហេតុដូចនេះ គណៈគ្រប់គ្រងបានចាត់ទុកថា ផ្នែកនេះ មានការពេញចិត្តបន្តិចបន្តួចបំផុតសម្រាប់គម្រោងនេះ។ គណៈគ្រប់គ្រង បានកំណត់ថា "*ការតាក់*

*តែងគម្រោង ប៉ាន់ស្មានមិនគ្រប់គ្រាន់សម្រាប់ធាតុនៃភាពស្មុគស្មាញ និងបញ្ហានយោបាយ ចំពោះការគ្រប់គ្រងដីរដ្ឋ"*។[១៥៤]

**២៧០. ក្រុមអធិការកិច្ចរកឃើញថា មិនបានអនុវត្តនូវវិធានការទាំងអស់ដែលបានតាក់តែងដាក់លាក់សម្រាប់គាំទ្រដល់អ្នកក្រីក្រ និងអ្នកដែលងាយរងគ្រោះ ដូចដែលមានចែងនៅក្នុងផែនការគម្រោងទេ។ ក្រុមអធិការកិច្ចបានរកឃើញថា គណៈគ្រប់គ្រងមិនបានតាមឱ្យជាប់លាប់ចំពោះការប្ដេជ្ញាចិត្តអនុវត្តគម្រោង ដើម្បីពង្រឹងការយល់ដឹងដល់សាធារណៈជន និងសហគមន៍ចូលរួម ធានាការពារផ្លូវច្បាប់ដល់ប្រជាជនដែលប្រឈមនឹងហានិភ័យនៃការបណ្ដេញចេញ និងមិនបានផ្ដល់ឱ្យបានគ្រប់គ្រាន់ចំពោះការទទួលបានយន្តការដោះស្រាយវិវាទ។ ទាំងនេះមិនបានអនុលោមទៅនឹងគោលការណ៍ OP/BP ១៣.០៥។** ក្រុមអធិការកិច្ចរកឃើញថា ការខ្វះខាតការគាំទ្រចំពោះអ្នកក្រីក្រទាំងនេះ គឺដោយសារការអនុវត្តមិនបានគ្រប់ជ្រុងជ្រោយ និង មិនបានគ្រប់គ្រាន់ចំពោះ ផ្នែកមួយចំនួននៃគម្រោង ដែលវាបង្កឱ្យពួកគាត់ងាយរងគ្រោះចំពោះការទាមទារដីរបស់ពួកគេ។ ថ្នាក់គ្រប់គ្រងបានអះអាងនៅក្នុងឯកសារឆ្លើយតបរបស់ខ្លួនថា សកម្មភាពទាំងនេះមានសារៈសំខាន់ដើម្បីអនុវត្តគម្រោងទាំងស្រុង ត្រូវបានពន្យាពេល ឬមិនបានអនុវត្តរហូតមកដល់ពេលដែលឥណទាននេះត្រូវបិទ។

## ច. មានការប្ដឹងតវ៉ាថាសហគមន៍ផ្សេងៗទៀតនៅខេត្តដែលគម្រោងនេះគ្របដណ្ដប់ក៏មានការបណ្ដេញ ចេញដោយបង្ខំដែរ

### ១. ការទាមទាររបស់អ្នកដាក់សំណើរ និងការឆ្លើយតបរបស់គណៈគ្រប់គ្រង

២៧១. អ្នកដាក់សំណើរបានទាមទាថា *"បឹងកក់ មិនមែនជារឿងដាក់ដោយឡែកទេ។ នៅតាមបណ្ដាទីប្រជុំជននានា នៅជនបទ និងសហគមន៍ជនជាតិដើមនៅទូទាំងប្រទេសកម្ពុជាក៏មិនអាចទទួលបានកម្មសិទ្ធិដីធ្លី និង/ឬមិនទទួលបានយន្តការដោះស្រាយវិវាទក្រោមគម្រោង LMAP ហើយអ្នកទាំងនោះមិនអាចការពារសិទ្ធិលើដីធ្លីក្រោមប្រព័ន្ធផ្លូវការមួយដែលចែងដោយគម្រោង LMAP ។ សហគមន៍មួយចំនួនក្នុងចំណោមសហគមន៍ទាំងនេះ មានការកើនឡើងករណីកម្មសិទ្ធិមិនមានសុវត្ថិភាព និងការបណ្ដេញ ចេញដោយបង្ខំ"*។

២៧២. នៅក្នុងការឆ្លើយតបរបស់ខ្លួន គណៈគ្រប់គ្រងបានទទួលស្គាល់ថា *"អសុវត្ថិភាពកម្មសិទ្ធិលើដីធ្លីនៅបន្តជាបញ្ហាចំបងនៅកម្ពុជា"* ហើយការកើនឡើងតម្លៃដីនាពេលថ្មីៗកន្លងទៅនេះបាននាំទៅរកការដាក់គំនាប *"ជាពិសេសទៅលើសហគមន៍ងាយរងគ្រោះនានាដែលកំពុងតែរស់នៅលើដីសាធារណៈរបស់រដ្ឋ"*។[១៥៥] ថ្នាក់គ្រប់គ្រងបានថ្លែងថា គឺថា *"ពេលនេះបានដឹងថាតំបន់មួយចំនួន ដែលបានប្រកាសជាតំបន់វិនិច្ឆ័យក្រោមគម្រោង ដែលគ្រួសារទាំងនោះរស់នៅ*

---

[១៥៤] ការឆ្លើយតបរបស់គណៈគ្រប់គ្រង ទំព័រទី ៣១។

[១៥៥] ការឆ្លើយតបរបស់គណៈគ្រប់គ្រង ទំព័រទី ៥០។

*ត្រូវបានបណ្តេញចេញ ឬគំរាមបណ្តេញចេញ"*។ ថ្នាក់គ្រប់គ្រងក៏បានកត់សម្គាល់ដែរថា *"នៅមានការគំរាមបន្តទៀតចំពោះការដោះដូរដី និងការបណ្តេញចេញចំពោះសហគមន៍ ដែលងាយរងគ្រោះ"*។[១៥៦]

២៧៣. ថ្នាក់គ្រប់គ្រងបានដាក់ចេញនូវសកម្មភាពមួយចំនួនដើម្បីដោះស្រាយការព្រួយបារម្ភទាំងនេះ ដោយបានកត់សម្គាល់ថា *"ប្រធានគម្រោងកំពុងតែប្រមូលព័ត៌មានដើម្បីកំណត់ករណីដែលអាចកើតមានឡើងចំពោះសហមន៍ ដែលប្រហែលជាត្រូវបាន គេបណ្តេញចេញពីតំបន់វិនិច្ឆ័យដោយមិនមានការអនុវត្តឱ្យបានត្រឹមត្រូវតាមអ្វីដែលមានចែងនៅក្នុង RPF"*។ គណៈគ្រប់គ្រងបានថ្លែងថា *"រហូតដល់ខែ តុលា ឆ្នាំ ២០០៩ មាន៨ករណី ត្រូវបានកំណត់មានភូមិចំនួន ១០ (ឬផ្នែកខ្លះ នៃភូមិ)"*។ បន្ថែមពីលើនេះ ថ្នាក់គ្រប់គ្រងបានអះអាងថា ចាប់តាំងពីខែមេសា ឆ្នាំ ២០០៩ មានការស្នើសុំម្តងហើយម្តងទៀត សុំឱ្យរដ្ឋាភិបាលដាក់ចេញនូវការផ្អាក់ជាបណ្តោះអាសន្នចំពោះការបណ្តេញចេញដោយបង្ខំទាំងនៅ *"ទីក្រុងភ្នំពេញ និងនៅតំបន់ផ្សេងៗទៀត"*។

## ២. ការវិភាគរបស់ក្រុមអធិការកិច្ច

២៧៤. **ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា។** ការបណ្តេញចេញដោយបង្ខំគឺជាបញ្ហាមួយដ៏ធំទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្សនៅកម្ពុជា ដែលប៉ះពាល់ដល់គ្រួសាររាប់ពាន់នៅទូទាំងប្រទេស ទាំងនៅតំបន់ទីក្រុង និងនៅជនបទ ជាពិសេសប្រជាជន ដែលរស់នៅក្នុងភាពក្រីក្រ។ មានការកត់ត្រាយ៉ាងច្រើនក្នុងឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាលទាក់ទងទៅនឹងបញ្ហានេះ។[១៥៧] គម្រោងអភិវឌ្ឍន៍បានទទួលជាលទ្ធផលនូវការជំលៀស ជាពិសេសនៅតំបន់ទីក្រុង និងតំបន់ជាយក្រុង។ យោងតាមរបាយការណ៍វាយតម្លៃភាពក្រីក្រនៅឆ្នាំ ២០០៦ របស់ធនាគារពិភពលោក បានរាយការណ៍ថា នៅចន្លោះ ឆ្នាំ ១៩៩៨ និង ឆ្នាំ ២០០៣ សាលា ក្រុងបានបណ្តេញប្រជាជន ១១០០០ គ្រួសារដោយបង្ខំ ភាគច្រើនគឺគ្រួសារក្រីក្រនៅទីក្រុងដែលរស់នៅក្នុងឬជិតតំបន់កណ្តាលទីក្រុង។[១៥៨] យោងតាមអង្គការលើកលែងទោសអន្តរជាតិបានឱ្យដឹងថា ប្រជាជនកម្ពុជាប្រមាណ ១៥០០០០ នាក់នៅទូទាំងប្រទេស ត្រូវបានគេដឹងថារស់នៅក្នុងហានិភ័យនៃការបណ្តេញចេញ។[១៥៩]

---

[១៥៦] ការឆ្លើយតបរបស់គណៈគ្រប់គ្រង ទំព័រទី ២៦ កថាខ័ណ្ឌទី ៦១។

[១៥៧] ជាឧទាហរណ៍ សូមមើល Rights Razed: ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា ដោយអង្គការលើកលែងទោសអន្តរជាតិឆ្នាំ ២០០៨។ Losing Ground របស់គណៈកម្មការសកម្មភាពសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ ២០០៩។ Untitled របស់អង្គការ BABSEA និង JRS ឆ្នាំ ២០០៩។

[១៥៨] ប្រទេសកម្ពុជាៈ តើអាចកាត់បន្ថយបានពាក់កណ្តាលទេនៅឆ្នាំ ២០១៥? ការវាយតម្លៃភាពក្រីក្រនៅកម្ពុជា ធនាគារពិភពលោក ភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០០៦ ទំព័រទី ៤៨ (អង់គ្លេស)។

[១៥៩] Rights Razed: ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា ដោយអង្គការលើកលែងទោសអន្តរជាតិឆ្នាំ ២០០៨ ទំព័រទី ៧ (អង់គ្លេស)។

២៧៥. នៅឆ្នាំ ១៩៩២ កម្ពុជាបានចុះសច្ចាប័នសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌[១៦០] ដែលបង្កើតចេញជាសិទ្ធិលើលំនៅដ្ឋានសមរម្យ។[១៦១] គណៈកម្មការតាមដានការអនុវត្តអនុសញ្ញានេះ បានបញ្ចេញការព្រួយបារម្ភចំពោះការបណ្តេញចេញដោយបង្ខំ និងបង្ខំឱ្យទទួលយកដែលវាមិនឆ្លើយតបទៅនឹងតម្រូវការនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនេះ។[១៦២]

២៧៦. **ក្រុមអធិការកិច្ចបានកត់សម្គាល់ថា ការបណ្តេញចេញដោយបង្ខំ វាមិនមែនជារឿងថ្មីនៅកម្ពុជាទេ ហើយដូចអ្វីដែលឯកសារវាយតម្លៃភាពក្រីក្រនៅកម្ពុជាដែលរៀបរៀងឡើងដោយធនាគារពិភពលោក បានសរសេរថា រឿងនេះវាបានកើតឡើងនៅភ្នំពេញមុនពេលដែលគម្រោងនេះរៀបចំមកម្លេះ។ ដោយសារតែគម្រោងបានបញ្ចូលការតាំងទីលំនៅ នៅក្នុងទីក្រុងធំៗ ដោយរួម ទាំងទីក្រុងភ្នំពេញ ដែលជាទីកន្លែងមួយក្នុងចំណោមខេត្តផ្សេងៗដែលដាក់នៅក្នុងគម្រោង នេះជាការប្រឈមទៅនឹងហានិភ័យ ខ្ពស់សម្រាប់ធនាគារពិភពលោក។ ក្រុមអធិការកិច្ចបានកត់សម្គាល់ថា ការរៀបចំគម្រោង នេះមិនបានដោះស្រាយបញ្ហាដ៏សំខាន់ និងហានិភ័យលើកេរ្តិ៍ឈ្មោះនេះឱ្យបានគ្រប់គ្រាន់នោះទេ ។**

២៧៧. **ការអនុវត្តគម្រោង និងការផ្ទៀងផ្ទាត់ទៅនឹង RPF។** មានការព្រួយបារម្ភមួយចំនួន ត្រូវបានលើកឡើងក្នុងអំឡុងពេលអនុវត្តគម្រោង LMAP ទាក់ទិនទៅនឹងមម្លាភាព និងគណនេយ្យភាពក្នុងប្រព័ន្ធនិងនីតិវិធីចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ ចាប់តាំងពីដើមឆ្នាំ ២០០៥។ ជាលទ្ធផល មានការត្រួតពិនិត្យឡើងវិញជាឯករាជមួយត្រូវបានធ្វើឡើងរវាង ខែវិច្ឆិកា ឆ្នាំ ២០០៥ និងខែមករា ឆ្នាំ ២០០៦ ដោយកំណត់លើខេត្តទាំង១១ដែលគម្រោងនេះគ្របដណ្តប់ និងបានអនុវត្ត។[១៦៣] យោងតាមសេចក្តីសង្ខេបរបស់វា ឯកសារពិនិត្យមើលឡើងវិញនេះ បានកំណត់ និងបញ្ចូលវិធីសាស្ត្រចូលរួមដោយប្រើប្រាស់ការសម្ភាសន៍ជាមួយនឹងគ្រួសារ ដែលបានទទួលផល ដោយបញ្ចូលជាមួយនឹងការរកឃើញនានា ដែលបានមកពីការពិភាក្សាជាក្រុមមិនផ្លូវការរៀបចំដោយអ្នកភូមិ និងអ្នកផ្តល់ដំណឹង

---

[១៦០] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) គឺសន្ធិសញ្ញាពហុភាគីមួយដែលអនុម័តដោយសភាអង្គការសហប្រជាជាតិកាលពីថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ហើយចាប់ផ្តើមចូលជាធរមានចាប់តាំងពីថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៦។ អនុសញ្ញានេះគឺតម្រូវឱ្យភាគីចុះហត្ថលេខីធ្វើ ការឆ្ពោះទៅរកការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ESCR) សម្រាប់បុគ្គលម្នាក់ៗ ដោយរួមទាំង សិទ្ធិលើពលកម្ម និងសិទ្ធិលើសុខភាព អប់រំ និងការរស់នៅប្រកបទៅដោយស្តង់ដារសមរម្យ។ អនុសញ្ញានេះគឺជាផ្នែកមួយនៃច្បាប់សិទ្ធិ មនុស្សអន្តរជាតិ ស្របជាមួយនឹងសេចក្តីប្រកាសជា សកលស្តីពីសិទ្ធិមនុស្ស (UDHR) និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជាជនស៊ីវិល និងនយោបាយ ICCPR។

[១៦១] មាត្រាទី១១នៃ ICESCR

[១៦២] គណៈកម្មការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ កំណត់សម្គាល់ទូទៅទី៤: សិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ (មាត្រាទី ១១ នៃអនុសញ្ញា) សម័យប្រជុំទី៦ ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ១៩៩១ កឋាខ័ណ្ឌទី ១៨ (អង់គ្លេស)។

[១៦៣] ការពិនិត្យមើលឡើងវិញនៃបញ្ហាតម្លាភាព និងការទទួលខុសត្រូវ ខែកុម្ភៈឆ្នាំ ២០០៦

សំខាន់ៗ ដើម្បីបញ្ជាក់ និងបង្ហាញព័ត៌មានបន្ថែមលើបទពិសោធន៍នៅមូលដ្ឋាន ជាមួយនឹងដំណើរការចុះ បញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ។

២៧៨. ជារួម តំណាងគ្រួសារចំនួន ១២៣៦ នាក់បានចូលរួមក្នុងការធ្វើបទសម្ភាសន៍នេះ ហើយក្រុមពិភាក្សាមិនផ្លូវការត្រូវបានរៀបចំធ្វើឡើងនៅភូមិចំនួន ៥៣ ដែលប្រកាសជាតំបន់វិនិច្ឆ័យក្នុងខេត្តទាំង ១១។ ឯកសារពិនិត្យមើលឡើងវិញបានកត់សម្គាល់ ដូចនេះ មិនមានព័ត៌មានស្តីពីសិទ្ធិដែលអាច និងសិទ្ធិទទួលបាន ក្នុងការទាមទារលើទ្រព្យសម្បត្តិ (ជាពិសេសទ្រព្យសម្បត្តិរដ្ឋ) តាមរយៈការទាមទារយករបស់រដ្ឋត្រូវបានផ្តល់ឱ្យនោះទេ **ហើយការខ្វះចន្លោះនេះ វាហាក់ដូចជាលេចចេញនូវផលប៉ះពាល់ជាខ្លាំង យ៉ាងហោចណាស់ប្រមាណជា ១ភាគ៥ (១៩,៦ ភាគរយ) នៃគ្រួសារទាំងអស់ គឺរកឃើញបែបនេះនៅក្នុងស្រុក ប្រកាសជា តំបន់វិនិច្ឆ័យចំនួន ១៣**[១៦៤] **ក្នុងចំណោម ១៩ ដែលបានទៅទស្សនកិច្ច។** *(មានចែងនៅក្នុងច្បាប់ដើម)*។

២៧៩. យោងតាមការពិនិត្យមើលឡើងវិញដោយឯករាជ ពុំមានហេតុផលជាឯកសារចំពោះការបដិសេធលើកម្មសិទ្ធិ ឬការចុះ បញ្ជីនេះត្រូវបានផ្តល់ជូនដល់មេគ្រួសារនិងគ្រួសារ។ លើសពីនេះទៅទៀតឯកសារពិនិត្យមើលឡើងវិញនេះ បានលើកឡើងថា ការមិនបង្ហាញឱ្យច្បាស់នៃការរក្សាទុកដីរបស់រដ្ឋ គឺបានលើកឡើងថាវានឹងមានផលប៉ះពាល់ដ៏ខ្លាំងមួយដល់គោលដៅ និងគោលបំណងរបស់គម្រោង LMAP។ ដូចដែលបានចែងខាងលើ ឯកសារពិនិត្យមើលឡើងវិញនេះ បានរាយការណ៍ថា ២០ ភាគរយ នៃសហគមន៍ដែលបានប្រឹក្សាមានអារម្មណ៍ថាពួកគេ *"បាត់"* ដីរបស់ពួកគេមួយចំនួនដោយសាររដ្ឋបានទាមទារថាដីនោះជាដីរបស់រដ្ឋ។ ដូចដែលក្នុងករណីបឹងកក់ ឯកសារពិនិត្យមើលឡើងវិញបានកត់សម្គាល់អំពីហេតុការនេះថាជាកន្លែងដែលប្រជាជនត្រូវបានគេប្រាប់ថា ពួកគាត់កំពុងតែរស់នៅលើតំបន់ដីមានជម្លោះ គឺមានន័យថា *"ដីរដ្ឋ"*។ លើសពីនេះទៅទៀត របាយការណ៍នោះបានកត់សម្គាល់ថា មិនមានព័ត៌មានត្រូវបានគេផ្តល់ជូនដល់គ្រួសារទាក់ទិនទៅនឹងសិទ្ធិអាចទទួលបានសំណងសម្រាប់ការប៉ះពាល់ធ្ងន់ធ្ងរ ដូចដែលបានចែងនៅក្នុងឯកសារការងារសង្គមដែលបានដាក់នៅក្នុងគម្រោង LMAP។

២៨០. **ទោះបីជាមានការរកឃើញដ៏ជាក់លាក់នៃក្រុមត្រួតពិនិត្យ និងការរកឃើញម្តងហើយម្តងទៀត ក្នុងរបាយការណ៍ពិនិត្យមើលគម្រោងរបស់គណៈគ្រប់គ្រង ដែលបង្ហាញអំពីភាពមិនគ្រប់គ្រាន់នៃយន្តការដោះស្រាយជំលោះ ជាពិសេសនៅពេលដែលភាគីពាក់ព័ន្ធនោះជាអ្នកមានអំណាចក្តី ធនាគារពិភពលោកមិនមានវិធានការគន្លឹះណាមួយដើម្បីដោះស្រាយផលប៉ះពាល់មិនល្អទាំងនោះទេ។** យោងតាមការរកឃើញរបស់ក្រុមត្រួតពិនិត្យ មិនមានរបាយការណ៍ត្រួតពិនិត្យគម្រោង បានសរសេរឧប្បត្តិហេតុណាមួយដែលផ្ទៀងផ្ទាត់ទៅនឹង RPF។ ក្រុម

[១៦៤] ឯកសារពិនិត្យមើលឡើងវិញនេះបានចុះភ្នំពេញ (ខ័ណ្ឌទួលគោក) ខេត្តកណ្តាល (ស្រុកកណ្តាលស្ទឹង) ខេត្តកំពត់ (ស្រុកកំពង់ត្រាចអង្គរជ័យ) ខេត្តកំពង់ស្ពឺ (ស្រុកសំរោង) ខេត្តព្រៃវែង (ស្រុកបាភ្នំ ស្រុកព្រៃវែង) ក្រុងព្រះសីហនុ (ខ័ណ្ឌមិត្តភាព) ខេត្តសៀមរាប (ស្រុកសៀមរាប) ខេត្តតាកែវ (ស្រុកសំរោង និងស្រុកបាទី) ខេត្តកំពង់ធំ (ស្រុកសន្ទុក) ខេត្តកំពង់ចាម (ស្រុកបាធាយ)។

អធិការកិច្ចកត់សម្គាល់ថាគោលនយោបាយ RPF មិនត្រូវបានគេអនុវត្តក្នុងអំឡុង ពេលនៃការអនុវត្តគម្រោងទេ ដោយពិចារណាទៅលើវិសាលភាពគ្របដណ្តប់របស់វាចំពោះដីរដ្ឋ។

២៨១. **សកម្មភាពថ្មីៗរបស់ថ្នាក់គ្រប់គ្រង។** យោងតាមប្រភពផ្សេងៗ ការបណ្តេញចេញដោយបង្ខំបានឡើងដល់កំពូល នៅឆ្នាំ ២០០៩ នៅពេលដែលមានទីតាំងចំនួន ២៦ កន្លែង មានប្រជាជនចំនួន ២៧០០០ នាក់ ត្រូវបានគេបណ្តេញចេញដោយបង្ខំ។ នៅ ខែមករា ឆ្នាំ ២០០៩ មន្ត្រីឯកទេសឯករាជរបស់អង្គការសហប្រជាជាតិម្នាក់បានហៅការបណ្តេញចេញដោយបង្ខំនៅកម្ពុជាថាជា *"ផ្នែកបំសិទ្ធិមនុស្ស"* ហើយបានស្នើសុំឱ្យមានការសងដល់អ្នកដែលបានបង់ផ្ទះសំបែង និងផ្តល់ជម្រើសជាផ្ទះសំបែង។[១៦៥]

៣៨២. ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០៩ បន្ទាប់ពីបេសកកម្មពិនិត្យមើលឡើងវិញសម្រាប់ការលើកកម្ពស់គម្រោង រកឃើញថា ហេតុការណ៍នៅបឹងកក់មានពាក់ព័ន្ធនឹងគម្រោង LMAP ថ្នាក់គ្រប់គ្រង និងម្ចាស់ជំនួយ៩ទៀត បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ ស្នើសុំឱ្យបញ្ឈប់ការបណ្តេញចេញប្រជាជនក្រីក្រនៅទីក្រុងនៅប្រទេសកម្ពុជា ។ មានអង្គការជាតិ និងអន្តរជាតិ ជាង ៦០ បាន សាទរចំពោះសេចក្តីប្រកាសនេះ។

៣៨៣. ថ្នាក់គ្រប់គ្រងធនាគារពិភពលោក បានជំរាបទៅក្រុមអធិការកិច្ចថា នៅខែធ្នូឆ្នាំ ២០០៩ ថ្នាក់គ្រប់គ្រងបានធ្វើការស្រាវជ្រាវនៅតាមទីតាំងដើម្បីស្វែងយល់ថា តើមានការត្រួតត្រារាំងរបាយការណ៍ការបណ្តេញចេញដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ហើយសារព័ត៌មាន និងការចុះបញ្ជីដីលក្ខណៈជាប្រព័ន្ធនៅតំបន់ដែលគ្របដណ្តប់ដោយគម្រោង LMAP។ ក្រុមត្រួតពិនិត្យរកឃើញថា បន្ថែមពីលើការបណ្តេញចេញនៅតំបន់បឹងកក់ដែលវាប៉ះពាល់ដល់ប្រជាជនប្រមាណ ៤២៥០ គ្រួសារ នៅមានភូមិចំនួន ២០ ទៀត ដែលត្រូវបានគេប្រកាសជាតំបន់វិនិច្ឆ័យ ប៉ុន្តែប្រជាជននៅភូមិទាំងនោះត្រូវបានគេបង្ខំឱ្យចេញ ឬទទួលរងការគំរាមកំហែងឱ្យចាកចេញ។ ភូមិទាំង ២០ នេះ មានប្រជាជនប្រមាណ ២៦០០ គ្រួសារ។ ក្រុមត្រួតពិនិត្យនេះក៏បានរក ឃើញថា គម្រោងមិនបានបិទប្រកាសជាសាធារណៈនូវករណីចំនួនពាក់កណ្តាលលើករណី ២៣ ហើយស្ទើរតែគ្រប់ករណីទាំងអស់ មិនបានឆ្លងកាត់នីតិវិធីការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធទេ។ យោងតាមការត្រួតពិនិត្យនេះ បានឱ្យដឹងថា នៅពេលដែលមានការបណ្តេញមួយចំនួនកើតឡើងលើប្រជាជនដែលរស់នៅលើដីរដ្ឋ ដែលអះអាងដោយរដ្ឋាភិបាលគោលនយោ-បាយ RPF មិនបានអនុវត្ត ហើយស្ទើរតែគ្រប់ករណីទាំងអស់ដែលប៉ះពាល់ដល់ប្រជាជនពួកគាត់មិនបានទទួលសំណង ឬទទួលបានសំណងដែរ ប៉ុន្តែមិនឆ្លើយតបទៅនឹងគោលនយោបាយ O.D 4.30 របស់ធនាគារពិភពលោកស្តីពីការផ្លាស់ប្តូរទីលំនៅដោយស្ម័គ្រចិត្ត។

---

[១៦៥] ការបណ្តេញចេញដោយបង្ខំបានបន្សល់ទុកប្រជាជនរាមពាន់នាក់គ្មានផ្ទះសំបែងជ្រកនៅកម្ពុជា នេះបើតាមការបរិយាយរបស់អ្នកឯកទេស អង្គការសហប្រជាជាតិ ដែលដកស្រង់ចេញពីមណ្ឌលព័ត៌មានអង្គការសហប្រជាជាតិ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩។ http://www.un.org/apps/news/story.asp?NewsID=29723&Cr=housing&Cr1=human+rights

២៨៥. **មិនមានការតាមដាន និងវាយតម្លៃឱ្យបានគ្រប់គ្រាន់។** DCA បានទាមទារថាប្រព័ន្ធតាមដាន និងវាយតម្លៃមួយត្រូវតែបង្កើតឡើងសម្រាប់គម្រោងតាំងពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០២ ។ ការត្រួតពិនិត្យមើលលើរបាយការណ៍ត្រួតពិនិត្យគម្រោងបានបង្ហាញថា ប្រព័ន្ធតាមដាននិងវាយតម្លៃមិនត្រូវបានគេបង្កើតឡើងទេ រហូតដល់ឆ្នាំ ២០០៧។ ក្នុងអំឡុងពេលពិនិត្យមើលឡើងវិញនៅពាក់កណ្តាលអាណត្តិនៃគម្រោង ចាប់ពីថ្ងៃទី២៧ ខែកញ្ញា ដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០០៤ ប្រធានគម្រោងបានកត់ត្រា នូវការទាមទារឱ្យបង្កើតប្រព័ន្ធតាមដាននិងវាយតម្លៃជាប្រព័ន្ធនិងរឹងមាំមួយសម្រាប់គម្រោង LMAP ឱ្យបានចប់រួចរាល់នៅថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៥ ។ ក្រោយមកទៀតមានបេសកកម្មត្រួតពិនិត្យចំនួនពីរ គឺមួយនៅខែមិថុនា និងមួយទៀតនៅខែវិច្ឆិកា ឆ្នាំ ២០០៥ បានកត់ត្រាដដែលថា មិនមានសកម្មភាពបង្កើតជាប្រព័ន្ធតាមដាននិងវាយតម្លៃទេ។

២៨៦. ដោយមានការតាមពិនិត្យមើលលើការទាមទារនេះ គោលការណ៍តាមដាននិងការវាយតម្លៃមួយ ត្រូវបានអនុម័តដោយគម្រោង LMAP នៅខែធ្នូ ឆ្នាំ២០០៦ ។ បេសកកម្មត្រួតពិនិត្យគម្រោងដែលធ្វើឡើងចាប់ពីថ្ងៃទី ៣០ ខែឧសភា ដល់ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០៧ បានរាយការណ៍ថា គម្រោងបានចាប់ផ្តើមអនុវត្តតាមប្រព័ន្ធតាមដាន និងវាយតម្លៃដែលមានការកែតម្រូវនេះ។ តែទោះជាយ៉ាងណាក៏ដោយ វាមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តនូវអ្វីដែលបានកន្លងហួស ចាប់តាំងពីការអនុម័តនៃប្រព័ន្ធដើម្បីវាយតម្លៃប្រសិទ្ធិភាពរបស់វាទេ។ ដូចដែលបានទទួលស្គាល់ដោយគណៈគ្រប់គ្រងថា ហេតុការណ៍នៅកណ្តាលទីក្រុងភ្នំពេញ នៅតំបន់ប្រកាសវិនិច្ឆ័យដែលទាក់ទិននឹងមនុស្សចំនួនជាង ៤០០០ គ្រួសារ បានទាញចំណាប់អារម្មរបស់ពួកខ្លួនដោយ ផែដន្យក្នុងអំឡុងពេលមានបេសកកម្មត្រួតពិនិតគម្រោងកាលពីខែមិថុនា ឆ្នាំ ២០០៨។ **ការពិនិត្យមួយចំពោះរបាយការណ៍ បេសកកម្មបានបង្ហាញថា មិនមានប្រព័ន្ធតាមដាននិងវាយតម្លៃសម្រាប់គម្រោងរហូតដល់ឆ្នាំ ២០០៧។ ក្រុមអធិការកិច្ចរកឃើញថា ដោយមានការខ្វះចន្លោះប្រព័ន្ធតាមដាននិងវាយតម្លៃដ៏រឹងមាំមួយសម្រាប់គម្រោង ថ្នាក់គ្រប់គ្រងមិនបានដឹងអំពីបញ្ហាដ៏ធំ ដែលបានកើតឡើងចំពោះគម្រោង។ ការនេះវាមិនបានប្រតិបត្តិតាមគោលនយោបាយ** OP/BP 13.05 **ទេ។**

# ជំពូក ៤ : មេរៀន និងបញ្ហាដែលមានលក្ខណៈជាប្រព័ន្ធ

២៨៧. ការស៊ើបអង្កេតនេះបានបង្ហាញអំពីបញ្ហាដែលមានលក្ខណៈជាប្រព័ន្ធនៃភាពពាក់ព័ន្ធដែលកាន់តែច្រើនឡើងទៅនឹងប្រតិបត្តិការរបស់ធនាគារពិភពលោក។ ជំពូកនេះពិភាក្សាអំពីបញ្ហាប្រភេទនេះចំនួន៣ដែលក្រុមអធិការកិច្ចចាត់ទុកថា មានសារៈសំខាន់ជាពិសេសៈ ការគ្រប់គ្រងហានិភ័យ ការផ្តល់ប័ណ្ណកម្មសិទ្ធិដីដែលជាវិធីសាស្ត្រយន្តការតែមួយ និង បញ្ហាប្រឈមនៃគម្រោងគ្រប់គ្រងដី និងរដ្ឋបាល។ យើងសង្ឃឹមថា ការពិភាក្សានេះ អាចផ្តល់នូវមេរៀនជាច្រើន ដែល អាចជួយពង្រឹងការអនុវត្តតាមគោលនយោបាយនាពេលអនាគត និងប្រសិទ្ធិភាពនៃការអភិវឌ្ឍជារួម។

២៨៨. **ការគ្រប់គ្រងហានិភ័យ។** ការបង្កើតគម្រោងដំបូង បានប្រមើរមើលដល់យុទ្ធសាស្ត្រចំរុះមួយ រួមបញ្ចូលទាំងសមាសធាតុជាច្រើន ទាំងដើម្បីឆ្លើយតបទៅនឹងបញ្ហានៃការគាំទ្រដល់ជនក្រីក្រ និងជនងាយរងគ្រោះ នៅក្នុងដំណើរការវិនិច្ឆ័យផង និងដើម្បីបង្កើនតម្លាភាព និងលទ្ធភាពព្យាករណ៍ទុកក្នុងការកំណត់ដីរបស់រដ្ឋផង។ PAD បានទទួលស្គាល់ថាមានហានិភ័យខ្ពស់ឬច្រើនទាក់ទងទៅនឹងការសន្មត់ជាច្រើន ដែលបានចាត់ទុកថា មានលក្ខណៈសំខាន់ចំពោះការសម្រេចបាននូវទិសដៅដែលបានកំណត់ទុក។ ជាឧទាហរណ៍ PAD បានបញ្ជាក់ថា មានហានិភ័យច្រើនដែលរដ្ឋាភិបាល នឹងខ្វះការប្តេជ្ញាចិត្តក្នុងការធានាថា យន្តការដំណោះស្រាយជំលោះដំណើរការទៅប្រកបដោយប្រសិទ្ធិផល និងត្រឹមត្រូវ ហើយចាត់ទុកថាជាវិធានការកាត់បន្ថយហានិភ័យមួយដែល *"គម្រោងនេះនឹងត្រូវដើរថយក្រោយវិញ ប្រសិនបើ ខ្វះការប្តេជ្ញាចិត្តចំពោះដំណើរការដោះស្រាយជំលោះដ៏ត្រឹមត្រូវមួយ"*។

២៨៩. ដូចដែលបានរាយការណ៍នៅក្នុងជំពូក៣ សមាសធាតុសំខាន់ៗទាំងអស់នៃយុទ្ធសាស្ត្ររបស់គម្រោង ដែលមានគោលបំណងដើម្បីកាត់បន្ថយហានិភ័យនេះ ត្រូវបានពន្យាពេលនៅក្នុងការអនុវត្ត បានអនុវត្តដោយផ្នែក ឬមិនបានចាប់ផ្តើម។ ក៏ប៉ុន្តែ គម្រោងដែលមានការលើកទឹកចិត្តដ៏សកម្មពីថ្នាក់គ្រប់គ្រង បានចាប់ផ្តើមបង្កើនកិច្ចប្រឹងប្រែងដើម្បីសម្រេចគោលដៅនានាទាក់ទងទៅនឹងការផ្តល់ប័ណ្ណកម្មសិទ្ធិ។ ការងារនេះរួមមាន ការបង្ហាញឱ្យដឹងអំពីប្រាក់ខែសម្រាប់បុគ្គលិកផ្អែកលើការប្រតិបត្តិការងារ។ ដោយពិចារណាលើដំណើរការបច្ចុប្បន្ន នៅក្នុងធនាគារពិភពលោក ដើម្បី បង្ហាញឱ្យដឹងអំពីវិធីសាស្ត្រប្លែកគេសម្រាប់ការផ្តល់ប្រាក់កម្ចីសម្រាប់ការវិនិយោគផ្អែកលើការវាយតម្លៃហានិភ័យ បទពិសោធន៍របស់ LMAP គឺជាមេរៀនដែលមានសារៈសំខាន់។

២៩០. ទីមួយ ការរៀបចំ LMAP ត្រូវបានគាំទ្រដោយការវាយតម្លៃ (គឺការវាយតម្លៃសង្គម) លើសេដ្ឋកិច្ចនយោបាយនៃការគ្រប់គ្រងដីនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងហានិភ័យដែលបានពាក់ព័ន្ធ។ ក៏ប៉ុន្តែ ការយល់ឃើញក្រោយពីអ្វីដែលបានកើតឡើង បង្ហាញភស្តុតាងថា គ្មានភាពជាម្ចាស់ពេញលេញទេ នៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងឡាយនៃវិធីសាស្ត្រចំរុះនេះ ដែលត្រូវបានបង្កើតឡើង។ អ្វីដែលមើលឃើញថាសមហេតុផលនៅលើក្រដាស លទ្ធផលទទួលបានមិនដូច្នោះទេ។

២៩១. ក្រុមអធិការកិច្ចជឿថា ធនាគារពិភពលោកមានតួនាទីអភិវឌ្ឍដ៏សំខាន់មួយក្នុងការផ្តល់ហិរញ្ញប្បទានលើប្រតិបត្តិការដែលមានហានិភ័យខ្ពស់ ក៏ប៉ុន្តែ បទពិសោធន៍របស់ LMAP បង្ហាញអំពីគ្រោះថ្នាក់នៃការឆ្លើយតបទៅនឹងហានិភ័យនានា តាមរយៈការបង្កើតគម្រោងមួយដែលមានលក្ខណៈស្មុគស្មាញខ្លាំង។ ក្រុមអធិការកិច្ចបានរកឃើញថាសមាស-ធាតុ ថ្មីៗត្រូវបានដាក់បន្ថែមក្នុងអំឡុងពេលដំណើរការរៀបចំ ដោយបាត់បង់នូវភាពច្បាស់លាស់អំពីរបៀបដែលផ្នែកផ្សេងៗ ត្រូវបានសន្មត់ថា មានទំនាក់ទំនងគ្នាយ៉ាងល្អ និងគ្មានការពិចារណាត្រឹមត្រូវលើលទ្ធភាពរបស់វិធីសាស្ត្រទាំងអស់។

២៩២. ទីពីរ ការត្រួតពិនិត្យមើលរបស់ LMAP មិនបានពិចារណាគ្រប់គ្រាន់លើហានិភ័យនានាដែលពាក់ព័ន្ធនោះទេ ក្រុមអធិការកិច្ច ដូចដែលបានកត់សំគាល់នៅក្នុងជំពូកខាងដើម បានរកឃើញថា អ្នកជំនាញខាងសង្គមមិនត្រូវបានដាក់បញ្ចូល ទៅក្នុងបេសកកម្មត្រួតពិនិត្យនោះទេ ទោះបីជាមានក្ដីកង្វល់បានលើកឡើងនៅក្នុង PAD ទាក់ទងទៅនឹងការការពារផលប្រយោជន៍ជនក្រីក្រ និងជនងាយរងគ្រោះក្តី។ សញ្ញាព្រមានពីអ្នកសង្កេតការណ៍ឯករាជ្យជាច្រើន ហាក់ដូចជាមិនត្រូវបានយកមកពិចារណាទេ។ កម្មវិធីសម្រាប់ការត្រួតពិនិត្យមើលផលប៉ះពាល់បានចាប់ផ្តើមយឺតយ៉ាវណាស់ ជាមួយនឹងការសិក្សាជាមូលដ្ឋាននៅក្នុងទីក្រុងដែលបានបញ្ចប់នៅក្នុងឆ្នាំ២០០៧ គឺ៥ឆ្នាំក្រោយគម្រោងបានចាប់ផ្តើម។ ក្រុមអធិការកិច្ចមិនអាចរកឃើញនូវឯកសារកត់ត្រារបស់ថ្នាក់គ្រប់គ្រងដែលបានធ្វើការតស៊ូមតិលើការយឺតយ៉ាវក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិនោះទេ ដោយរងចាំទាល់តែមានការពង្រីកសមាសធាតុដទៃៗដែលកំពុងតែមានការអភិវឌ្ឍយឺត។

២៩៣. ក្រុមអធិការកិច្ចទទួលស្គាល់ថា កត្តាជាច្រើនក្រៅពីការត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រងបានបង្កឱ្យមានភាពមិនស្មើគ្នានៅក្នុងដំណើរការនេះ ក៏ប៉ុន្តែ បញ្ហានេះមិនបានពន្យល់ ឬធ្វើយុត្តិកម្មអំពីកង្វះខាតជាក់ស្តែងរបស់យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យដ៏រឹងមាំសម្រាប់គម្រោងនេះទេ។ ជាមួយនឹងយុទ្ធសាស្ត្រដែលមានស្រាប់បែបនេះ ពីការចាប់ផ្តើមនៃប្រតិបត្តិការនេះ ការលំបាកបន្ទាប់របស់គម្រោង អាចទំនងជាមានតិចតួច។

២៩៤. **ការផ្តល់ប័ណ្ណកម្មសិទ្ធិដីជាវិធីសាស្ត្រយន្តការតែមួយ។** LMAP ស្របគ្នាមួយនឹងគម្រោង គ្រប់គ្រងដីដែលមានស្រាប់ដទៃៗទៀតជាច្រើន ត្រូវបានធ្វើយុត្តិកម្ម ទាំងជាមធ្យោបាយដើម្បីជំរុញកំណើនសេដ្ឋកិច្ចផង និងទាំងដើម្បីកាត់បន្ថយភាពក្រីក្រផង តាមរយៈការកែលម្អសន្តិសុខនៃការកាន់កាប់ដីធ្លីសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។ មេរៀន នានាទទួលបានពី LMAP និងការស៊ើបអង្កេតដែលពាក់ព័ន្ធទៅនឹងដីធ្លីដទៃៗទៀត បង្ហាញថា ការផ្តល់ប័ណ្ណកម្មសិទ្ធិដី ខ្លួនឯងមិនអាចត្រូវបានគេរំពឹងថា ទទួលស្គាល់ទិសដៅនៃនយោបាយសង្គម និងសេដ្ឋកិច្ចផ្សេងៗគ្នា នៅក្នុងបរិបទនេះទេ។ បើពិចារណាទៅលើឯកទេសរបស់ក្រុមជំនាញ វាបានបង្ហាញច្បាស់អំពីប្រសិទ្ធិភាពនៅក្នុងតំបន់នានាដែលការប្រកួតប្រជែងដណ្តើមយកដីធ្លីមានកម្រិតទាប ហើយកន្លែងដែលជំលោះមានកម្រិត ក៏ប៉ុន្តែ គ្នាប្រសិទ្ធិភាពហើយនៅក្នុងកាលៈទេសៈខ្លះ វាផ្ទុយពីអត្ថប្រយោជន៍ និងនៅកន្លែងដែលសកម្មភាពនេះ អាចបណ្តាលឱ្យមានការកេងប្រវ័ញ្ចអត្ថប្រយោជន៍។

២៩៥. ក្រុមអធិការកិច្ចបានរកឃើញថា ភាពមានន័យមិនច្បាស់លាស់បែបនេះនៅក្នុងរចនាបទគម្រោង និងលទ្ធផល ត្រូវបានលើកឡើងនៅក្នុងការសិក្សាឯករាជ្យ និងការត្រួតពិនិត្យរបស់បុគ្គលិកមួយចំនួន រាយការណ៍តែពីរបីឆ្នាំប៉ុណ្ណោះក្រោយ ពេលគម្រោងបានចាប់ផ្តើម។ សញ្ញានៃការព្រមានទាំងនេះ ទំនងជាមិនត្រូវបានយកចិត្តទុកដាក់ខ្លាំងទេ រហូតទាល់តែបញ្ហា BKL ក្លាយជាបញ្ហាបន្ទាន់។ ក្រៅពីការត្រួតពិនិត្យមើលឡើងវិញលើមេរៀនទាំងនេះដែលបានកើតឡើង គម្រោងនេះបានសំដៅទៅរកចំនុចតែមួយកាន់តែច្រើនឡើងៗឆ្ពោះទៅរកវិធីសាស្ត្រយន្តការតែមួយដែលវាស់វែងភាពជោគជ័យទាក់ទងទៅនឹងប័ណ្ណកម្មសិទ្ធិមួយចំនួនដែលបានផ្តល់ឱ្យ។ ប្រសិទ្ធិភាពនៃវិធីសាស្ត្រនេះទាក់ទងទៅនឹងការកាត់បន្ថយភាពក្រីក្រ ទិសដៅទីពីរ មិនដែលត្រូវបានគេធ្វើការស៊ើបអង្កេតហ្មត់ចត់នោះទេ។ មេរៀនប្រតិបត្តិមួយគឺថា ការត្រួតពិនិត្យមើលឡើងវិញពាក់កណ្តាលអាណត្តិអាចត្រូវបានដាក់បញ្ចូលការត្រួតពិនិត្យមើលហ្មត់ចត់លើទិសដៅនិង រចនាបទរបស់គម្រោង ។

២៩៦. ក៏ប៉ុន្តែ បទពិសោធន៍របស់ LMAP មិនគួររារាំងធនាគារពិភពលោកមិនឱ្យធ្វើប្រតិបត្តិការនៅក្នុងតំបន់ទីក្រុងនោះទេ ទោះបីជាបទពិសោធន៍នេះផ្តល់ជាយោបល់ថា គេចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមឱ្យបានច្រើនក្នុងការបង្កើតគម្រោង និងកម្មវិធីនានាដែលឆ្លើយតបទៅនឹងបរិបទក្នុងស្រុកក្តី។ បទពិសោធន៍នេះអនុវត្តន៏ជាពិសេសចំពោះគម្រោងនានាដែលពាក់ព័ន្ធទៅនឹងការកែលំអប្រសិទ្ធិភាព និងសមធមិនៃទីផ្សារដី និងទីផ្សារលំនៅដ្ឋាន នៅក្នុងតំបន់ធ្វើនគរូបនីយកម្មឆាប់រហ័យ។

២៩៧. **បញ្ហាប្រឈមរបស់គម្រោងគ្រប់គ្រងដី និងរដ្ឋបាល។** ដោយសារតែក្រុមអធិការកិច្ចក៏បានកត់សម្គាល់ផងដែរនៅក្នុងរបាយការណ៍របស់ខ្លួននាពេលថ្មីៗស្តីអំពីប្រទេសប៉ាណាម៉ា គឺគម្រោងរដ្ឋបាលដីធ្លី ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចលើគម្រោងទាំងពីរនេះបានគូសបញ្ជាក់ហានិភ័យជាច្រើនទាក់ទងទៅនឹងគម្រោងគ្រប់គ្រងដី និងរដ្ឋបាល ដែលបង្ហាញថា គម្រោងដីធ្លីមានលក្ខណៈស្មុគ្រស្មាញ និងពិបាកអនុវត្តឱ្យមានប្រសិទ្ធិភាព ហើយជាញឹកញាប់ គឺតែងតែមានភាពចម្រូងចម្រាស់ផ្នែកនយោបាយ។ ការចូលរួមពាក់ព័ន្ធក្នុងពេលអនាគតនៅក្នុងគម្រោងទាំងនេះ នឹងទទួលបានអត្ថប្រយោជន៍ ពីការគាំទ្រផ្នែកបច្ចេកទេសដែលត្រូវបានពង្រឹង ការវាយតម្លៃលើហានិភ័យប្រតិបត្តិការដែលមានលក្ខណៈជាប្រព័ន្ធ កាន់តែច្រើនឡើង និងហានិភ័យនៃលក្ខណៈសេដ្ឋកិច្ចនយោបាយ និងការបែងចែកបុគ្គលិកដែលបានបណ្តុះបណ្តាលគ្រប់គ្រាន់ និងធនធាន។

## ឧបសម្ព័ន្ធ ១ : តារាងលទ្ធផល

| បញ្ហា | ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង | លទ្ធផលរកឃើញដោយក្រុមអធិការកិច្ច |
|---|---|---|
| **ការប្រកាសទាមទារដែលព្រឹត្តិការណ៍នៅក្នុង BKL ត្រូវបានដាក់បញ្ចូនជាបន្តបន្ទាប់ ទៅកាន់ LMAP** | តាមការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងបញ្ជាក់ថា *"តំបន់វិនិច្ឆ័យស្រះចកគឺជាតំបន់មួយដែលគម្រោងនេះ កំពុងអនុវត្តការផ្តល់ប័ណ្ណកម្មសិទ្ធិដីដែលមានលក្ខណៈជាប្រព័ន្ធ"* ហើយនីតិវិធីនានាសម្រាប់ការធ្វើវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធនេះ និងគោលការណ៍ណែនាំផ្នែកបរិស្ថាន និងសង្គមដែលបានឯកភាពសម្រាប់ LMAP នឹងយកមកអនុវត្ត ។ | **ក្រុមអធិការកិច្ចបានរកឃើញថា តំបន់ BKL ស្ថិតនៅក្នុងខេត្តដែលគ្របដណ្តប់ដោយគម្រោងមួយ ហើយត្រូវបាន ប្រកាសតំបន់វិនិច្ឆ័យក្រោម LMAP ដូច្នេះ សកម្មភាពនានាដែលពាក់ព័ន្ធទៅនឹងការ បញ្ជាក់អំពីសិទ្ធិកាន់កាប់ដី និងភាពជាម្ចាស់ បន្ទាប់ពីការជូនដំណឹងអំពីការធ្វើតំបន់វិនិច្ឆ័យ មានទំនាក់ទំនងផ្ទាល់ទៅនឹងគម្រោងនេះ ។ នេះ ស្របគ្នាទៅនឹងគោលជំហររបស់ថ្នាក់ គ្រប់គ្រង ។** |
| **ការប្រកាសទាមទារដែលអ្នកតាំងទីលំនៅនៅ BKL បានបដិសេធ ការធ្វើវិនិច្ឆ័យលើការទាមទារទ្រព្យសម្បត្តិរបស់ខ្លួនក្រោម LMAP ។** | ថ្នាក់គ្រប់គ្រងព្រមព្រៀងជាមួយអ្នកស្នើសុំដោយបានបញ្ជាក់ថា *"ថ្នាក់គ្រប់គ្រងបានសន្និដ្ឋានថា នីតិវិធីត្រឹមត្រូវនានា មិនត្រូវបានអនុវត្តតាមនៅក្នុងការធ្វើវិនិច្ឆ័យក្នុងតំបន់ឃុំស្រះចកនោះទេ"* ។ យោងតាមការឆ្លើយតបបានឱ្យដឹងថា អ្នកតាំងទីលំនៅក្នុងតំបន់ BKL មិនត្រូវបានផ្តល់ឱកាសឱ្យដើម្បី បង្ហាញនូវការទាមទារភាពជាម្ចាស់ដីរបស់ពួកខ្លួនទេ ហើយគ្មានភស្តុតាងដែលមានការចូលរួមមានលក្ខណៈតម្លាភាពមិនត្រូវបានអនុវត្ត ដើម្បីកំណត់ការធ្វើចំណាត់ថ្នាក់នៅក្នុងនោះទេ ។ ថ្នាក់គ្រប់គ្រង ក៏បានកត់សម្គាល់ផងដែរថា *"ដំណើរការដែលបានចាប់ផ្តើមក្រោម LMAP ជា មួយនឹងការធ្វើតំបន់វិនិច្ឆ័យ មិនត្រូវបានបំពេញ ទៅតាមនីតិវិធីដែលបានព្រមព្រៀងនោះទេ"* ។<br><br>ថ្នាក់គ្រប់គ្រងបញ្ជាក់ថា *"យោងតាមព័ត៌មានផ្តល់ឱ្យដោយបុគ្គលិករបស់ MLMUPC នៅក្នុងខែមិថុនា ឆ្នាំ២០០៨ បានឱ្យដឹងថា នៅក្នុងភូមិជា* | **វាជាទស្សនៈរបស់ក្រុមអធិការកិច្ចដែលថាផ្នែកជាច្រើននៃតំបន់ BKL អាចសមនឹងធ្វើការពិចារណាក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិសម្រាប់ភាពជាម្ចាស់ឯកជនក្រោមនីតិវិធីនៃការធ្វើតំបន់វិនិច្ឆ័យរបស់ LMAP ។ ក្រុមអធិការកិច្ចព្រមព្រាងជាមួយថ្នាក់គ្រប់គ្រងថា អ្នកតាំងទីលំនៅនៅក្នុងតំបន់ BKL ត្រូវបាន បដិសេធន៍មិនផ្តល់លទ្ធភាពឱ្យទទួលបាននូវ ដំណើរការធ្វើការវិនិច្ឆ័យសមស្របមួយសម្រាប់ទាមទារនូវទ្រព្យសម្បត្តិរបស់ខ្លួននោះទេ ។ ក្រុមអធិការកិច្ចរកឃើញថាអ្នកតាំងទីលំនៅ នៅក្នុងតំបន់BKL ត្រូវបានធ្វើយុត្តិកម្មដោយ រំពឹងថាការប្រកាសទាមទាររបស់ពួកគេដើម្បីយកដីនោះគឺសមនឹងពិចារណាក្រោមការផ្តល់ប័ណ្ណកម្មសិទ្ធិដីដែលមានលក្ខណៈជាប្រព័ន្ធ ហើយក្រៅពីនេះថាការប្រកាសទាមទារដីធ្លី ទាំងអស់នៅ ក្នុងឃុំនឹងត្រូវបានធ្វើការវិនិច្ឆ័យអនុលោមទៅ** |

| | | |
|---|---|---|
| | *ច្រើននៅ ជុំវិញតំបន់ BKL មានតែព្រំប្រទល់ភូមិប៉ុណ្ណោះ ត្រូវបានកំណត់ក្នុងកំឡុងពេលនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ ដែលមានលក្ខណៈជាប្រព័ន្ធ ហើយគ្មាន ការកំណត់ព្រំប្រទល់ដោយផ្នែកសម្រាប់បុគ្គលនោះទេ។ ភាពជាម្ចាស់នៅក្នុងតំបន់នេះត្រូវបានគេ យល់ថា នឹងមានបង្ហាញនៅលើឯកសារកត់ត្រាសូរិយោដីថា "មិនដឹង"។ នេះទំនងជាការធ្វើចំណាត់ថ្នាក់មួយ ដែលជាទូទៅត្រូវបានប្រើប្រាស់នៅពេល ដែលដីសាធារណៈរបស់រដ្ឋត្រូវបានឆ្លើយតបក្នុង កំឡុងពេលដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ ព្រមទាំងនៅពេលដែលដីនោះស្ថិតនៅក្រោមជំលោះមួយដែល មិនអាចដោះស្រាយបានក្នុងកំឡុងពេលដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិនៅឯថ្នាក់មូលដ្ឋាន"។*<br><br>ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា នៅក្នុងអតីតកាល *"ការត្រួតពិនិត្យមើលលើវិធានការការពារសុវត្ថិភាព និងវិធានការសង្គមដទៃៗទៀតគួរតែមានលក្ខណៈរឹងមាំ... ហើយទទួលស្គាល់ថា ការរាយការណ៍អំពីការត្រួតពិនិត្យស្តីអំពីបញ្ហាការពាររហូតដល់បេសកម្មការពារថ្មីបំផុតនៅក្នុងពាក់កណ្តាលឆ្នាំ ២០០៩ អាចត្រូវបានកែលម្អ"*។<br><br>នៅក្នុងការឆ្លើយតបរបស់ខ្លួន ថ្នាក់គ្រប់គ្រងក៏បានសង្ខេបផងដែរថាពួកគេមានផែនការចាត់វិធានការដើម្បីកែលម្អស្ថានការណ៍នេះ។ ថ្នាក់គ្រប់គ្រង កត់សម្គាល់ថា ទំនាក់ទំនងរវាងធនាគារពិភពលោក និងរដ្ឋាភិបាលត្រូវបានខូចខាត ដោយសារតែការអភិវឌ្ឍនៅជុំវិញព្រឹត្តិការណ៍ BKL ហើយដែលរដ្ឋាភិបាលបានបញ្ជាក់ម្តងហើយម្តងទៀតអំពីការ | **តាមនីតិវិធីនានា និងដំណើរ ការនានាសម្រាប់ធ្វើការវិនិច្ឆ័យលើការទាមទារ ទ្រព្យសម្បត្តិ ដោយមានការយល់ព្រមរវាង រដ្ឋាភិបាល ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៏នានា ដែលគាំទ្រដល់ LMAP។**<br><br>**ក្រុមអធិការកិច្ចកត់សម្គាល់ថា អនុក្រិត្យលេខ ៤៦ និងនីតិវិធីធ្វើវិនិច្ឆ័យដែលបានបង្កើតឡើង ក្រោមLMAPមិនបានដាក់បញ្ចូល ខ ចែងសម្រាប់ដកចេញផ្នែកនានានៃតំបន់វិនិច្ឆ័យដែលបានប្រកាសហើយនោះទេ ដូច្នេះដំណើរ ការនេះបានចាប់ផ្តើមឡើងដោយស្របច្បាប់។ ក្រុមអធិការកិច្ចក៏បានកត់សម្គាល់ផងដែរថា គ្មានឯកសារយោងនៅក្នុងឯកសារគម្រោង សំខាន់ៗ ចំពោះគោល-ការណ៍នានាសម្រាប់ កំណត់ "តំបន់ដែលមានជំលោះ" ឬនីតិវិធី ថាតើត្រូវដកចេញនូវតំបន់បែបនេះចេញពី ការផ្តល់ប័ណ្ណកម្មសិទ្ធិដែលមានលក្ខណៈជា ប្រព័ន្ធយ៉ាងដូចម្តេច។**<br><br>**ក្រុមអធិការកិច្ចកត់សម្គាល់ ថា ការសម្រេចចិត្ត មិនគាំទ្រនិយ័តកម្មនៃការតាំងទីលំនៅក្រៅ ផ្លូវការក្រោមគម្រោងនេះ មិនស្របគ្នាជា មួយនឹង (នៅក្នុងPADឬកិច្ចព្រមព្រាងឥណទានអភិវឌ្ឍន៏) ការកំណត់និយមន័យជាផ្លូវការនៃពាក្យ "អ្នកតាំងទីលំនៅក្រៅផ្លូវការ" "ការតាំងទីលំនៅក្រៅផ្លូវការ" ឬ "អ្នកតាំងទីលំនៅខុសច្បាប់"។ ក្រុមអ្នកជំនាញយល់ឃើញថា ទិសដៅសំខាន់របស់** |

| | | |
|---|---|---|
| | មិនឯកភាពរបស់ខ្លួនជាមួយនឹងទំនាក់ទំនងរវាងគម្រោងនេះ និងការបណ្តេញចេញនូវតំបន់ BKL ។ រដ្ឋាភិបាលបានលុបចោលនូវគម្រោង នេះកាលពី ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ដែលជាលទ្ធផលនៃការមិនឯកភាពនេះ ។ ទោះបីជាថ្នាក់គ្រប់គ្រង របស់ធនាគារពិភពលោកបានចង្អុលបង្ហាញទៅរដ្ឋាភិបាលថា កាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៏នេះ នៅតែបន្តរហូតដល់ការបង់ប្រាក់ពេញលេញនៃឥណទាននេះក្តី ក៏រដ្ឋាភិបាល បានបន្តមិនយល់ព្រមលើការអនុវត្តសកម្មភាព ដែលបានស្នើឡើងដោយថ្នាក់គ្រប់គ្រងរបស់ធនា គារពិភពលោកនោះដែរ ។ | **គម្រោង គឺ (ដោយគ្មានព្រំប្រទល់បែងចែកចំណាត់ថ្នាក់ដីច្បាស់លាស់) ដើម្បីកំណត់នីត្យានុកូលភាពនៃការទាមទារដីនោះ រួមបញ្ចូលទាំងប្រជាជនដែលពីដំបូងមើលទៅហាក់ដូចជាកំពុងកាន់កាប់ដីធ្លីដោយខុសច្បាប់ តាមរយៈដំណើរការធ្វើការវិនិច្ឆ័យ ។**<br><br>**ទោះបីជាការបញ្ជាក់នៅក្នុងPAD ដើម្បីសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយកម្មវិធីរបស់ UNCHS/UNDPដែលគ្រប់គ្រងអ្នក តាំងទីលំនៅក្រៅផ្លូវការ និងអ្នកតាំងទីលំនៅ ខុសច្បាប់ ក្រុមអធិការកិច្ចគ្មានលទ្ធភាពទទួល បាននូវភស្តុតាងក្នុងកំឡុងពេលធ្វើការស៊ើប អង្កេតរបស់ខ្លួនទេ ដែលកិច្ចសម្របសម្រួល បែបនេះ ឬការគាំទ្របែបនេះត្រូវបានផ្តល់ ដោយគម្រោង ដល់កម្មវិធី UNCHS/UNDP មុននឹងគម្រោង នេះត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០០៤។ ហើយក៏គ្មានភស្តុតាងផងដែរ អំពីការផ្លាស់ប្តូរវិធីសាស្ត្រទាក់ទងទៅនឹងការតាំងទីលំនៅខុសច្បាប់ក្រោយកាលបរិច្ឆេទនេះ ។ ក្រុមអធិការកិច្ចព្រមព្រាងជាមួយលទ្ធផលរបស់ERM'sថាកង្វះខាតនៃការកំណត់ផែនទី ដីរដ្ឋបាននាំឱ្យមានការកំណត់ពិតប្រាកដនៃដី រដ្ឋ (សាធារណៈ និងឯកជន) ដោយមិនបាន អនុវត្តនូវដំណើរធ្វើវិនិច្ឆ័យរបស់ LMAP ។**<br><br>**ក្រុមអធិការកិច្ចបានរកឃើញថា រចនាបទនៃគម្រោង មានលក្ខណៈមិនច្បាស់លាស់ថាតើ** |

| | | |
|---|---|---|
| | | គម្រោង នឹងមានយុទ្ធសាស្ត្រអ្វី ទាំងទាក់ទងទៅនឹងការកំណត់យកតំបន់នានាសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីដែលមានលក្ខណៈជាប្រព័ន្ធ (គឺ តំបន់វិនិច្ឆ័យ) ហើយដោះស្រាយជំលោះនានារវាងស្ថាប័នរបស់រដ្ឋ និងបុគ្គលឯកជននានាក្នុង កំឡុងដំណើរការធ្វើការវិនិច្ឆ័យ។<br><br>ក្រុមអធិការកិច្ចរកឃើញថា ភាពមិនច្បាស់លាស់ទាំងនេះនៅក្នុងរចនាបទគម្រោង ដោយផ្នែក បានបណ្តាលឱ្យមានផលប៉ះពាល់ដែលអ្នកស្នើសុំកំពុងតែជួបប្រទះ។ ជាលទ្ធផលក្រុមអធិការកិច្ចរកឃើញថា ទោះបីជាហានិភ័យនានាដែលពាក់ព័ន្ធទៅនឹងគម្រោង ត្រូវបានកំណត់រកឃើញយ៉ាងត្រឹមត្រូវក៏ដោយ ក៏ថ្នាក់គ្រប់គ្រងមិនបានអនុវត្តតាមOMS2.20ស្តីអំពីការវាយតម្លៃគម្រោង ទាក់ទងទៅនឹងការដោះស្រាយហានិភ័យទាំងនេះដែរ។<br><br>ក្រុមអធិការកិច្ចរកឃើញថា ការត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រងលើគម្រោងនេះសម្រាប់រយៈពេលច្រើនឆ្នាំបានមើលរំលងបញ្ហាសំខាន់នៃការធ្វើវិនិច្ឆ័យលើការទាមទារយកដីជាលក្ខណៈឯកជនដែលរដ្ឋបានប្រកាសយក។ ការបរាជ័យរបស់ថ្នាក់គ្រប់គ្រងនេះ តាមទស្សនៈរបស់ក្រុមអធិការកិច្ចយល់ឃើញថា បានចូលរួមចំណែកឱ្យមានព្រឹត្តិការណ៍នៅក្នុងតំបន់ BKL និងធ្វើឱ្យមានការខូចខាតដែលអ្នកស្នើសុំកំពុងជួបប្រទះ។ ការត្រួតពិនិត្យ |

| | | |
|---|---|---|
| | | **របស់ថ្នាក់គ្រប់គ្រងលើបញ្ហាសំខាន់នេះមិនបានឆ្លើយតបទៅនឹងតម្រូវការរបស់ OP/BP 13.05. នោះទេ។**<br><br>**ក្រុមអធិការកិច្ចបានរកឃើញថា ថ្នាក់គ្រប់គ្រងខកខានមិនបានចាត់វិធានការណ៍លើព័ត៌មាននៅពេលដែលបញ្ហានានាដែលកំពុងកើតមានឡើងនៅក្នុងតំបន់BKL ត្រូវបានគេចាប់អារម្មណ៍ជាលើដំបូង ហើយរកឃើញថាការត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រងក្នុងបញ្ហានេះមិនស្របគ្នាជាមួយនឹងតម្រូវការរបស់ OP/BP 13.05 នោះទេ។**<br><br>**ក្រុមអធិការកិច្ចរកឃើញថា ការត្រួតពិនិត្យមើលគម្រោងនាពេលថ្មីៗរបស់ថ្នាក់គ្រប់គ្រងលើបញ្ហាដែលបានលើកឡើងតាមការស្នើសុំស្របគ្នាជាមួយនឹងគោលនយោបាយរបស់ធនាគារពិភពលោកស្តីអំពីការត្រួតពិនិត្យគម្រោង OP/BP 13.05។**<br><br>**ក៏ប៉ុន្តែ ក្រុមអធិការកិច្ចព្រមព្រាងជាមួយនឹងការវាយតម្លៃរបស់អ្នកស្នើសុំថា *"វាគឺជាភស្តុតាងដែលបង្ហាញថា ចំណាត់វិធានការដែលធ្វើឡើងដោយថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក គឺមានលក្ខណៈយឺតពេកក្នុងការទប់ស្កាត់ផលប៉ះពាល់ដែលកំពុងកើតឡើងក្នុងពេលបច្ចុប្បន្ន"*។** |
| **ការប្រកាសទាមទារដែលអ្នកតាំងទីលំនៅនៅក្នុងBKL ត្រូវបាន** | តាមការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង បញ្ជាក់អះអាងថា DCA បានទាមទារឱ្យអនុវត្ត RPF នៅក្នុង | **ក្រុមអធិការកិច្ចរកឃើញថា ការសម្រេចចិត្តដើម្បីរៀបចំក្របខណ្ឌគោលនយោបាយតាំងទីលំនៅសាជាថ្មី ស្របគ្នាជាមួយនឹង ៥ ថែង** |

| | | |
|---|---|---|
| **គេឱ្យប្តូរទីតាំងដោយបង្ខំតាមគោលនយោបាយដែលបានព្រមព្រាងសម្រាប់ការតាំងទី លំនៅឡើងវិញដោយបង្ខំ។** | ព្រឹត្តិការណ៏នៃការបណ្តេញចេញពីដីរបស់រដ្ឋក្រោមផ្នែកនៃគម្រោងនេះដែលបានផ្តល់ឱ្យសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដែលមានលក្ខណៈជាប្រព័ន្ធ និងមិនទៀងទាត់។ ថ្នាក់គ្រប់គ្រងបញ្ជាក់ថា ការផ្តល់ប័ណ្ណកម្មសិទ្ធិលើផ្នែករបស់គម្រោង ដោយសារ តែបញ្ហាកំហិតផ្នែកហិរញ្ញវត្ថុ ស្ថាប័នបច្ចេកទេស និងសមត្ថភាពធនធានមនុស្សត្រូវ បានបង្កើតឡើងដើម្បី អនុវត្តតាមលំដាប់លំដោយនៅក្នុងតំបន់វិនិច្ឆ័យ ដែលបានជ្រើសរើសលើកដំបូង ហើយបន្ទាប់មក បន្តទៅទីតាំងដទៃទៀត នៅពេលដែលទីតាំងចាស់ ត្រូវបានបញ្ចប់។ ថ្នាក់គ្រប់គ្រងបន្ថែមថា ការអនុវត្ត RPF ត្រូវបានគេសន្មត់ថាដើរតាមលំដាប់នៃព្រឹត្តិការណ៏ដូចគ្នា។ ដូច្នេះ ថ្នាក់គ្រប់គ្រងបញ្ជាក់ថា *"វាត្រូវបានគេពិចារណាយ៉ាងច្បាស់លាស់និងហ្មត់ចត់"* ដែលគម្រោងនោះមិនមានសកម្មភាព ហើយ ដែល RPF មិនបានយកមកអនុវត្ត។<br><br>ទាក់ទងទៅនឹងតំបន់ BKL ជាពិសេស ថ្នាក់គ្រប់គ្រងព្រមព្រាងជាមួយអ្នកស្នើសុំទាំងឡាយថាក្របខណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញគួរតែត្រូវបានអនុវត្តសម្រាប់ការប្តូរទីតាំងដែលបានកើតឡើងនៅក្នុងឃុំស្រះចក។ ដូចដែលបានកំណត់ច្បាស់លាស់នៅក្នុង DCA RPF ត្រូវតែបានអនុវត្តនៅក្នុងព្រឹត្តិការណ៏នៃការបណ្តេញចេញពីដីរដ្ឋដែលជាលទ្ធផលនៃសកម្មភាពរបស់គម្រោង ហើយ ផែនការសកម្មភាពតាំងទីលំនៅឡើងវិញជាក់លាក់ សម្រាប់តំបន់មួយ គួរតែត្រូវបានរៀបចំឡើងសម្រាប់ឱ្យធនាគារពិភពលោកត្រួតពិនិត្យមើលឡើងវិញ និងអនុម័ត។ ថ្នាក់គ្រប់គ្រង | **នៃគោលនយោបាយដែលអាចអនុវត្តបាន គឺ OD4.30។ ក្រុមអធិការកិច្ចផ្តល់យោបល់ដល់ ថ្នាក់គ្រប់គ្រងឱ្យពង្រីកទំហំនៃស្ថានការណ៏ ដែលគោលនយោបាយនេះនឹងអនុវត្តន្ធុះ បញ្ជាំងឱ្យឃើញអំពីការគិតគូរថ្មីនៅក្នុងធនាគារពិភពលោកក្នុងពេលនោះ ដែលទាក់ទងទៅនឹងការអនុវត្តដ៏ត្រឹមត្រូវនៃវិធានការការពាររបស់ធនាគារពិភពលោក។ ក្រុមអធិការកិច្ចរកឃើញថា មានភាពមិនច្បាស់លាស់ជាច្រើនទាក់ទងទៅនឹងរបៀបដែលក្របខណ្ឌគោលនយោបាយតាំងទីលំនៅសាជាថ្មីត្រូវបានចាប់ផ្តើម និងត្រូវបានអនុវត្តយ៉ាងណានោះ។ ក្រុមអធិការកិច្ចរកឃើញថា ការបង្កើតក្របខណ្ឌគោលនយោបាយតាំងទីលំនៅសាជាថ្មី មានចំនុចខ្វះខាតថែងជា ច្រើនដែលរំពឹងថាមាននៅក្នុង OD4.30 ដែលទាក់ទងទៅនឹង *"គោលការណ៏ធ្វើផែនការ ការរៀបចំស្ថាប័ន និងលក្ខខិកៈនៃការបង្កើត"*។<br><br>ក្រុមអធិការកិច្ចរកឃើញថាការចាប់អារម្មណ៏របស់ថ្នាក់គ្រប់គ្រងចំពោះផលវិបាកសង្គមនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដី រួមទាំងការបណ្តេញចេញដែលមានលក្ខណៈសក្តានុពល គឺគ្មានលក្ខណៈជាប្រព័ន្ធនោះទេ ហើយទទួលរងផលប៉ះពាល់ពីការខ្វះខាតនៃការចាប់អារម្មណ៏ពីអ្នកជំនាញការពារសុវត្ថិភាពសង្គម។ វាគឺជាបញ្ហានៃក្តីបារម្ភមួយដែលបេសកម្មត្រួតពិនិត្យជាច្រើនបានសន្និដ្ឋានថា គ្មានស្ថានការណ៏ដែលទាមទារឱ្យអនុវត្តវិធានការការពារសង្គម** |

| | | |
|---|---|---|
| | ឯកភាពជា មួយនឹងអ្នកស្នើសុំនានាថា ទោះបីជាវាមិនទាន់មានលក្ខណៈ ច្បាស់លាស់នៅឡើយថាតើតំបន់ BKL ត្រូវបានផ្តល់កម្មសិទ្ធិទៅឱ្យរដ្ឋក្តី ក៏កិច្ចសន្យាជួលនោះដែលរដ្ឋាភិបាលបាន ផ្តល់ទៅឱ្យអ្នកអភិវឌ្ឍន៏ឯកជនមួយនៅ លើដីនោះនៅក្នុងឆ្នាំ ២០០៧ បង្ហាញអំពីការសម្រេច ចិត្តដ៏ពិតប្រាកដ ដែលដីនោះគឺជាដីរបស់រដ្ឋ។ តាមទស្សនៈរបស់ថ្នាក់គ្រប់គ្រង : *"ដើម្បីដកចេញនូវ ការអនុវត្ត RPF ចំពោះការបណ្តេញចេញនៅក្នុងតំបន់វិនិច្ឆ័យគម្រោង ដោយសារដំណើរការវិនិច្ឆ័យទំនងជាមិនត្រូវបានអនុវត្តតាមសម្រាប់ធ្វើការសន្និដ្ឋានរបស់ខ្លួន និងគ្មានប័ណ្ណកម្មសិទ្ធិផ្លូវការត្រូវបានផ្តល់ឱ្យក្នុងនាមជារដ្ឋ វានឹងផ្ទុយទៅនឹងគោលបំណង ដែលស្ថិតនៅក្រោមការអនុវត្ត RPF ដូចដែលបានកំណត់នៅក្នុង DCA"*។<br><br>តាមការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង គឺសំដៅទៅលើគោលជំហររបស់រដ្ឋាភិបាលដែលអះអាងថាតំបន់ BKL មិនមែនជាក្តីកង្វល់របស់គម្រោងទេ ព្រោះដី BKL មិនត្រូវបានផ្តល់កម្មសិទ្ធិទៅឱ្យរដ្ឋតាមរយៈ LMAP ទេ។ នៅពេលដែលថ្នាក់គ្រប់គ្រងជំទាស់ទៅនឹងការអះអាងនេះសម្រាប់ហេតុផលជាច្រើនដែលបានកត់សំគាល់នៅក្នុងកថាខ័ណ្ឌខាង ដើម ថ្នាក់គ្រប់គ្រងក៏បានទទួលស្គាល់ផងដែរថា *"កង្វះខាតភាពជាក់លាក់នៅក្នុងឯកសារគម្រោង និងការគ្មានកិច្ចពិភាក្សាលំអិតអំពីទំហំរបស់ RPF ទាំងក្នុងកំឡុងពេលបង្កើតគម្រោង ឬទាំងក្នុងពេលអនុវត្ត អាចធ្វើឱ្យរដ្ឋាភិបាលយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួន"*។ ថ្នាក់គ្រប់គ្រងក៏បានបញ្ជាក់ផងដែរថា រហូតទាល់តែព្រឹត្តិការណ៏ BKL បាន | **និងបរិស្ថាននោះទេ រួមទាំង RPF ផងដែរ ដែល ទំនងជាគ្មានការត្រួតពិនិត្យដោយហ្មត់ចត់លើបញ្ហានេះ។ ក្រុមអធិការកិច្ចរកឃើញភស្តុតាង នៅក្នុងឯកសារកត់ត្រាត្រួតពិនិត្យថាថ្នាក់គ្រប់ គ្រងនៅក្នុងកាលៈទេសៈជាច្រើន បានលើក បញ្ហានានាទាក់ទងទៅនឹងការគ្រប់គ្រងដីរដ្ឋ ដែលពាក់ព័ន្ធជាសក្តានុពលទៅនឹងការអនុវត្ត RPF។ ក្រុមអធិការកិច្ចផ្តល់យោបល់ឱ្យធនាគារពិភពលោកបន្តបញ្ហាគោលនយោបាយដ៏លំបាកនេះនៅក្នុងបរិបទនៃប្រទេសកម្ពុជា ដែលមានលក្ខណៈរសើបផ្នែកនយោបាយ និងស្មុគ្រស្មាញ។ ក៏ប៉ុន្តែ ការតាមដានលើបញ្ហាទាំងនេះ មានលក្ខណៈមិនគ្រប់គ្រាន់ ហើយបានបណ្តាលឱ្យមានបញ្ហាជាច្រើននៅក្នុងតំបន់ BKL។ បញ្ហានេះមិនស្របជាមួយនឹង ខ ចែងនានារបស់ OP/BP13.05 ស្តីអំពី ការត្រួតពិនិត្យគម្រោងនោះទេ។**<br><br>**ក្រុមអធិការកិច្ចរកឃើញថាការបរាជ័យរបស់ថ្នាក់គ្រប់គ្រងក្នុងការធានាដល់ការអនុវត្តក្របខណ្ឌគោលនយោបាយតាំងទីលំនៅសាជាថ្មី មិនស្របគ្នាជាមួយនឹង OD4.30ទេ និង ជាមួយ OP/BP13.05 ស្តីអំពីការត្រួតពិនិត្យគម្រោងទេ។**<br><br>**ជារួមក្រុមអធិការកិច្ចមើលឃើញថាថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកគួរតែរកឱ្យឃើញនូវបញ្ហាធ្ងន់ធ្ងរនានាដែលប្រជាពលរដ្ឋនៅក្នុងតំបន់BKL បានជួបប្រទះនៅក្នុង** |

| | | |
|---|---|---|
| | កើតឡើងទាំងថ្នាក់គ្រប់គ្រង និងទាំងក្រសួងដែនដី មិនបានពិចារណាថា ប្រសិនបើដំណើរការនៃការផ្ដល់ប័ណ្ណកម្មសិទ្ធិមិនបានបញ្ចប់សកម្មភាពនានាអាចកើតឡើងនៅក្នុងតំបន់វិនិច្ឆ័យមួយដែលអាចស្នើសុំឱ្យមានការអនុវត្ត RPF ។<br><br>ថ្នាក់គ្រប់គ្រងទទួលស្គាល់ថាប្រជាជននៅក្នុងតំបន់ BKL បានទទួលរងនូវគំនាបឱ្យប្ដូរទីតាំង និងថាគ្មានការពិគ្រោះយោបល់គ្រប់គ្រាន់ ឬដំណើរការចរចាពាក់ព័ន្ធទៅនឹងការប្ដូរទីតាំងនេះទេ។ ទាក់ទងទៅនឹងសំណងដែលបានផ្ដល់ទៅឱ្យប្រជាជន ថ្នាក់គ្រប់គ្រងបានបញ្ជាក់ថា *"វាមើលទៅទំនងជាថា កញ្ចប់ដែលបានស្នើឡើងនោះ វាមិនស្មើទៅនឹងអ្វីដែលប្រជាជនបានទទួលពីការអនុវត្តរបស់ RPF នោះទេ"*។ ថ្នាក់គ្រប់គ្រងកត់សម្គាល់ថាចាប់តាំងពីនីតិវិធីបានចែងនៅក្នុង RPF មិនត្រូវបានអនុវត្ត ការ វាយតម្លៃជាក់លាក់មួយលើភាពត្រឹមត្រូវ និងភាពសមល្មមនៃកញ្ចប់សំណងដែលបានផ្ដល់ឱ្យមិនអាច ត្រូវបានធ្វើឡើងនោះទេ។<br><br>ការឆ្លើយតបនេះក៏បានលំអិតផងដែរអំពីកិច្ចប្រឹងប្រែងរបស់ថ្នាក់គ្រប់គ្រងក្នុងការចូលរួមនៅក្នុងកិច្ចពិភាក្សាផ្លាស់ប្ដូរយោបល់ជាមួយរដ្ឋាភិបាលស្ដីអំពីបញ្ហាបណ្ដេញចេញនៅក្នុងតំបន់ទីក្រុង។ ការឆ្លើយតបនេះរួមបញ្ចូលទាំងការស្នើសុំឱ្យមានការផ្អាកលើការបណ្ដេញចេញរង់ចាំរហូតទាល់តែមានគោលនយោបាយតាំងទីលំនៅសាជាថ្មីថ្នាក់ជាតិ និងការកែលំអលក្ខខណ្ឌនៃតំបន់តាំងទីលំនៅសាជាថ្មី។ ជាពិសេសថ្នាក់គ្រប់គ្រងបានផ្ដល់នៅការគាំទ្ររបស់ខ្លួនដើម្បីកែលំអលក្ខខណ្ឌរស់នៅ និងជីវភាព | **ដំណាក់កាលដើមដំបូង និងគួរពិចារណាអំពីវិធានការដែលសមរម្យ។ ការខកខានមិនបានធ្វើដូច្នេះ គឺមិនអនុលោមទៅតាមគោលនយោបាយរបស់ធនាគារពិភពលោកស្ដីអំពីការត្រួតពិនិត្យគម្រោងនោះទេ។**<br><br>**ក្រុមអធិការកិច្ចរកឃើញថា RPF ជាទូទៅអនុលោមទៅតាម OD4.30។ ក៏ប៉ុន្តែ មានកង្វះខាតអំពីការណែនាំចំពោះការស្ដារឡើងវិញនិងសកម្មភាពស្ដារប្រាក់ចំណូលឡើងវិញដែលយោងទៅតាម RPF គួរតែត្រូវបានលំអិតនៅក្នុងផែនការតាំងទីលំនៅសាជាថ្មី។**<br><br>**ក្រុមអធិការកិច្ចរកឃើញថា ដំណើរនៃការអនុវត្តការបណ្ដេញនៅក្នុងតំបន់ BKL កម្រិតនៃការទូទាត់សំណង និងបទដ្ឋាននៃតំបន់តាំងទីលំនៅសាជាថ្មី មិនស្របទៅតាមគោល ការណ៍ដែលបានដាក់ចេញដោយ RPF និង ពាក់ព័ន្ធទៅនឹងខចែងនានារបស់ OD4.30 នោះទេ។** |

| | | |
|---|---|---|
| | រស់នៅរបស់ប្រជាពលរដ្ឋចេញពីតំបន់បឹងកក់ដែលបានជ្រើសរើសតាំងទីលំនៅសាជាថ្មីនៅក្នុងតំបន់ក្រៅរាជធានីភ្នំពេញ។ | |
| **ការប្រកាសទាមទារដែលដំណើរផ្តល់ប័ណ្ណកម្មសិទ្ធិអនុម័តដោយគម្រោងធ្វើឱ្យចុះខ្សោយសិទ្ធិកាន់កាប់ដីដែលមានពីមុនមក** | តាមការឆ្លើយតបរបស់ខ្លួនថ្នាក់គ្រប់គ្រងបញ្ជាក់ថា *"វាមានលក្ខណៈមិនប្រាកដប្រជាថាតើពាក្យ 'សិទ្ធិជាប្រពៃណី ' កំពុងត្រូវបានប្រើប្រាស់"*។ យោងតាមថ្នាក់គ្រប់គ្រងបានឱ្យដឹងថា លក្ខណៈសំខាន់នៃច្បាប់ដីធ្លីឆ្នាំ២០០១បង្ហាញថាសិទ្ធិនៃភាពជាម្ចាស់ត្រូវបានទទួលស្គាល់ថា អាចផ្លាស់ប្តូរបានទៅជាប័ណ្ណកម្មសិទ្ធិផ្លូវការ ប្រសិនបើឆ្លើយតបទៅនឹងលក្ខខណ្ឌពិតប្រាកដ។ ថ្នាក់គ្រប់គ្រងកត់សម្គាល់ថា ការផ្តល់ប័ណ្ណកម្មសិទ្ធិគួរតែពង្រឹងសិទ្ធិភាពជា ម្ចាស់ដែលមានការទទួលស្គាល់ក្រោមច្បាប់ភូមិបាល។ ក៏ប៉ុន្តែ ថ្នាក់គ្រប់គ្រងបញ្ជាក់ថា *"សិទ្ធិដែល មានមកពីមុនអាចត្រូវបានសម្របសម្រួលដោយ ដំណើរមួយជាមួយនឹងចំនុចខ្វះខាតនានាដែលជា ភស្តុតាងនៅក្នុងករណីនៃការធ្វើវិនិច្ឆ័យនៅក្នុងឃុំស្រះចក រួមទាំងការគ្មានការសម្រេចចិត្តដែលមានតម្លាភាព ផ្អែកលើលក្ខិកៈ និងអាចត្រួតពិនិត្យ មើលឡើងវិញបាន ថាតើដីដែលមិនច្បាស់លាស់ នោះគឺជាដីសាធារណៈរបស់រដ្ឋឬយ៉ាងណា។"* | **ក្រុមអធិការកិច្ចកត់សម្គាល់ថា គម្រោងបានផ្តល់អត្ថប្រយោជន៍យ៉ាងពិតប្រាកដដល់ក្រុមគ្រួសារប្រហែល១លានគ្រួសារ និងទទួលស្គាល់សមិទ្ធិផលដ៏សំខាន់នេះរបស់ LMAP។**<br><br>**ក្រុមអធិការកិច្ចរកឃើញថា ចំនុចខ្សោយនៃការបង្កើតគម្រោង នេះបាននាំឱ្យមានការមិនដាក់បញ្ចូលដី ដោយបំពានលើដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ ហើយថាដំណើរការនេះបានបដិសេធអ្នកតាំងទីលំនៅជាពិសេសប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ ឱកាសក្នុងការទាមទារ និងធ្វើឱ្យសិទ្ធិដែលមានពីមុនមករបស់ពួកគេក្លាយទៅជាផ្លូវការ តាមរយៈដំណើរការវិនិច្ឆ័យក្រោមLMAP។**<br><br>**ក្រុមអធិការកិច្ចរកឃើញថាថ្នាក់គ្រប់គ្រងខកខានមិនបានទទួលស្គាល់ពាក្យថា 'អ្នកតាំងទីលំនៅខុសច្បាប់' និង 'ការតាំងទីលំនៅក្រៅផ្លូវការ' មានលក្ខណៈសត្យានុម័តរហូតទាល់តែត្រូវបានកំណត់ជាក់លាក់ តាមរយៈដំណើរនៃការធ្វើវិនិច្ឆ័យ។**<br><br>**កំហុសនៃការបង្កើតគម្រោង ទាំងនេះបានធ្វើឱ្យមានការលំបាកសម្រាប់ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកក្នុងការសម្រេចបានទិសដៅគម្រោង ដែលបានកំណត់ទាក់ទងទៅ** |

| | | |
|---|---|---|
| | | **នឹងការកាត់បន្ថយភាពក្រីក្រ និងការផ្តល់សន្តិសុខក្នុងការកាន់កាប់ដីធ្លីសម្រាប់ប្រជាជនក្រីក្រ និងមិនអនុវត្តតាម OMS2.20 នោះទេ។**<br><br>**ក្រុមអធិការកិច្ចរកឃើញថាមិនមានវិធានការទាំងអស់ ត្រូវបានបង្កើតឡើងយ៉ាងជាក់លាក់ ដើម្បីគាំទ្រដល់ប្រជាជនក្រីក្រ និងប្រជាជន ងាយរងគ្រោះត្រូវបានអនុវត្តទៅតាមផែនការនោះទេ។ ក្រុមអធិការកិច្ចរកឃើញថា ថ្នាក់គ្រប់គ្រងមិនបានពិនិត្យតាមដានមើល គ្រប់គ្រាន់លើការប្តេជ្ញាចិត្តរបស់គម្រោងក្នុង ការពង្រឹងការយល់ដឹងជាសាធារណៈ និងការ ចូលរួមរបស់សហគមន៍នោះទេ ដែលធានា ដល់ការការពារផ្លូវច្បាប់ដល់អ្នកតាំងទីលំនៅ ដែលបានប្រឈមទៅនឹងហានិភ័យនៃការបណ្តេញចេញ និងផ្តល់លទ្ធភាពគ្រប់គ្រាន់ ដល់យន្តការដោះស្រាយជំលោះ។ បញ្ហានេះ មិនអនុលោមទៅតាម OP/BP13.05 នោះទេ។** |
| **ការប្រកាសទាមទារដែលសហគមន៍ដទៃទៀតនៅក្នុងខេត្តដែលគ្រប់ដណ្តប់ដោយគម្រោង កំពុង ជួបប្រទះការបណ្តេញចេញដោយបង្ខំ។** | នៅក្នុងការឆ្លើយតបរបស់ខ្លួន ថ្នាក់គ្រប់គ្រងទទួលស្គាល់ថា *"អសន្តិសុខនៃសិទ្ធិកាន់កាប់ដីធ្លីបន្តជាបញ្ហាសំខាន់មួយនៅក្នុងប្រទេសកម្ពុជា"* និងថាការកើនឡើងថ្មីៗនៃតម្លៃដីបាននាំឱ្យមានការគៀបសង្កត់កើនឡើង *"ជាពិសេសលើសហគមន៍ងាយរងគ្រោះដែលកំពុងរស់នៅលើដីដែលចាត់ទុកថាជាដីសាធារណៈរបស់រដ្ឋ"*។ ថ្នាក់គ្រប់គ្រងបញ្ជាក់ថាខ្លួន *"ឥឡូវនេះដឹងអំពីតំបន់ដទៃទៀតដែលបានប្រកាសការវិនិច្ឆ័យក្រោមគម្រោងនេះដែលគ្រួសារ* | **ក្រុមអធិការកិច្ចកត់សម្គាល់ថា ការបណ្តេញចេញដោយបង្ខំមិនមែនជារឿងថ្មីទេនៅក្នុងប្រទេសកម្ពុជា ហើយដូចដែលបានកត់សម្គាល់ នៅក្នុងការវាយតម្លៃអំពីភាពក្រីក្ររបស់ធនាគារពិភពលោកនៅក្នុងប្រទេសកម្ពុជា បានកំពុង បន្តធ្វើនៅក្នុងទីក្រុងភ្នំពេញចាប់តាំងពីមុនរៀបចំគម្រោងនេះ។ ដោយសារតែគម្រោង នេះបានដាក់បញ្ចូលនូវការតាំងទីលំនៅក្នុង ទីក្រុងសំខាន់ៗ** |

| | | |
|---|---|---|
| | *នានាត្រូវបានគេបណ្តេញចេញ ឬត្រូវបានគេគំរាមកំហែងបណ្តេញចេញ*"។ ថ្នាក់គ្រប់គ្រងក៏បានកត់សម្គាល់ផងដែរថា "*នៅមានការគំរាមកំហែងជាបន្តលើការផ្លាស់ប្តូរម្ចាស់ដី និងការបណ្តេញចេញសម្រាប់សហគមន៍ងាយរងគ្រោះ*"។<br><br>ថ្នាក់គ្រប់គ្រងសង្ខេបអំពីវិធានការនានាក្នុងការដោះស្រាយក្តីកង្វល់ទាំងនេះ ដោយកត់សម្គាល់ថា "*ក្រុមការងារកំពុងតែប្រមូលព័ត៌មានដើម្បីធ្វើអត្តសញ្ញាណកម្មករណីសក្តានុពលដទៃៗទៀតរបស់សហគមន៍នានាដែលអាចនឹងត្រូវបានគេបណ្តេញពីតំបន់វិនិច្ឆ័យដោយគ្មានការអនុវត្ត RPF ត្រឹមត្រូវ*"។ ថ្នាក់គ្រប់គ្រងបញ្ជាក់ថា "*រហូតមកដល់ថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០០៩ ករណីសក្តានុពលចំនួន៨ករណីត្រូវបានរកឃើញ រួមមានទាំងភូមិចំនួន១០ (ឬផ្នែកជាច្រើនក្នុងចំណោមនោះ)*"។ ក្រៅពីនេះថ្នាក់គ្រប់គ្រងអះអាងថា ចាប់តាំងពីខែមេសាឆ្នាំ២០០៩មក ខ្លួនបានអំពាវនាវម្តងហើយម្តងទៀតឱ្យរដ្ឋាភិបាលផ្អាកការបណ្តេញចេញដោយបង្ខំ "*នៅក្នុងរាជធានីភ្នំពេញ និងតំបន់ដទៃទៀត*"។ | **រួមទាំងរាជធានីភ្នំពេញ ក្នុង ចំណោមខេត្តដែលគ្រប់ដណ្តប់ដោយគម្រោង បញ្ហានេះគឺជាហានិភ័យជាក់លាក់ដែលទាក់ ទងទៅនឹងកេរ្តិ៍ឈ្មោះរបស់ធនាគារពិភពលោក។ ក្រុមអធិការកិច្ចកត់សម្គាល់ថា រចនាបទគម្រោង មិនបានឆ្លើយតបគ្រប់គ្រាន់ទៅនឹងបញ្ហាសំខាន់នេះ និងហានិភ័យដែលទាក់ទងទៅនឹង កេរ្តិ៍ឈ្មោះនេះទេ។**<br><br>**ទោះបីជាមានលទ្ធផលច្បាស់លាស់នៃការត្រួតពិនិត្យមើលឡើងវិញឯករាជ្យ និងលទ្ធផលដូចគ្នានៅក្នុងរបាយការណ៍ត្រួតពិនិត្យរបស់ថ្នាក់គ្រប់គ្រងដែលបង្ហាញអំពីភាពមិនគ្រប់គ្រាន់នៃយន្តការដោះស្រាយជំលោះនោះក្តី ជាពិសេសនៅពេលដែលមានភាគីដែលមានអំណាចដែលបានចូលរួម ក៏ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកមិនបានចាត់វិធានការរឹងមាំដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមានទាំងនេះដែរ។ ការត្រួតពិនិត្យមើលឡើងវិញលើរបាយការណ៍ត្រួតពិនិត្យបង្ហាញថាគ្មានប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ គម្រោងនេះរហូតដល់ឆ្នាំ២០០៧។ ក្រុមអ្នក ជំនាញរកឃើញថា ដោយសារតែកង្វះខាតនៃប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរឹងមាំសម្រាប់ គម្រោងនេះ ថ្នាក់ដឹកនាំរបស់ធនាគារពិភពលោក មិនបានដឹងអំពីបញ្ហាជាក់លាក់នានាដែល កើតចេញពីគម្រោងនេះទេ។ ករណីនេះមិន បានអនុលោមទៅតាម OP/BP13.05 ទេ។** |

| | | |
|---|---|---|
| | | ក្រុមអធិការកិច្ចកត់សម្គាល់ថា ទោះបីជាមានឯកសារជាច្រើនបង្ហាញថា គ្រួសារជាក់លាក់មួយចំនួនត្រូវបានទទួលរងផលប៉ះពាល់អវិជ្ជមានក៏ដោយ ក៏គេមិនបានដឹងអំពីទំហំនៃផលប៉ះពាល់អវិជ្ជមានលើគ្រួសារនានាដែលកំពុងរស់នៅក្នុងតំបន់វិនិច្ឆ័យនោះដែរ។ ក្រុមអធិការកិច្ចមានក្តីបារម្ភយ៉ាងខ្លាំងអំពីចំនួនមនុស្ស ដ៏ច្រើនដែលត្រូវបានបណ្តេញចេញដោយបង្ខំ ប្តូរទីតាំងដោយបង្ខំ ឬស្ថិតនៅក្រោមការគំរាមកំហែងនៃការបណ្តេញចេញនៅក្នុង តំបន់គម្រោង ។ |

# ឧបសម្ព័ន្ធ ២: ជីវប្រវត្តិ

## ក្រុមសមាជិកអធិការកិច្ច

**លោក រ៉ូប៊ើតូ ឡែនតុន** (Roberto Lenton) (ជនជាតិអាសង់ទីន) ត្រូវបានតែងតាំងជាសមាជិកក្រុមអធិការកិច្ចនៅខែកញ្ញា ឆ្នាំ ២០០៧ ហើយបានក្លាយទៅជាប្រធានក្រុមអធិការកិច្ចនៅខែវិច្ឆិកាឆ្នាំ ២០០៩។ លោកទទួលបានសញ្ញាប័ត្រវិស្វកស៊ីវិលពីសាកលវិទ្យាល័យ Buenos Aires និងសញ្ញាប័ត្របណ្ឌិតពីវិទ្យាស្ថានបច្ចេកទេស ម៉ាសាជុសសេត (Massachusetts)។ ដោយសារ លោកមានជំនាញខាងធនធានទឹក និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ជាមួយនឹងបទពិសោធន៍អន្តរជាតិ ៣០ ឆ្នាំ លើវិស័យនេះ លោកត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាសហប្រតិបត្តិការផ្គត់ផ្គង់ទឹក និងអនាម័យ ហើយជាសមាជិកក្រុមប្រឹក្សានាយកនៃ ជំនួយផ្នែកទឹកអាមេរិក (WaterAid America) បន្ទាប់ទៀតលោកទទួលតំណែងជាប្រធានគណៈកម្មការបច្ចេកទេសនៃភាព ជាដៃគូទឹកសកល (Global Water Partnership) រហូតដល់ខែកក្កដាឆ្នាំ ២០០៩ ។ លោក ឡែនតុន ជាសហនិពន្ធសៀវភៅមួយ មានចំណងជើងថា *Applied Water Resources Systems* (ការអនុវត្តទៅតាមប្រព័ន្ធធនធានទឹក) ហើយលោកក៏ជាសហនិពន្ធ សៀវភៅដែលមានចំណងជើងថា “Integrated Water Resources Management in Practices,” (សមាហរណកម្មការ គ្រប់គ្រងធនធានទឹកទៅក្នុងការប្រតិបត្តិ) លោកក៏ដឹកនាំក្រុមនិពន្ធសៀវភៅមួយមានចំណងជើងថា *health, Dignity and Development: What will it Take? (សុខភាព សេចក្តីថ្លៃថ្នូ និងការអភិវឌ្ឍ: តើជ្រើសរើសយកមួយណា?)* ហើយរបាយការណ៍ចុងក្រោយនៃក្រុមការងារគម្រោងសហសវត្សរបស់អង្គការសហប្រជាជាតិ ស្តីពីទឹកនិងអនាម័យ គឺលោកក៏ជាសហប្រធានដែរ។ មុននោះ លោក ឡែនតុន ជានាយកផ្នែកថាមពល និងបរិស្ថានប្រកបដោយនិរន្តរភាព របស់កម្មវិធីអភិវឌ្ឍន៍អង្គការ សហប្រជាជាតិ (UNDP) នៅទីក្រុង ញូយ៉ក ហើយជាអគ្គនាយកវិទ្យាស្ថានគ្រប់គ្រងទឹកអន្តរជាតិនៅប្រទេសស្រីឡង្កា និងមន្ត្រីកម្មវិធីនៅក្នុងកម្មវិធីភាពក្រីក្រនិងធនធាននៅជនបទនៃមូលនិធិ Ford ដែលមានទីតាំងនៅក្រុងញូដេលី និងទីក្រុងញូយ៉ក ។ លោកបានបំរើការជាសាស្ត្រាចារ្យជំនួយនៅផ្នែកកិច្ចការអន្តរជាតិ និងសាធារណៈនៅសាកលវិទ្យាល័យកូឡុមប៊ូ និងជាជំនួយការ សាស្ត្រាចារ្យ ផ្នែកវិស្វករស៊ីវិល និងបរិស្ថាននៅវិទ្យាស្ថាន MIT ។

**លោក អល្ហ ជើវ** (Alf Jerve) (ជនជាតិណ័រវេ) បានតែងតាំងជាក្រុមការងារអធិការកិច្ចនៅខែវិច្ឆិការឆ្នាំ ២០០៨ ។ លោក ជើវ បានពាំនាំឱ្យក្រុមអធិការកិច្ចនូវបទពិសោធន៍ការងារជិតពាទសវត្សរ៍លើផ្នែកអភិវឌ្ឍន៍។ ការទទួលបានការអប់រំខាងនរវិទូសង្គម លោកបានចូលរួមយ៉ាងទូលំទូលាយក្នុងសកម្មភាពអភិវឌ្ឍន៍ ដោយរួមទាំងការសិក្សាស្រាវជ្រាវប្រកបដោយស៊ីជំរៅនៅតំបន់ អាហ្វ្រិក និងអាស៊ី។ ក្នុងចំណោមការងារដែលលោកទទួលបន្ទុក គឺលោកបានធ្វើការជិត ៣ ឆ្នាំ នៅប្រទេសតាន់សាញៀ ជាមួយ នឹងភ្នាក់ងារណ័រវេសម្រាប់កិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ មានតួនាទីជាអ្នកសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍ជនបទ។ ពីឆ្នាំ ១៩៩៣ ដល់ ឆ្នាំ ១៩៩៥ លោកទទួលបន្ទុកសម្រាប់ដោះស្រាយបញ្ហាការផ្លាស់ប្តូរទីលំនៅ និងការស្តារឡើងវិញនៅក្នុងគម្រោង មួយនៅប្រទេស បង់ក្លាដេស នៅពេលនោះលោកទទួលបានការងារពីធនាគារពិភពលោក។ នៅឆ្នាំ ១៩៩៥ លោកបានក្លាយ ទៅជាជំនួយការនាយក ហើយក៏បានបំរើការងារជានាយកនៅឆ្នាំ ២០០៥ និង ២០០៦ នៅវិទ្យាស្ថាន Christian Michelsen នៅប្រទេសណ័រវេ វិទ្យាស្ថាននេះទទួលស្គាល់ជាអន្តរជាតិលើការសិក្សាស្រាវជ្រាវ

ផ្នែកអភិវឌ្ឍន៍ ហើយនៅទីនោះ លោកបានចំណាយទាំងកំលាំងកាយ និងជំនាញ ដើម្បីសិក្សាស្រាវជ្រាវនិងវិភាគលើផ្នែកជាច្រើននៃបញ្ហាគោលនយោបាយ និងកម្មវិធី ដែលប៉ះពាល់ដល់ប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនោះ លោកបានចូលរួមយ៉ាងច្រើនជាមួយនឹងគណៈ កម្មការវាយតម្លៃដោយឯករាជ ដោយភ្នាក់ងារអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី ហើយលោកក៏ជាសមាជិកម្នាក់នៃក្រុមជំនាញការ (Roster of Experts) សម្រាប់ការងារអធិការកិច្ចនៅធនាការអភិវឌ្ឍន៍អាស៊ី ។ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតផ្នែក នរវិទ្យាសង្គមពីសាកលវិទ្យាល័យបើហ្គេន ហើយលោកទទួលបរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្របរិស្ថាននិងជីវវិទ្យា។ សៀវភៅរបស់ លោកគឺផ្តោតទៅលើការអភិវឌ្ឍជនបទ វិមជ្ឈការ ការកាត់បន្ថយភាពក្រីក្រ ហើយនៅពេលថ្មីៗនេះគឺទៅលើភាពជាម្ចាស់លើ កិច្ចសហប្រតិបត្តិការជំនួយសម្រាប់ការអភិវឌ្ឍ ។

**លោកស្រី អេមី វ៉ាតាណាបេ** (Eimi Watanabe) (ជនជាតិជប៉ុន) បានតែងតាំងជាសមាជិកក្រុមអធិការកិច្ចនៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។ ឆ្លងតាមបទពិសោធន៍ការងារ លោកស្រី វ៉ាតាណាបេ បានបង្ហាញពីការប្តេជ្ញាចិត្តដើម្បីយក មកអនុវត្តនូវការវិភាគ ក៏ដូចជាយុទ្ធសាស្ត្រចូលរួមដើម្បីបង្កើតជាកម្មវិធីអភិវឌ្ឍន៍មួយឡើង ហើយមានកំណត់ត្រាដ៏រឹងមាំមួយចំពោះការសហការការងារជាមួយនឹងអង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងអង្គការអភិវឌ្ឍន៍នានា។ ដោយទទួលបានការអប់រំផ្នែកសង្គមសាស្ត្រ លោកស្រីបានចូលរួមយ៉ាងទូលំទូលាយនៅក្នុងវិស័យសំខាន់ៗ ទាំងនៅកម្រិតគម្រោង និងកម្រិតគោលនយោបាយ ដោយរួមមាន ការកាត់បន្ថយភាពក្រីក្រ អភិបាលកិច្ច យេនឌ័រ សុខភាព និងអាហាររូបតម្ភកុមារ អភិវឌ្ឍន៍សមត្ថភាព បរិស្ថាន និងអន្តោប្រវេសន៍អន្តរជាតិ។ លោកស្រី វ៉ាតាណបេ ទទួលសញ្ញាប័ត្រអនុបណ្ឌិត និងបណ្ឌិត ពីសាលាសេដ្ឋកិច្ចទីក្រុងឡុងដ៏ និង បានទទួលបរិញ្ញាប័ត្រផ្នែកសង្គមពីសាលកវិទ្យាល័យគ្រិស្ទិនអន្តរជាតិនៅទីក្រុងតូក្យូ។ ពីឆ្នាំ ១៩៩៨ ដល់ ឆ្នាំ ២០០១ លោក ស្រីបានបំរើការជាជំនួការអគ្គលេខាធិការ និងជានាយកការិយាល័យផ្នែកគោលនយោបាយអភិវឌ្ឍន៍នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។ មុនពេលនោះ លោកស្រី គឺជាអ្នកសម្របសម្រួលអង្គការសហប្រជាជាតិ និងជាតំណាង UNDP ប្រចាំ ប្រទេសបង់ក្លាដេស ហើយជាតំណាងអង្គការ UNICEF ប្រចាំប្រទេសឥណ្ឌា។ នាពេលថ្មីៗនេះ លោកស្រីបានបំរើការងារជា សមាជិកម្នាក់ ក្នុងគណៈកម្មការផ្តល់យោបល់យុទ្ធសាស្ត្រ និងសវនកម្ម នៃការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាគម្រោង។ លោកស្រី វ៉ាតាណាបេ នាំមកឱ្យក្រុមអធិការកិច្ចនូវបទពិសោធន៍របស់គាត់ជាង ៣០ ឆ្នាំ ក្នុងវិស័យអភិវឌ្ឍន៍។

---

## ទីប្រឹក្សាជំនាញ

លោក ជើហ្វ្រី ផែន (Geoffrey Payne) គឺជាទីប្រឹក្សាផ្នែកខាងអភិវឌ្ឍន៍ផ្ទះសំបែង និងទីក្រុង ដោយបទពិសោធន៍រយៈពេល ៤ ទសវត្សមកហើយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ លោកបានបំរើការងារជាទីប្រឹក្សា ការស្រាវជ្រាវ និងការបណ្តុះបណ្តាលនៅស្ទើ គ្រប់ផ្នែកនៃពិភពលោកសម្រាប់ភ្នាក់ងារអភិវឌ្ឍន៍ជាច្រើន និងបង្រៀនដោយផ្ទាល់ចំពោះកម្រិតក្រោយឧត្តម និងកម្មវិធីបណ្តុះ បណ្តាលឯកទេសនៅស្ថាប័នអប់រំនាំមុខគេនៅប្រទេសអង់គ្លេស និងនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនទៀត។

លោក ជើហ្វ្រី (Geoffrey Payne) បានបង្កើត GPA (www.gpa.rog.uk) នៅឆ្នាំ ១៩៩៥ ហើយបានបោះពុម្ពឯកសារទាក់ទិន ទៅនឹងផ្ទះសំបែង គោលនយោបាយដីធ្លី សិទ្ធិលើកម្មសិទ្ធិ ក្របខ័ណ្ឌច្បាប់នានា និងភាពជាដៃគូរវាងសាធារណៈនិងឯកជន។ លោក គឺជាក្រុមប្រឹក្សាភិបាលមូលនិធិសំណង់អាគារ និងផ្ទះសង្គមកិច្ច និងជាអ្នកប្រឹក្សាខាងក្រៅដល់ក្រុមប្រឹក្សាប្រទេសអង់គ្លេស និងជាសហសេវិននៃរាជាសិល្បៈសង្គម និងរាជាសង្គមអាស៊ី។ លោកជាសមាជិកបង្កើតបណ្តាញអភិវឌ្ឍន៍ក្រោយគ្រោះមហន្តរាយ (DFDN: www.developmentfromdisasters.net) ហើយក៏ជាសមាជិកនៃ RIBA សហគមន៍ចំណេះដឹងសម្រាប់ការអភិវឌ្ឍ និងជំនួយសង្គ្រោះគ្រោះមហន្តរាយនៃក្រុមឯកទេស។ ឯកទេសរបស់លោកជើហ្វ្រី រួមមាន កម្មសិទ្ធិដីធ្លីនៅតំបន់ទីក្រុង និងសិទ្ធិលើកម្មសិទ្ធិ គោលនយោបាយផ្ទះសំបែង និងផែនការគម្រោង គោលការណ៍បទដ្ឋានច្បាប់សម្រាប់ការអភិវឌ្ឍតំបន់ទីក្រុង និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកសាងសមត្ថភាព។ ប្រធានបទស្នូលនៃការងាររបស់លោកគឺទាក់ទងទៅនឹងកសាងសមត្ថភាពនៅ មូលដ្ឋាន ដើម្បីលើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅទីក្រុង។

ជាមួយនឹងការសហការណ៍ជាមួយអ្នកស្រាវជ្រាវនៅមូលដ្ឋាន លោក ជើហ្វ្រី បានធ្វើការសិក្សាស្រាវជ្រាវលើបញ្ហាកម្មសិទ្ធិដីធ្លីនៅប្រទេសមួយចំនួន ដោយរួមទាំងប្រទេសកម្ពុជា ដោយមានការពិនិត្យមើល មួយធ្វើឡើងនៅចន្លោះឆ្នាំ ២០០៣ និង ២០០៤។ ការស្រាវជ្រាវនេះផ្តោតលើតែទីក្រុងភ្នំពេញ និងមានការស្ទង់មតិយ៉ាងទូលំទូលាយ និងមានករណីសិក្សាមួយចំនួន ហើយបានបញ្ចប់ដោយធ្វើសិក្ខាសាលាមួយ និងរបាយការណ៍កំណត់ជម្រើសគោលនយោបាយ មួយចំនួនសម្រាប់ការផ្លាស់ប្តូរនានា។


IBRD 38242
CAMBODIA
LAND MANAGEMENT AND ADMINISTRATION PROJECT
Referenced Villages
REFERENCED VILLAGES:
ADJUDICATED
NON-ADJUDICATED
BOEUNG KOK LAKE DEVELOPMENT AREA BOUNDARY
SAND FILL AS SHOWN IN MANAGEMENT RESPONSE DATED NOVEMBER 2, 2009
DISTRICT HEADQUARTERS
COMMUNE BOUNDARIES
DISTRICT BOUNDARIES
PROVINCE BOUNDARY
ROADS
CHINA
MYANMAR
LAO P.D.R.
THAILAND
VIETNAM
CAMBODIA
Phnom Penh
Gulf of Thailand
SOUTH CHINA SEA
KANDAL PROVINCE
PHNOM PENH PROVINCE
Area of Main Map
For detail, see IBRD 38243
Ruessei Kaev
Phnom Penh Thmei
Tuol Sangkae
Boeung Kok Lake Development Area (~133 ha.)
Boeung Kok Lake (~90 ha.)
Boeung Kok Muoy (Boeung Kok 1)
Boeung Kok Pir (Boeung Kok 2)
Tuol Kouk
Doun Penh
Sras Chok
Voat Phnum
Chrouy Changva
TONLE SAP
MEKONG
Phsar Thmei Muoy
Phsar Chas
Phsar Kandal Muoy
Phsar Kandal Pir
Phsar Thmei Pir
Phsar Thmei Bei
Phsar Depou Muoy
Phsar Depou Pir
Phsar Depou Bei
Mittakpheap
Monourom
7 Makkara
Ou Ruessei Bei
Ou Ruessei Buon
Ou Ruessei Muoy
Tuek L'ak Muoy
Tuek L'ak Pir
Tuek L'ak Bei
Tuek Thla
Chey Chumneah
Boeng Reang
Veal Vong
Boeng Proluet
Chakto Mukh
Phsar Daeum Kor
Boeng Salang
Tuol Svay Prey Pir
Tuol Svay Prey Muoy
Oulampik
Boeng Keng Kang Pir
Boeng Keng Kang Muoy
Boeng Keng Kang Bei
Dey Krahom
Group 78
Chamkar Mon
Tumnob Tuek
TONLE BASSAC
Tonle Basak
Mean Chey
Tuol Tumpung Pir
Tuol Tumpung Muoy
Boeng Tumpun
Boeng Trabaek
Stueng Mean Chey
Chbar Ampov Pir
Chbar Ampov Muoy
Niroth
Phsar Daeum Thkov
Chak Angrae Leu
0 1 2 3 Kilometers
The boundaries, colors, denominations and any other information shown on this map do not imply, on the part of The World Bank Group, any judgment on the legal status of any territory, or any endorsement or acceptance of such boundaries.
NOVEMBER 2010


IBRD 38243
CAMBODIA
LAND MANAGEMENT AND ADMINISTRATION PROJECT
Sras Chok Commune
REFERENCED VILLAGES
SRAS CHOK COMMUNE
BOEUNG KOK LAKE DEVELOPMENT AREA BOUNDARY
SAND FILL AS SHOWN IN MANAGEMENT RESPONSE DATED NOVEMBER 2, 2009
DISTRICT HEADQUARTERS
COMMUNE BOUNDARIES
DISTRICT BOUNDARIES
PROVINCE BOUNDARY (inset)
ROADS
CHINA
MYANMAR
LAO P.D.R.
THAILAND
VIETNAM
CAMBODIA
Phnom Penh
SOUTH CHINA SEA
Gulf of Thailand
Ruessei Kaev
Area of Main Map
Tuol Kouk
7 Makkara
Doun Penh
Dang Ko
Chamkar Mon
Mean Chey
KANDAL PROVINCE
PHNOM PENH PROVINCE
KANDAL PROVINCE
0 1 2 3 Kilometers
0 .1 .2 .5 1
KILOMETERS
The boundaries, colors, denominations and any other information shown on this map do not imply, on the part of The World Bank Group, any judgment on the legal status of any territory, or any endorsement or acceptance of such boundaries.
Ruessei Kaev
Tuol Sangkae
Boeung Kok Lake Development Area (~133 ha.)
Chrouy Changva
Tuol Kouk
Boeung Kok Muoy (Boeung Kok 1)
TONLE SAP
Sras Chok
Boeung Kok Lake (~90 ha.)
Doun Penh
June 2009
March 2009
Nov 2008
Sep 2008
Boeung Kok Pir (Boeung Kok 2)
Voat Phnum
Phsar Thmei Muoy
Phsar Chas
Phsar Kandal Muoy
Phsar Depou Muoy
Mittakpheap
Monourom
Phsar Thmei Pir
Phsar Kandal Pir
7 Makkara
Phsar Depou Pir
Veal Vong
Ou Ruessei Bei
Ou Ruessei Pir
Phsar Thmei Bei
Boeng Reang
Chey Chumneah
Phsar Depou Bei
Ou Ruessei Buon
Ou Ruessei Muoy
NOVEMBER 2010